ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# ព្រះ
# ត្រៃបិដកបាលី
## នឹង
# សេចក្តីប្រែជាភាសាខ្មែរ
# វិនយបិដក ចុល្លវគ្គ
# ទុតិយភាគ
# ១០

សមថក្ខន្ធកៈ ខុទ្ទកវត្ថុក្ខន្ធកៈ
នឹង សេនាសនក្ខន្ធកៈ

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕

# វិនយបិដកេ ចុល្លវគ្គស្ស

## ទុតិយោ ភាគោ

---

## សមថក្ខន្ធកំ

(១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ អសម្មុខីភូតានំ ភិក្ខូនំ កម្មានិ ករោន្តិ តជ្ជនីយម្បិ និយស្សម្បិ បព្វាជនីយម្បិ បដិសារណីយម្បិ ឧក្ខេបនីយម្បិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ អសម្មុខីភូតានំ ភិក្ខូនំ កម្មានិ ករិស្សន្តិ តជ្ជនីយម្បិ និយស្សម្បិ បព្វាជនីយម្បិ បដិសារណីយម្បិ ឧក្ខេបនីយម្បីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្ពគ្គិយា ភិក្ខូ អសម្មុខីភូតានំ ភិក្ខូនំ កម្មានិ ករោន្តិ តជ្ជនីយម្បិ និយស្សម្បិ បព្វាជនីយម្បិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# វិនយបិដក ចុល្លវគ្គ

## ទុតិយភាគ

---

## សមថក្ខន្ធកៈ

(១) សម័យនោះ ព្រះសម្មាសម្ពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ តែងធ្វើកម្មទាំងឡាយ គឺ តជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយដែលមិនមានក្នុងទីចំពោះមុខ ។ ភិក្ខុទាំងឡាយណា ជាអ្នកប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងធ្វើកម្មទាំងឡាយ គឺ តជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយដែលមិនមាន ក្នុងទីចំពោះមុខសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយភិក្ខុតែងធ្វើកម្មទាំងឡាយ គឺ តជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បដិសារណីយម្បិ ឧក្ខេបនីយម្បីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ ភិក្ខវេ តេសំ មោឃបុរិសានំ អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា អសម្មុខីភូតានំ ភិក្ខូនំ កម្មានិ ករិស្សន្តិ តជ្ជនីយម្បិ និយស្សម្បិ បព្វាជនីយម្បិ បដិសារណីយម្បិ ឧក្ខេបនីយម្បិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ អសម្មុខីភូតានំ ភិក្ខូនំ កម្មំ កាតព្វំ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា យោ ករេយ្យ អាបត្តិ ទុក្កដស្ស ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយដែលមិនមានក្នុងទីចំពោះមុខ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ ព្រះពុទ្ធមានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែបផែន មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងធ្វើកម្មទាំងឡាយ គឺ តជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយដែលមិនមានក្នុងទីចំពោះមុខទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ។ បេ ។ លុះទ្រង់តិះដៀលហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយដែលមិនមានក្នុងទីចំពោះមុខទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២) អធម្មវាទី បុគ្គលោ អធម្មវាទី សម្ពហុលា អធម្មវាទី សង្ឃោ ធម្មវាទី បុគ្គលោ ធម្មវាទី សម្ពហុលា ធម្មវាទី សង្ឃោ ។

(៣) អធម្មវាទី បុគ្គលោ ធម្មវាទី បុគ្គលំ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ អធម្មេន វូបសម្មតិ សម្មុខាវិនយប្បដិរូបកេន ។ អធម្មវាទី បុគ្គលោ ធម្មវាទី សម្ពហុលេ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ អធម្មេន វូបសម្មតិ សម្មុខាវិនយប្បដិរូបកេន ។ អធម្មវាទី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមចិត្តវគ្គ: បុគ្គលជាអធម្មវាទីនឹងបុគ្គលជាធម្មវាទី

(២) (បទមាតិកាទាំង ៦) គឺ បុគ្គលជាអធម្មវាទី (អ្នកពោលមិនត្រូវធម៌) ១ ភិក្ខុទាំងឡាយច្រើន[១] ជាអធម្មវាទី ១ សង្ឃជាអធម្មវាទី ១ បុគ្គលជាធម្មវាទី (អ្នកពោលត្រូវធម៌) ១ ភិក្ខុទាំងឡាយច្រើនជាធម្មវាទី ១ សង្ឃជាធម្មវាទី ១ ។

(៣) បុគ្គលជាអធម្មវាទីញុំាងបុគ្គលជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរគាប់ចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ ជាសម្មុខាវិន័យប្លម គឺគ្រាន់តែប្រហែលគ្នានឹងសម្មុខាវិន័យ ។ បុគ្គលជាអធម្មវាទី ញុំាងភិក្ខុទាំងឡាយច្រើនជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះបើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នានឹងសម្មុខាវិន័យ ។ បុគ្គលជាអធម្មវាទី

---

១ សំដៅយកភិក្ខុ២.៣រូប បើនឹងហៅថា គណៈវិញក៏បាន ចំណែកភិក្ខុតែមួយរូប បាលីហៅថា បុគ្គល តាំងពី ៤ រូបឡើងទៅហៅថា សង្ឃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បុគ្គលោ ធម្មវាទី សង្ឃំ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ អធម្មេន វូបសម្មតិ សម្មុខាវិនយប្បដិរូបកេន ។ អធម្មវាទី សម្ពហុលា ធម្មវាទី បុគ្គលំ សញ្ញាបេន្តិ និជ្ឈាបេន្តិ បេក្ខេន្តិ អនុបេក្ខេន្តិ ទស្សេន្តិ អនុទស្សេន្តិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ អធម្មេន វូបសម្មតិ សម្មុខាវិនយប្បដិរូបកេន ។ អធម្មវាទី សម្ពហុលា ធម្មវាទី សម្ពហុលេ សញ្ញាបេន្តិ និជ្ឈាបេន្តិ បេក្ខេន្តិ អនុបេក្ខេន្តិ ទស្សេន្តិ អនុទស្សេន្តិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ អធម្មេន វូបសម្មតិ សម្មុខាវិនយប្បដិរូបកេន ។ អធម្មវាទី សម្ពហុលា ធម្មវាទី សង្ឃំ សញ្ញាបេន្តិ និជ្ឈាបេន្តិ បេក្ខេន្តិ អនុបេក្ខេន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



## វិនយបិដក ចុល្លវគ្គ

ញុំាងសង្ឃជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នានឹងសម្មុខាវិន័យ ។ ភិក្ខុទាំងឡាយច្រើនជាអធម្មវាទី ញុំាងបុគ្គលជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នានឹងសម្មុខាវិន័យ ។ ភិក្ខុទាំងឡាយច្រើនជាអធម្មវាទី ញុំាងភិក្ខុទាំងឡាយច្រើនជាធម្មវាទីឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នានឹងសម្មុខាវិន័យ ។ ភិក្ខុទាំងឡាយច្រើនជាអធម្មវាទីញុំាងសង្ឃជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទស្សេន្តិ អនុទស្សេន្តិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ អធម្មេន វូបសម្មតិ សម្មុខាវិនយប្បដិរូបកេន ។ អធម្មវាទី សង្ឃោ ធម្មវាទី បុគ្គលំ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ អធម្មេន វូបសម្មតិ សម្មុខាវិនយប្បដិរូបកេន ។ អធម្មវាទី សង្ឃោ ធម្មវាទី សម្ពហុលេ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាថ ឥមំ រោចេថាតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ អធម្មេន វូបសម្មតិ សម្មុខាវិនយប្បដិរូបកេន ។ អធម្មវាទី សង្ឃោ ធម្មវាទី សង្ឃំ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នានឹងសម្មុខាវិន័យ ។ សង្ឃជាអធម្មវាទីញ៉ាំងបុគ្គលជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នានឹងសម្មុខាវិន័យ ។ សង្ឃជាអធម្មវាទីញ៉ាំងភិក្ខុច្រើនជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នានឹងសម្មុខាវិន័យ ។ សង្ឃជាអធម្មវាទីញ៉ាំងសង្ឃជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវម្បេតំ អធិករណំ វូបសម្មតិ អធម្មេន វូបសម្មតិ សម្មុខាវិនយប្បដិរូបកេន ។

កណ្ហបក្ខនវកំ និដ្ឋិតំ ។

(៦) ធម្មវាទី បុគ្គលោ អធម្មវាទី បុគ្គលំ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវម្បេតំ អធិករណំ វូបសម្មតិ ធម្មេន វូបសម្មតិ សម្មុខាវិនយេន ។ ធម្មវាទី បុគ្គលោ អធម្មវាទី សម្ពហុលេ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវម្បេតំ អធិករណំ វូបសម្មតិ ធម្មេន វូបសម្មតិ សម្មុខាវិនយេន ។ ធម្មវាទី បុគ្គលោ អធម្មវាទី សង្ឃំ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



របស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នានឹងសម្មុខាវិន័យ ១

ចប់ កណ្ហបក្ខ មានចំនួន ៩ ។

(៤) បុគ្គលជាធម្មវាទី ញ៉ាំងបុគ្គលជាអធម្មវាទីឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យហើយ ៗ ឲ្យឃើញ ឲ្យឃើញហើយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ ១ បុគ្គលជាធម្មវាទី ញ៉ាំងភិក្ខុទាំងឡាយច្រើនជាអធម្មវាទីឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យហើយ ៗ ឲ្យឃើញ ឲ្យឃើញហើយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ ១ បុគ្គលជាធម្មវាទី ញ៉ាំងសង្ឃជាអធម្មវាទីឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យហើយ ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



### សមថក្ខន្ធកេ ធម្មវាទី សម្ពហុលា អធម្មវាទី សង្ឃោ

ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ ធម្មេន វូបសម្មតិ សម្មុខាវិនយេន ។ ធម្មវាទី សម្ពហុលា អធម្មវាទី បុគ្គលំ សញ្ញាបេន្តិ និជ្ឈាបេន្តិ បេក្ខេន្តិ អនុបេក្ខេន្តិ ទស្សេន្តិ អនុទស្សេន្តិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ ធម្មេន វូបសម្មតិ សម្មុខាវិនយេន ។ ធម្មវាទី សម្ពហុលា អធម្មវាទី សម្ពហុលេ សញ្ញាបេន្តិ និជ្ឈាបេន្តិ បេក្ខេន្តិ អនុបេក្ខេន្តិ ទស្សេន្តិ អនុទស្សេន្តិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ ធម្មេន វូបសម្មតិ សម្មុខាវិនយេន ។ ធម្មវាទី សម្ពហុលា អធម្មវាទី សង្ឃំ សញ្ញាបេន្តិ និជ្ឈាបេន្តិ បេក្ខេន្តិ អនុបេក្ខេន្តិ ទស្សេន្តិ អនុទស្សេន្តិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ តំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ ។ ភិក្ខុទាំងឡាយច្រើនជាធម្មវាទី ញ៉ាំងបុគ្គលជាអធម្មវាទីឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ ។ ភិក្ខុទាំងឡាយច្រើនជាធម្មវាទី ញ៉ាំងភិក្ខុច្រើនជាអធម្មវាទីឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ ។ ភិក្ខុទាំងឡាយច្រើនជាធម្មវាទី ញ៉ាំងសង្ឃជាអធម្មវាទីឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អធិករណំ វូបសម្មតិ ធម្មេន វូបសម្មតិ សម្មុខាវិន-
យេន ។ ធម្មវាទី សង្ឃោ អធម្មវាទី បុគ្គលំ សញ្ញាបេតិ
និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ
អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ
គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ
ធម្មេន វូបសម្មតិ សម្មុខាវិនយេន ។ ធម្មវាទី សង្ឃោ
អធម្មវាទី សម្ពហុលេ សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ
អនុបេក្ខេតិ ទស្សេតិ អនុទស្សេតិ អយំ ធម្មោ អយំ
វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេ-
ថាតិ ឯវញ្ចេ តំ អធិករណំ វូបសម្មតិ ធម្មេន វូបសម្មតិ
សម្មុខាវិនយេន ។ ធម្មវាទី សង្ឃោ អធម្មវាទី សង្ឃំ
សញ្ញាបេតិ និជ្ឈាបេតិ បេក្ខេតិ អនុបេក្ខេតិ ទស្សេតិ
អនុទស្សេតិ អយំ ធម្មោ អយំ វិនយោ ឥទំ
សត្ថុសាសនំ ឥមំ គណ្ហាហិ ឥមំ រោចេហីតិ ឯវញ្ចេ
តំ អធិករណំ វូបសម្មតិ ធម្មេន វូបសម្មតិ សម្មុ-
ខាវិនយេនាតិ ។

សុក្កបក្ខនយំ និដ្ឋិតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិន័យបិដក ចុល្លវគ្គ

ឈ្មោះថារម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ ។ សង្ឃជាធម្មវាទី ញុំាងបុគ្គលជាអធម្មវាទីឲ្យគត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ ។ សង្ឃជាធម្មវាទី ញុំាងភិក្ខុទាំងឡាយច្រើន ជាអធម្មវាទីឲ្យគត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយ ៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្តា អ្នកទាំងឡាយចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ ។ សង្ឃជាធម្មវាទី ញុំាងសង្ឃជាអធម្មវាទី ឲ្យគត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយ ៗ ឲ្យឃើញ ឲ្យឃើញរឿយៗ ថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះរម្ងាប់យ៉ាងនេះ ឈ្មោះថារម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យដូច្នេះ ។

ចប់ សុក្កបក្ខ មានចំនួន ៨ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## អដ្ឋមសិក្ខាបទេ ទព្វមល្លបុត្តវត្ថុ

(៥) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មតា ទព្វេន មល្លបុត្តេន ជាតិយា សត្តវស្សេន អរហត្តំ សច្ឆិកតំ ហោតិ យញ្ចិញ្ចិ សាវកេន បត្តព្វំ សព្វំ តេន អនុប្បត្តំ ហោតិ នត្ថិ ចស្ស កិញ្ចិ ឧត្តរិ ករណីយំ កតស្ស វា បតិចយោ ។

(៦) អថខោ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ មយា ខោ ជាតិយា សត្តវស្សេន អរហត្តំ សច្ឆិកតំ យញ្ចិញ្ចិ សាវកេន បត្តព្វំ សព្វំ មយា អនុប្បត្តំ នត្ថិ ច មេ កិញ្ចិ ឧត្តរិ ករណីយំ កតស្ស វា បតិចយោ កិំ នុ ខោ អហំ សង្ឃស្ស វេយ្យាវច្ចំ ករេយ្យន្តិ ។ អថខោ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស ឯតទហោសិ យន្នូនាហំ សង្ឃស្ស សេនាសនញ្ច បញ្ញាបេយ្យំ ភត្តានិ ច ឧទ្ទិសេយ្យន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សមថក្ខន្ធក: និទានព្រះទព្វមល្លបុត្ត

(៥) សម័យនោះ ព្រះសម្មាសម្ពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះទព្វមល្លបុត្តដ៏មានអាយុ បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល តាំងអំពីកើតមកបាន ៧ ឆ្នាំ ថែមទាំងគុណជាតណាមួយ ដែលសាវ័កត្រូវដល់ គុណជាតនោះលោកក៏បានដល់ ដោយលំដាប់សព្វគ្រប់ហើយ កិច្ចអ្វីមួយដែលលោកគប្បីធ្វើតទៅទៀត ឬការសន្សំនូវកិច្ចដែលធ្វើរួចហើយ ក៏មិនមានដល់លោក ។

(៦) លំដាប់នោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ ទៅកាន់ទីស្ងាត់ សម្ងំនៅស្ងប់ស្ងៀមតែម្នាក់ឯង ហើយមានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល តាំងពីកើតមកបាន ៧ ឆ្នាំ គុណជាតណាទីមួយដែលសាវ័កត្រូវដល់ អាត្មាអញក៏បានដល់នូវគុណជាតនោះ ដោយលំដាប់សព្វគ្រប់ហើយ មួយទៀត កិច្ចអ្វីមួយដែលអាត្មាអញត្រូវធ្វើតទៅទៀត ឬការសន្សំនូវកិច្ចដែលធ្វើរួចហើយ ក៏មិនមានដល់អាត្មាអញ (បើដូច្នោះ) គួរអាត្មាអញធ្វើការខ្វល់ខ្វាយបម្រើដល់សង្ឃដូចម្ដេចហ្ន៎ ។ គ្រានោះ ព្រះទព្វមល្លបុត្តមានអាយុ បានត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញត្រូវរៀបចំសេនាសនៈផង ត្រូវចាត់ចែងចង្ហាន់ដល់សង្ឃផងចុះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

(៧) អថខោ អាយស្មា ទព្វោ មល្លបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ទព្វោ មល្លបុត្តោ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ មយា ខោ ជាតិយា សត្តវស្សេន អរហត្តំ សច្ឆិកតំ យំកិញ្ចិ សាវកេន បត្តព្វំ សព្វំ មយា អនុប្បត្តំ នត្ថិ ច មេ កិញ្ចិ ឧត្តរិ ករណីយំ កតស្ស វា បតិចយោ កឹ នុ ខោ អហំ សង្ឃស្ស វេយ្យាវច្ចំ ករេយ្យន្តិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ យន្នូនាហំ សង្ឃស្ស សេនាសនញ្ច បញ្ញបេយ្យំ ភត្តានិ ច ឧទ្ទិសេយ្យន្តិ ឥច្ឆាមហំ ភន្តេ សង្ឃស្ស សេនាសនញ្ច បញ្ញបេតុំ ភត្តានិ ច ឧទ្ទិសិតុន្តិ ។ សាធុ សាធុ ទព្វ តេនហិ ត្វំ ទព្វ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៧) គ្រានោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ លុះសោយល្ហាសម័យ ក៏ចេញពីទីពួនសម្ងំទៅ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន កាលដែលខ្ញុំព្រះអង្គទៅកាន់ទីស្ងាត់ ពួនសម្ងំនៅតែម្នាក់ឯង ក៏មានចិត្តត្រិះរិះ កើតឡើងយ៉ាងនេះថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល តាំងអំពីកើតមកបាន ៧ ឆ្នាំ ហើយគុណជាតណាមួយ ដែលសាវ័កត្រូវដល់ អាត្មាអញក៏បានដល់នូវគុណជាតនោះដោយលំដាប់សព្វគ្រប់ហើយ មួយទៀត កិច្ចអ្វីមួយដែលអាត្មាអញគប្បីធ្វើតទៅទៀត ឬការសន្សំនូវកិច្ចដែលបានធ្វើរួចហើយ មិនមានដល់អាត្មាអញទេ គួរអាត្មាអញធ្វើការខ្វល់ខ្វាយបម្រើដល់សង្ឃដូចម្តេចហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គក៏មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះមានតែអាត្មាអញត្រូវរៀបចំសេនាសនៈផង ត្រូវចាត់ចែងចង្ហាន់ដល់សង្ឃផងចុះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់រៀបចំសេនាសនៈផង ចង់ចាត់ចែងចង្ហាន់ដល់សង្ឃផង ។ ព្រះបរមគ្រូទ្រង់ត្រាស់ថា ម្នាលទព្វៈ ប្រពៃហើយ ៗ ម្នាលទព្វៈ បើដូច្នោះ អ្នក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សង្ឃស្ស សេនាសនញ្ច បញ្ញាបេហិ ភត្តានិ ច ឧទ្ទិសាហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា ទព្វោ មល្លបុត្តោ ភគវតោ បច្ចស្សោសិ ។

(៨) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ ទព្វំ មល្លបុត្តំ សេនាសនបញ្ញាបកញ្ច ភត្តុទ្ទេសកញ្ច សម្មន្នតុ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ទព្វោ យាចិតព្វោ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ អាយស្មន្តំ ទព្វំ មល្លបុត្តំ សេនាសនបញ្ញាបកញ្ច ភត្តុទ្ទេសកញ្ច សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ អាយស្មន្តំ ទព្វំ មល្លបុត្តំ សេនាសនបញ្ញាបកញ្ច ភត្តុទ្ទេសកញ្ច សម្មន្នតិ ។ យស្សាយស្មតោ ខមតិ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស សេនាសនបញ្ញាបកស្ស ច ភត្តុទ្ទេសកស្ស ច សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ចូររៀបចំសេនាសនៈ ហើយចាត់ចែងចង្ហាន់ដល់សង្ឃចុះ ៗ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណា ព្រះអង្គ ។

(៨) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរសន្មតទព្វមល្លបុត្ត ឲ្យជាសេនាសនបញ្ញាបកៈ (អ្នកចាត់ចែងសេនាសនៈ) ផង ឲ្យជាភត្តុទ្ទេសកៈ (អ្នកចាត់ចែងចង្ហាន់) ផង ៗ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ ៗ មុនដំបូង ត្រូវសង្ឃសូមទព្វភិក្ខុ លុះសូមរួចហើយ ត្រូវភិក្ខុដែលឈ្លាសវៃប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើការសន្មតិមានកាលគួរដល់សង្ឃហើយ សូមសង្ឃសន្មតទព្វមល្លបុត្តមានអាយុ ឲ្យជាសេនាសនបញ្ញាបកៈផង ឲ្យជាភត្តុទ្ទេសកៈផង ៗ នេះជាញត្តិ ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតទព្វមល្លបុត្តមានអាយុឲ្យជាសេនាសនបញ្ញាបកៈផង ឲ្យជាភត្តុទ្ទេសកៈផង ៗ ការសន្មតិព្រះទព្វមល្លបុត្តមានអាយុ ឲ្យជាសេនាសនបញ្ញាបកៈផង ឲ្យជាភត្តុទ្ទេសកៈផង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ៗ សង្ឃ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អាយស្មា ទព្វោ មល្លបុត្តោ សេនាសនបញ្ញាបកោ ច ភត្តុទ្ទេសកោ ច ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៩) សម្មតោ ចាយស្មា ទព្វោ មល្លបុត្តោ សភាគានំ សភាគានំ ភិក្ខូនំ ឯកជ្ឈំ សេនាសនំ បញ្ញបេតិ យេ តេ ភិក្ខូ សុត្តន្តិកា តេសំ ឯកជ្ឈំ សេនាសនំ បញ្ញបេតិ តេ អញ្ញមញ្ញំ សុត្តន្តំ សង្គាយិស្សន្តីតិ យេ តេ ភិក្ខូ វិនយធរា តេសំ ឯកជ្ឈំ សេនាសនំ បញ្ញបេតិ តេ អញ្ញមញ្ញំ វិនយំ វិនិច្ឆិនិស្សន្តីតិ យេ តេ ភិក្ខូ ធម្មកថិកា តេសំ ឯកជ្ឈំ សេនាសនំ បញ្ញបេតិ តេ អញ្ញមញ្ញំ ធម្មំ សាកច្ឆិស្សន្តីតិ យេ តេ ភិក្ខូ ឈាយិនោ តេសំ ឯកជ្ឈំ សេនាសនំ បញ្ញបេតិ តេ អញ្ញមញ្ញំ ន ព្យាពាធិស្សន្តីតិ យេ តេ ភិក្ខូ តិរច្ឆានកថិកា កាយទឡ្ហិពហុលា វិហរន្តិ តេសម្បិ ឯកជ្ឈំ

បានសន្មតព្រះទព្វមល្លបុត្តមានអាយុ ឲ្យជាសេនាសនប្បញ្ញាបកៈផង ឲ្យជាភត្តុទ្ទេសកៈផងហើយ ការសន្មតិនេះគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

(៤) ព្រះទព្វមល្លបុត្តដ៏មានអាយុ ដែលសង្ឃបានសន្មតរួចហើយក៏រៀបចំសេនាសនៈដើម្បីភិក្ខុទាំងឡាយ ដែលសុទ្ធតែជាសភាគៈនឹងគ្នាក្នុងទីជាមួយគ្នា ពួកភិក្ខុណាជាអ្នករៀនព្រះសូត្រ ព្រះទព្វមល្លបុត្តដ៏មានអាយុក៏រៀបចំសេនាសនៈ ដើម្បីពួកភិក្ខុនោះក្នុងទីជាមួយគ្នា ដោយគិតថា ភិក្ខុទាំងនោះ នឹងនាំគ្នាហាត់សមព្រះសូត្រ ពួកភិក្ខុណាជាអ្នកទ្រទ្រង់វិន័យ ព្រះទព្វមល្លបុត្តក៏រៀបចំសេនាសនៈ ដើម្បីពួកភិក្ខុទាំងនោះក្នុងទីជាមួយគ្នា ដោយគិតថា ភិក្ខុទាំងនោះនឹងនាំគ្នាវិនិច្ឆ័យវិន័យ ពួកភិក្ខុណាជាធម្មកថិក ព្រះទព្វមល្លបុត្តក៏រៀបចំសេនាសនៈ ដើម្បីភិក្ខុទាំងនោះក្នុងទីជាមួយគ្នាដោយគិតថា ភិក្ខុទាំងនោះនឹងនាំគ្នាធ្វើសាកច្ឆាធម៌ ពួកភិក្ខុណាជាអ្នកចំរើនឈាន ព្រះទព្វមល្លបុត្តក៏រៀបចំសេនាសនៈ ដើម្បីភិក្ខុទាំងនោះក្នុងទីជាមួយគ្នា ដោយគិតថា ពួកភិក្ខុនោះនឹងមិនបៀតបៀនគ្នាទៅវិញទៅមក ពួកភិក្ខុណាជាអ្នកពោលនូវតិរច្ឆានកថា ច្រើនតែមានពងកាយមាំមួន ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនៈ ដើម្បីពួកភិក្ខុនោះក្នុងទីជាមួយគ្នា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនំ បញ្ញាបេតិ ឥមាយបិមេ អាយស្មន្តា រត្តិយា អច្ឆិស្សន្តីតិ យេបិ តេ ភិក្ខូ វិកាលេ អាគច្ឆន្តិ តេសម្បិ តេជោធាតុំ សមាបជ្ជិត្វា តេនេវ អាលោកេន សេនាសនំ បញ្ញាបេតិ ។ អបិស្សុ ភិក្ខូ សញ្ចិច្ច វិកាលេ អាគច្ឆន្តិ មយំ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស ឥទ្ធិបាដិហារិយំ បស្សិស្សាមាតិ ។ តេ អាយស្មន្តំ ទព្វំ មល្លបុត្តំ ឧបសង្កមិត្វា ឯវំ វទេន្តិ អម្ហាកំ អាវុសោ ទព្វ សេនាសនំ បញ្ញាបេហីតិ ។ តេ អាយស្មា ទព្វោ មល្លបុត្តោ ឯវំ វទេតិ កត្ថ អាយស្មន្តា ឥច្ឆន្តិ កត្ថ បញ្ញាបេមីតិ ។ តេ សញ្ចិច្ច ទូរេ អបទិសន្តិ អម្ហាកំ អាវុសោ ទព្វ គិជ្ឈកូដេ បព្វតេ(១) សេនាសនំ បញ្ញាបេហិ ។ អម្ហាកំ អាវុសោ ទព្វ(២) ចោរប្បបាតេ សេនាសនំ បញ្ញាបេហិ ។ អម្ហាកំ អាវុសោ ទព្វ ឥសិគិលិបស្សេ កាឡសិលាយំ សេនាសនំ បញ្ញាបេហិ ។

---

១ ឱ. គិជ្ឈកូដេសុ បព្វតេតិ ឥតិ ទិស្សតិ ។ ២ ឥតោ បរំ ទព្វាលបនំ សព្វត្ថ ឥតិ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដោយគិតថា លោកមានអាយុទាំងឡាយនេះនឹងនៅផាសុកក្តី ដោយពោលនូវតំរាប់កថានេះ ភិក្ខុទាំងឡាយណាមកដល់ក្នុងវេលាវិកាល (១) ព្រះទព្វមល្លបុត្តក៏ចូលតេជោធាតុ ហើយរៀបចំសេនាសនៈ ដើម្បីភិក្ខុទាំងនោះដោយពន្លឺនៃតេជោធាតុនោះឯង ៗ ជួនកាលមានភិក្ខុទាំងឡាយក្លែងមកក្នុងវេលាវិកាល ដោយគិតថា យើងទាំងឡាយនឹងបានឃើញឥទ្ធិប្បាដិហារ្យរបស់ព្រះទព្វមល្លបុត្តដ៏មានអាយុ ៗ ភិក្ខុទាំងឡាយនោះក៏ចូលទៅរកព្រះទព្វមល្លបុត្តដ៏មានអាយុ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោទព្វៈ ចូរលោករៀបចំសេនាសនៈដើម្បីយើងទាំងឡាយ ៗ ព្រះទព្វមល្លបុត្តដ៏មានអាយុ និយាយយ៉ាងនេះនឹងភិក្ខុទាំងនោះថា លោកទាំងឡាយដ៏មានអាយុ ចង់នៅក្នុងទីណា ឲ្យខ្ញុំរៀបចំក្នុងទីណា ៗ ភិក្ខុទាំងឡាយនោះក្លែងបង្អួលទៅរកទីឆ្ងាយដោយពាក្យថា ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈលើភ្នំគិជ្ឈកូដ ដើម្បីយើងទាំងឡាយផង ៗ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈជិតជ្រោះសម្រាប់ទម្លាក់ចោរ ដើម្បីយើងទាំងឡាយផង ៗ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈលើកាឡសិលាខាងភ្នំឥសិគិលិ ដើម្បីយើងទាំងឡាយផង ៗ

---

១ វេលាវិកាល កន្លែងខ្លះសំដៅយកពេលតាំងពីថ្ងៃត្រង់ទៅរហូតអរុណរះ កន្លែងខ្លះសំដៅយកពេលតាំងពីព្រលប់ឡើងទៅ ត្រង់ក្នុងទីនេះសំដៅយកពេលព្រលប់ឡើងទៅ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អម្ហាកំ អាវុសោ ទព្វ វេភារបស្សេ សត្តបណ្ណិគុហាយំ សេនាសនំ បញ្ញាបេហិ ។ អម្ហាកំ អាវុសោ ទព្វ សីតវនេ សប្បសោណ្ឌិកបព្ភារេ សេនាសនំ បញ្ញាបេហិ ។ អម្ហាកំ អាវុសោ ទព្វ គោតមកកន្ទរាយំ សេនាសនំ បញ្ញាបេហិ ។ អម្ហាកំ អាវុសោ ទព្វ តិណ្ឌុកកន្ទរាយំ(១) សេនាសនំ បញ្ញាបេហិ ។ អម្ហាកំ អាវុសោ ទព្វ កបោតកន្ទរាយំ(២) សេនាសនំ បញ្ញាបេហិ ។ អម្ហាកំ អាវុសោ ទព្វ តបោទារាមេ សេនាសនំ បញ្ញាបេហិ ។ អម្ហាកំ អាវុសោ ទព្វ ជីវកម្ពវនេ សេនាសនំ បញ្ញាបេហិ ។ អម្ហាកំ អាវុសោ ទព្វ មទ្ទកុច្ឆិម្ហិ មិគទាយេ សេនាសនំ បញ្ញាបេហីតិ ។ តេសំ អាយស្មា ទព្វោ មល្លបុត្តោ តេជោធាតុំ សមាបជ្ជិត្វា អង្គុលិយា ជលមានាយ បុរតោ បុរតោ គច្ឆតិ ។ តេបិ តេនេវ អាលោកេន អាយស្មតោ ទព្វស្ស មល្លបុត្តស្ស បិដ្ឋិតោ បិដ្ឋិតោ គច្ឆន្តិ ។ តេសំ អាយស្មា ទព្វោ មល្លបុត្តោ ឯវំ សេនាសនំ បញ្ញាបេតិ អយំ មញ្ចោ ឥទំ បីឋំ អយំ ភិសិ ឥទំ ពិម្ពោហនំ ឥទំ វច្ចដ្ឋានំ ឥទំ បស្សាវដ្ឋានំ ឥទំ បានីយំ

---

១ ម. តិន្ទុកកន្ទរាយំ ។ ២ ម. តបោទកន្ទរាយំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ក្នុងសត្តបណ្ណិគុហា ខាងក្នុងវេភារៈ ដើម្បីពួកយើងទាំងឡាយចុះ ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ទៀបញកភ្នំឈ្មោះបព្ភារសោណ្ឌិកៈ ក្នុងសីតវ័ន (ព្រៃត្រជាក់) ដើម្បីពួកយើងទាំងឡាយចុះ ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ទៀបជ្រោះភ្នំឈ្មោះគោមដៈ ដើម្បីពួកយើងទាំងឡាយចុះ ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ទៀបជ្រោះភ្នំឈ្មោះតិណ្ឌុកៈ ដើម្បីពួកយើងទាំងឡាយចុះ ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ទៀបជ្រោះភ្នំឈ្មោះកបោតៈ ដើម្បីពួកយើងទាំងឡាយចុះ ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ក្នុងវត្តកបោតា ដើម្បីពួកយើងទាំងឡាយចុះ ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ក្នុងជីវកម្ពវ័ន ដើម្បីពួកយើងទាំងឡាយចុះ ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ក្នុងមិគទាយវ័ន ទៀបភ្នំមទ្ទកុច្ឆិ ដើម្បីពួកយើងទាំងឡាយចុះ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ចូលកាន់តេជោធាតុ ហើយមានម្រាមដៃរុងរឿង ដើរទៅអំពីខាងមុខ ៗ នៃភិក្ខុទាំងឡាយនោះ ៗ ភិក្ខុទាំងឡាយនោះក៏ដើរទៅអំពីខាងក្រោយ ៗ នៃព្រះទព្វមល្លបុត្តមានអាយុដោយពន្លឺនោះឯង ។ ព្រះទព្វមល្លបុត្តមានអាយុរៀបចំសេនាសនៈ ដល់ភិក្ខុទាំងឡាយនោះយ៉ាងនេះថា នេះគ្រែ នេះតាំង នេះពូក នេះខ្នើយ នេះទីសម្រាប់បន្ទោបង់ឧច្ចារៈ នេះទីសម្រាប់បន្ទោបង់បស្សាវៈ នេះទឹក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥទំ បរិភោជនីយំ អយំ កត្តរទណ្ឌោ ឥទំ សង្ឃស្ស កតិកសណ្ឋានំ ឥមំ កាលំ បវិសិតព្វំ ឥមំ កាលំ និក្ខមិតព្វន្តិ ។ តេសំ អាយស្មា ទព្វោ មល្លបុត្តោ ឃ៌ំ សេនាសនំ បញ្ញាបេត្វា បុនទេវ វេឡុវនំ បច្ចាគច្ឆតិ ។

(១៤) តេន ខោ បន សមយេន មេត្តិយភុម្មជកា ភិក្ខូ នវកា ចេវ ហោន្តិ អប្បបុញ្ញា ច ។ យានិ សង្ឃស្ស លាមកានិ សេនាសនានិ តានិ តេសំ បាបុណន្តិ លាមកានិ ច ភត្តានិ ។ តេន ខោ បន សមយេន រាជគហេ មនុស្សា ឥច្ឆន្តិ ថេរានំ ភិក្ខូនំ អភិសង្ខារិកំ ទាតុំ សប្បិម្បិ តេលម្បិ ឧត្តរិភង្គម្បិ មេត្តិយភុម្មជកានំ បន ភិក្ខូនំ បាកតិកំ ទេន្តិ យថារន្ធំ កាណាជកំ ពិលង្គទុតិយំ ។ តេ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា ថេរេ ភិក្ខូ បុច្ឆន្តិ តុម្ហាកំ អាវុសោ ភត្តគ្គេ កឹ អហោសិ តុម្ហាកំ កឹ អហោសីតិ[១] ។

---

១ ឱ. ម. កឹ អហោសីតិ ។ ឥសេរន្ត ឥ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សម្រាប់ឆាន់ នេះទឹកសម្រាប់ប្រើប្រាស់ នេះឈើច្រត់ នេះទី កតិកា-សញ្ញារបស់សង្ឃ ពេលនេះ ត្រូវលោកទាំងឡាយចូល ពេលនេះត្រូវលោកទាំងឡាយចេញ ។ ព្រះទព្វមល្លបុត្តមានអាយុ រៀបចំសេនាសនៈយ៉ាងនេះដល់ភិក្ខុទាំងឡាយនោះ ហើយទើបត្រឡប់មកវត្តវេឡុវ័នវិញ ។

(១០) សម័យនោះឯង មេត្តិយភិក្ខុនិងភុម្មជកភិក្ខុទាំងឡាយ ជាភិក្ខុថ្មីផង មានបុណ្យតិចផង ។ លោកទាំងនោះតែងបានសេនាសនៈទាំងឡាយរបស់សង្ឃដែលជារបស់ថោកទាប និងគ្រែដ៏ថោកទាប ។ សម័យនោះឯង មនុស្សទាំងឡាយក្នុងក្រុងរាជគ្រឹះ ចង់ប្រគេនសប្បិខ្លះ ប្រេងខ្លះ សម្ភុត្តរិកង្គខ្លះ(១) ដែលគេតាក់តែងឡើងដោយផ្ចិតផ្ចង់ដល់ភិក្ខុទាំងឡាយជាថេរៈ ចំណែកខាងមេត្តិយភិក្ខុនិងភុម្មជកភិក្ខុវិញ គេប្រគេនតែត្រឹមបាយបុងអង្ករមានទឹកជ្រក់ជាគំរប់ពីរ ជាភោជនប្រក្រតី ដែលគេប្រាព្វហើយយ៉ាងណា(២) ។ ពួកមេត្តិយភិក្ខុនិងភុម្មជកភិក្ខុទាំងនោះត្រឡប់ពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្ត ហើយក៏សួរភិក្ខុទាំងឡាយជាថេរៈថា ម្នាលអាវុសោទាំងឡាយ ក្នុងរោងភត្តរបស់លោកមានអ្វីខ្លះ មិនមានអ្វីខ្លះ ។

---

១ ជាឈ្មោះសម្លម្យ៉ាង ប្រែថា សម្លបំផុតនូវរសដ៏ក្រៃលែង គឺជាសម្លរកន្ទុះការសន្ធុះញ៉ាំ ជាងភោជនឯទៀត ៗ ដែលគេរៀបចំក្នុងផ្ទះនោះ ។ ២ គេប្រគេនត្រឹមតែបាយបុងអង្ករគំរប់ពីរ នឹងទឹកជ្រក់ជាភោជនធម្មតាដែលគេធ្វើរួចស្រាប់តែបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯកច្ចេ ថេរា ឯវំ វទន្តិ អម្ហាកំ អាវុសោ សប្បិ អហោសិ តេលំ អហោសិ ឧត្តរិភង្គំ អហោសីតិ ។ មេត្តិយភុម្មជកា បន ភិក្ខូ ឯវំ វទន្តិ អម្ហាកំ អាវុសោ ន កិញ្ចិ អហោសិ បាកតិកំ យថារន្ធំ កណាជកំ ពិលង្គទុតិយន្តិ ។

(១១) តេន ខោ បន សមយេន កល្យាណភត្តិកោ គហបតិ សង្ឃស្ស ចតុក្កភត្តំ ទេតិ និច្ចភត្តំ ។ សោ ភត្តគ្គេ សបុត្តទារោ ឧបតិដ្ឋិត្វា បរិវិសតិ ។ អញ្ញេ ឱទនេន បុច្ឆន្តិ អញ្ញេ សូបេន បុច្ឆន្តិ អញ្ញេ តេលេន បុច្ឆន្តិ អញ្ញេ ឧត្តរិភង្គេន បុច្ឆន្តិ ។

(១២) តេន ខោ បន សមយេន កល្យាណភត្តិកស្ស គហបតិនោ ភត្តំ ស្វាតនាយ មេត្តិយភុម្មជកានំ ភិក្ខូនំ ឧទ្ទិដ្ឋំ ហោតិ ។ អថ ខោ កល្យាណភត្តិកោ គហបតិ អារាមំ អគមាសិ កេនចិទេវ ករណីយេន យេនាយស្មា ទព្វោ មល្លបុត្តោ តេនុបសង្កមិ ឧប-

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះថេរៈទាំងឡាយពួកខ្លះប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ក្នុងពេលឆាន់របស់យើងមានសប្បិ មានប្រេង មានសម្លឧត្តរិភង្គ ។ ឯមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ និយាយប្រាប់យ៉ាងនេះថា ម្នាលអាវុសោ យើងគ្មានវត្ថុអ្វីទេ មានតែបាយបុំងអង្ករ និងទឹកជ្រក់ជាគំរប់ពីរ ជាភោជនប្រក្រតី ដែលគេប្រារព្ធហើយ យ៉ាងណាប៉ុណ្ណោះ ។

(១១) សម័យនោះឯង គហបតីឈ្មោះកល្យាណភត្តិកៈ តែងប្រគេនចតុក្កភត្ត(១)ជានិច្ចភត្តដល់សង្ឃ ។ គហបតីនោះព្រមទាំងកូនប្រពន្ធ តែងចូលទៅបម្រើអង្គាស (ព្រះសង្ឃ) ក្នុងរោងភត្ត ។ ភិក្ខុទាំងឡាយដទៃ ៗ ក៏សួររកបាយ សួររកសម្ល រកប្រេង រកសម្លឧត្តរិភង្គ ។

(១២) សម័យនោះឯង ភត្តុទ្ទេសកភិក្ខុបានចាត់ពួកមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ (ឲ្យទៅទទួល) ចង្ហាន់របស់កល្យាណភត្តិកគហបតីក្នុងថ្ងៃព្រឹកស្អែក ។ គ្រានោះ កល្យាណភត្តិកគហបតីបានទៅកាន់អារាម ដោយមានកិច្ចអ្វីមួយ ហើយក៏ចូលទៅរកព្រះទព្វមល្លបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ

១ ភត្តសម្រាប់ភិក្ខុ ៤ រូប ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សង្កមិត្វា អាយស្មន្តំ ទព្វំ មល្លបុត្តំ អភិវាទេត្វា
ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ កល្យា-
ណភត្តិកំ គហបតឹ អាយស្មា ទព្វោ មល្លបុត្តោ
ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេ-
ជេសិ សម្បហំសេសិ ។ អថខោ កល្យាណភត្តិកោ
គហបតិ អាយស្មតា ទព្វេន មល្លបុត្តេន ធម្មិយា
កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ
សម្បហំសិតោ អាយស្មន្តំ ទព្វំ មល្លបុត្តំ ឯតទវោច
កស្ស ភន្តេ អម្ហាកំ ឃរេ ស្វាតនាយ ភត្តំ ឧទ្ទិដ្ឋន្តិ ។
មេត្តិយភុម្មជកានំ ខោ គហបតិ ភិក្ខូនំ តុម្ហាកំ ឃរេ
ស្វាតនាយ ភត្តំ ឧទ្ទិដ្ឋន្តិ ។ អថខោ កល្យាណភត្តិកោ
គហបតិ អនត្តមនោ អហោសិ កថំ ហិ នាម បាបភិក្ខូ
អម្ហាកំ ឃរេ ភុញ្ជិស្សន្តីតិ ឃរំ គន្ត្វា ទាសឹ អាណា-
បេសិ យេ ជេ ស្វេ ភត្តិកា អាគច្ឆន្តិ តេ កោដ្ឋកេ
អាសនំ បញ្ញាបេត្វា កណាជកេន ពិលង្គទុតិយេន
បរិវិសាតិ ។ ឯវំ អយ្យោតិ ខោ សា ទាសី កល្យា-
ណភត្តិកស្ស គហបតិនោ បច្ចស្សោសិ ។ អថខោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



### សមថក្ខន្ធកៈ និទានព្រះមេត្តិយភុម្មជកភិក្ខុ

ក៏ថ្វាយបង្គំព្រះទព្វមល្លបុត្តដ៏មានអាយុ រួចអង្គុយក្នុងទីដ៏សមគួរ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ បាននិយាយពន្យល់កល្យាណភត្តិកគហបតិ ដែលអង្គុយនៅក្នុងទីដ៏សមគួរ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ កល្យាណភត្តិកគហបតិ កាលព្រះទព្វមល្លបុត្តដ៏មានអាយុ និយាយពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយនិយាយពាក្យនេះនឹងព្រះទព្វ-មល្លបុត្តដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ស្អែកនេះលោកម្ចាស់ចាត់ភិក្ខុអង្គណា (ឲ្យទៅទទួល) ភត្តក្នុងផ្ទះរបស់ខ្ញុំ ។ ព្រះទព្វមល្លបុត្តឆ្លើយថា ម្នាលគហបតិ ស្អែកនេះអាត្មានឹងចាត់មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុទាំងឡាយ (ឲ្យទៅទទួល) ភត្តក្នុងផ្ទះអ្នកក្នុងថ្ងៃស្អែក ។ លំដាប់នោះ កល្យា-ណភត្តិកគហបតិមានសេចក្តីអាក់អន់ចិត្តដោយគិតថា ចុះហេតុអ្វីបានជាភិក្ខុលាមកទាំងឡាយទៅឆាន់ក្នុងផ្ទះរបស់អាត្មាអញ (លុះគិតដូច្នេះហើយ) ក៏ទៅផ្ទះបង្គាប់ទាសីថា នែហ្ន៎ ស្អែកត្រូវពួកលោកណាមកទទួលបង្អាន់ ហ្នឯងចូរក្រាលអាសនៈក្នុងជង្រុក ហើយអង្គាសលោកទាំងនោះដោយបាយចុងអង្ករមានទឹកជ្រក់ជាគំរប់ពីរចុះ ។ ទាសីនោះទទួលស្តាប់ពាក្យកល្យាណភត្តិកគហបតិដោយពាក្យថា ចា៎ះ អ្នកម្ចាស់ ។ លំដាប់នោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មេត្តិយភុម្មជកា ភិក្ខូ ហិយ្យោ ខោ អាវុសោ អម្ហាកំ កល្យាណភត្តិកស្ស គហបតិនោ ភត្តំ ឧទ្ទិដ្ឋំ ស្វេ អម្ហេ កល្យាណភត្តិកោ គហបតិ សបុត្តទារោ ឧបតិដ្ឋិត្វា បរិវិសិស្សតិ អញ្ញេ ឱទនេន បុច្ឆិស្សន្តិ អញ្ញេ សូបេន បុច្ឆិស្សន្តិ អញ្ញេ តេលេន បុច្ឆិស្សន្តិ អញ្ញេ ឧត្តរិភង្គេន បុច្ឆិស្សន្តីតិ ។ តេ តេនេវ សោមនស្សេន ន ចិត្តរូបំ រត្តិយា សុបឹសុ ។ អថខោ មេត្តិយភុម្មជកា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន កល្យាណភត្តិកស្ស គហបតិនោ និវេសនំ តេនុបសង្កមឹសុ ។ អទ្ទសា ខោ សា ទាសី មេត្តិយភុម្មជកេ ភិក្ខូ ទូរតោវ អាគច្ឆន្តេ ទិស្វាន កោដ្ឋកេ អាសនំ បញ្ញាបេត្វា មេត្តិយភុម្មជកេ ភិក្ខូ ឯតទវោច និសីទថ ភន្តេតិ ។ អថខោ មេត្តិយភុម្មជកានំ ភិក្ខូនំ ឯតទហោសិ និស្សំសយំ ខោ ន តាវ ភត្តំ សិទ្ធំ ភវិស្សតិ យថា មយំ កោដ្ឋកេ និសីទាបិយាមាតិ[១] ។

១ សព្វត្ថ និសីទាបេយ្យាមាតិ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុទាំងឡាយគិតគ្នាថា ម្នាលអាវុសោ អំពីថ្ងៃម្សិលមិញ ភត្តុទ្ទេសកភិក្ខុបានចាត់ឲ្យយើងទៅទទួលភត្តរបស់កល្យាណភត្តិកគហបតី កល្យាណភត្តិកគហបតីព្រមទាំងកូនប្រពន្ធនឹងចូលមកបំរើអង្គាសពួកយើងក្នុងថ្ងៃស្អែក ភិក្ខុទាំងឡាយដទៃៗមុខជានឹងសួរគេបាយ គេសម្លគេប្រេង គេសម្លខ្ទិះគេគ្រឿង ។ ដោយសេចក្តីសោមនស្សនោះឯង មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុនោះក៏ដេកមិនលក់ តាមសេចក្តីគាប់ចិត្តក្នុងរាត្រី (នោះ) ។ គ្រានោះ មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុ ក៏ស្លៀកស្បង់ប្រដាប់បាត្រចីវរចូលទៅកាន់លំនៅរបស់កល្យាណភត្តិកគហបតីអំពីព្រឹកព្រហាម ។ ទាសីនោះបានឃើញមេត្តិយភិក្ខុនឹងភុម្មជកភិក្ខុ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយក៏ក្រាលអាសនៈក្នុងជង្រុក ហើយបាននិយាយពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុថា បពិត្រលោកទាំងឡាយដ៏ចំរើន សូមលោកទាំងឡាយគង់ចុះ ។ លំដាប់នោះ មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុ ត្រិះរិះដូច្នេះថា កុំសង្ស័យឡើយ បង្អាន់មិនទាន់ស្រេចទេ បានជាគេឲ្យយើងអង្គុយក្នុងជង្រុកសិន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកេ មេត្តិយភុម្មជកភិក្ខុវត្ថុ

អថខោ សា ទាសី កាណាជកេន ពិលង្គទុតិយេន ឧបគញ្ឆិ ភុញ្ជថ ភន្តេតិ ។ មយំ ខោ ភគិនិ និច្ចភត្តិកាតិ ។ ជានាមិ អយ្យា និច្ចភត្តិកាត្ថ អបិចាហំ ហិយ្យោ គហបតិនា អាណត្តា យេ ជេ ស្វេ ភត្តិកា អាគច្ឆន្តិ កោដ្ឋកេ អាសនំ បញ្ញបេត្វា កាណាជកេន ពិលង្គទុតិយេន បរិវិសាតិ ភុញ្ជថ ភន្តេតិ ។ អថខោ មេត្តិយភុម្មជកា ភិក្ខូ ហិយ្យោ ខោ អាវុសោ កល្យាណភត្តិកោ គហបតិ អារាមំ អគមាសិ ទព្វស្ស មល្លបុត្តស្ស សន្តិកេ និស្សំសយំ ខោ មយំ ទព្វេន មល្លបុត្តេន គហបតិនោ សន្តិកេ បរិភិន្នាតិ(១) ។ តេ តេនេវ ទោមនស្សេន ន ចិត្តរូបំ ភុញ្ជឹសុ ។ អថខោ មេត្តិយភុម្មជកា ភិក្ខូ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា អារាមំ គន្ត្វា បត្តចីវរំ បដិសាមេត្វា ពហារាមកោដ្ឋកេ សង្ឃាដិបល្លត្ថិកាយ និសីទឹសុ តុណ្ហីភូតា មង្កុភូតា បត្តក្ខន្ធា អធោមុខា

១ ឱ. និស្សំសយំ ទព្វេន មល្លបុត្តេន គហបតិនោ អន្តិកា បរិភិន្នាតិ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកៈ វិវាទមេត្តិយភិក្ខុនិកាក្ខ

គ្រានោះ ទាសីនោះ ក៏ផ្គត់ផ្គង់ដោយបាយបុងអង្ករមានទឹកជ្រក់ជាគំរប់ពីរ ហើយនិមន្តថា បពិត្រលោកដ៏ចំរើន សូមលោកទាំងឡាយឆាន់ចុះ ។ មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុ ឆ្លើយថា ម្នាលប្អូនស្រី យើងទាំងឡាយ បុគ្គលតែជាអ្នកទទួលនិច្ចភត្ត ។ ទាសីនោះឆ្លើយថា ខ្ញុំព្រះករុណាដឹងថា លោកម្ចាស់ទាំងឡាយ ជាអ្នកទទួលនិច្ចភត្តហើយ តែម្សិលមិញគហបតិបង្គាប់ខ្ញុំព្រះករុណាថា នែនាង លោកទាំងឡាយណា ត្រូវការដោយចង្ហាន់និមន្តមកក្នុងថ្ងៃស្អែក នាងឯងចូរក្រាលអាសនៈក្នុងជង្រុកចុះ ហើយអង្គាសលោកទាំងនោះ ដោយបាយបុងអង្ករមានទឹកជ្រក់ជាគំរប់ពីរចុះ បពិត្រលោកទាំងឡាយដ៏ចំរើន សូមលោកទាំងឡាយឆាន់ចុះ ។ លំដាប់នោះ មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុ និយាយគ្នាថា ម្នាលអាវុសោ កាលថ្ងៃម្សិលមិញ កល្យាណភត្តិកគហបតិ បានទៅកាន់អារាមនៅឯសំណាក់ទព្វមល្លបុត្ត ពួកយើងប្រាកដជាទព្វមល្លបុត្តញុះញង់ ក្នុងសំណាក់នៃគហបតិពិតហើយ ។ មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុទាំងនោះ ក៏មិនបានឆាន់ដូចចិត្តដែលប៉ុនប៉ងព្រោះតែសេចក្តីទោមនស្សនោះឯង ។ មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុត្រឡប់ពីបិណ្ឌបាត ក្នុងវេលាក្រោយភត្តហើយទៅកាន់អារាមក្នុងពេលនោះ ក៏រៀបទុកដាក់បាត្រនឹងចីវរ ហើយអង្គុយត្រោបាមក្បាលជង្គង់ទាំងសងខាងនៅក្រៅកោង្គាវេត្តនៅស្ងៀម មានសេចក្តីអៀនអន់ ទទកចុះ មានមុខជ្រប់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បញ្ញាយន្តា អប្បដិភាណា ។ អថខោ មេត្តិយា ភិក្ខុនី
យេន មេត្តិយភុម្មជកា ភិក្ខូ តេនុបសង្កមិ ឧបសង្ក-
មិត្វា មេត្តិយភុម្មជកេ ភិក្ខូ ឯតទវោច វន្ទាមិ អយ្យាតិ ។
ឯវំ វុត្តេ មេត្តិយភុម្មជកា ភិក្ខូ នាលបឹសុ ។ ទុតិ-
យម្បិ ខោ ។ បេ ។ តតិយម្បិ ខោ មេត្តិយា ភិក្ខុនី
មេត្តិយភុម្មជកេ ភិក្ខូ ឯតទវោច វន្ទាមិ អយ្យាតិ ។
តតិយម្បិ ខោ មេត្តិយភុម្មជកា ភិក្ខូ នាលបឹសុ ។
ក្យាហំ អយ្យានំ អបរជ្ឈាមិ កិស្ស មំ អយ្យា
នាលបន្តីតិ ។ តថាហិ បន ត្វំ ភគិនិ អម្ហេ ទព្វេន
មល្លបុត្តេន វិហេឋិយមានេ អជ្ឈុបេក្ខសីតិ ។ ក្យាហំ
អយ្យា ករោមីតិ ។ សចេ ខោ ត្វំ ភគិនិ ឥច្ឆេយ្យាសិ
អជ្ជេវ ភគវា អាយស្មន្តំ ទព្វំ មល្លបុត្តំ នាសាបេយ្យា-
តិ ។ ក្យាហំ អយ្យា ករោមិ កិំ មយា សក្កា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ស្រពាប់ស្រពោន ឥតមាននិយាយអ្វីសោះ ។ គ្រានោះ ភិក្ខុនីឈ្មោះមេត្តិយា ចូលទៅរកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងមេត្តិយភិក្ខុ និងភុម្មជកភិក្ខុថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណាសូមថ្វាយបង្គំ ។ កាលបើមេត្តិយាភិក្ខុនីនិយាយយ៉ាងនេះហើយ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុមិននិយាយតបសោះឡើយ ។ មេត្តិយាភិក្ខុនីបាននិយាយពាក្យនេះ ចំពោះមេត្តិយភុម្មជកភិក្ខុជាគំរប់ពីរដងផង ។ បេ ។ ជាគំរប់បីដងផងថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណាសូមថ្វាយបង្គំ ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុមិននិយាយតបជាគំរប់បីដងផង ។ ទើបមេត្តិយាភិក្ខុនីសួរថា ខ្ញុំព្រះករុណាបានប្រទូស្តនឹងលោកម្ចាស់ពីរអង្គដូចម្តេចខ្លះ ហេតុអ្វីបានជាលោកម្ចាស់ពីរអង្គមិននិយាយនឹងខ្ញុំព្រះករុណា ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ឆ្លើយថា ម្នាលប្អូនស្រី ពិតដូច្នោះហើយ ទព្វមល្លបុត្តកំពុងបៀតបៀនយើង នាងឯងក៏ព្រងើយកន្តើយ ។ មេត្តិយាភិក្ខុនីសួរថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណានឹងធ្វើដូចម្តេច ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី បើនាងប្រាថ្នានឹង (ធ្វើ) ត្រូវក្រាបបង្គំទូលព្រះមានព្រះភាគឲ្យញុំាងទព្វមល្លបុត្តមានអាយុឲ្យវិនាសចេញ ក្នុងថ្ងៃនេះឲ្យបាន ។ មេត្តិយាភិក្ខុនីសួរថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំនឹងធ្វើដូចម្តេច ចុះអំពើអ្វីដែលខ្ញុំនឹងអាច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាតុន្តិ ។ តេន ហិ ត្វំ ភគិនិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯវំ វទេហិ ឥទំ ភន្តេ នច្ឆន្នំ នប្បតិរូបំ យាយំ ភន្តេ ទិសា អភយា អនីតិកា អនុបទ្ទវា សាយំ ទិសា សភយា សឦតិកា សឧបទ្ទវា យតោ និវាតំ តតោ បវាតំ ឧទកំ មញ្ញេ អាទិត្តំ អយ្យេនម្ហិ ទព្វេន មល្លបុត្តេន ទូសិតាតិ ។ ឯវំ អយ្យាតិ ខោ មេត្តិយា ភិក្ខុនី មេត្តិយភុម្មជកានំ ភិក្ខូនំ បដិស្សុណិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា(១) មេត្តិយា ភិក្ខុនី ភគវន្តំ ឯតទវោច ឥទំ ភន្តេ នច្ឆន្នំ នប្បតិរូបំ យាយំ ភន្តេ ទិសា អភយា អនីតិកា អនុបទ្ទវា សាយំ ទិសា សភយា សឦតិកា សឧបទ្ទវា យតោ និវាតំ

---

១ ឧភយបោត្ថកេ សាតិ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



[illegible]ខន្ធកៈ និទានមេត្តិយភុម្មជកភិក្ខុ

ធ្វើបាន ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី នាងចូរមក នាងចូរទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ការនេះមិនមែនជាការកំប៉ាំងទេ មិនមែនជាការសមគួរ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនមានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះត្រឡប់ជាប្រកបដោយភ័យ ប្រកបដោយចង្រៃ ប្រកបដោយឧបទ្រពទៅវិញ ទីណាដែលមិនធ្លាប់មានខ្យល់ ទីនោះត្រឡប់ជាមានខ្យល់វិញ ដូចជាទឹកធ្លាប់ត្រជាក់ប្រែទៅជាក្តៅ ឥឡូវព្រះទព្វមល្លបុត្តជាម្ចាស់បានប្រទូស្តនឹងខ្ញុំព្រះអង្គហើយ ។ មេត្តិយាភិក្ខុនីទទួលស្តាប់ពាក្យមេត្តិយភិក្ខុនិងភុម្មជកភិក្ខុដោយពាក្យថា យ៉ាងហ្នឹងហើយ លោកម្ចាស់ រួចហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ មេត្តិយាភិក្ខុនីនោះលុះឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ការនេះមិនមែនជាការកំប៉ាំងទេ មិនមែនជាការសមគួរទេ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនធ្លាប់មានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះត្រឡប់ទៅជាប្រកបដោយភ័យ ប្រកបដោយចង្រៃ ប្រកបដោយឧបទ្រពទៅវិញ ទីណាដែលមិនធ្លាប់មានខ្យល់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តតោ បវាតំ ឧទកំ មញ្ញេ អាទិត្តំ អយ្យេនម្ហិ ទព្វេន មល្លបុត្តេន ទូសិតាតិ ។

(១៣) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ ទព្វំ មល្លបុត្តំ បដិបុច្ឆិ សរសិ ត្វំ ទព្វ ឯវរូបំ កត្តា យថាយំ ភិក្ខុនី អាហាតិ ។ យថា មំ ភន្តេ ភគវា ជានាតីតិ ។ ទុតិយម្បិ ខោ ភគវា ។បេ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ ទព្វំ មល្លបុត្តំ ឯតទវោច សរសិ ត្វំ ទព្វ ឯវរូបំ កត្តា យថាយំ ភិក្ខុនី អាហាតិ ។ យថា មំ ភន្តេ ភគវា ជានាតីតិ ។ ន ខោ ទព្វ ទព្វា ឯវំ និព្វេឋេន្តិ សចេ តយា កតំ កតន្តិ វទេហិ សចេ អកតំ អកតន្តិ វទេហីតិ ។ យតោហំ ភន្តេ ជាតោ នាភិជានាមិ សុបិនន្តេនាបិ មេថុនំ ធម្មំ បដិសេវិតា បគេវ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទីនោះត្រឡប់ទៅជាបានខ្យល់វិញ ដូចជាទឹកធ្លាប់ត្រជាក់ ប្រែខ្លួនជាក្តៅវិញ ឥឡូវព្រះទព្វមល្លបុត្តជាម្ចាស់បានប្រទូស្តនឹងខ្ញុំព្រះអង្គហើយ ។

(១៣) ព្រោះនិទាននេះ ព្រោះបករណ៍នេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់នូវព្រះទព្វមល្លបុត្តដ៏មានអាយុក្នុងវេលានោះថា ម្នាលទព្វៈ អ្នកលើកឃើញថា អ្នកបានធ្វើអំពើដូចភិក្ខុនីនេះបានពោលឬទេ ។ ព្រះទព្វមល្លបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ដូចជាព្រះមានព្រះភាគទ្រង់ជ្រាប នូវខ្ញុំព្រះអង្គស្រាប់ហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរព្រះទព្វមល្លបុត្តជាគំរប់ពីរដងផង ។ បេ ។ ជាគំរប់បីដងផងថា ម្នាលទព្វៈ អ្នកលើកឃើញថា អ្នកបានធ្វើអំពើដូចជាភិក្ខុនីនេះបានពោលឬទេ ។ ព្រះទព្វមល្លបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ដូចជាព្រះមានព្រះភាគទ្រង់ជ្រាប នូវខ្ញុំព្រះអង្គស្រាប់ហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយ មិននិយាយបណ្តោះបណ្តោយយ៉ាងនេះទេ បើអំពើដែលអ្នកបានធ្វើហើយ អ្នកចូរនិយាយថា ខ្ញុំបានធ្វើហើយ បើអំពើដែលអ្នកមិនបានធ្វើទេ អ្នកចូរនិយាយថា ខ្ញុំមិនបានធ្វើទេ ។ ព្រះទព្វមល្លបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន តាំងពីខ្ញុំព្រះអង្គកើតមក សូម្បីតែយល់សប្តិសេពមេថុនធម្មក៏មិនដែលស្គាល់សោះឡើយ ចំណង់បាច់និយាយទៅថ្វី ដល់ការ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ជាគរោតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ មេត្តិយំ ភិក្ខុនឹ នាសេថ ឥមេ ច ភិក្ខូ អនុយុញ្ជថាតិ ។ ឥទំ វត្វា ភគវា ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ តេ ភិក្ខូ មេត្តិយំ ភិក្ខុនឹ នាសេសុំ ។ អថខោ មេត្តិយភុម្មជកា ភិក្ខូ តេ ភិក្ខូ ឯតទវោចុំ មា អាវុសោ មេត្តិយំ ភិក្ខុនឹ នាសេថ ន សា កិញ្ចិ អបរជ្ឈតិ អម្ហេហិ សា ឧស្សាហិតា កុបិតេហិ អនត្តមនេហិ ចាវនាធិប្បាយេហីតិ ។ កឹ បន តុម្ហេ អាវុសោ អាយស្មន្តំ ទព្វំ មល្លបុត្តំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេថាតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្វំ មល្លបុត្តំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ក្រាក់រលើកឡើង ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះអ្នកទាំងឡាយ ចូរឲ្យមេត្តិយាភិក្ខុនីសឹកចេញ មួយទៀត អ្នកទាំងឡាយ ចូរសាកសួរពួកភិក្ខុទាំងនេះមើល ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់ក្រោកចាកអាសនៈចូលទៅកាន់វិហារវិញ ។ ភិក្ខុទាំងឡាយនោះ ក៏ឲ្យមេត្តិយាភិក្ខុនីសឹកចេញក្នុងពេលនោះ ។ ទើបមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ និយាយពាក្យនេះនឹងភិក្ខុទាំងឡាយនោះថា ម្នាលអាវុសោ ចូរលោកទាំងឡាយកុំផ្សឹកមេត្តិយាភិក្ខុនីឡើយ នាងនោះឥតមានកំហុសអ្វីទេ (ហេតុដើមមកពី) យើងខឹងអាក់អន់ចិត្តចង់ឲ្យទព្វមល្លបុត្តឃ្លាតចាកសមណភេទ ទើបឲ្យមេត្តិយាភិក្ខុនីនោះទាស់ខ្នងឡើង ។ ភិក្ខុទាំងឡាយសួរថា ម្នាលអាវុសោ អ្នកបានចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយសីលវិបត្តិមិនមានមូលដែរឬ ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុឆ្លើយថា ម្នាលអាវុសោ យ៉ាងហ្នឹងហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ចោទព្រះទព្វមល្លបុត្តមានអាយុដោយសីលវិបត្តិមិនមានមូលសោះ ។ ឯភិក្ខុទាំងនោះក៏បានក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មេត្តិយភុម្មជកា ភិក្ខូ ទព្វំ មល្លបុត្តំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេន្តិ ។ សច្ចំ ភគវាតិ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ ទព្វស្ស មល្លបុត្តស្ស សតិវេបុល្លប្បត្តស្ស សតិវិនយំ ទេតុ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វោ ។ តេន ភិក្ខវេ ទព្វេន មល្លបុត្តេន សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ ឥមេ មំ ភន្តេ មេត្តិយភុម្មជកា ភិក្ខូ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេន្តិ សោហំ ភន្តេ សតិវេបុល្លប្បត្តោ សង្ឃំ សតិវិនយំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វោ ។បេ។ តតិយម្បិ យាចិតព្វោ ឥមេ មំ ភន្តេ មេត្តិយភុម្មជកា ភិក្ខូ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេន្តិ សោហំ សតិវេបុល្លប្បត្តោ តតិយម្បិ ភន្តេ សង្ឃំ(១) សតិវិនយំ យាចាមីតិ ។

---

១ ឧភោមិយបោត្ថកេ សោហំ ភន្តេ សតិវេបុល្លប្បត្តោ តតិយម្បិ សង្ឃន្តិ អាគតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឮថា មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុ ចោទទព្វមល្លបុត្តដោយសីលវិបត្តិមិនមានមូល ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន ។បេ។ លុះទ្រង់តិះដៀលហើយទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យសតិវិន័យដល់ទព្វមល្លបុត្តជាអ្នកបរិបូណ៌ដោយសតិចុះ ។ ម្នាលភិក្ខុទាំងឡាយ សតិវិន័យនោះ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ទព្វមល្លបុត្តនោះត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើងនិយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុទាំងឡាយនេះ ចោទខ្ញុំដោយសីលវិបត្តិមិនមានមូល បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាអ្នកបរិបូណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃ ។ ទព្វមល្លបុត្ត គប្បីសូមជាគំរប់ពីរដងផង ។បេ។ គប្បីសូមជាគំរប់បីដងផងថា បពិត្រព្រះសង្ឃដ៏ចំរើន មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុទាំងឡាយនេះ ចោទខ្ញុំដោយសីលវិបត្តិមិនមានមូល បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាអ្នកបរិបូណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃជាគំរប់បីដងផង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(១៤) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញា-
បេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ មេត្តិយ-
ភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្វំ មល្លបុត្តំ អមូលិកាយ
សីលវិបត្តិយា អនុទ្ធំសេន្តិ ។ អាយស្មា ទព្វោ មល្ល-
បុត្តោ សតិវេបុល្លប្បត្តោ សង្ឃំ សតិវិនយំ យាចតិ ។
យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ អាយស្មតោ ទព្វស្ស
មល្លបុត្តស្ស សតិវេបុល្លប្បត្តស្ស សតិវិនយំ ទទេយ្យ ។
ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ មេត្តិយ-
ភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្វំ មល្លបុត្តំ អមូលិកាយ
សីលវិបត្តិយា អនុទ្ធំសេន្តិ ។ អាយស្មា ទព្វោ មល្ល-
បុត្តោ សតិវេបុល្លប្បត្តោ សង្ឃំ សតិវិនយំ យាចតិ ។
សង្ឃោ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស សតិវេ-
បុល្លប្បត្តស្ស សតិវិនយំ ទេតិ ។ យស្សាយស្មតោ
ខមតិ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស សតិវេ-
បុល្លប្បត្តស្ស សតិវិនយស្ស ទានំ សោ តុណ្ហស្ស យស្ស
នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ
។បេ។ តតិយម្បិ ឯតមត្ថំ វទាមិ សុណាតុ មេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកៈ ការសូមសតិវិន័យ

(១៤) ភិក្ខុដែលឈ្លាសប្រតិពលគប្បីប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុទាំងឡាយនេះ ចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយសីលវិបត្តិមិនមានមូល ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃ ។ បើការសូមសតិវិន័យមានកាលគួរដល់សង្ឃហើយ សូមសង្ឃឲ្យសតិវិន័យដល់ព្រះទព្វមល្លបុត្តដ៏មានអាយុជាអ្នកបរិបូណ៌ដោយសតិចុះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ មេត្តិយភិក្ខុនឹងភុម្មជកភិក្ខុទាំងឡាយនេះ ចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយសីល-វិបត្តិមិនមានមូល ។ ព្រះទព្វមល្លបុត្ត ដ៏មានអាយុជាអ្នកបរិបូណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃ ។ សង្ឃបានឲ្យសតិវិន័យ ដល់ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ ។ ការឲ្យសតិ-វិន័យ ដល់ព្រះទព្វមល្លបុត្តដ៏មានអាយុជាអ្នកបរិបូណ៌ដោយសតិ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ។បេ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភន្តេ សង្ឃោ ឥមេ មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្ពំ មល្លបុត្តំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេន្តិ ។ អាយស្មា ទព្ពោ មល្លបុត្តោ សតិវេបុល្លប្បត្តោ សង្ឃំ សតិវិនយំ យាចតិ ។ សង្ឃោ អាយស្មតោ ទព្ពស្ស សតិវេបុល្លប្បត្តស្ស សតិវិនយំ ទេតិ ។ យស្សាយស្មតោ ខមតិ អាយស្មតោ ទព្ពស្ស មល្លបុត្តស្ស សតិវេបុល្លប្បត្តស្ស សតិវិនយស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នោ សង្ឃេន អាយស្មតោ ទព្ពស្ស មល្លបុត្តស្ស សតិវេបុល្លប្បត្តស្ស សតិវិនយោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(១៩) បញ្ចិមានិ ភិក្ខវេ ធម្មិកានិ សតិវិនយស្ស ទានានិ សុទ្ធោ ហោតិ ភិក្ខុ អនាបត្តិកោ អនុវទន្តិ ច នំ យាចតិ ច តស្ស សង្ឃោ សតិវិនយំ ទេតិ ធម្មេន សមគ្គេន(១) ឥមានិ ខោ ភិក្ខវេ បញ្ច ធម្មិកានិ សតិវិនយស្ស ទានានីតិ ។

---

១ ឱ. សមគ្គោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មេត្តិយភិក្ខុនីចង់កម្ចាត់ភិក្ខុទាំងឡាយនេះ ចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយសីលវិបត្តិមិនមានមូល ។ ព្រះទព្វមល្លបុត្តដ៏មានអាយុជាអ្នកបរិបូ-ណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃ ។ សង្ឃបានឲ្យសតិវិន័យដល់ព្រះទព្វមល្លបុត្តដ៏មានអាយុជាអ្នកបរិបូណ៌ដោយសតិ ។ ការឲ្យសតិ-វិន័យដល់ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើយ ។ សង្ឃបានឲ្យសតិវិន័យដល់ព្រះទព្វមល្លបុត្តដ៏មានអាយុជាអ្នកបរិបូណ៌ដោយសតិហើយ (ការឲ្យសតិវិន័យនេះ) សមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(១៥) ម្នាលភិក្ខុទាំងឡាយ ការឲ្យសតិវិន័យ[1] ដែលប្រកបដោយធម៌នេះមាន ៥ យ៉ាង គឺ ឲ្យដល់ភិក្ខុបរិសុទ្ធមិនមានអាបត្តិ ១ ភិក្ខុឯទៀតចោទភិក្ខុនោះ ១ ភិក្ខុនោះសូម ១ សង្ឃឲ្យសតិវិន័យដល់ភិក្ខុនោះ ១ សង្ឃព្រមព្រៀងឲ្យដោយធម៌ ១ ម្នាលភិក្ខុទាំងឡាយ ការឲ្យសតិវិន័យប្រកបដោយធម៌ ៥ យ៉ាងនេះឯង ។

---

១ អដ្ឋកថា ថា សតិវិន័យនេះ សង្ឃត្រូវឲ្យតែព្រះខីណាស្រពប៉ុណ្ណោះ មិនត្រូវឲ្យដល់ភិក្ខុឯទៀតទេ ដោយហោចទៅសូម្បីតែភិក្ខុជាអនាគាមីក៏មិនត្រូវឲ្យដែរ ។ សតិវិន័យនោះត្រូវឲ្យដល់ភិក្ខុដែលភិក្ខុដទៃចោទ បើគេមិនចោទក៏មិនត្រូវឲ្យដែរ ។ កាលបើសង្ឃឲ្យសតិ-វិន័យហើយ អ្នកចោទក៏ចោទមិនឡើងឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកេ គគ្គភិក្ខុវត្ថុ

(១៦) តេន ខោ បន សមយេន គគ្គោ ភិក្ខុ ឧម្មត្តកោ ហោតិ ចិត្តវិបរិយាសកតោ ។ តេន ឧម្មត្ត-កេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈា-ចិណ្ណំ ហោតិ ភាសិតបរិក្កន្តំ ។ ភិក្ខូ គគ្គំ ភិក្ខុំ ឧម្មត្ត-កេន ចិត្តវិបរិយាសកតេន អជ្ឈាចិណ្ណេន អាបត្តិយា ចោទេន្តិ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ ឯវំ វទេតិ អហំ ខោ អាវុសោ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយា-សកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតប-រិក្កន្តំ នាហន្តំ សរាមិ មូឡ្ហេន មេ ឯតំ កតន្តិ ។ ឯវម្បិ នំ វុច្ចមានា ចោទេន្តេវ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈា-យន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ គគ្គំ ភិក្ខុំ ឧម្មត្តកេន ចិត្តវិបរិយាសកតេន អជ្ឈាចិណ្ណេន អាបត្តិ-យា ចោទេស្សន្តិ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិ-

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សមថក្ខន្ធកៈ និទានគគ្គភិក្ខុ

(១៦) សម័យនោះឯង គគ្គភិក្ខុ ជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែ
ប្រួល ។ ភិក្ខុឆ្កួតដែលមានចិត្តវិបល្លាសប្រែប្រួលហើយនោះ រមែងតែ
ប្រព្រឹត្តអនាចារ បានពោលនូវពាក្យយាមល្មើសនូវកិច្ចមិនមែនជារបស់
សមណៈជាច្រើន ។ ភិក្ខុទាំងឡាយចោទគគ្គភិក្ខុដោយអាបត្តិ ព្រោះតែ
លោកជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារថា លោក
ដ៏មានអាយុចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះ
ហើយ ។ គគ្គភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំ
ជាមនុស្សឆ្កួតមានចិត្តវិបល្លាសប្រែប្រួល កាលខ្ញុំឆ្កួតមានចិត្តវិបល្លាសប្រែ
ប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោលនូវពាក្យយាមល្មើស
នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញនូវអំពើនោះ
ថា អំពើនេះអាត្មាអញបានធ្វើដោយសេចក្ដីវង្វេង ។ ភិក្ខុទាំងឡាយក៏នៅ
តែពោលចោទគគ្គភិក្ខុនោះយ៉ាងនេះទៀតថា លោកដ៏មានអាយុ ចូររលឹក
មើលចុះ លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ។ ភិក្ខុទាំង
ឡាយណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោល
ទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងចោទគគ្គ-
ភិក្ខុដោយអាបត្តិ ព្រោះតែលោកជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួលបាន
ប្រព្រឹត្តអនាចារថា លោកដ៏មានអាយុចូររលឹកមើលចុះ លោកជាអ្នកត្រូវ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តាតិ សោ ឯវំ វទេតិ អហំ ខោ អាវុសោ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ នាហំ តំ សរាមិ មូឡ្ហេន មេ ឯតំ កតន្តិ ឯវម្បិ នំ វុច្ចមានា ចោទេន្តេវ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ។បេ។ សច្ចំ ភគវាតិ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ គគ្គស្ស ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយំ ទេតុ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វោ ។ តេន ភិក្ខវេ គគ្គេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ ឧម្មត្តកោ អហោសឹ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាបត្តិមានសភាពយ៉ាងនេះហើយ  គគ្គភិក្ខុនោះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ  ខ្ញុំជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល  កាលដែលខ្ញុំឆ្កួតមានចិត្តវិបល្លាសប្រែប្រួលហើយនោះ  ក៏បានប្រព្រឹត្តអនាចារ បានពោល បានព្យាយាមល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញនូវអំពើនោះថា  អំពើនេះគ្នាអញ  បានធ្វើដោយសេចក្តីវង្វេង  ភិក្ខុទាំងឡាយ  ក៏នៅតែពោលចោទគគ្គភិក្ខុនោះយ៉ាងនេះទៀតថា លោកដ៏មានអាយុ  ចូររលឹកមើលចុះ  លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ។ លំដាប់នោះភិក្ខុទាំងឡាយនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។  ព្រះអង្គទ្រង់ត្រាស់ថា  ម្នាលភិក្ខុទាំងឡាយ ដំណើរនោះពិតមែនឬ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន  ។ បេ ។  លុះទ្រង់តិះដៀលហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា  ម្នាលភិក្ខុទាំងឡាយ  បើដូច្នោះ សង្ឃចូរឲ្យអមូឡ្ហវិន័យដល់គគ្គភិក្ខុដែលបាត់វង្វេងចុះ ។ ម្នាលភិក្ខុទាំងឡាយ អមូឡ្ហវិន័យនោះសង្ឃគប្បីឲ្យយ៉ាងនេះ ។  ម្នាលភិក្ខុទាំងឡាយ  គគ្គភិក្ខុនោះគប្បីចូលទៅកេសង្ឃ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ  រួចអង្គុយច្រហោង  ផ្គងអញ្ជលីឡើង  និយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន  ខ្ញុំជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល  កាលខ្ញុំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## សមថក្ខន្ធកេ អមូឡ្ហវិនយយាចនា

ចិត្តវិបរិយាសកតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយា-
សកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតប-
រិក្កន្តំ មំ ភិក្ខូ ឧម្មត្តកេន ចិត្តវិបរិយាសកតេន អជ្ឈា-
ចិណ្ណេន អាបត្តិយា ចោទេន្តិ សរតាយស្មា ឯវរូបឹ អាបត្តឹ
អាបជ្ជិតាតិ ត្យាហំ ឯវំ វទាមិ អហំ ខោ អាវុសោ
ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ
ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ
អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ នាហំ តំ សរាមិ មូឡ្ហេន
មេ ឯតំ កតន្តិ ឯវម្បិ មំ វុច្ចមានា ចោទេន្តេវ សរតា-
យស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ សោហំ ភន្តេ
អមូឡ្ហោ សង្ឃំ អមូឡ្ហវិនយំ យាចាមីតិ ។ ទុតិយម្បិ
យាចិតព្វោ ។ បេ ។ តតិយម្បិ យាចិតព្វោ អហំ ភន្តេ
ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ
ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ
អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ មំ ភិក្ខូ ឧម្មត្តកេន ចិត្ត-
វិបរិយាសកតេន អជ្ឈាចិណ្ណេន អាបត្តិយា ចោទេន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឆ្កួតមានចិត្តវិបល្លាសប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តកន្លង បានពោល
ទឹងតព្យាយាមល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ឯភិក្ខុទាំង
ឡាយក៏ចោទខ្ញុំដោយអាបត្តិ ព្រោះតែខ្ញុំជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែ
ប្រួលបានប្រព្រឹត្តអនាចារថា លោកដ៏មានអាយុចូររលឹកមើលចុះ លោក
ជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ខ្ញុំបាននិយាយនឹងភិក្ខុទាំង
ឡាយនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាភិក្ខុឆ្កួតមានចិត្តវិប-
ល្លាសប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួតមានចិត្តវិបល្លាស ប្រែប្រួលនោះ
ក៏បានប្រព្រឹត្តអនាចារ បានពោលទឹងតព្យាយាមល្មើស នូវកិច្ចមិនមែនជា
របស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញនូវអំពើនោះថា អំពើនេះអាត្មា
អញបានធ្វើហើយដោយសេចក្ដីវង្វេង ភិក្ខុទាំងឡាយក៏ពោលចោទខ្ញុំយ៉ាង
នេះទៀតថា លោកដ៏មានអាយុចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ
មានសភាពយ៉ាងនេះហើយ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំបាត់វង្វេងហើយ
មកសូមអមូឡ្ហវិន័យនឹងសង្ឃ ។ គគ្គភិក្ខុត្រូវសូមជាគំរប់ពីរដងផង
។ បេ ។ សូមជាគំរប់បីដងផងថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាភិក្ខុឆ្កួត
មានចិត្តវិបល្លាស ប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួតមានចិត្តវិបល្លាសប្រែ
ប្រួលនោះ ក៏បានប្រព្រឹត្តអនាចារ បានពោលទឹងតព្យាយាមល្មើសនូវកិច្ច
មិនមែនជារបស់សមណៈជាច្រើន ឯភិក្ខុទាំងឡាយក៏ចោទខ្ញុំដោយអាបត្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ស្វាហំ ឯវំ វទាមិ អហំ ខោ អាវុសោ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ នាហំ តំ សរាមិ មូឡ្ហេន មេ ឯតំ កតន្តិ ឯវម្បិ មំ វុច្ចមានា ចោទេន្តេវ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ សោហំ អមូឡ្ហោ តតិយម្បិ ភន្តេ សង្ឃំ អមូឡ្ហវិនយំ យាចាមីតិ ។

(១៧) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ គគ្គោ ភិក្ខុ ឧម្មត្តកោ អហោសិ ចិត្តវិបរិយាសកតោ តេន ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ ភិក្ខូ គគ្គំ ភិក្ខុំ ឧម្មត្តកេន ចិត្តវិបរិយាសកតេន អជ្ឈាចិណ្ណេន អាបត្តិយា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រោះតែខ្ញុំឆ្កួតមានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារថា លោកដ៏មានអាយុចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ខ្ញុំក៏បាននិយាយនឹងភិក្ខុទាំងឡាយនោះវិញ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួតមានចិត្តវិបល្លាសប្រែប្រួលនោះ ក៏បានប្រព្រឹត្តអនាចារ បានពោលនូវពាក្យហាមល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញនូវអំពើនោះថា អំពើនេះអាត្មាអញបានធ្វើហើយ ដោយសេចក្តីវង្វេង ឯភិក្ខុទាំងឡាយពោលចោទខ្ញុំយ៉ាងនេះទៀតថា លោកដ៏មានអាយុចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំបាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃជាគំរប់ពីរដងផង ។

[១៧] ភិក្ខុដែលឈ្លាសប្រតិពលគប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ គគ្គភិក្ខុនោះជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល កាលដែលលោកកំពុងឆ្កួតមានចិត្តវិបល្លាសប្រែប្រួលនោះ ក៏បានប្រព្រឹត្តអនាចារ បានពោលនូវពាក្យហាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ។ ឯភិក្ខុទាំងឡាយចោទគគ្គភិក្ខុដោយអាបត្តិ ព្រោះតែលោកឆ្កួតមានចិត្តវិបល្លាស ប្រែប្រួល បានប្រព្រឹត្តអនាចារថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ចោទេន្តិ សរតាយស្មា ឯវរូបិំ អាបត្តឹ អាបជ្ជិតាតិ ។ សោ ឯវំ វទេតិ អហំ ខោ អាវុសោ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយា-សកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិត-បរិក្កន្តំ នាហន្តំ សរាមិ មូឡ្ហេន មេ ឯតំ កតន្តិ ។ ឯវម្បិ នំ វុច្ចមានា ចោទេន្តេវ សរតាយស្មា ឯវរូបិំ អាបត្តឹ អាបជ្ជិតាតិ ។ សោហំ អមូឡ្ហោ សង្ឃំ អមូឡ្ហវិនយំ យាចាមិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ គគ្គស្ស ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ គគ្គោ ភិក្ខុ ឧម្មត្តកោ អហោសិ ចិត្តវិបរិយាសកតោ តេន ឧម្មត្តកេន ចិត្ត-វិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ ភិក្ខូ គគ្គំ ភិក្ខុំ ឧម្មត្តកេន ចិត្តវិប-រិយាសកតេន អជ្ឈាចិណ្ណេន អាបត្តិយា ចោទេន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ។ គគ្គភិក្ខុនោះឆ្លើយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ខ្ញុំជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួតមានចិត្តវិបល្លាសប្រែប្រួលនោះ បានប្រព្រឹត្តអនាចារ បានពោលនឹងព្យាយាមល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញនូវអំពើនោះថា អំពើនេះអាត្មាអញបានធ្វើហើយ ដោយសេចក្តីវង្វេង ។ ឯភិក្ខុទាំងឡាយក៏នៅតែពោលចោទគគ្គភិក្ខុនោះយ៉ាងនេះទៀតថា លោកដ៏មានអាយុចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ។ ឥឡូវគគ្គភិក្ខុនោះបាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ ។ បើការសូមអមូឡ្ហវិន័យ មានកាលគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យអមូឡ្ហវិន័យដល់គគ្គភិក្ខុជាអ្នកបាត់វង្វេងហើយចុះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ គគ្គភិក្ខុនេះជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល កាលដែលលោកកំពុងឆ្កួតមានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារ បានពោលនឹងព្យាយាមល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ។ ឯភិក្ខុទាំងឡាយក៏ចោទគគ្គភិក្ខុដោយអាបត្តិ ព្រោះតែលោកជាភិក្ខុឆ្កួតមានចិត្តវិបល្លាស ប្រែប្រួល បានប្រព្រឹត្តអនាចារថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ ឯវំ វទេតិ អហំ ខោ អាវុសោ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ នាហន្តំ សរាមិ មូឡ្ហេន មេ ឯតំ កតន្តិ ។ ឯវម្បិ នំ វុច្ចមានា ចោទេន្តេវ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ អមូឡ្ហោ សង្ឃំ អមូឡ្ហវិនយំ យាចតិ ។ សង្ឃោ គគ្គស្ស ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយំ ទេតិ ។ យស្សាយស្មតោ ខមតិ គគ្គស្ស ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ ទិន្នោ សង្ឃេន គគ្គស្ស ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ចូរលោកដ៏មានអាយុរលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ។ គគ្គភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួតមានចិត្តវិបល្លាសប្រែប្រួលនោះ បានប្រព្រឹត្តអនាចារ បានពោលនឹងព្យាយាមលើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញនូវអំពើនោះថា អំពើនេះអាត្មាអញបានធ្វើហើយ ដោយសេចក្តីវង្វេង ។ ភិក្ខុទាំងឡាយក៏នៅតែពោលចោទគគ្គភិក្ខុនោះ យ៉ាងនេះទៀតថា លោកមានអាយុចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ។ គគ្គភិក្ខុនោះបាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ ។ សង្ឃឲ្យអមូឡ្ហវិន័យ ដល់គគ្គភិក្ខុជាអ្នកបាត់វង្វេងហើយ ។ ការឲ្យអមូឡ្ហវិន័យ ដល់គគ្គភិក្ខុជាអ្នកបាត់វង្វេង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បេ ។ សង្ឃបានឲ្យអមូឡ្ហវិន័យ ដល់គគ្គភិក្ខុជាអ្នកបាត់វង្វេងហើយ ការឲ្យអមូឡ្ហវិន័យនេះគួរដល់សង្ឃ ព្រោះហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៨) តីណិមានិ ភិក្ខវេ អធម្មិកានិ អមូឡ្ហវិនយស្ស ទានានិ តីណិ ធម្មិកានិ ។ កតមានិ តីណិ អធម្មិកានិ អមូឡ្ហវិនយស្ស ទានានិ ។ ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តឹ អាបន្នោ ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ សរមានោវ ឯវំ វទេតិ ន ខោ អហំ អាវុសោ សរាមិ ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ តស្ស សង្ឃោ អមូឡ្ហវិនយំ ទេតិ ។ អធម្មិកំ អមូឡ្ហវិនយស្ស ទានំ ។

(១៩) ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តឹ អាបន្នោ ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ សរមានោ វ ឯវំ វទេតិ សរាមិ ខោ អហំ អាវុសោ យថា សុបិនន្តេនាតិ ។ តស្ស សង្ឃោ អមូឡ្ហវិនយំ ទេតិ ។ អធម្មិកំ អមូឡ្ហវិនយស្ស ទានំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកៈ ការឲ្យអមូឡ្ហវិន័យមិនប្រកបដោយធម៌មាន ៣ យ៉ាង

[១៨] ម្នាលភិក្ខុទាំងឡាយ ការឲ្យអមូឡ្ហវិន័យនេះ ដែលមិនប្រកបដោយធម៌មាន ៣ យ៉ាង ដែលប្រកបដោយធម៌មាន ៣ យ៉ាង ។ ការឲ្យអមូឡ្ហវិន័យមិនប្រកបដោយធម៌មាន ៣ យ៉ាង ( នោះ ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូរលើកមើលចុះ លោកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ។ ភិក្ខុនោះកាលលើកឃើញក៏និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះ ខ្ញុំលើកមិនឃើញទេ ។ សង្ឃឲ្យអមូឡ្ហវិន័យដល់ភិក្ខុនោះ ។ ការឲ្យអមូឡ្ហវិន័យ ( យ៉ាងនេះ ) ឈ្មោះថាមិនប្រកបដោយធម៌ ។

[១៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុចូរលើកមើលចុះ លោកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ។ កាលភិក្ខុនោះលើកឃើញក៏និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំលើកឃើញដែរ តែដូចជាយល់សប្តិ ។ សង្ឃឲ្យអមូឡ្ហវិន័យដល់ភិក្ខុនោះ ។ ការឲ្យអមូឡ្ហវិន័យ (យ៉ាងនេះ) ឈ្មោះថាមិនប្រកបដោយធម៌ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២០) ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តឹ អាបន្នោ ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ អនុម្មត្តកោ ឧម្មត្តកាលយំ ករោតិ អហម្បិ ឯវំ ករោមិ តុម្ហេបិ ឯវំ ករោថ មយ្ហម្បិ ឯតំ កប្បតិ តុម្ហាកម្បេតំ កប្បតីតិ ។ តស្ស សង្ឃោ អមូឡ្ហវិនយំ ទេតិ ។ អធម្មិកំ អមូឡ្ហវិនយស្ស ទានំ ។ ឥមានិ តីណិ អធម្មិកានិ អមូឡ្ហវិនយស្ស ទានានិ ។

(២១) កតមានិ តីណិ ធម្មិកានិ អមូឡ្ហវិនយស្ស ទានានិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឧម្មត្តកោ ហោតិ ចិត្តវិបរិយាសកតោ ។ តេន ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ហោតិ ភាសិតបរិក្កន្តំ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ អស្សរមានោវ ឯវំ វទេតិ ន ខោ អហំ អាវុសោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



(២០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូរលើកមើលចុះ លោកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ។ ភិក្ខុនោះមិនមែនជាភិក្ខុឆ្គង តែក្លែងធ្វើជាឆ្គងនិយាយថា ខ្ញុំមែនធ្វើយ៉ាងនេះ សូម្បីលោកទាំងឡាយក៏ធ្វើយ៉ាងនេះដែរ អំពើនេះសមគួរដល់ខ្ញុំផង អំពើនេះសមគួរដល់លោកទាំងឡាយផង ។ សង្ឃក៏ឲ្យអមូឡ្ហវិន័យដល់ភិក្ខុនោះ ។ ការឲ្យអមូឡ្ហវិន័យ (យ៉ាងនេះ) ឈ្មោះថាមិនប្រកបដោយធម៌ ។ ការឲ្យអមូឡ្ហវិន័យ ដែលមិនប្រកបដោយធម៌មាន ៣ យ៉ាងប៉ុណ្ណេះឯង ។

(២១) ការឲ្យអមូឡ្ហវិន័យ ដែលប្រកបដោយធម៌មាន ៣ យ៉ាង (នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាភិក្ខុឆ្គង មានចិត្តវិបល្លាសប្រែប្រួល ។ ភិក្ខុឆ្គងនោះមានចិត្តវិបល្លាសប្រែប្រួលហើយក៏ប្រព្រឹត្តអនាចារ បានពោលនិងព្យាយាមល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុចូរលើកមើលចុះ លោកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ។ ភិក្ខុឆ្គងនោះរលឹកមិនឃើញសោះ ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាអ្នកត្រូវអាបត្តិ មាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សរាមិ ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ តស្ស សង្ឃោ អមូឡ្ហវិនយំ ទេតិ ។ ធម្មិកំ អមូឡ្ហវិនយស្ស ទានំ ។

(៨២) ឥធ បន ភិក្ខវេ ភិក្ខុ ឧម្មត្តកោ ហោតិ ចិត្តវិបរិយាសកតោ ។ តេន ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ហោតិ ភាសិតបរិក្កន្តំ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា សរាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ អស្សរមានោវ ឯវំ វទេតិ សរាមិ ខោ អហំ អាវុសោ យថាសុបិនន្តេនាតិ ។ តស្ស សង្ឃោ អមូឡ្ហវិនយំ ទេតិ ។ ធម្មិកំ អមូឡ្ហវិនយស្ស ទានំ ។

(៨៣) ឥធ បន ភិក្ខវេ ភិក្ខុ ឧម្មត្តកោ ហោតិ ចិត្តវិបរិយាសកតោ ។ តេន ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ហោតិ ភាសិតបរិក្កន្តំ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា សរាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ ឧម្មត្តកោ ឧម្មត្តកាលយំ ករោតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





សភាពយ៉ាងនេះ ខ្ញុំរលឹកមិនឃើញទេ ។ សង្ឃឲ្យអមូឡ្ហវិន័យដល់ភិក្ខុនោះ ។ ការឲ្យអមូឡ្ហវិន័យ ( យ៉ាងនេះ ) ឈ្មោះថាប្រកបដោយធម៌ ។

( ៦២ ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល ។ ភិក្ខុនោះឆ្កួតមានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារ បានពោលនឹងពាក្យយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ។ ភិក្ខុនោះរលឹកមិនឃើញសោះ តែនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំរលឹកឃើញដែរ តែថាដូចជាយល់សប្តិ ។ សង្ឃក៏ឲ្យអមូឡ្ហវិន័យដល់ភិក្ខុនោះ ។ ការឲ្យអមូឡ្ហវិន័យ ( យ៉ាងនេះ ) ឈ្មោះថាប្រកបដោយធម៌ ។

( ៦៣ ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល ។ ភិក្ខុឆ្កួតនោះមានចិត្តវិបល្លាសប្រែប្រួលហើយ បានប្រព្រឹត្តអនាចារ បានពោលនឹងពាក្យយាមល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ។ ភិក្ខុនោះឆ្កួតមែន ក៏ធ្វើអាការជាឆ្កួតហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អហម្បិ ឯវំ ករោមិ តុម្ហេបិ ឯវំ ករោថ មយ្ហម្បិ ឯតំ កប្បតិ តុម្ហាកម្បេតំ កប្បតីតិ ។ តស្ស សង្ឃោ អមូឡ្ហវិនយំ ទេតិ ។ ធម្មិកំ អមូឡ្ហវិនយស្ស ទានំ ។ ឥមានិ តីណិ ធម្មិកានិ អមូឡ្ហវិនយស្ស ទានានីតិ ។

(២៤) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អប្បដិញ្ញាយ ភិក្ខូនំ កម្មានិ ករោន្តិ តជ្ជនីយម្បិ និយស្សម្បិ បព្វាជនីយម្បិ បដិសារណីយម្បិ ឧក្ខេបនីយម្បិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អប្បដិញ្ញាយ ភិក្ខូនំ កម្មានិ ករិស្សន្តិ តជ្ជនីយម្បិ និយស្សម្បិ បព្វាជនីយម្បិ បដិសារណីយម្បិ ឧក្ខេបនីយម្បីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ។បេ។ សច្ចំ ភគវាតិ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



និយាយថា ខ្ញុំមែនធ្វើយ៉ាងនេះ សូម្បីលោកទាំងឡាយក៏ធ្វើយ៉ាងនេះដែរ អំពើនេះសមគួរដល់ខ្ញុំផង អំពើនេះសមគួរដល់លោកទាំងឡាយផង ។ សង្ឃឲ្យអមូឡ្ហវិន័យដល់ភិក្ខុនោះ ។ ការឲ្យអមូឡ្ហវិន័យ (យ៉ាងនេះ) ឈ្មោះថាប្រកបដោយធម៌ ។ ការឲ្យអមូឡ្ហវិន័យដែលប្រកបដោយធម៌ មាន ៣ យ៉ាងប៉ុណ្ណេះឯង ។

(២៤) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើកម្មទាំងឡាយ គឺតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយដោយមិនតាមពាក្យប្តេជ្ញា ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងធ្វើកម្មទាំងឡាយ គឺតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយដោយមិនតាមពាក្យប្តេជ្ញាសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ដំណើរនោះពិតមែនឬ ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។បេ។ លុះទ្រង់តិះដៀលហើយទ្រង់ធ្វើធម្មីកថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ភិក្ខុ អាបន្នោសិ ន ភិក្ខវេ អប្បដិញ្ញាយ ភិក្ខូនំ កម្មំ កាតព្វំ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា យោ ករេយ្យ អាបត្តិ ទុក្កដស្ស ។

(២៨) ឯវំ ខោ ភិក្ខវេ អធម្មិកំ ហោតិ បដិញ្ញាតករណំ ឯវំ ធម្មិកំ ។ កថញ្ច ភិក្ខវេ អធម្មិកំ ហោតិ បដិញ្ញាតករណំ ។ ភិក្ខុ បារាជិកំ អជ្ឈាបន្នោ ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា បារាជិកំ អាយស្មា អជ្ឈាបន្នោតិ ។ សោ ឯវំ វទេតិ ន ខោ អហំ អាវុសោ បារាជិកំ អជ្ឈាបន្នោ សង្ឃាទិសេសំ អជ្ឈាបន្នោតិ ។ តំ សង្ឃោ សង្ឃាទិសេសេន ការេតិ ។ អធម្មិកំ បដិញ្ញាតករណំ ។ ភិក្ខុ បារាជិកំ អជ្ឈាបន្នោ ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា បារាជិកំ អាយស្មា អជ្ឈាបន្នោតិ ។ សោ ឯវំ វទេតិ ន ខោ អហំ អាវុសោ បារាជិកំ អជ្ឈាបន្នោ ថុល្លច្ចយំ អជ្ឈាបន្នោតិ ។ តំ សង្ឃោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើតជ្ជនីយកម្ម និយស្សកម្ម បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយកម្ម ដល់ភិក្ខុទាំងឡាយដោយមិនតាមពាក្យច្រើនទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ។

(២៥) ម្នាលភិក្ខុទាំងឡាយ ការធ្វើតាមពាក្យច្រើនមិនប្រកបដោយធម៌យ៉ាងនេះ ការធ្វើតាមពាក្យច្រើនប្រកបដោយធម៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯការធ្វើតាមពាក្យច្រើន ដែលមិនប្រកបដោយធម៌ នោះដូចម្តេច ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកមានអាយុត្រូវអាបត្តិបារាជិកហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិសង្ឃាទិសេសទេតើ ។ សង្ឃក៏ឲ្យភិក្ខុនោះធ្វើ (វុដ្ឋានវិធី) ដោយអាបត្តិសង្ឃាទិសេស ។ ការធ្វើតាមពាក្យច្រើន (យ៉ាងនេះ) ឈ្មោះថាមិនប្រកបដោយធម៌ ។ ភិក្ខុត្រូវអាបត្តិបារាជិក ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុត្រូវអាបត្តិបារាជិកហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិថុល្លច្ច័យទេតើ ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី)

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ថុល្លច្ចយេន ការេ ។ អធម្មិកំ បដិញ្ញាតករណំ ។
ភិក្ខុ បារាជិកំ អជ្ឈាបន្នោ ហោតិ ។ តមេនំ ចោទេតិ
សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា បារាជិកំ
អាយស្មា អជ្ឈាបន្នោតិ ។ សោ ឯវំ វទេតិ ន ខោ
អហំ អាវុសោ បារាជិកំ អជ្ឈាបន្នោ បាចិត្តិយំ អជ្ឈា-
បន្នោតិ ។ តំ សង្ឃោ បាចិត្តិយេន ការេតិ ។ អធម្មិកំ
បដិញ្ញាតករណំ ។ ភិក្ខុ បារាជិកំ អជ្ឈាបន្នោ
ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា
វា ឯកបុគ្គលោ វា បារាជិកំ អាយស្មា អជ្ឈាបន្នោ-
តិ ។ សោ ឯវំ វទេតិ ន ខោ អហំ អាវុសោ បារា-
ជិកំ អជ្ឈាបន្នោ បាដិទេសនីយំ អជ្ឈាបន្នោតិ ។
តំ សង្ឃោ បាដិទេសនីយេន ការេតិ ។ អធម្មិកំ
បដិញ្ញាតករណំ ។ ភិក្ខុ បារាជិកំ អជ្ឈាបន្នោ ហោតិ ។
តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គ-
លោ វា បារាជិកំ អាយស្មា អជ្ឈាបន្នោតិ ។ សោ
ឯវំ វទេតិ ន ខោ អហំ អាវុសោ បារាជិកំ អជ្ឈាបន្នោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដោយអាបត្តិថុល្លច្ច័យ ។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុត្រូវអាបត្តិបារាជិកហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនបានត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិបាចិត្តិយៈទេតើ ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិបាចិត្តិយៈ ។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុត្រូវអាបត្តិបារាជិកហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិបាដិទេសនីយៈទេតើ ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិបាដិទេសនីយៈ ។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុត្រូវអាបត្តិបារាជិកហើយ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទុក្កដំ អជ្ឈាបន្នោតិ ។ តំ សង្ឃោ ទុក្កដេន ការេតិ ។ អធម្មិកំ បដិញ្ញាតករណំ ។ កថញ្ច បារាជិកំ អជ្ឈាបន្នោ ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា បារាជិកំ អាយស្មា អជ្ឈាបន្នោតិ ។ សោ ឯវំ វទេតិ ន ខោ អហំ អាវុសោ បារាជិកំ អជ្ឈាបន្នោ ទុព្ភាសិតំ អជ្ឈាបន្នោតិ ។ តំ សង្ឃោ ទុព្ភាសិតេន ការេតិ ។ អធម្មិកំ បដិញ្ញាតករណំ ។ កថញ្ច សង្ឃាទិសេសំ អជ្ឈាបន្នោ ។ បេ ។ ថុល្លច្ចយំ ។ បេ ។ បាចិត្តិយំ ។ បេ ។ បាដិទេសនីយំ ។ បេ ។ ទុក្កដំ ។ បេ ។ ទុព្ភាសិតំ អជ្ឈាបន្នោ ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា ទុព្ភាសិតំ អាយស្មា អជ្ឈាបន្នោតិ ។ សោ ឯវំ វទេតិ ន ខោ អហំ អាវុសោ ទុព្ភាសិតំ អជ្ឈាបន្នោ បារាជិកំ អជ្ឈាបន្នោតិ ។ តំ សង្ឃោ បារាជិកេន ការេតិ ។ អធម្មិកំ បដិញ្ញាតករណំ ។ កថញ្ច ទុព្ភាសិតំ អជ្ឈាបន្នោ ហោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សមថក្ខន្ធកៈ ការធ្វើតាមពាក្យប្ដេជ្ញាមិនប្រកបដោយធម៌

ត្រូវអាបត្តិទុក្កដទេតើ ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិទុក្កដ ។ ការធ្វើតាមពាក្យប្ដេជ្ញា (យ៉ាងនេះ) ឈ្មោះថាមិនប្រកបដោយធម៌ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុត្រូវអាបត្តិបារាជិកហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិទុព្ភាសិតទេតើ ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិទុព្ភាសិត ។ ការធ្វើតាមពាក្យប្ដេជ្ញា (យ៉ាងនេះ) ឈ្មោះថាមិនប្រកបដោយធម៌ ។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេសហើយ ។ បេ ។ ថុល្លច្ច័យ ។ បេ ។ បាចិត្តិយៈ ។ បេ ។ បាដិទេសនីយៈ ។ បេ ។ ទុក្កដ ។ បេ ។ ត្រូវអាបត្តិទុព្ភាសិតហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុត្រូវអាបត្តិទុព្ភាសិតហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រូវអាបត្តិទុព្ភាសិតទេ ត្រូវអាបត្តិបារាជិកទេតើ ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ការប្ដេជ្ញាខ្លួនជាគ្រហស្ថ) ដោយអាបត្តិបារាជិក ។ ការធ្វើតាមពាក្យប្ដេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌ ។ ភិក្ខុត្រូវអាបត្តិទុព្ភាសិតហើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា ទុព្ភាសិតំ អាយស្មា អជ្ឈាបន្នោតិ ។ សោ ឯវំ វទេតិ ន ខោ អហំ អាវុសោ ទុព្ភាសិតំ អជ្ឈាបន្នោ សង្ឃាទិសេសំ ។ បេ ។ ថុល្លច្ចយំ ។ បេ ។ បាចិត្តិយំ ។ បេ ។ បាដិទេសនីយំ ។ បេ ។ ទុក្កដំ អជ្ឈាបន្នោតិ ។ តំ សង្ឃោ ទុក្កដេន ការេតិ ។ អធម្មិកំ បដិញ្ញាតករណំ ។ ឯវំ ខោ ភិក្ខវេ អធម្មិកំ ហោតិ បដិញ្ញាតករណំ ។

(២៦) កថញ្ច ភិក្ខវេ ធម្មិកំ ហោតិ បដិញ្ញាតករណំ ។ ភិក្ខុ បារាជិកំ អជ្ឈាបន្នោ ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា បារាជិកំ អាយស្មា អជ្ឈាបន្នោតិ ។ សោ ឯវំ វទេតិ អាមាវុសោ បារាជិកំ អជ្ឈាបន្នោតិ ។ តំ សង្ឃោ បារាជិកេន ការេតិ ។ ធម្មិកំ បដិញ្ញាតករណំ ។ ភិក្ខុ សង្ឃាទិសេសំ ។ បេ ។ ថុល្លច្ចយំ ។ បេ ។ បាចិត្តិយំ ។ បេ ។ បាដិទេសនីយំ ។ បេ ។ ទុក្កដំ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិទុព្ភាសិតហើយ ៗ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ខ្ញុំមិនត្រូវអាបត្តិទុព្ភាសិតទេ ត្រូវអាបត្តិសង្ឃាទិសេសទេតើ ៗ បេ ៗ ថុល្លច្ច័យ ៗ បេ ៗ បាចិត្តិយៈ ៗ បេ ៗ បាដិទេសនីយៈ ៗ បេ ៗ ត្រូវអាបត្តិទុក្កដ ៗ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិទុក្កដ ៗ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌ ៗ ម្នាលភិក្ខុទាំងឡាយ ការធ្វើតាមពាក្យប្តេជ្ញាដែលមិនប្រកបដោយធម៌យ៉ាងនេះឯង ៗ

(២៦) ម្នាលភិក្ខុទាំងឡាយ ចំណែកឯការធ្វើតាមពាក្យប្តេជ្ញាដែលប្រកបដោយធម៌ (នោះ) ដូចម្តេច ៗ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ៗ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិបារាជិកហើយ ៗ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ អើខ្ញុំត្រូវអាបត្តិបារាជិកមែន ៗ សង្ឃឲ្យភិក្ខុនោះធ្វើ (ការប្តេជ្ញាខ្លួនជាគ្រហស្ថ) ដោយអាបត្តិបារាជិក ៗ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថាប្រកបដោយធម៌ ៗ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស បេ ៗ ថុល្លច្ច័យ ៗ បេ ៗ បាចិត្តិយៈ ៗ បេ ៗ បាដិទេសនីយៈ ៗ បេ ៗ ទុក្កដ ៗ បេ ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទុព្ភាសិតំ អជ្ឈាបន្នោ ហោតិ ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា ទុព្ភាសិតំ អាយស្មា អជ្ឈាបន្នោតិ ។ សោ ឯវំ វទេតិ អាមាវុសោ ទុព្ភាសិតំ អជ្ឈាបន្នោតិ ។ តំ សង្ឃោ ទុព្ភាសិតេន ការេតិ ។ ធម្មិកំ បដិញ្ញាតករណំ ។ ឯវំ ខោ ភិក្ខវេ ធម្មិកំ ហោតិ បដិញ្ញាតករណន្តិ ។

[២៧] តេន ខោ បន សមយេន ភិក្ខូ សង្ឃមជ្ឈេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ន សក្កោន្តិ តំ អធិករណំ វូបសមេតុំ ។ តេ ភិក្ខូ[១] ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឯវរូបំ អធិករណំ យេភុយ្យសិកាយ វូបសមេតុំ ។ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ សលាកគ្គាហាបកោ សម្មន្និតព្វោ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ គហិតាគហិតញ្ច ជានេយ្យ ។ ឯវញ្ច

---

១ ឱ. ម. បោត្ថកេសុ តេ ភិក្ខូតិ បទទ្វយំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទុក្កដ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិទុក្កដហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ អើខ្ញុំត្រូវអាបត្តិទុក្កដមែន ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិទុក្កដ ។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថាប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើតាមពាក្យប្តេជ្ញា ដែលប្រកបដោយធម៌យ៉ាងនេះឯង ។

(២៧) សម័យនោះឯង ភិក្ខុទាំងឡាយបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ក្នុងកណ្តាលជំនុំសង្ឃ ពោលពាក្យចាក់ដោតគ្នាទៅវិញទៅមកដោយលំពែងគឺមាត់ ភិក្ខុទាំងឡាយមិនអាចញុំាងអធិករណ៍នោះឲ្យរម្ងាប់បាន ។ ភិក្ខុទាំងឡាយនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរម្ងាប់អធិករណ៍ មានសភាពយ៉ាងនេះដោយយេភុយ្យសិកា(១) ។ សង្ឃគប្បីសន្មតភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុដែលមិនលុះនូវឆន្ទាគតិ ១ មិនលុះនូវទោសាគតិ ១ មិនលុះនូវមោហាគតិ ១ មិនលុះនូវភយាគតិ ១ ដឹងនូវស្លាកដែលបានចាប់ហើយនិងមិនទាន់បានចាប់ ១ ឲ្យ(ធ្វើ)ជាសលាកគ្គាហាបកៈ (អ្នកចាត់ចែងឲ្យគេចាប់ស្លាក) ម្នាលភិក្ខុទាំងឡាយ ឯសលាកគ្គាហាបកៈនោះ

---

១ គឺកំណត់យកពួកខាងធម្មវាទីមានចំនួនច្រើនជាង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សលាកគ្គាហាបកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សលាកគ្គាហាបកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សលាកគ្គាហាបកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ សលាកគ្គាហាបកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(២៨) ទសយិមេ ភិក្ខវេ អធម្មិកា សលាកគ្គាហា ទស ធម្មិកា ។ កតមេ ទស អធម្មិកា សលាកគ្គាហា ។ ឱរមត្តកញ្ច អធិករណំ ហោតិ ន ច គតិគតំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



សង្ឃត្រូវសន្មតយ៉ាងនេះ ៗ មុនដំបូងត្រូវសង្ឃសូមភិក្ខុ (នោះ) លុះសូមរួចហើយ ត្រូវភិក្ខុដែលឈ្លាសប្រតិពលផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើការសន្មតិមានកាលគួរដល់សង្ឃហើយ សូមសង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាសលាកគ្គាហាបកៈចុះ ៗ នេះជាញត្តិ ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាសលាកគ្គាហាបកៈ ៗ ការសន្មតិភិក្ខុឈ្មោះនេះឲ្យជាសលាកគ្គាហាបកៈ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង ៗ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាសលាកគ្គាហាបកៈហើយ ការសន្មតិនេះគួរដល់សង្ឃ ព្រោះហេតុនោះទើបសង្ឃស្ងៀម ៗ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ៗ

(២៨) ម្នាលភិក្ខុទាំងឡាយ ការឲ្យចាប់ស្លាកនេះដែលមិនប្រកបដោយធម៌មាន ១០ យ៉ាង ដែលប្រកបដោយធម៌មាន១០ យ៉ាង ៗ ការឲ្យចាប់ស្លាកដែលមិនប្រកបដោយធម៌ ១០ យ៉ាង (នោះ) តើដូចម្តេច ៗ គឺមានអធិករណ៍បន្តិចបន្តួច ១ អធិករណ៍មិនទៅតាមគតិ ១ អធិករណ៍

១ អដ្ឋកថា ថា អធិករណ៍នោះមិនទាន់រាលដាលដល់អាវាសទី៣ ឬមិនទាន់បានវិនិច្ឆ័យពីរបីលើកនៅឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហោតិ ន ច សរិតសារិតំ ហោតិ ជានាតិ អធម្មវាទី ពហុតរាតិ អប្បេវនាម អធម្មវាទី ពហុតរា អស្សូតិ ជានាតិ សង្ឃោ ភិជ្ជិស្សតីតិ អប្បេវនាម សង្ឃោ ភិជ្ជេយ្យាតិ អធម្មេន គណ្ហន្តិ វគ្គា គណ្ហន្តិ ន ច យថាទិដ្ឋិយា គណ្ហន្តិ ឥមេ ទស អធម្មិកា សលាកគ្គាហា ។

[២៩] កតមេ ទស ធម្មិកា សលាកគ្គាហា ។ ន ច ឱរមត្តកំ អធិករណំ ហោតិ គតិគតញ្ច ហោតិ សរិតសារិតញ្ច ហោតិ ជានាតិ ធម្មវាទី ពហុតរាតិ អប្បេវនាម ធម្មវាទី ពហុតរា អស្សូតិ ជានាតិ សង្ឃោ ន ភិជ្ជិស្សតីតិ អប្បេវនាម សង្ឃោ ន ភិជ្ជេយ្យាតិ ធម្មេន គណ្ហន្តិ សមគ្គា គណ្ហន្តិ យថាទិដ្ឋិយា ច គណ្ហន្តិ ឥមេ ទស ធម្មិកា សលាកគ្គាហាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដែលភិក្ខុមិនទាន់បានលើកឃើញខ្លួនឯងនឹងលើកអ្នកដទៃ ១ ភិក្ខុដឹងថា ពួកអធម្មវាទីមានចំនួនច្រើនជាង ១ ភិក្ខុគិតថា ធ្វើម្ដេចហ្ន៎ទើបពួកអធម្មវាទីមានចំនួនច្រើនជាង ១ ភិក្ខុដឹងថា សង្ឃនឹងបែកគ្នា ១ ភិក្ខុគិតថា ធ្វើម្ដេចហ្ន៎ទើបសង្ឃបែកគ្នា ១ ភិក្ខុទាំងឡាយចាប់ស្លាកដោយមិនតាមធម៌(១) ១ ភិក្ខុទាំងឡាយចាប់ស្លាកជាពួកៗ ១ ភិក្ខុទាំងឡាយមិនចាប់ស្លាកតាមសមគួរដល់ទិដ្ឋិ(២) ១ ការឲ្យចាប់ស្លាកដែលមិនប្រកបដោយធម៌មាន ១០ យ៉ាងប៉ុណ្ណេះឯង ។

( ៦៩ ) ការឲ្យចាប់ស្លាកដែលប្រកបដោយធម៌មាន ១០ យ៉ាង (នោះ) តើដូចម្ដេច ។ គឺមិនមានអធិករណ៍បន្តិចបន្តួច ១ អធិករណ៍ប្រព្រឹត្តទៅតាមគតិ ១ អធិករណ៍ដែលភិក្ខុបានលើកឃើញខ្លួនឯងឬបានលើកអ្នកដទៃ ១ ភិក្ខុដឹងថា ពួកធម្មវាទីមានចំនួនច្រើនជាង ១ ភិក្ខុគិតថា ធ្វើម្ដេចហ្ន៎ទើបពួកធម្មវាទីមានចំនួនច្រើនជាង ១ ភិក្ខុដឹងថា សង្ឃនឹងមិនបែកគ្នា ១ ភិក្ខុគិតថា ធ្វើម្ដេចហ្ន៎ទើបសង្ឃមិនបែកគ្នា ១ ភិក្ខុទាំងឡាយចាប់ស្លាកប្រកបដោយធម៌ ១ ព្រមព្រៀងគ្នាចាប់ស្លាក ១ ចាប់ស្លាកដោយសមគួរដល់ទិដ្ឋិ ១ ការឲ្យចាប់ស្លាកដែលប្រកបដោយធម៌មាន ១០ យ៉ាងប៉ុណ្ណេះឯង ។

---

១ ពួកអធម្មវាទីពោលថា ពួកយើងមានចំនួនច្រើនជាង ហើយចាប់ស្លាកពីរ ៗ ម្នាក់ ។

២ ពួកធម្មវាទីពោលថា ពួកយើងជាបក្ខពួកមានកំឡាំងហើយទៅចាប់ស្លាករបស់អធម្មវាទីវិញ ។

[៣០] តេន ខោ បន សមយេន ឧបវាឡោ(១) ភិក្ខុ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ អវជានិត្វា បដិជានាតិ បដិជានិត្វា អវជានាតិ អញ្ញេន អញ្ញំ បដិចរតិ សម្បជានមុសា ភាសតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឧបវាឡោ ភិក្ខុ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ អវជានិត្វា បដិជានិស្សតិ បដិជានិត្វា អវជានិស្សតិ អញ្ញេន អញ្ញំ បដិចរិស្សតិ សម្បជានមុសា ភាសិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ ឧបវាឡស្ស ភិក្ខុនោ តស្សបាបិយសិកាកម្មំ(២) ករោតុ ។ ឯវញ្ច បន ភិក្ខវេ កាតព្វំ ។ បឋមំ ឧបវាឡោ ភិក្ខុ ចោទេតព្វោ ចោទេត្វា សារេតព្វោ សារេត្វា អាបត្តិ

---

១ ឧវាឡោតិបិ ឧបវាឡោតិបិ បាឋោ ទិស្សតិ ។ ២ ម· ពោត្ថកេសុ តស្សបាបិយ្យសិកាកម្មន្តិ បាឋោ អាគតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣០) សម័យនោះឯង ឧបវាឡភិក្ខុកាលត្រូវគេសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏គេចកែសំដីហើយខ្ចលដឹង ខ្ចលដឹងហើយបែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃដោយហេតុដទៃវិញ ពោលសម្បជានមុសាវាទ គឺពោលពាក្យកុហកដោយដឹងខ្លួន ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបវាឡភិក្ខុកាលត្រូវគេសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ មិនសមបើនឹងគេចកែសំដីហើយបែរជាខ្ចលដឹងខ្ចលដឹងហើយបែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃដោយហេតុដទៃពោលសម្បជានមុសាវាទសោះ ។ គ្រានោះ ភិក្ខុទាំងឡាយនោះក្រាបបង្គំទូលរឿងនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ដំណើរនោះ ពិតមែនឬ ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។បេ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះសង្ឃចូរធ្វើ តស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុចុះ ។ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្មនោះ សង្ឃគប្បីធ្វើយ៉ាងនេះ ។ មុនដំបូង សង្ឃគប្បីចោទឧបវាឡភិក្ខុ លុះចោទហើយ គប្បីរំលឹក លុះរំលឹកហើយ គប្បីលើក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អារោបេតព្វោ អាបត្តឹ អារោបេត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧបវាឡោ ភិក្ខុ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ អវជានិត្វា បដិជានាតិ បដិជានិត្វា អវជានាតិ អញ្ញេន អញ្ញំ បដិចរតិ សម្បជានមុសា ភាសតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧបវាឡស្ស ភិក្ខុនោ តស្សបាបិយសិកាកម្មំ ករេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧបវាឡោ ភិក្ខុ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ អវជានិត្វា បដិជានាតិ បដិជានិត្វា អវជានាតិ អញ្ញេន អញ្ញំ បដិចរតិ សម្បជានមុសា ភាសតិ ។ សង្ឃោ ឧបវាឡស្ស(១) ភិក្ខុនោ តស្សបាបិយសិកាកម្មំ ករោតិ ។ យស្សាយស្មតោ ខមតិ ឧបវាឡស្ស(២) ភិក្ខុនោ តស្សបាបិយសិកាកម្មស្ស ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

១ - ២ ឧបវាឡហស្សាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឈ្លាសប្រតិពលគប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបវាឡភិក្ខុនេះកាលត្រូវគេសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ក៏គេចកែសំដីហើយបែរជាទទួលដឹង ទទួលដឹងហើយបែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលសម្បជានមុសាវាទ ។ បើការធ្វើតស្សបាបិយសិកាកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីធ្វើតស្សបាបិយសិកាកម្មដល់ឧបវាឡភិក្ខុ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបវាឡភិក្ខុនេះកាលត្រូវគេសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏គេចកែសំដីហើយបែរជាទទួលដឹង ទទួលដឹងហើយបែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលសម្បជានមុសាវាទ ។ សង្ឃធ្វើតស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុ ។ ការធ្វើតស្សបាបិយសិកាកម្មដល់ឧបវាឡភិក្ខុ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ កតំ សង្ឃេន ឧបវាឡស្ស ភិក្ខុនោ តស្សបាបិយសិកាកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៣១) បញ្ចិមានិ ភិក្ខវេ ធម្មិកានិ តស្សបាបិយសិកាកម្មស្ស ករណានិ អសុចិ ច ហោតិ អលជ្ជី ច សានុវាទោ ច តស្ស សង្ឃោ តស្សបាបិយសិកាកម្មំ ករោតិ ធម្មេន សមគ្គេន[១] ឥមានិ ខោ ភិក្ខវេ បញ្ច ធម្មិកានិ តស្សបាបិយសិកាកម្មស្ស ករណានិ ។

(៣២) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ តស្សបាបិយសិកាកម្មំ អធម្មកម្មញ្ចេវ[២] ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសម្មុខា កតំ ហោតិ អប្បដិបុច្ឆា កតំ ហោតិ អប្បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តស្សបាបិយសិកាកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច

១ ម. សមគ្គោ ។ ២ ម. ពោត្ថកេសុ ឯវសទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខ្ញុំសូមប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំសូមប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បេ ។ សង្ឃបានធ្វើតស្សបាបិយសិកាកម្មដល់ឧវាឡភិក្ខុហើយ (ការធ្វើតស្សបាបិយសិកាកម្មនេះ) សមគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។

[៣១] ម្នាលភិក្ខុទាំងឡាយ ការធ្វើតស្សបាបិយសិកាកម្មនេះ ប្រកបដោយធម៌មាន ៥ យ៉ាង គឺ ភិក្ខុនោះ (មានកាយវាចា) មិនស្អាត ១ ជាអ្នកមិនមានសេចក្តីអៀនខ្មាស ១ ជាអ្នកប្រកបដោយពាក្យតិះដៀល ១ សង្ឃធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុនោះ ១ សង្ឃធ្វើដោយសេចក្តីព្រមព្រៀងគ្នាត្រូវតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយ ការធ្វើតស្សបាបិយសិកាកម្ម ដែលប្រកបដោយធម៌មាន ៥ យ៉ាង ប៉ុណ្ណេះឯង ។

[៣២] ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ គឺកម្មដែលសង្ឃធ្វើកំបាំងមុខ ១ ធ្វើដោយមិនបានសាកសួរជាមុន ១ ធ្វើដោយមិនតាមប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គទាំង ៣ នេះឯង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



។បេ។ អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តស្សបាបិយសិកាកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អាបត្តិ អនារោបេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តស្សបាបិយសិកាកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៣៣) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ តស្សបាបិយសិកាកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច សម្មុខា កតំ ហោតិ បដិបុច្ឆា កតំ ហោតិ បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តស្សបាបិយសិកាកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។បេ។ អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តស្សបាបិយសិកាកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តិ អារោបេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



។បេ។ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀតគឺកម្មដែលសង្ឃមិនលើកអាបត្តិឡើងហើយ ស្រាប់តែធ្វើ ១ ធ្វើមិនត្រូវតាមធម៌ ១ ធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គទាំង ៣ នេះឯង ។

(៣៣) ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ គឺកម្មដែលសង្ឃធ្វើក្នុងទីចំពោះមុខ ១ ធ្វើដោយបានសាកសួរជាមុន ១ ធ្វើតាមប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មរម្ងាប់ដោយល្អផង ប្រកបដោយអង្គទាំង ៣ នេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលសង្ឃលើកអាបត្តិឡើងហើយទើបធ្វើ ១ ធ្វើត្រូវតាមធម៌ ១ ធ្វើដោយសេចក្តីព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តីហង្គេហិ សមន្នាគតំ តស្សបាបិយសិកាកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៣៦) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តស្សបាបិយសិកាកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តស្សបាបិយសិកាកម្មំ ករេយ្យ ។

(៣៧) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តស្សបាបិយសិកាកម្មំ ករេយ្យ អធិសីលេ សីលវិបន្នោ ហោតិ អជ្ឈាចារេ អាចារវិបន្នោ ហោតិ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ឥមេហិ ខោ ភិក្ខវេ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តស្សបាបិយសិកាកម្ម ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មរម្ងាប់ដោយល្អផង ប្រកបដោយអង្គទាំង ៣ នេះឯង ។

(៣៤) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា (ទឹងធ្វើ) ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ បាន គឺភិក្ខុអ្នកធ្វើនូវសេចក្តីបង្កហេតុ ធ្វើជម្លោះ ធ្វើសេចក្តីទាស់ទែង បង្កើតវិវាទកថា ធ្វើអធិករណ៍ក្នុងសង្ឃ ១ ភិក្ខុល្ងង់មិនឈ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ ១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គទាំង ៣ នេះឯង ។

(៣៥) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្ស-បាបិយសិកាកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុមានសីលវិបត្តិក្នុងអធិសីល ១ មានអាចារវិបត្តិក្នុងអជ្ឈាចារ ១ មានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ ១ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(៣៦) អបរេហិបិ ភិក្ខវេ ។បេ។ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តស្សបាបិយសិកាកម្មំ ករេយ្យ ។

(៣៧) តិណ្ណំ ភិក្ខវេ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តស្សបាបិយសិកាកម្មំ ករេយ្យ ឯកោ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ឯកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ ឯកោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តស្សបាបិយសិកាកម្មំ ករេយ្យ ។

(៣៨) អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តស្សបាបិយសិកាកម្មំ ករេយ្យ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកៈ ការធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុ ៣ ពួក

[៣៦] ម្នាលភិក្ខុទាំងឡាយ ។បេ។ អង្គ ៣ ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ ១ ពោលតិះដៀលព្រះធម៌ ១ ពោលតិះដៀលព្រះសង្ឃ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្ស-បាបិយសិកាកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គទាំង ៣ នេះឯង ។

[៣៧] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្ស-បាបិយសិកាកម្ម ដល់ភិក្ខុ ៣ ពួក គឺភិក្ខុអ្នកធ្វើការបង្កហេតុ ធ្វើជម្លោះ ធ្វើសេចក្តីទាស់ទែង បង្កតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃពួក ១ ភិក្ខុល្ងង់មិនឈ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិពួក ១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុទាំង ៣ ពួកនេះឯង ។

[៣៨] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុមានសីលវិបត្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯកោ អធិសីលេ សីលវិបន្នោ ហោតិ ឯកោ អជ្ឈាចារេ អាចារវិបន្នោ ហោតិ ឯកោ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ឥមេសំ ខោ ភិក្ខវេ ។ បេ ។

(៣៩) អបរេសម្បិ ភិក្ខវេ ។ បេ ។ ឯកោ ពុទ្ធស្ស អវណ្ណំ ភាសតិ ឯកោ ធម្មស្ស អវណ្ណំ ភាសតិ ឯកោ សង្ឃស្ស អវណ្ណំ ភាសតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តស្សបាបិយសិកាកម្មំ ករេយ្យ ។

(៤០) តេន[1] តស្សបាបិយសិកាកម្មកតេន ភិក្ខវេ[2] ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា ។ បេ ។ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វន្តិ ។ អថខោ សង្ឃោ ឧបវណ្ណស្ស ភិក្ខុនោ តស្សបាបិយសិកាកម្មំ អកាសិ ។

---

១ អយំ សទ្ទោ ឱ. បោត្ថកេ ន ទិស្សតិ ។ ២ ទ. បោត្ថកេ ភិក្ខវេត្យាលបនំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ក្នុងអធិសីលពួក ១ ភិក្ខុមានអាចារវិបត្តិក្នុងអជ្ឈាចារពួក ១ ភិក្ខុមានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិពួក ១ ។បេ។

(៣៩) ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធពួក ១ ពោលតិះដៀលព្រះធម៌ពួក ១ ពោលតិះដៀលព្រះសង្ឃពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុទាំង ៣ ពួកនេះឯង ។

(៤០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើតស្សបាបិយសិកាកម្មហើយនោះ ត្រូវប្រព្រឹត្តិវត្តដោយប្រពៃ ។ ឯការប្រព្រឹត្តិវត្ត ដោយប្រពៃ ក្នុងតស្សបាបិយសិកាកម្មនោះដូច្នេះ គឺ ភិក្ខុនោះមិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើ មិនត្រូវត្រេកអរក្នុងការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ទុកជាបានទទួលការសន្មតិហើយ ក៏មិនត្រូវប្រដៅភិក្ខុនី ។ បេ ។ មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុដទៃគ្នា ។ គ្រានោះ សង្ឃបានធ្វើតស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកេ តិណវត្ថារកេន វូបសមោ

(៤១) តេន ខោ បន សមយេន ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា វិហរន្តិ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ហោតិ ភាសិតបរិក្កន្តំ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អម្ហាកំ ខោ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម(១) សិយាបិ តំ អធិករណំ កក្ខឡតាយ វាឡតាយ(២) ភេទាយ សំវត្តេយ្យ កថំ នុ ខោ អម្ហេហិ បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

(៤២) ឥធ បន ភិក្ខវេ ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា វិហរន្តិ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ហោតិ ភាសិតបរិក្កន្តំ ។ តត្រ ចេ ភិក្ខូនំ ភិក្ខូនំ ឯវំ ហោតិ អម្ហាកំ ខោ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណ-

---

១ ម. ការេយ្យាម ។ ២ ម. កក្ខឡត្តាយ វាឡត្តាយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សមថក្ខន្ធកៈ ការរំងាប់ (អធិករណ៍) ដោយតិណវត្ថារកសមថៈ

(៤១) សម័យនោះឯង ពួកភិក្ខុនាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោលនូវពាក្យយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើនៗ គ្រានោះ ភិក្ខុទាំងនោះមានសេចក្តីបរិវិតក្ក យ៉ាងនេះថា ពួកយើងនាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោលនូវពាក្យយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើពួកយើងនឹងញុំាងគ្នានឹងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ) តើពួកយើងគប្បីប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។

(៤២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះនាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នាហើយបានប្រព្រឹត្តអនាចារ បានពោលនូវពាក្យយាមល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើនៗ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុក្នុងទីនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងនាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នាហើយបានប្រព្រឹត្តអនាចារ បានពោលនូវពាក្យយាម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យាតិ ។ អនុជានាមិ ភិក្ខវេ ឯវរូបំ អធិករណំ តិណវត្ថារកេន វូបសមេតុំ ។

(៤៣) ឯវញ្ច បន ភិក្ខវេ វូបសមេតព្វំ ។ សព្វេហេវ ឯកជ្ឈំ សន្និបតិតព្វំ សន្និបតិត្វា ព្យត្តេន ភិក្ខុនា បដិ-ពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ អធិករណំ តិណវត្ថារកេន វូបសមេយ្យ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លើស ខុវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើពួកយើង ញុំាងគ្នានឹងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះក៏បានដែរ តែអធិករណ៍ នោះគប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃរម្ងាប់អធិករណ៍ មានសភាពយ៉ាងនេះ ដោយតិណវត្ថារកសមថៈ[១] ។

(៤៣) ម្នាលភិក្ខុទាំងឡាយ អធិករណ៍នោះ សង្ឃត្រូវរម្ងាប់ យ៉ាងនេះ ។ ភិក្ខុទាំងអស់គប្បីប្រជុំក្នុងទីជាមួយគ្នា លុះប្រជុំគ្នាហើយ ភិក្ខុដែលឈ្លាសប្រតិពល ត្រូវផ្សៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ យើងខ្ញុំទាំងឡាយនាំគ្នាបង្កហេតុឈ្លោះទាស់ទែងគ្នា ហើយ បានប្រព្រឹត្តអនាចារ បានពោលនូវពាក្យលើសខុវកិច្ចមិនមែនជារបស់ សមណៈជាច្រើន ប្រសិនបើយើងខ្ញុំទាំងឡាយនឹងញុំាងគ្នានឹងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងនេះក៏បានដែរ តែអធិករណ៍នោះនឹងគប្បីប្រព្រឹត្តទៅដើម្បី សេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ(សង្ឃ) ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់អធិករណ៍នេះ ដោយតិណវត្ថារកសមថៈ

---

១ ប្រែថា ធម៌ជាគ្រឿងរម្ងាប់ដូចគ្របទុកដោយស្មៅ បានដល់កិរិយាដែលឲ្យមានសេចក្តីស្រុះស្រួលគ្នាទាំងពីរខាង គឺមិនជំរុះរកសេចក្តីដើម (ផ្សះផ្សា) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឋបេត្វា ថុល្លវជ្ជំ(១) ឋបេត្វា គិហិប្បដិសំយុត្តន្តិ ។ ឯកតោបក្ខិកានំ ភិក្ខូនំ ព្យត្តេន ភិក្ខុនា បដិពលេន សកោ បក្ខោ ញាបេតព្វោ សុណន្តុ មេ អាយស្មន្តា អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ ។ យទាយស្មន្តានំ បត្តកល្លំ អហំ យា ចេវ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ អាយស្មន្តានញ្ចេវ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេយ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តន្តិ ។

(៤៤) អថាបរេសំ ឯកតោបក្ខិកានំ ភិក្ខូនំ ព្យត្តេន ភិក្ខុនា បដិពលេន សកោ បក្ខោ ញាបេតព្វោ សុណន្តុ មេ អាយស្មន្តា អម្ហាកំ ភណ្ឌនជាតានំ

១ ម. ថូលវជ្ជំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វៀរលែងតែអាបត្តិមានទោសធ្ងន់(១) វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត(២) ។ បណ្តាភិក្ខុទាំងឡាយដែលជាបក្សពួកជាមួយគ្នា ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវផ្តៀងបក្សពួករបស់ខ្លួនថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ ពួកយើងនាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ ជាំងពោលទំនងពាក្យយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើយើងទាំងឡាយនឹងនាំគ្នាធ្វើដោយអាបត្តិទាំងនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាចដើម្បីចំណាយ (សង្ឃ) ។ បើគម្មមានកាលគួរ ដល់លោកមានអាយុទាំងឡាយហើយ ខ្ញុំសូមសំដែងអាបត្តិ របស់លោកមានអាយុទាំងឡាយផងអាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈដើម្បីប្រយោជន៍ ដល់លោកដ៏មានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ ទឹងវៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត ។

(៤៤) បណ្តាភិក្ខុទាំងឡាយដែលជាពួកជាមួយគ្នាដទៃទៀត ភិក្ខុដែលឈ្លាសប្រតិពលត្រូវផ្តៀងពួករបស់ខ្លួនក្នុងវេលានោះថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ យើងទាំងឡាយនាំគ្នាបង្កហេតុ ឈ្លោះ

---

១ អដ្ឋកថា ថា បានដល់អាបត្តិបារាជិក ១ សង្ឃាទិសេស ១ ។ ២ បានដល់អាបត្តិដែលភិក្ខុត្រូវដោយដើរប្រទេចផ្លូវពួកគ្រហស្ថ ដោយពាក្យថោកទាបនឹងការទទួលពាក្យប្តេជ្ញា ប្រកបដោយធម៌ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ។ យេនាយស្មន្តានំ បត្តកល្លំ អហំ យា ចេវ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ អាយស្មន្តានញ្ចេវ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេយ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តន្តិ។

(៤៩) ឯកតោបក្ខិកានំ ភិក្ខូនំ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ។ យទិ សង្ឃស្ស បត្តកល្លំ អហំ យា ចេវ ឥមេសំ អាយស្មន្តានំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោលនូវពាក្យយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើពួកយើងនឹងញ៉ាំងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ) ។ បើកម្មមានកាលដ៏សមគួរដល់លោកដ៏មានអាយុទាំងឡាយហើយ ខ្ញុំសូមសំដែងអាបត្តិរបស់លោកដ៏មានអាយុទាំងឡាយផង អាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្ដាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ដល់លោកដ៏មានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិមានទោសធ្ងន់ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត ។

(៤៥) បណ្ដាភិក្ខុទាំងឡាយដែលជាបក្សពួកជាមួយគ្នា ភិក្ខុដែលឈ្លាសប្រតិពល ត្រូវផ្ដៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ យើងខ្ញុំទាំងឡាយនាំគ្នាបង្កហេតុឈ្លោះ ទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោលនូវពាក្យយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើពួកយើងនឹងញ៉ាំងគ្នានឹងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ) ។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំសូមសំដែងអាបត្តិ របស់លោកដ៏មានអាយុ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





អាបត្តិ យា ច អត្តនោ អាបត្តិ ឥមេសញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថា-រកេន ទេសេយ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិ-សំយុត្តំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវា-ទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡ-ត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ ។ អហំ យា ចេវ ឥមេសំ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ ឥមេសញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេមិ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ។ យស្សា-យស្មតោ ខមតិ អម្ហាកំ ឥមាសំ អាបត្តីនំ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសនា ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ សោ តុណ្ហស្ស យស្ស នក្ខមតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទាំងនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ដល់លោកដ៏មានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពួកយើងនាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នាហើយបានប្រព្រឹត្តអនាចារ បានពោលនឹងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើយើងទាំងឡាយនឹងនាំគ្នាធ្វើ ដោយអាបត្តិទាំងឡាយនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ) ។ ខ្ញុំសូមសំដែងអាបត្តិ របស់លោកមានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ដល់លោកដ៏មានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត ។ ការសំដែងអាបត្តិទាំងឡាយនេះ របស់ពួកយើង ក្នុងកណ្តាលជំនុំសង្ឃដោយតិណវត្ថារកសមថៈ វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សោ ភាសេយ្យ ។ ទេសិតា អម្ហាកំ ឥមា អាបត្តិយោ សង្ឃមជ្ឈេ តិណវត្ថារកេន ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៤៦] អថាបរេសំ ឯកតោបក្ខិកានំ ភិក្ខូនំ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ ។ យទិ សង្ឃស្ស បត្តកល្លំ អហំ យា ចេវ ឥមេសំ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ ឥមេសញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេយ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ អាបត្តិទាំងឡាយនេះ យើងទាំងឡាយបានសំដែងហើយ ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត ការសំដែងនេះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(៩៦) បណ្តាភិក្ខុដែលជាពួកជាមួយគ្នាដទៃទៀត ភិក្ខុដែលឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃក្នុងវេលានោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ យើងទាំងឡាយនាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា បានប្រព្រឹត្តអនាចារ បានពោលទងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើយើងទាំងឡាយញ៉ាំងគ្នានិងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះ អធិករណ៍នោះគប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ) ។ បើកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសំដែងអាបត្តិ របស់លោកដ៏មានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ដល់លោកដ៏មានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកេ តិណវត្ថារកេន ទេសនា

ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ ។ អហំ យា ចេវ ឥមេសំ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ ឥមេសញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេមិ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិបដិសំយុត្តំ ។ យស្សាយស្មតោ ខមតិ អម្ហាកំ ឥមាសំ អាបត្តីនំ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសនា ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិបដិសំយុត្តំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទេសិតា អម្ហាកំ ឥមា អាបត្តិយោ សង្ឃមជ្ឈេ តិណវត្ថារកេន ឋបេត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យើងខ្ញុំទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារបានពោលនូវពាក្យយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើនៗប្រសិនបើយើងទាំងឡាយញុំាងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងនេះ អធិករណ៍នោះគប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ) ៗ ខ្ញុំសូមសំដែងអាបត្តិរបស់លោកដ៏មានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្តាលជុំនុំសង្ឃ ដោយតិណវត្ថារក-សមថៈ ដើម្បីប្រយោជន៍ដល់លោកដ៏មានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត ៗ ការសំដែងអាបត្តិទាំងនេះ របស់យើងទាំងឡាយក្នុងកណ្តាលជុំនុំសង្ឃ ដោយតិណវត្ថារកសមថៈ វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង ៗ អាបត្តិទាំងនេះ យើងទាំងឡាយបានសំដែងហើយក្នុងកណ្តាលជុំនុំសង្ឃ ដោយតិណវត្ថារកសមថៈវៀរលែងតែអាបត្តិ ដែលមាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤៧) ឯវញ្ច បន ភិក្ខវេ តេ ភិក្ខូ តាហិ អាបត្តីហិ វុដ្ឋិតា ហោន្តិ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ឋបេត្វា ទិដ្ឋាវិកម្មំ ឋបេត្វា យេ ច តត្ថ ហោន្តីតិ ។

(៤៨) តេន ខោ បន សមយេន ភិក្ខូបិ ភិក្ខុនីហិ វិវទន្តិ ។ ភិក្ខុនិយោបិ ភិក្ខូហិ វិវទន្តិ ។ ឆន្នោបិ ភិក្ខុ ភិក្ខុនីនំ អនុបខជ្ជ ភិក្ខូហិ សទ្ធឹ វិវទតិ ភិក្ខុនីនំ បក្ខំ គាហេតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆន្នោ ភិក្ខុ ភិក្ខុនីនំ អនុបខជ្ជ ភិក្ខូហិ សទ្ធឹ វិវទិស្សតិ ភិក្ខុនីនំ បក្ខំ គាហេស្សតីតិ ។ អថខោ តេ ភិក្ខូ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត ការសំដែងអាបត្តិនោះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។

(៤៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឈ្មោះថាបានចេញចាកអាបត្តិទាំងឡាយនោះ ដោយអាការយ៉ាងនេះហើយ វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត វៀរលែងតែការធ្វើឲ្យច្បាស់នូវទិដ្ឋិ វៀរលែងតែភិក្ខុទាំងឡាយណាដែលមិនមាននៅក្នុងទីនោះ[១] ។

(៤៨) សម័យនោះឯង ភិក្ខុទាំងឡាយទាស់ទែងនឹងពួកភិក្ខុនី ។ ពួកភិក្ខុនីក៏ទាស់គ្នានឹងពួកភិក្ខុ ។ ចំណែកខាងឆន្នភិក្ខុក៏ចូលជ្រៀតជ្រែកទៅរកពួកភិក្ខុនី ហើយទាស់ទែងនឹងពួកភិក្ខុ ប្រកាន់ គឺចូលដៃខាងពួកភិក្ខុនី ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុមិនសមបើនឹងចូលជ្រៀតជ្រែកទៅរកពួកភិក្ខុនី ហើយមកទាស់ទែងនឹងពួកភិក្ខុ ប្រកាន់ខាងពួកភិក្ខុនីសោះ ។ លំដាប់នោះ ភិក្ខុទាំងឡាយនោះក្រាបបង្គំ

---

១ គឺមិនបានមកក្នុងទីនោះ ឬមកហើយឲ្យឆន្ទៈហើយ តែទៅអង្គុយក្នុងទីដទៃ មានបរិវេណជាដើម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ចត្តារិមានិ ភិក្ខវេ អធិករណានិ វិវាទាធិករណំ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ(១) ។

(៤៩) តត្ថ កតមំ វិវាទាធិករណំ ។ ឥធ បន(២) ភិក្ខវេ ភិក្ខូ វិវទន្តិ ធម្មោតិ វា អធម្មោតិ វា វិនយោតិ វា អវិនយោតិ វា ភាសិតំ លបិតំ តថាគតេនាតិ វា អភាសិតំ អលបិតំ តថាគតេនាតិ វា អាចិណ្ណំ តថាគតេនាតិ វា អនាចិណ្ណំ តថាគតេនាតិ វា បញ្ញត្តំ តថាគតេនាតិ វា អប្បញ្ញត្តំ តថាគតេនាតិ អាបត្តីតិ វា អនាបត្តីតិ វា លហុកា អាបត្តីតិ វា គរុកា អាបត្តីតិ វា សាវសេសា អាបត្តីតិ វា អនវសេសា អាបត្តីតិ វា ទុដ្ឋុល្លា អាបត្តីតិ វា

---

១ ឱ. កិច្ចាធិករណញ្ច ។ ២ ឱ. ម. បោត្ថកេសុ បនសទ្ទោ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដំណើរនោះ ពិតមែនឬ ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ដំណើរនោះពិតមែន ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អធិករណ៍ទាំងឡាយ ៤ នេះ គឺ វិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ ។

(៤៩) បណ្តាអធិករណ៍ ៤ យ៉ាងនោះ វិវាទាធិករណ៍ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះទាស់ទែងគ្នាថា នេះជាធម៌ ឬថា នេះមិនមែនជាធម៌ នេះជាវិន័យ ឬថា នេះមិនមែនជាវិន័យ នេះជាពាក្យដែលព្រះតថាគត ទ្រង់ត្រាស់សំដែងទុកមកហើយ ឬថា នេះជាពាក្យដែលព្រះតថាគត មិនបានទ្រង់ត្រាស់សំដែងទុកមកទេ នេះជាកិច្ចដែលព្រះតថាគតទ្រង់ប្រព្រឹត្តសន្សំមកហើយ ឬថា នេះជាកិច្ច ដែលព្រះតថាគតមិនបានទ្រង់ប្រព្រឹត្តសន្សំមកទេ នេះជាពាក្យ ដែលព្រះតថាគតទ្រង់បញ្ញត្តទុកមកហើយ ឬថា នេះជាពាក្យ ដែលព្រះតថាគតមិនបានទ្រង់បញ្ញត្តទុកមកទេ នេះជាអាបត្តិ ឬថា នេះមិនមែនជាអាបត្តិ នេះជាអាបត្តិស្រាល ឬថា នេះជាអាបត្តិធ្ងន់ នេះជាអាបត្តិមានចំណែកសេសសល់ ឬថា នេះជាអាបត្តិមិនមានចំណែកសេសសល់ នេះជាអាបត្តិអាក្រក់ ឬថានេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អទុដ្ឋុល្លា អាបត្តីតិ វា យំ តត្ថ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ នានាវាទោ អញ្ញថាវាទោ វិបច្ចតាយ វោហារោ មេធគំ[១] ឥទំ វុច្ចតិ វិវាទាធិករណំ ។

(៩០) តត្ថ កតមំ អនុវាទាធិករណំ ។ ឥធ បន ភិក្ខូ ភិក្ខុំ អនុវទន្តិ សីលវិបត្តិយា វា អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អាជីវវិបត្តិយា វា យោ តត្ថ អនុវាទោ អនុវទនា អនុល្លបនា អនុភណនា អនុសម្បវង្កតា អព្ភុស្សហនតា អនុពលប្បទានំ ឥទំ វុច្ចតិ អនុវាទាធិករណំ ។

(៩១) តត្ថ កតមំ អាបត្តាធិករណំ ។ បញ្ចបិ អាបត្តិក្ខន្ធា អាបត្តាធិករណំ សត្តបិ អាបត្តិក្ខន្ធា អាបត្តាធិករណំ ឥទំ វុច្ចតិ អាបត្តាធិករណំ ។

(៩២) តត្ថ កតមំ កិច្ចាធិករណំ ។ យា សង្ឃស្ស កិច្ចយតា ករណីយតា អបលោកនកម្មំ ញត្តិកម្មំ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ឥទំ វុច្ចតិ កិច្ចាធិករណំ ។

---

១ ម. មេធកំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មិនមែនជាអាបត្តិអាក្រក់ បណ្ដាអធិករណ៍ទាំង ៤ នោះ ការបង្កហេតុ ការឈ្លោះ ការប្រកាន់ផ្សេងគ្នា ការទាស់ទែងគ្នា ការពោលផ្សេង ៗ គ្នា ការពោលដោយខ្វែកពីគ្នា ការពោលដើម្បីសេចក្ដីទុក្ខដល់ចិត្ត ការប្រកួតប្រកាន់ណា ការបង្កហេតុជាដើមនេះ តថាគតហៅថាវិវាទាធិករណ៍ ។

(៥០) បណ្ដាអធិករណ៍ទាំង ៤ នោះ អនុវាទាធិករណ៍តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះចោទភិក្ខុផងគ្នា ដោយសីលវិបត្តិ ដោយអាចារវិបត្តិ ដោយទិដ្ឋិវិបត្តិ ដោយអាជីវវិបត្តិ បណ្ដាអធិករណ៍ទាំង ៤ នោះ ការចោទ ការតិះដៀល ការពោលរឿយ ៗ ការនិយាយរឿយ ៗ ការបង្អោនទៅ (កាន់អធិករណ៍) ការប្រឹងប្រែងឡើង ការបន្ថែមកំលាំងណា ការចោទជាដើមនោះ តថាគតហៅថា អនុវាទាធិករណ៍ ។

(៥១) បណ្ដាអធិករណ៍ទាំង ៤ នោះ អាបត្តាធិករណ៍តើដូចម្ដេច ។ អាបត្តិទាំង៥កង ជាអាបត្តាធិករណ៍ក៏មាន អាបត្តិទាំង៧កង ជាអាបត្តាធិករណ៍ក៏មាន នេះតថាគតហៅថា អាបត្តាធិករណ៍ ។

(៥២) បណ្ដាអធិករណ៍ទាំង ៤ នោះ កិច្ចាធិករណ៍តើដូចម្ដេច ។ កិច្ចរបស់សង្ឃ(ឬ)កម្មដែលសង្ឃត្រូវធ្វើបាន(ដូចយ៉ាង)អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម នេះតថាគតហៅថា កិច្ចាធិករណ៍ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៨៣) វិវាទាធិករណស្ស កឹ មូលំ ។ ឆ វិវាទមូលានិ វិវាទាធិករណស្ស មូលំ តីណិបិ អកុសលមូលានិ វិវាទាធិករណស្ស មូលំ តីណិបិ កុសលមូលានិ វិវាទាធិករណស្ស មូលំ ។ កតមានិ ឆ វិវាទមូលានិ វិវាទាធិករណស្ស មូលំ ។ ឥធ ភិក្ខវេ ភិក្ខុ កោធនោ ហោតិ ឧបនាហី យោ សោ ភិក្ខវេ ភិក្ខុ កោធនោ ហោតិ ឧបនាហី សោ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី(១) ហោតិ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិបិ(២) អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ(៣) សោ សង្ឃេ វិវាទំ ជនេតិ យោ(៤) ហោតិ វិវាទោ ពហុជនអហិតាយ ពហុជនអសុខាយ ពហុនោ ជនស្ស

---

១ ឱ. ម. បរិបូរការី ។ ២ ឱ. ម. បោត្ថកេសុ អបិសទ្ទោ នត្ថិ ។ ៣ អយំ សទ្ទោ ឱ. ម. បោត្ថកេសុ ន ទិស្សតិ ។ ៤ សោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សមថក្ខន្ធកៈ មូលនៃវិវាទាធិករណ៍

(៥៣) អ្វីជាមូលនៃវិវាទាធិករណ៍ ។ ធម៌ ៦ យ៉ាងជាមូលនៃសេចក្តីវិវាទ ចាត់ជាមូលនៃវិវាទាធិករណ៍ គឺអកុសលមូល ៣ យ៉ាង ជាមូលនៃវិវាទាធិករណ៍ ទាំងកុសលមូល ៣ យ៉ាង ជាមូលនៃវិវាទាធិករណ៍ដែរ ។ ធម៌ ៦ យ៉ាងជាមូលនៃវិវាទ ដែលចាត់ជាមូលនៃវិវាទាធិករណ៍នោះដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីក្រោធច្រើន ជាអ្នកចងគំនុំទុក ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មានសេចក្តីក្រោធច្រើន ជាអ្នកចងគំនុំទុក ភិក្ខុនោះឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង ឈ្មោះថា មិនធ្វើឲ្យពេញលេញក្នុងសិក្ខាផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង មិនធ្វើឲ្យពេញលេញក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថាញុំាងសេចក្តីវិវាទ ដែលកំពុងកើតឲ្យកើតឡើងក្នុងសង្ឃ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនបានសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីមិនចំរើនដល់ជនច្រើន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្សេវ បាបកស្ស វិវាទមូលស្ស បហានាយ វាយមេយ្យាថ ។ ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។

(៨៤) បុន ចបរំ ភិក្ខវេ ភិក្ខុ មក្ខី ហោតិ បឡាសី ។ បេ ។ ឥស្សុកី ហោតិ មច្ឆរី ។ បេ ។ សឋោ ហោតិ មាយាវី ។ បេ ។ បាបិច្ឆោ ហោតិ មិច្ឆាទិដ្ឋិ ។ បេ ។ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី(១) ទុប្បដិនិស្សគ្គី យោ សោ ភិក្ខវេ ភិក្ខុ សន្ទិដ្ឋិបរាមាសី

---

១ ឱ. ម. អាធានគ្គាហិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយពិចារណាឃើញ នូវមូលនៃសេចក្តីវិវាទខាងក្នុងក្តី ខាងក្រៅក្តី មានសភាពយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីព្យាយាម ដើម្បីលះបង់នូវមូលនៃសេចក្តីវិវាទដ៏លាមកនោះឯង ក្នុងអធិករណ៍នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនបានពិចារណាឃើញ នូវមូលនៃសេចក្តីវិវាទខាងក្នុង ទឹងខាងក្រៅ មានសភាពយ៉ាងនេះទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរប្រតិបត្តិកុំឲ្យមូលនៃវិវាទដ៏លាមកនោះ ចំរើនតទៅខាងមុខ ក្នុងអធិករណ៍នោះទៀតឡើយ ។ យ៉ាងនេះឯងឈ្មោះថា ការលះបង់នូវមូលនៃសេចក្តីវិវាទដ៏លាមកនុ៎ះ ។ យ៉ាងនេះឯងឈ្មោះថា មិនឲ្យមូលនៃសេចក្តីវិវាទដ៏លាមកនោះ ចំរើនតទៅខាងមុខទៀតបាន ។

(៩២) ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកប្រណាំងប្រជែង ១ ទេ១ ជាអ្នកមានសេចក្តីច្រណែន ជាអ្នកមានសេចក្តីកំណាញ់ ១ ទេ១ ជាអ្នកអួតអាង ជាអ្នកមានមាយា ១ ទេ១ ជាអ្នកមានសេចក្តីប្រាថ្នាលាមក ជាអ្នកមានសេចក្តីឃើញខុស ១ ទេ១ ជាអ្នកប៉ោសអង្អែលទិដ្ឋិរបស់ខ្លួន ប្រកាន់ខ្ជាប់ខ្ជួន លះបង់បានដោយកម្រ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកប៉ោសអង្អែលទិដ្ឋិរបស់ខ្លួន ប្រកាន់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី សោ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ ។ បេ ។ សង្ឃេបិ ។ បេ ។ សិក្ខាយបិ ន បរិបូរការី ហោតិ សោ សង្ឃេ វិវាទំ ជនេតិ យោ ហោតិ វិវាទោ ពហុជនអហិតាយ ពហុជនអសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្សេវ បាបកស្ស វិវាទមូលស្ស បហានាយ វាយមេយ្យាថ ។ ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខ្ជាប់មាំ លះបង់បានដោយកម្រ ភិក្ខុនោះឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណាឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង ។ បេ ។ ក្នុងព្រះសង្ឃផង ។ បេ ។ មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ញ៉ាំងវិវាទដែលកំពុងកើតឲ្យកើតឡើងក្នុងសង្ឃ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនបានសេចក្តីសុខដល់ជនច្រើន ដើម្បីមិនមានសេចក្តីចំរើនដល់ជនច្រើន ដើម្បីមិនមានប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានឹងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយពិចារណាឃើញនូវមូលនៃសេចក្តីវិវាទ ខាងក្នុងក្តី ខាងក្រៅក្តី មានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវព្យាយាម ដើម្បីលះបង់នូវមូលនៃសេចក្តីវិវាទដ៏លាមកនោះឯង ក្នុងអធិករណ៍នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនពិចារណាឃើញមូល នៃវិវាទខាងក្នុងក្តីខាងក្រៅក្តី ដែលមានសភាពយ៉ាងនេះទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខវេ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ឥមានិ ឆ វិវាទមូលានិ វិវាទាធិករណស្ស មូលំ ។

(៥៥) កតមានិ តីណិ អកុសលមូលានិ វិវាទាធិករណស្ស មូលំ ។ ឥធ បន ភិក្ខវេ(១) ភិក្ខូ លុទ្ធចិត្តា វិវទន្តិ ទុដ្ឋចិត្តា វិវទន្តិ មូឡ្ហចិត្តា វិវទន្តិ ធម្មោតិ វា អធម្មោតិ វា វិនយោតិ វា អវិនយោតិ វា ភាសិតំ លបិតំ តថាគតេនាតិ វា អភាសិតំ អលបិតំ តថាគតេនាតិ វា អាចិណ្ណំ តថាគតេនាតិ វា អនាចិណ្ណំ តថាគតេនាតិ វា បញ្ញត្តំ តថាគតេនាតិ វា អប្បញ្ញត្តំ តថាគតេនាតិ វា អាបត្តីតិ វា អនាបត្តីតិ វា លហុកា អាបត្តីតិ វា គរុកា អាបត្តីតិ វា សាវសេសា អាបត្តីតិ វា អនវសេសា អាបត្តីតិ វា ទុដ្ឋុល្លា អាបត្តីតិ វា អទុដ្ឋុល្លា អាបត្តីតិ វា ឥមានិ តីណិ អកុសលមូលានិ វិវាទាធិករណស្ស មូលំ ។

១ ឱ. ម. បោត្ថកេសុ បន ភិក្ខវេតិ បទទ្វយំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គួរប្រតិបត្តិកុំឲ្យមូលនៃវិវាទដ៏លាមកនោះចំរើនតទៅខាងមុខ ក្នុងអធិករណ៍នោះទៀតឡើយ ។ យ៉ាងនេះឯងឈ្មោះថាការលះបង់នូវមូលនៃវិវាទដ៏លាមកនុ៎ះ ។ យ៉ាងនេះឯងឈ្មោះថាមិនឲ្យមូលនៃវិវាទដ៏លាមកនុ៎ះ ចំរើនតទៅខាងមុខទៀតបាន មូលនៃវិវាទ ៦ យ៉ាងនេះ ចាត់ជាមូលនៃវិវាទាធិករណ៍ ។

(៨៩) អកុសលមូល ៣ ដែលចាត់ជាមូលនៃវិវាទាធិករណ៍នោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តលោភទាស់នឹងគ្នា មានចិត្តប្រទូស្តទាស់នឹងគ្នា មានចិត្តវង្វេង ទាស់នឹងគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី នេះជាវិន័យក្តី នេះមិនមែនជាវិន័យក្តី នេះជាពាក្យដែលព្រះតថាគត ទ្រង់ត្រាស់សំដែងទុកមកហើយក្តី នេះមិនមែនជាពាក្យដែលព្រះតថាគត ទ្រង់ត្រាស់សំដែងទុកមកទេក្តី នេះជាកិច្ចដែលព្រះតថាគត ទ្រង់ប្រព្រឹត្តសន្សំមកហើយក្តី នេះមិនមែនជាកិច្ចដែលព្រះតថាគត ទ្រង់ប្រព្រឹត្តសន្សំមកក្តី នេះជាពាក្យដែលព្រះតថាគត ទ្រង់បញ្ញត្តក្តី នេះមិនមែនជាពាក្យដែលព្រះតថាគត ទ្រង់បញ្ញត្តក្តី នេះជាអាបត្តិក្តី នេះមិនមែនជាអាបត្តិក្តី នេះជាអាបត្តិស្រាលក្តី នេះជាអាបត្តិធ្ងន់ក្តី នេះជាអាបត្តិមានចំណែកសេសសល់ក្តី នេះជាអាបត្តិមិនមានចំណែកសេសសល់ក្តី នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី អកុសលមូលទាំង ៣ នេះឯង ចាត់ជាមូលនៃវិវាទាធិករណ៍ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សមថក្ខន្ធកេ អនុវាទាធិករណស្ស មូលំ

(៥៦) កតមានិ តីណិ កុសលមូលានិ វិវាទាធិករណស្ស មូលំ ។ ឥធ បន ភិក្ខវេ(១) ភិក្ខូ អលុទ្ធចិត្តា វិវទន្តិ អទុដ្ឋចិត្តា វិវទន្តិ អមូឡ្ហចិត្តា វិវទន្តិ ធម្មោតិ វា អធម្មោតិ វា ។បេ។ ទុដ្ឋុល្លា អាបត្តីតិ វា អទុដ្ឋុល្លា អាបត្តីតិ វា ឥមានិ តីណិ កុសលមូលានិ វិវាទាធិករណស្ស មូលំ ។

(៥៧) អនុវាទាធិករណស្ស កឹ មូលំ ។ ឆ អនុវាទមូលានិ អនុវាទាធិករណស្ស មូលំ តីណិបិ អកុសលមូលានិ អនុវាទាធិករណស្ស មូលំ តីណិបិ កុសលមូលានិ អនុវាទាធិករណស្ស មូលំ កាយោបិ អនុវាទាធិករណស្ស មូលំ វាចាបិ អនុវាទាធិករណស្ស មូលំ ។

(៥៨) កតមានិ ឆ អនុវាទមូលានិ អនុវាទាធិករណស្ស មូលំ ។ ឥធ បន ភិក្ខវេ ភិក្ខុ កោធនោ ហោតិ ឧបនាហី យោ សោ ភិក្ខវេ ភិក្ខុ កោធនោ ហោតិ ឧបនាហី សោ សត្ថរិបិ អគារវោ វិហរតិ អប្ប-

---

១ ឱ. ម. បន ភិក្ខវេតិ បទទ្វយំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៩៦) កុសលមូល ៣ យ៉ាង ដែលចាត់ជាមូលនៃវិវាទាធិករណ៍ នោះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តមិនលោភទាស់ទែងគ្នា មានចិត្តមិនប្រទូស្តទាស់ទែងគ្នា មានចិត្តមិនវង្វេងទាស់ទែងគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី ។បេ។ នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី កុសលមូលទាំង ៣ យ៉ាងនេះឯង ចាត់ជាមូលនៃវិវាទាធិករណ៍ ។

(៩៧) មូលនៃអនុវាទាធិករណ៍នោះតើដូចម្តេច ។ មូលនៃការចោទគ្នាមាន ៦ យ៉ាង ចាត់ជាមូលនៃអនុវាទាធិករណ៍ គឺអកុសលមូល ៣ យ៉ាងក៏ចាត់ជាមូលនៃអនុវាទាធិករណ៍ កុសលមូល ៣ យ៉ាងក៏ចាត់ជាមូលនៃអនុវាទាធិករណ៍ដែរ កាយក៏ចាត់ជាមូលនៃអនុវាទាធិករណ៍ ទាំងវាចាក៏ចាត់ជាមូលនៃអនុវាទាធិករណ៍ដែរ ។

(៩៨) មូលនៃការចោទគ្នាមាន ៦ យ៉ាង ចាត់ជាមូលនៃអនុវាទាធិករណ៍នោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកមានសេចក្តីក្រោធ ជាអ្នកចងគំនុំទុក ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកមានសេចក្តីក្រោធ ជាអ្នកចងគំនុំទុក ភិក្ខុនោះឈ្មោះថាឥតមានសេចក្តី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ សោ សង្ឃេ អនុវាទំ ជនេតិ យោ ហោតិ អនុវាទោ ពហុជនអហិតាយ ពហុជនអសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ អនុវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្សេវ បាបកស្ស អនុវាទមូលស្ស បហានាយ វាយមេយ្យាថ ។ ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ អនុវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែងក្នុងព្រះសង្ឃផង មិនធ្វើឲ្យពេញលេញក្នុងសិក្ខាផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឥតមានសេចក្តីគោរពឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង មិនធ្វើឲ្យពេញលេញក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ញុំាងអទុក់ខ គឺការវោទ ដែលកំពុងកើតឲ្យកើតក្នុងសង្ឃ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនមានសេចក្តីសុខដល់ជនច្រើន ដើម្បីមិនមានសេចក្តីចំរើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយពិចារណាឃើញមូលនៃអទុក់ខទាំងខាងក្នុង និងខាងក្រៅ មានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីព្យាយាមដើម្បីលះបង់នូវមូលនៃអទុក់ខដ៏លាមកនោះ ក្នុងអធិករណ៍នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនពិចារណាឃើញមូល នៃអទុក់ខទាំងខាងក្នុង និងខាងក្រៅមានសភាពយ៉ាងនេះទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តស្សេវ បាបកស្ស អនុវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស អនុវាទមូលស្ស បហានំ ហោតិ ។ ឯវមេតស្ស បាបកស្ស អនុវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។

(៤៩) បុន ចបរំ ភិក្ខវេ ភិក្ខុ មក្ខី ហោតិ បឡាសី ។ បេ ។ ឥស្សុកី ហោតិ មច្ឆរី ។ បេ ។ សឋោ ហោតិ មាយាវី ។ បេ ។ បាបិច្ឆោ ហោតិ មិច្ឆាទិដ្ឋិ ។ បេ ។ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី យោ សោ ភិក្ខវេ ភិក្ខុ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី សោ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ ។ បេ ។ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ ។ បេ ។ សង្ឃេបិ ។ បេ ។ សិក្ខាយបិ ន បរិបូរការី ហោតិ សោ សង្ឃេ អនុវាទំ ជនេតិ យោ ហោតិ អនុវាទោ

គប្បីប្រតិបត្តិដើម្បីកុំឲ្យមូលនៃអនុវាទ ដ៏លាមកនោះចំរើនតទៅខាងមុខ ក្នុងអធិករណ៍នោះទៀតឡើយ ។ យ៉ាងនេះឯង ឈ្មោះថាលះបង់នូវមូលនៃអនុវាទដ៏លាមកនុ៎ះ ។ យ៉ាងនេះឯង ឈ្មោះថាមិនឲ្យមូល នៃអនុវាទ ដ៏លាមកនុ៎ះចំរើនតទៅទៀតបាន ។

(៨៩) ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកប្រណាំងសនា ។ បេ ។ ជាអ្នកមានសេចក្តីឫស្យា ជាអ្នកមានសេចក្តីកំណាញ់ ។ បេ ។ ជាអ្នកមានអំនួត ជាអ្នកមានមាយា ។ បេ ។ ជាអ្នកមានសេចក្តីប្រាថ្នាលាមក ជាអ្នកមានសេចក្តីយល់ខុស ។ បេ ។ ជាអ្នកបោសអង្អែលទិដ្ឋិរបស់ខ្លួន ប្រកាន់មាំ លះបង់បានដោយក្រ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកបោសអង្អែលទិដ្ឋិរបស់ខ្លួន ប្រកាន់មាំ លះបង់បានដោយក្រ ភិក្ខុនោះឈ្មោះថាឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង ។ បេ ។ ឈ្មោះថាឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង ឈ្មោះថាមិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង ។ បេ ។ ក្នុងព្រះសង្ឃផង ។ បេ ។ មិនធ្វើឲ្យពេញលេញក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ញុំាងអនុវាទដែលកំពុងកើតឲ្យកើត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពហុជនអហិតាយ ពហុជនអសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ច តុម្ហេ ភិក្ខវេ អនុភនមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្ស ទាយកស្ស អនុភនមូលស្ស បហានាយ វាយមេយ្យាថ ។ ឯវរូបញ្ច តុម្ហេ ភិក្ខវេ អនុភនមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្ស ទាយកស្ស អនុភនមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស ទាយកស្ស អនុភនមូលស្ស បហានំ ហោតិ ។ ឯវមេតស្ស ទាយកស្ស អនុភនមូលស្ស អាយតឹ អនវស្សវោ ហោតិ ឥមានិ ច អនុភនមូលានិ អនុភនានិការណស្ស មូលំ ។

(៦០) ឥតិមានិ តីណិ អកុសលមូលានិ អនុភនានិការណស្ស មូលំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុំ លុទ្ធចិត្តា អនុវត្តន្តិ ទុដ្ឋចិត្តា អនុវត្តន្តិ មូឡ្ហចិត្តា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ទៀតក្នុងសង្ឃ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនមានសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីមិនចំរើនដល់ជនច្រើន ដើម្បីមិនជាប្រ.យោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានឹងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយពិចារណាឃើញមូល នៃអនុវាទទាំងខាងក្នុងនឹងខាងក្រៅមានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីព្យាយាម ដើម្បីលះបង់មូលនៃអនុវាទដ៏លាមកនោះ ក្នុងអធិករណ៍នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនពិចារណាឃើញមូលនៃអនុវាទទាំងខាងក្នុងនឹងខាងក្រៅ មានសភាពយ៉ាងនេះទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីប្រតិបត្តិ ដើម្បីកុំឲ្យមូលនៃអនុវាទដ៏លាមកនោះ ចំរើនតទៅខាងមុខ ក្នុងអធិករណ៍នោះទៀតបានឡើយ ។ យ៉ាងនេះឯង ឈ្មោះថាលះបង់នូវមូល នៃអនុវាទដ៏លាមកនុ៎ះ ។ យ៉ាងនេះឯងឈ្មោះថាមិនបានឲ្យមូលនៃអនុវាទដ៏លាមកនុ៎ះ ចំរើនតទៅទៀតបាន មូលនៃអនុវាទទាំង៦ យ៉ាងនេះ ចាត់ជាមូលនៃអនុវាទាធិករណ៍ ។

(៦០) អកុសលមូល ៣ យ៉ាងដែលចាត់ជាមូល នៃអនុវាទាធិករណ៍នោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តលោភពោលទោស មានចិត្តប្រទូស្តពោលទោស មានចិត្តវង្វេង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុវទន្តិ សីលវិបត្តិយា វា អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អាជីវវិបត្តិយា វា ឥមានិ តីណិ អកុសលមូលានិ អនុវាទាធិករណស្ស មូលំ ។

(៦១) កតមានិ តីណិ កុសលមូលានិ អនុវាទាធិករណស្ស មូលំ ។ ឥធ បន ភិក្ខវេ ភិក្ខូ អលុទ្ធចិត្តា អនុវទន្តិ អទុដ្ឋចិត្តា អនុវទន្តិ អមូឡ្ហចិត្តា អនុវទន្តិ សីលវិបត្តិយា វា អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អាជីវវិបត្តិយា វា ឥមានិ តីណិ កុសលមូលានិ អនុវាទាធិករណស្ស មូលំ ។

(៦២) កតមោ ច (១) កាយោ អនុវាទាធិករណស្ស មូលំ ។ ឥធេកច្ចោ ទុព្វណ្ណោ ហោតិ ទុទ្ទស្សិកោ ឱកោដិមកោ ពហ្វាពាធោ កាណោ វា កុណី វា ខញ្ជោ វា បក្ខហតោ វា យេន នំ អនុវទន្តិ អយំ កាយោ អនុវាទាធិករណស្ស មូលំ ។

---

១ ឱ. ម. ចោទកេសុ បសញ្ជេន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពោលទោស នូវភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី អកុសលមូលទាំង ៣ យ៉ាងនេះ ជាមូលនៃអនុវាទាធិករណ៍ ។

(៦១) កុសលមូល ៣ យ៉ាង ដែលចាត់ជាមូលនៃអនុវាទាធិករណ៍ នោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តមិនលោភពោលទោស មានចិត្តមិនប្រទូស្តពោលទោស មានចិត្តមិនវង្វេងពោលទោស នូវភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី កុសលមូលទាំង ៣ យ៉ាងនេះ ជាមូលនៃអនុវាទាធិករណ៍ ។

(៦២) ឯកាយ ចាត់ជាមូលនៃអនុវាទាធិករណ៍នោះ តើដូចម្តេច ។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ មានសម្បុរអាក្រក់ មានរូបអាក្រក់ ជាមនុស្សតឿ មានអាពាធច្រើន ខ្វាក់ ក្ញែង ខ្ញក ឬ ស្លាប់ខ្លួន ១ ចំហៀង(១) ភិក្ខុទាំងឡាយពោលទោសភិក្ខុនោះដោយកាយណា កាយនេះជាមូលនៃអនុវាទាធិករណ៍ ។

១ ក្នុងដីកាថា ខ្វិន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៦៣) កតមា ច[១] វាចា អនុវាទាធិករណស្ស មូលំ ។ ឥធេកច្ចោ ទុព្ពចោ ហោតិ មម្មនោ ឯឡគលវាចោ យាយ នំ អនុវទន្តិ អយំ វាចា អនុវាទាធិករណស្ស មូលំ ។

(៦៤) អាបត្តាធិករណស្ស កឹ មូលំ ។ ឆ អាបត្តិសមុដ្ឋានា អាបត្តាធិករណស្ស មូលំ អត្ថាបត្តិ កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ អត្ថាបត្តិ វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ អត្ថាបត្តិ កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ អត្ថាបត្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ អត្ថាបត្តិ វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ អត្ថាបត្តិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ឥមេ ឆ អាបត្តិសមុដ្ឋានា អាបត្តាធិករណស្ស មូលំ ។

(៦៥) កិច្ចាធិករណស្ស កឹ មូលំ ។ កិច្ចាធិករណស្ស ឯកំ មូលំ សង្ឃោ ។

---

១ ឱ. ម. ពោត្ថកេសុ ចសទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៦៣] ចុះវាចាដូចម្តេច ដែលជាមូលនៃអនុវាទាធិករណ៍ ។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកមានវាចាអាក្រក់ ជាអ្នកនិយាយដាច់ ជាអ្នកមានវាចាប៉ឡោចប៉ះប៉ោច ភិក្ខុទាំងឡាយពោលភិក្ខុនោះ ដោយវាចាណា វាចានេះឈ្មោះថាជាមូលនៃអនុវាទាធិករណ៍ ។

[៦៤] អ្វីដែលជាមូលនៃអាបត្តាធិករណ៍ ។ សមុដ្ឋាននៃអាបត្តិ ៦ យ៉ាង ជាមូលនៃអាបត្តាធិករណ៍ (សមុដ្ឋាននៃអាបត្តិ ៦ នោះគឺ) អាបត្តិកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា អំពីចិត្ត ១ អាបត្តិកើតឡើងអំពីវាចា មិនកើតឡើងអំពីកាយ អំពីចិត្ត ១ អាបត្តិកើតឡើងអំពីកាយ អំពីវាចា មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើងអំពីកាយ អំពីចិត្ត មិនកើតឡើងអំពីវាចា ១ អាបត្តិកើតឡើងអំពីវាចា អំពីចិត្ត មិនកើតឡើងអំពីកាយ ១ អាបត្តិកើតឡើងអំពីកាយ អំពីវាចា អំពីចិត្ត ១ សមុដ្ឋាននៃអាបត្តិ ៦ យ៉ាងនេះ ជាមូលនៃអាបត្តាធិករណ៍ ។

[៦៥] អ្វីជាមូលនៃកិច្ចាធិករណ៍ ។ មានតែសង្ឃមួយ ជាមូលនៃកិច្ចាធិករណ៍(១) ។

---

១ អធិករណ៍ឯទៀតមានមូលច្រើន ចំណែកកិច្ចាធិករណ៍នេះមានមូលតែ ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៦៦) វិវាទាធិករណំ កុសលំ អកុសលំ អព្យាកតំ ។ វិវាទាធិករណំ សិយា កុសលំ សិយា អកុសលំ សិយា អព្យាកតំ ។

(៦៧) តត្ថ កតមំ វិវាទាធិករណំ អកុសលំ ។ ឥធ បន ភិក្ខវេ[1] ភិក្ខូ អកុសលចិត្តា វិវទន្តិ ធម្មោតិ វា អធម្មោតិ វា ។ បេ ។ ទុដ្ឋុល្លា អាបត្តីតិ វា អទុដ្ឋុល្លា អាបត្តីតិ វា យំ តត្ថ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ នានាវាទោ អញ្ញថាវាទោ វិបច្ចតាយ វោហារោ មេធគំ[2] ឥទំ វុច្ចតិ វិវាទាធិករណំ អកុសលំ ។

(៦៨) តត្ថ កតមំ វិវាទាធិករណំ កុសលំ ។ ឥធ បន ភិក្ខវេ ភិក្ខូ កុសលចិត្តា វិវទន្តិ ធម្មោតិ វា អធម្មោតិ វា ។ បេ ។ ទុដ្ឋុល្លា អាបត្តីតិ វា អទុដ្ឋុល្លា អាបត្តីតិ វា យំ តត្ថ ភណ្ឌនំ កលហោ

---

១ ឱ. បន ភិក្ខវេតិ ន ទិស្សតិ ។ ២ ឱ. មេធកំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៦៦) (សំដែងអំពី) វិវាទាធិករណ៍ ជាកុសល ជាអកុសល ជាអព្យាកតៈ ។ វិវាទាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។

(៦៧) បណ្ដាវិវាទាធិករណ៍ទាំង ៣ នោះ វិវាទាធិករណ៍ជាអកុសល តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង មានចិត្តជាអកុសល ជជែកគ្នាថា នេះជាធម៌ក្ដី នេះមិនមែនជាធម៌ក្ដី ។ បេ ។ នេះជាអាបត្តិអាក្រក់ក្ដី នេះមិនមែនជាអាបត្តិអាក្រក់ក្ដី ការបង្កហេតុ ជម្លោះ សេចក្ដីប្រកាន់ខុស ទាស់ទែង ការពោលផ្សេងៗ ការពោលដោយឡែកពីគ្នា ការនិយាយដើម្បីឲ្យព្រួយចិត្ត សេចក្ដីប្រកួតប្រកាន់ណា ក្នុងអធិករណ៍នោះ ការបង្កហេតុជាដើមនេះ តថាគតហៅថា វិវាទាធិករណ៍ជាអកុសល ។

(៦៨) បណ្ដាវិវាទាធិករណ៍ទាំង ៣ នោះ វិវាទាធិករណ៍ជាកុសល តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង មានចិត្តជាកុសល ជជែកគ្នាថា នេះជាធម៌ក្ដី នេះមិនមែនជាធម៌ក្ដី ។ បេ ។ នេះជាអាបត្តិអាក្រក់ក្ដី នេះមិនមែនជាអាបត្តិអាក្រក់ក្ដី ការបង្កហេតុ ជម្លោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វិគ្គហោ វិវាទោ នានាវាទោ អញ្ញថាវាទោ វិបច្ចតាយ វោហារោ មេធគំ ឥទំ វុច្ចតិ វិវាទាធិករណំ កុសលំ[1]។

(៦៩) តត្ថ កតមំ វិវាទាធិករណំ អព្យាកតំ ។ ឥធ បន ភិក្ខវេ ភិក្ខូ ភិក្ខុំ[2] អព្យាកតចិត្តា វិវទន្តិ ធម្មោតិ វា អធម្មោតិ វា ។បេ។ ទុដ្ឋុល្លា អាបត្តីតិ វា អទុដ្ឋុល្លា អាបត្តីតិ វា យំ តត្ថ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ នានាវាទោ អញ្ញថាវាទោ វិបច្ចតាយ វោហារោ មេធគំ ឥទំ វុច្ចតិ វិវាទាធិករណំ អព្យាកតំ ។

(៧០) អនុវាទាធិករណំ កុសលំ អកុសលំ អព្យា-កតំ ។ អនុវាទាធិករណំ សិយា កុសលំ សិយា អកុ-សលំ សិយា អព្យាកតំ ។

(៧១) តត្ថ កតមំ អនុវាទាធិករណំ អកុសលំ ។ ឥធ បន ភិក្ខវេ ភិក្ខូ ភិក្ខុំ អកុសលចិត្តា

---

១ ឱ. ម. ពោត្ថកេសុ បឋមំ កុសលំ អាគតំ បច្ឆា អកុសលំ អាគតំ ។ ២ ឱ. បន ភិក្ខវេ ភិក្ខូ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេចក្តីប្រកាន់ខុស ការទាស់ទែង ការពោលផ្សេងៗ ការពោលដោយវៀកពីគ្នា ការនិយាយដើម្បីឲ្យព្រួយចិត្ត ការប្រកួតប្រកាន់ណា ក្នុងអធិករណ៍នោះ ការបង្កហេតុជាដើមនេះ តថាគតហៅថា វិវាទាធិករណ៍ជាកុសល ។

(៦៩) បណ្តាវិវាទាធិករណ៍ទាំង ៣ នោះ វិវាទាធិករណ៍ជាអព្យាកតៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង មានចិត្តជាអព្យាកតៈជជែកទទឹងភិក្ខុផងគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី ។បេ។ នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី ការបង្កហេតុ ជម្លោះ សេចក្តីប្រកាន់ខុស ការទាស់ទែងគ្នា ការពោលផ្សេងៗ ការពោលដោយវៀកពីគ្នា ការនិយាយដើម្បីឲ្យព្រួយចិត្ត ការប្រកួតប្រកាន់ណា ក្នុងវិវាទាធិករណ៍នោះ ការបង្កហេតុជាដើមនេះ តថាគតហៅថា វិវាទាធិករណ៍ជាអព្យាកតៈ ។

(៧០) (សំដែងអំពី) អនុវាទាធិករណ៍ជាកុសល ជាអកុសល ជាអព្យាកតៈ ។ អនុវាទាធិករណ៍ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។

(៧១) បណ្តាអនុវាទាធិករណ៍ ទាំង ៣ នោះ អនុវាទាធិករណ៍ជាអកុសល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុវទន្តិ សីលវិបត្តិយា វា អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អាជីវវិបត្តិយា វា យោ តត្ថ អនុវាទោ អនុវទនា អនុល្លបនា អនុភណនា អនុសម្បវង្កតា អព្ភុស្សហនតា អនុពលប្បទានំ ឥទំ វុច្ចតិ អនុវាទាធិករណំ អកុសលំ ។

(៧២) តត្ថ កតមំ អនុវាទាធិករណំ កុសលំ ។ ឥធ បន ភិក្ខវេ ភិក្ខូ ភិក្ខុំ កុសលចិត្តា អនុវទន្តិ សីលវិបត្តិយា វា អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អាជីវវិបត្តិយា វា យោ តត្ថ អនុវាទោ អនុវទនា អនុល្លបនា អនុភណនា អនុសម្បវង្កតា អព្ភុស្សហនតា អនុពលប្បទានំ ឥទំ វុច្ចតិ អនុវាទាធិករណំ កុសលំ(១) ។

(៧៣) តត្ថ កតមំ អនុវាទាធិករណំ អព្យាកតំ ។ ឥធ បន ភិក្ខវេ ភិក្ខូ ភិក្ខុំ អព្យាកតចិត្តា អនុវទន្តិ សីលវិបត្តិយា វា អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អាជីវវិបត្តិយា វា យោ តត្ថ អនុវាទោ អនុវទនា

---

១ ឧ.ម. ពោត្ថកេសុ បឋមំ កុសលំ អាគតំ បច្ឆា អកុសលំ អាគតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មានចិត្តជាអកុសល ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិ ដោយអាចារវិបត្តិ ដោយទិដ្ឋិវិបត្តិ ដោយអាជីវវិបត្តិ ការចោទ ការតិះដៀល ការចរចារឿយ ៗ ការនិយាយរឿយ ៗ ការពោលបញ្ជាក់ ការប្រឹងប្រែង ការបន្ថែមកម្លាំងឲ្យណា ក្នុងអធិករណ៍នោះ ការចោទជាដើមនេះ តថាគតហៅថា អនុវាទាធិករណ៍ជាអកុសល ។

(៧២) បណ្ដាអនុវាទាធិករណ៍ទាំង ៣ នោះ អនុវាទាធិករណ៍ជាកុសល តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តជាកុសល ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិ ដោយអាចារវិបត្តិ ដោយទិដ្ឋិវិបត្តិ ដោយអាជីវវិបត្តិ ការចោទ ការតិះដៀល ការចរចារឿយ ៗ ការនិយាយរឿយ ៗ ការពោលបញ្ជាក់ ការប្រឹងប្រែង ការបន្ថែមកម្លាំងឲ្យណា ក្នុងអធិករណ៍នោះ ការចោទជាដើមនេះ តថាគតហៅថា អនុវាទាធិករណ៍ជាកុសល ។

(៧៣) បណ្ដាអនុវាទាធិករណ៍ ទាំង ៣ នោះ អនុវាទាធិករណ៍ជាអព្យាកតៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តជាអព្យាកតៈ ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិ ដោយអាចារវិបត្តិ ដោយទិដ្ឋិវិបត្តិ ដោយអាជីវវិបត្តិ ការចោទ ការតិះដៀល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





អនុល្លបនា អនុភណនា អនុសម្បវង្កតា អព្ភុស្សហនតា អនុពលប្បទានំ ឥទំ វុច្ចតិ អនុវាទាធិករណំ អព្យាកតំ ។

(៧៦) អាបត្តាធិករណំ អកុសលំ អព្យាកតំ ។ អាបត្តាធិករណំ សិយា អកុសលំ សិយា អព្យាកតំ នត្ថិ អាបត្តាធិករណំ កុសលំ ។

(៧៨) តត្ថ កតមំ អាបត្តាធិករណំ អកុសលំ ។ យំ ជានន្តោ សញ្ជានន្តោ ចេច្ច អភិវិតរិត្វា វីតិក្កមោ ឥទំ វុច្ចតិ អាបត្តាធិករណំ អកុសលំ ។ តត្ថ កតមំ អាបត្តាធិករណំ អព្យាកតំ ។ យំ អជានន្តោ អសញ្ជានន្តោ អចេច្ច អនភិវិតរិត្វា វីតិក្កមោ ឥទំ វុច្ចតិ អាបត្តាធិករណំ អព្យាកតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ការចោទរឿយ ៗ ការនិយាយរឿយ ៗ ការពោលបន្ទាប់ ការប្រឹងប្រែង ការបន្ថែមកម្លាំងឲ្យណា ក្នុងអធិករណ៍នោះ ការចោទជាដើមនេះ តថាគត ហៅថា អនុវាទាធិករណ៍ជាអព្យាកត: ។

(៧៦) (សំដែងអំពី) អាបត្តាធិករណ៍ជាអកុសល ជាអព្យាកត: ។ អាបត្តាធិករណ៍ជាអកុសលក៏មាន ជាអព្យាកត:ក៏មាន អាបត្តាធិករណ៍ជាកុសលគ្មានទេ ។

(៧៨) បណ្ដាអាបត្តាធិករណ៍ ទាំង ២ នោះ អាបត្តាធិករណ៍ជាអកុសល តើដូចម្ដេច ។ ភិក្ខុកាលបើដឹង ស្គាល់ហើយ ក្លែងព្យាយាមកន្លង នូវអាបត្តិណា អាបត្តិនេះ តថាគតហៅថា អាបត្តាធិករណ៍ជាអកុសល ។ បណ្ដាអាបត្តាធិករណ៍ ទាំង ២ នោះ អាបត្តាធិករណ៍ជាអព្យាកត: តើដូចម្ដេច ។ ភិក្ខុកាលបើមិនដឹង មិនស្គាល់ហើយ មិនក្លែង មិនព្យាយាមកន្លង នូវអាបត្តិណា អាបត្តិនេះ តថាគតហៅថា អាបត្តាធិករណ៍ជាអព្យាកត:(១) ។

---

១ អដ្ឋកថា ថា អាបត្តាធិករណ៍ជាអព្យាកត:នោះ គឺភិក្ខុមិនបានក្លែង មិនបានដឹងអ្វីសោះ តែត្រូវអាបត្តិ (ជាអចិត្តក:) មានបឋមសហសេយ្យសិក្ខាបទជាដើម ។ ក្នុងដីកាថា ដូចជាភិក្ខុមានចិត្តប៉ុះស័ប៉កាត់កម្មដ្ឋាន ហើយសិងលក់ទៅ បើមានមាតុគ្រាមមកដេកជាមួយ ត្រូវអាបត្តិ ដោយការដេកក្នុងខណៈនោះ តែមិនមានចិត្តជាអកុសល បានជាលោកហៅថា អាបត្តាធិករណ៍ជាអព្យាកត: ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៧៦) កិច្ចាធិករណំ កុសលំ អកុសលំ អព្យាកតំ ។ កិច្ចាធិករណំ សិយា កុសលំ សិយា អកុសលំ សិយា អព្យាកតំ ។

(៧៧) តត្ថ កតមំ កិច្ចាធិករណំ អកុសលំ ។ យំ សង្ឃោ អកុសលចិត្តោ កម្មំ ករោតិ អបលោកនកម្មំ ញត្តិកម្មំ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ឥទំ វុច្ចតិ កិច្ចាធិករណំ អកុសលំ ។

(៧៨) តត្ថ កតមំ កិច្ចាធិករណំ កុសលំ ។ យំ សង្ឃោ កុសលចិត្តោ កម្មំ ករោតិ អបលោកនកម្មំ ញត្តិកម្មំ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ឥទំ វុច្ចតិ កិច្ចាធិករណំ កុសលំ[១] ។

(៧៩) តត្ថ កតមំ កិច្ចាធិករណំ អព្យាកតំ ។ យំ សង្ឃោ អព្យាកតចិត្តោ កម្មំ ករោតិ អបលោកនកម្មំ ញត្តិកម្មំ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ឥទំ វុច្ចតិ កិច្ចាធិករណំ អព្យាកតំ ។

---

១ ឱ. ម. ពោត្ថកេសុ បឋមំ កុសលំ អាគតំ បច្ឆា អកុសលំ អាគតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សមថពិច្ឆន្ទកៈ កិច្ចាធិករណ៍ ជាកុសល ជាអកុសល ជាអព្យាកតៈ

(៧៦) (សិផែនិគិតិ) កិច្ចាធិករណ៍ ជាកុសល ជាអកុសល ជាអព្យាកតៈ ។ កិច្ចាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។

(៧៧) បណ្ដាកិច្ចាធិករណ៍ទាំង ៣ នេះ កិច្ចាធិករណ៍ជាអកុសល តើដូចម្ដេច ។ សង្ឃមានចិត្តជាអកុសលធ្វើកម្មណា គឺអបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម កម្មនេះ តថាគតហៅថា កិច្ចាធិករណ៍ជាអកុសល ។

(៧៨) បណ្ដាកិច្ចាធិករណ៍ទាំង ៣ នេះ កិច្ចាធិករណ៍ ជាកុសល តើដូចម្ដេច ។ សង្ឃមានចិត្តជាកុសលធ្វើកម្មណា គឺ អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម កម្មនេះ តថាគតហៅថា កិច្ចាធិករណ៍ជាកុសល ។

(៧៩) បណ្ដាកិច្ចាធិករណ៍ទាំង ៣ នោះ កិច្ចាធិករណ៍ជាអព្យាកតៈ តើដូចម្ដេច ។ សង្ឃមានចិត្តជាអព្យាកតៈធ្វើកម្មណា គឺ អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម កម្មនេះ តថាគតហៅថា កិច្ចាធិករណ៍ជាអព្យាកតៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៨០) វិវាទោ វិវាទាធិករណំ វិវាទោ នោ អធិករណំ អធិករណំ នោ វិវាទោ អធិករណញ្ចេវ វិវាទោ ច ។ សិយា វិវាទោ វិវាទាធិករណំ សិយា វិវាទោ នោ អធិករណំ សិយា អធិករណំ នោ វិវាទោ សិយា អធិករណញ្ចេវ វិវាទោ ច ។

(៨១) តត្ថ កតមោ វិវាទោ វិវាទាធិករណំ ។ ឥធ បន ភិក្ខវេ ភិក្ខូ វិវទន្តិ ធម្មោតិ វា អធម្មោតិ វា ។បេ។ ទុដ្ឋុល្លា អាបត្តីតិ វា អទុដ្ឋុល្លា អាបត្តីតិ វា យំ តត្ថ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ នានាវាទោ អញ្ញថាវាទោ វិបច្ចតាយ វោហារោ មេធគំ អយំ វិវាទោ វិវាទាធិករណំ ។ តត្ថ កតមោ វិវាទោ នោ អធិករណំ ។ មាតាបិ បុត្តេន វិវទតិ បុត្តោបិ មាតរា វិវទតិ បិតាបិ បុត្តេន វិវទតិ បុត្តោបិ បិតរា វិវទតិ ភាតាបិ ភាតរា វិវទតិ ភាតាបិ ភគិនិយា វិវទតិ

## វិនយបិដក ចុល្លវគ្គ

(៨០) (សំដែងអំពី) ការទាស់ទែងគ្នាចាត់ជាវិវាទាធិករណ៍ ការទាស់ទែងគ្នាមិនចាត់ជាអធិករណ៍ អធិករណ៍មិនចាត់ជាការទាស់ទែងគ្នា ចាត់ជាអធិករណ៍ផង ជាការទាស់ទែងគ្នាផង ។ ការទាស់ទែងគ្នាចាត់ជាវិវាទាធិករណ៍ក៏មាន ការទាស់ទែងគ្នាមិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍មិនចាត់ជាការទាស់ទែងគ្នាក៏មាន ចាត់ជាអធិករណ៍ផង ជាការទាស់ទែងគ្នាផងក៏មាន ។

(៨១) បណ្ដាអធិករណ៍ទាំងនោះ ការទាស់ទែងគ្នាដែលចាត់ជាវិវាទាធិករណ៍ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ ជជែកគ្នាថា នេះជាធម៌ នេះមិនមែនជាធម៌ ។ បេ ។ នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី ការបង្កហេតុ ជម្លោះ ការប្រកាន់ខុស ការទាស់ទែង ការនិយាយផ្សេង ៗ ការនិយាយផ្ទុយផ្ទាស់ ការនិយាយដើម្បីឲ្យព្រួយចិត្ត ការប្រកួតប្រកាន់ណា ក្នុងអធិករណ៍នោះ ការបង្កហេតុជាដើមនេះ ចាត់ជាការទាស់ទែងគ្នា ហៅថា វិវាទាធិករណ៍ ។ បណ្ដាអធិករណ៍ទាំងនោះ ការទាស់ទែងគ្នា ដែលមិនមែនជាអធិករណ៍ តើដូចម្ដេច ។ មាតាទាស់ទែងនឹងបុត្រក្តី បុត្រទាស់ទែងនឹងមាតាក្តី បិតាទាស់ទែងនឹងបុត្រក្តី បុត្រទាស់ទែងនឹងបិតាក្តី បងប្អូនប្រុសទាស់ទែងនឹងបងប្អូនប្រុសក្តី បងប្អូនប្រុសទាស់ទែងនឹងបងប្អូនស្រីក្តី បងប្អូនស្រីទាស់ទែងនឹងបងប្អូន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគិនីបិ ភាតរា វិវទតិ សហាយោបិ សហាយេន វិវទតិ អយំ វិវាទោ នោ អធិករណំ ។ តត្ថ កតមំ អធិករណំ នោ វិវាទោ ។ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ ឥទំ អធិករណំ នោ វិវាទោ ។ តត្ថ កតមំ អធិករណញ្ចេវ វិវាទោ ច ។ វិវាទាធិករណំ អធិករណញ្ចេវ វិវាទោ ច ។

(៨២) អនុវាទោ អនុវាទាធិករណំ អនុវាទោ នោ អធិករណំ អធិករណំ នោ អនុវាទោ អធិករណញ្ចេវ អនុវាទោ ច ។ សិយា អនុវាទោ អនុវាទាធិករណំ សិយា អនុវាទោ នោ អធិករណំ សិយា អធិករណំ នោ អនុវាទោ សិយា អធិករណញ្ចេវ អនុវាទោ ច ។

(៨៣) តត្ថ កតមោ អនុវាទោ អនុវាទាធិករណំ ។ ឥធ បន ភិក្ខវេ ភិក្ខូ ភិក្ខុំ អនុវទន្តិ សីលវិបត្តិយា វា អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អាជីវវិបត្តិយា វា យោ តត្ថ អនុវាទោ អនុវទនា អនុល្លបនា អនុភណនា អនុសម្បវង្កតា អព្ភុស្សហនតា អនុពលប្បទានំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ប្រុសក្តី សម្លាញ់ទាស់នឹងសម្លាញ់ក្តី នេះហៅថា ការទាស់ទែងគ្នា មិនមែនជាអធិករណ៍ ។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ដែលមិនបាត់ជាការទាស់ទែងគ្នា តើដូចម្តេច ។ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ នេះហៅថា អធិករណ៍ ដែលមិនបាត់ជាការទាស់ទែងគ្នា ។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ដែលបាត់ពេញថាជាអធិករណ៍ផង ជាការទាស់ទែងគ្នាផង តើដូចម្តេច ។ វិវាទាធិករណ៍បាត់ជាអធិករណ៍ផង ជាការទាស់ទែងគ្នាផង ។

(៨២) (សំដែងអំពី) ការចោទបាត់ជាអនុវាទាធិករណ៍ ការចោទមិនបាត់ជាអធិករណ៍ អធិករណ៍មិនបាត់ជាការចោទ ទាំងជាអធិករណ៍ផង បាត់ជាការចោទផង ។ ការចោទបាត់ជាអនុវាទាធិករណ៍ក៏មាន ការចោទមិនបាត់ជាអធិករណ៍ក៏មាន អធិករណ៍មិនបាត់ជាការចោទក៏មាន ទាំងជាអធិករណ៍ផង បាត់ជាការចោទផងក៏មាន ។

(៨៣) បណ្តាអធិករណ៍ទាំងនោះ ការចោទបាត់ជាអនុវាទាធិករណ៍ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង ចោទប្រកាន់ភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី ការចោទ ការតិះដៀល ការបេរោរឿយ ៗ ការនិយាយរឿយ ៗ ការពោលបន្ទាប់ ការប្រឹងប្រែង ការបន្ថែមកម្លាំង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អយំ អនុវាទោ អនុវាទាធិករណំ ។ តត្ថ កតមោ អនុវាទោ ន អធិករណំ ។ មាតាបិ បុត្តំ អនុវទតិ បុត្តោបិ មាតរំ អនុវទតិ បិតាបិ បុត្តំ អនុវទតិ បុត្តោបិ បិតរំ អនុវទតិ ភាតាបិ ភាតរំ អនុវទតិ ភាតាបិ ភគិនឹ អនុវទតិ ភគិនីបិ ភាតរំ អនុវទតិ សហាយោបិ សហាយំ អនុវទតិ អយំ អនុវាទោ ន អធិករណំ ។ តត្ថ កតមំ អធិករណំ ន អនុវាទោ ។ អាបត្តាធិករណំ កិច្ចាធិករណំ វិវាទាធិករណំ ឥទំ អធិករណំ ន អនុវាទោ ។ តត្ថ កតមំ អធិករណញ្ចេវ អនុវាទោ ច ។ អនុវាទាធិករណំ អធិករណញ្ចេវ អនុវាទោ ច ។

(៨៤) អាបត្តិ អាបត្តាធិករណំ អាបត្តិ ន អធិករណំ អធិករណំ ន អាបត្តិ អធិករណញ្ចេវ អាបត្តិ ច ។ សិយា អាបត្តិ អាបត្តាធិករណំ សិយា អាបត្តិ ន អធិករណំ សិយា អធិករណំ ន អាបត្តិ សិយា អធិករណញ្ចេវ អាបត្តិ ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឲ្យណា ក្នុងអធិករណ៍នោះ ការចោទជាដើមនេះ ហៅថា អនុវាទាធិករណ៍ ។ បណ្ដាអធិករណ៍ទាំងនោះ ការចោទដែលមិនចាត់ជាអធិករណ៍ តើដូចម្ដេច ។ មាតាចោទបុត្រក្ដី បុត្រចោទមាតាក្ដី បិតាចោទបុត្រក្ដី បុត្រចោទបិតាក្ដី បងប្អូនប្រុសចោទបងប្អូនប្រុសក្ដី បងប្អូនប្រុសចោទបងប្អូនស្រីក្ដី បងប្អូនស្រីចោទបងប្អូនប្រុសក្ដី សម្លាញ់ចោទសម្លាញ់ក្ដី នេះឯងហៅថា ការចោទដែលមិនមែនជាអធិករណ៍ ។ បណ្ដាអធិករណ៍ទាំងនោះ អធិករណ៍តែមិនចាត់ជាការចោទ តើដូចម្ដេច ។ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ វិវាទាធិករណ៍ ១ នេះហៅថា អធិករណ៍ តែមិនចាត់ជាការចោទទេ ។ បណ្ដាអធិករណ៍ទាំងនោះ អធិករណ៍ដែលចាត់ពេញជាជាអធិករណ៍ផង ចាត់ជាការចោទផង តើដូចម្ដេច ។ អនុវាទាធិករណ៍ ចាត់ជាអធិករណ៍ផង ចាត់ជាការចោទផង ។

(៨៤) (សំដែងអំពី) អាបត្តិចាត់ជាអាបត្តាធិករណ៍ អាបត្តិមិនមែនជាអធិករណ៍ អធិករណ៍មិនមែនជាអាបត្តិ ទាំងអធិករណ៍ទាំងអាបត្តិ ។ អាបត្តិចាត់ជាអាបត្តាធិករណ៍ក៏មាន អាបត្តិមិនមែនជាអធិករណ៍ក៏មាន អធិករណ៍មិនមែនជាអាបត្តិក៏មាន អធិករណ៍ផង អាបត្តិផងក៏មាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៨៥) តត្ថ កតមា[១] អាបត្តិ អាបត្តាធិករណំ ។ បញ្ចបិ អាបត្តិក្ខន្ធា អាបត្តាធិករណំ សត្តបិ អាបត្តិក្ខន្ធា អាបត្តាធិករណំ អយំ អាបត្តិ អាបត្តាធិករណំ ។ តត្ថ កតមា[២] អាបត្តិ នោ អធិករណំ ។ សោតាបត្តិ សមាបត្តិ អយំ អាបត្តិ នោ អធិករណំ ។ តត្ថ កតមំ អធិករណំ នោ អាបត្តិ ។ កិច្ចាធិករណំ វិវាទាធិករណំ អនុវាទាធិករណំ ឥទំ អធិករណំ នោ អាបត្តិ ។ តត្ថ កតមំ អធិករណញ្ចេវ អាបត្តិ ច ។ អាបត្តាធិករណំ អធិករណញ្ចេវ អាបត្តិ ច ។

(៨៦) កិច្ចំ កិច្ចាធិករណំ កិច្ចំ នោ អធិករណំ អធិករណំ នោ កិច្ចំ អធិករណញ្ចេវ កិច្ចញ្ច ។ សិយា កិច្ចំ កិច្ចាធិករណំ សិយា កិច្ចំ នោ អធិករណំ សិយា អធិករណំ នោ កិច្ចំ សិយា អធិករណញ្ចេវ កិច្ចញ្ច ។

---

១-២ ឱ. ម. កតមំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកៈ អាបត្តិដែលចាត់ជាអាបត្តាធិករណ៍

(៨៥) បណ្ដាអធិករណ៍ទាំងនោះ អាបត្តិដែលចាត់ជាអាបត្តាធិករណ៍ តើដូចម្ដេច ។ អាបត្តិទាំង ៥ កងក៏ចាត់ជាអាបត្តាធិករណ៍ អាបត្តិទាំង ៧ កងក៏ចាត់ជាអាបត្តាធិករណ៍ នេះហៅថា អាបត្តិដែលចាត់ជាអាបត្តាធិករណ៍ ។ បណ្ដាអធិករណ៍ទាំងនោះ អាបត្តិដែលមិនចាត់ជាអធិករណ៍ តើដូចម្ដេច ។ សោតាបត្តិនិងសមាបត្តិ នេះហៅថា អាបត្តិ តែមិនចាត់ជាអធិករណ៍ ។ បណ្ដាអធិករណ៍ទាំងនោះ អធិករណ៍ដែលមិនចាត់ជាអាបត្តិ តើដូចម្ដេច ។ កិច្ចាធិករណ៍ ១ វិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ នេះហៅថា អធិករណ៍មិនមែនជាអាបត្តិ ។ បណ្ដាអធិករណ៍ទាំងនោះ អធិករណ៍ដែលចាត់ជាអធិករណ៍ផង ជាអាបត្តិផង តើដូចម្ដេច ។ អាបត្តាធិករណ៍ចាត់ជាអធិករណ៍ផង ជាអាបត្តិផង ។

(៨៦) (សំដែងអំពី) កិច្ចចាត់ជាកិច្ចាធិករណ៍ កិច្ចមិនមែនជាអធិករណ៍ អធិករណ៍មិនមែនជាកិច្ច ជាអធិករណ៍ផង កិច្ចផង ។ កិច្ចចាត់ជាកិច្ចាធិករណ៍ក៏មាន កិច្ចមិនមែនជាអធិករណ៍ក៏មាន អធិករណ៍មិនមែនជាកិច្ចក៏មាន ជាអធិករណ៍ផង កិច្ចផងក៏មាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៨៧) តត្ថ កតមំ កិច្ចំ កិច្ចាធិករណំ ។ យា សង្ឃស្ស កិច្ចយតា ករណីយតា អបលោកនកម្មំ ញត្តិកម្មំ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ឥទំ កិច្ចំ កិច្ចាធិករណំ ។ តត្ថ កតមំ កិច្ចំ នោ អធិករណំ ។ អាចរិយកិច្ចំ ឧបជ្ឈាយកិច្ចំ សមានុបជ្ឈាយកិច្ចំ សមានាចរិយកិច្ចំ ឥទំ កិច្ចំ នោ អធិករណំ ។ តត្ថ កតមំ អធិករណំ នោ កិច្ចំ ។ វិវាទាធិករណំ អនុវាទាធិករណំ អាបត្តាធិករណំ ឥទំ អធិករណំ នោ កិច្ចំ ។ តត្ថ កតមំ អធិករណញ្ចេវ កិច្ចញ្ច ។ កិច្ចាធិករណំ អធិករណញ្ចេវ កិច្ចញ្ច ។

(៨៨) វិវាទាធិករណំ កតីហិ សមថេហិ សម្មតិ ។ វិវាទាធិករណំ ទ្វីហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច យេភុយ្យសិកាយ ច ។ សិយា វិវាទាធិករណំ ឯកំ សមថំ អនាគម្ម យេភុយ្យសិកំ ឯកេន សមថេន សម្មេយ្យ សម្មុខាវិនយេនាតិ ។ សិយាតិស្ស វចនីយំ ។ យថាកថំ វិយ ។ ឥធ បន ភិក្ខូ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៨៧) បណ្ដាអធិករណ៍ទាំងនោះ កិច្ចដែលចាត់ជាកិច្ចាធិករណ៍ តើដូចម្ដេច ។ កិច្ច ឬកម្មណាដែលសង្ឃគប្បីធ្វើ គឺ អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម ទាំងនេះហៅថា កិច្ចដែលចាត់ជាកិច្ចាធិករណ៍ ។ បណ្ដាអធិករណ៍ទាំងនោះ កិច្ចដែលមិនមែនជាអធិករណ៍ តើដូចម្ដេច ។ អាចរិយកិច្ច ឧបជ្ឈាយកិច្ច សមានុបជ្ឈាយកិច្ច សមានាចរិយកិច្ច ទាំងនេះហៅថា កិច្ចមិនមែនជាអធិករណ៍ ។ បណ្ដាអធិករណ៍ទាំងនោះ អធិករណ៍មិនមែនជាកិច្ច តើដូចម្ដេច ។ វិវាទាធិករណ៍ អនុវាទាធិករណ៍ អាបត្តាធិករណ៍ នេះហៅថា អធិករណ៍មិនមែនជាកិច្ច ។ បណ្ដាអធិករណ៍ទាំងនោះ អធិករណ៍ដែលចាត់ជាអធិករណ៍ផង ជាកិច្ចផង តើដូចម្ដេច ។ កិច្ចាធិករណ៍ ចាត់ជាអធិករណ៍ផង ជាកិច្ចផង ។

(៨៨) វិវាទាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ វិវាទាធិករណ៍រម្ងាប់ដោយសមថៈពីរយ៉ាង គឺ សម្មុខាវិន័យ ១ យេភុយ្យសិកា ១ ។ វិវាទាធិករណ៍មិនអាស្រ័យសមថៈ១ គឺ យេភុយ្យសិកា គ្រាន់តែរម្ងាប់ដោយសមថៈតែ ១ គឺ សម្មុខាវិន័យក៏មាន ។ ពាក្យដែលបណ្ឌិតគប្បីពោលថា ក៏មានដូច្នេះ ។ ពាក្យនោះតើដូចសំដែងត្រង់ចំណុណា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ភិក្ខូ វិវទន្តិ ធម្មោតិ វា អធម្មោតិ វា វិនយោតិ វា អវិនយោតិ វា ភាសិតំ លបិតំ តថាគតេនាតិ វា អភាសិតំ អលបិតំ តថាគតេនាតិ វា អាចិណ្ណំ តថាគតេនាតិ វា អនាចិណ្ណំ តថាគតេនាតិ វា បញ្ញត្តំ តថាគតេនាតិ វា អប្បញ្ញត្តំ តថាគតេនាតិ វា អាបត្តីតិ វា អនាបត្តីតិ វា លហុកា អាបត្តីតិ វា គរុកា អាបត្តីតិ វា សាវសេសា អាបត្តីតិ វា អនវសេសា អាបត្តីតិ វា ទុដ្ឋុល្លា អាបត្តីតិ វា អទុដ្ឋុល្លា អាបត្តីតិ វា តេ ចេ ភិក្ខវេ ភិក្ខូ សក្កោន្តិ តំ អធិករណំ វូបសមេតុំ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ កា ច តត្ថ សង្ឃសម្មុខតា ។ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ពួកភិក្ខុក្នុងសាសនានេះជជែកគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី នេះជាវិន័យក្តី នេះមិនមែនជាវិន័យក្តី នេះជាពាក្យដែលព្រះតថាគតបាន ទ្រង់ត្រាស់សំដែងទុកក្តី នេះមិនមែនជាពាក្យដែលព្រះតថាគតទ្រង់ត្រាស់ សំដែងទុកមកទេក្តី នេះជាកិច្ចដែលព្រះតថាគត ទ្រង់ប្រព្រឹត្តសន្សំទុកក្តី នេះមិនមែនជាកិច្ចដែលព្រះតថាគតទ្រង់ប្រព្រឹត្តសន្សំមកទេក្តី នេះជាពាក្យ ដែលព្រះតថាគតទ្រង់បញ្ញត្តក្តី នេះមិនមែនជាពាក្យដែលព្រះតថាគតទ្រង់ បញ្ញត្តទេក្តី នេះជាអាបត្តិក្តី នេះមិនមែនជាអាបត្តិក្តី នេះជាអាបត្តិស្រាលក្តី នេះជាអាបត្តិធ្ងន់ក្តី នេះជាអាបត្តិមានចំណែកសេសសល់ក្តី នេះជាអាបត្តិ មិនមានចំណែកសេសសល់ក្តី នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិ អាក្រក់ក្តី ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះអាចរម្ងាប់អធិករណ៍នោះ បាន ម្នាលភិក្ខុទាំងឡាយ នេះហើយដែលតថាគតហៅថា អធិករណ៍ រម្ងាប់ ។ អធិករណ៍នោះរម្ងាប់ដោយអ្វី ។ អធិករណ៍នោះរម្ងាប់ដោយ សម្មុខាវិន័យ ។ ក្នុងសម្មុខាវិន័យនោះមានអង្គប៉ុន្មាន ។ ការចំពោះមុខ សង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គ ក្នុងសម្មុខាវិន័យនោះ) ។ ការចំពោះមុខសង្ឃក្នុងសម្មុខាវិន័យនោះ តើដូច ម្តេច ។ ពួកភិក្ខុមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះក៏បានមក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា ន បដិក្កោសន្តិ អយំ តត្ថ សង្ឃសម្មុខតា ។ កា ច តត្ថ ធម្មសម្មុខតា វិនយសម្មុខតា ។ យេន ធម្មេន យេន វិនយេន យេន សត្ថុសាសនេន តំ អធិករណំ វូបសម្មតិ អយំ តត្ថ ធម្មសម្មុខតា វិនយសម្មុខតា ។ កា ច តត្ថ បុគ្គលសម្មុខតា ។ យោ ច វិវទតិ យេន ច វិវទតិ ឧភោ អត្តប្បច្ចត្ថិកា[១] សម្មុខីភូតា ហោន្តិ អយំ តត្ថ បុគ្គលសម្មុខតា ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឆន្ទទាយកោ ខីយតិ ខីយនកំ បាចិត្តិយំ ។

(៨៩) តេ ចេ ភិក្ខវេ ភិក្ខូ ន សក្កោន្តិ តំ អធិករណំ តស្មឹ អាវាសេ វូបសមេតុំ តេហិ ភិក្ខវេ ភិក្ខូហិ យស្មឹ អាវាសេ ពហុតរា[២] ភិក្ខូ សោ អាវាសោ គន្តព្វោ ។ តេ ចេ ភិក្ខវេ ភិក្ខូ តំ អាវាសំ គច្ឆន្តា អន្តរាមគ្គេ សក្កោន្តិ តំ អធិករណំ វូបសមេតុំ

១ ឱ. អត្ថប្បច្ចត្ថិកា ។ ២ ម. សម្ពហុលា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏បាននាំមកហើយ ភិក្ខុទាំងឡាយមកប្រជុំចំពោះមុខ មិនឃាត់ឃាម នេះហៅថា ការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ ។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ។ អធិករណ៍នោះរម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា នេះហៅថា ចំពោះមុខធម៌ ចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ ឯការចំពោះមុខបុគ្គលក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ។ បុគ្គលណាទាស់ទែងគ្នាទៅវិញទៅមក បុគ្គលទាំងពីរនេះជាសត្រូវនឹងគ្នា មាននៅក្នុងទីចំពោះមុខ នេះហៅថា ចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ មានភិក្ខុអ្នកធ្វើត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ (ត្រូវអាបត្តិបាចិត្តិយៈព្រោះរើរុស) ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ (ត្រូវអាបត្តិបាចិត្តិយៈព្រោះតិះដៀល) ។

(៨៩) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះមិនអាចរម្ងាប់អធិករណ៍នោះក្នុងអាវាសនោះបានទេ ម្នាលភិក្ខុទាំងឡាយ (បើ) អាវាសណាមានភិក្ខុច្រើនក្រាស់ក្រែល ត្រូវភិក្ខុទាំងនោះទៅរកអាវាសនោះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះកំពុងទៅរកអាវាសនោះ អាចរម្ងាប់អធិករណ៍

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូប-
សន្តំ ។ សម្មុខាវិនយេន ។ កិញ្ច តត្ថ សម្មុខាវិន-
យស្មឹ ។ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា
បុគ្គលសម្មុខតា ។ កា ច តត្ថ សង្ឃសម្មុខតា ។ យាវ-
តិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ
ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា ន បដិក្កោសន្តិ
អយំ តត្ថ សង្ឃសម្មុខតា ។ កា ច តត្ថ ធម្មសម្មុ-
ខតា វិនយសម្មុខតា ។ យេន ធម្មេន យេន វិនយេន
យេន សត្ថុសាសនេន តំ អធិករណំ វូបសម្មតិ អយំ
តត្ថ ធម្មសម្មុខតា វិនយសម្មុខតា ។ កា ច តត្ថ
បុគ្គលសម្មុខតា ។ យោ ច វិវទតិ យេន ច វិវទតិ
ឧភោ អត្ថប្បច្ចត្ថិកា សម្មុខីភូតា ហោន្តិ អយំ តត្ថ
បុគ្គលសម្មុខតា ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នោះក្នុងកណ្តាលផ្លូវបាន ម្នាលភិក្ខុទាំងឡាយ នេះទើបគប្បីហៅថា អធិករណ៍រម្ងាប់ ៗ អធិករណ៍នោះរម្ងាប់ដោយធម៌ ដូចម្តេច ៗ រម្ងាប់ដោយសម្មុខាវិន័យ ៗ ចុះក្នុងសម្មុខាវិន័យនោះមានអង្គប៉ុន្មាន ៗ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ) ៗ ក៏ការចំពោះមុខសង្ឃក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ៗ ពួកភិក្ខុមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះក៏បានមក ទាំងឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈក៏បាននាំមក ភិក្ខុទាំងឡាយមានក្នុងទីចំពោះមុខ ក៏មិនបានហាមឃាត់ នេះហៅថា ការចំពោះមុខសង្ឃក្នុងសម្មុខាវិន័យនោះ ៗ ឯការចំពោះមុខធម៌ ការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ៗ អធិករណ៍នោះរម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា នេះហៅថា ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ ៗ ឯការចំពោះមុខបុគ្គលក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ៗ បុគ្គលណាទាស់ទែងគ្នាទៅវិញទៅមក បុគ្គលទាំងពីររូបជាសត្រូវនឹងគ្នា មានក្នុងទីចំពោះមុខ នេះហៅថា ការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ ៗ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់ យ៉ាងនេះហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឆន្ទទាយកោ ខីយតិ ខីយនកំ បាចិត្តិយំ ។

[៩០] តេ ចេ ភិក្ខវេ ភិក្ខូ តំ អាវាសំ គច្ឆន្តា អន្តរាមគ្គេ ច សក្កោន្តិ តំ អធិករណំ វូបសមេតុំ តេហិ ភិក្ខវេ ភិក្ខូហិ តំ អាវាសំ គន្ត្វា អាវាសិកា ភិក្ខូ ឯវមស្សុ វចនីយា ឥទំ ខោ អាវុសោ អធិករណំ ឯវំជាតំ ឯវំសមុប្បន្នំ សាធាយស្មន្តោ(១) ឥមំ អធិករណំ វូបសមេថ ធម្មេន វិនយេន សត្ថុសាសនេន យថាយិទំ អធិករណំ សុវូបសន្តំ អស្សាតិ ។ សចេ ភិក្ខវេ អាវាសិកា ភិក្ខូ វុឌ្ឍតរា ហោន្តិ អាគន្តុកា ភិក្ខូ នវកតរា តេហិ ភិក្ខវេ អាវាសិកេហិ ភិក្ខូហិ អាគន្តុកា ភិក្ខូ ឯវមស្សុ វចនីយា ឥង្ឃ តុម្ហេ អាយស្មន្តោ មុហុត្តំ ឯកមន្តំ ហោថ យាវ មយំ មន្តេមាតិ ។ សចេ បន ភិក្ខវេ អាវាសិកា ភិក្ខូ នវកតរា ហោន្តិ អាគន្តុកា ភិក្ខូ វុឌ្ឍតរា តេហិ ភិក្ខវេ អាវាសិកេហិ ភិក្ខូហិ អាគន្តុកា ភិក្ខូ ឯវមស្សុ វចនីយា តេនហិ តុម្ហេ

---

១ ឱ. សាធាយស្មន្តា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មានភិក្ខុអ្នកធ្វើត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។ ភិក្ខុអ្នកធ្វើឲ្យឆន្ទៈហើយត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ ។

(៩០) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះកំពុងទៅកាន់អាវាសនោះមិនអាចរម្ងាប់អធិករណ៍ ក្នុងកណ្ដាលផ្លូវបានទេ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងនោះទៅកាន់អាវាសនោះហើយ ពោលយ៉ាងនេះនឹងភិក្ខុទាំងឡាយជាម្ចាស់អាវាសថា ម្នាលលោកទាំងឡាយមានអាយុ អធិករណ៍នេះកើតប្រាកដយ៉ាងនេះហើយ សូមលោកមានអាយុទាំងឡាយរម្ងាប់អធិករ-ណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ដោយប្រពៃ តាមដំណើរដែលអធិករណ៍នេះស្ងប់រម្ងាប់ទៅដោយប្រពៃចុះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុជាម្ចាស់អាវាសចាស់ជាង ពួកភិក្ខុជាអាគន្តុកៈខ្ចីជាង ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុជាម្ចាស់អាវាសទាំងនោះនិយាយទៅនឹងពួកភិក្ខុជាអាគន្តុកៈយ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ បើដូច្នោះចូរលោកទាំងឡាយនៅរង់ចាំ ក្នុងទីសមគួរមួយរំពេចសិន ទំរាំយើងទាំងឡាយប្រឹក្សាគ្នា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកភិក្ខុជាម្ចាស់អាវាសខ្ចីជាង ពួកភិក្ខុជាអាគន្តុកៈចាស់ជាង ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុជាម្ចាស់អាវាសទាំងនោះនិយាយទៅនឹងពួកភិក្ខុជាអាគន្តុកៈ យ៉ាងនេះថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាយស្មន្តា មុហុត្តំ វិនេវ តាវ(១) ហោថ យាវ មយំ មន្តេមាតិ ។ សចេ(២) ភិក្ខវេ អាវាសិកានំ ភិក្ខូនំ មន្តយមានានំ ឯវំ ហោតិ ន មយំ សក្កោម ឥមំ អធិករណំ វូបសមេតុំ ធម្មេន វិនយេន សត្ថុសាសនេនាតិ ន តំ អធិករណំ អាវាសិកេហិ ភិក្ខូហិ(៣)បដិច្ឆិតព្វំ ។ សចេ បន ភិក្ខវេ អាវាសិកានំ ភិក្ខូនំ មន្តយមានានំ ឯវំ ហោតិ សក្កោម មយំ ឥមំ អធិករណំ វូបសមេតុំ ធម្មេន វិនយេន សត្ថុសាសនេនាតិ តេហិ ភិក្ខវេ អាវាសិកេហិ ភិក្ខូហិ អាគន្តុកា ភិក្ខូ ឯវមស្សុ វចនីយា សចេ តុម្ហេ អាយស្មន្តោ អម្ហាកំ ឥមំ អធិករណំ យថាជាតំ យថាសមុប្បន្នំ អាចិក្ខិស្សថ យថា ច មយំ ឥមំ អធិករណំ វូបសមេស្សាម ធម្មេន វិនយេន សត្ថុសាសនេន តថា សុវូបសន្តំ ភវិស្សតិ

---

១ ឱ. ហោន្តុកេ តាវសទ្ទោ ន ទិស្សតិ ។ ២ ម. សចេ បន ។ ៣ ឱ. ម. ហោន្តុកេសុ អាវាសិកេហិ ភិក្ខូហីតិ បទទ្វយំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ម្នាលលោកមានអាយុទាំងឡាយ បើដូច្នោះចូរលោកទាំងឡាយនៅរង់ចាំក្នុងទីនេះមួយរំពេចសិន ទំរាំយើងទាំងឡាយប្រឹក្សាគ្នា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកភិក្ខុជាម្ចាស់អាវាស កំពុងប្រឹក្សាគ្នាមានសេចក្តីត្រិះរិះយ៉ាងនេះថា យើងទាំងឡាយមិនអាច នឹងរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាបានទេ អធិករណ៍នោះ ភិក្ខុជាម្ចាស់អាវាសទាំងឡាយមិនត្រូវទទួលទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកភិក្ខុជាម្ចាស់អាវាស កំពុងប្រឹក្សាគ្នាមានសេចក្តីត្រិះរិះយ៉ាងនេះថា យើងទាំងឡាយអាចនឹងរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាបាន ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុជាម្ចាស់អាវាសនោះត្រូវនិយាយនឹងពួកភិក្ខុជាអាគន្តុកៈយ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ ប្រសិនបើលោកទាំងឡាយ ប្រាប់អធិករណ៍នេះ តាមរឿងដែលកើតប្រាកដហើយ ដល់យើងទាំងឡាយ យើងទាំងឡាយនឹងរម្ងាប់អធិករណ៍នេះ ឲ្យសមគួរតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាបាន អធិករណ៍មុខជានឹងរម្ងាប់បាន ដោយស្រួល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯវំ មយំ ឥមំ អធិករណំ បដិច្ឆិស្សាម[១] ។ នោ ចេ តុម្ហេ អាយស្មន្តោ អម្ហាកំ ឥមំ អធិករណំ យថាជាតំ យថាសមុប្បន្នំ អារោចេស្សថ យថា ច មយំ ឥមំ អធិករណំ វូបសមេស្សាម ធម្មេន វិនយេន សត្ថុសាសនេន តថា ន សុវូបសន្តំ ភវិស្សតិ ន មយំ ឥមំ អធិករណំ បដិច្ឆិស្សាមាតិ ។ ឯវំ សុបរិគ្គហិតំ ខោ ភិក្ខវេ កត្វា អាវាសិកេហិ ភិក្ខូហិ តំ អធិករណំ បដិច្ឆិតព្វំ ។ តេហិ ភិក្ខវេ អាគន្តុកេហិ ភិក្ខូហិ អាវាសិកា ភិក្ខូ ឯវមស្សុ វចនីយា យថាជាតំ យថាសមុប្បន្នំ ខោ[២] មយំ ឥមំ អធិករណំ អាយស្មន្តានំ អារោចេស្សាម សចេ អាយស្មន្តោ[៣] សក្កោន្តិ ឯត្តកេន វា ឯត្តកេន វា[៤] អន្តរេន ឥមំ អធិករណំ វូបសមេតុំ ធម្មេន វិនយេន សត្ថុសាសនេន តថា សុវូបសន្តំ ភវិស្សតិ ឯវំ មយំ ឥមំ អធិករណំ អាយស្មន្តានំ និយ្យាទេស្សាម

---

១ ម. សម្បដិច្ឆិស្សាម ។ ២ ឱ. ម. បោត្ថកេសុ ខោសទ្ទោ នត្ថិ ។ ៣ ឱ. អាយស្មន្តា ។
៤ ឱ. ម. បោត្ថកេសុ អាមេឌិតវចនំ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បើយ៉ាងនេះ ទើបយើងទាំងឡាយនឹងទទួលអធិករណ៍នេះ ។ ម្នាលលោកមានអាយុទាំងឡាយ ប្រសិនបើលោកទាំងឡាយ មិនប្រាប់អធិករណ៍នេះ តាមរឿងដែលកើតប្រាកដ ដល់យើងទាំងឡាយទេ ចំណែកខាងយើងទាំងឡាយនឹងរម្ងាប់អធិករណ៍នេះឲ្យសមគួរ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា អធិករណ៍នោះមុខជាមិនបានរម្ងាប់ ដោយល្អឡើយ យើងទាំងឡាយមិនព្រមទទួលអធិករណ៍នេះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុជាម្ចាស់អាវាសធ្វើសេចក្តីកំណត់ឲ្យស្រួលបួលយ៉ាងនេះ រួចហើយត្រូវទទួលអធិករណ៍នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុជាអាគន្តុកៈនោះត្រូវនិយាយទៅនឹងពួកភិក្ខុជាម្ចាស់អាវាសយ៉ាងនេះថា យើងទាំងឡាយនឹងប្រាប់អធិករណ៍នេះ តាមរឿងដែលកើតប្រាកដ ដល់លោកមានអាយុទាំងឡាយ ប្រសិនបើលោកមានអាយុទាំងឡាយ អាចនឹងរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ដោយហេតុមានប្រមាណប៉ុណ្ណេះក្តី ។ អធិករណ៍នោះមុខជានឹងរម្ងាប់ដោយល្អ បើយ៉ាងនេះទើបយើងទាំងឡាយនឹងប្រគល់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នោ ចេ អាយស្មន្តោ សក្កោន្តិ ឯត្តកេន វា ឯត្តកេន វា អន្តរេន ឥមំ អធិករណំ វូបសមេតុំ ធម្មេន វិនយេន សត្ថុសាសនេន តថា ន សុវូបសន្តំ ភវិស្សតិ ន មយំ ឥមំ អធិករណំ អាយស្មន្តានំ និយ្យាតេស្សាម មយមេវ ឥមស្ស អធិករណស្ស សាមិនោ ភវិស្សាមាតិ ។ ឯវំ សុបរិគ្គហិតំ ខោ ភិក្ខវេ កត្វា អាគន្តុកេហិ ភិក្ខូហិ តំ អធិករណំ អាវាសិកានំ ភិក្ខូនំ និយ្យាតេតព្វំ ។ តេ ចេ ភិក្ខវេ ភិក្ខូ សក្កោន្តិ តំ អធិករណំ វូបសមេតុំ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ បេ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឆន្ទទាយកោ ខីយតិ ខីយនកំ បាចិត្តិយំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អធិករណ៍នេះ ឲ្យលោកមានអាយុទាំងឡាយ បើលោកមានអាយុទាំងឡាយមិនអាចនឹងរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ដោយហេតុមានប្រមាណប៉ុណ្ណេះក្តី ។ អធិករណ៍នោះ ក៏មុខជានឹងមិនរម្ងាប់ ដោយប្រពៃឡើយ យើងទាំងឡាយនឹងមិនប្រគល់អធិករណ៍នេះឲ្យលោកមានអាយុទាំងឡាយទេ យើងទាំងឡាយនឹងជាម្ចាស់អធិករណ៍នេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុជាអាគន្តុកៈធ្វើសេចក្តីកំណត់ឲ្យស្រួលបួលយ៉ាងនេះ រួចហើយសឹមប្រគល់អធិករណ៍នោះដល់ពួកភិក្ខុជាម្ចាស់វត្តចុះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនោះអាចនឹងរម្ងាប់អធិករណ៍នោះបាន ម្នាលភិក្ខុទាំងឡាយ នេះទើបតថាគតហៅថា អធិករណ៍រម្ងាប់បានដោយស្រួលល្អ ។ អធិករណ៍នោះរម្ងាប់បានដោយអ្វី ។ រម្ងាប់បានដោយសម្មុខាវិន័យ ។ ក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេចខ្លះ ។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ) ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់ស៊ើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។ ភិក្ខុអ្នកឲ្យឆន្ទៈ ហើយត្រឡប់តិះដៀលត្រូវខីយនកបាចិត្តិយៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៩១) តេហិ ចេ ភិក្ខវេ ភិក្ខូហិ តស្មឹ អធិករណេ វិនិច្ឆិយមានេ អនន្តានិ(១) ចេវ ភស្សានិ ជាយន្តិ ន ចេតស្ស(២) ភាសិតស្ស អត្ថោ វិញ្ញាយតិ អនុជានាមិ ភិក្ខវេ ឯវរូបំ អធិករណំ ឧព្វាហិកាយ វូបសមេតុំ ។ ទសហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ(៣) អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ(៤) កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធាតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ

---

១ ម. អនគ្គានិ ។ ២ ម. នចេតស្ស ។ ៣ ម. អាចារសម្បន្នោ ។ ៤ សាត្ថា សព្យញ្ជនា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៩១) ម្នាលភិក្ខុទាំងឡាយ កាលបើអធិករណ៍នោះ ភិក្ខុទាំងឡាយនោះកំពុងវិនិច្ឆ័យ ក៏មានពាក្យច្រើនអឺងអាំងមិនមានទីបំផុត គឺមិនចេះអស់ មិនចេះហើយកើតឡើងផង ទាំងសេចក្តីអធិប្បាយនៃភាសិតនុ៎ះ ក៏មិនមានខ្លឹមសារណាជាច្បាស់ផង ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យរម្ងាប់អធិករណ៍បែបនេះដោយឧព្វាហិកា[១]កម្មវាចា ។ សង្ឃគប្បីសន្មតភិក្ខុដែលប្រកបដោយអង្គ ១០ ប្រការ ដោយឧព្វាហិកាកម្មវាចា (ឯអង្គ ១០ ប្រការនោះ) គឺ ភិក្ខុជាអ្នកមានសីល ១ សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ១ ឃើញភ័យក្នុងទោសបន្តិចបន្តួចហើយសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូតទ្រទ្រង់នូវពុទ្ធវចនៈ ជាអ្នកសន្សំនូវពុទ្ធវចនៈ ១ ធម៌ណាដែលមានពីរោះបទខាងដើម ពីរោះបទកណ្តាល ពីរោះបទចុង ពោលសរសើរព្រហ្មចរិយធម៌ ព្រមទាំងអត្ថទាំងព្យញ្ជនៈ ឲ្យបរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយ មានសភាពយ៉ាងនេះ ភិក្ខុនោះក៏បានស្តាប់ច្រើន បានចាំទុក បានសន្សំទុកដោយវាចា ( ស្ទាត់ជំនាញ ) ជាក់ច្បាស់ក្នុងចិត្ត ត្រាស់ដឹងល្អដោយទិដ្ឋិ ១ មិនតែប៉ុណ្ណោះឡើយ បាតិមោក្ខទាំងពីរយ៉ាងក៏ភិក្ខុនោះចាំបានដោយពិស្តារ

១ អដ្ឋកថា ថា ត្រូវសង្ឃអបលោកហើយសន្មត ឬសន្មតដោយញត្តិទុតិយកម្មវាចា ឯភិក្ខុដែលសង្ឃសន្មតយ៉ាងនេះហើយត្រូវទៅអង្គុយផ្សេងគ្នា ភិក្ខុឯទៀតប្រកាសដល់បរិសទ្យនោះថា អ្នកទាំងឡាយកុំនិយាយអ្វីឡើយ ហើយសឹមវិនិច្ឆ័យអធិករណ៍នោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ[១] អនុព្យញ្ជនសោ វិនយេ ខោ បន ឋិតោ[២] ហោតិ អសំហីរោ បដិពលោ ហោតិ ឧភោ អត្ថប្បច្ចត្ថិកេ សញ្ញាបេតុំ និជ្ឈាបេតុំ បេក្ខេតុំ បស្សិតុំ បសាទេតុំ អធិករណសមុប្បាទំ វូបសមេតុំ កុសលោ[៣] ហោតិ អធិករណំ ជានាតិ អធិករណសមុទយំ ជានាតិ អធិករណនិរោធំ ជានាតិ អធិករណនិរោធគាមិនិំ បដិបទំ ជានាតិ អនុជានាមិ ភិក្ខវេ ឥមេហិ ទសហង្គេហិ សមន្នាគតំ ភិក្ខុំ ឧព្វាហិកាយ សម្មន្និតុំ ។

(៩២) ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ឥមស្មឹ អធិករណេ វិនិច្ឆិយមានេ អនន្តានិ ចេវ ភស្សានិ ជាយន្តិ ន ចេកស្ស ភាសិតស្ស អត្ថោ វិញ្ញាយតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមញ្ច

---

១ ឱ. សុត្តតោ ។ ២ ឱ.ម. ឋិតោ ។ ៣ ឱ.ម. អធិករណសមុប្បាទវូបសមនកុសលោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ចេះវែកញែកស្រួល ចេះស្ទាត់ត្រង់មាត់ វិនិច្ឆ័យបានដោយល្អ តាមសុត្តៈ តាមអនុព្យញ្ជនៈ ១ ជាអ្នកខ្ជាប់ខ្ជួនឥតទើសទាល់ក្នុងផ្លូវវិន័យ ១ ជាអ្នកអង់អាចដើម្បីធ្វើបុគ្គលទាំងពីរ ដែលជាសត្រូវនឹងគ្នាឲ្យដឹងច្បាស់ ឲ្យពិនិត្យ ឲ្យពិចារណា ឲ្យឃើញ ឲ្យជ្រះថ្លាបាន១ ជាអ្នកឈ្លាសដើម្បីរម្ងាប់អធិករណ៍ដែលកើតឡើងហើយ ១ ស្គាល់អធិករណ៍ ស្គាល់ហេតុដែលឲ្យកើតអធិករណ៍ ស្គាល់ធម៌សម្រាប់រលត់អធិករណ៍ ទាំងស្គាល់ផ្លូវទៅកាន់ធម៌សម្រាប់រំលត់អធិករណ៍ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គទាំង ១០ ប្រការនេះ ដោយឧព្វាហិកាកម្ម ។

(៩២) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតភិក្ខុនោះយ៉ាងនេះ ។ សង្ឃត្រូវសូមភិក្ខុជាមុន លុះសូមរួចហើយ ភិក្ខុជាអ្នកឈ្លាសប្រតិពល គប្បីផ្ញៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ អធិករណ៍នេះ យើងទាំងឡាយកំពុងវិនិច្ឆ័យ ក៏មានពាក្យច្រើនអនេក មិនមានទីបំផុតកើតឡើង សេចក្តីអធិប្បាយនៃភាសិតនុ៎ះ ក៏មិនមាននរណាដឹងច្បាស់ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវសន្មតភិក្ខុឈ្មោះនេះផង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥត្ថន្នាមញ្ច ភិក្ខុំ សម្មន្នេយ្យ ឧព្វាហិកាយ ឥមំ អធិករណំ វូបសមេតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ឥមស្មឹ អធិករណេ វិនិច្ឆិយមានេ អនន្តានិ ចេវ ភស្សានិ ជាយន្តិ ន ចេតស្ស ភាសិតស្ស អត្ថោ វិញ្ញាយតិ ។ សង្ឃោ ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច ភិក្ខុំ សម្មន្នតិ ឧព្វាហិកាយ ឥមំ អធិករណំ វូបសមេតុំ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ច ឥត្ថន្នាមស្ស ច ភិក្ខុនោ សម្មតិ ឧព្វាហិកាយ ឥមំ អធិករណំ វូបសមេតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច ភិក្ខុ ឧព្វាហិកាយ ឥមំ អធិករណំ វូបសមេតុំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៩៣) តេ ចេ ភិក្ខវេ ភិក្ខូ សក្កោន្តិ តំ អធិករណំ ឧព្វាហិកាយ វូបសមេតុំ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឈ្មោះនេះផង ដើម្បីឲ្យរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកាកម្មវាចា ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ អធិករណ៍នេះយើងទាំងឡាយកំពុងវិនិច្ឆ័យ ក៏មានពាក្យច្រើនអឺងកង មិនមានទីបំផុតកើតឡើង សេចក្តីអធិប្បាយនៃភាសិតនុះ ក៏មិនមានទទណាដឹងច្បាស់ ។ សង្ឃសន្មតភិក្ខុឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យរម្ងាប់នូវអធិករណ៍នេះ ដោយឧព្វាហិកាកម្មវាចា ។ ការសន្មតិនូវភិក្ខុឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីរម្ងាប់នូវអធិករណ៍នេះ ដោយឧព្វាហិកាកម្មវាចា គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវពោលឡើង ។ ភិក្ខុឈ្មោះនេះផង ឈ្មោះនេះផង សង្ឃបានសន្មត ដើម្បីឲ្យរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកាកម្មវាចាហើយ ការសន្មតភិក្ខុដើម្បីឲ្យរម្ងាប់នូវអធិករណ៍នេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះអាចដើម្បីរម្ងាប់អធិករណ៍នោះ ដោយឧព្វាហិកាកម្មវាចាបាន ម្នាលភិក្ខុទាំងឡាយនេះទើបតថាគតហៅថាអធិករណ៍រម្ងាប់ហើយ ។ អធិករណ៍នោះរម្ងាប់ដោយធម៌អ្វី ។ រម្ងាប់ដោយសម្មុខាវិន័យ ។ ក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ បេ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។

(៩៤) តេហិ ចេ ភិក្ខវេ ភិក្ខូហិ តស្មឹ អធិករណេ វិនិច្ឆិយមានេ តត្រស្ស ភិក្ខុ ធម្មកថិកោ តស្ស នេវ សុត្តំ អាគតំ ហោតិ នោ សុត្តវិភង្គោ សោ អត្ថំ អសល្លក្ខេន្តោ ព្យញ្ជនច្ឆាយាយ អត្ថំ បដិពាហតិ ព្យត្តេន ភិក្ខុនា បដិពលេន តេ ភិក្ខូ ញាបេតព្វា សុណន្តុ មេ អាយស្មន្តា អយំ ឥត្ថន្នាមោ ភិក្ខុ ធម្មកថិកោ ឥមស្ស នេវ សុត្តំ អាគតំ ហោតិ(១) នោ សុត្តវិភង្គោ សោ អត្ថំ អសល្លក្ខេន្តោ ព្យញ្ជនច្ឆាយាយ អត្ថំ បដិពាហតិ ។ យទាយស្មន្តានំ បត្តកល្លំ ឥត្ថន្នាមំ ភិក្ខុំ វុដ្ឋាបេត្វា អវសេសា មយំ អធិករណំ វូបសមេយ្យាមាតិ ។ តេ ចេ ភិក្ខវេ ភិក្ខូ តំ ភិក្ខុំ វុដ្ឋាបេត្វា សក្កោន្តិ តំ អធិករណំ វូបសមេតុំ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។

១ ម. បោត្ថកេ ហោតិសទ្ទោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គនៃសម្មុខាវិន័យនោះ)។ បេ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។

(៩៤) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះកំពុងតែវិនិច្ឆ័យអធិក-រណ៍នោះ មានភិក្ខុជាធម្មកថិកនៅក្នុងបរិសទ្យនោះ មិនចាំសុត្តៈ (មាតិកា) មិនចាំសុត្តវិភង្គ (វិន័យ) ភិក្ខុនោះមិនបានកំណត់សេចក្តី ប្រកាន់យកតែព្យញ្ជនៈជាប្រមាណ ហើយត្រឡប់បដិសេធសេចក្តីចោលចេញ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវនិយាយបញ្ជាក់ភិក្ខុទាំងនោះថា លោកមានអាយុទាំងឡាយចូរប្រុងស្តាប់ខ្ញុំ ភិក្ខុជាធម្មកថិកឈ្មោះនេះ ។ មិនចាំសុត្តៈ មិនស្ទាត់សុត្តវិភង្គទេ ភិក្ខុជាធម្មកថិកនោះកំណត់សេចក្តីមិនបានទេ ប្រកាន់យកតែព្យញ្ជនៈជាប្រមាណ ហើយត្រឡប់បដិសេធសេចក្តីចោលចេញ ។ បើកម្មមានកាលគួរ ដល់លោកមានអាយុទាំងឡាយហើយ យើងទាំងឡាយជំរេស គប្បីឲ្យភិក្ខុឈ្មោះនេះក្រោកឡើង ហើយសឹមរម្ងាប់នូវអធិ-ករណ៍នេះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះឲ្យភិក្ខុនោះ ក្រោកឡើងហើយ អាចដើម្បីរម្ងាប់អធិករណ៍នោះបាន ម្នាលភិក្ខុទាំងឡាយ នេះទើបតថាគតហៅថាអធិករណ៍រម្ងាប់ ។ អធិករណ៍នោះរម្ងាប់ដោយធម៌អ្វី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សម្មុខាវិនយេន ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។បេ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។

(៩៨) ឥធ បន ភិក្ខវេ ភិក្ខូហិ តស្មឹ អធិក-រណេ វិនិច្ឆិយមានេ តត្រស្ស ភិក្ខុ ធម្មកថិកោ តស្ស សុត្តំ ហិ ខោ អាគតំ ហោតិ នោ សុត្តវិភង្គោ សោ អត្ថំ អសល្លក្ខេន្តោ ព្យញ្ជនច្ឆាយាយ អត្ថំ បដិពាហតិ ព្យត្តេន ភិក្ខុនា បដិពលេន តេ ភិក្ខូ ញាបេតព្វា សុ-ណន្តុ មេ អាយស្មន្តា អយំ ឥត្ថន្នាមោ ភិក្ខុ ធម្ម-កថិកោ ឥមស្ស សុត្តំ ហិ ខោ អាគតំ ហោតិ នោ សុត្តវិភង្គោ សោ អត្ថំ អសល្លក្ខេន្តោ ព្យញ្ជនច្ឆាយា-យ អត្ថំ បដិពាហតិ ។ យថាយស្មន្តានំ បត្តកល្លំ ឥត្ថន្នាមំ ភិក្ខុំ វុដ្ឋាបេត្វា អវសេសា ឥមំ អធិករណំ វូបសមេយ្យាថាតិ ។ តេ ចេ ភិក្ខវេ ភិក្ខូ តំ ភិក្ខុំ វុដ្ឋាបេត្វា សក្កោន្តិ តំ អធិករណំ វូបសមេតុំ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រម្ងាប់ដោយសម្មុខាវិន័យ ។ ចុះក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេច ។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គនៃសម្មុខាវិន័យនោះ) ។បេ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។

(៩៥) ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍នោះ ភិក្ខុទាំងឡាយនោះកំពុងតែវិនិច្ឆ័យ មានភិក្ខុជាធម្មកថិកក្នុងបរិសទ្យនោះ ជាអ្នកចាំសូត្រ តែមិនចាំសុត្តវិភង្គ ភិក្ខុនោះកំណត់សេចក្តីមិនបាន ប្រកាន់យកតែព្យញ្ជនៈជាប្រមាណ ហើយត្រឡប់បដិសេធសេចក្តីចោលចេញ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវនិយាយបញ្ជាក់ភិក្ខុទាំងនោះថា សូមលោកមានអាយុទាំងឡាយស្តាប់ខ្ញុំ (ផង) ភិក្ខុជាធម្មកថិកឈ្មោះនេះ ១ លោកជាអ្នកចាំសុត្តៈ តែមិនចាំសុត្តវិភង្គទេ លោកកំណត់សេចក្តីមិនបាន ប្រកាន់យកតែព្យញ្ជនៈជាប្រមាណ ហើយត្រឡប់បដិសេធសេចក្តីចោលចេញ ។ បើកម្មមានកាលគួរដល់លោកដ៏មានអាយុទាំងឡាយហើយ យើងទាំងឡាយដ៏សេស គប្បីញ៉ាំងភិក្ខុឈ្មោះនេះឲ្យក្រោកចេញ ហើយសឹមរម្ងាប់អធិករណ៍នេះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះបានឲ្យភិក្ខុនោះក្រោកចេញ ហើយអាចដើម្បីនឹងរម្ងាប់អធិករណ៍នោះបាន ម្នាលភិក្ខុទាំងឡាយ នេះទើបគប្បីគេហៅថា អធិករណ៍រម្ងាប់ហើយ ។ អធិករណ៍នោះរម្ងាប់ ដោយធម៌អ្វី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សម្មុខាវិនយេន ។ កា ច តត្ថ សម្មុខាវិនយស្មឹ ។ ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។បេ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។

[៩៦] តេ ចេ ភិក្ខវេ ភិក្ខូ ន សក្កោន្តិ តំ អធិករណំ ឧព្ពាហិកាយ វូបសមេតុំ តេហិ ភិក្ខវេ ភិក្ខូហិ តំ អធិករណំ សង្ឃស្ស និយ្យាតេតព្វំ ន មយំ ភន្តេ សក្កោម ឥមំ អធិករណំ ឧព្ពាហិកាយ វូបសមេតុំ សង្ឃោវ ឥមំ អធិករណំ វូបសមេតូតិ ។ អនុជានាមិ ភិក្ខវេ ឯវរូបំ អធិករណំ យេភុយ្យសិកាយ វូបសមេតុំ ។ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ សលាកគ្គាហាបកោ សម្មន្និតព្វោ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ គហិតាគហិតញ្ច ជានេយ្យ ។បេ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ សលាកគ្គាហាបកោ ខមតិ សង្ឃស្ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រម្ងាប់ដោយសម្មុខាវិន័យ ។ ក៏គឺសម្មុខាវិន័យនោះ មានអង្គដូចម្តេច ។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គគឺសម្មុខាវិន័យនោះ) ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើគ្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។

(៩៦) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ មិនអាចដើម្បីនឹងរម្ងាប់អធិករណ៍នោះ ដោយឧព្វាហិកាកម្មបានទេ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងនោះ ប្រគល់អធិករណ៍នោះដល់សង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន យើងទាំងឡាយមិនអាចដើម្បីរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកាកម្មបានទេ សូមសង្ឃរម្ងាប់អធិករណ៍នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីរម្ងាប់អធិករណ៍បែបនេះ ដោយយេភុយ្យសិកាវិញ ។ សង្ឃត្រូវសន្មតភិក្ខុប្រកបដោយអង្គ ៥ ប្រការឲ្យជាសលាកគ្គាហាបកៈ (អ្នកចែកស្លាក) គឺភិក្ខុណាមិនលំអៀងទៅខាងឆន្ទាគតិ ១ មិនលំអៀងទៅខាងទោសាគតិ ១ មិនលំអៀងទៅខាងមោហាគតិ ១ មិនលំអៀងទៅខាងភយាគតិ ១ ដឹងស្លាកដែលគេបានចាប់និងមិនបានចាប់ ១ ។ បេ ។ ភិក្ខុឈ្មោះនេះសង្ឃបានសន្មតឲ្យជាសលាកគ្គាហាបកៈ ការសន្មតគួរដល់សង្ឃ ហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ តេន សលាកគ្គាហាបកេន ភិក្ខុនា សលាកា គាហាបេតព្វា(១) ។ យថា ពហុតរា ភិក្ខូ ធម្មវាទិនោ វទន្តិ តថា តំ អធិករណំ វូបសមេតព្វំ ។ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ច យេភុយ្យសិកាយ ច ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ កា ច តត្ថ សង្ឃសម្មុខតា ។ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា ន បដិក្កោសន្តិ អយំ តត្ថ សង្ឃសម្មុខតា ។ កា ច តត្ថ ធម្មសម្មុខតា វិនយសម្មុខតា ។ យេន ធម្មេន យេន វិនយេន យេន សត្ថុសាសនេន តំ អធិករណំ វូបសម្មតិ អយំ តត្ថ ធម្មសម្មុខតា វិនយសម្មុខតា ។ កា ច តត្ថ បុគ្គលសម្មុខតា ។ យោ

១ ឱ. ម. គាហេតព្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។ សលាកគ្គាហាបកភិក្ខុនោះ គប្បីឲ្យភិក្ខុទាំងឡាយចាប់ស្លាកចុះ ។ (បើ) ភិក្ខុទាំងឡាយជាធម្មវាទីមានចំនួនច្រើនជាងពោលឡើងយ៉ាងណា សង្ឃត្រូវរម្ងាប់អធិករណ៍នោះយ៉ាងនោះចុះ ម្នាលភិក្ខុទាំងឡាយ នេះទើបតថាគតហៅថាអធិករណ៍រម្ងាប់ ។ អធិករណ៍នោះរម្ងាប់ដោយធម៌អ្វី ។ រម្ងាប់ដោយសម្មុខាវិន័យនិងយេភុយ្យសិកា ។ ចុះក្នុងសម្មុខាវិន័យនោះមានអង្គដូចម្តេច ។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ) ក៏ការចំពោះមុខសង្ឃក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ។ ពួកភិក្ខុមានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះក៏បានមក ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយ ភិក្ខុទាំងឡាយដែលមាននៅក្នុងទីចំពោះមុខ ក៏មិនបានហាមឃាត់ នេះហៅថា ការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ ។ ឯការចំពោះមុខធម៌និងការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ។ អធិករណ៍នោះរម្ងាប់តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា នេះហៅថា ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ ។ ការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ។ ភិក្ខុណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ន វិវទតិ យេន ន វិវទតិ ឧភោ អត្តប្បច្ចត្ថិកា សម្មុខីភូតា ហោន្តិ អយំ តត្ថ បុគ្គលសម្មុខតា ។ កា ច តត្ថ យេភុយ្យសិកាយ ។ យា យេភុយ្យសិកាយ កម្មស្ស កិរិយា ករណំ ឧបគមនំ អជ្ឈុបគមនំ អធិវាសនា អប្បដិក្កោសនា អយំ តត្ថ យេភុយ្យសិកាយ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឆន្ទទាយកោ ខីយតិ ខីយនកំ បាចិត្តិយន្តិ ។

(៩៧) តេន ខោ បន សមយេន សាវត្ថិយា ឯវំជាតំ ឯវំសមុប្បន្នំ អធិករណំ ហោតិ ។ អថ ខោ តេ ភិក្ខូ អសន្តុដ្ឋា សាវត្ថិយា សង្ឃស្ស អធិករណវូបសមេន អស្សោសុំ ខោ អមុកស្មឹ កិរ អាវាសេ សម្ពហុលា ថេរា វិហរន្តិ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា បណ្ឌិតា វិយត្តា មេធាវិនោ លជ្ជិនោ កុក្កុច្ចកា សិក្ខាកាមា តេ ចេ ថេរា ឥមំ អធិករណំ វូបសមេយ្យុំ ធម្មេន វិនយេន សត្ថុសាសនេន ឯវយិមំ អធិករណំ សុវូបសន្តំ អស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពាស់វែងគ្នាទៅវិញទៅមក ភិក្ខុទាំងពីររូបនោះជាសត្រូវនឹងគ្នា ព្រោះការពាស់វែងគ្នា ក៏មានទៅក្នុងទីចំពោះមុខ នេះហៅថា ការចំពោះមុខបុគ្គលក្នុងសម្មុខាវិន័យនោះ ។ ក្នុងយេភុយ្យសិកាកម្មនោះ មានវិធីធ្វើដូចម្ដេច ។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅអែបនែប ការទទួលនឹងការមិនហាមឃាត់នូវយេភុយ្យសិកាកម្មណា នេះហៅថា វិធីធ្វើក្នុងយេភុយ្យសិកា-កម្មនោះ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយត្រឡប់តិះដៀលត្រូវខីយនកបាចិត្តិយៈ ។

(៩៧) សម័យនោះឯង ក្នុងក្រុងសាវត្ថី មានអធិករណ៍កើតប្រាកដយ៉ាងនេះឡើង ។ គ្រានោះឯង ភិក្ខុទាំងនោះជាអ្នកមិនត្រេកអរ ដោយវិធីរម្ងាប់អធិករណ៍របស់សង្ឃ ក្នុងក្រុងសាវត្ថីឡើយ ហើយបានឮដំណឹងថាមានព្រះថេរៈច្រើនអង្គ គង់នៅក្នុងអាវាសឯណោះ ជាពហុស្សូត ចេះចាំនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាអ្នកប្រាជ្ញវាងវៃ មានប្រាជ្ញា មានអៀនខ្មាស ជាអ្នកមានរង្កៀស ជាអ្នកប្រាថ្នាការសិក្សា បើព្រះថេរៈទាំងនោះរម្ងាប់អធិករណ៍នេះតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រ-ដៅរបស់ព្រះសាស្ដា យ៉ាងនេះទើបអធិករណ៍នេះរម្ងាប់បានដោយស្រួល ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អថខោ តេ ភិក្ខូ តំ អាវាសំ គន្ត្វា តេ ថេរេ ឯតទវោចុំ ឥទំ ភន្តេ អធិករណំ ឯវំជាតំ ឯវំសមុប្បន្នំ សាធុ ភន្តេ ថេរា ឥមំ អធិករណំ វូបសមេន្តុ ធម្មេន វិនយេន សត្ថុសាសនេន យថាយិទំ អធិករណំ សុវូបសន្តំ អស្សាតិ។ អថខោ តេ ថេរា យថា សាវត្ថិយា សង្ឃេន អធិករណំ វូបសមិតំ យថា សុវូបសន្តំ(១) តថា តំ អធិករណំ វូបសមេសុំ ។ អថខោ តេ ភិក្ខូ អសន្តុដ្ឋា សាវត្ថិយា សង្ឃស្ស អធិករណវូបសមនេន អសន្តុដ្ឋា សម្ពហុលានំ ថេរានំ អធិករណសុវូបសមនេន អស្សោសុំ ខោ អមុកស្មឹ កិរ អាវាសេ តយោ ថេរា វិហរន្តិ ។បេ។ ទ្វេ ថេរា វិហរន្តិ ។បេ។ ឯកោ ថេរោ វិហរតិ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ វិយត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ សោ ចេ ថេរោ ឥមំ អធិករណំ វូបសមេយ្យ

១ ឱ.ម. តថាសុវូបសន្តំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គ្រានោះឯង ភិក្ខុទាំងឡាយនោះ នាំគ្នាទៅកាន់អាវាសនោះហើយនិយាយពាក្យនុ៎ះនឹងព្រះថេរៈទាំងនោះថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន អធិករណ៍នេះកើតប្រាកដយ៉ាងនេះហើយ បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន យើងខ្ញុំសូមអង្វរ សូមព្រះថេរៈទាំងឡាយរម្ងាប់នូវអធិករណ៍នេះតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ដោយទំនងដែលអធិករណ៍នេះគប្បីរម្ងាប់បានដោយស្រួល ។ គ្រានោះឯង ព្រះថេរៈទាំងនោះបានរម្ងាប់អធិករណ៍ទាំងនោះ តាមទំនងដែលអធិករណ៍បានរម្ងាប់ដោយស្រួល ដូចជាអធិករណ៍ដែលសង្ឃបានរម្ងាប់ហើយ ក្នុងក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុទាំងឡាយនោះក៏នៅតែមិនត្រេកអរដោយការរម្ងាប់អធិករណ៍របស់សង្ឃ ក្នុងក្រុងសាវត្ថី ទាំងមិនត្រេកអរដោយការរម្ងាប់អធិករណ៍របស់ព្រះថេរៈទាំងឡាយច្រើនអង្គ បានឮដំណឹងថា ព្រះថេរៈទាំងឡាយបីអង្គគង់នៅក្នុងអាវាសឯណោះ ។ បេ ។ ព្រះថេរៈទាំងឡាយពីរអង្គគង់នៅ ។ បេ ។ ព្រះថេរៈមួយអង្គគង់នៅ (ក្នុងអាវាសឯណោះ) ជាពហុស្សុត ចេះចាំនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាអ្នកប្រាជ្ញ ជាអ្នកឈ្លាសវៃ មានប្រាជ្ញា មានអៀនខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាការសិក្សា ប្រសិនបើព្រះថេរៈអង្គនោះ គប្បីរម្ងាប់អធិករណ៍នេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សមថក្ខន្ធកេ ភិក្ខូ អធិករណវូបសមនេន អសន្តុដ្ឋា

ធម្មេន វិនយេន សត្ថុសាសនេន ឯវមិទំ អធិករណំ វូបសន្តំ អស្សាតិ ។ អថខោ តេ ភិក្ខូ តំ អាវាសំ គន្ត្វា តំ ថេរំ ឯតទវោចុំ ឥទំ ភន្តេ អធិករណំ ឯវំជាតំ ឯវំសមុប្បន្នំ សាធុ ភន្តេ ថេរោ ឥមំ អធិ-ករណំ វូបសមេតុ ធម្មេន វិនយេន សត្ថុសាសនេន យថាយិទំ អធិករណំ សុវូបសន្តំ អស្សាតិ ។ អថខោ សោ ថេរោ យថា សាវត្ថិយា សង្ឃេន អធិករណំ វូបសមិតំ យថា សម្ពហុលេហិ ថេរេហិ អធិករណំ វូបសមិតំ យថា តីហិ ថេរេហិ អធិករណំ វូបសមិតំ យថា ទ្វីហិ ថេរេហិ អធិករណំ វូបសមិតំ យថា-សុវូបសន្តំ[១] តថា តំ អធិករណំ វូបសមេសិ ។ អថខោ តេ ភិក្ខូ អសន្តុដ្ឋា សាវត្ថិយា សង្ឃស្ស អធិករណ-វូបសមនេន អសន្តុដ្ឋា សម្ពហុលានំ ថេរានំ អធិករ-ណវូបសមនេន អសន្តុដ្ឋា តិណ្ណំ ថេរានំ អធិករណវូប-សមនេន អសន្តុដ្ឋា ទ្វិន្នំ ថេរានំ អធិករណវូបសមនេន អសន្តុដ្ឋា ឯកស្ស ថេរស្ស អធិករណវូបសមនេន

១ ឱ. តថាសុវូបសន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា យ៉ាងនេះ ទើបអធិករណ៍នេះរម្ងាប់បានដោយស្រួល ៗ គ្រានោះឯង ភិក្ខុទាំងឡាយនោះបាននាំគ្នាទៅកាន់អាវាសនោះ ហើយនិយាយពាក្យនុ៎ះនឹងព្រះថេរៈនោះថា បពិត្រលោកម្ចាស់ដ៏ចំរើន អធិករណ៍នេះកើតប្រាកដយ៉ាងនេះ បពិត្រលោកម្ចាស់ដ៏ចំរើន យើងខ្ញុំសូមអង្វរ សូមព្រះថេរៈរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ដោយវិធីដែលអធិករណ៍នេះ គប្បីរម្ងាប់បានដោយស្រួល ៗ គ្រានោះឯង ព្រះថេរៈនោះក៏បានរម្ងាប់អធិករណ៍នោះ តាមវិធីដែលអធិករណ៍រម្ងាប់ទៅដោយស្រួល ដូចជាអធិករណ៍ដែលសង្ឃបានរម្ងាប់ហើយក្នុងក្រុងសាវត្ថី ដូចជាអធិករណ៍ដែលព្រះថេរៈច្រើនអង្គបានរម្ងាប់ហើយ ដូចជាអធិករណ៍ដែលព្រះថេរៈទាំងឡាយបីអង្គបានរម្ងាប់ហើយ ដូចជាអធិករណ៍ដែលព្រះថេរៈទាំងឡាយពីរអង្គបានរម្ងាប់ហើយ ៗ គ្រានោះឯង ភិក្ខុទាំងឡាយនោះ ក៏នៅតែមិនត្រេកអរដោយការរម្ងាប់អធិករណ៍របស់សង្ឃក្នុងក្រុងសាវត្ថី មិនត្រេកអរដោយការរម្ងាប់អធិករណ៍របស់ព្រះថេរៈទាំងឡាយច្រើនអង្គ មិនត្រេកអរដោយការរម្ងាប់អធិករណ៍ របស់ព្រះថេរៈទាំងឡាយបីអង្គ មិនត្រេកអរដោយការរម្ងាប់អធិករណ៍របស់ព្រះថេរៈទាំងឡាយពីរអង្គ មិនត្រេកអរដោយការរម្ងាប់អធិករណ៍របស់ព្រះថេរៈមួយអង្គ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ ។ ជ៏ហាតមេតំ ភិក្ខវេ អធិករណំ សន្តំ វូបសន្តំ សុវូបសន្តំ(១) ។ អនុជានាមិ ភិក្ខវេ តេសំ ភិក្ខូនំ សញ្ញត្តិយា តយោ សលាកគ្គាហេ គូឡ្ហកំ សកណ្ណជប្បកំ វិវដកំ ។ កថញ្ច ភិក្ខវេ គូឡ្ហកោ សលាកគ្គាហោ ហោតិ ។ តេន សលាកគ្គាហាបកេន ភិក្ខុនា សលាកាយោ វណ្ណាវណ្ណាយោ កត្វា ឯកេកោ ភិក្ខុ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អយំ ឯវំវាទិស្ស សលាកា អយំ ឯវំវាទិស្ស សលាកា យំ ឥច្ឆសិ តំ គណ្ហាហីតិ ។ គហិតេ វត្តព្វោ មា ច កស្សចិ ទស្សេហីតិ ។ សចេ ជានាតិ អធម្មវាទី ពហុតរាតិ ទុគ្គហោតិ បច្ចុក្កឌ្ឍិតព្វំ ។ សចេ ជានាតិ

១ ឱ.ម. សុវូបសន្តន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហើយក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អធិករណ៍នុ៎ះសង្ឃបានកំចាត់បង់ឲ្យស្ងប់រម្ងាប់ហើយ ឈ្មោះថារម្ងាប់ដោយប្រពៃហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការចាប់ស្លាកបីយ៉ាង គឺ គូឡ្ហកៈ (បិទមុខ) ១ សកណ្ណជប្បកៈ (ខ្សឹបប្រាប់) ១ វិវដកៈ(១) (បើកចំហ) ១ ដើម្បីបញ្ញាក់ដល់ភិក្ខុទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ចុះការចាប់ស្លាកឈ្មោះគូឡ្ហកៈនោះដូចម្ដេច ។ ត្រូវសលាកគ្គាហាបកភិក្ខុនោះធ្វើស្លាកឲ្យមានពណ៌ផ្សេងគ្នា ហើយចូលទៅរកភិក្ខុ ១ រូបម្ដងៗ ហើយនិយាយយ៉ាងនេះថា នេះស្លាករបស់ភិក្ខុមានវាទៈយ៉ាងនេះ នេះស្លាករបស់ភិក្ខុមានវាទៈយ៉ាងនេះ លោកចង់ចាប់ស្លាកណា ចូរលោកចាប់ស្លាកនោះចុះ។ លុះភិក្ខុអ្នកចាប់នោះចាប់យកទៅហើយ សលាកគ្គាហាបកភិក្ខុត្រូវប្រាប់ថា លោកកុំបង្ហាញអ្នកណាឲ្យឃើញ ។ បើសលាកគ្គាហាបកភិក្ខុដឹងថា ភិក្ខុជាអធម្មវាទីមានចំនួនច្រើនជាង ត្រូវប្រាប់ថាការចាប់នេះមិនល្អទេ ហើយសើរើជាថ្មីទៀត(២) ។ បើសលាកគ្គាហាបកភិក្ខុដឹងថា

---

១ អដ្ឋកថា ថា កាលបើភិក្ខុបរិសទ្យជាអលជ្ជីច្រើនជាង ត្រូវធ្វើស្លាកបិទមុខ ។ បើភិក្ខុបរិសទ្យជាលជ្ជីច្រើនជាង ត្រូវធ្វើស្លាកបើកមុខ ។ បើភិក្ខុបរិសទ្យជាមនុស្សល្ងង់ច្រើនជាង ត្រូវខ្សឹបប្រាប់ដិតត្រចៀក ។ អដ្ឋកថា ថា ត្រូវឲ្យចាប់ជាថ្មីទៀត ដរាបទាល់តែគ្រប់បីដង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ធម្មវាទី ពហុតរាតិ សុគ្គហោតិ សាវេតព្វំ ។ ឯវំ ខោ ភិក្ខវេ គូឡ្ហកោ សលាកគ្គាហោ ហោតិ ។ កថញ្ច ភិក្ខវេ សកណ្ណជប្បកោ សលាកគ្គាហោ ហោតិ ។ តេន សលាកគ្គាហាបកេន ភិក្ខុនា ឯកមេកស្ស ភិក្ខុនោ ឧបកណ្ណកេ អារោចេតព្វំ អយំ អធម្មវាទិស្ស សលាកា អយំ ធម្មវាទិស្ស សលាកា យំ ឥច្ឆសិ តំ គណ្ហាហីតិ ។ គហិតេ វត្តព្វោ មា ច កស្សចិ អារោចេហីតិ ។ សចេ ជានាតិ អធម្មវាទី ពហុតរាតិ ទុគ្គហោតិ បច្ចុក្កឌ្ឍិតព្វំ ។ សចេ ជានាតិ ធម្មវាទី ពហុតរាតិ សុគ្គហោតិ សាវេតព្វំ ។ ឯវំ ខោ ភិក្ខវេ សកណ្ណជប្បកោ សលាកគ្គាហោ ហោតិ ។ កថញ្ច ភិក្ខវេ វិវដកោ សលាកគ្គាហោ ហោតិ ។ សចេ ជានាតិ ធម្មវាទី ពហុតរាតិ វិស្សដ្ឋេនេវ វិវដេន សលាកគ្គាហេន គាហេតព្វំ(១) ឯវំ ខោ ភិក្ខវេ វិវដកោ សលាកគ្គាហោ ហោតិ ឥមេ ខោ ភិក្ខវេ តយោ សលាកគ្គាហាតិ ។

---

១ ឱ. ម. បោត្ថកេសុ វិស្សដ្ឋេនេវ វិវដេន សលាកគាហេន គាហេតព្វោតិ ឥយោ អាគតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សមថក្ខន្ធកៈ ការចាប់ស្លាកឈ្មោះសកណ្ណជប្បកៈ

ភិក្ខុជាធម្មវាទីមានចំនួនច្រើនជាង ត្រូវប្រកាសថា ការចាប់នេះល្អហើយ ។ ម្នាលភិក្ខុទាំងឡាយ ការចាប់ស្លាកយ៉ាងនេះហើយដែលហៅថា គូឡ្ហកៈ ។ ម្នាលភិក្ខុទាំងឡាយ ការចាប់ស្លាកឈ្មោះសកណ្ណជប្បកៈនោះ តើដូចម្តេច ។ សលាកគ្គាហាបកភិក្ខុនោះត្រូវខ្សឹបដាក់ត្រចៀកភិក្ខុមួយរូប ៗ ថា នេះស្លាករបស់ភិក្ខុមានវាទៈយ៉ាងនេះ នេះស្លាករបស់ភិក្ខុមានវាទៈយ៉ាងនេះ លោកចង់ចាប់ស្លាកណា ចូរយកស្លាកនោះចុះ ។ លុះភិក្ខុចាប់ស្លាកទៅហើយ ត្រូវសលាកគ្គាហាបកភិក្ខុនិយាយថា លោកកុំប្រាប់អ្នកណាឲ្យសោះ ។ បើសលាកគ្គាហាបកភិក្ខុដឹងថា ភិក្ខុជាអធម្មវាទីមានចំនួនច្រើនជាង ត្រូវប្រាប់ថា ការចាប់នេះមិនល្អទេ ហើយសើរើជាថ្មីទៀត ។ បើសលាកគ្គាហាបកភិក្ខុដឹងថា ភិក្ខុជាធម្មវាទីមានចំនួនច្រើនជាង ត្រូវប្រកាសថា ការចាប់នេះល្អហើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះការចាប់យ៉ាងនេះដែលហៅថាសកណ្ណជប្បកៈ ។ ម្នាលភិក្ខុទាំងឡាយ ការចាប់ស្លាកឈ្មោះវិវដកៈនោះដូចម្តេច ។ បើសលាកគ្គាហាបកភិក្ខុដឹងថា ភិក្ខុជាធម្មវាទីមានចំនួនច្រើនជាង ត្រូវបណ្តោយឲ្យចាប់ដោយវិធីចាប់ស្លាកឈ្មោះវិវដកៈចុះ ម្នាលភិក្ខុទាំងឡាយ ការចាប់ស្លាកយ៉ាងនេះហើយដែលហៅថាវិវដកៈ ម្នាលភិក្ខុទាំងឡាយ វិធីចាប់ស្លាកមាន៣យ៉ាងប៉ុណ្ណេះឯង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៩៨) អនុវាទាធិករណំ កតិហិ សមថេហិ សម្មតិ ។ អនុវាទាធិករណំ ចតូហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច សតិវិនយេន ច អមូឡ្ហវិនយេន ច តស្សបាបិយសិកាយ ច ។

(៩៩) សិយា អនុវាទាធិករណំ ទ្វេ សមថេ អនាគម្ម អមូឡ្ហវិនយញ្ច តស្សបាបិយសិកញ្ច ទ្វីហិ សមថេហិ សម្មេយ្យ សម្មុខាវិនយេន ច សតិវិនយេន ចាតិ ។ សិយាតិស្ស វចនីយំ ។ យថា កថំ វិយ ។ ឥធ បន ភិក្ខវេ ភិក្ខូ ភិក្ខុំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេន្តិ ។ តស្ស ខោ តំ ភិក្ខវេ ភិក្ខុនោ សតិវេបុល្លប្បត្តស្ស សតិវិនយោ ទាតព្វោ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វោ ។ តេន ភិក្ខវេ ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ។ បេ ។ ឯវមស្ស វចនីយោ មំ ភន្តេ ភិក្ខូ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេន្តិ សោហំ ភន្តេ សតិវេបុល្លប្បត្តោ សង្ឃំ សតិវិនយំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វោ ។ តតិយម្បិ យាចិតព្វោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៩៨) អនុវាទាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ អនុវាទាធិករណ៍រម្ងាប់ដោយសមថៈ ៤ យ៉ាង គឺ សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ ។

(៩៩) អនុវាទាធិករណ៍ មិនបាច់អាស្រ័យសមថៈពីរយ៉ាង គឺ អមូឡ្ហវិន័យ និងតស្សបាបិយសិកាទេ គ្រាន់តែរម្ងាប់ដោយសមថៈពីរយ៉ាង គឺ សម្មុខាវិន័យ និងសតិវិន័យ (ប៉ុណ្ណោះ) ក៏មាន ។ ពាក្យដែលបណ្ឌិតគប្បីពោលថា ក៏មាន ដូច្នេះ ។ ពាក្យនោះតើដូចសំដែងត្រង់បទណា ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះចោទភិក្ខុផងគ្នា ដោយសីលវិបត្តិឥតមានមូល ។ ម្នាលភិក្ខុទាំងឡាយ សតិវិន័យសង្ឃត្រូវឲ្យដល់ភិក្ខុដែលមានសតិបរិបូណ៌នោះឯង ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសតិវិន័យយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវចូលទៅរកសង្ឃធ្វើចីវរឆៀងស្មាម្ខាង ។ បេ ។ ហើយនិយាយនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ភិក្ខុទាំងឡាយចោទខ្ញុំដោយសីលវិបត្តិឥតមានមូល បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាអ្នកមានសតិពេញបរិបូណ៌ ហើយ មកសូមសតិវិន័យនឹងសង្ឃ ។ ភិក្ខុនោះត្រូវសូមសតិវិន័យជាគំរប់ពីរដងផង ។ ភិក្ខុនោះត្រូវសូមសតិវិន័យជាគំរប់បីដងផង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកេ សតិវេបុល្លប្បត្តស្ស សតិវិនយទានំ

(១០០) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ភិក្ខូ ឥត្ថន្នាមំ ភិក្ខុំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេន្តិ ។ សោ សតិវេបុល្លប្បត្តោ សង្ឃំ សតិវិនយំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ សតិវេបុល្លប្បត្តស្ស សតិវិនយំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ភិក្ខូ ឥត្ថន្នាមំ ភិក្ខុំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេន្តិ ។ សោ សតិវេបុល្លប្បត្តោ សង្ឃំ សតិវិនយំ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ សតិវេបុល្លប្បត្តស្ស សតិវិនយំ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សតិវេបុល្លប្បត្តស្ស សតិវិនយស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ តតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ ទិន្នោ សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ សតិវេបុល្លប្បត្តស្ស សតិវិនយោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកៈ ការឲ្យសតិវិន័យដល់ភិក្ខុជាអ្នកមានសតិពេញបរិបូណ៌

(១០០) ភិក្ខុអ្នកឈ្លាសវាងវៃ ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុទាំងឡាយចោទភិក្ខុឈ្មោះនេះដោយសីលវិបត្តិឥតមានមូល ៗ ភិក្ខុនោះជាអ្នកមានសតិពេញបរិបូណ៌ ហើយមកសូមសតិវិន័យនឹងសង្ឃ ៗ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវឲ្យសតិវិន័យដល់ភិក្ខុឈ្មោះនេះ ជាអ្នកមានសតិពេញបរិបូណ៌ហើយ ៗ នេះជាញត្តិ ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុទាំងឡាយចោទភិក្ខុឈ្មោះនេះដោយសីលវិបត្តិឥតមានមូល ៗ ភិក្ខុនោះជាអ្នកមានសតិពេញបរិបូណ៌ ហើយមកសូមសតិវិន័យនឹងសង្ឃ ៗ សង្ឃបានឲ្យនូវសតិវិន័យដល់ភិក្ខុឈ្មោះនេះ ដែលជាអ្នកមានសតិពេញបរិបូណ៌ហើយ ៗ ការឲ្យនូវសតិវិន័យដល់ភិក្ខុឈ្មោះនេះ ដែលជាអ្នកមានសតិពេញបរិបូណ៌ហើយ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីពោលឡើង ៗ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរផងផង ៗ បេ ៗ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីផងផង ៗ បេ ៗ សតិវិន័យសង្ឃបានឲ្យដល់ភិក្ខុឈ្មោះនេះ ដែលជាអ្នកមានសតិពេញបរិបូណ៌ហើយ ការឲ្យសតិវិន័យនេះគួរដល់សង្ឃហើយ ព្រោះហេតុនោះទើបសង្ឃស្ងៀម ៗ ខ្ញុំសូមចាំទុក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ធារយាមីតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ច សតិវិនយេន ច ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ បេ ។ កា ច តត្ថ បុគ្គលសម្មុខតា ។ យោ ច អនុវទតិ យញ្ច អនុវទតិ ឧភោ សម្មុខីភូតា ហោន្តិ អយំ តត្ថ បុគ្គលសម្មុខតា ។ កិញ្ច តត្ថ សតិវិនយស្មឹ ។ យា សតិវិនយស្ស កម្មស្ស កិរិយា ករណំ ឧបគមនំ អជ្ឈុបគមនំ អធិវាសនា អប្បដិក្កោសនា ឥទំ តត្ថ សតិវិនយស្មឹ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឆន្ទទាយកោ ខីយតិ ខីយនកំ បាចិត្តិយំ ។

(១០១) សិយា អនុវាទាធិករណំ ទ្វេ សមថេ អនាគម្ម សតិវិនយញ្ច តស្សបាបិយសិកញ្ច ទ្វីហិ សមថេហិ សម្មេយ្យ សម្មុខាវិនយេន ច អមូឡ្ហវិនយេន ចាតិ ។ សិយាតិស្ស វចនីយំ ។ យថា កថំ វិយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នូវសេចក្តីនេះដោយការការស្មើយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះ គឺជាគតហៅថាអធិករណ៍ស្ងប់ហើយ ។ អធិករណ៍នោះរម្ងាប់ដោយធម៌អ្វី ។ រម្ងាប់ដោយសម្មុខាវិន័យ និងសតិវិន័យ ។ ចុះកងសម្មុខាវិន័យនោះមានអង្គដូចម្តេច ។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គកងសម្មុខាវិន័យនេះ) ។ បេ ។ ចុះការចំពោះមុខបុគ្គលកងសម្មុខាវិន័យនោះតើដូចម្តេច ។ បុគ្គលណាចោទគ្នាទៅវិញទៅមក បុគ្គលទាំងពីរនាក់នោះក៏មាននៅក្នុងទីចំពោះមុខ នេះហៅថាការចំពោះមុខបុគ្គលកងសម្មុខាវិន័យនោះ ។ ចុះកងសតិវិន័យនោះមានកិច្ចដូចម្តេច ។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅឯបរិច ការទទួលនូវកិរិយាមិនឃាត់ហាមនូវសតិវិន័យកម្មណា នេះជាកិច្ចកងសតិ-វិន័យនោះ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ ។

(១០១) អនុវាទាធិករណ៍ មិនបាច់អាស្រ័យសមថៈពីរយ៉ាង គឺសតិវិន័យ ១ តស្សបាបិយសិកា ១ គ្រាន់តែរម្ងាប់ដោយសមថៈពីរយ៉ាង គឺសម្មុខាវិន័យ ១ អមូឡ្ហវិន័យ ១ ក៏មាន ។ ពាក្យដែលបណ្ឌិតគប្បីពោលថា ក៏មាន ដូច្នេះ ។ ពាក្យនោះតើដូចសំដែងត្រង់ចំណុចណា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥធ បន ភិក្ខវេ ភិក្ខុ ឧម្មត្តកោ ហោតិ ចិត្តវិបរិយាសកតោ តេន ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ហោតិ ភាសិតបរិក្កន្តំ ។ តំ ភិក្ខូ ឧម្មត្តកេន ចិត្តវិបរិយាសកតេន អជ្ឈាចិណ្ណេន អាបត្តិយា ចោទេន្តិ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ ឯវំ វទេតិ អហំ ខោ អាវុសោ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ នាហន្តំ សរាមិ មូឡ្ហេន មេ ឯតំ កតន្តិ ។ ឯវំបិ នំ វុច្ចមានា ចោទេន្តេវ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ តស្ស ខោ ភិក្ខវេ ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយោ ទាតព្វោ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វោ ។ តេន ភិក្ខវេ ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ។ បេ ។ ឯវមស្ស វចនីយោ អហំ ភន្តេ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សមបិណ្ឌកៈ ភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាមនុស្សឆ្កួត មានចិត្តវិបល្លាសប្រែប្រួល ភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួលហើយនោះក៏បានប្រព្រឹត្តអនាចារ បានពោលនិងព្យាយាមធ្វើល្មើសនូវកិច្ចដែលមិនមែនជារបស់សមណៈជាច្រើន ៗ ព្រោះហេតុតែភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួលហើយបានប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយក៏នាំគ្នាចោទភិក្ខុនោះដោយអាបត្តិថា លោកមានអាយុត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ចូរនឹកមើល ៗ ភិក្ខុឆ្កួតនោះឆ្លើយយ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ខ្ញុំឯងជាមនុស្សឆ្កួតមានចិត្តវិបល្លាសប្រែប្រួល ខ្ញុំឆ្កួតមានចិត្តវិបល្លាសប្រែប្រួលហើយនោះក៏បានប្រព្រឹត្តអនាចារ បានពោលនិងព្យាយាមធ្វើល្មើសនូវកិច្ចដែលមិនមែនជារបស់សមណៈជាច្រើន ខ្ញុំនឹកអំពើនោះមិនឃើញទេ អំពើនុះខ្ញុំបានធ្វើហើយដោយសេចក្តីវង្វេង ៗ ភិក្ខុទាំងឡាយក៏នៅតែពោលចោទភិក្ខុឆ្កួតនោះយ៉ាងនេះទៀតថា លោកមានអាយុត្រូវអាបត្តិមានសភាពយ៉ាងនេះហើយ ចូរនឹកមើល ៗ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឆ្កួតនោះបាត់វង្វេងហើយ សង្ឃគប្បីឲ្យអមូឡ្ហវិន័យចុះ ៗ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីឲ្យអមូឡ្ហវិន័យយ៉ាងនេះ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ។បេ។ ហើយពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាមនុស្សឆ្កួតមានចិត្តវិបល្លាស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



តេន មេ ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ មំ ភិក្ខូ ឧម្មត្តកេន ចិត្តវិបរិយាសកតេន អជ្ឈាចិណ្ណេន អាបត្តិយា ចោទេន្តិ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ត្យាហំ ឯវំ វទាមិ អហំ ខោ អាវុសោ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ នាហន្តំ សរាមិ មូឡ្ហេន មេ ឯតំ កតន្តិ ។ ឯវំបិ មំ វុច្ចមានា ចោទេន្តេវ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោហំ ភន្តេ អមូឡ្ហោ សង្ឃំ អមូឡ្ហវិនយំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វោ ។ តតិយម្បិ យាចិតព្វោ ។

(១០៦) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ ឧម្មត្តកោ អហោសិ ចិត្តវិបរិយាសកតោ តេន ឧម្មត្តកេន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ប្រែប្រួល កាលខ្ញុំឆ្គួតមានចិត្តវិបល្លាសប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោលនិងព្យាយាមធ្វើល្មើស នូវកិច្ចដែលមិនមែនជារបស់សមណៈជាច្រើន ព្រោះតែខ្ញុំជាមនុស្សឆ្គួត មានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយក៏នាំគ្នាចោទខ្ញុំដោយអាបត្តិថា លោកមានអាយុត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល ខ្ញុំក៏បានឆ្លើយតបនឹងភិក្ខុទាំងឡាយនោះវិញយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាមនុស្សឆ្គួតមានចិត្តវិបល្លាសប្រែប្រួលមែន ខ្ញុំឆ្គួតមានចិត្តវិបល្លាសប្រែប្រួលហើយនោះក៏បានប្រព្រឹត្តអនាចារ បានពោលនិងព្យាយាមធ្វើល្មើស នូវកិច្ចដែលមិនមែនជារបស់សមណៈជាច្រើន ខ្ញុំនឹកអំពើនោះមិនឃើញទេ អំពើនុ៎ះខ្ញុំបានធ្វើហើយដោយសេចក្ដីវង្វេង ។ ភិក្ខុទាំងឡាយក៏នៅតែពោលចោទខ្ញុំយ៉ាងនេះទៀតថា លោកមានអាយុត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំបាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ ។ ភិក្ខុនោះត្រូវសូមអមូឡ្ហវិន័យអស់វារៈពីរដងផង ។ ត្រូវសូមអមូឡ្ហវិន័យអស់វារៈបីដងផង ។

[១០៦] ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវផ្ដៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុឈ្មោះនេះជាមនុស្សឆ្គួត ជាអ្នកមានចិត្តវិបល្លាសប្រែប្រួល ភិក្ខុឆ្គួតមានចិត្តវិបល្លាស ប្រែប្រួលហើយនោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ តំ ភិក្ខូ ឧម្មត្តកេន ចិត្តវិបរិយា-សកតេន អជ្ឈាចិណ្ណេន អាបត្តិយា ចោទេន្តិ សរតា-យស្មា ឯវរូប អាបត្តឹ អាបជ្ជិតាតិ ។ សោ ឯវំ វទេតិ អហំ ខោ អាវុសោ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាស-កតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ នាហំ តំ ស-រាមិ មូឡ្ហេន មេ ឯតំ កតន្តិ ។ ឯវម្បិ នំ វុច្ចមានា ចោ-ទេន្តេវ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ អមូឡ្ហោ សង្ឃំ អមូឡ្ហវិនយំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ ឧម្មត្តកោ អហោសិ ចិត្តវិបរិយាសកតោ តេន ឧម្មត្តកេន ចិត្តវិបរិយាសក-តេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ តំ ភិក្ខូ ឧម្មត្តកេន ចិត្តវិបរិយាសកតេន អជ្ឈាចិណ្ណេន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ក៏បានប្រព្រឹត្តអនាចារ បានពោលនិងពន្យាយាមធ្វើល្មើសនូវកិច្ចដែលមិនមែនជារបស់សមណៈជាច្រើន ៗ ព្រោះតែភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល ប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយនាំគ្នាចោទភិក្ខុនោះដោយអាបត្តិថា លោកមានអាយុត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល ៗ ភិក្ខុនោះក៏ឆ្លើយយ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ខ្ញុំជាមនុស្សឆ្កួតមានចិត្តវិបល្លាសប្រែប្រួលមែន ខ្ញុំឆ្កួតមានចិត្តវិបល្លាសប្រែប្រួលហើយ នោះក៏បានប្រព្រឹត្តអនាចារ បានពោលនិងពន្យាយាមធ្វើល្មើស នូវកិច្ចដែលមិនមែនជារបស់សមណៈជាច្រើន ខ្ញុំនឹករកអំពើនោះមិនឃើញទេ អំពើនុ៎ះ ខ្ញុំបានធ្វើហើយដោយសេចក្តីវង្វេង ៗ ភិក្ខុទាំងឡាយក៏នៅតែចោទភិក្ខុនោះ យ៉ាងនេះទៀតថា លោកមានអាយុត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល ៗ ភិក្ខុនោះបាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ ៗ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវអមូឡ្ហវិន័យដល់ភិក្ខុឈ្មោះនេះ ជាអ្នកបាត់វង្វេង ៗ នេះជាញត្តិ ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះជាមនុស្សឆ្កួតមានចិត្តវិបល្លាសប្រែប្រួល ភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោលនិងពន្យាយាមធ្វើល្មើស នូវកិច្ចដែលមិនមែនជារបស់សមណៈជាច្រើន ៗ ព្រោះតែភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល ប្រព្រឹត្ត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាបត្តិយា ចោទេន្តិ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ ឯវំ វទេតិ អហំ ខោ អាវុសោ ឧម្មត្តកោ អហោសឹ ចិត្តវិបរិយាសកតោ តេន មេ ឧម្មត្តកេន ចិត្តវិបរិយាសកតេន ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ នាហន្តំ សរាមិ មូឡ្ហេន មេ ឯតំ កតន្តិ ។ ឯវម្បិ នំ វុច្ចមានា ចោទេន្តេវ សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតាតិ ។ សោ អមូឡ្ហោ សង្ឃំ អមូឡ្ហវិនយំ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយំ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ ទិន្នោ សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ អមូឡ្ហស្ស អមូឡ្ហវិនយោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនាចារ ភិក្ខុទាំងឡាយក៏នាំគ្នាចោទភិក្ខុនោះ ដោយអាបត្តិថា លោកមានអាយុត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល ។ ភិក្ខុនោះក៏ឆ្លើយតបយ៉ាងនេះវិញថា ម្នាលលោកមានអាយុទាំងឡាយ ខ្ញុំជាមនុស្សឆ្កួតមានចិត្តវិបល្លាសប្រែប្រួលមែន កាលខ្ញុំឆ្កួតមានចិត្តវិបល្លាសប្រែប្រួលហើយនោះក៏បានប្រព្រឹត្តអនាចារ បានពោលទំនងព្យាយាមធ្វើល្មើស នូវកិច្ចដែលមិនមែនជារបស់សមណៈជាច្រើន ខ្ញុំនឹករកអំពើនោះមិនឃើញទេ អំពើនុ៎ះខ្ញុំបានធ្វើហើយ ដោយសេចក្តីវង្វេង ។ ភិក្ខុទាំងឡាយក៏នៅតែពោលចោទភិក្ខុនោះយ៉ាងនេះទៀតថា លោកមានអាយុត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល ។ ភិក្ខុនោះបាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ ។ សង្ឃក៏ឲ្យអមូឡ្ហវិន័យដល់ភិក្ខុឈ្មោះនេះដែលបាត់វង្វេងហើយ ។ ការឲ្យអមូឡ្ហវិន័យដល់ភិក្ខុឈ្មោះនេះ ជាអ្នកបាត់វង្វេងហើយ សមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីស្ងៀម មិនសមគួរ ដល់លោកមានអាយុអង្គណាទេ លោកមានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះ អស់វារៈពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះ អស់វារៈបីដងផង ។ បេ ។ អមូឡ្ហវិន័យសង្ឃបានឲ្យដល់ភិក្ខុឈ្មោះនេះ ដែលបាត់វង្វេងហើយ ការឲ្យអមូឡ្ហវិន័យនេះគួរ ដល់សង្ឃ ព្រោះហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ធារយាមីតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ច អមូឡ្ហវិនយេន ច ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ បេ ។ កិញ្ច តត្ថ អមូឡ្ហវិនយស្មឹ ។ យា អមូឡ្ហវិនយស្ស កម្មស្ស កិរិយា ករណំ ឧបគមនំ អជ្ឈុបគមនំ អធិវាសនា អប្បដិក្កោសនា ឥទំ តត្ថ អមូឡ្ហវិនយស្មឹ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឆន្ទទាយកោ ខីយតិ ខីយនកំ បាចិត្តិយំ ។

(១០៣) សិយា អនុវាទាធិករណំ ទ្វេ សមថេ អនាគម្ម សតិវិនយញ្ច អមូឡ្ហវិនយញ្ច ទ្វីហិ សមថេហិ សម្មេយ្យ សម្មុខាវិនយេន ច តស្សបាបិយសិកាយ ចាតិ ។ សិយាតិស្ស វចនីយំ ។ យថា កថំ វិយ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុំ សង្ឃមជ្ឈេ គរុកាយ អាបត្តិយា ចោទេតិ សរតាយស្មា ឯវរូបឹ គរុកំ អាបត្តឹ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដោយអាការៈស្ងៀមយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថាអធិករណ៍រម្ងាប់ហើយ ។ អធិករណ៍នោះរម្ងាប់ដោយធម៌អ្វី ។ រម្ងាប់ដោយសម្មុខាវិន័យនឹងអមូឡ្ហវិន័យ ។ ចុះក្នុងសម្មុខាវិន័យនោះមានអង្គដូចម្តេច ។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល ( ជាអង្គក្នុងសម្មុខាវិន័យនោះ ) ។ បេ ។ ក្នុងអមូឡ្ហវិន័យនោះមានកិច្ចដូចម្តេច ។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅកែបនែប ការទទួល នឹងការមិនហាមឃាត់នូវអមូឡ្ហវិន័យកម្មណា នេះជាកិច្ចក្នុងអមូឡ្ហវិន័យនោះ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ភិក្ខុអ្នកឲ្យឆន្ទៈត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ ។

[១០៣] អនុវាទាធិករណ៍មិនបាច់អាស្រ័យសមថៈពីរយ៉ាង គឺសតិវិន័យ ១ អមូឡ្ហវិន័យ ១ គ្រាន់តែរម្ងាប់ដោយសមថៈពីរយ៉ាង គឺ សម្មុខាវិន័យ ១ តស្សបាបិយសិកា ១ ក៏មាន ។ ពាក្យដែលបណ្ឌិតគប្បីពោលថា ក៏មាន ដូច្នេះ ។ ពាក្យនោះតើដូចសំដែងត្រង់ចំណា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចោទភិក្ខុផងគ្នាដោយគរុកាបត្តិ ក្នុងកណ្តាលជំនុំសង្ឃថា លោកមានអាយុត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ សោ ឯវំ វទេតិ ន ខោ អហំ អាវុសោ សរាមិ ឯវរូបឹ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ តមេនំ សោ និព្វេឋេន្តំ អតិវេឋេតិ ឥង្ឃាយស្មា សាធុកមេវ ជានាហិ យទិ សរសិ ឯវរូបឹ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ សោ ឯវំ វទេតិ ន ខោ អហំ អាវុសោ សរាមិ ឯវរូបឹ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វា សរាមិ ច ខោ អហំ អាវុសោ ឯវរូបឹ អប្បមត្តិកំ អាបត្តឹ អាបជ្ជិតាតិ ។ តមេនំ សោ និព្វេឋេន្តំ អតិវេឋេតិ ឥង្ឃាយស្មា សាធុកមេវ ជានាហិ យទិ សរសិ ឯវរូបឹ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ សោ ឯវំ វទេតិ ឥមំ ហិ នាមាហំ អាវុសោ អប្បមត្តិកំបិ(១) អាបត្តឹ អាបជ្ជិតា(២) អបុដ្ឋោ បដិជានិស្សាមិ កឹ បនាហំ

---

១ ឱ. ម. បិសទ្ទោ ន ទិស្សតិ ។ ២ ឱ. ម. អាបជ្ជិត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គឺ អាបត្តិបារាជិក ឬ អាបត្តិជិតបារាជិក(១) ហើយ ចូរនឹកមើលទៅ ៗ ភិក្ខុនោះក៏ឆ្លើយតបយ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ខ្ញុំនឹកមិនឃើញថា ខ្ញុំត្រូវត្រូវអាបត្តិមានសភាពយ៉ាងនេះ គឺ អាបត្តិបារាជិក ឬ អាបត្តិជិតបារាជិកទេ ៗ ភិក្ខុនោះក៏នៅតែចោទប្រកាន់ភិក្ខុ ដែលប្រកែកនោះដោយពាក្យថា លោកមានអាយុ ខ្ញុំសូមដាស់តឿន លោកចូរដឹងដោយស្រួលបួលចុះ បើលោកមានអាយុត្រូវត្រូវអាបត្តិ មានសភាពយ៉ាងនេះ គឺ អាបត្តិបារាជិក ឬ អាបត្តិជិតបារាជិកហើយ នឹកឃើញ ៗ ភិក្ខុនោះក៏ឆ្លើយតបវិញថា ម្នាលលោកមានអាយុ ខ្ញុំនឹកមិនឃើញថា ខ្ញុំត្រូវត្រូវអាបត្តិ មានសភាពយ៉ាងនេះ គឺ អាបត្តិបារាជិក ឬ អាបត្តិជិតបារាជិកទេ ម្នាលលោកមានអាយុ ខ្ញុំនឹកឃើញត្រឹមតែថា ខ្ញុំត្រូវអាបត្តិបន្តិចបន្តួច មានសភាពយ៉ាងនេះប៉ុណ្ណោះ ៗ ភិក្ខុនោះក៏នៅតែចោទប្រកាន់ភិក្ខុ ដែលប្រកែកនោះដោយពាក្យថា លោកមានអាយុ ខ្ញុំសូមដាស់តឿន លោកចូរដឹងដោយស្រួលបួលចុះ បើលោកមានអាយុត្រូវត្រូវអាបត្តិ មានសភាពយ៉ាងនេះ គឺ អាបត្តិបារាជិក ឬ អាបត្តិជិតបារាជិកហើយ នឹកឃើញ ៗ ភិក្ខុនោះក៏ឆ្លើយតបយ៉ាងនេះវិញថា ម្នាលលោកមានអាយុ ខ្ញុំត្រូវអាបត្តិឈ្មោះនេះបន្តិចបន្តួច ទោះបើឥតគេសួរសោះ ក៏គង់តែខ្ញុំប្រាប់ ចំណង់បើខ្ញុំ

១ អដ្ឋកថាថា អាបត្តិទុក្កដ ឈ្មោះថា អាបត្តិជិតបារាជិក ក្នុងមេថុនធម្មសិក្ខាបទ ។ អាបត្តិថុល្លច្ច័យ ឈ្មោះថា អាបត្តិជិតបារាជិក ក្នុងសិក្ខាបទឯទៀតមានអទិន្នាទានសិក្ខាបទជាដើម។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកេ តស្សបាបិយសិកាកម្មករណំ

ឯវរូបឹ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិក-
សាមន្តំ វា បុដ្ឋោ ន បដិជានិស្សាមីតិ ។ សោ ឯវំ វទេតិ
ឥមំ ហិ នាម ត្វំ អាវុសោ អប្បមត្តកំ អាបត្តឹ អាបជ្ជិតា
អបុដ្ឋោ ន បដិជានិស្សសិ កឹ បន ត្វំ ឯវរូបឹ គរុកំ
អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វា
អបុដ្ឋោ បដិជានិស្សសិ ឥង្ឃាយស្មា សាធុកមេវ
ជានាហិ យទិ សរសិ ឯវរូបឹ គរុកំ អាបត្តឹ អាបជ្ជិតា
បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ សោ ឯវំ វទេតិ
សរាមិ ខោ អហំ អាវុសោ ឯវរូបឹ គរុកំ អាបត្តឹ
អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វា ទវា មេ
ឯតំ វុត្តំ រវា មេ ឯតំ វុត្តំ នាហំ តំ សរាមិ ឯវរូបឹ
គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ
វាតិ ។ តស្ស ខ្វេតំ(១) ភិក្ខវេ ភិក្ខុនោ តស្សបាបិយ-
សិកាកម្មំ កាតព្វំ ។

---

១ យុរោបិយបោត្ថកេ តស្ស ខោតិ វចនំ អាគតំ ។ មរម្មបោត្ថកេ តស្ស ខោ តត្តិ
អាគតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រូវតែត្រូវអាបត្តិ មានសភាពយ៉ាងនេះ គឺ អាបត្តិបារាជិក ឬ អាបត្តិជិតបារាជិក គេសួរហើយ ខ្ញុំនឹងមិនប្រព្រឹត្តដូចម្ដេចបាន ។ ភិក្ខុនោះក៏ឆ្លើយតបវិញថា ម្នាលលោកមានអាយុ លោកត្រូវអាបត្តិឈ្មោះនេះ បន្តិចបន្តួច ទោះបើគេសួរសោះ ក៏គង់តែលោកមិនប្រព្រឹត្ត ចំណង់បើលោកត្រូវតែត្រូវអាបត្តិ មានសភាពយ៉ាងនេះ គឺ អាបត្តិបារាជិក ឬ អាបត្តិជិតបារាជិក គេមិនសួរហើយ លោកនឹងប្រព្រឹត្តដូចម្ដេចបាន លោកមានអាយុ ខ្ញុំសូមដាស់តឿន លោកចូរដឹងដោយស្រួលបួលចុះ បើលោកត្រូវតែត្រូវអាបត្តិ មានសភាពយ៉ាងនេះ គឺ អាបត្តិបារាជិក ឬអាបត្តិជិតបារាជិកហើយ នឹករកឃើញ ។ ភិក្ខុនោះក៏ឆ្លើយតបវិញយ៉ាងនេះថា ម្នាលលោកមានអាយុ ខ្ញុំនឹកឃើញត្រឹមតែថាខ្ញុំត្រូវតែត្រូវអាបត្តិ មានសភាពយ៉ាងនេះ គឺ អាបត្តិបារា-ជិក ឬ អាបត្តិជិតបារាជិក ពាក្យនេះខ្ញុំនិយាយលេងទេ ពាក្យនេះខ្ញុំនិយាយភ្លាត់ទេ ខ្ញុំនឹកមិនឃើញថាខ្ញុំត្រូវតែត្រូវអាបត្តិ មានសភាពយ៉ាងនេះ គឺ អាបត្តិបារាជិក ឬ អាបត្តិជិតបារាជិកទេ ។ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយ-សិកាកម្មនេះ សង្ឃត្រូវតែធ្វើដល់ភិក្ខុនោះកុំខានឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១០៤) ឯវញ្ច បន ភិក្ខវេ ការេតព្វំ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃមជ្ឈេ គរុកាយ អាបត្តិយា អនុយុញ្ជិយមានោ អវជានិត្វា បដិជានាតិ បដិជានិត្វា អវជានាតិ អញ្ញេន អញ្ញំ បដិចរតិ សម្បជានមុសា ភាសតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ តស្សបាបិយសិកាកម្មំ ករេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃមជ្ឈេ គរុកាយ អាបត្តិយា អនុយុញ្ជិយមានោ អវជានិត្វា បដិជានាតិ បដិជានិត្វា អវជានាតិ អញ្ញេន អញ្ញំ បដិចរតិ សម្បជានមុសា ភាសតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ តស្សបាបិយសិកាកម្មំ ករោតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ តស្សបាបិយសិកាកម្មស្ស ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ កតំ សង្ឃេន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១០៤) ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម សង្ឃត្រូវធ្វើយ៉ាងនេះ ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ កាលសង្ឃសាកសួរដោយគរុកាបត្តិក្នុងកណ្តាលជំនុំសង្ឃ គេចកែសំដីហើយបែរជាប្តេជ្ញា ប្តេជ្ញាហើយបែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលសម្បជានមុសាវាទ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុឈ្មោះនេះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ កាលសង្ឃសាកសួរដោយគរុកាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏គេចកែសំដីហើយបែរជាប្តេជ្ញា ប្តេជ្ញាហើយបែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលសម្បជានមុសាវាទ ។ សង្ឃធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុឈ្មោះនេះ ។ ការធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុឈ្មោះនេះ សមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីស្ងៀម មិនសមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីពោលឡើង ខ្ញុំពោលសេចក្តីនេះ អស់វារៈពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះ អស់វារៈបីដងផង ។ បេ ។ តស្សបាបិយសិកាកម្ម សង្ឃបានធ្វើហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥត្ថន្នាមស្ស ភិក្ខុនោ តស្សបាបិយសិកាកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ច តស្សបាបិយសិកាយ ច ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។បេ។ កា ច តត្ថ តស្សបាបិយសិកាយ ។ យា តស្សបាបិយសិកាយ កម្មស្ស កិរិយា ករណំ ឧបគមនំ អជ្ឈុបគមនំ អធិវាសនា អប្បដិក្កោសនា អយំ តត្ថ តស្សបាបិយសិកាយ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ ការកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឆន្ទទាយកោ ខីយតិ ខីយនកំ បាចិត្តិយំ ។

(១០៩) អាបត្តាធិករណំ កតីហិ សមថេហិ សម្មតិ ។ អាបត្តាធិករណំ តីហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច បដិញ្ញាតករណេន ច តិណវត្ថារកេន ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដល់ភិក្ខុឈ្មោះនេះ ការធ្វើនូវតស្សបាបិយសិកាកម្មនេះ សមគួរដល់សង្ឃ ព្រោះហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អធិ-ករណ៍រម្ងាប់ហើយ ។ អធិករណ៍នោះរម្ងាប់ដោយធម៌អ្វី ។ រម្ងាប់ដោយសម្មុខាវិន័យ នឹងតស្សបាបិយសិកា ។ ចុះក្នុងសម្មុខាវិន័យនោះមានអ្វីដូចម្តេច ។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ) ។ បេ ។ ក្នុងតស្សបាបិ-យសិកាកម្មនោះមានកិរិយាធ្វើដូចម្តេច ។ ការធ្វើ កិរិយាធ្វើ ការចូលទៅដល់ ការចូលទៅអែបអប ការទទួល នឹងការមិនឃាត់ហាមនូវតស្សបាបិយ-សិកាកម្មណា នេះជាកិរិយាធ្វើក្នុងតស្សបាបិយសិកាកម្មនោះ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់សើរើឡើងវិញ ត្រូវទុក្កដនកបាចិត្តិយៈ ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយត្រឡប់តិះដៀលវិញ ត្រូវខីយនកបាចិត្តិយៈ ។

(១០៩) អាបត្តាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ អាបត្តា-ធិករណ៍ រម្ងាប់ដោយសមថៈបីយ៉ាងគឺ សម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ តិណវត្ថារកៈ ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣០៦) សិយា អាបត្តាធិករណំ ឯកំ សមថំ អនាគម្ម ធិណ្ណាវត្តំ ទ្វីហិ សមថេហិ សម្មេយ្យ សម្មុខាវិនយេន ច បដិញ្ញាតករណេន ចាតិ ។ សិយាតិស្ស វចនីយំ ។ យថា កថំ វិយ ។ ឥធ បន ភិក្ខវេ ភិក្ខុ លហុកំ អាបត្តឹ អាបន្នោ ហោតិ ។ តេន ភិក្ខវេ ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ អាវុសោ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ តំ បដិទេសេមីតិ ។ តេន វត្តព្វោ បស្សសីតិ ។ អាម បស្សាមីតិ ។ អាយតឹ សំវរេយ្យាសីតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ច បដិញ្ញាតករណេន ច ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ បេ ។ កា ច តត្ថ បុគ្គលសម្មុខតា ។ យោ ច ទេសេតិ យស្ស ច ទេសេតិ ឧភោ សម្មុខីភូតា ហោន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១០៦] អាបត្តាធិករណ៍មិនបាច់អាស្រ័យសមថៈ១ គឺ តិណវត្ថារកៈ គ្រាន់តែរម្ងាប់ដោយសមថៈពីរយ៉ាង គឺ សម្មុខាវិន័យ ១ បដិញ្ញាតករណៈ១ ក៏មាន ។ ពាក្យដែលបណ្ឌិតគប្បីពោលថា ក៏មាន ដូច្នេះ ។ ពាក្យនោះតើដូចសំដែងត្រង់បទណា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវលហុកាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចូលទៅរកភិក្ខុ ១ រូប ហើយធ្វើចីវរឆៀងស្មាម្ខាង អង្គុយច្រហោងផ្គងអញ្ជលីឡើងហើយពោលយ៉ាងនេះនឹងភិក្ខុនោះថា ម្នាលលោកមានអាយុ ខ្ញុំត្រូវអាបត្តិឈ្មោះនេះហើយ សូមសំដែងអាបត្តិនោះចេញ ។ ភិក្ខុអ្នកទទួលអាបត្តិនោះត្រូវពោលថា លោកឃើញឬទេ ។ ភិក្ខុអ្នកសំដែងឆ្លើយថា ករុណា ខ្ញុំឃើញហើយ ។ ភិក្ខុអ្នកទទួលត្រូវប្រាប់ថា លោកត្រូវសង្រួមតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថាអធិករណ៍រម្ងាប់ហើយ ។ អធិករណ៍នោះរម្ងាប់ដោយធម៌អ្វី ។ រម្ងាប់ដោយសម្មុខាវិន័យ នឹងបដិញ្ញាតករណៈ ។ ចុះក្នុងសម្មុខាវិន័យនោះមានអង្គដូចម្តេច ។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ) ។ បេ ។ ឯការចំពោះមុខបុគ្គលក្នុងសម្មុខាវិន័យនោះតើដូចម្តេច ។ បុគ្គលទាំងពីររូបដែលសំដែងអាបត្តិដល់គ្នានឹងគ្នាក៏មាននៅក្នុងទីចំពោះមុខ នេះហៅថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អយំ តត្ថ បុគ្គលសម្មុខតា ។ កិញ្ច តត្ថ បដិញ្ញាត-ករណស្មឹ ។ យា បដិញ្ញាតករណស្ស កម្មស្ស កិរិ-យា ករណំ ឧបគមនំ អជ្ឈុបគមនំ អធិវាសនា អប្ប-ដិក្កោសនា ឥទំ តត្ថ បដិញ្ញាតករណស្មឹ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ បដិគ្គាហកោ ឧក្កោដេតិ ឧក្កោ-ដនកំ បាចិត្តិយំ ។ ឯវញ្ចេ តំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ តេន ភិក្ខវេ ភិក្ខុនា សម្ពហុលេ ភិក្ខូ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយា អហំ ភន្តេ ឥត្ថន្នាមំ អា-បត្តឹ អាបន្នោ តំ បដិទេសេមីតិ ។ ព្យត្តេន ភិក្ខុនា បដិពលេន តេ ភិក្ខូ ញាបេតព្វា សុណន្តុ មេ អាយ-ស្មន្តា អយំ ឥត្ថន្នាមោ ភិក្ខុ អាបត្តឹ សរតិ វិវរតិ ឧត្តា-និំ ករោតិ ទេសេតិ ។ យទាយស្មន្តានំ បត្តកល្លំ អហំ ឥត្ថន្នាមស្ស ភិក្ខុនោ អាបត្តឹ បដិគ្គណ្ហេយ្យន្តិ ។ តេន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ការចំពោះមុខបុគ្គលក្នុងសម្មុខាវិន័យនោះ ។ ចុះក្នុងបដិញ្ញាតករណៈនោះ មានកិច្ចដូចម្តេច ។ ការធ្វើកិរិយាធ្វើ ការចូលទៅជិត ការចូលទៅផែបនែប ការទទួលនឹងការមិនឃាត់ឃាមនូវបដិញ្ញាតករណកម្មណា នេះជាកិច្ចក្នុងបដិញ្ញាតករណកម្មនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកទទួលត្រឡប់សើរើឡើងវិញ ត្រូវចុះក្នុងបាចិត្តិយៈ ។ បើភិក្ខុនោះបានភិក្ខុអ្នកទទួលយ៉ាងនេះហើយ ការបានយ៉ាងនេះ នេះជាការស្រួល បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវចូលទៅរកភិក្ខុច្រើនរូប ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ក្រាបសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីគប្បីពោលយ៉ាងនេះនឹងភិក្ខុទាំងនោះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណាត្រូវអាបត្តិឈ្មោះនេះហើយ សូមសំដែងអាបត្តិនោះចេញ ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងភិក្ខុទាំងនោះថា លោកមានអាយុទាំងឡាយចូរស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ នេះនឹកឃើញអាបត្តិ បង្ហើបអាបត្តិ ធ្វើអាបត្តិឲ្យងាយ សំដែងអាបត្តិ ។ បើកម្មមានកាលដ៏សមគួរ ដល់លោកមានអាយុទាំងឡាយហើយ ខ្ញុំគប្បីទទួលអាបត្តិរបស់ភិក្ខុឈ្មោះនេះ ។ ភិក្ខុអ្នកទទួលនោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



វត្តព្វោ បស្សសីតិ ។ អាម បស្សាមីតិ ។ អាយតឹ សំវរេយ្យាសីតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ច បដិញ្ញាតករណេន ច ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។បេ។ កា ច តត្ថ បុគ្គលសម្មុខតា ។ យោ ច ទេសេតិ យស្ស ច ទេសេតិ ឧភោ សម្មុខីភូតា ហោន្តិ អយំ តត្ថ បុគ្គលសម្មុខតា ។ កិញ្ច តត្ថ បដិញ្ញាតករណស្មឹ ។ យា បដិញ្ញាតករណស្ស កម្មស្ស កិរិយា ករណំ ឧបគមនំ អជ្ឈុបគមនំ អធិវាសនា អប្បដិក្កោសនា ឥទំ តត្ថ បដិញ្ញាតករណស្មឹ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ បដិគ្គាហកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឯវញ្ចេ តំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ តេន ភិក្ខវេ ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រូវពោលថា លោកឃើញឬទេ ។ ភិក្ខុនោះពោលថា ករុណា ខ្ញុំឃើញហើយ ។ ភិក្ខុអ្នកទទួលត្រូវប្រាប់ថា លោកត្រូវសម្រេចតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថាអធិករណ៍រម្ងាប់ហើយ ។ អធិករណ៍នោះរម្ងាប់ដោយធម៌អ្វី ។ រម្ងាប់ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ ។ ក្នុងសម្មុខាវិន័យនោះមានអង្គដូចម្តេច ។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ) ។ បេ ។ ចុះការចំពោះមុខបុគ្គលក្នុងសម្មុខាវិន័យនោះតើដូចម្តេច ។ បុគ្គលទាំងពីររូបដែលសំដែងអាបត្តិដល់គ្នានឹងគ្នា ក៏មាននៅក្នុងទីចំពោះមុខ នេះហៅថាការចំពោះមុខបុគ្គលក្នុងសម្មុខាវិន័យនោះ ។ ក្នុងបដិញ្ញាតករណៈមានកិច្ចដូចម្តេច ។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅអែបខែប ការទទួលនឹងការមិនហាមឃាត់នូវបដិញ្ញាតករណកម្មណា នេះជាកិច្ចក្នុងបដិញ្ញាតករណកម្មនោះ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកទទួលត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។ បើភិក្ខុបានភិក្ខុអ្នកទទួលនុ៎ះយ៉ាងនេះហើយ ការបានយ៉ាងនេះជាការស្រួល បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវចូលទៅកេសង្ឃ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយក្រាបសំពះបាទភិក្ខុចាស់ទាំងឡាយ អង្គុយច្រហោងផ្គងអញ្ជលីពោលនឹងសង្ឃយ៉ាងនេះថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកេ អាបត្តិទេសនា

អហំ ភន្តេ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ តំ បដិទេសេមីតិ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ អាបត្តឹ សរតិ វិវរតិ ឧត្តានីករោតិ ទេសេតិ ។ យទិ សង្ឃស្ស បត្តកល្លំ អហំ ឥត្ថន្នាមស្ស ភិក្ខុនោ អាបត្តឹ បដិគ្គណ្ហេយ្យន្តិ ។ តេន វត្តព្វោ បស្សសីតិ ។ អាម បស្សាមីតិ ។ អាយតឹ សំវរេយ្យាសីតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។ សម្មុខាវិនយេន ច បដិញ្ញាតករណេន ច ។ កិញ្ច តត្ថ សម្មុខាវិនយស្មឹ ។ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ បេ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ បដិគ្គាហកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឆន្ទទាយកោ ខីយតិ ខីយនកំ បាចិត្តិយំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកៈ ការសំដែងអាបត្តិ

បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិឈ្មោះនេះហើយ សូមសំដែងនូវអាបត្តិនោះចេញ ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះទើបឃើញនូវអាបត្តិ បង្ហើបអាបត្តិ ធ្វើអាបត្តិឲ្យងាយ សំដែងអាបត្តិ ។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំត្រូវទទួលនូវអាបត្តិរបស់ភិក្ខុឈ្មោះនេះ ។ ភិក្ខុអ្នកទទួលនោះត្រូវពោលថា លោកឃើញឬទេ ។ ភិក្ខុអ្នកសំដែងឆ្លើយថា ករុណា ខ្ញុំឃើញហើយ ។ ភិក្ខុអ្នកទទួលត្រូវប្រាប់ថា លោកត្រូវសង្រួមតទៅទៀតចុះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អធិករណ៍ស្ងប់ហើយ ។ អធិករណ៍ស្ងប់ដោយធម៌អ្វី ។ ស្ងប់ដោយសម្មុខាវិន័យនឹងបដិញ្ញាតករណៈ ។ ក្នុងសម្មុខាវិន័យនោះមានអង្គដូចម្តេច ។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ) ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍ស្ងប់យ៉ាងនេះហើយ ភិក្ខុអ្នកទទួលត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយត្រឡប់តិះដៀលវិញ ត្រូវខីយនកបាចិត្តិយៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១០៧) សិយា អាបត្តាធិករណំ ឯកំ សមថំ អនាគម្ម បដិញ្ញាតករណំ ទ្វីហិ សមថេហិ សម្មេយ្យ សម្មុខាវិនយេន ច តិណវត្ថារកេន ចាតិ ។ សិយាតិស្ស វចនីយំ ។ យថា កថំ វិយ ។ ឥធ បន ភិក្ខូ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ហោតិ ភាសិតបរិក្កន្តំ។ តត្រ ចេ ភិក្ខូ ភិក្ខូនំ ឯវំ ហោតិ អម្ហាកំ ខោ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យាតិ ។ អនុជានាមិ ភិក្ខវេ ឯវរូបំ អធិករណំ តិណវត្ថារកេន វូបសមេតុំ ។ ឯវញ្ច បន ភិក្ខវេ វូបសមេតព្វំ ។ សព្វេហេវ ឯកជ្ឈំ សន្និបតិតព្វំ សន្និបតិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(១០៧) អាបត្តាធិករណ៍មិនបាច់អាស្រ័យសមថៈ ១ គឺបដិញ្ញាតករណៈ គ្រាន់តែរម្ងាប់ដោយសមថ ពីរយ៉ាងគឺ សម្មុខាវិន័យ ១ តិណវត្ថារកៈ ១ ក៏មាន ។ ពាក្យដែលបណ្ឌិតតែងពោលថា ក៏មាន ដូច្នេះ ។ ពាក្យនោះ ដូចសំដែងត្រង់បទណា ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ បង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោលនិងព្យាយាមធ្វើល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយក្នុងទីនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើយើងទាំងឡាយនាំបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោលនិងព្យាយាមធ្វើល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន បើយើងទាំងឡាយនឹងញុំាងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងឡាយនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក (សង្ឃ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យរម្ងាប់អធិករណ៍មានសភាពយ៉ាងនេះ ដោយតិណវត្ថារកៈ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់អធិករណ៍យ៉ាងនេះ ។ ភិក្ខុទាំងឡាយពល់គ្នាត្រូវប្រជុំក្នុងទីជាមួយគ្នា លុះប្រជុំគ្នាហើយ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កថញ្ច សង្ឃោ អញ្ញតរំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ អធិករណំ តិណវត្ថារកេន វូបសមេយ្យ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិបដិសំយុត្តន្តិ ។ ឯកតោបក្ខិកានំ ភិក្ខូនំ ព្យត្តេន ភិក្ខុនា បដិពលេន សកោ បក្ខោ ញាបេតព្វោ សុណន្តុ មេ អាយស្មន្តានំ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ ។ យទាយស្មន្តានំ បត្តកល្លំ អហំ យា ចេវ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាលយើងទាំងឡាយបង្កហេតុឈ្លោះ ទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោលនូវពាក្យហាមធ្វើល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ៗ បើយើងទាំងឡាយនឹងញុំាងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងឡាយនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក (សង្ឃ) ៗ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់នូវអធិករណ៍នេះ ដោយតិណវត្ថារកៈ វៀរលែងតែអាបត្តិដែលមានទោសធំ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្តចេញ ៗ បណ្តាភិក្ខុទាំងឡាយដែលជាបក្សពួកជាមួយគ្នា ភិក្ខុអ្នកឈ្លាសប្រតិពលគួរផ្តៀងពួករបស់ខ្លួនថា លោកមានអាយុទាំងឡាយចូរស្តាប់ខ្ញុំ កាលយើងទាំងឡាយនាំគ្នាបង្កហេតុឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោលនូវពាក្យហាមធ្វើល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ៗ ប្រសិនបើយើងទាំងឡាយនឹងញុំាងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងឡាយនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក(សង្ឃ) ៗ បើកម្មមានកាលដ៏សមគួរដល់លោកមានអាយុទាំងឡាយហើយ ខ្ញុំគប្បីសំដែងអាបត្តិរបស់លោកមានអាយុទាំងឡាយផង អាបត្តិរបស់ខ្លួនខ្ញុំផង ដោយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាយស្មន្តានញ្ចេវ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេយ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ។

(១០៨) អថាបរេសំ ឯកតោបក្ខិកានំ ភិក្ខូនំ ព្យត្តេន ភិក្ខុនា បដិពលេន សកោ បក្ខោ ញាបេតព្វោ សុណាតុ មេ អាយស្មន្តា អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ ។ យទាយស្មន្តានំ បត្តកល្លំ អហំ យា ចេវ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ អាយស្មន្តានញ្ចេវ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេយ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ ដើម្បីប្រយោជន៍ដល់លោកមានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធំ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្តចេញ ។

[១០៨] បណ្តាភិក្ខុទាំងឡាយ ដែលជាបក្ខពួកជាមួយគ្នាម្ខាងទៀត ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្ទៀងពួករបស់ខ្លួនថា លោកមានអាយុទាំងឡាយចូរស្តាប់ខ្ញុំ កាលដែលយើងទាំងឡាយនាំគ្នាបង្កហេតុឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោលទំនងពាក្យហាមផ្តើលើសខុសកិច្ច មិនមែនជារបស់សមណៈជាច្រើន ៗ ប្រសិនបើយើងទាំងឡាយនឹងញ៉ាំងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងឡាយនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបែក(សង្ឃ) ។ បើកម្មមានកាលដ៏សមគួរដល់លោកមានអាយុទាំងឡាយហើយ ខ្ញុំគប្បីសំដែងអាបត្តិរបស់លោកមានអាយុទាំងឡាយផង អាបត្តិរបស់ខ្លួនខ្ញុំផង ដោយតិណវត្ថារកៈក្នុងកណ្តាលជំនុំសង្ឃ ដើម្បីប្រយោជន៍ដល់លោកមានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធំ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្តចេញ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(១០៩) ឯកតោបក្ខិកានំ ភិក្ខូនំ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡតាយ វាឡតាយ ភេទាយ សំវត្តេយ្យ ។ យទិ សង្ឃស្ស បត្តកល្លំ អហំ យា ចេវ ឥមេសំ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ ឥមេសញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេយ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ ។ សចេ មយំ ឥមាហិ អាបត្តីហិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកៈ ការសំដែងដោយតិណវត្ថារកៈកណ្តាលជំនុំសង្ឃ

(១០៩) បណ្តាភិក្ខុទាំងឡាយដែលជាបក្សពួកជាមួយគ្នា ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលដែលយើងទាំងឡាយនាំគ្នាបង្កហេតុឈ្លោះទាស់ទែងគ្នា ក៏បានប្រព្រឹត្តអនាចារ បានពោលនិងព្យាយាមធ្វើល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើនៗ ប្រសិនបើយើងទាំងឡាយនឹងញុំាងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងឡាយនេះក៏បានដែរ តែអធិករណ៍នោះគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីរឹងរូស ដើម្បីអំណាច ដើម្បីបំបែក(សង្ឃ)ៈ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំគប្បីសំដែងអាបត្តិរបស់លោកមានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្ញុំផង ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ ដើម្បីប្រយោជន៍ដល់លោក មានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធំ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្តចេញ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលដែលយើងទាំងឡាយនាំគ្នាបង្កហេតុឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោលនិងព្យាយាមធ្វើល្មើសនូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ៗ ប្រសិនបើយើងទាំងឡាយនឹងញុំាងគ្នានឹងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះក៏បានដែរ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ ។ អហំ យាចេវ ឥមេសំ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ ឥមេសញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេមិ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិបដិសំយុត្តំ ។ យស្សាយស្មតោ ខមតិ អម្ហាកំ ឥមាសំ អាបត្តីនំ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសនា ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិបដិសំយុត្តំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទេសិតា អម្ហាកំ ឥមា អាបត្តិយោ សង្ឃមជ្ឈេ តិណវត្ថារកេន ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិបដិសំយុត្តំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក (សង្ឃ) ។ ខ្ញុំសូមសំដែងអាបត្តិរបស់លោកមានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ដោយតិណវត្ថារកៈ ក្នុងកណ្តាលជុំនុំសង្ឃ ដើម្បីប្រយោជន៍ដល់លោកមានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធំ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្តចេញ ។ ការសំដែងអាបត្តិទាំងឡាយនេះរបស់យើងទាំងឡាយដោយតិណវត្ថារកៈ ក្នុងកណ្តាលជុំនុំសង្ឃ វៀរលែងតែអាបត្តិដែលមានទោសធំ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្តចេញ ។ ការសំដែងអាបត្តិនេះសមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនសមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីពោលឡើង ។ អាបត្តិទាំងឡាយនេះ យើងទាំងឡាយបានសំដែងហើយ ដោយតិណវត្ថារកៈ ក្នុងកណ្តាលជុំនុំសង្ឃ វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្តចេញ ការសំដែងនេះសមគួរដល់សង្ឃ ព្រោះហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អថាបរេសំ ។ បេ ។ ឯវមេតំ ធារយាមីតិ ។ ឥទំ វុច្ចតិ
ភិក្ខវេ អធិករណំ វូបសន្តំ ។ កេន វូបសន្តំ ។
សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ កិញ្ច តត្ថ សម្មុ-
ខាវិនយស្មឹ ។ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខ-
តា បុគ្គលសម្មុខតា ។ កា ច តត្ថ សង្ឃសម្មុខតា ។
យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារ-
ហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា ន បដិ-
ក្កោសន្តិ អយំ តត្ថ សង្ឃសម្មុខតា ។ កា ច តត្ថ ធម្ម-
សម្មុខតា វិនយសម្មុខតា ។ យេន ធម្មេន យេន
វិនយេន យេន សត្ថុសាសនេន តំ អធិករណំ វូបសម្មតិ
អយំ តត្ថ ធម្មសម្មុខតា វិនយសម្មុខតា ។ កា ច
តត្ថ បុគ្គលសម្មុខតា ។ យោ ច ទេសេតិ យស្ស ច
ទេសេតិ ឧភោ សម្មុខីភូតា ហោន្តិ អយំ តត្ថ បុគ្គ-
លសម្មុខតា ។ កិញ្ច តត្ថ តិណវត្ថារកស្មឹ ។ យា
តិណវត្ថារកស្ស កម្មស្ស កិរិយា ករណំ ឧបគមនំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លំដាប់នោះភិក្ខុទាំងឡាយ ១ ពួកទៀត ។ បេ ។ ខ្ញុំសូមបាំងទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអធិករណ៍រម្ងាប់ហើយ ។ អធិករណ៍នោះរម្ងាប់ដោយធម៌អ្វី ។ រម្ងាប់ដោយសម្មុខាវិន័យនឹងតិណវត្ថារកៈ ។ ក្នុងសម្មុខាវិន័យនោះ តើមានអង្គដូចម្តេច ។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ) ។ ចុះការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះតើដូចម្តេច ។ ភិក្ខុទាំងឡាយដែលគួរដល់កម្មមានចំនួនប៉ុន្មានរូប ភិក្ខុទាំងនោះក៏បានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏បាននាំមកហើយ ភិក្ខុទាំងឡាយមាននៅក្នុងទីចំពោះមុខ ក៏មិនបានហាមឃាត់ នេះហៅថាការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ ។ ចុះការចំពោះមុខធម៌នឹងការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ។ អធិករណ៍នោះរម្ងាប់តាមធម៌ណា តាមវិន័យណា តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា នេះហៅថាការចំពោះមុខធម៌ នឹងការចំពោះមុខវិន័យក្នុងសម្មុខាវិន័យនោះ ។ ចុះការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច ។ បុគ្គលទាំងពីររូបដែលសំដែងអាបត្តិ ដល់គ្នានឹងគ្នាក៏មាននៅក្នុងទីចំពោះមុខ នេះហៅថាការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ ។ ក្នុងតិណវត្ថារកៈមានកិច្ចដូចម្តេច ។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អជ្ឈុបគមនំ អធិវាសនា អប្បដិក្កោសនា ឥទំ តត្ថ តិណវត្ថារកស្មឹ ។ ឯវំ វូបសន្តំ ចេ ភិក្ខវេ អធិករណំ បដិគ្គាហកោ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយំ ។ ឆន្ទទាយកោ ខីយតិ ខីយនកំ បាចិត្តិយំ ។

(១១០) កិច្ចាធិករណំ កតីហិ សមថេហិ សម្មតិ ។ កិច្ចាធិករណំ ឯកេន សមថេន សម្មតិ សម្មុខាវិនយេនាតិ ។

សមថក្ខន្ធកំ និដ្ឋិតំ ចតុត្ថំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ការចូលទៅកែបនែប ការទទួល និងការមិនហាមឃាត់នូវតិណវត្ថារកកម្មណា នេះជាកិច្ចក្នុងតិណវត្ថារកកម្មនោះ ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកទទួលត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយត្រឡប់តិះដៀលវិញ ត្រូវខីយនកបាចិត្តិយៈ ។

(១១០) កិច្ចាធិករណ៍រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ កិច្ចាធិករណ៍រម្ងាប់ដោយសមថៈតែមួយ គឺសម្មុខាវិន័យ ។

ចប់ សមថក្ខន្ធកៈ ទី ៤ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕

# ខុទ្ទកវត្ថុក្ខន្ធកំ

៥ ១២៥

(១១១) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ នហាយមានា រុក្ខេ កាយំ ឧគ្ឃំសេន្តិ ឩរុម្បិ ពាហុម្បិ(១) ឧរម្បិ បិដ្ឋិម្បិ ។ មនុស្សា បស្សិត្វា(២) ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា នហាយមានា រុក្ខេ កាយំ ឧគ្ឃំសេស្សន្តិ ឩរុម្បិ ពាហុម្បិ ឧរម្បិ បិដ្ឋិម្បិ សេយ្យថាបិ មល្លមុដ្ឋិកា គាមបូជកាតិ(៣) ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ បេ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ នហាយមានា រុក្ខេ កាយំ ឧគ្ឃំសេន្តិ ឩរុម្បិ ពាហុម្បិ ឧរម្បិ បិដ្ឋិម្បីតិ ។

---

១ ឧរោបិយបោត្ថកេ ពាហម្បីតិ បាឋោ អាគតោ ។ ២ អយំ បាឋោ ទ. ម. បោត្ថកេសុ នទិស្សតិ ។ ៣ ឧរោបិយបរម្ហបោត្ថកេសុ គាមបោទ្ទវាតិ បាឋោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# ខុទ្ទកវត្ថុក្ខន្ធកៈ

(១១១) សម័យនោះ ព្រះពុទ្ធមានព្រះភាគទ្រង់គង់នៅវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ពួកឆព្វគ្គិយ-ភិក្ខុនាំគ្នាងូតទឹកហើយត្រដុសកាយ ត្រង់ក្លៀខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងដើមឈើ ។ មនុស្សទាំងឡាយបានឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តិយ៍មិនសមបើនឹងមកងូតទឹកត្រដុសកាយ ត្រង់ក្លៀខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះនឹងដើមឈើ ដូចអ្នកប្រដាល់ ឬដូចពួកមនុស្សអ្នកនៅក្នុងក្រុង ដែលជាអ្នកខ្វល់ខ្វាយនឹងការប្រដាប់កាយដូច្នេះសោះ ។ ពួកភិក្ខុបានឮមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។ បេ ។ គ្រានោះ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃហើយ ទ្រង់សួរបញ្ជាក់ពួកភិក្ខុ ក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយភិក្ខុនាំគ្នាងូតទឹកត្រ-ដុសកាយត្រង់ក្លៀខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះនឹងដើមឈើ ពិតមែនឬ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ(១) ភិក្ខវេ តេសំ មោឃបុរិសានំ អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា នហាយមានា រុក្ខេ កាយំ ឧគ្ឃំសេស្សន្តិ ឩរុម្បិ ពាហុម្បិ ឧរម្បិ បិដ្ឋិម្បិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ នហាយមានេន(២) រុក្ខេ កាយោ ឧគ្ឃំសេតព្វោ យោ ឧគ្ឃំសេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១១២) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ នហាយមានា ថម្ភេ កាយំ ឧគ្ឃំសេន្តិ ឩរុម្បិ ពាហុម្បិ ឧរម្បិ បិដ្ឋិម្បិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា នហាយមានា ថម្ភេ កាយំ ឧគ្ឃំសេស្សន្តិ ឩរុម្បិ ពាហុម្បិ ឧរម្បិ បិដ្ឋិម្បិ សេយ្យថាបិ មល្លមុដ្ឋិកា គាមបូជកាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ

១ ឱ. អននុច្ឆវិយំ ។ ២ ឥតោ បរំ ឱរោបិយមរម្មបោត្ថកេសុ ភិក្ខុនាតិ បាឋោ បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ ព្រះពុទ្ធមានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃ-បុរសទាំងនោះជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ នែភិក្ខុទាំងឡាយ មោឃបុរសទាំងនោះមិនសមបើនឹងមកនាំគ្នាងូតទឹក ត្រដុសកាយត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងដើមឈើទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយក៏ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុងូតទឹកមិនត្រូវត្រដុសកាយនឹងដើមឈើទេ ភិក្ខុណាត្រដុស ត្រូវអាបត្តិទុក្កដ ។

(១១២) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាងូតទឹកត្រដុសកាយត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងសសរ[១]។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តិយមិនសមបើនឹងងូតទឹកត្រដុសកាយត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងសសរ ដូចអ្នកប្រដាល់ ឬដូចពួកមនុស្សអ្នកនៅក្នុងក្រុង ដែលជាអ្នកខ្វល់ខ្វាយនឹងការប្រដាប់កាយសោះ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះ

---

១ សសរដែលគេបោះទុកក្បែរកំពង់សម្រាប់ងូតទឹក ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ បេ ។ អថខោ
តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ
កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ វិគរហិត្វា ធម្មឹ កថំ
កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ នហាយមានេន
ថម្ភេ កាយោ ឧគ្ឃំសេតព្វោ យោ ឧគ្ឃំសេយ្យ អាបត្តិ
ទុក្កដស្សាតិ ។

(១១៣) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ
នហាយមានា កុឌ្ឌេ កាយំ ឧគ្ឃំសេន្តិ ឩរុម្បិ ពាហុម្បិ
ឧរម្បិ បិដ្ឋិម្បិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ
កថំ ហិ នាម សមណា សក្យបុត្តិយា នហាយមានា
កុឌ្ឌេ កាយំ ឧគ្ឃំសេស្សន្តិ ឩរុម្បិ ពាហុម្បិ ឧរម្បិ
បិដ្ឋិម្បិ សេយ្យថាបិ មល្លមុដ្ឋិកា គាមបូជកាតិ ។ បេ ។
ន ភិក្ខវេ នហាយមានេន កុឌ្ឌេ កាយោ ឧគ្ឃំសេតព្វោ
យោ ឧគ្ឃំសេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។បេ។ វេលានោះ ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពិតមែនឬ ។បេ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ ព្រះមានព្រះភាគទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយ មកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុងូតទឹកមិនត្រូវត្រដុសកាយនឹងសសរទេ ភិក្ខុណាត្រដុស ត្រូវអាបត្តិទុក្កដ ។

( ១១៣ ) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាងូតទឹកត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះនឹងជញ្ជាំង ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យ-បុត្តិយមិនសមបើនឹងមកងូតទឹកត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះនឹងជញ្ជាំង ដូចអ្នកប្រដាល់ ឬដូចពួកមនុស្សអ្នកនៅ ក្នុងក្រុង ដែលជាអ្នកខ្វល់ខ្វាយនឹងការប្រដាប់កាយសោះ ។បេ។ ព្រះមានបុណ្យទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុងូតទឹក មិនត្រូវត្រដុសកាយនឹងជញ្ជាំងទេ ភិក្ខុណាត្រដុស ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



[១១៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ នហាយមានា អដ្ឋានេ នហាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ បេ ។ អថ ខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ នហាយមានេន អដ្ឋានេ នហាយិតព្វំ យោ នហាយេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[១១៧] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ គន្ធព្វហត្ថកេន នហាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(១១៨) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកាលងូតទឹក ក៏នាំគ្នាទៅដុសក្នុងទីមិនគួរ(១) ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ។ បេ ។ ដូចជាពួកគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។ បេ ។ គ្រានោះ ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយពិតមែនឬ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ បេ ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលងូតទឹក មិនត្រូវដុសក្នុងទីមិនគួរទេ ភិក្ខុណាដុស ត្រូវអាបត្តិទុក្កដ ។

(១១៩) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាងូតទឹក ដោយឈើដែលគេធ្វើជាដៃគន្ធព្វ(២) ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល

---

១ ឈើដែលគេយកទៅបោះធ្វើជាដែនក្តារ ហើយធ្វើឲ្យមានស្នាមគំនូសដូចជាក្រឡាបត្រង្គ ហើយដីកដាំទុកក្បែរកំពង់សម្រាប់ងូតទឹក ហៅថា ទីមិនគួរ មនុស្សយកគ្រឿងលំអ ទៅដាក់ក្នុងដែនក្តារនោះហើយត្រដុសកាយ ។ ២ ឈើដែលគេធ្វើដូចជាដៃមនុស្សហើយគេដាំទុកក្បែរកំពង់សម្រាប់ងូតទឹក មនុស្សទាំងឡាយយកគ្រឿងលំអិតទៅដាក់ត្រង់ឈើនោះ ហើយត្រដុសកាយដោយឈើនោះ (អដ្ឋកថា) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ចាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ បេ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ គន្ធព្វហត្ថកេន នហាយិតព្វំ យោ នហាយេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១១៦) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កុរុវិន្ទកសុត្តិយា នហាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោ-គិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ កុរុវិន្ទកសុត្តិយា នហាយិតព្វំ យោ នហា-យេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១១៧) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ វិគ្គយ្ហ បរិកម្មំ ការាបេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបា-ចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



បន្ទះបន្ទាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះក៏ពោលទោស តិះដៀល បន្ទះបន្ទាប់ ។បេ។ គ្រានោះ ភិក្ខុទាំងនោះក៏បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវងូតទឹកដោយឈើដែលគេធ្វើជាដៃគន្ធព្វទេ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ ។

(១១៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាងូតទឹកដោយដុំលំអិតថ្មឈ្មោះកុរុវិន្ទកៈ(១) ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្ទះបន្ទាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។បេ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវងូតទឹក ដោយដុំលំអិតថ្មឈ្មោះកុរុវិន្ទកៈឡើយ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ ។

(១១៧) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុញាំងគ្នានឹងគ្នាឲ្យធ្វើបរិកម្ម(២)ទៅវិញទៅមក ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្ទះបន្ទាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។បេ។

១ គេយកលំអិតថ្មឈ្មោះកុរុវិន្ទកៈមកលាយប្របល់នឹងល័ក្ខហើយសូនធ្វើជាដុំ ហើយស្រេះដោយអម្បោះ ហើយកាន់របស់នោះខាងចុងខាងដើម ហើយដុះកាយក្នុងវេលាងូតទឹក (អដ្ឋកថា) ។ ២ ដុសខ្លួននឹងខ្លួនទៅវិញទៅមក ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ វិក្កយ្ហ បរិកម្មំ ការាបេតព្វំ យោ ការាបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១១៨) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ មល្លកេន នហាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ មល្លកេន នហាយិតព្វំ យោ នហា-យេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១១៩) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ កច្ឆុរោគាពាធោ ហោតិ ។ តស្ស វិនា មល្លកា ន ផាសុ ហោតិ[១] ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ គិលានស្ស អកតមល្លកន្តិ ។

---

១ ម. ន តស្ស វិនា មល្លកេន ផាសុ ហោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវញុំាងគ្នានឹងគ្នាឲ្យធ្វើបរិកម្មទៅវិញទៅមកទេ ភិក្ខុណាឲ្យធ្វើ ត្រូវអាបត្តិទុក្កដ ។

[១១៨] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដូតទឹកដោយឈើមានសណ្ឋានដូចជើងកន្ធោរ[១] ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀលបន្ទះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដូតទឹកដោយឈើមានសណ្ឋានដូចជើងកន្ធោរទេ ភិក្ខុណាដូត ត្រូវអាបត្តិទុក្កដ ។

[១១៩] សម័យនោះឯង មានភិក្ខុ១រូបកើតអាពាធកមរមាស់ ។ ភិក្ខុនោះវៀរចាកឈើមានសណ្ឋានដូចជើងកន្ធោរ ក៏មិនបានសេចក្តីសប្បាយ ។ បេ ។ ភិក្ខុទាំងឡាយ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើមានសណ្ឋានដូចជើងកន្ធោរ ដែលគេមិនបានឆ្លាក់ជាក្បាច់ចេញមក ដល់ភិក្ខុមានជម្ងឺ ។

---

១ ឈើដែលគេឆ្លាក់ជាក្បាច់ចេញមក ហើយធ្វើឲ្យមានទ្រង់ទ្រាយដូចជើងកន្ធោរ (អដ្ឋកថា) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១២០) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ជរាទុព្វលោ នហាយមានោ ន សក្កោតិ អត្តនោ កាយំ ឧបឃំសេតុំ(១) ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧក្កាសិកន្តិ ។

(១២១) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បិដ្ឋិបរិកម្មំ កាតុំ កុក្កុច្ចាយតិ(២) ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ បុថុបាណិកន្តិ(៣) ។

(១២២) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ វល្លិកំ ធារេន្តិ ។ បេ ។ បាមង្គំ ធារេន្តិ ។ កណ្ឋសុត្តកំ ធារេន្តិ ។ កដិសុត្តកំ ធារេន្តិ ។ ឱវដ្ដិកំ ធារេន្តិ ។ កាយុរំ ធារេន្តិ ។ ហត្ថាភរណំ ធារេន្តិ ។ អង្គុលិមុទ្ទិកំ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី

---

១ ឱ. ម. ឧគ្ឃំសេតុំ ។ ២ ឱ. ម. ពោត្ថកេសុ តេន ខោ បន សមយេន ភិក្ខូ បិដ្ឋិបរិកម្មំ កាតុំ កុក្កុច្ចាយន្តីតិ វចនំ អាគតំ ។ ៣ ឱ. បុថុបាណិយន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## ខុទ្ទកវត្ថុក្ខន្ធកៈ រឿងភិក្ខុចាស់ជរាកំលាំងថយ នហានវត្ត

(១៦០) សម័យនោះឯង មានភិក្ខុ ១ រូបចាស់ជរាកំឡាំងថយ កាលបើងូតទឹកមិនអាចនឹងដុសកាយខ្លួនឯងបាន ។ បេ ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆ្នាញ់សំពត់(១) (សម្រាប់ភិក្ខុចាស់ជរាងូតទឹកដុសខ្លួនបាន) ។

(១៦១) សម័យនោះឯង មានភិក្ខុ ១ រូបរង្កៀសនឹងការបរិកម្មខ្លួន (ដុសខ្លួន) ។ បេ ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការដុសខ្លួនដោយដៃបាន ។

(១៦២) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទ្រទ្រង់គ្រឿងប្រដាប់ត្រចៀក(២) ។ បេ ។ ទ្រទ្រង់សង្វារ ។ ទ្រទ្រង់គ្រឿងប្រដាប់ក ។ ទ្រទ្រង់គ្រឿងប្រដាប់ចង្កេះ ។ ពាក់កង ។ ទ្រទ្រង់គ្រឿងប្រដាប់ដើមដៃ(៣) ។ ទ្រទ្រង់គ្រឿងប្រដាប់ដៃ ។ ពាក់ចិញ្ចៀន ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថ

---

១ ឆ្នាញ់ឬធ្នុងសំពត់ដែលគេត្របាញ់ ។ ២ គ្រឿងប្រដាប់ត្រចៀកដែលគេព្យួរសំយុងចុះឲ្យផុតអំពីត្រចៀកជាដើម (បើតាមដីកាថាគ្រឿងប្រដាប់ត្រចៀកមានកណ្ឌលជាដើម) ។ អដ្ឋកថា។
៣ ព្រះសុវណ្ណពាហុរតន៍ (កន្ត្រុំ) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។បេ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្ពគ្គិយា ភិក្ខូ វល្លិកំ ធារេន្តិ ។ ពាមង្គំ ធារេន្តិ។ កណ្ណសុត្តកំ ធារេន្តិ ។ កដិសុត្តកំ ធារេន្តិ ។ ឱវដ្ដិកំ ធារេន្តិ ។ កាយុរំ ធារេន្តិ ។ ហត្ថាភរណំ ធារេន្តិ ។ អង្គុលិមុទ្ទិកំ ធារេន្តីតិ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ វល្លិកា ធារេតព្វា ន ពាមង្គំ ធារេតព្វំ ន កណ្ណសុត្តកំ ធារេតព្វំ ន កដិសុត្តកំ ធារេតព្វំ ន ឱវដ្ដិកំ ធារេតព្វំ ន កាយុរំ ធារេតព្វំ ន ហត្ថាភរណំ ធារេតព្វំ ន អង្គុលិមុទ្ទិកំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៦៣) តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ទីឃេ កេសេ[១] ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហីតិ

១ កត្ថចិ បោត្ថកេ ទីឃកេសេតិ បាឋោ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះក៏ពុំពោលទោស តិះដៀល បន្តុះបង្អាប់ ។បេ។ លំដាប់នោះ ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយភិក្ខុទ្រទ្រង់គ្រឿងប្រដាប់ត្រចៀក ។ ទ្រទ្រង់សង្វារ ។ ទ្រទ្រង់គ្រឿងប្រដាប់ក ។ ទ្រទ្រង់គ្រឿងប្រដាប់ចង្កេះ ។ ពាក់កង ។ ទ្រទ្រង់គ្រឿងប្រដាប់ដើមដៃ ។ ទ្រទ្រង់គ្រឿងប្រដាប់ដៃ ។ ពាក់ចិញ្ចៀន ពិតមែនឬ ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។បេ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ត្រចៀក មិនត្រូវទ្រទ្រង់សង្វារ មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ក មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ចង្កេះ មិនត្រូវពាក់កង មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ដើមដៃ មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ដៃ មិនត្រូវពាក់ចិញ្ចៀន ភិក្ខុណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ ។

(១២៣) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទុកសក់វែង ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។បេ។ ដូចពួកគ្រហស្ថ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ទីឃា កេសា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ ទុមាសិកំ វា ទ្វង្គុលំ វាតិ ។

(១២៤) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កោច្ឆេន កេសេ ឱសណ្ឋេន្តិ ។ ផណកេន កេសេ ឱសណ្ឋេន្តិ ។ ហត្ថផណកេន កេសេ ឱសណ្ឋេន្តិ ។ សិត្ថតេលកេន កេសេ ឱសណ្ឋេន្តិ ។ ឧទកតេលកេន កេសេ ឱសណ្ឋេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ កោច្ឆេន កេសា ឱសណ្ឋេតព្វា ន ផណកេន កេសា ឱសណ្ឋេតព្វា ន ហត្ថផណកេន កេសា ឱសណ្ឋេតព្វា ន សិត្ថតេលកេន កេសា ឱសណ្ឋេតព្វា ន ឧទកតេលកេន កេសា ឱសណ្ឋេតព្វា យោ ឱសណ្ឋេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អ្នកបរិភោគកាម ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកសក់វែងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យទុកសក់កំណត់កាលត្រឹមពីរខែ ឬកំណត់ត្រឹមពីរធ្នាប់(១) ។

(១២៨) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសិតសក់ដោយស្និត ។ សិតសក់ដោយក្រាស ។ ជ្រងសក់ដោយក្រាស គឺដៃធ្វើជាក្រាស ។ សិតសក់ដោយក្រមួនទឹងប្រេង ។ សិតសក់ដោយប្រេងដែលលាយដោយទឹក ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសិតសក់ដោយស្និត មិនត្រូវសិតសក់ដោយក្រាស មិនត្រូវជ្រងសក់ដោយដៃធ្វើជាក្រាស មិនត្រូវសិតសក់ដោយក្រមួនទឹងប្រេង មិនត្រូវសិតសក់ដោយប្រេង ដែលលាយដោយទឹកទេ ភិក្ខុណាសិត ត្រូវអាបត្តិទុក្កដ ។

១ ពីរធ្នាប់ទទឹងម្រាមដៃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១២៥] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អាធារេបិ ឧទកបត្តេបិ មុខនិមិត្តំ ឱលោកេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ អាធារេ វា ឧទកបត្តេ វា មុខនិមិត្តំ ឱលោកេតព្វំ ។ យោ ឱលោកេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[១២៦] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ មុខេ វណោ ហោតិ ។ សោ ភិក្ខូ បុច្ឆិ កីទិសោ មេ អាវុសោ វណោតិ ។ ភិក្ខូ ឯវមាហំសុ ឦទិសោ[១] តេ អាវុសោ វណោតិ ។ សោ ន សទ្ទហតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា អាធារេ វា ឧទកបត្តេ វា មុខនិមិត្តំ ឱលោកេតុន្តិ ។

---

១ ម. ឯទិសោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៤៥) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមើលមុខនិមិត្តគឺស្រមោលមុខក្នុងកញ្ចក់ខ្លះ ក្នុងភាជនៈទឹកខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវមើលមុខនិមិត្ត ក្នុងកញ្ចក់ ឬក្នុងភាជនៈទឹកទេ ភិក្ខុណាមើល ត្រូវអាបត្តិទុក្កដ ។

(១៤៦) សម័យនោះឯង មានភិក្ខុ ១ រូបកើតដំបៅត្រង់មុខ ។ ភិក្ខុនោះសួរភិក្ខុទាំងឡាយថា ម្នាលលោកមានអាយុ ដំបៅខ្ញុំដូចម្តេចទៅ ។ ភិក្ខុទាំងឡាយប្រាប់យ៉ាងនេះថា ម្នាលលោកមានអាយុ ដំបៅលោកដូច្នេះ ។ ភិក្ខុនោះមិនជឿ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានអាពាធជាហេតុ តថាគតអនុញ្ញាតឲ្យភិក្ខុមើលនិមិត្តក្នុងកញ្ចក់ ឬក្នុងភាជនៈទឹកបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១២៧) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ មុខំ អាលិម្បេន្តិ[១] ។ មុខំ ឧម្មទ្ទេន្តិ ។ មុខំ ចុណ្ណេន្តិ ។ មនោសិលកាយ[២] មុខំ លញ្ឆេន្តិ[៣] ។ អង្គរាគំ ករោន្តិ ។ មុខរាគំ ករោន្តិ ។ អង្គរាគមុខរាគំ ករោន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ មុខំ អាលិម្បិតព្វំ ន មុខំ ឧម្មទ្ទិតព្វំ ន មុខំ ចុណ្ណេតព្វំ ន មនោសិលកាយ មុខំ លញ្ឆេតព្វំ ន អង្គរាគោ កាតព្វោ ន មុខរាគោ កាតព្វោ ន អង្គរាគមុខរាគោ កាតព្វោ យោ ករេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១២៨) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ចក្ខុរោគាពាធោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា មុខំ អាលិម្បិតុន្តិ ។

---

១ ឱ. ម. អាលិម្បន្តិ ។ ២ ឱ. ម. មនោសិលិកាយ ។ ៣ ឱ. លញ្ជន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(១២៧) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាផាត់មុខ ។ ដុសខាត់មុខ ។ ប្រស់មុខ ។ ចុចមុខដោយថ្នាំមនោសិលា ។ ធ្វើការលាបខ្លួន ។ ធ្វើការលាបមុខ ។ ធ្វើការលាបទាំងខ្លួនទាំងមុខ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវផាត់មុខ មិនត្រូវដុសខាត់មុខ មិនត្រូវប្រស់មុខ មិនត្រូវចុចមុខដោយថ្នាំមនោសិលា មិនត្រូវធ្វើការលាបខ្លួន មិនត្រូវធ្វើការលាបមុខ មិនត្រូវធ្វើការលាបទាំងខ្លួនទាំងមុខទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ។

(១២៨) សម័យនោះឯង មានភិក្ខុ ១ រូបកើតអាពាធឈឺភ្នែក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានអាពាធជាហេតុ តថាគតអនុញ្ញាតឲ្យភិក្ខុផាត់មុខបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១២៩) តេន ខោ បន សមយេន រាជគហេ គិរគ្គសមជ្ជោ ហោតិ ។ ឆព្វគ្គិយា ភិក្ខូ គិរគ្គសមជ្ជំ ទស្សនាយ អគមំសុ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា នច្ចម្បិ គីតម្បិ វាទិតម្បិ ទស្សនាយ គច្ឆិស្សន្តិ(១) សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ នច្ចំ វា គីតំ វា វាទិតំ វា ទស្សនាយ គន្តព្វំ យោ គច្ឆេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៣០) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អាយតកេន គីតស្សរេន ធម្មំ គាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ យថេវ មយំ គាយាម ឯវមេវិមេ សមណា សក្យបុត្តិយា អាយតកេន គីតស្សរេន ធម្មំ គាយន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ

---

១ ម. អាគច្ឆិស្សន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១២៩) សម័យនោះឯង មានល្បែងមហោស្រពលើកំពូលភ្នំ ទៀបក្រុងរាជគ្រឹះ ។ ពួកឆព្វគ្គិយភិក្ខុនាំគ្នាទៅមើលល្បែងមហោស្រពលើកំពូលភ្នំ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈសក្យបុត្តិយ៍មិនសមបើនឹងទៅមើលរាំ ឬស្តាប់ច្រៀង ទឹងស្តាប់ភ្លេងប្រគំ ដូចពួកគ្រហស្ថអ្នកបរិភោគកាមដូច្នេះសោះ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទៅមើលរាំ ស្តាប់ច្រៀង ឬភ្លេងប្រគំទេ ភិក្ខុណាទៅ ត្រូវអាបត្តិទុក្កដ ។

(១៣០) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុច្រៀងធម៌ដោយសម្លេងច្រៀងដ៏វែង [១] ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា យើងច្រៀងយ៉ាងណាមិញ ពួកសមណៈសក្យបុត្តិយ៍ទាំងនេះក៏ច្រៀងធម៌ដោយសម្លេងច្រៀងដ៏វែង [១] យ៉ាងនោះដែរ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អាយតកេន គីតស្សរេន ធម្មំ គាយិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ បញ្ចិមេ ភិក្ខវេ អាទីនវា អាយតកេន គីតស្សរេន ធម្មំ គាយន្តស្ស អត្តនាបិ[១] តស្មឹ សរេ សារជ្ជតិ បរេបិ តស្មឹ សរេ សារជ្ជន្តិ គហបតិកាបិ ឧជ្ឈាយន្តិ សរកុត្តិបិ និកាមយមានស្ស សមាធិស្ស ភង្គោ ហោតិ បច្ឆិមា ជនតា ទិដ្ឋានុគតិមាបជ្ជតិ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា អាយតកេន គីតស្សរេន ធម្មំ គាយន្តស្ស ។ ន ភិក្ខវេ អាយតកេន គីតស្សរេន ធម្មោ គាយិតព្វោ យោ គាយេយ្យ អាបត្តិ ទុក្កដស្សាតិ ។

---

១ ឱ. ម. អត្តនាបិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងច្រៀងធម៌ដោយសម្លេងច្រៀងដ៏វែង ៗ ដូច្នេះសោះ ។ លំដាប់នោះ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូលព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពិតមែនឬ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ បេ ។ ព្រះអង្គទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ទោសទាំង ៥ នេះនឹងមានដល់ភិក្ខុអ្នកច្រៀងធម៌ ដោយសម្លេងច្រៀងវែង ៗ គឺ ភិក្ខុនោះត្រេកអរក្នុងសម្លេងរបស់ខ្លួននោះ ១ ជនទាំងឡាយដទៃរមែងត្រេកអរក្នុងសម្លេងនោះ ១ គហបតីទាំងឡាយតែងពោលទោស ១ បុគ្គលដែលពេញចិត្តនឹងការសូត្រលាក់រលេក សម្លេងរមែងខូចសមាធិ ១ ពួកជនខាងក្រោយនឹងដល់នូវទិដ្ឋានុគតិ (យកតម្រាប់តាម) ១ ម្នាលភិក្ខុទាំងឡាយ ទោសទាំង ៥ នេះឯង នឹងមានដល់ភិក្ខុអ្នកច្រៀងធម៌ដោយសម្លេងច្រៀងដ៏វែង ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវច្រៀងធម៌ដោយសម្លេងច្រៀងដ៏វែង ៗ ទេ ភិក្ខុណាច្រៀង ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៣១) តេន ខោ បន សមយេន ភិក្ខូ សរភញ្ញេ កុក្កុច្ចាយន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សរភញ្ញន្តិ ។

(១៣២) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ពាហិរលោមឹ ឧណ្ណឹ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ ពាហិរលោមី ឧណ្ណី ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៣៣) តេន ខោ បន សមយេន រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស អារាមេ អម្ពា ផលិនោ(១) ហោន្តិ ។ រញ្ញា ច មាគធេន សេនិយេន ពិម្ពិសារេន អនុញ្ញាតំ ហោតិ យថាសុខំ អយ្យា អម្ពំ បរិភុញ្ជន្តូតិ ។ ឆព្វគ្គិយា ភិក្ខូ តរុណញ្ញេវ អម្ពំ ធាតាបេត្វា បរិភុញ្ជឹសុ ។

---
១ ម. ផលិតា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៣១) សម័យនោះឯង ភិក្ខុទាំងឡាយរង្កៀសក្នុងសរភញ្ញ គឺការស្ងួតដោយប្រែសំឡេង(១) ។ លំដាប់នោះ ភិក្ខុទាំងនោះបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យស្ងួតសរភញ្ញបាន ។

(១៣២) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់សំពត់ដែលគេធ្វើដោយរោមសត្វ មានរោមចេញមកខាងក្រៅ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់សំពត់ដែលគេធ្វើដោយរោមសត្វ មានរោមចេញមកខាងក្រៅទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

(១៣៣) សម័យនោះឯង ក្នុងសួនរបស់ព្រះរាជាទ្រង់ព្រះនាមមាគធសេនិយពិម្ពិសារ មានស្វាយផ្លែជាច្រើន ។ ព្រះរាជាទ្រង់ព្រះនាមមាគធសេនិយពិម្ពិសារទ្រង់បវារណាថា សូមលោកម្ចាស់ទាំងឡាយនិមន្តឆាន់ផ្លែស្វាយតាមសប្បាយចុះ ។ ពួកឆព្វគ្គិយភិក្ខុនាំគ្នាបេះផ្លែស្វាយខ្ចីៗឆាន់ ។

---

១ អដ្ឋកថា ថា វត្ថុសម្រាប់ស្ងួតសរភញ្ញមាន ៣២ យ៉ាង មានតរង្គវត្ត ទោហកវត្ត និងគលិតវត្តជាដើម ។ ភិក្ខុពេញចិត្តចង់ស្ងួតដោយវត្ត បែបណាក៏បាន ប៉ុន្តែត្រូវប្រយ័ត្នកុំធ្វើបទនិងព្យញ្ជនៈឲ្យខូច ត្រូវស្ងួតដោយន័យជាចតុរស្ស សមគួរតាមសណ្តាប់ធ្នាប់របស់សមណៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រញ្ញោ ច មាគធស្ស សេនិយស្ស ពិម្ពិសារស្ស អម្ពេន អត្ថោ ហោតិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិ-សារោ មនុស្សេ អាណាបេសិ គច្ឆថ ភណេ អារាមំ គន្ត្វា អម្ពំ អាហរថាតិ ។ ឯវំ ទេវាតិ ខោ តេ មនុស្សា រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បដិស្សុត្វា អារាមំ គន្ត្វា អារាមបាលំ[១] ឯតទវោចុំ ទេវស្ស ភណេ អម្ពេន អត្ថោ អម្ពំ ទេថាតិ ។ នត្ថយ្យា[២] អម្ពំ តរុ-ណញ្ញេវ អម្ពំ ពាតាបេត្វា ភិក្ខូ បរិភុញ្ជិំសូតិ ។ អថខោ តេ មនុស្សា រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិ-សារស្ស ឯតមត្ថំ អារោចេសុំ ។ សុបរិភុត្តំ ភណេ អយ្យេហិ អម្ពំ អបិច ភគវតា មត្តា វណ្ណិតាតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ន មត្តំ ជានិត្វា រញ្ញោ អម្ពំ បរិភុញ្ជិស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ បេ ។

---

១ ម. អារាមបាលេ ។ ២ ម. នត្ថយ្យោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ក៏ជួនជា ព្រះរាជាមាគធសេនិយពិម្ពិសារទ្រង់មានសេចក្តីត្រូវការដោយផ្លែស្វាយផែ ៗ លំដាប់នោះ ព្រះរាជាមាគធសេនិយពិម្ពិសារទ្រង់បង្គាប់មនុស្សទាំងឡាយថា ម្នាលនាយ អ្នកទាំងឡាយចូរទៅសួនហើយបេះផ្លែស្វាយមក ៗ មនុស្សទាំងនោះ ទទួលព្រះរាជឱង្ការព្រះរាជាមាគធសេនិយពិម្ពិសារដោយពាក្យថា ព្រះករុណាពិសេស ហើយក៏ទៅកាន់សួននិយាយនឹងនាយអារាមបាល (អ្នករក្សាសួន) យ៉ាងនេះថា នែនាយ ព្រះសម្មតិទេពទ្រង់ត្រូវការដោយផ្លែស្វាយ ចូរអ្នកទាំងឡាយថ្វាយផ្លែស្វាយខ្លះ ៗ នាយអារាមបាលក៏ឆ្លើយថា បពិត្រលោកទាំងឡាយ ផ្លែស្វាយគ្មានទេ ព្រោះពួកភិក្ខុបេះផ្លែស្វាយខ្ចី ៗ យកទៅឆាន់អស់ហើយ ៗ លំដាប់នោះ មនុស្សទាំងនោះក៏នាំយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូលព្រះរាជាមាគធសេនិយពិម្ពិសារ ៗ ព្រះមហាក្សត្រមានព្រះបន្ទូលថា ម្នាលនាយ លោកម្ចាស់ទាំងឡាយបានឆាន់ផ្លែស្វាយ ក៏ជាការប្រពៃហើយ តែថាព្រះមានព្រះភាគ ទ្រង់សរសើរការដឹងប្រមាណ ៗ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈសក្យបុត្តិយ៍មិនសមបើនឹងឆាន់ផ្លែស្វាយរបស់ព្រះរាជាមិនដឹងប្រមាណសោះ ៗ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ៗ បេ ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ អម្ពំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៣៦) តេន ខោ បន សមយេន អញ្ញតរស្ស បូគស្ស សង្ឃភត្តំ ហោតិ ។ សូបេ អម្ពបេសិកា[1] បក្ខិត្តា ហោន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។បេ។ បដិគ្គណ្ហថ ភិក្ខវេ បរិភុញ្ជថ អនុជានាមិ ភិក្ខវេ អម្ពបេសិកន្តិ ។

(១៣៧) តេន ខោ បន សមយេន អញ្ញតរស្ស បូគស្ស សង្ឃភត្តំ ហោតិ ។ តេ ន បរិយាបុណឹសុ អម្ពបេសិកំ កាតុំ ។ ភត្តគ្គេ សកលេហេវ អម្ពេហិ ទេន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។បេ។ បដិគ្គណ្ហថ ភិក្ខវេ បរិភុញ្ជថ អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ អគ្គិបរិចិតំ សត្ថបរិចិតំ

---

១ ម. អម្ពបេសិកាយោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



លំដាប់នោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ផ្លែស្វាយ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

( ១៣៨ ) សម័យនោះ មានសង្ឃភត្តរបស់ប្រជុំជន ១ ពួក ។ ប្រជុំជននោះបានដាក់ចំណិតផ្លែស្វាយក្នុងសម្ល ។ ភិក្ខុទាំងឡាយមានសេចក្តីរង្កៀសមិនហ៊ានទទួល ។ បេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចំណិតផ្លែស្វាយ ។

( ១៣៩ ) សម័យនោះឯង មានសង្ឃភត្តរបស់ប្រជុំជន ១ ពួក ។ មនុស្សទាំងនោះមិនអាចនឹងធ្វើចំណិតផ្លែស្វាយបាន ។ ជនទាំងនោះក៏នាំយកផ្លែស្វាយទាំងមូលទៅក្នុងរោងភត្ត ។ ភិក្ខុទាំងឡាយមានសេចក្តីរង្កៀសមិនហ៊ានទទួល ។ បេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើដោយសមណកប្ប (១) ៥ យ៉ាង គឺ ផ្លែឈើដែលគេខ្ជប្ហុតកំដៅដោយភ្លើង ១ ដែលគេបោះពុះចិតដោយសស្ត្រា ១

---

១ ផ្លែឈើដែលគេធ្វើឲ្យសមគួរដល់សមណៈ ហៅថា សមណកប្ប ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



នខបរិចិតំ អពីជំ និព្វដ្ដពីជញ្ញេវ(១) បញ្ចមំ អនុជានាមិ ភិក្ខវេ ឥមេហិ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុន្តិ ។

(១៣៦) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អហិនា ទដ្ឋោ កាលកតោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ហិ នូន សោ ភិក្ខវេ ភិក្ខុ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិ ។ សចេ ហិ សោ ភិក្ខវេ ភិក្ខុ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរេយ្យ ន ហិ សោ ភិក្ខវេ ភិក្ខុ អហិនា ទដ្ឋោ កាលំ ករេយ្យ ។ កតមានិ ចត្តារិ អហិរាជកុលានិ ។ វិរូបក្ខំ អហិរាជកុលំ ឯរាបថំ អហិរាជកុលំ ឆព្យាបុត្តំ អហិរាជកុលំ កណ្ហាគោតមកំ អហិរាជកុលំ ន ហិ នូន សោ ភិក្ខវេ ភិក្ខុ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិ ។ សចេ ហិ សោ ភិក្ខវេ ភិក្ខុ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរេយ្យ ន ហិ សោ ភិក្ខវេ ភិក្ខុ អហិនា ទដ្ឋោ កាលំ ករេយ្យ ។

១ ឱ. និវត្តពីជញ្ញេវ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដែលគេចុចដោយក្រចក ១ ដែលគ្មានពូជផុតទៅ ១ មានពូជដែរ តែគួរបន្ទុចគ្រាប់ចេញបាន ១ ជាគំរប់ប្រាំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើ ដោយសមណកប្បទាំង ៥ នេះឯង ។

(១៣៦) សម័យនោះឯង ភិក្ខុ ១ រូបពស់ចឹកហើយក៏ស្លាប់ទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានជាដូច្នោះ ព្រោះភិក្ខុនោះមិនផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះបានផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ទាំង ៤ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះប្រហែលជាពស់ចឹកក៏មិនបានស្លាប់ទេ ។ ត្រកូលស្តេចពស់ទាំង ៤ ដូចម្តេចខ្លះ ។ ត្រកូលស្តេចពស់ទាំង ៤ នោះ គឺត្រកូលស្តេចពស់ឈ្មោះវិរូបក្ខៈ ត្រកូលស្តេចពស់ឈ្មោះឯកបថៈ ត្រកូលស្តេចពស់ឈ្មោះឆព្យាបុត្តៈ ត្រកូលស្តេចពស់ឈ្មោះកណ្ហាគោតមកៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបានជាដូច្នោះ ព្រោះភិក្ខុនោះមិនបានផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ទាំង ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះ បានផ្សាយមេត្តាចិត្តទៅកាន់ត្រកូលស្តេចពស់ទាំង ៤ នេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះប្រហែលជាពស់ចឹកក៏មិនបានស្លាប់ទេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិតុំ អត្តគុត្តិយា អត្តរក្ខាយ អត្តបរិត្តាយ(១) ។ ឯវញ្ច បន ភិក្ខវេ កាតព្វំ ។

(១៣៧) វិរូបក្ខេហិ មេ មេត្តំ
មេត្តំ ឯរាបថេហិ មេ
ឆព្យាបុត្តេហិ មេ មេត្តំ
មេត្តំ កណ្ហាគោតមកេហិ ច
អបាទកេហិ មេ មេត្តំ
មេត្តំ ទិបាទកេហិ(២) មេ
ចតុប្បទេហិ មេ មេត្តំ
មេត្តំ ពហុប្បទេហិ មេ
មា មំ អបាទកោ ហឹសិ
មា មំ ហឹសិ ទិបាទកោ ។

---

១ ម. អត្តបរិត្តំ កាតុំ ។ ២ ឧ. ទ្វិបាទកេហិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្សាយមេត្តាចិត្តទៅកាន់ត្រកូលស្តេចពស់ទាំង ៤ នេះ ដើម្បីគ្រប់គ្រងខ្លួន ដើម្បីរក្សាខ្លួន ដើម្បីការពារខ្លួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវធ្វើមេត្តាចិត្តយ៉ាងនេះឯង ៗ

[១៣៧] មេត្តារបស់យើង ( ចូរប្រព្រឹត្តទៅ ) ជាមួយនឹងពួកត្រកូលស្តេចពស់ឈ្មោះវិរូបក្ខៈផង(១) មេត្តារបស់យើង(ចូរប្រព្រឹត្តទៅ)ជាមួយនឹងពួកត្រកូលស្តេចពស់ឈ្មោះឯរាបថៈផង មេត្តារបស់យើង ( ចូរប្រព្រឹត្តទៅ ) ជាមួយនឹងពួកត្រកូលស្តេចពស់ឈ្មោះឆព្យាបុត្តៈផង មេត្តារបស់យើង ( ចូរប្រព្រឹត្តទៅ ) ជាមួយនឹងពួកត្រកូលស្តេចពស់ឈ្មោះកណ្ហាគោតមកៈផង មេត្តារបស់យើង ( ចូរប្រព្រឹត្តទៅ ) ជាមួយនឹងពួកសត្វមិនមានជើងផង មេត្តារបស់យើង ( ចូរប្រព្រឹត្តទៅ ) ជាមួយនឹងពួកសត្វមានជើងពីរផង មេត្តារបស់យើង ( ចូរប្រព្រឹត្តទៅ ) ជាមួយនឹងពួកសត្វមានជើងបួនផង មេត្តារបស់យើង ( ចូរប្រព្រឹត្តទៅ ) ជាមួយនឹងពួកសត្វមានជើងច្រើនផង សត្វគ្មានជើង កុំបៀតបៀនយើង សត្វមានជើងពីរ កុំបៀតបៀនយើងឡើយ ៗ

---

១ យើងមានមេត្តាចិត្ត គឺចិត្តដែលឥតមានព្យាបាទដល់ពួកត្រកូលពស់ឈ្មោះ វិរូបក្ខៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មា មំ ចតុប្បទោ ហឹសិ
មា មំ ហឹសិ ពហុប្បទោ ។
សព្វេ សត្តា សព្វេ បាណា
សព្វេ ភូតា ច កេវលា
សព្វេ ភទ្រានិ បស្សន្តុ
មា កិញ្ចិ បាបមាគមា ។

អប្បមាណោ ពុទ្ធោ អប្បមាណោ ធម្មោ អប្បមាណោ សង្ឃោ បមាណវន្តានិ សរីសបានិ អហិវិច្ឆិកា សតបទី ឧណ្ណានាភី សរពូ មូសិកា កតា មេ រក្ខា កតា មេ បរិត្តា បដិក្កមន្តុ ភូតានិ សោហំ នមោ ភគវតោ នមោ សត្តន្នំ សម្មាសម្ពុទ្ធានន្តិ(១) ។

(១៣៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អនភិរតិយា បីឡិតោ អត្តនោ អង្គជាតំ ឆិន្ទិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អញ្ញម្ហិ

១ ឥតោ បរំ យុរោបិយបោត្ថកេ អនុជានាមិ ភិក្ខវេ លោហិតំ មោចេតុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សត្វមានជើងបួន កុំបៀតបៀនយើង សត្វមានជើងច្រើន កុំបៀតបៀនយើងឡើយ ។ ពួកសត្វ(១)ទាំងអស់ផង ពួកបាណៈ(២)ទាំងអស់ផង ពួកភូត(៣)ទាំងអស់ផង គ្រប់យ៉ាង សត្វទាំងអស់ (នោះ) ចូរឃើញ នូវអារម្មណ៍ដ៏ចំរើន អំពើដ៏អាក្រក់តិចតួចកុំបីមកឡើយ ។

ព្រះពុទ្ធមានគុណប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃមានគុណប្រមាណមិនបាន ពួកសត្វទីឃជាតិគឺ ពស់ ខ្ទួយ ក្អែប ពីងពាង តុកកែ ទីងកណ្ដុរ ជាសត្វប្រកបដោយគុណសម្បត្តិ (តិច) ការរក្សា យើងបានធ្វើហើយ សេចក្តីការពារយើងបានធ្វើហើយ សត្វទាំងឡាយចូរចៀសចេញទៅ យើងធ្វើកិរិយានមស្ការ ចំពោះព្រះមានព្រះភាគ ធ្វើកិរិយានមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធទាំង ៧ ព្រះអង្គ (មានព្រះពុទ្ធទ្រង់ព្រះនាមវិបស្សីជាដើម) ។

(១៣៨) សម័យនោះឯង ភិក្ខុ ១ រូបមានសេចក្តីអផ្សុកបៀតបៀន ហើយក៏កាត់នូវអង្គជាតរបស់ខ្លួន ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា

១-២-៣ ពាក្យទាំង៣នេះជាពាក្យសម្រាប់ផ្លាស់ព្យញ្ជនៈពាក្យថាបុគ្គល(សារត្ថទីបនីដីកា)។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សោ ភិក្ខវេ មោឃបុរិសោ ឆិន្ទិតព្វម្ហិ(១) អញ្ញំ ឆិន្ទិ ន ហិ(២) ភិក្ខវេ អត្តនោ អង្គជាតំ ឆិន្ទិតព្វំ(៣) យោ ឆិន្ទេយ្យ អាបត្តិ ថុល្លច្ចយស្សាតិ ។

(១៣៩) តេន ខោ បន សមយេន រាជគហកស្ស សេដ្ឋិស្ស មហគ្ឃស្ស ចន្ទនសារស្ស ចន្ទនគណ្ឋិ ឧប្បន្នា ហោតិ ។ អថខោ រាជគហកស្ស សេដ្ឋិស្ស ឯតទហោសិ យន្នូនាហំ ឥមាយ ចន្ទនគណ្ឋិយា បត្តំ លិខាបេយ្យំ លិខញ្ច(៤) មេ បរិភោគំ ភវិស្សតិ បត្តញ្ច ទានំ ទស្សាមីតិ ។ អថខោ រាជគហកោ សេដ្ឋី តាយ ចន្ទនគណ្ឋិយា បត្តំ លិខាបេត្វា សិក្កាយំ ឧឌ្ឌិត្វា(៥) វេឡុគ្គេ(៦) អាលគ្គេត្វា វេឡុបរម្បរាយ ពន្ធិត្វា(៧) ឯវមាហ យោ សមណោ វា ព្រាហ្មណោ វា អរហា ចេវ ឥទ្ធិមា ច ទិន្នំយេវ បត្តំ ឱហរតូតិ ។

១ ខ. ឆេតព្វម្ហិ ។ ២ ខ. ហិសទ្ទោ នត្ថិ ។ ៣ ខ. ឆេតព្វំ ។ ៤ ខ. លេខញ្ច ។
៥ ខ. បក្ខិបិត្វា ។ ៦ ខ. វេឡគ្គេ ។ ៧ ខ. ម. ពន្ធិត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ម្នាលភិក្ខុទាំងឡាយ វត្ថុដទៃ(១) ដែលខ្លួនគួរកាត់ក៏មាន តែមោឃបុរសនោះទៅកាត់ឯវត្ថុដទៃ (អង្គជាត)វិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវកាត់អង្គជាតរបស់ខ្លួនទេ ភិក្ខុណាកាត់ ត្រូវអាបត្តិថុល្លច្ច័យ ។

(១៣៩) សម័យនោះឯង រាជគហសេដ្ឋី (ជាសេដ្ឋីនៅក្នុងក្រុងរាជគ្រឹះ) បានពកចន្ទន៍នៃខ្លឹមចន្ទន៍មានតម្លៃច្រើន ។ លំដាប់នោះ រាជ.គហសេដ្ឋីមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះគួរតែអាត្មាអញឲ្យជាងក្រឡឹងបាត្រដោយពកចន្ទន៍នេះ លំអិតដែលបានពីការក្រឡឹងក៏ជាគ្រឿងប្រើប្រាស់របស់អាត្មាអញផង ហើយអាត្មាអញនឹងបានឲ្យបាត្រទៅជាទានផង ។ គ្រានោះ រាជគហសេដ្ឋីក៏ឲ្យជាងក្រឡឹងបាត្រដោយពកចន្ទន៍នោះហើយប្រកក្នុងសង្រែកញ្ជ្រលើចុងឫស្សី ហើយលើកឫស្សីត ៗ គ្នា (ឲ្យខ្ពស់)ឡើង រួចនិយាយយ៉ាងនេះថា លោកណាទោះបីជាសមណៈក្តី ព្រាហ្មណ៍ក្តី ដែលជាព្រះអរហន្តមានឫទ្ធិ លោកនោះចូរដាក់យកបាត្រដែលយើងឲ្យហើយទៅចុះ ។

១ ក្នុងដីកាថា រាគានុសយៈ ហៅថា វត្ថុដទៃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៤០) អថខោ បូរណោ កស្សបោ យេន រាជគហកោ សេដ្ឋី តេនុបសង្កមិ ឧបសង្កមិត្វា រាជគហកំ សេដ្ឋឹ ឯតទវោច អហំ ហិ គហបតិ អរហា ចេវ ឥទ្ធិមា ច ទេហិ មេ បត្តន្តិ ។ សចេ ភន្តេ អាយស្មា អរហា ចេវ ឥទ្ធិមា ច ទិន្នំយេវ បត្តំ ឱហរតូតិ ។ អថខោ មក្ខលិ គោសាលោ អជិតោ កេសកម្ពលោ[១] បកុធោ កច្ចាយនោ សញ្ចយោ វេឡដ្ឋបុត្តោ[២] និគណ្ឋោ នាដបុត្តោ[៣] យេន រាជគហកោ សេដ្ឋី តេនុបសង្កមិ ឧបសង្កមិត្វា រាជគហកំ សេដ្ឋឹ ឯតទវោច អហំ ហិ គហបតិ អរហា ចេវ ឥទ្ធិមា ច ទេហិ មេ បត្តន្តិ ។ សចេ ភន្តេ អាយស្មា អរហា ចេវ ឥទ្ធិមា ច ទិន្នំយេវ បត្តំ ឱហរតូតិ ។

(១៤១) តេន ខោ បន សមយេន អាយស្មា ច មហាមោគ្គល្លានោ អាយស្មា ច បិណ្ឌោលភារទ្វាជោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសឹសុ ។ អាយស្មាហិ ខោ

---

១ ម. កេសកម្ពលី ។ ២ ឱ. ម. ពេលដ្ឋបុត្តោ ។ ៣ ឱ. នាតបុត្តោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកៈ រឿងគ្រូ ៦ នាក់ ជាគ្រូពកបជ្ជូន

(១៤០) គ្រានោះ គ្រូឈ្មោះបូរណកស្សបៈចូលទៅរករាជគហសេដ្ឋី លុះចូលទៅដល់ហើយក៏និយាយយ៉ាងនេះនឹងរាជគហសេដ្ឋីថា នែគហបតិ អាត្មាជាព្រះអរហន្តទាំងមានឫទ្ធិផង សូមអ្នកឲ្យបាត្រមកអាត្មាចុះ ។ សេដ្ឋីនិយាយថា បពិត្រលោកដ៏ចំរើន បើលោកមានអាយុជាព្រះអរហន្ត ទាំងមានឫទ្ធិផងមែន ចូរលោកដាក់យកបាត្រដែលយើងឲ្យហើយទៅចុះ ។ លំដាប់នោះ គ្រូឈ្មោះមក្ខលិគោសាល គ្រូឈ្មោះអជិតកេសកម្ពល គ្រូឈ្មោះបកុធកច្ចាយនៈ គ្រូឈ្មោះសញ្ជយវេឡដ្ឋបុត្ត គ្រូឈ្មោះនិគ្គណ្ឋនាដបុត្ត បានចូលទៅរករាជគហសេដ្ឋី លុះចូលទៅដល់ហើយ ក៏និយាយយ៉ាងនេះនឹងរាជគហសេដ្ឋីថា នែគហបតិ អាត្មាជាព្រះអរហន្ត ទាំងមានឫទ្ធិផង សូមអ្នកឲ្យបាត្រមកអាត្មាចុះ ។ សេដ្ឋីនិយាយថា បពិត្រលោកដ៏ចំរើន បើលោកមានអាយុជាព្រះអរហន្ត ទាំងមានឫទ្ធិមែន ចូរលោកដាក់យកបាត្រដែលយើងឲ្យហើយទៅចុះ ។

(១៤១) សម័យនោះឯង ព្រះមហាមោគ្គល្លានមានអាយុនឹងព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ស្លៀកដណ្ដប់ក្នុងបុព្វណ្ហសម័យ ហើយទ្រង់បាត្រនិងចីវរចូលទៅ កាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ។ ចំណែកខាង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បិណ្ឌោលភារទ្វាជោ អរហា ចេវ ឥទ្ធិមា ច ។ អាយស្មាបិ ខោ មហាមោគ្គល្លានោ អរហា ចេវ ឥទ្ធិមា ច ។ អថខោ អាយស្មា បិណ្ឌោលភារទ្វាជោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច គច្ឆាវុសោ មោគ្គល្លាន ឯតំ បត្តំ ឱហរ តុយ្ហេសោ បត្តោតិ ។ អាយស្មាបិ ខោ មោគ្គល្លានោ អាយស្មន្តំ បិណ្ឌោលភារទ្វាជំ ឯតទវោច គច្ឆាវុសោ ភារទ្វាជ ឯតំ បត្តំ ឱហរ តុយ្ហេសោ បត្តោតិ(១) ។ អថខោ អាយស្មា បិណ្ឌោលភារទ្វាជោ វេហាសំ អព្ភុគ្គន្ត្វា តំ បត្តំ គហេត្វា តិក្ខត្តុំ រាជគហំ អនុបរិយាយិ(២) ។

---

១ ឱ. ម. បោត្ថកេសុ តេន ខោ បន សមយេន អាយស្មា ច មហាមោគ្គល្លានោ ។ បេ ។ ឃាវីសីសុ ។ អថខោ អាយស្មា បិណ្ឌោលភារទ្វាជោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច អាយស្មា ខោ មហាមោគ្គល្លានោ អរហា ចេវ ឥទ្ធិមា ច គច្ឆាវុសោ មោគ្គល្លាន ឯតំ បត្តំ ឱហរ តុយ្ហេសោ បត្តោតិ ។ អាយស្មា ខោ បិណ្ឌោលភារទ្វាជោ អរហា ចេវ ឥទ្ធិមា ច គច្ឆាវុសោ ភារទ្វាជ ឯតំ បត្តំ ឱហរ តុយ្ហេសោ បត្តោតិ ។ នយេន វចនំ អាគតំ ។
២ ឱ. អនុបរិយាសិ ។ ម. អនុបរិវត្តេសិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ជាព្រះអរហន្ត ទាំងមានឫទ្ធិផង ។ ព្រះមហាមោគ្គល្លានមានអាយុ ជាព្រះអរហន្ត ទាំងមានឫទ្ធិផងដែរ ។ គ្រានោះ ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ និយាយនឹងព្រះមហាមោគ្គល្លានមានអាយុយ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន ចូរលោកនិមន្តទៅជាក់យកបាត្រនុ៎ះមក បាត្រនុ៎ះជាបាត្ររបស់លោកហើយ ។ ឯព្រះមហាមោគ្គល្លានមានអាយុ ក៏និយាយទៅនឹងព្រះបិណ្ឌោលភារទ្វាជៈ មានអាយុយ៉ាងនេះវិញថា ម្នាលអាវុសោភារទ្វាជៈ ចូរលោកនិមន្តទៅជាក់យកបាត្រនុ៎ះមក បាត្រនុ៎ះជាបាត្ររបស់លោកហើយ ។ លំដាប់នោះ ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ក៏ហោះទៅឯអាកាសកាន់យកបាត្រនោះ ហើយហោះក្រឡឹងក្រុងរាជគ្រឹះបីជុំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(១៦២) តេន ខោ បន សមយេន រាជគហកោ សេដ្ឋី សមុទ្ទធាភេ សកោ និវេសនេ ឋិតោ ហោតិ បញ្ជលិកោ នមស្សមានោ ឥធេវ ភន្តេ អយ្យោ ភារទ្វាជោ អម្ហាកំ និវេសនេ បតិដ្ឋាតូតិ ។ អថខោ អាយស្មា បិណ្ឌោលភារទ្វាជោ រាជគហកស្ស សេដ្ឋិស្ស និវេសនេ បតិដ្ឋាតិ(១) ។ អថខោ រាជគហកោ សេដ្ឋី អាយស្មតោ បិណ្ឌោលភារទ្វាជស្ស ហត្ថតោ បត្តំ គហេត្វា មហគ្ឃស្ស ខាទនីយស្ស បូរេត្វា អាយស្មតោ បិណ្ឌោលភារទ្វាជស្ស អទាសិ(២) ។ អថខោ អាយស្មា បិណ្ឌោលភារទ្វាជោ តំ បត្តំ គហេត្វា អារាមំ អគមាសិ ។ អស្សោសុំ ខោ មនុស្សា អយ្យេន កិរ បិណ្ឌោលភារទ្វាជេន រាជគហកស្ស សេដ្ឋិស្ស បត្តោ ឱហារិតោតិ ។ តេ ច មនុស្សា ឧច្ចាសទ្ទា មហាសទ្ទា អាយស្មន្តំ បិណ្ឌោលភារទ្វាជំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិំសុ ។ អស្សោសិ ខោ ភគវា ឧច្ចាសទ្ទំ មហាសទ្ទំ សុត្វាន អាយស្មន្តំ អានន្ទំ អាមន្តេសិ កិំ នុ ខោ សោ អានន្ទ ឧច្ចាសទ្ទោ

---

១ ឱ. បតិដ្ឋាសិ ។ ២ ឱ. អទាសិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(១៤២) សម័យនោះឯង រាជគហសេដ្ឋីព្រមទាំងកូនចៅប្រពន្ធ ឈរនៅទីផ្ទះរបស់ខ្លួន ផ្គងអញ្ជលីនមស្ការនិយាយថា បពិត្រលោកដ៏ចំរើន សូមព្រះភារទ្វាជៈជាម្ចាស់ មកប្រតិស្ឋានក្នុងផ្ទះរបស់យើងឯនេះ ។ លំដាប់នោះ ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ក៏មកប្រតិស្ឋានក្នុងទីផ្ទះរបស់រាជគហសេដ្ឋី ។ លំដាប់នោះ រាជគហសេដ្ឋីទទួលយកបាត្រ អំពីព្រះហស្តព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ហើយដាក់ខាទនីយៈដែលមានថ្លៃច្រើនឲ្យពេញ រួចប្រគេនដល់ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ។ ឯព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ក៏ទទួលយកបាត្រនោះហើយ ដើរទៅកាន់អារាម ។ មនុស្សទាំងឡាយបានឮច្បាស់ថា ឥឡូវបាត្ររបស់រាជគហសេដ្ឋីព្រះបិណ្ឌោលភារទ្វាជៈជាម្ចាស់ បានដាក់យកទៅហើយ ។ មនុស្សទាំងនោះក៏ហ៊ោកញ្ជ្រៀវដើរទៅតាមក្រោយ ៗ ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ។ ព្រះមានព្រះភាគទ្រង់បានឮសំឡេងហ៊ោកញ្ជ្រៀវ លុះឮហើយទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកសួរថា ម្នាលអានន្ទ សំឡេងហ៊ោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មហាសទ្ទោតិ ។ អាយស្មតា ភន្តេ បិណ្ឌោលភារទ្វាជេន រាជគហកស្ស សេដ្ឋិស្ស បត្តោ ឱហារិតោ អស្សោសុំ ខោ ភន្តេ មនុស្សា អយ្យេន កិរ បិណ្ឌោលភារទ្វាជេន រាជគហកស្ស សេដ្ឋិស្ស បត្តោ ឱហារិតោតិ តេ ច ភន្តេ មនុស្សា ឧច្ចាសទ្ទា មហាសទ្ទា អាយស្មន្តំ បិណ្ឌោលភារទ្វាជំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា សោ ឯសោ ភគវ(1) ឧច្ចាសទ្ទោ មហាសទ្ទោតិ ។

(១៦៣) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ បិណ្ឌោលភារទ្វាជំ បដិបុច្ឆិ សច្ចំ កិរ តយា ភារទ្វាជ រាជគហកស្ស សេដ្ឋិស្ស បត្តោ ឱហារិតោតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ ភារទ្វាជ អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម ត្វំ ភារទ្វាជ ឆវស្ស ទារុបត្តស្ស ការណា គិហីនំ ឧត្តរិមនុស្សធម្មំ ឥទ្ធិបាដិហារិយំ ទស្សេស្សសិ សេយ្យថាបិ នាម ភារទ្វាជ មាតុគាមោ ឆវស្ស មាសករូបស្ស ការណា កោបីនំ(2) ទស្សេតិ

១ ឱ ម. ភន្តេ ភគវា ។ ២ ឱ. កោបីនំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កញ្ច្រៀវនោះ ជាសំឡេងអ្វី ៗ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវបាត្ររបស់រាជគហសេដ្ឋី ព្រះបិណ្ឌោលភារទ្វាជៈមានអាយុបានដាក់យកទៅហើយ បពិត្រព្រះអង្គដ៏ចំរើន មនុស្សទាំងឡាយបានឮដំណឹងថា បាត្ររបស់រាជគហសេដ្ឋី លោកម្ចាស់បិណ្ឌោលភារទ្វាជៈបានដាក់យកទៅហើយ បពិត្រព្រះអង្គដ៏ចំរើន មនុស្សទាំងនោះក៏ហៅកញ្ច្រៀវឡើងដើរទៅតាមក្រោយ ៗ ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ បពិត្រព្រះមានព្រះភាគ សំឡេងហៅកញ្ច្រៀវនោះ គឺជាសំឡេងនុ៎ះឯង ។

(១៤៣) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរព្រះបិណ្ឌោលភារទ្វាជៈ មានអាយុថា ម្នាលភារទ្វាជៈ ឮថាអ្នកបានដាក់យកបាត្ររបស់រាជគហសេដ្ឋី ពិតមែនឬ ។ ព្រះបិណ្ឌោលភារទ្វាជៈក្រាបបង្គំទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធមានព្រះភាគទ្រង់បន្ទោសថា ម្នាលភារទ្វាជៈ ( អំពើនេះ ) មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បីមិនត្រូវធ្វើ ម្នាលភារទ្វាជៈ អ្នកមិនសមបើនឹងសំដែងឥទ្ធិប្បាដិហារ្យដែលជាធម៌របស់មនុស្សជាន់ខ្ពស់ ដល់ពួកគ្រហស្ថ ព្រោះតែបាត្រឈើជារបស់ថោកទាបទេ ម្នាលភារទ្វាជៈ មាតុគ្រាមបង្ហាញកេរ្តិ៍ខ្មាស ព្រោះតែរូបមាសក[១] ដូចជាសាកសពជារបស់ថោកទាប យ៉ាងណាមិញ

---

១ វត្ថុសម្រាប់ចាយមានប្រាក់ជាដើម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឃាមេវ ខោ តយា ភារទ្វាជ ឆវស្ស ទារុបត្តស្ស ការណា គិហីនំ ឧត្តរិមនុស្សធម្មំ ឥទ្ធិបាដិហារិយំ ទស្សិតំ នេតំ ភារទ្វាជ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ គិហីនំ ឧត្តរិមនុស្សធម្មំ ឥទ្ធិបាដិហារិយំ ទស្សេតព្វំ យោ ទស្សេយ្យ អាបត្តិ ទុក្កដស្ស ភិន្ទថេតំ ភិក្ខវេ ទារុបត្តំ សកលិកំ សកលិកំ ករិត្វា ភិក្ខូនំ អញ្ជនូបិសនំ[១] ទេថ ន ច ភិក្ខវេ ទារុបត្តោ ធារេតព្វោ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៦៤) តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឧច្ចាវចេ បត្តេ ធារេន្តិ សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។បេ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ សោវណ្ណមយោ បត្តោ ធារេតព្វោ ន រូបិយមយោ បត្តោ ធារេតព្វោ

១ ឱ. ម. អញ្ជនូបបិសនំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ម្នាលភារទ្វាជៈ អ្នកឯងសំដែងឥទ្ធិប្បាដិហារ្យ ដែលជាធម៌របស់មនុស្សជាន់ខ្ពស់ដល់ពួកគ្រហស្ថ ព្រោះតែបាត្រឈើជារបស់ថោកទាប ក៏យ៉ាងនោះដែរ ម្នាលភារទ្វាជៈ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងឥទ្ធិប្បាដិហារ្យ ដែលជាធម៌របស់មនុស្សជាន់ខ្ពស់ ដល់ពួកគ្រហស្ថទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរបំបែកបាត្រឈើនុះចេញហើយធ្វើឲ្យជាចំណែក ៗ ហើយឲ្យដល់ភិក្ខុទាំងឡាយ សម្រាប់គិនធ្វើជាថ្នាំលាបភ្នែក ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បាត្រឈើទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

(១៤៤) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់បាត្រខ្ពស់ទាំងទាប គឺ ល្អក្រក់ គឺបាត្រធ្វើពីមាសខ្លះ ធ្វើពីប្រាក់ខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បាត្រធ្វើដោយមាស មិនត្រូវប្រើប្រាស់បាត្រធ្វើដោយប្រាក់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ន មណិមយោ បត្តោ ធារេតព្វោ ន វេឡុរិយមយោ បត្តោ ធារេតព្វោ ន ផលិកមយោ បត្តោ ធារេតព្វោ ន កំសមយោ បត្តោ ធារេតព្វោ ន កាចមយោ បត្តោ ធារេតព្វោ ន តិបុមយោ បត្តោ ធារេតព្វោ ន សីសមយោ បត្តោ ធារេតព្វោ ន តម្ពលោហមយោ បត្តោ ធារេតព្វោ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ទ្វេ បត្តេ អយោបត្តំ មត្តិកាបត្តន្តិ ។

(១៤៥) តេន ខោ បន សមយេន បត្តមូលំ ឃំសិយតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បត្តមណ្ឌលន្តិ ។

(១៤៦) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចាវចានិ បត្តមណ្ឌលានិ ធារេន្តិ សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឧច្ចាវចានិ បត្តមណ្ឌលានិ ធារេតព្វានិ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ទ្វេ បត្តមណ្ឌលានិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មិនត្រូវប្រើប្រាស់បាត្រ ធ្វើដោយកែវមណី មិនត្រូវប្រើប្រាស់បាត្រធ្វើដោយកែវពិទូរ្យ មិនត្រូវប្រើប្រាស់បាត្រធ្វើដោយកែវផលិក មិនត្រូវប្រើប្រាស់បាត្រធ្វើដោយសំរិទ្ធ មិនត្រូវប្រើប្រាស់បាត្រធ្វើដោយកែវកញ្ចក់ មិនត្រូវប្រើប្រាស់បាត្រធ្វើដោយសំណប៉ាហាំង មិនត្រូវប្រើប្រាស់បាត្រធ្វើដោយសំណកក់ មិនត្រូវប្រើប្រាស់បាត្រធ្វើដោយស្ពាន់ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបាត្រពីរយ៉ាង គឺ បាត្រដែកម្យ៉ាង បាត្រដីម្យ៉ាង ។

(១៨៥) សម័យនោះឯង ផ្ទៃបាត្រខាងក្រោមក៏សឹករិលរលេបទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជើងបាត្រ ។

(១៨៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់ជើងបាត្រខ្ពស់ទីងទាប គឺ ល្អអាក្រក់ គឺ ធ្វើដោយមាសខ្លះ ធ្វើដោយប្រាក់ខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ជើងបាត្រ ខ្ពស់ទីងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជើងបាត្រពីរយ៉ាង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តិបុមយំ សីសមយន្តិ ។ ពហលានិ បត្តមណ្ឌលានិ ន អច្ឆុបិយន្តិ(១) ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ លិខិតុន្តិ ។ វលី ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ មករទន្តកំ ឆិន្ទិតុន្តិ ។

(១៨៧) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ចិត្រានិ បត្តមណ្ឌលានិ ធារេន្តិ រូបកាកិណ្ណានិ ភិត្តិកម្មកតានិ(២)តានិ រថិកាយបិ ទស្សេន្តា អាហិណ្ឌន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ចិត្រានិ បត្តមណ្ឌលានិ ធារេតព្វានិ រូបកាកិណ្ណានិ ភិត្តិកម្មកតានិ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ បកតិមណ្ឌលន្តិ ។

---

១ ម. ពហលានិ មណ្ឌលានិ ន អច្ឆុបិយន្តិ ។ ២ ម. យ. រូបកោកិណ្ណានិ ភត្តកម្មកតានិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គឺ ធ្វើដោយសំណប៉ាហាំងម្យ៉ាង ធ្វើដោយសំណភក់ម្យ៉ាង ។ ជើងបាត្រក្រាស់ពេក ភិក្ខុបាប់កាន់មិនស្ទួន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រឡឹងបាន[1] ។ ល្អសក៏កើតមាន (ដល់ពួកភិក្ខុក្នុងសម័យនោះ) ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាត់ល្អសនោះ ធ្វើជាក្បាច់ធ្មេញមករ ។

(១៤៧) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ជើងបាត្រទាំងឡាយដ៏វិចិត្រ ឆ្លាក់ ដេរដោសដោយរូបស្រីនិងប្រុសជាដើម ហើយលាបឲ្យមានពណ៌ផ្សេង ៗ ក៏ដើរបង្ហាញជើងបាត្រទាំងនោះ (ដល់មនុស្សទាំងពួង) តាមផ្លូវថ្នល់ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាពួកគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ជើងបាត្រដ៏វិចិត្រ ឆ្លាក់ ដេរដោសដោយរូបស្រីនិងប្រុសជាដើម និងលាបឲ្យមានពណ៌ផ្សេង ៗ ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជើងបាត្រជាប្រក្រតី[2] ។

១ អដ្ឋកថា ថា ធ្វើឲ្យស្តើង ។ ២ គ្រឿងប្រដាប់សម្រាប់ទ្រលំបាត្រជាធម្មតា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៦៨] តេន ខោ បន សមយេន ភិក្ខូ សោទកំ
បត្តំ បដិសាមេន្តិ ។ បត្តោ ទុស្សតិ ។ ភគវតោ ឯត-
មត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ សោទកោ បត្តោ
បដិសាមេតព្វោ យោ បដិសាមេយ្យ អាបត្តិ ទុក្កដស្ស
អនុជានាមិ ភិក្ខវេ ឱតាបេត្វា បត្តំ បដិសាមេតុន្តិ ។

[១៦៩] តេន ខោ បន សមយេន ភិក្ខូ សឧទកំ
បត្តំ ឱតាបេន្តិ ។ បត្តោ ទុគ្គន្ធោ ហោតិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ សឧទកោ
បត្តោ ឱតាបេតព្វោ យោ ឱតាបេយ្យ អាបត្តិ ទុក្កដស្ស
អនុជានាមិ ភិក្ខវេ និរុទកំ[១] កត្វា ឱតាបេត្វា បត្តំ
បដិសាមេតុន្តិ ។

[១៧០] តេន ខោ បន សមយេន ភិក្ខូ ឧណ្ហេ
បត្តំ និទហន្តិ ។ បត្តស្ស វណ្ណោ ទុស្សតិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឧណ្ហេ បត្តោ និទហិ-
តព្វោ យោ និទហេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ
ភិក្ខវេ មុហុត្តំ ឧណ្ហេ ឱតាបេត្វា បត្តំ បដិសាមេតុន្តិ ។

---

១ ឱ. ម. វោទកំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៨៨) សម័យនោះឯង ភិក្ខុទាំងឡាយទុកដាក់បាត្រទាំងទទឹក ។ បាត្រក៏វិនាសខូចទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកដាក់បាត្រទាំងទទឹកទេ ភិក្ខុណាទុកដាក់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុហាលបាត្រសិនហើយសឹមទុកដាក់ ។

(១៨៩) សម័យនោះឯង ភិក្ខុទាំងឡាយហាលបាត្រទាំងទទឹក ។ បាត្រក៏មានក្លិនអាក្រក់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវហាលបាត្រទាំងទទឹកទេ ភិក្ខុណាហាល ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជូតបាត្រ ឲ្យស្ងួតទឹកសិនហើយ សឹមហាលទុកដាក់ចុះ ។

(១៩០) សម័យនោះឯង ភិក្ខុទាំងឡាយទុកបាត្រក្នុងទីក្ដៅ ។ បាត្រក៏ខូចពណ៌ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកបាត្រក្នុងទីក្ដៅទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យហាលបាត្រក្នុងទីក្ដៅមួយរំពេច ហើយសឹមទុកដាក់ចុះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៨១) តេន ខោ បន សមយេន សម្ពហុលា បត្តា អជ្ឈោកាសេ អនាធារកា និក្ខិត្តា ហោន្តិ ។ វាតមណ្ឌលិកាយ អាវដ្ដិត្វា បត្តា ភិជ្ជិំសុ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ បត្តាធារកន្តិ ។

(១៨២) តេន ខោ បន សមយេន ភិក្ខូ មិឍន្តេ បត្តំ និក្ខិបន្តិ ។ បរិវដ្ដិត្វា(១) បត្តោ ភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ មិឍន្តេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៨៣) តេន ខោ បន សមយេន ភិក្ខូ បរិភណ្ឌន្តេ បត្តំ និក្ខិបន្តិ ។ បរិវដ្ដិត្វា បត្តោ ភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ បរិភណ្ឌន្តេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

---

១ ឱ. ម. បរិបតិត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៩១) សម័យនោះឯង មានបាត្រជាច្រើន តែមិនទាន់មានគ្រឿងរងដំកល់ ភិក្ខុទុកដាក់ក្នុងទីវាលស្រឡះ ។ បាត្រទាំងនោះក៏រមៀលបែកខូចទៅដោយខ្យល់កំបុតត្បូង ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រឿងរងដំកល់បាត្រ[១] ។

(១៩២) សម័យនោះឯង ពួកភិក្ខុដាក់បាត្រលើទីបំផុតនៃផែនក្តារតាំង[២] ។ បាត្រក៏រមៀលទង្គិចបែក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រលើទីបំផុតនៃផែនក្តារតាំងទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។

(១៩៣) សម័យនោះឯង ពួកភិក្ខុដាក់បាត្រក្នុងទីបំផុតនៃថ្នាក់[៣] ។ បាត្រក៏រមៀលធ្លាក់បែក ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រក្នុងទីបំផុតនៃថ្នាក់ទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។

---

១ តាមអដ្ឋកថា ថា គ្រឿងរងដំកល់បាត្រដែលគេធ្វើដោយភ្នកនឹងវល្លិនិងផ្តៅជាដើម ។ វិមតិវិនោទនីដីកាថា គ្រឿងរងដំកល់បាត្រមានសណ្ឋានដូចជាកងដែលគេធ្វើដោយវត្ថុមានភ្នកជាដើម (ឬនឹង ហៅថា រង្វេល ជាទ្រនាប់ ឆ្លូវប្រេះវិញក៏បាន) ។ ២ អដ្ឋកថា ថា ក្នុងទីបំផុតនៃផែនក្តារតាំងដែលគេដំកល់ទុកក្នុងរបៀងជាដើម ។ ៣ សារត្ថទីបនីដីកាថា ផែនក្តារតាំងដែលស្តើងគេធ្វើឲ្យមាំដល់ជើងជញ្ជាំងខាងក្រៅនៃផ្ទះ ហៅថា ថ្នាក់ ( ក្តារបែន ) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៩៤) តេន ខោ បន សមយេន ភិក្ខូ ឆមាយំ បត្តំ និក្ខិបន្តិ ។ ឱដ្ឋោ ឃំសិយតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ តិណសន្ថារកន្តិ ។ តិណសន្ថារកោ ឧបចិកាហិ ខជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ចោឡកន្តិ ។ ចោឡកំ ឧបចិកាហិ ខជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ បត្តមាឡកន្តិ ។ បត្តមាឡកា បរិបតិត្វា បត្តោ ភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ បត្តកុណ្ឌោលិកន្តិ ។ បត្តកុណ្ឌោលិកាយ បត្តោ ឧគ្ឃំសិយតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ បត្តត្ថវិកន្តិ ។ អំសវទ្ធកោ ន ហោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៥៤) សម័យនោះឯង ភិក្ខុទាំងឡាយផ្កាប់បាត្រលើផែនដី ។ រមែងមាត់បាត្រក៏សឹករលែបទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកម្រាលស្មៅ ។ ពួកកណ្តៀរក៏កាត់កម្រាលស្មៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកំណាត់សំពត់ ។ ពួកកណ្តៀរក៏កាត់កំណាត់សំពត់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតពេងសម្រាប់ទុកបាត្រ ។ បាត្រក៏រមៀលធ្លាក់អំពីពេងសម្រាប់ទុកបាត្របែកទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភាជនៈដី មានមាត់ជ (ថ្ពាន) សម្រាប់ទុកបាត្រ ។ បាត្រក៏សឹកដោយភាជនៈដី មានមាត់ជ សម្រាប់ទុកបាត្រ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថង់បាត្រ ។ យោគបាត្រមិនទាន់មាននៅឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ អំសវទ្ធកំ ពន្ធនសុត្តកន្តិ ។

(១៥៥) តេន ខោ បន សមយេន ភិក្ខូ ភិត្តិខីលេបិ នាគទន្តកេបិ បត្តំ លគ្គេន្តិ ។ បរិបតិត្វា បត្តោ ភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ បត្តោ លគ្គេតព្វោ យោ លគ្គេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៥៦) តេន ខោ បន សមយេន ភិក្ខូ មញ្ចេ បត្តំ និក្ខិបន្តិ ។ សតិសម្មោសា និសីទន្តា ឱត្ថរិត្វា បត្តំ ភិន្ទន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ មញ្ចេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៥៧) តេន ខោ បន សមយេន ភិក្ខូ បីឋេ បត្តំ និក្ខិបន្តិ ។ សតិសម្មោសា និសីទន្តា ឱត្ថរិត្វា បត្តំ ភិន្ទន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ បីឋេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយោគបាត្រ នឹងខ្សែសម្រាប់ចង ។

(១៨៥) សម័យនោះឯង ភិក្ខុទាំងឡាយព្យួរបាត្រនឹងមេជញ្ជាំងខ្លះ នឹងដៃកែវខ្លះ ។ បាត្រក៏រមៀលធ្លាក់បែកទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវព្យួរបាត្រទេ ភិក្ខុណាព្យួរ ត្រូវអាបត្តិទុក្កដ ។

(១៨៦) សម័យនោះឯង ភិក្ខុទាំងឡាយទុកបាត្រលើគ្រែ ។ ភិក្ខុទាំងឡាយភ្លេចស្មារតីក៏អង្គុយសង្កត់បាត្របែកទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកបាត្រលើគ្រែទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ។

(១៨៧) សម័យនោះឯង ភិក្ខុទាំងឡាយទុកបាត្រលើតាំង ។ ភិក្ខុទាំងឡាយភ្លេចស្មារតីអង្គុយសង្កត់បាត្របែកទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកបាត្រលើតាំងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៥៨) តេន ខោ បន សមយេន ភិក្ខូ អង្កេ បត្តំ និក្ខិបន្តិ ។ សតិសម្មោសា ឧដ្ឋហន្តិ(១) ។ បរិបតិត្វា បត្តោ ភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ អង្កេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៥៩) តេន ខោ បន សមយេន ភិក្ខូ ឆត្តេ បត្តំ និក្ខិបន្តិ ។ វាតមណ្ឌលិកាយ ឆត្តំ ឧក្ខិបិយតិ ។ បរិបតិត្វា បត្តោ ភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឆត្តេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៦០) តេន ខោ បន សមយេន ភិក្ខូ បត្តហត្ថា កវាដំ បណាមេន្តិ ។ កវាដំ(២) អាវដ្ដិត្វា បត្តោ ភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ បត្តហត្ថេន ភិក្ខុនា កវាដំ បណាមេតព្វំ យោ បណាមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

---

១ ឱ. វុដ្ឋហន្តិ ។ ២ ឱ. ម. កវាដោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៥៨] សម័យនោះឯង ភិក្ខុទាំងឡាយដាក់បាត្រលើក្តៅទាំងក្នែន ។ ក្រោកឡើងដោយភ្លេចស្មារតី ។ បាត្រក៏រមៀលធ្លាក់បែកទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រលើក្តៅទាំងក្នែនទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។

[១៥៩] សម័យនោះឯង ភិក្ខុទាំងឡាយដាក់បាត្រក្នុងឆត្រ ។ ខ្យល់កំបុតត្បូងក៏បក់ផើយប៉ើងឆត្រឡើង ។ បាត្រក៏ធ្លាក់បែកទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រក្នុងឆត្រទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។

[១៦០] សម័យនោះឯង ភិក្ខុទាំងឡាយមានបាត្រនៅដៃ ច្រានសន្ទះទ្វារ ។ បាត្រក៏ទង្គិចនឹងសន្ទះទ្វារបែកទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានបាត្រនៅដៃ មិនត្រូវច្រានសន្ទះទ្វារទេ ភិក្ខុណាច្រាន ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៦១) តេន ខោ បន សមយេន ភិក្ខូ តុម្ពកដាហេន(១) បិណ្ឌាយ ចរន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ តិត្ថិយាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ តុម្ពកដាហេន បិណ្ឌាយ ចរិតព្វំ យោ ចរេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៦២) តេន ខោ បន សមយេន ភិក្ខូ ឃដិកដាហេន(២) បិណ្ឌាយ ចរន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ តិត្ថិយាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឃដិកដាហេន បិណ្ឌាយ ចរិតព្វំ យោ ចរេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៦៣) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សព្វបំសុកូលិកោ ហោតិ ។ សោ ឆវសីសស្ស បត្តំ ធារេតិ ។ អញ្ញតរា ឥត្ថី បស្សិត្វា ភីតា វិស្សរមកាសិ អភុម្មេ បិសាចោ វតាយន្តិ(៣) ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ

១ ឱ. ម. តុម្ពកដាហេ ។ ២ ឱ. ឃដីកដាហេ ។ ៣ ឱ. ម. វតមន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



### ខុទ្ទកវត្ថុក្ខន្ធកៈ រឿងភិក្ខុច្រើនរូប និយាយអំពីបាត្រ

(១៦១) សម័យនោះឯង ភិក្ខុទាំងឡាយដើរទៅបិណ្ឌបាតដោយសំបកឃ្លោក (កាន់សំបកឃ្លោក) ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកតិរ្ថិយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដើរទៅបិណ្ឌបាតដោយសំបកឃ្លោកទេ ភិក្ខុណាដើរទៅ ត្រូវអាបត្តិទុក្កដ ។

(១៦២) សម័យនោះឯង ពួកភិក្ខុដើរទៅបិណ្ឌបាតដោយអម្បែងឆ្នាំង ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកតិរ្ថិយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដើរទៅបិណ្ឌបាតដោយអម្បែងឆ្នាំងទេ ភិក្ខុណាដើរទៅ ត្រូវអាបត្តិទុក្កដ ។

(១៦៣) សម័យនោះឯង ភិក្ខុ ១ រូប ជាអ្នកប្រព្រឹត្តយកវត្ថុបំសុកូលគ្រប់មុខ(១) ។ ភិក្ខុនោះប្រើប្រាស់បាត្រក្បាលខ្មោច ។ មានស្រីម្នាក់ឃើញហើយខ្លាចស្រែកភ្ញាក់សំឡេងថា នុ៎ះជាបិសាចធ្វើសេចក្តីវិនាសដល់អញតើ ។ មនុស្សទាំងឡាយពោលទោស តិះដៀល

១ យកវត្ថុបង្សុកូលតាមតែប្រទះ គឺវត្ថុផងទៃក្រៅអំពីត្រៃចីវរ នឹងគ្រែ តាំង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ឆវសីសស្ស បត្តំ ធារេស្សន្តិ សេយ្យថាបិ បិសាចិល្លិកាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឆវសីសស្ស បត្តោ ធារេតព្វោ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។ ន ច ភិក្ខវេ សព្វបំសុកូលិកេន ភវិតព្វំ យោ ភវេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៦៤) តេន ខោ បន សមយេន ភិក្ខូ ចលកានិបិ អដ្ឋិកានិបិ ឧច្ឆិដ្ឋោទកម្បិ បត្តេន នីហរន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ យស្មិំយេវិមេ សមណា សក្យបុត្តិយា ភុញ្ជន្តិ សោវ នេសំ បដិគ្គហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ចលកានិ វា អដ្ឋិកានិ វា ឧច្ឆិដ្ឋោទកំ វា បត្តេន នីហរិតព្វំ យោ នីហរេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ បដិគ្គហន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បន្តុះបង្អាប់ថា មិនសមបើពួកសមណសក្យបុត្តិយ៍ប្រើប្រាស់បាត្រក្បាលខ្មោចដូចពួកបិសាចសោះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បាត្រក្បាលខ្មោចទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុមិនត្រូវជាអ្នកប្រព្រឹត្តយកវត្ថុបង្សុកូលគ្រប់មុខទេ ភិក្ខុណាប្រព្រឹត្តយក ត្រូវអាបត្តិទុក្កដ ។

(១៦៤) សម័យនោះឯង ភិក្ខុទាំងឡាយយកបាត្រដាក់កាកអាមិសៈដែលគេចោលខ្លះ ឆ្អឹងខ្លះ ទឹកជាដែលខ្លះ ហើយនាំយកទៅចោល ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្តិយ៍ទាំងនេះឆាន់ក្នុងបាត្រណា បាត្រនោះឯងជាកន្ធោររបស់លោក ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវយកបាត្រដាក់កាកអាមិសៈដែលគេចោលក្តី ឆ្អឹងក្តី ទឹកជាដែលក្តី នាំយកទៅចោលទេ ភិក្ខុណានាំយកទៅចោល ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកន្ធោរ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៦៥) តេន ខោ បន សមយេន ភិក្ខូ មហន្តេន ចីវរំ វិជាលេត្វា(១) ចីវរំ សិព្វន្តិ ។ ចីវរំ វិលោមំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ សត្ថកំ នមតកន្តិ ។

(១៦៦) តេន ខោ បន សមយេន សង្ឃស្ស ទណ្ឌសត្ថកំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ទណ្ឌសត្ថកន្តិ ។

(១៦៧) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចាវចេ សត្ថកទណ្ឌេ ធារេន្តិ សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឧច្ចាវចា សត្ថកទណ្ឌា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ អដ្ឋិមយំ ទន្តមយំ វិសាណមយំ នឡមយំ វេឡុមយំ កដ្ឋមយំ ជតុមយំ ផលមយំ លោហមយំ សង្ខនាភិមយន្តិ ។

១ ខ. មហន្តេន វិជាដេត្វា ។ ម. មហន្តេន វិជាលេត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៦៥) សម័យនោះឯង ភិក្ខុទាំងឡាយហែកចីវរដោយដៃហើយដេរចីវរ ។ ចីវរក៏មិនស្មើគ្នា ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាំបិត និងកំណាត់សំពត់សម្រាប់រុំកាំបិត ។

(១៦៦) សម័យនោះឯង កាំបិតមានដងកើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាំបិតមានដង ។

(១៦៧) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ដងកាំបិតដ៏ខ្ពស់ និងទាប[១] គឺធ្វើដោយមាស និងធ្វើដោយប្រាក់ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្ទះបង្អាប់ថា ។ បេ ។ ដូចជាពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ដងកាំបិតខ្ពស់និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដងកាំបិតធ្វើដោយឆ្អឹង ធ្វើដោយភ្លុក ធ្វើដោយស្នែង ធ្វើដោយបបុស ធ្វើដោយឫស្សី ធ្វើដោយឈើ ធ្វើដោយជ័រ ធ្វើដោយផ្លែ ធ្វើដោយលោហធាតុ[២] ធ្វើដោយគូថសង្ខ ។

---

១ ល្អនិងអន់ ។ ២ លោហធាតុផ្សេង ៗ មានទង់ដែងជាដើម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៦៨) តេន ខោ បន សមយេន ភិក្ខូ កុក្កុដបត្តេនបិ វេឡុបេសិកាយបិ ចីវរំ សិព្វន្តិ ។ ចីវរំ ទុស្សិព្វិតំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ សូចិន្តិ ។ សូចិយោ កណ្ណកិតាយោ ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ សូចិនាឡិកន្តិ ។ នាឡិកាយបិ កណ្ណកិតាយោ ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ កិណ្ណេន បូរេតុន្តិ ។ កិណ្ណេបិ កណ្ណកិតាយោ ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ សត្តុយា[១] បូរេតុន្តិ ។ សត្តុយាបិ កណ្ណកិតាយោ ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ សរិតកន្តិ ។ សរិតកោបិ កណ្ណកិតាយោ ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ មធុសិត្ថកេន សារេតុន្តិ ។ សរិតកម្បិ បរិភិជ្ជតិ ។ អនុជានាមិ ភិក្ខវេ សរិតសិបាដិកន្តិ[២] ។

១ ឱ. សត្ថុយា ។ ២ ម. សរិតកសិបាដិកន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៦៨) សម័យនោះឯង ភិក្ខុទាំងឡាយដេរចីវរដោយស្នាមមាន់ខ្វះ ដោយចំរៀកឬស្សីខ្វះ ។ ចីវរមានថ្នេរមិនល្អ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតម្ជុល ។ ម្ជុលទាំងឡាយក៏មានប្រែះបាក់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបំពង់ម្ជុល ។ ប្រែះក៏បាក់ក្នុងបំពង់ម្ជុលទៀត ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យដាក់លំអិតបំពេញ (ក្នុងបំពង់ម្ជុល) ។ ប្រែះក៏កើតឡើងក្នុងលំអិតទៀត ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យបំពេញបំពង់ម្ជុលដោយលំអិតម្សៅដំណាយដោយរមៀត ។ ប្រែះក៏កើតឡើងក្នុងលំអិតម្សៅដំណាយដោយរមៀតទៀត ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតលំអិតថ្ម ។ ប្រែះក៏កើតឡើងក្នុងលំអិតថ្មទៀត ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាបដោយក្រមួនឃ្មុំ ។ ក្រមួនឃ្មុំដែលភិក្ខុលាបហើយក៏បែករាត់រាយទៅ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកំណាត់សំពត់សម្រាប់ក្រមួនឃ្មុំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៦៩] តេន ខោ បន សមយេន ភិក្ខូ តត្ថ តត្ថ
ខីលំ និខណិត្វា សម្ពន្ធិត្វា ចីវរំ សិព្វេន្តិ ។ ចីវរំ វិកណ្ណំ
ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុ-
ជានាមិ ភិក្ខវេ កឋិនំ កឋិនរជ្ជុំ តត្ថ តត្ថ ឱពន្ធិត្វា
ចីវរំ សិព្វេតុន្តិ ។ វិសមេ កឋិនំ បត្ថរន្តិ ។ កឋិនំ
បរិភិជ្ជតិ ។ បេ ។ ន ភិក្ខវេ វិសមេ កឋិនំ បត្ថរិតព្វំ
យោ បត្ថរេយ្យ អាបត្តិ ទុក្កដស្សាតិ ។ ឆមាយំ
កឋិនំ បត្ថរន្តិ ។ កឋិនំ បំសុកិតំ ហោតិ ។ បេ ។
អនុជានាមិ ភិក្ខវេ តិណសន្ថារកន្តិ ។ កឋិនស្ស
អន្តោ ជីរតិ ។ បេ ។ អនុជានាមិ ភិក្ខវេ អនុវាតំ
បរិភណ្ឌំ អារោបេតុន្តិ ។ កឋិនំ នប្បហោតិ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៦៩) សម័យនោះឯង ភិក្ខុទាំងឡាយជីកដាំបង្គោលក្នុងទីនោះ ៗ ហើយចងដេរចីវរ ៗ ចីវរក៏ស្មោកមិនស្មើល្អ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចងឈើស្ដឹង(១)និងខ្សែស្ដឹង(២)ដើម្បីឲ្យភិក្ខុចងចីវរហើយដេរក្នុងទីនោះ ៗ ។ ភិក្ខុទាំងឡាយលាតឈើស្ដឹងក្នុងទីមិនស្មើ ។ ឈើស្ដឹងក៏បែកបាក់ទៅ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវលាតឈើស្ដឹងក្នុងទីមិនស្មើទេ ភិក្ខុណាលាត ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយលាតឈើស្ដឹងលើផែនដី ។ ឈើស្ដឹងក៏ប្រឡាក់ដោយធូលី ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកម្រាលស្មៅ ។ ជាយចីវរដែលចងនឹងឈើស្ដឹងក៏ទុកទំអស់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលើក (ថែម) អនុវាតបណ្ដោយនឹងអនុវាតទទឹងរបស់ចីវរ ។ ឈើស្ដឹងមិនល្មមគ្នានឹងចីវរ(៣) ។ បេ ។

---

១ គេយកឈើ ៤ កំណាត់មកផ្គុំគ្នាជា ៤ ជ្រុងរាងទ្រវែង ឲ្យល្មមដាក់ចីវរដេរបាន មានទាំងទ្រនាប់សម្រាប់ឈើស្ដឹងនោះផង។ ២ ខ្សែសម្រាប់ចងចីវរតឹងឈើស្ដឹងចំពោះភិក្ខុដែលដេរចីវរតែរដាន់ ។ ៣ ឈើស្ដឹងដែលគេធ្វើតម្រូវនឹងភិក្ខុខ្ពស់ លុះដេរចីវរ ភិក្ខុទាបក៏មិនល្មម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ ឧណ្ណភិសិំ វិកលកំ(១) សលាកំ វិនន្ធនរជ្ជុំ វិនន្ធនសុត្តកំ វិនន្ធិត្វា(២) ចីវរំ សិព្វេតុន្តិ ។ សុត្តន្តរិកាយោ វិសមា ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ កឡិម្ពកន្តិ ។ សុត្តា វង្កា ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ មោឃសុត្តកន្តិ ។

(១៧០) តេន ខោ បន សមយេន ភិក្ខូ អធោតេហិ បាទេហិ ភិសិំ អក្កមន្តិ ។ ភិសិ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ អធោតេហិ បាទេហិ ភិសិ អក្កមិតព្វា យោ អក្កមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

១ ឱ. ម. បុទលេកំ ។ ២ ឱ. វិនន្ធនរជ្ជុំ វិនន្ធនសុត្តកំ វិនន្ធិត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផងឈើស្ពឹង(១) ទឹងការបត់ទ្រនាប់ឈើស្ពឹងឲ្យជាពីរជាន់(២) ស្អកសម្រាប់បញ្ចូលក្នុងចន្លោះនៃចីវរមានជាន់ពីរ ខ្សែសម្រាប់តឈើស្ពឹងតូចជាមួយទឹងឈើស្ពឹងធំ ទឹងខ្សែសម្រាប់តចីវរភ្ជាប់ទឹងឈើស្ពឹងតូច ដើម្បីចងចីវរដេរ ។ ចន្លោះថ្នេរចីវរមិនស្មើគ្នា ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្នាតសម្រាប់វាស់ ។ ថ្នេរចីវរក៏វៀចមិនត្រង់ល្អ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែបន្ទាត់ ។

(១៧០) សម័យនោះឯង ភិក្ខុទាំងឡាយមានជើងមិនស្អាតហើយដើរជាន់ឈើស្ពឹង ។ ឈើស្ពឹងក៏ប្រឡាក់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានជើងមិនស្អាត មិនត្រូវដើរជាន់ឈើស្ពឹងទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ ។

---

១ ទ្រង់អនុញ្ញាតឲ្យចងឈើស្ពឹងតូច ត្រង់កណ្ដាលឈើស្ពឹងធំ ។ ២ ទ្រង់អនុញ្ញាតឲ្យបត់ដាយទ្រនាប់ជាពីរជាន់ជុំវិញ ឲ្យល្មមនឹងឈើស្ពឹងតូចនោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៧១) តេន ខោ បន សមយេន ភិក្ខូ អល្លេហិ បាទេហិ សេនាសនំ អក្កមន្តិ ។ សេនាសនំ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ អល្លេហិ បាទេហិ សេនាសនំ អក្កមិតព្វំ យោ អក្កមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៧២) តេន ខោ បន សមយេន ភិក្ខូ សឧបាហនា សេនាសនំ អក្កមន្តិ ។ សេនាសនំ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ សឧបាហនេន សេនាសនំ អក្កមិតព្វំ យោ អក្កមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៧៣) តេន ខោ បន សមយេន ភិក្ខូ ចីវរំ សិព្វេន្តា អង្គុលិយា បដិគ្គណ្ហន្តិ ។ អង្គុលិយា ទុក្ខា ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ បដិគ្គហន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកៈ ពួកភិក្ខុពាក់ស្បែកជើងដើរជាន់ឈើស្តឹង និយាយអំពីស្នាប់ម្រាមដៃ

(១៧១) សម័យនោះឯង ភិក្ខុទាំងឡាយមានជើងទទឹក ដើរជាន់លើឈើស្តឹង ៗ ឈើស្តឹងក៏ប្រឡាក់ ៗ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានជើងទទឹក មិនត្រូវជាន់ឈើស្តឹងទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ ។

(១៧២) សម័យនោះឯង ភិក្ខុទាំងឡាយពាក់ស្បែកជើងដើរជាន់ឈើស្តឹង ៗ ឈើស្តឹងក៏សៅហ្មង ៗ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងជាន់ឈើស្តឹងទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ ។

(១៧៣) សម័យនោះឯង ភិក្ខុទាំងឡាយដេរចីវរកាន់ដោយម្រាមដៃ ៗ ម្រាមដៃក៏ឈឺ ៗ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្នាប់ម្រាមដៃ[១] ។

---

១ ស្នាប់ដៃដែលគេពាក់សម្រាប់ដេរ ដើម្បីកុំឲ្យម្ជុលមុតដៃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៧៦] តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឧច្ចាវចេ បដិគ្គហេ ធារេន្តិ សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ ឧច្ចាវចា បដិគ្គហា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ អដ្ឋិមយំ ។បេ។ សង្ខនាភិមយន្តិ ។

[១៧៨] តេន ខោ បន សមយេន សូចិយោបិ សត្ថកាបិ បដិគ្គហាបិ នស្សន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាវេសនវិត្ថកន្តិ ។ អាវេសនវិត្ថកេ សមាកុលា ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បដិគ្គហត្ថវិកន្តិ ។ អំសវទ្ធកោ ន ហោតិ ។បេ។ អនុជានាមិ ភិក្ខវេ អំសវទ្ធកំ ពន្ធនសុត្តកន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៧៤) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ស្លាបព្រាមដៃដ៏ខ្ពស់នឹងទាប គឺធ្វើដោយមាសនឹងធ្វើដោយប្រាក់ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាពួកគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ស្លាបព្រាមដៃខ្ពស់នឹងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្លាបព្រាមដៃធ្វើដោយឆ្អឹង ។ បេ ។ ធ្វើដោយគូថស័ង្ខ ។

(១៧៥) សម័យនោះឯង ម្ជុល កាំបិត នឹងស្លាបព្រាមដៃធ្លាក់ទៅ ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវត្ថុសម្រាប់ដាក់[១] ។ (លុះដាក់) ក្នុងវត្ថុសម្រាប់ដាក់ក៏នៅតែពត់ពយ ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថង់សម្រាប់ដាក់ស្លាបព្រាមដៃ ។ ខ្សែយោគមិនទាន់មាននៅឡើយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែយោគនឹងខ្សែសម្រាប់ចង ។

---

១ វត្ថុណានីមួយមានភាជនៈ នឹងប្រអប់ជាដើម (អដ្ឋកថា) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៧៦) តេន ខោ បន សមយេន ភិក្ខូ អជ្ឈោកាសេ(១) ចីវរំ សិព្វន្តា សីតេនបិ ឧណ្ហេនបិ កិលមន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កឋិនសាលំ កឋិនមណ្ឌបន្តិ ។ កឋិនសាលា នីចវត្ថុកា ហោតិ ។ ឧទកេន ឱត្ថរិយតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោហន្តា វិហញ្ញន្តិ ។បេ។ អនុជានាមិ ភិក្ខវេ តយោ សោបានេ ឥដ្ឋកាសោបានំ សិលាសោបានំ ទារុសោបានន្តិ ។ អារោហន្តា បរិបតន្តិ ។បេ។ អនុជានាមិ ភិក្ខវេ អាលម្ពនពាហន្តិ ។

(១៧៧) តេន ខោ បន សមយេន កឋិនសាលាយ តិណចុណ្ណំ បរិបតតិ ។បេ។ អនុជានាមិ ភិក្ខវេ ឱគុម្ផេត្វា(២) ឧល្លិត្តាវលិត្តំ កាតុំ សេតវណ្ណំ

១ ឱ. អព្ភោកាសេ ។ ២ ឱ. ឱគុម្ពេត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកៈ ការអនុញ្ញាតរោងសម្រាប់ដាក់ឈើស្ទឹងនិងបាំសម្រាប់ដាក់ឈើស្ទឹងជាដើម

[ ១៧៦ ] សម័យនោះឯង ភិក្ខុទាំងឡាយដេរចីវរក្នុងទីវាល លំបាកដោយត្រជាក់និងក្តៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរោងសម្រាប់ដាក់ឈើស្ទឹង បាំសម្រាប់ដាក់ឈើស្ទឹង ។ រោងសម្រាប់ដាក់ឈើស្ទឹងមានទីដ៏ទាប ។ ទឹកក៏លិច ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង ។ ខឿនក៏របេះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូនខឿន ៣ យ៉ាង គឺ ខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១ ។ ភិក្ខុទាំងឡាយក៏លំបាកនឹងឡើង ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ ៣ យ៉ាង គឺ ជណ្តើរឥដ្ឋ ១ ជណ្តើរថ្ម ១ ជណ្តើរឈើ ១ ។ កាលភិក្ខុទាំងឡាយឡើងទៅក៏ធ្លាក់មកវិញ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ ។

[ ១៧៧ ] សម័យនោះឯង កំទេចស្មៅ ជ្រុះក្នុងរោងឈើស្ទឹង ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបជម្លូល ហើយបូកទាំងខាងក្នុងខាងក្រៅ ធ្វើឲ្យមានពណ៌ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាឡវណ្ណំ គេរុកបរិកម្មំ មាលាកម្មំ លតាកម្មំ មក-រទន្តកំ បញ្ចបដិកំ ចីវរវំសំ ចីវររជ្ជុន្តិ ។

(១៧៨) តេន ខោ បន សមយេន ភិក្ខូ ចីវរំ សិព្វេត្វា តត្ថេវ កឋិនំ ឧជ្ឈិត្វា បក្កមន្តិ ។ ឧន្ទូរេហិបិ ឧបចិកាហិបិ ខជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កឋិនំ សង្ហរិតុន្តិ ។ កឋិនំ បរិភិជ្ជតិ ។ បេ ។ អនុជានាមិ ភិក្ខវេ គោឃំសិកាយ កឋិនំ សង្ហរិតុន្តិ ។ កឋិនំ វិនិវេឋិយតិ[១] ។ បេ ។ អនុជានាមិ ភិក្ខវេ ពន្ធនរជ្ជុន្តិ ។

(១៧៩) តេន ខោ សមយេន ភិក្ខូ កុដ្ដេបិ ថម្ភេបិ កឋិនំ ឧស្សាបេត្វា បក្កមន្តិ ។ បរិបតិត្វា កឋិនំ ភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិត្តិខីលេ វា នាគទន្តកេ វា លគ្គេតុន្តិ ។

---

១ ម. វិវេឋិយតិ ។ ឱ. វិវេឋេតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពណ៌ខ្មៅ និងបរិកម្មដោយរេង ក្បាច់ផ្កា ក្រវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥ យ៉ាង ស្នូរចីវរ និងខ្សែស្ពៀងចីវរ ។

(១៧៨) សម័យនោះឯង ភិក្ខុទាំងឡាយដេរចីវររួចហើយទុកឈើស្ទឹងចោលក្នុងវិហារនោះហើយចៀសចេញទៅ ។ ពួកកណ្ដុរខ្លះ កណ្ដៀរខ្លះ កាត់កោរ(ឈើស្ទឹង) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសាឈើស្ទឹងទុក ។ ឈើស្ទឹងក៏បាក់បែក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យមូរឈើស្ទឹងដោយឈើស្នូល ។ ឈើស្ទឹងក៏រលាចេញ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែសម្រាប់ចង ។

(៤៧៩) សម័យនោះឯង ភិក្ខុទាំងឡាយផ្អែកឈើស្ទឹងទុកនឹងជញ្ជាំងខ្លះ នឹងសសរខ្លះ ហើយចៀសចេញទៅ ។ ឈើស្ទឹងក៏រលំបាក់ ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពាក់(ឈើស្ទឹង) នឹងមេជញ្ជាំង ឬដៃកែវ ។

ខុទ្ទកវត្ថុក្ខន្ធកេ អំសវទ្ធកពន្ធនសុត្តកអនុជាននំ

(១៨០) អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន វេសាលី តេន ចារិកំ បក្កាមិ ។ តេន ខោ បន សមយេន ភិក្ខូ សូចិកម្បិ សត្ថកម្បិ ភេសជ្ជម្បិ បត្តេន អាទាយ គច្ឆន្តិ ។ ភគវតោ ឯត-មត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភេសជ្ជត្ថវិ-កន្តិ ។ អំសវទ្ធកោ ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ អំសវទ្ធកំ ពន្ធនសុត្តកន្តិ ។

(១៨១) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ឧបាហនាយោ កាយពន្ធនេន[១] ពន្ធិត្វា គាមំ បិណ្ឌា-យ បាវិសិ ។ អញ្ញតរោ ឧបាសកោ តំ ភិក្ខុំ អភិវា-ទេន្តោ ឧបាហនាយោ សីសេន ឃដ្ដេសិ ។ សោ ភិក្ខុ មង្កុ អហោសិ ។ អថខោ សោ ភិក្ខុ អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧបាហ-នត្ថវិកន្តិ ។ អំសវទ្ធកោ ន ហោតិ ។ បេ ។ អនុជា-នាមិ ភិក្ខវេ អំសវទ្ធកំ ពន្ធនសុត្តកន្តិ ។

---

១ ឱ. កាយពន្ធេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកៈ ការទ្រង់អនុញ្ញាតខ្សែយោគនឹងខ្សែសម្រាប់ចង

[១៨០] គ្រានោះឯង ព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងរាជគ្រឹះតាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់យាងទៅកាន់ចារិកក្នុងវេសាលី ។ សម័យនោះឯង ភិក្ខុទាំងឡាយយកម្ជុលខ្លះ កាំបិតខ្លះ ភេសជ្ជៈខ្លះ ដាក់ក្នុងបាត្រដើរទៅ ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថង់សម្រាប់ដាក់ភេសជ្ជៈ ។ ខ្សែយោគមិនទាន់មាននៅឡើយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែយោគនឹងខ្សែសម្រាប់ចង ។

[១៨១] សម័យនោះឯង ភិក្ខុ ១ រូបចងស្បែកជើងនឹងវត្តពន្ធចង្កេះ ហើយចូលទៅបិណ្ឌបាតក្នុងស្រុក ។ មានឧបាសកម្នាក់ថ្វាយបង្គំភិក្ខុនោះ ក៏ទង្គិចក្បាលនឹងស្បែកជើង ។ ភិក្ខុនោះមានសេចក្តីអៀនខ្មាស ។ ចំណែកខាងភិក្ខុនោះទៅកាន់អារាម ហើយក៏បានប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុបានយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថង់សម្រាប់ដាក់ស្បែកជើង ។ ខ្សែយោគមិនទាន់មាននៅឡើយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែយោគនឹងខ្សែសម្រាប់ចង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៨២] តេន ខោ បន សមយេន អន្តរាមគ្គេ ឧទកំ អកប្បិយំ ហោតិ ។ បរិស្សាវនំ ន ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បរិស្សាវនន្តិ ។ ចោឡកំ នប្បហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ កដច្ឆុបរិស្សាវនន្តិ ។ ចោឡកំ នប្បហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ធម្មករកន្តិ ។

[១៨៣] តេន ខោ បន សមយេន ទ្វេ ភិក្ខូ កោសលេសុ ជនបទេសុ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ ឯកោ ភិក្ខុ អនាចារំ អាចរតិ ។ ទុតិយោ ភិក្ខុ តំ ភិក្ខុំ ឯតទវោច មា អាវុសោ ឯវរូបមកាសិ នេតំ កប្បតីតិ ។ សោ តស្មឹ ឧបនន្ធិ(១) ។ អថខោ សោ ភិក្ខុ បិបាសាយ បីឡិតោ ឧបនន្ធំ(២) ភិក្ខុំ ឯតទវោច ទេហិ មេ អាវុសោ បរិស្សាវនំ បានីយំ បិវិស្សាមីតិ ។ ឧបនន្ធោ ភិក្ខុ ន អទាសិ ។ សោ ភិក្ខុ បិបាសាយ បីឡិតោ កាលមកាសិ ។ អថខោ សោ ភិក្ខុ

១ ឱ. ឧបនយ្ហិ ។ ២ ឱ. ឧបនយ្ហំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៨២) សម័យនោះឯង មានទឹកជាអកប្បិយៈក្នុងចន្លោះផ្លូវ ។ សំពត់តម្រងទឹកមិនទាន់មាននៅឡើយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់តម្រងទឹក ។ កំណាត់សំពត់មិនគ្រាន់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតម្រងទឹកដែលគេរឹតភ្ជាប់នឹងឈើបីកំណាត់ ។ កំណាត់សំពត់មិនគ្រាន់ ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតធម្មក្រក ។

(១៨៣) សម័យនោះឯង ក្នុងកោសលជនបទ មានភិក្ខុពីររូបនាំគ្នាដើរទៅកាន់ផ្លូវឆ្ងាយ ។ ភិក្ខុមួយរូបប្រព្រឹត្តអនាចារ ។ ភិក្ខុទីពីរបាននិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ អ្នកកុំធ្វើអំពើយ៉ាងនេះឡើយ អំពើនេះមិនគួរទេ ។ ភិក្ខុដែលប្រព្រឹត្តអនាចារនោះក៏ចងគំនុំនឹងភិក្ខុនោះ ។ ចំណែកខាងភិក្ខុអ្នកប្រព្រឹត្តអនាចារនោះស្រេកទឹក ក៏និយាយទៅនឹងភិក្ខុដែលខ្លួនចងគំនុំយ៉ាងនេះថា ម្នាលអាវុសោ ចូរលោកឲ្យតម្រងទឹកមកខ្ញុំ ។ នឹងផឹកទឹក ។ ភិក្ខុដែលគេចងគំនុំមិនព្រមឲ្យ ។ ភិក្ខុដែលប្រព្រឹត្តអនាចារនោះស្រេកទឹកខ្លាំង ក៏ធ្វើមរណកាលទៅ ។ កាលភិក្ខុដែលគេចងគំនុំនោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ តំ បន ត្វំ អាវុសោ បរិស្សាវនំ យាចិយមានោ ន អទាសីតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ បរិស្សាវនំ យាចិយមានោ ន ទស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

[១៨៦] អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា តំ ភិក្ខុំ បដិបុច្ឆិ សច្ចំ កិរ ត្វំ ភិក្ខុ បរិស្សាវនំ យាចិយមានោ ន អទាសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ តេ មោឃបុរិស អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម ត្វំ មោឃបុរិស បរិស្សាវនំ យាចិយមានោ ន ទស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ អទ្ធានមគ្គប្បដិបន្នេន ភិក្ខុនា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ទៅអារាម ក៏បានប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក៏និយាយថា ម្នាលអាវុសោ កាលគេសុំសំពត់តម្រងទឹក លោកមិនឲ្យគេមែនឬ ។ ភិក្ខុនោះឆ្លើយថា មែនហើយអាវុសោ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀលបន្តុះបង្អាប់ថា កាលបើគេខ្ចីសំពត់តម្រងទឹក ភិក្ខុមិនសមបើមិនឲ្យគេទេ ។ លំដាប់នោះ ភិក្ខុទាំងនោះបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។

(១៨៤) ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃក្នុងវេលានោះ ហើយត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថាគេខ្ចីសំពត់តម្រងទឹក អ្នកមិនឲ្យគេ ពិតមែនឬ ។ ភិក្ខុនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះមានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អំពើរបស់អ្នកជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនត្រូវធ្វើ ម្នាលមោឃ-បុរស កាលបើគេខ្ចីសំពត់តម្រងទឹក អ្នកមិនសមបើនឹងមិនឲ្យគេទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើងទេ ។បេ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដើរទៅតាមផ្លូវឆ្ងាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បរិស្សាវនំ យាចិយមានេន ន ទាតព្វំ យោ ន ទទេយ្យ អាបត្តិ ទុក្កដស្ស ន ច ភិក្ខវេ អបរិស្សាវនកេន អទ្ធានមគ្គោ បដិបជ្ជិតព្វោ យោ បដិបជ្ជេយ្យ អាបត្តិ ទុក្កដស្ស សចេ ន ហោតិ បរិស្សាវនំ វា ធម្មករណោ វា សង្ឃាដិកណ្ណោបិ អធិដ្ឋាតព្វោ ឥមិនា បរិស្សាវេត្វា បិវិស្សាមីតិ ។

(១៨៥) អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន វេសាលី តទវសរិ ។ តត្រ សុទំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។

(១៨៦) តេន ខោ បន សមយេន ភិក្ខូ នវកម្មំ ការេន្តិ ។ បរិស្សាវនំ ន សម្មតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ទណ្ឌបរិស្សាវនន្តិ ។ ទណ្ឌបរិស្សាវនំ ន សម្មតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឱត្ថរកន្តិ(១) ។

---

១ ឱ ម. វិក្ខិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



កាលបើគេខ្ចីតម្រងទឹក កុំគប្បីមិនឲ្យ ភិក្ខុណាមិនឲ្យ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុគ្មានសំពត់តម្រងទឹក មិនត្រូវដើរផ្លូវឆ្ងាយទេ ភិក្ខុណាដើរ ត្រូវអាបត្តិទុក្កដ បើមិនមានសំពត់តម្រងទឹកក្តី ធម្មករកក្តី ទុកជាជាយសង្ឃាដិ ក៏ត្រូវអធិដ្ឋានបានថា អាត្មាអញនឹងត្រងទឹកដោយជាយសង្ឃាដិនេះចាន់ ។

(១៨៥) លំដាប់នោះ ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ទ្រង់សំដៅទៅកាន់ក្រុងវេសាលី ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងកូដាគារសាលា ព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះ ។

(១៨៦) សម័យនោះឯង ភិក្ខុទាំងឡាយធ្វើនវកម្ម (ការធ្វើថ្មី) ។ ភិក្ខុទាំងនោះ មិនបានសន្ធតសំពត់តម្រងទឹកនៅឡើយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់តម្រងទឹកមានដង ។ ភិក្ខុមិនទាន់សន្ធតសំពត់តម្រងទឹកមានដងនៅឡើយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់តម្រងត្រាំ[១] ។

---

១ សំពត់ដែលគេចងជាយទាំង ៤ ភ្ជាប់នឹងបង្គោលទាំង ៤ ដែលគេបោះក្នុងទឹកហើយសង្កត់ត្រង់កណ្តាលសំពត់នោះ ឲ្យទឹកជ្រាបចូលមក ហើយយកភាជន៍ទៅដងទឹកនោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៨៧) តេន ខោ បន សមយេន ភិក្ខូ មកសេហិ ឧព្វាឡ្ហា ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មកសកុដិកន្តិ ។

(១៨៨) តេន ខោ បន សមយេន វេសាលិយំ បណីតានំ ភត្តានំ ភត្តប្បដិបាដិ អដ្ឋិតា(១) ហោតិ ។ ភិក្ខូ បណីតានិ ភោជនានិ ភុញ្ជិត្វា អភិសន្នកាយា ហោន្តិ ពវ្ហាពាធា ។ អថខោ ជីវកោ កោមារភច្ចោ វេសាលឹ អគមាសិ កេនចិទេវ ករណីយេន ។ អទ្ទសា ខោ ជីវកោ កោមារភច្ចោ ភិក្ខូ អភិសន្នកាយេ ពវ្ហាពាធេ ទិស្វាន យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជីវកោ កោមារភច្ចោ ភគវន្តំ ឯតទវោច ឯតរហិ ភន្តេ ភិក្ខូ អភិសន្នកាយា ពវ្ហាពាធា សាធុ ភន្តេ ភគវា ភិក្ខូនំ ចង្កមញ្ច ជន្តាឃរញ្ច អនុជានាតុ ឯវំ ភិក្ខូ អប្បាពាធា ភវិស្សន្តីតិ ។ អថខោ ភគវា

---

១ ម. អធិដ្ឋិតា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ខុទ្ទកវត្ថុក្ខន្ធកៈ ការទ្រង់អនុញ្ញាតមុង

(១៨៧) សម័យនោះឯង មូសខៀតខៀនភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតមុង ។

(១៨៨) សម័យនោះឯង ក្រុងវេសាលីពួកជនបានចាត់ចែងភត្តដ៏ឧត្តម (ប្រគេនពួកភិក្ខុ) ។ ពួកភិក្ខុបានឆាន់ភោជនទាំងឡាយដ៏ឧត្តម មានកាយច្រើនទៅដោយទោស ( រោគទល់ ) មានអាពាធច្រើន ។ គ្រានោះឯង ជីវកកោមារភច្ចបានទៅក្រុងវេសាលី ដោយកិច្ចនីមួយ ។ ជីវកកោមារភច្ចបានឃើញភិក្ខុទាំងឡាយមានកាយច្រើនទៅដោយរោគ មានអាពាធច្រើន លុះបានឃើញហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះជីវកកោមារភច្ចអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ភិក្ខុទាំងឡាយមានកាយច្រើនទៅដោយទោស មានអាពាធច្រើន បពិត្រព្រះមានព្រះភាគដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះអង្គអនុញ្ញាតទីចង្ក្រមនឹងរោងភ្លើងដល់ភិក្ខុទាំងឡាយ ជាការប្រពៃ កាលបើយ៉ាងនេះ ភិក្ខុទាំងឡាយនឹងមិនសូវមានអាពាធ ។ លំដាប់នោះ ព្រះមានព្រះភាគ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ជីវកំ កោមារភច្ចំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ ជីវកោ កោមារភច្ចោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

(១៨៩) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ចង្កមញ្ច ជន្តាឃរញ្ចាតិ ។

(១៩០) តេន ខោ បន សមយេន ភិក្ខូ វិសមេ ចង្កមេ ចង្កមន្តិ ។ បាទា ទុក្ខា ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សមំ កាតុន្តិ ។

(១៩១) តេន ខោ បន សមយេន ចង្កមោ នីចវត្ថុកោ ហោតិ ។ ឧទកេន ឱត្ថរិយតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោហន្តា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទ្រង់ពន្យល់ជីវកកោមារភច្ច ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ វេលានោះ ជីវកកោមារភច្ច កាលដែលព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថារួចហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។

(១៨៩) ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទីចង្ក្រមនឹងរោងភ្លើង ។

(១៩០) សម័យនោះឯង ភិក្ខុទាំងឡាយចង្ក្រមក្នុងទីចង្ក្រមមិនរាបស្មើ ។ ជើងទាំងឡាយក៏ឈឺ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីចង្ក្រមឲ្យរាបស្មើ ។

(១៩១) សម័យនោះឯង ទីចង្ក្រមជាទីទាប ។ ទឹកក៏លិចក្នុងទីចង្ក្រមនោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីចង្ក្រមឲ្យខ្ពស់ឡើង ។ ជើងកំរបេះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូនជើង ៣ យ៉ាង គឺ ជើងឥដ្ឋ ១ ជើងថ្ម ១ ជើងឈើ ១ ។ ភិក្ខុទាំងឡាយនាំគ្នាឡើង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វិហញ្ញន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ តយោ សោ-
បាណេ ឥដ្ឋកាសោបាណំ សិលាសោបាណំ ទារុសោ-
បាណន្តិ ។ អារោហន្តា បរិបតន្តិ ។ បេ ។ អនុជានាមិ
ភិក្ខវេ អាលម្ពនពាហន្តិ ។

(១៩២) តេន ខោ បន សមយេន ភិក្ខូ ចង្កមេ
ចង្កមន្តា បរិបតន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។
អនុជានាមិ ភិក្ខវេ ចង្កមនវេទិកន្តិ ។

(១៩៣) តេន ខោ បន សមយេន ភិក្ខូ អជ្ឈោ-
កាសេ ចង្កមន្តា សីតេនបិ ឧណ្ហេនបិ កិលមន្តិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ
ចង្កមនសាលន្តិ ។ ចង្កមនសាលាយំ តិណចុណ្ណំ បរិ-
បតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឱគុម្ពេត្វា ឧល្លិត្តាវ-
លិត្តំ កាតុំ សេតវណ្ណំ កាឡវណ្ណំ គេរុកបរិកម្មំ
មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកំ
ចីវរវំសំ ចីវររជ្ជុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទៅក៏លំបាក ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ៣យ៉ាង គឺ ជណ្តើរឥដ្ឋ ១ ជណ្តើរថ្ម ១ ជណ្តើរឈើ ១ ។ ភិក្ខុទាំងឡាយនាំគ្នាឡើងទៅ ក៏ធ្លាក់ចុះមកវិញ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ ។

(១៩២) សម័យនោះឯង ពួកភិក្ខុកំពុងចង្ក្រមលើទីចង្ក្រម ក៏ធ្លាក់ចុះមក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ(១)ក្នុងទីចង្ក្រម ។

(១៩៣) សម័យនោះឯង ភិក្ខុទាំងឡាយកំពុងចង្ក្រមក្នុងទីវាល ក៏លំបាកដោយត្រជាក់ខ្លះ ក្តៅខ្លះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរោងចង្ក្រម ។ កំទេចស្មៅក៏ជ្រុះមកក្នុងរោងចង្ក្រម ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបជម្បូលហើយបូកទាំងខាងក្នុងខាងក្រៅ ធ្វើឲ្យមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ ក្បាច់ភីផ្កា ភីវល្លិ៍ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់ ៥ សរុចីវរ ទីងខ្សែស្បៀង ។

---

១ វត្ថុដែលបោះភ្ជាប់ទីចង្ក្រមបង្ការកុំឲ្យធ្លាក់ ហៅថា បង្កាន់ដៃ ស្រុកខ្លះ ហៅថា ដៃរបៃ ក៏មាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(១៩៦) តេន ខោ បន សមយេន ជន្តាឃរំ នីច-
វត្ថុកំ ហោតិ ។ ឧទកេន ឱត្ថរិយតិ ។ បេ ។ អនុជា-
នាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ
។ បេ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ
ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោហន្តា
វិហញ្ញន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ តយោ សោ-
បានេ ឥដ្ឋកាសោបានំ សិលាសោបានំ ទារុសោ-
បានន្តិ ។ អារោហន្តា បរិបតន្តិ ។ បេ ។ អនុជានាមិ
ភិក្ខវេ អាលម្ពនពាហន្តិ ។ ជន្តាឃរស្ស កវាដំ ន
ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ កវាដំ បិដ្ឋ-
សង្ឃាដំ ឧទុក្ខលិកំ ឧត្តរបាសកំ អគ្គឡវដ្ដឹ កបិ-
សីសកំ សូចិកំ ឃដិកំ តាលច្ឆិទ្ទំ អាវិញ្ឆនច្ឆិទ្ទំ
អាវិញ្ឆនរជ្ជុន្តិ ។ ជន្តាឃរស្ស កុឌ្ឌបាទោ ជីរតិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៩៤] សម័យនោះឯង ពេងភ្លើងមានទីដីទាប ៗ ទឹក (ជោរជន់មក) ក៏លិចពេងភ្លើងនោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីដីឲ្យខ្ពស់ឡើង ។ ខឿនក៏របេះធ្លាក់ចុះ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូនខឿន ៣ យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ទាំងខឿនឈើ១ ។ ពួកភិក្ខុនាំគ្នាឡើងទៅក៏លំបាក ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្ដើរ ៣ យ៉ាង គឺ ជណ្ដើរឥដ្ឋ ១ ជណ្ដើរថ្ម ១ ជណ្ដើរឈើ ១ ។ ពួកភិក្ខុនាំគ្នាឡើងទៅក៏ធ្លាក់ចុះមកវិញ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ ។ ពេងភ្លើងមិនទាន់មានទ្វារបង្អួចនៅឡើយ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ត្បាល់ថ្មដំណាប់ក្រោម ឈើអន្ទាក់លើ (ដំណាប់លើ) សសររបស់សន្ទះទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់ទាញ ទាំងខ្សែសម្រាប់ទាញ (បិទបើក)។ ជើងជញ្ជាំងពេងភ្លើងក៏ពុក ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មណ្ឌលិកំ កាតុន្តិ ។ ជន្តាឃរស្ស ធូមនេត្តំ ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ធូមនេត្តន្តិ ។

(១៩៥) តេន ខោ បន សមយេន ភិក្ខូ ខុទ្ទកេ ជន្តាឃរេ មជ្ឈេ អគ្គិដ្ឋានំ ករោន្តិ ។ ឧបចារោ ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ខុទ្ទកេ ជន្តាឃរេ ឯកមន្តំ អគ្គិដ្ឋានំ កាតុំ មហល្លកេ មជ្ឈេតិ ។ ជន្តាឃរេ អគ្គិ មុខំ ឌហតិ ។ បេ ។ អនុជានាមិ ភិក្ខវេ មុខមត្តិកន្តិ ។ ហត្ថេន មត្តិកំ តេមេន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ មត្តិកាទោណិកន្តិ ។ មត្តិកា ទុគ្គន្ធា ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ វាសេតុន្តិ ។

(១៩៦) តេន ខោ បន សមយេន ជន្តាឃរេ អគ្គិ កាយំ ឌហតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧទកំ អតិហរិតុន្តិ ។ បាតិយាបិ បត្តេនបិ ឧទកំ អតិហរន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



តថាគតអនុញ្ញាតឲ្យធ្វើទីដីឲ្យទាបជុំវិញ[១] ។ ប្រហោងសម្រាប់បង្ហូរផ្សែងរបស់រោងភ្លើងមិនទាន់មាននៅឡើយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតប្រហោងសម្រាប់បង្ហូរផ្សែង ។

(១៩៥) សម័យនោះឯង ពួកភិក្ខុធ្វើបង្រ្គានកណ្តាលរោងភ្លើងតូច ។ ទីឱកាសសម្រាប់ចេញចូលមិនមាន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើរោងភ្លើងតូច តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើបង្រ្គានក្នុងទីដ៏សមគួរមួយ កាលបើរោងភ្លើងធំ ឲ្យធ្វើបង្រ្គានក្នុងទីពាក់កណ្តាល ។ ភ្លើងក្នុងរោងភ្លើងក៏ឆេះបំពាយក្តៅមកត្រូវមុខ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកដីមកលាបមុខ ។ ពួកភិក្ខុធ្វើដីឲ្យទទឹកដោយដៃ (របស់ខ្លួន) ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្នូកសម្រាប់ដាក់ដីស្អិត ។ ដីស្អិតក៏ធុំក្លិនស្អុយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអប់ដោយគ្រឿងក្រអូប ។

(១៩៦) សម័យនោះឯង ភ្លើងក្នុងរោងភ្លើងក៏ឆេះបំពាយក្តៅមកត្រូវកាយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យដងទឹកទុក ។ ពួកភិក្ខុដងទឹកដោយចានខ្លះ ដោយបាត្រខ្លះ

---

១ ធ្វើទីដីឲ្យទាបព័ទ្ធជុំវិញជញ្ជាំងដើម្បីនឹងទប់ជើងជញ្ជាំង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



។ បេ ។ អនុជានាមិ ភិក្ខវេ ឧទកភាជនំ(១) ឧទកស-
រាវកន្តិ ។ ជន្តាឃរំ តិណចុណ្ណនំ ន សោធេន្តិ ។ បេ ។
អនុជានាមិ ភិក្ខវេ ឱកុម្មេត្វា ឧល្លិត្តាវលិត្តំ កាតុំ ។
ជន្តាឃរំ ចិក្ខល្លំ ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ
សន្ថរិតុំ តយោ សន្ថារេ ឥដ្ឋកាសន្ថារំ សិលាសន្ថារំ
ទារុសន្ថារន្តិ ។ ចិក្ខល្លំយេវ ហោតិ ។ បេ ។ អនុជានាមិ
ភិក្ខវេ ធោវិតុន្តិ ។ ឧទកំ សន្តិដ្ឋតិ ។ បេ ។ អនុជានាមិ
ភិក្ខវេ ឧទកនិទ្ធមនន្តិ ។

(១៩៧) តេន ខោ បន សមយេន ភិក្ខូ ជន្តាឃរេ
ឆមាយំ និសីទន្តិ គត្តានិ កណ្ឌូវន្តិ(២) ។ បេ ។ អនុជា-
នាមិ ភិក្ខវេ ជន្តាឃរបីឋន្តិ ។

(១៩៨) តេន ខោ បន សមយេន ជន្តាឃរំ អប-
រិក្ខិត្តំ ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ បរិក្ខិបិតុំ
តយោ បាការេ ឥដ្ឋកាបាការំ សិលាបាការំ ទារុបា-
ការន្តិ ។ កោដ្ឋកោ ន ហោតិ ។ បេ ។ អនុជានាមិ

---

១ ម. ឧទកដ្ឋានំ ។ ២ ម. កណ្ដុវន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត សៀនទីងផ្តិល ។ ពេងភ្លើងដែលប្រក់ដោយស្មៅក៏គ្មានបំហាយភ្លើស ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូលហើយបូកលាបដីស្អិតទាំងខាងក្នុងខាងក្រៅ ។ ពេងភ្លើងក៏មានភក់ជ្រាំ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាល ៣ យ៉ាង គឺ កម្រាលឥដ្ឋ ១ កម្រាលថ្ម ១ កម្រាលឈើ ១ ។ ពេងភ្លើងក៏នៅតែមានភក់ជ្រាំដដែល ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាងចេញ ។ ទឹកក៏ដក់នៅ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយទឹក ។

(១៩៧) សម័យនោះឯង ពួកភិក្ខុអង្គុយផ្ទាល់លើផែនដីក្នុងពេងភ្លើង យកដៃអេះខ្លួន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងសម្រាប់ពេងភ្លើង ។

(១៩៨) សម័យនោះឯង ពេងភ្លើងមិនមានវត្ថុបិទបាំងនៅឡើយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបិទបាំងកំពែង ៣ យ៉ាង គឺ កំពែងឥដ្ឋ ១ កំពែងថ្ម ១ កំពែងឈើ ១ ។ បន្ទប់មិនទាន់មាននៅឡើយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ភិក្ខវេ កោដ្ឋកន្តិ ។ កោដ្ឋកោ នីចវត្ថុកោ ហោតិ ។ ឧទកេន ឱត្ថរិយតិ ។បេ។ អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។បេ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោហន្តា វិហញ្ញន្តិ ។បេ។ អនុជានាមិ ភិក្ខវេ តយោ សោបានេ ឥដ្ឋកាសោបានំ សិលាសោបានំ ទារុសោបានន្តិ ។ អារោហន្តា បរិបតន្តិ ។បេ។ អនុជានាមិ ភិក្ខវេ អាលម្ពនពាហន្តិ ។ កោដ្ឋកស្ស កវាដំ ន ហោតិ ។បេ។ អនុជានាមិ ភិក្ខវេ កវាដំ បិដ្ឋសង្ឃាដំ ឧទុក្ខលិកំ ឧត្តរបាសកំ អគ្គឡវដ្ដឹ កបិសីសកំ សូចិកំ ឃដិកំ តាលច្ឆិទ្ទំ អាវិញ្ឆនច្ឆិទ្ទំ អាវិញ្ឆនរជ្ជុន្តិ ។

(១៩៩) តេន ខោ បន សមយេន កោដ្ឋកេ តិណចុណ្ណំ បរិបតតិ ។បេ។ អនុជានាមិ ភិក្ខវេ ឱគុម្ផេត្វា ឧល្លិត្តាវលិត្តំ កាតុំ សេតវណ្ណំ កាឡវណ្ណំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបន្ទប់ ។ បន្ទប់មានទីដីទាប ។ ទឹកក៏ជោរជន់លិចមក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង ។ ជឿនក៏របេះធ្លាក់ចេញ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូនជឿន ៣ យ៉ាង គឺ ជឿនឥដ្ឋ ១ ជឿនថ្ម ១ ជឿនឈើ ១ ។ ភិក្ខុទាំងឡាយក៏ទាំគ្នាឡើងទៅបានដោយលំបាក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ ៣ យ៉ាង គឺ ជណ្តើរឥដ្ឋ ១ ជណ្តើរថ្ម ១ ជណ្តើរឈើ ១ ។ ពួកភិក្ខុឡើងទៅក៏ធ្លាក់ចុះមក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ ។ បន្ទប់មិនទាន់មានទ្វារបង្អួចនៅឡើយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ត្បាល់ ឬដំណាប់ក្រោមឈើអន្ទាក់លើ (ដំណាប់លើ) សសរបេស់សន្ទះទ្វារ ត្រដោកទ្វារ ទុកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់ទាញ នឹងខ្សែសម្រាប់ទាញ (បិទបើក) ។

(១៩៩) សម័យនោះឯង កំទេចស្មៅក៏ធ្លាក់ចុះមកក្នុងបន្ទប់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបជម្បូលហើយបូកលាបទាំងខាងក្នុងខាងក្រៅ ធ្វើឲ្យមានពណ៌ស ពណ៌ខ្មៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គោប្ផកបរិកម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដ្ដិកន្តិ ។ បរិវេណំ ចិក្ខល្លំ ហោតិ ។បេ។ អនុជានាមិ ភិក្ខវេ មរុម្ពំ ឧបកិរិតុន្តិ ។ ន បរិយាបុណន្តិ ។បេ។ អនុជានាមិ ភិក្ខវេ បទរសិលំ(១) និក្ខិបិតុន្តិ ។ ឱទកំ សន្តិដ្ឋតិ ។បេ។ អនុជានាមិ ភិក្ខវេ ឧទកនិទ្ធមនន្តិ ។

(២០០) តេន ខោ បន សមយេន ភិក្ខូ នគ្គា នគ្គំ អភិវាទេន្តិ ។ នគ្គា អនគ្គំ អភិវាទេន្តិ ។ នគ្គា នគ្គំ អភិវាទាបេន្តិ ។ នគ្គា អនគ្គំ អភិវាទាបេន្តិ(២) ។ នគ្គា នគ្គស្ស បរិកម្មំ ករោន្តិ ។ នគ្គា នគ្គស្ស បរិកម្មំ ការាបេន្តិ ។ នគ្គា នគ្គស្ស ទេន្តិ ។ នគ្គា បដិគ្គណ្ហន្តិ ។ នគ្គា ខាទន្តិ ។ នគ្គា ភុញ្ជន្តិ ។ នគ្គា សាយន្តិ ។ នគ្គា បិវន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ នគ្គេន(៣) នគ្គោ អភិវាទេតព្វោ ន នគ្គេន អភិវាទេតព្វំ ន នគ្គេន(៤) នគ្គោ អភិវាទាបេតព្វោ

---

១ ឱ. ម. បទរសិលំ ។ ២ ឧរោបិយបោត្ថកេសុ នគ្គា នគ្គំ អភិវាទេន្តិ ។ នគ្គា នគ្គំ អភិវាទាបេន្តីតិ ឋបនក្កមោ អាទិតោ បដ្ឋាយ ឯវរូបោយេវ អាគតោ ។ ៣-៤ ឱ. បោត្ថកេសុ ឯត្ថ ទ្វីសុ ឋានេសុ នគ្គោតិ បទំ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទឹងលាបដោយរងើ ធ្វើភ្ជក់ ភ្ជល់ គ្រាប់ធ្មេញមករ ទឹងគ្រាប់មានស្រទាប់ ៥ ។ ទីបរិវេណក៏មានភក់ជ្រាំ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកខ្សាច់ចាក់ពេយពយចុះ ។ ដីខ្សាច់មិនរាបស្មើ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាលថ្ម ។ ទឹកក៏ដក់នៅ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយសម្រាប់បង្ហូរទឹក ។

(២០០) សម័យនោះឯង ពួកភិក្ខុអាក្រាតសំពះភិក្ខុអាក្រាត ។ ពួកភិក្ខុអាក្រាតសំពះភិក្ខុមិនអាក្រាត ។ ពួកភិក្ខុអាក្រាតឲ្យគេសំពះភិក្ខុអាក្រាត ។ ពួកភិក្ខុអាក្រាតឲ្យគេសំពះភិក្ខុមិនអាក្រាត ។ ពួកភិក្ខុអាក្រាតធ្វើបរិកម្មដល់ភិក្ខុអាក្រាត ។ ពួកភិក្ខុអាក្រាតឲ្យគេធ្វើបរិកម្មដល់ភិក្ខុអាក្រាត ។ ពួកភិក្ខុអាក្រាតឲ្យ (របស់) ដល់ភិក្ខុអាក្រាត ។ ពួកភិក្ខុអាក្រាតទទួល (របស់) ។ ពួកភិក្ខុអាក្រាតទំពាស៊ី ។ ពួកភិក្ខុអាក្រាតបរិភោគ ។ ពួកភិក្ខុអាក្រាតលិតភ្លក្ស ។ ពួកភិក្ខុអាក្រាតផឹក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រាតមិនត្រូវសំពះភិក្ខុអាក្រាត ភិក្ខុអាក្រាតមិនត្រូវសំពះ (គេ) ភិក្ខុអាក្រាតមិនត្រូវឲ្យគេសំពះភិក្ខុអាក្រាត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ន នគ្គេន អភិវាទាបេតព្វំ ន នគ្គេន នគ្គស្ស បរិកម្មំ កាតព្វំ ន នគ្គេន បរិកម្មំ ការាបេតព្វំ ន នគ្គេន នគ្គស្ស ទាតព្វំ ន នគ្គេន បដិគ្គហេតព្វំ ន នគ្គេន ខាទិតព្វំ ន នគ្គេន ភុញ្ជិតព្វំ ន នគ្គេន សាយិតព្វំ ន នគ្គេន បាតព្វំ យោ បិវេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២០១) តេន ខោ បន សមយេន ភិក្ខូ ជន្តាឃរេ ឆមាយំ ចីវរំ និក្ខិបន្តិ ។ ចីវរំ បំសុកិតំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ជន្តាឃរេ ចីវរវំសំ ចីវររជ្ជុន្តិ ។ ទេវេ វស្សន្តេ ចីវរំ ឱវស្សតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ជន្តាឃរសាលន្តិ ។ ជន្តាឃរសាលា នីចវត្ថុកា ហោតិ ។ ឧទកេន ឱត្ថរិយតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ ។ បេ ។ អារោហន្តា វិហញ្ញន្តិ ។ បេ ។ អារោហន្តា បរិបតន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ អាលម្ពនពាហន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុអាក្រាតមិនត្រូវឲ្យគេសំពះខ្លួន ភិក្ខុអាក្រាតមិនត្រូវធ្វើបរិកម្មដល់ភិក្ខុអាក្រាត ភិក្ខុអាក្រាតមិនត្រូវឲ្យគេធ្វើបរិកម្មដល់ខ្លួន ភិក្ខុអាក្រាតមិនត្រូវឲ្យរបស់ដល់ភិក្ខុអាក្រាត ភិក្ខុអាក្រាតមិនត្រូវទទួលរបស់ ភិក្ខុអាក្រាតមិនត្រូវទំពាស៊ី ភិក្ខុអាក្រាតមិនត្រូវបរិភោគ ភិក្ខុអាក្រាតមិនត្រូវលិតភក្សា ភិក្ខុអាក្រាតមិនត្រូវផឹកទេ ភិក្ខុណាផឹក ត្រូវអាបត្តិទុក្កដ ។

(២០១) សម័យនោះឯង ពួកភិក្ខុដាក់ចីវរលើផែនដីក្នុងពេនភ្លើង ៗ ចីវរក៏ប្រឡាក់ទៅដោយអាចម៍ដី ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែស្នូរចីវរនិងខ្សែស្បៀងចីវរក្នុងពេនភ្លើង ។ កាលដែលភ្លៀងបង្អុរចុះមក ចីវរក៏ទទឹក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាលាជិតពេនភ្លើង ។ សាលាជិតពេនភ្លើងមានទីទាប ។ ទឹកក៏ជោរជន់មកលិចចុះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង ។ ទឿនក៏របេះធ្លាក់ចេញ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូន ។ បេ ។ ពួកភិក្ខុនាំគ្នាឡើងទៅ ក៏លំបាក ។ បេ ។ ពួកភិក្ខុឡើងទៅ ក៏ធ្លាក់ចុះមក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) បង្កាន់ដៃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២០២) តេន ខោ បន សមយេន ជន្តាឃរសាលាយំ តិណចុណ្ណំ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឱកុម្ពេត្វា ឧល្លិត្តាវលិត្តំ កាតុំ ។ បេ ។ ចីវរវំសំ ចីវររជ្ជុន្តិ ។

(២០៣) តេន ខោ បន សមយេន ភិក្ខូ ជន្តាឃរេបិ ឧទកេបិ បិដ្ឋិបរិកម្មំ(១) កាតុំ កុក្កុច្ចាយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តិស្សោ បដិច្ឆាទិយោ ជន្តាឃរបដិច្ឆាទឹ(២) ឧទកបដិច្ឆាទឹ វត្ថបដិច្ឆាទិន្តិ ។

(២០៤) តេន ខោ បន សមយេន ជន្តាឃរេ ឧទកំ ន ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧទបានន្តិ ។ ឧទបានស្ស កូលំ លុជ្ជតិ ។ បេ ។ អនុជានាមិ ភិក្ខវេ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ ឧទបានោ នីចវត្ថុកោ ហោតិ ។ ឧទកេន ឱត្ថរិយតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

១ ឱ.ម. បរិកម្មំ ។ ២ ម. ឃរបដិច្ឆាទិំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២០២) សម័យនោះឯង កំទេចស្មៅ ក៏ធ្លាក់ចុះក្នុងរោងភ្លើង ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគោប ផ្សាលហើយបូកលាបដោយដីទាំងខាងក្នុងខាងក្រៅ ។បេ។ (តថាគត អនុញ្ញាតឲ្យធ្វើ) ស្បៀងស្ងចីវរនឹងខ្សែស្បៀងចីវរ ។

(២០៣) សម័យនោះឯង ពួកភិក្ខុមានសេចក្តីរង្កៀសនឹងធ្វើបរិកម្ម ខ្លួន (ដុសខ្លួន) ក្នុងរោងភ្លើងខ្លះ ក្នុងទឹកខ្លះ ។ ភិក្ខុទាំងនោះក៏ក្រាបបង្គំ ទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទីបិទបាំង ៣ យ៉ាង គឺ ទីបិទបាំងដោយ រោងភ្លើង ១ ទីបិទបាំងដោយទឹក ១ ទីបិទបាំងដោយសំពត់ ១ ។

(២០៤) សម័យនោះឯង រោងភ្លើងមិនទាន់មានទឹកនៅឡើយ ។ ភិក្ខុទាំងអម្បាលនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើអណ្តូង ទឹក ។ ប្រាំងអណ្តូងក៏បាក់ចុះ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ តថាគតអនុញ្ញាត (ឲ្យក) ខឿន ៣ យ៉ាង គឺ ខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ ១ ។ អណ្តូងទឹកមានទីទាប ។ ទឹកក៏ជោរជន់ លិច ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។ បេ ។ អារោហន្តា វិហញ្ញន្តិ ។ បេ ។ អារោហន្តា បរិបតន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ អាលម្ពនពាហន្តិ ។

(២០៥) តេន ខោ បន សមយេន ភិក្ខូ វល្លិយាបិ(១) កាយពន្ធនេនបិ ឧទកំ វាហេន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧទបានរជ្ជុន្តិ(២) ។ ហត្ថា ទុក្ខា ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ តុលំ ករកដកំ ចក្កវដ្ដកន្តិ ។ ភាជនា ពហូ ភិជ្ជន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ តយោ វារកេ លោហវារកំ ទារុវារកំ ចម្មខណ្ឌន្តិ ។

(២០៦) តេន ខោ បន សមយេន ភិក្ខូ អជ្ឈោកាសេ ឧទកំ វាហេន្តា(៣) សីតេនបិ ឧណ្ហេនបិ កិលមន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧទបានសាលន្តិ ។ ឧទបានសាលាយ តិណចុណ្ណំ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ

១ ឱ. វល្លិកាយបិ ។ ២ ឱ. ឧទកវាហនរជ្ជុន្តិ ។ ៣ ឱ. វាហេត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីដីឲ្យខ្ពស់ឡើង ។ ទឿងក៏របេះធ្លាក់ចេញ ។ បេ ។ ពួកភិក្ខុនាំគ្នាឡើង ក៏លំបាក ។ បេ ។ ពួកភិក្ខុនាំគ្នាឡើងទៅ ក៏ធ្លាក់ចុះមក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) បង្កាន់ដៃ ។

(២០៥) សម័យនោះឯង ពួកភិក្ខុយោងទឹកឡើងដោយវល្លិខ្លះ ដោយវត្ថពន្ធបង្កេះខ្លះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត(ឲ្យធ្វើ)ខ្សែសម្រាប់យោងទឹកអណ្ដូង ។ ដៃក៏ឈឺ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ឈើថ្លឹងយន្តសម្រាប់យោង (ទឹក) ព្រ័ត្រនៃរនទឹនរ៉ក ( សម្រាប់យោង ) ។ កាជនក៏បែកធ្លាក់ជាច្រើន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបំពង់ ៣ យ៉ាង គឺ បំពង់លោហជាតិ ១ បំពង់ឈើ ១ បំពង់ស្បែក ១ ។

(២០៦) សម័យនោះឯង ពួកភិក្ខុយោងទឹកក្នុងទីវាលក៏លំបាក ដោយរងាខ្លះ ដោយក្ដៅខ្លះ ភិក្ខុទាំងឡាយនោះក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើរោងអណ្ដូងទឹក ។ កំទេចស្មៅក៏ធ្លាក់ចុះក្នុងរោងអណ្ដូងទឹក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឱគុម្ពេត្វា ឧល្លិត្តាវលិត្តំ កាតុំ សេតវណ្ណំ កាឡវណ្ណំ គេរុកបរិកម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដ្ដិកំ ចីវរវំសំ ចីវររជ្ជុន្តិ ។

(២០៧) តេន ខោ បន សមយេន ឧទកចាដោ អបារុតោ ហោតិ ។ តិណចុណ្ណេហិបិ បំសុកេហិបិ ឱកិរិយតិ ។ បេ ។ អនុជានាមិ ភិក្ខវេ អបិធានន្តិ ។

(២០៨) តេន ខោ បន សមយេន ឧទកភាជនំ ន សំវិជ្ជតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧទកទោណឹ ឧទកកដាហន្តិ ។

(២០៩) តេន ខោ បន សមយេន ភិក្ខូ អារាមេ តហំ តហំ នហាយន្តិ ។ អារាមោ ចិក្ខល្លោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧទកចន្ទនិកន្តិ(១) ។ ចន្ទនិកា បាកដា ហោតិ ។ ភិក្ខូ ហិរិយន្តិ នហាយិតុំ ។ បេ ។ អនុជានាមិ ភិក្ខវេ

១ ឱ. ម. ចន្ទនិកន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តថាគតអនុញ្ញាត ឲ្យគាបជម្រួលហើយបូកលាបដីស្អិត ទាំងខាងក្នុងខាងក្រៅ ឲ្យមានពណ៌ស ឲ្យមានពណ៌ខ្មៅ លាបដោយរង់ ធ្វើភ្ញី ភ្ញីវល្លិ ក្បាច់ធ្មេញមករ ធ្វើក្បាច់មានស្រទាប់៥ ស្បៀងស្នរចីវរ ខ្សែស្បៀងចីវរ ។

(២០៧) សម័យនោះឯង អណ្តូងទឹកមិនទាន់មានគិរបនៅឡើយ ។ កំទេចស្មៅខ្លះ អាចម៍ដីខ្លះ ក៏ពេយពាយចុះ (ក្នុងអណ្តូងនោះ) ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើគិរប ។

(២០៨) សម័យនោះឯង ភាជន៍សម្រាប់ដងទឹកមិនទាន់មាននៅឡើយ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្នូកសម្រាប់ដាក់ទឹក និងផើងសម្រាប់ដាក់ទឹក ។

(២០៩) សម័យនោះឯង ពួកភិក្ខុដងទឹកក្នុងទីពីសពាសក្នុងអាកាស។ អាកាសក៏មានភក់ជ្រាំ ។ ភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអណ្តូងសម្រាប់ដាក់ទឹកជ្រាំ ។ អណ្តូងសម្រាប់ដាក់ទឹកជ្រាំ តាំងនៅក្នុងទីវាល មិនទាន់បានបិទបាំងនៅឡើយ ។ ពួកភិក្ខុក៏អៀនខ្មាស មិនហ៊ានដួសទឹក ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



បរិក្ខិបិតុំ តយោ ចាការេ ឥដ្ឋកាចាការំ សិលា-ចាការំ ទារុចាការន្តិ ។ ចន្ទនិកា ចិក្ខល្លា ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ សន្ថរិតុំ តយោ សន្ថារេ ឥដ្ឋកាសន្ថារំ សិលាសន្ថារំ ទារុសន្ថារន្តិ ។ ឧទកំ សន្តិដ្ឋតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧទកនិទ្ធមនន្តិ ។

(២១០) តេន ខោ បន សមយេន ភិក្ខូនំ គត្តានិ សីតិគតានិ ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧទកបុញ្ឆនិំ ចោឡកេនបិ បច្ចុទ្ធ-រិតុន្តិ ។

(២១១) តេន ខោ បន សមយេន អញ្ញតរោ ឧបាសកោ សង្ឃស្ស អត្ថាយ បោក្ខរណិំ ការេតុ-កាមោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បោក្ខរណិន្តិ ។ បោក្ខរណិយា កូលំ លុជ្ជតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោហន្តា វិហញ្ញន្តិ ។ អនុជានាមិ ភិក្ខវេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តថាគតអនុញ្ញាតឲ្យបិទបាំងដោយកំពែង ៣ យ៉ាង គឺ កំពែងឥដ្ឋ ១ កំពែងថ្ម ១ កំពែងឈើ ១ ។ អណ្តូងសម្រាប់ដាក់ទឹកជ្រាំក៏មានភក់ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាល ៣ យ៉ាង គឺ កម្រាលឥដ្ឋ ១ កម្រាលថ្ម ១ កម្រាលឈើ ១ ។ ទឹកក៏ដក់នៅ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយទឹក ។

(២១០) សម័យនោះឯង ពួកភិក្ខុមានខ្លួនត្រជាក់ (ដោយដំណក់ទឹក) ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើវត្ថុសម្រាប់ជូតទឹក (មានភួកជាដើម) ឬទឹងជូតដោយកំណាត់សំពត់ក៏បាន ។

(២១១) សម័យនោះឯង មានឧបាសកម្នាក់មានចំណង់នឹងធ្វើស្រះជាប្រយោជន៍ដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើស្រះបាន ។ (វេលានោះ)ក្តីស្រះក៏របេះចេញ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើខឿន ៣ យ៉ាង គឺ ខឿនឥដ្ឋ ១ ខឿនថ្ម ១ ខឿនឈើ ១ ។ ពួកភិក្ខុនាំគ្នាឡើងក៏លំបាក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តយោ សោបាណោ ឥដ្ឋកាសោបាណំ សិលាសោបាណំ ទារុសោបាណន្តិ ។ អារោហន្តា បរិបតន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ អាលម្ពនពាហន្តិ ។ ពោក្ខរណិយោ ឧទកំ បុរាណំ ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧទកាមាតិកំ(១) ឧទកនិទ្ធមនន្តិ ។

(២១២) តេន ខោ បន សមយេន អញ្ញតរោ ឧបាសកោ ភិក្ខុសង្ឃស្ស អត្ថាយ និល្លេខំ ជន្តាឃរំ កត្តុកាមោ(២) ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ និល្លេខំ ជន្តាឃរន្តិ ។

(២១៣) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ចាតុម្មាសំ និសីទនេន វិប្បវសន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ចាតុម្មាសំ និសីទនេន វិប្បវសិតព្វំ ។ យោ វិប្បវសេយ្យ អាបត្តិ ទុក្កដស្សាតិ ។

---

១ ឱ. ឧទកាយតិកំ ។ ២ ឱ ម. អញ្ញតរោ ភិក្ខុ សង្ឃស្ស អត្ថាយ និល្លេខំ ជន្តាឃរំ កត្តុកាមោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ជណ្ដើរ ៣ យ៉ាង គឺ ជណ្ដើរឥដ្ឋ ១ ជណ្ដើរថ្ម ១ ជណ្ដើរឈើ ១ ។ ភិក្ខុទាំងនោះនាំគ្នាឡើងទៅក៏ធ្លាក់ចុះមកវិញ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃ ។ (វេលានោះ) ក្នុងស្រះមានទឹកចាស់ដក់នៅ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយទឹក នឹងចបង្ហូរទឹក ។

(២១២) សម័យនោះឯង មានឧបាសកម្នាក់មានបំណងនឹងធ្វើរោងភ្លើង ជាទីគេក្រាកាយ(ប្រកបដោយ)ជញ្ជាំងក្ដារ ដើម្បីជាប្រយោជន៍ដល់ភិក្ខុសង្ឃ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើរោងភ្លើងជាទីគេក្រាកាយមានជញ្ជាំងក្ដារ ។

(២១៣) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនៅប្រាសចាកនិសីទនៈអស់ ៤ ខែ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនៅប្រាសចាកនិសីទនៈអស់ ៤ ខែទេ ភិក្ខុណានៅប្រាស ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកេ បុប្ផាភិកិណ្ណសយនាទិ

(៨១៤) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បុប្ផាភិកិណ្ណេសុ សយនេសុ សយន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោ-តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ បុប្ផាភិកិណ្ណេសុ សយនេសុ សយិតព្វំ យោ សយេយ្យ អាបត្តិ ទុក្កដស្សា-តិ ។

(៨១៥) តេន ខោ បន សមយេន មនុស្សា គន្ធម្បិ មាលម្បិ អាទាយ អារាមំ អាគច្ឆន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គន្ធំ គហេត្វា កវាដេ បញ្ចង្គុលិកំ ទាតុំ បុប្ផំ គហេត្វា វិហារេ ឯកមន្តំ និក្ខិបិតុន្តិ ។

(៨១៦) តេន ខោ បន សមយេន សង្ឃស្ស នមតកំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេ-សុំ ។ អនុជានាមិ ភិក្ខវេ នមតកន្តិ ។ អថខោ ភិក្ខូនំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





[២១៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដេកលើដំណេកដែលគេរោយកាយដោយផ្កា ។ មនុស្សទាំងឡាយដើរទៅកាន់វិហារ បានឃើញ ហើយក៏ពោលទោស តិះដៀល បន្ទោសថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដេកលើដំណេកដែលគេរោយកាយដោយផ្កាទេ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ ។

[២១៥] សម័យនោះឯង មនុស្សទាំងឡាយនាំយកគ្រឿងក្រអូបខ្លះ ផ្កាកម្រងខ្លះ មកកាន់អារាម ។ ពួកភិក្ខុមានសេចក្តីរង្កៀសមិនហ៊ានទទួល ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យទទួលគ្រឿងក្រអូប ហើយឲ្យប្រស់ព្រំដោយម្រាមដៃ ៥ ត្រង់ទ្វារនៃបង្អួច ព្រមទាំងទទួលយកផ្កាទៅទុកក្នុងទីដ៏សមគួរក្នុងវិហារបាន ។

[២១៦] សម័យនោះឯង កម្រាលស្នាច់ដែលគេធ្វើដោយរោមចៀមកើតឡើងដល់សង្ឃ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកម្រាលស្នាច់ ដែលគេធ្វើដោយរោមចៀម ។ ភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯតទហោសិ ឆមតកំ អធិដ្ឋាតព្ពំ នុ ខោ ឧទាហុ វិកប្បេតព្ពន្តិ ។ បេ ។ ន ភិក្ខវេ ឆមតកំ អធិដ្ឋាតព្ពំ ន វិកប្បេតព្ពន្តិ ។

(២១៧) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អាសិត្តកូបធានេ[1] ភុញ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អាសិត្តកូបធានេ ភុញ្ជិតព្វំ យោ ភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២១៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ សោ ភុញ្ជមានោ ន សក្កោតិ ហត្ថេន បត្តំ សន្ធារេតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មឡោរិកន្តិ ។

---

១ ឱ. អាសិត្តកូបធានេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មានសេចក្តីត្រិះរិះថា កម្រាលស្នាប់ដែលគេធ្វើដោយរោមចៀមនេះ យើងគួរអធិដ្ឋាន ឬគួរវិកប្ប ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបាច់អធិដ្ឋាន មិនបាច់វិកប្បនូវកម្រាលស្នាប់ដែលគេធ្វើដោយរោមចៀមទេ ។

(២១៧) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់ភោជនក្នុងភាជន៍ពិសេស(១) សម្រាប់ដើបឆ្ហាន់ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ភោជន ក្នុងភាជន៍ពិសេសសម្រាប់ដើបឆ្ហាន់ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

(២១៨) សម័យនោះឯង ភិក្ខុ១រូបមានជម្ងឺ ។ កាលដែលភិក្ខុនោះឆាន់មិនអាចនឹងទប់បាត្រដោយដៃបាន ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភាជន៍សម្រាប់ដើដែលធ្វើដោយឈើ ។

---

១ អដ្ឋកថា តុប្បជាស ដែលធ្វើដោយស្ពាន់ឬទង់ដែងនឹងប្រាក់ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(២១៩) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឯកភាជនេបិ ភុញ្ជន្តិ ។ ឯកថាលកេបិ[១] បិវន្តិ ។ ឯកមញ្ចេបិ តុវដ្ដេន្តិ ។ ឯកត្ថរណេបិ តុវដ្ដេន្តិ ។ ឯកបាវុរណេបិ តុវដ្ដេន្តិ ។ ឯកត្ថរណបាវុរណេបិ តុវដ្ដេន្តិ[២] ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។បេ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ ឯកភាជនេ ភុញ្ជិតព្វំ ន ឯកថាលកេ បាតព្វំ ន ឯកមញ្ចេ តុវដ្ដិតព្វំ ន ឯកត្ថរណេ តុវដ្ដិតព្វំ ន ឯកបាវុរណេ តុវដ្ដិតព្វំ ន ឯកត្ថរណបាវុរណេ តុវដ្ដិតព្វំ[៣] យោ តុវដ្ដេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២២០) តេន ខោ បន សមយេន វឌ្ឍោ លិច្ឆវី មេត្តិយភុម្មជកានំ ភិក្ខូនំ សហាយោ ហោតិ ។ អថ ខោ វឌ្ឍោ លិច្ឆវី យេន មេត្តិយភុម្មជកា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា មេត្តិយភុម្មជកេ ភិក្ខូ ឯតទវោច

---

១ ម. ឯកថាលកេបិ ។ ២ ឱ. ម. ឯកត្ថរណាបិ តុវដ្ដេន្តិ ។ ឯកបាវុរណាបិ តុវដ្ដេន្តិ ។ ឯកត្ថរណាបាវុរណាបិ តុវដ្ដេន្តិ ។ ៣ ឱ. ម. ន ឯកត្ថរណា តុវដ្ដិតព្វំ ។ ន ឯកបាវុរណា តុវដ្ដិតព្វំ ។ ន ឯកត្ថរណាបាវុរណា តុវដ្ដិតព្វំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៦១៩) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់ (ភោជន) ក្នុងភាជន៍ជាមួយគ្នាខ្លះ ។ ផឹកទឹកក្នុងផ្តិលជាមួយគ្នាខ្លះ ។ ដេកលើគ្រែជាមួយគ្នាខ្លះ ។ ដេកលើកម្រាលជាមួយគ្នាខ្លះ ។ ដេកដណ្តប់ជាមួយគ្នាខ្លះ ។ ដេកលើកម្រាលនិងដណ្តប់ជាមួយគ្នាខ្លះ ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ (ភោជន) រួមភាជន៍ជាមួយគ្នា មិនត្រូវផឹកទឹករួមផ្តិលជាមួយគ្នា មិនត្រូវដេកលើគ្រែជាមួយគ្នា មិនត្រូវដេកលើកម្រាលជាមួយគ្នា មិនត្រូវដេកដណ្តប់ជាមួយគ្នា មិនត្រូវដេកលើកម្រាលនិងដណ្តប់ជាមួយគ្នាទេ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ ។

(៦២០) សម័យនោះឯង វឌ្ឍលិច្ឆវីជាសំឡាញ់មេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ។ លំដាប់នោះ វឌ្ឍលិច្ឆវីចូលទៅរកមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ លុះចូលទៅដល់ហើយ ក៏និយាយនឹងមេត្តិយភិក្ខុនិងភុម្មជកភិក្ខុថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វន្ទាមិ អយ្យាតិ ។ ឯវំ វុត្តេ មេត្តិយភុម្មជកា ភិក្ខូ នាលបឹសុ ។ ទុតិយម្បិ ខោ វឌ្ឍោ លិច្ឆវិ មេត្តិយភុម្មជកេ ភិក្ខូ ឯតទវោច វន្ទាមិ អយ្យាតិ ។ ទុតិយម្បិ ខោ មេត្តិយភុម្មជកា ភិក្ខូ នាលបឹសុ ។ តតិយម្បិ ខោ វឌ្ឍោ លិច្ឆវិ មេត្តិយភុម្មជកេ ភិក្ខូ ឯតទវោច វន្ទាមិ អយ្យាតិ ។ តតិយម្បិ ខោ មេត្តិយភុម្មជកា ភិក្ខូ នាលបឹសុ ។ ក្យាហំ អយ្យានំ អបរជ្ឈាមិ កិស្ស មំ អយ្យា នាលបន្តីតិ ។ តថា ហិ បន ត្វំ អាវុសោ វឌ្ឍ អម្ហេ ទព្វេន មល្លបុត្តេន វិហេឋិយមានេ អជ្ឈុបេក្ខសីតិ ។ ក្យាហំ អយ្យា ករោមីតិ ។ សចេ ខោ ត្វំ អាវុសោ វឌ្ឍ ឥច្ឆេយ្យាសិ អជ្ជេវ ភគវា អាយស្មន្តំ ទព្វំ មល្លបុត្តំ នាសាបេយ្យាតិ ។ ក្យាហំ អយ្យា ករោមិ កឹ មយា សក្កា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លោកម្ចាស់ ខ្ញុំព្រះករុណាថ្វាយបង្គំ ។ កាលវឌ្ឍលិច្ឆវីនិយាយយ៉ាងនេះហើយ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុមិនបាននិយាយរាក់ទាក់មកវិញឡើយ ។ វឌ្ឍលិច្ឆវីក៏និយាយទៅរកមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ជាគំរប់ពីរដងទៀតថា លោកម្ចាស់ ខ្ញុំព្រះករុណាថ្វាយបង្គំ ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ក៏មិនបាននិយាយរាក់ទាក់ ជាគំរប់ពីរដងទៀត ។ វឌ្ឍលិច្ឆវីនិយាយទៅរកមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ជាគំរប់បីដងទៀតថា លោកម្ចាស់ ខ្ញុំព្រះករុណាថ្វាយបង្គំ ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុក៏មិនបាននិយាយរាក់ទាក់ ជាគំរប់បីដងទៀត ។ វឌ្ឍលិច្ឆវីនិយាយថា ខ្ញុំធ្វើខុសនឹងលោកម្ចាស់ដូចម្តេច ហេតុអ្វីក៏បានជាលោកម្ចាស់មិននិយាយរាក់ទាក់នឹងខ្ញុំ ។ មេត្តិយ-ភិក្ខុនិងភុម្មជកភិក្ខុនិយាយថា នែអាវុសោ វឌ្ឍៈ បានជាយើងមិននិយាយរាក់ទាក់ទៅរកអ្នក ព្រោះព្រះទព្វមល្លបុត្របៀតបៀនយើង អ្នកមិនអើពើសោះ ។ វឌ្ឍលិច្ឆវីនិយាយថា លោកម្ចាស់ ខ្ញុំនឹងធ្វើដូចម្តេច ។ មេត្តិយ-ភិក្ខុនិងភុម្មជកភិក្ខុនិយាយថា នែអាវុសោ វឌ្ឍៈ ប្រសិនបើអ្នកចង់ដែរ (ចូលដៃផង) ព្រះមានព្រះភាគគប្បីឲ្យព្រះទព្វមល្លបុត្ត ឋានអាយុវិនាសក្នុងថ្ងៃនេះឯង ។ វឌ្ឍលិច្ឆវីនិយាយថា លោកម្ចាស់ ខ្ញុំនឹងធ្វើដូចម្តេច ខ្ញុំនឹងអាច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាតុន្តិ ។ ឯហិ ត្វំ អាវុសោ វឌ្ឍ យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា ភគវន្តំ ឯវំ វទេហិ ឥទំ ភន្តេ នច្ឆន្នំ នប្បតិរូបំ យាយំ ភន្តេ ទិសា អភយា អនីតិកា អនុបទ្ទវា សាយំ ទិសា សភយា សឦតិកា សឧបទ្ទវា យតោ និវាតំ តតោ បវាតំ ឧទកំ មញ្ញេ អាទិត្តំ អយ្យេន មេ ទព្វេន មល្លបុត្តេន បជាបតិ ទូសិតាតិ ។ ឯវំ អយ្យាតិ ខោ វឌ្ឍោ លិច្ឆវិ មេត្តិយភុម្មជកានំ ភិក្ខូនំ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វឌ្ឍោ លិច្ឆវិ ភគវន្តំ ឯតទវោច ឥទំ ភន្តេ នច្ឆន្នំ នប្បតិរូបំ យាយំ ភន្តេ ទិសា អភយា អនីតិកា អនុបទ្ទវា សាយំ ទិសា សភយា សឦតិកា សឧបទ្ទវា យតោ និវាតំ តតោ បវាតំ ឧទកំ មញ្ញេ អាទិត្តំ អយ្យេន មេ ទព្វេន មល្លបុត្តេន បជាបតិ ទូសិតាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដើម្បីធ្វើដូចម្តេច ៗ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុនិយាយបង្គាប់ថា នែអាវុសោវឌ្ឍៈ អ្នកឯងចូរមក អ្នកចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ត្រូវក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ទំនេះមិនកំពុំង មិនសមគួរ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនមានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះក៏ត្រឡប់ទៅជាមានភ័យ មានចង្រៃ មានឧបទ្រពវិញ ខ្យល់ចេញអំពីទិសណា ទិសនោះត្រឡប់ទៅជាមានខ្យល់ចូលវិញ ទឹក (ត្រជាក់) ត្រឡប់ទៅជាក្តៅវិញ ឥឡូវនេះ លោកម្ចាស់ទព្វមល្លបុត្ត បានប្រទូស្តនឹងប្រពន្ធខ្ញុំ ៗ វឌ្ឍលិច្ឆវីទទួលស្តាប់ពាក្យរបស់មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងនោះថា ករុណា លោកម្ចាស់ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏សមគួរ ៗ លុះវឌ្ឍលិច្ឆវីអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ទំនេះមិនកំពុំង មិនសមគួរ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនមានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះក៏ត្រឡប់ទៅជាមានភ័យ មានចង្រៃ មានឧបទ្រព ខ្យល់ចេញអំពីទិសណា ទិសនោះត្រឡប់ទៅជាមានខ្យល់ចូលវិញ ទឹក (ត្រជាក់) ត្រឡប់ទៅជាក្តៅវិញ ឥឡូវនេះលោកម្ចាស់ទព្វមល្លបុត្ត ប្រទូស្តនឹងភរិយារបស់ខ្ញុំ ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៦៦១) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ ទព្វំ មល្លបុត្តំ បដិបុច្ឆិ សរសិ ត្វំ ទព្វ ឯវរូបំ កត្តា យថាយំ ភិក្ខុនី អាហាតិ ។ យថា មំ ភន្តេ ភគវា ជានាតីតិ ។ ទុតិយម្បិ ខោ ភគវា ។ បេ ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ ទព្វំ មល្លបុត្តំ ឯតទវោច សរសិ ត្វំ ទព្វ ឯវរូបំ កត្តា យថាយំ ភិក្ខុនី អាហាតិ ។ យថា មំ ភន្តេ ភគវា ជានាតីតិ ។ ន ខោ ទព្វ ទព្វា ឯវំ និព្វេឋេន្តិ សចេ តយា កតំ កតន្តិ វទេហិ សចេ អកតំ អកតន្តិ វទេហីតិ ។ យតោហំ ភន្តេ ជាតោ នាភិជានាមិ សុបិ-នន្តេនបិ មេថុនំ ធម្មំ បដិសេវិតា បគេវ ជាគរោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(២២១) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់សួរព្រះទព្វមល្លបុត្តមានអាយុថា ម្នាលទព្វៈ អ្នករលឹកមើល អ្នកបានធ្វើអំពើយ៉ាងនេះដូចជាវឌ្ឍៈនេះពោលមែនឬ ។ ព្រះទព្វមល្លបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគទ្រង់ជ្រាបខ្ញុំព្រះអង្គស្រាប់ហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ទៅនឹងព្រះទព្វមល្លបុត្ត ដ៏មានអាយុ ជាគំរប់ពីរដងផង ។ បេ ។ ជាគំរប់បីដងផងថា ម្នាលទព្វៈ អ្នករលឹកមើល អ្នកបានធ្វើអំពើយ៉ាងនេះដូចជាវឌ្ឍៈនេះពោលមែនឬ ។ ព្រះទព្វមល្លបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគទ្រង់ជ្រាបខ្ញុំព្រះអង្គស្រាប់ហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយមិនពោលបណ្តោះបណ្តោយយ៉ាងនេះទេ បើអំពើអ្វីដែលអ្នកបានធ្វើហើយ អ្នកចូរឆ្លើយថាធ្វើហើយ បើអំពើដែលអ្នកមិនបានធ្វើទេ អ្នកចូរឆ្លើយថាមិនបានធ្វើទេ ។ ព្រះទព្វមល្លបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គតាំងពីកើតមកវេលាណា មិនដែលស្គាល់សេពមេថុនធម្មទេ សូម្បីតែយល់សប្តិក៏មិនដែលឃើញឡើយ ចាំបាច់និយាយទៅថ្វីដល់កាលភ្ញាក់រលឹក ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## ខុទ្ទកវត្ថុក្ខន្ធកេ វឌ្ឍលិច្ឆវិស្ស បត្តស្ស និក្កុជ្ជនា

(២២២) អថខោ ភគវា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ និក្កុជ្ជតុ អសម្ភោគំ សង្ឃេន ករោតុ ។

(២២៣) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ឧបាសកស្ស បត្តោ និក្កុជ្ជិតព្វោ ភិក្ខូនំ អលាភាយ បរិសក្កតិ ភិក្ខូនំ អនត្ថាយ បរិសក្កតិ ភិក្ខូនំ អវាសាយ បរិសក្កតិ ភិក្ខូ អក្កោសតិ បរិភាសតិ ភិក្ខូ ភិក្ខូហិ ភេទេតិ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ អនុជានាមិ ភិក្ខវេ ឥមេហិ អដ្ឋហង្គេហិ សមន្នាគតស្ស ឧបាសកស្ស បត្តំ និក្កុជ្ជិតុំ ។

(២២៤) ឯវញ្ច បន ភិក្ខវេ និក្កុជ្ជិតព្វោ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ វឌ្ឍោ លិច្ឆវី អាយស្មន្តំ ទព្វំ មល្លបុត្តំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេតិ យទិ សង្ឃស្ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## ខុទ្ទកវត្ថុក្ខន្ធកៈ ការផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី

(២៦២) គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃត្រូវផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី គឺធ្វើមិនឲ្យសង្ឃសេពគប់គេ ។

(២៦៣) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្កាប់បាត្រដល់ឧបាសកប្រកបដោយអង្គ ៨ ប្រការ គឺឧបាសកព្យាយាមដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយបានលាភ ១ ព្យាយាមដើម្បីមិនឲ្យភិក្ខុទាំងឡាយបានប្រយោជន៍ ១ ព្យាយាមដើម្បីមិនឲ្យភិក្ខុទាំងឡាយបានទីលំនៅ ១ ជេរប្រទេចពួកភិក្ខុ ១ បំបែកពួកភិក្ខុឲ្យបែកចាកពួកភិក្ខុ ១ ពោលតិះដៀលព្រះពុទ្ធ ១ ពោលតិះដៀលព្រះធម៌ ១ ពោលតិះដៀលព្រះសង្ឃ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យផ្កាប់បាត្រ ដល់ឧបាសកដែលប្រកបដោយអង្គ ៨ ប្រការនេះឯង ។

(២៦៤) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្កាប់បាត្រយ៉ាងនេះ ។ ភិក្ខុដែលឈ្លាសប្រតិពលគប្បីផ្សៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ផ្សិត) វឌ្ឍលិច្ឆវី (ឧបាសក) ចោទព្រះទព្វមល្លបុត្រមានអាយុដោយសីលវិបត្តិមិនមានមូល បើកម្មមានកាលគួរដល់សង្ឃហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បត្តកល្លំ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ និក្កុជ្ជេយ្យ អសម្ភោគំ សង្ឃេន ករេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ វឌ្ឍោ លិច្ឆវី អាយស្មន្តំ ទព្វំ មល្ល-បុត្តំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេតិ ។ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ និក្កុជ្ជតិ អសម្ភោគំ សង្ឃេន ករោតិ ។ យស្សាយស្មតោ ខមតិ វឌ្ឍស្ស លិច្ឆវិស្ស បត្តស្ស និក្កុជ្ជនា អសម្ភោគំ សង្ឃេន ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ និក្កុជ្ជិ-តោ សង្ឃេន វឌ្ឍស្ស លិច្ឆវិស្ស បត្តោ អសម្ភោគោ សង្ឃេន ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ(១) ។

(២២៥) អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន វឌ្ឍស្ស លិច្ឆវិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា វឌ្ឍំ លិច្ឆវឹ ឯត-ទវោច សង្ឃេន តេ អាវុសោ វឌ្ឍ បត្តោ និក្កុជ្ជិតោ អសម្ភោគោសិ សង្ឃេនាតិ ។ អថខោ វឌ្ឍោ លិច្ឆវី

---

១ ឥតោ បរំ អថខោ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ និក្កុជ្ជិ អសម្ភោគំ សង្ឃេន អកាសីតិ បាឋេន មញ្ញេ ភវិតុំ វដ្ដតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សង្ឃត្រូវផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី គឺធ្វើវឌ្ឍលិច្ឆវីមិនឲ្យសង្ឃរាប់អាន ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វឌ្ឍលិច្ឆវីចោទព្រះទព្វមល្លបុត្រដ៏មានអាយុ ដោយសីលវិបត្តិមិនមានមូល ។ សង្ឃផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី គឺធ្វើវឌ្ឍលិច្ឆវីមិនឲ្យសង្ឃរាប់អាន ។ ការផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី គឺធ្វើវឌ្ឍលិច្ឆវីមិនឲ្យសង្ឃរាប់អាន គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សង្ឃបានផ្កាប់បាត្រ ដល់វឌ្ឍលិច្ឆវី គឺធ្វើវឌ្ឍលិច្ឆវីមិនឲ្យសង្ឃរាប់អានហើយ ការផ្កាប់បាត្រនេះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(២៦៨) គ្រានោះ ព្រះអានន្ទដ៏មានអាយុស្លៀកស្បង់កាន់យកបាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ផ្ទះវឌ្ឍលិច្ឆវី លុះចូលទៅដល់ហើយក៏ពោលនឹងវឌ្ឍលិច្ឆវីយ៉ាងនេះថា ម្នាលអាវុសោវឌ្ឍៈ សង្ឃបានផ្កាប់បាត្រដល់អ្នកហើយ ខ្លួនអ្នកសង្ឃលែងរាប់អានហើយ ។ ឯវឌ្ឍលិច្ឆវី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សង្ឃេន កិរ មេ បត្តោ និក្កុជ្ជិតោ អសម្ភោគោហំ កិរ សង្ឃេនាតិ តត្ថេវ មុច្ឆិតោ បបតោ ។ អថខោ វឌ្ឍស្ស លិច្ឆវិស្ស មិត្តាមច្ចា ញាតិសាលោហិតា វឌ្ឍំ លិច្ឆវឹ ឯតទវោចុំ អលំ អាវុសោ វឌ្ឍ មា សោចិ មា បរិទេវិ មយំ ភគវន្តំ បសាទេស្សាម ភិក្ខុសង្ឃញ្ចាតិ ។ អថខោ វឌ្ឍោ លិច្ឆវិ សបុត្តទារោ សមិត្តាមច្ចោ សញាតិសា-លោហិតោ អល្លវត្ថោ អល្លកេសោ យេន ភគវា តេនុ-បសង្កមិ ឧបសង្កមិត្វា ភគវតោ បាទេសុ សិរសា និប-តិត្វា ភគវន្តំ ឯតទវោច អច្ចយោ មំ ភន្តេ អច្ចគមា យ-ថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ អយ្យំ ទព្វំ មល្លបុត្តំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេសឹ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។ តគ្ឃ[១] ត្វំ អាវុសោ វឌ្ឍ អច្ច-យោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យំ ត្វំ ទព្វំ មល្លបុត្តំ អមូលិកាយ សីលវិបត្តិយា

---

១ ម. ប. តគ្ឃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឮដំណឹងថា សង្ឃផ្កាប់បាត្រដល់អាត្មាអញហើយ អាត្មាអញសង្ឃលែង
រាប់អានហើយ ក៏ជ្រប់ជ្ជុលនៅក្នុងទីនោះឯង ។ គ្រានោះ ពួកមិត្ត
អមាត្យញាតិសាលោហិតរបស់វឌ្ឍលិច្ឆវី ក៏បាននិយាយទៅនឹងវឌ្ឍលិច្ឆវី
យ៉ាងនេះថា ហើយ អាវុសោ វឌ្ឍៈ អ្នកកុំសោយសោក កុំខ្សឹកខ្សួលឡើយ
យើងនឹងធ្វើព្រះមានព្រះភាគ នឹងព្រះសង្ឃឲ្យជ្រះថ្លាឡើងវិញ ។ លំដាប់
នោះ វឌ្ឍលិច្ឆវីព្រមទាំងបុត្រភរិយាមិត្តអមាត្យ នឹងញាតិសាលោហិត
មានសំពត់ទទឹក មានសក់ទទឹក នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ
លុះចូលទៅដល់ហើយ ក៏ទុនសិរ្សៈទៀបព្រះបាទទាំងគូ របស់ព្រះមាន
ព្រះភាគ ហើយពោលនឹងព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះ
អង្គដ៏ចំរើន សេចក្តីឆ្គាំឆ្គងមានដល់ខ្ញុំព្រះអង្គហើយ តាមដោយខ្ញុំព្រះអង្គជា
មនុស្សល្ងង់ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ព្រោះថាខ្ញុំព្រះអង្គ
បានចោទលោកម្ចាស់ទព្វមល្លបុត្រដោយសីលវិបត្តិ មិនមានមូលហើយ
បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគអត់សេចក្តីឆ្គាំឆ្គង តាម
ដោយសេចក្តីឆ្គាំឆ្គងរបស់ខ្ញុំព្រះអង្គ ដើម្បីនឹងសង្រួមតទៅ ។ ព្រះមាន
ព្រះភាគទ្រង់ត្រាស់ថា ម្នាលអាវុសោ វឌ្ឍៈ អើ សេចក្តីឆ្គាំឆ្គងមានដល់អ្នក
ហើយ តាមដោយអ្នកជាមនុស្សល្ងង់ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស
ព្រោះថាអ្នកបានចោទទព្វមល្លបុត្រដោយសីលវិបត្តិ មិនមានមូលហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុទ្ធំសេសិ យតោ ច ខោ ត្វំ អាវុសោ វឌ្ឍ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម វុឌ្ឍិ ហេសា អាវុសោ វឌ្ឍ អរិយស្ស វិន-យេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិក-រោតិ អាយតឹ សំវរំ អាបជ្ជតីតិ ។

[២២៦] អថខោ ភគវា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ ឧក្កុជ្ជតុ អសម្ភោគំ សង្ឃេន ករោតុ ។ អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ឧបាសកស្ស បត្តោ ឧក្កុជ្ជិតព្វោ ឆ ភិក្ខូនំ អលាភាយ បរិសក្កតិ ឆ ភិក្ខូនំ អនត្ថាយ បរិសក្កតិ ឆ ភិក្ខូនំ អនាវាសាយ បរិសក្កតិ ឆ ភិក្ខូ អក្កោសតិ បរិភាសតិ ឆ ភិក្ខូ ភិក្ខូហិ ភេទេតិ ឆ ពុទ្ធស្ស អវណ្ណំ ភាសតិ ឆ ធម្មស្ស អវណ្ណំ ភាសតិ ឆ សង្ឃស្ស អវណ្ណំ ភាសតិ អនុជានាមិ ភិក្ខវេ ឥមេហិ អដ្ឋហង្គេហិ សមន្នាគតស្ស ឧបាសកស្ស បត្តំ ឧក្កុជ្ជិតុំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ម្នាលអាវុសោ វឌ្ឍៈ (ឥឡូវនេះ)អ្នកឃើញសេចក្តីឆ្គាំឆ្គង តាមដោយសេចក្តីឆ្គាំឆ្គង ហើយសំដែងទោសសមគួរតាមដំណើរទោស យើងក៏ទទួលទោសនោះដល់អ្នក ម្នាលអាវុសោ វឌ្ឍៈ អ្នកណាបានឃើញសេចក្តីឆ្គាំឆ្គង តាមដោយសេចក្តីឆ្គាំឆ្គង ហើយសំដែងទោសសមគួរតាមដំណើរទោស ដល់នូវសេចក្តីសង្រួមតទៅ នេះជាសេចក្តីចំរើនរបស់អ្នកនោះក្នុងអរិយវិន័យ ។

(២២៦) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរផ្ងារបាត្រដល់វឌ្ឍលិច្ឆវិ គឺធ្វើវឌ្ឍលិច្ឆវិឲ្យសង្ឃរាប់អានវិញ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្ងារបាត្រដល់ឧបាសកដែលប្រកបដោយអង្គ ៨ ប្រការ គឺ ឧបាសកមិនព្យាយាមដើម្បីនឹងឲ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ ១ មិនព្យាយាមដើម្បីឲ្យខូចប្រយោជន៍របស់ភិក្ខុទាំងឡាយ ១ មិនព្យាយាមដើម្បីឲ្យភិក្ខុទាំងឡាយខានបានទីលំនៅ ១ មិនជេរប្រទេចភិក្ខុទាំងឡាយ ១ មិនញុះញង់ភិក្ខុទាំងឡាយឲ្យបែកបាក់ភិក្ខុទាំងឡាយ ១ មិនពោលតិះដៀលព្រះពុទ្ធ ១ មិនពោលតិះដៀលព្រះធម៌ ១ មិនពោលតិះដៀលព្រះសង្ឃ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្ងារបាត្រ ដល់ឧបាសកដែលប្រកបដោយអង្គទាំង ៨ នេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



### ខុទ្ទកវត្ថុក្ខន្ធកេ បត្តស្ស ឧក្កុជ្ជនា

(២២៧) ឯវញ្ច បន ភិក្ខវេ ឧក្កុជ្ជិតព្វោ ។ តេន ភិក្ខវេ វឌ្ឍេន លិច្ឆវិនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ សង្ឃេន មេ ភន្តេ បត្តោ និក្កុជ្ជិតោ អសម្ភោគោម្ហិ សង្ឃេន សោហំ ភន្តេ សម្មា វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ សង្ឃំ បត្តុក្កុជ្ជនំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។

(២២៨) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃេន វឌ្ឍស្ស លិច្ឆវិស្ស បត្តោ និក្កុជ្ជិតោ អសម្ភោគោ សង្ឃេន ។ សោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ សង្ឃំ បត្តុក្កុជ្ជនំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ ឧក្កុជ្ជេយ្យ សម្ភោគំ សង្ឃេន ករេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃេន វឌ្ឍស្ស លិច្ឆវិស្ស បត្តោ និក្កុជ្ជិតោ អសម្ភោ-គោ សង្ឃេន ។ សោ សម្មា វត្តតិ លោមំ បាតេតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(២២៧) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្ងារបាត្រយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវវឌ្ឍលិច្ឆវិនោះចូលទៅរកសង្ឃ ធ្វើសំពត់បង់ស្មាម្ខាង ក្រាបសំពះបាទាភិក្ខុទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងនិយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃបានផ្កាប់បាត្រដល់ខ្ញុំហើយ សង្ឃលែងរាប់អានខ្ញុំហើយ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំបានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្របកេម ប្រព្រឹត្តវត្តគួរដល់កិរិយាលោសខ្លួនចេញចាកទោស ខ្ញុំមកសូមឲ្យព្រះសង្ឃ ផ្ងារបាត្រឡើងវិញ ។ វឌ្ឍលិច្ឆវិនោះត្រូវសូមជាគំរប់ពីរដងផង ជាគំរប់បីដង ។

(២២៨) ភិក្ខុដែលឈ្លាសប្រតិពលត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃបានផ្កាប់បាត្រដល់វឌ្ឍលិច្ឆវិ គឺធ្វើមិនឲ្យសង្ឃរាប់អាន ។ វឌ្ឍលិច្ឆវិនោះបានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្របកេម ប្រព្រឹត្តវត្តគួរដល់កិរិយាលោសខ្លួនចេញចាកទោស មកសូមឲ្យសង្ឃផ្ងារបាត្រឡើងវិញ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីផ្ងារបាត្រដល់វឌ្ឍលិច្ឆវិ គឺធ្វើឲ្យសង្ឃរាប់រកឡើងវិញ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃបានផ្កាប់បាត្រដល់វឌ្ឍលិច្ឆវិ គឺធ្វើមិនឲ្យសង្ឃរាប់រក ។ (ឥឡូវនេះ) វឌ្ឍលិច្ឆវិនោះបានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្របកេម ប្រព្រឹត្តវត្តគួរដល់កិរិយា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



នេត្ថារំ វត្តតិ សង្ឃំ បត្តុក្កុជ្ជនំ យាចតិ ។ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ ឧក្កុជ្ជតិ សម្ភោគំ សង្ឃេន ករោតិ ។ យស្សាយស្មតោ ខមតិ វឌ្ឍស្ស លិច្ឆវិស្ស បត្តស្ស ឧក្កុជ្ជនា សម្ភោគំ សង្ឃេន ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧក្កុជ្ជិតោ សង្ឃេន វឌ្ឍស្ស លិច្ឆវិស្ស បត្តោ សម្ភោគោ សង្ឃេន ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(២២៩) អថខោ ភគវា វេសាលិយំ យថាភិរន្តំ វិហរិត្វា យេន ភគ្គា តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន ភគ្គា តទវសរិ ។ តត្រ សុទំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។

(២៣០) តេន ខោ បន សមយេន ពោធិស្ស រាជ-កុមារស្ស កោកនទោ នាម បាសាទោ អចិរការិតោ ហោតិ អនជ្ឈាវុត្ថោ សមណេន វា ព្រាហ្មណេន វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហោស់ខ្លួនចេញចាកទោស មកសូមឲ្យសង្ឃផ្ងារបាត្រឡើងវិញ ។ សង្ឃក៏ផ្ងារបាត្រដល់វឌ្ឍលិច្ឆវិ គឺធ្វើឲ្យសង្ឃរាប់អានឡើងវិញ ។ ការផ្ងារបាត្រដល់វឌ្ឍលិច្ឆវិ គឺធ្វើឲ្យសង្ឃរាប់អានឡើងវិញ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវនិយាយឡើង ។ សង្ឃបានផ្ងារបាត្រដល់វឌ្ឍលិច្ឆវិ គឺធ្វើឲ្យសង្ឃរាប់អានវិញហើយ ការផ្ងារបាត្រនោះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្ដីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

[២២៩] គ្រានោះឯង ព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងវេសាលីគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងភគ្គជនបទ យាងទៅតាមលំដាប់ ក៏បានទៅដល់ភគ្គជនបទនោះ ។ ឮថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងភេសកឡាវ័ន(១) ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុំសុមារគិរៈក្នុងភគ្គជនបទនោះ ។

(២៣០) សម័យនោះឯង ពោធិរាជកុមារចាត់ការកសាងប្រាសាទឈ្មោះកោកនុទ(២) ទើបតែនឹងហើយថ្មី ៗ ដែលសមណៈនឹងព្រាហ្មណ៍

---

១ ព្រៃឈើហ៊ុំក្ដី ឬព្រៃនៃយក្ខិនី ឈ្មោះ ភេសកឡា នៅរក្សាគ្រប់គ្រង ។ ២ បានជាឈ្មោះថា កោកនុទ ព្រោះប្រាសាទនោះមានការរចនាមានលំអផ្កាឈូកក្រហម ។

កេនចិ វា មនុស្សភូតេន ។ អថខោ ពោធិ រាជកុមារោ សញ្ចិកាបុត្តំ មាណវំ អាមន្តេសិ ឯហិ ត្វំ សម្ម សញ្ចិកាបុត្ត យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ ពោធិ ភន្តេ រាជកុមារោ ភគវតោ បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ(១) ឯវញ្ច វទេហិ(២) អធិវាសេតុ កិរ ភន្តេ ភគវា ពោធិស្ស រាជកុមារស្ស ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ ឯវំ ភោតិ ខោ សញ្ចិកាបុត្តោ មាណវោ ពោធិស្ស រាជកុមារស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សញ្ចិកាបុត្តោ មាណវោ ភគវន្តំ ឯតទវោច ពោធិ(៣) រាជកុមារោ ភោតោ គោតមស្ស បាទេ សិរសា វន្ទតិ

១ យុរោបិយពោត្ថកេ ឥតិសទ្ទោ ន បញ្ញាយតិ ។ ២ ឱ. វទេតិ ។ ៣ ឱ.ម. ពោធិ ភោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុទ្ធកៈ រឿងព្រះពោធិរាជកុមារ

ថ្ងៃបុគ្គលណាមួយ ជាតិជាមនុស្សមិនដែលធ្លាប់បានទៅអាស្រ័យ ។ លំដាប់នោះ ពោធិរាជកុមារទ្រង់ហៅសញ្ជិកាបុត្តមាណពមកប្រាប់ថា នែសញ្ជិកាបុត្ត សំឡាញ់ អ្នកចូរមក អ្នកចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំបាទាព្រះមានព្រះភាគដោយត្បូង ទូលសួរអាពាធតិចតួច សេចក្តីលំបាកតិចតួច សេចក្តីព្យាយាមស្រួល កម្លាំងកាយមិនធមិជាគ្រឿងនៅសប្បាយ តាមពាក្យអញថា បពិត្រព្រះអង្គដ៏ចំរើន ពោធិរាជកុមារសូមថ្វាយបង្គំព្រះបាទាព្រះអង្គដោយត្បូង ទូលសួរអាពាធតិចតួច សេចក្តីលំបាកតិចតួច សេចក្តីព្យាយាមស្រួល កម្លាំងកាយ មិនធមិជាគ្រឿងនៅសប្បាយ ហើយទូលយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ សញ្ជិកាបុត្តមាណពទទួលព្រះបន្ទូលពោធិរាជកុមារថា ព្រះករុណាវិសេស ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ទៅនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ ពាក្យដែលគួររឭកហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះសញ្ជិកាបុត្តមាណពអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យយ៉ាងនេះថា ពោធិរាជកុមារសូមថ្វាយបង្គំព្រះបាទាព្រះគោតមដ៏ម្ចាស់ដោយត្បូង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ អធិវាសេតុ កិរ ភវំ គោតមោ ពោធិស្ស រាជកុមារស្ស ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សញ្ជិកាបុត្តោ មាណវោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា យេន ពោធិ រាជកុមារោ តេនុបសង្កមិ ឧបសង្កមិត្វា ពោធឹ រាជកុមារំ ឯតទវោច អវោចុម្ហ ខោ មយំ ភោតោ វចនេន តំ ភគវន្តំ គោតមំ ពោធិ រាជកុមារោ ភោតោ គោតមស្ស បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ អធិវាសេតុ កិរ ភវំ គោតមោ ពោធិស្ស រាជកុមារស្ស ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ អធិវុដ្ឋញ្ច បន សមណេន គោតមេនាតិ ។

(២៣១) អថខោ ពោធិ រាជកុមារោ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា កោកនទញ្ច បាសាទំ ឱទាតេហិ ទុស្សបដ្ដេហិ សន្ថរាបេត្វា យាវ បច្ឆិមា សោបាណកឡេវរា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ទូលសួរអាពាធតិចតួច សេចក្តីលំបាកតិចតួច សេចក្តីព្យាយាមស្រួល កម្លាំងកាយនឹងធម៌ជាគ្រឿងនៅសប្បាយ មួយទៀត ពោធិរាជកុមារឲ្យក្រាបទូលព្រះអង្គយ៉ាងនេះថា សូមព្រះគោតមដ៏ចំរើនព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះ សញ្ជិកាបុត្តមាណពដឹងថា ព្រះមានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈចូលទៅរកពោធិរាជ-កុមារ លុះចូលទៅដល់ហើយក៏ក្រាបទូលពោធិរាជកុមារយ៉ាងនេះថា ខ្ញុំព្រះអង្គបានក្រាបបង្គំទូលព្រះគោតមមានព្រះភាគ តាមបន្ទូលរបស់ទ្រង់ហើយថា ពោធិរាជកុមារសូមថ្វាយបង្គំព្រះបាទាព្រះគោតមដ៏ចំរើនដោយត្បូង ទូលសួរអាពាធតិចតួច សេចក្តីលំបាកតិចតួច សេចក្តីព្យាយាមស្រួល កម្លាំងកាយនឹងធម៌ជាគ្រឿងនៅសប្បាយ មួយទៀត ពោធិរាជកុមារឲ្យក្រាបទូលព្រះអង្គយ៉ាងនេះថា សូមព្រះគោតមដ៏ចំរើនព្រមទាំងភិក្ខុសង្ឃទទួលភត្ត របស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ព្រះសមណ-គោតមជាម្ចាស់ បានទទួលនិមន្តហើយ ។

(២៣១) លុះព្រឹកឡើង ពោធិរាជកុមារក៏ចាត់ចែងខាទនីយភោជ-នីយាហារដ៏ឧត្តម ហើយឲ្យក្រាលគោកនទប្រាសាទ ដោយសំពត់សទាំងឡាយ ដរាបដល់កាំជណ្តើរជាន់ខាងក្រោមបំផុត ហើយត្រាស់ហៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សញ្ជិកាបុត្តំ មាណវំ អាមន្តេសិ ឯហិ ត្វំ សម្ម សញ្ជិកាបុត្ត យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា ភគវតោ កាលំ អារោចេហិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ ឯវំ ភោតិ ខោ សញ្ជិកាបុត្តោ មាណវោ ពោធិស្ស រាជកុមារស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ កាលំ អារោចេតិ កាលោ ខោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។

(២៣២) អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ពោធិស្ស រាជកុមារស្ស និវេសនំ តេនុបសង្កមិ ។ តេន ខោ បន សមយេន ពោធិ រាជកុមារោ ពហិទ្វារកោដ្ឋកេ ឋិតោ ហោតិ ភគវន្តំ អាគមយមានោ ។ អទ្ទសា ខោ ពោធិ រាជកុមារោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន តតោ បច្ចុគ្គន្ត្វា ភគវន្តំ អភិវាទេត្វា បុរក្ខិត្វា យេន កោកនទោ បាសាទោ តេនុបសង្កមិ ។ អថខោ ភគវា បច្ឆិមំ សោបានកឡេវរំ និស្សាយ អដ្ឋាសិ ។ អថខោ ពោធិ រាជកុមារោ ភគវន្តំ ឯតទវោច អក្កមតុ ភន្តេ ភគវា ទុស្សានិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សញ្ជិកាបុត្តមាណពមកថា ម្នាលសញ្ជិកាបុត្ត សំឡាញ់ អ្នកចូរមក អ្នកចូរទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំទូលភត្តកាលដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តក៏សម្រេចហើយ ។ សញ្ជិកាបុត្តមាណពទទួលព្រះបន្ទូលរបស់ពោធិរាជកុមារថា ព្រះករុណាវិសេស ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តក៏សម្រេចហើយ ។

(២៣២) គ្រានោះ ព្រះមានព្រះភាគទ្រង់ស្លៀកស្បង់ទ្រង់បាត្រចីវរក្នុងបុព្វណ្ហសម័យ ទ្រង់ពុទ្ធដំណើរទៅកាន់និវេសនស្ថានរបស់ពោធិរាជកុមារ ។ សម័យនោះឯង ពោធិរាជកុមារឈរនៅខាងក្រៅខ្លោងទ្វារ រង់ចាំព្រះមានព្រះភាគ ។ ពោធិរាជកុមារបានឃើញព្រះមានព្រះភាគទ្រង់ស្តេចយាងមកអំពីចំងាយល្មម ។ លុះឃើញហើយក៏ក្រោកទៅទទួលក្នុងទីនោះ ហើយក្រាបថ្វាយបង្គំព្រះមានព្រះភាគ និមន្តព្រះអង្គឲ្យស្តេចយាងទៅខាងមុខ ហើយចូលទៅកាន់កោកនុទប្រាសាទ ។ វេលានោះ ព្រះមានព្រះភាគទ្រង់ឈប់អាស្រ័យនៅកាំជណ្តើរជាន់ខាងក្រោមបំផុត ។ លំដាប់នោះ ពោធិរាជកុមារក្រាបថ្វាយបង្គំ ទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់ជាន់សំពត់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អក្កមតុ ភន្តេ សុគតោ ទុស្សាដិំ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ ពោធិ រាជកុមារោ ភគវន្តំ ឯតទវោច អក្កមតុ ភន្តេ ភគវា ទុស្សាដិំ អក្កមតុ ភន្តេ(១) សុគតោ ទុស្សាដិំ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អវលោកេសិ(២) ។ អថខោ អាយស្មា អានន្ទោ ពោធឹ រាជកុមារំ ឯតទវោច សំហរតុ រាជកុមារ ទុស្សាដិំ ន ភគវា ចេលបដិកំ អក្កមិស្សតិ បច្ឆិមំ ជនតំ តថាគតោ អនុកម្បតីតិ ។ អថខោ ពោធិ រាជកុមារោ ទុស្សាដិំ សំហរាបេត្វា ឧបរិ កោកនទេ បាសាទេ អាសនំ បញ្ញាបេសិ ។ អថខោ ភគវា កោកនទំ បាសាទំ អភិរុហិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ ពោធិ រាជកុមារោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន

---

១ ឥទំ អាលបនំ ម. បោត្ថកេ ន ទិស្សតិ ។ ២ ម. ម. អបលោកេសិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទាំងឡាយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះសុគតទ្រង់ជាន់សំពត់ទាំងឡាយ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ខ្ញុំព្រះអង្គ អស់កាល ជាយូរអង្វែង ។ កាលពោធិរាជកុមារក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះអង្គទ្រង់នៅស្ងៀម ។ ពោធិរាជកុមារក្រាបបង្គំទូលព្រះមានព្រះភាគជាគំរប់ពីរដងផង ។ បេ ។ ជាគំរប់បីដងផងថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់ជាន់សំពត់ទាំងឡាយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះសុគតទ្រង់ស្ដេចយាងជាន់សំពត់ទាំងឡាយ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។ គ្រានោះ ព្រះមានព្រះភាគទ្រង់បែរព្រះភក្ត្រ ទៅរកព្រះអានន្ទមានអាយុ ។ ព្រះអានន្ទមានអាយុក៏មានថេរវាចាទៅនឹងពោធិរាជកុមារយ៉ាងនេះថា បពិត្រព្រះរាជកុមារ សូមទ្រង់សារសំពត់ចេញ ព្រះមានព្រះភាគ ព្រះអង្គមិនទ្រង់ជាន់កម្រាលសំពត់ទេ ព្រះតថាគតទ្រង់អនុគ្រោះដល់ប្រជុំជនជាខាងក្រោយ ។ គ្រានោះ ពោធិរាជកុមារទ្រង់ឲ្យសារសំពត់ទាំងឡាយចេញ ហើយទ្រង់ឲ្យក្រាលអាសនៈខាងលើកោកនុទប្រាសាទវិញ ។ ព្រះមានព្រះភាគស្ដេចយាងឡើងកាន់កោកនុទប្រាសាទ ហើយគង់លើអាសនៈដែលគេក្រាលស្រេចហើយព្រមទាំងភិក្ខុសង្ឃ ។ លំដាប់នោះ ពោធិរាជកុមារបានអង្គាសខាទនីយភោជនីយាហារ(ប្រណីត)

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



### ខុទ្ទកវត្ថុក្ខន្ធកេ ចេឡបដិកា អញ្ញតរិត្ថីវត្ថុ

សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីត-
បត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ
ពោធឹ រាជកុមារំ ភគវា ធម្មិយា កថាយ សន្ទស្សេត្វា
សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយា-
សនា បក្កាមិ ។

(២៣៣) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ
បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ
ចេឡបដិកា អក្កមិតព្វា យោ អក្កមេយ្យ អាបត្តិ
ទុក្កដស្សាតិ ។

(២៣៤) តេន ខោ បន សមយេន អញ្ញតរា ឥត្ថី
អបគតគព្ភា ភិក្ខូ និមន្តេត្វា ទុស្សំ បញ្ញបេត្វា ឯតទ-
វោច អក្កមថ ភន្តេ ទុស្សន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា
ន អក្កមន្តិ ។ អក្កមថ ភន្តេ ទុស្សំ មង្គលត្ថាយាតិ ។
ភិក្ខូ កុក្កុច្ចាយន្តា ន អក្កមឹសុ ។ អថខោ សា ឥត្ថី
ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម អយ្យា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ដ៏ឆ្ងាញ់ពិសារថ្វាយដោយព្រះហស្តព្រះអង្គឯង ចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់ទ្រង់ហាមឃាត់ លុះកំណត់ជ្រាបថា ព្រះមានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏គង់ក្នុងទីសមគួរ ។ លុះពោធិរាជកុមារគង់ក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគទ្រង់សំដែងធម៌ ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈស្តេចចេញទៅ ។

(២៣៣) ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវជាន់កម្រាលសំពត់ទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ ។

(២៣៤) សម័យនោះឯង មានស្រីម្នាក់សម្រាលកូនរួចហើយ និមន្តភិក្ខុទាំងឡាយ ហើយក្រាលសំពត់និយាយយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន សូមលោកទាំងឡាយជាន់សំពត់ចុះ ។ ភិក្ខុទាំងឡាយមានសេចក្តីរង្កៀសមិនហ៊ានជាន់ ។ ស្រីនោះនិយាយថា បពិត្រលោកទាំងឡាយដ៏ចំរើន សូមលោកទាំងឡាយជាន់សំពត់ដើម្បីប្រយោជន៍ជាមង្គល ។ ភិក្ខុទាំងឡាយក៏នៅតែរង្កៀសមិនហ៊ានជាន់សំពត់ (ទៀត) ។ លំដាប់នោះ ស្រីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មង្គលត្ថាយ យាចិយមានា ចេលប្បដិកំ ន អក្កា-មិស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្សា ឥត្ថិយា ឧជ្ឈាយន្តិយា ខីយន្តិយា វិបាចេន្តិយា ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ គិហី ភិក្ខវេ មង្គលិកា អនុជានាមិ ភិក្ខវេ គិហីនំ មង្គលត្ថាយ យាចិយមានេន ចេលប្បដិកំ អក្កមិតុន្តិ ។

(៤៣៥) តេន ខោ បន សមយេន ភិក្ខូ ធោតបា-ទកំ អក្កមិតុំ កុក្កុច្ចាយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ធោតបាទកំ អក្កមិតុន្តិ ។

ទុតិយភាណវារំ ។

(៤៣៦) អថខោ ភគវា ភគ្គេសុ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុ-បុព្វេន ចារិកញ្ចរមានោ យេន សាវត្ថី តទវសរិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទាំងឡាយ កាលបើគេអង្វរដើម្បីប្រយោជន៍ជាមណ្ឌល មិនសមបើនឹងមិនហ៊ើនជាទីកម្រាលសំពត់សោះ ។ ភិក្ខុទាំងឡាយបានឮស្រីនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។ ភិក្ខុអម្បាលនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) គ្រហស្ថត្រូវការមណ្ឌល ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលគ្រហស្ថអង្វរ ដើម្បីប្រយោជន៍ជាមណ្ឌល ជាទីកម្រាលសំពត់បាន ។

(២៣៥) សម័យនោះឯង ភិក្ខុទាំងឡាយរង្កៀសនឹងជាន់កម្រាល សម្រាប់ភិក្ខុដែលមានជើងស្អាតបាត ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាន់លើកម្រាល សម្រាប់ភិក្ខុដែលមានជើងស្អាតបាត ។

ចប់ភាណវារៈ ជាគំរប់ពីរ ។

(២៣៦) គ្រានោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងភគ្គជនបទគួរដល់ព្រះអធ្យាស្រ័យ ហើយយាងទៅកាន់ចារិកក្នុងក្រុងសាវត្ថី ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកេ ឃដកំ សម្មជ្ជនី វិសាខាមិគារមាតាវត្ថុ

តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថ-
បិណ្ឌិកស្ស អារាមេ ។ អថខោ វិសាខា មិគារមាតា
ឃដកញ្ច កតកញ្ច សម្មជ្ជនិញ្ច អាទាយ យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯក-
មន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ វិសាខា មិគា-
រមាតា ភគវន្តំ ឯតទវោច បដិគ្គណ្ហាតុ មេ ភន្តេ ភគវា
ឃដកញ្ច កតកញ្ច សម្មជ្ជនិញ្ច យំ មម អស្ស
ទីឃរត្តំ ហិតាយ សុខាយាតិ ។ បដិគ្គហេសិ ភគវា
ឃដកញ្ច សម្មជ្ជនិញ្ច ។ ន ភគវា កតកំ បដិគ្គហេ-
សិ ។ អថខោ ភគវា វិសាខំ មិគារមាតរំ ធម្មិយា
កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ
សម្បហំសេសិ ។ អថខោ វិសាខា មិគារមាតា
ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា
សមុត្តេជិតា សម្បហំសិតា ឧដ្ឋាយាសនា ភគវន្តំ
អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឮថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ ។ លំដាប់នោះ នាងវិសាខាមិគារមាតា នាំយកក្អមទឹកទ្រនាប់សម្រាប់ជូតជើង មានរចនាដូចពកផ្លែឈូក(១) នឹងអម្បោស ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទទួលក្អមទ្រនាប់ជូតជើងនឹងអម្បោស ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំម្ចាស់អស់កាលជាអង្វែងទៅ ។ ព្រះមានព្រះភាគទ្រង់ទទួលតែក្អមនឹងអម្បោស ។ ព្រះអង្គមិនទ្រង់ទទួលទ្រនាប់ជូតជើងឡើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ពន្យល់នាងវិសាខាមិគារមាតា ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ នាងវិសាខាមិគារមាតា កាលដែលព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

---

១ ទ្រនាប់សម្រាប់ជូតជើងដែលគេធ្វើឲ្យមានពកកន្ទួលខ្ពស់ៗ ឡើង មានអាការដូចគ្រាប់ឈូកដែលកន្ទួលផុលៗ ឡើងចេញពីផ្លែ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៣៧) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ឃដកញ្ច សម្មជ្ជនិញ្ច ន ភិក្ខវេ កតកំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តិស្សោ បាទឃំសនិយោ សក្ខរំ កថលំ សមុទ្ទផេណកន្តិ ។

(២៣៨) អថខោ វិសាខា មិគារមាតា វិធូបនញ្ច តាលវណ្ដញ្ច អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ វិសាខា មិគារមាតា ភគវន្តំ ឯតទវោច បដិគ្គណ្ហាតុ មេ ភន្តេ ភគវា វិធូបនញ្ច តាលវណ្ដញ្ច យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ បដិគ្គហេសិ ភគវា វិធូបនញ្ច តាលវណ្ដញ្ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(២៣៧) ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្អមទឹកអម្បោស ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ទ្រនាប់សម្រាប់ជូតជើងមានទេនាដូចពកផ្លែឈូក(១)ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់សម្រាប់ជូតជើង ៣ យ៉ាង គឺ ក្រួសឬដុំថ្ម ១ អម្បែងក្បឿងឬឥដ្ឋ ១ ផ្សិតដែលកើតពីពពុះទឹកសមុទ្រ ១ ។

(២៣៨) គ្រាខាងក្រោយ នាងវិសាខាមិគារមាតា នាំយកផ្ទិត ៤ ជ្រុងទងផ្ទិតមូល(២) ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាមិគារមាតាអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទទួលយកផ្ទិត ៤ ជ្រុងទងផ្ទិតមូល (ស្លឹកត្នោត) ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំម្ចាស់ អស់កាលជាអង្វែង ។ ព្រះមានព្រះភាគទ្រង់ទទួលយកផ្ទិត ៤ ជ្រុង ផ្ទិតមូល (ស្លឹកត្នោត) រួចហើយ ។

---

១ ក្នុងអដ្ឋកថា ពន្យល់ថា បានជាទ្រង់ហាម ព្រោះទ្រនាប់សម្រាប់ជូតជើងនោះប្រកបការច្រើន អស់ទ្រព្យក៏ច្រើន ។ ២ សារត្ថទីបនីដីកាពន្យល់ថា ផ្ទិតមូលគេធ្វើដោយស្លឹកត្នោតជាដើម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកេ វិធូបនតាលវណ្ដាទិកានុជាននំ

អថខោ ភគវា វិសាខំ មិគារមាតរំ ធម្មិយា កថាយ សន្ទស្សេសិ ។បេ។ បទក្ខិណំ កត្វា បក្កាមិ ។

(២៣៩) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ វិធូបនញ្ច តាលវណ្ដញ្ចាតិ ។

(២៤០) តេន ខោ បន សមយេន សង្ឃស្ស មកសវីជនី ឧប្បន្នា ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មកសវីជនិន្តិ ។ ចាមរីវីជនី ឧប្បន្នា ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ចាមរីវីជនី ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តិស្សោ វីជនិយោ វាកមយំ ឧសិរមយំ មោរបិញ្ឆមយន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទើបព្រះមានព្រះភាគទ្រង់ពន្យល់នាងវិសាខាមិគារមាតា ឲ្យយល់ (ប្រយោជន៍) ដោយធម្មីកថា ។ បេ ។ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

(២៣៩) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លិត ៤ ជ្រុងនឹងផ្លិតមូល (ស្លឹកត្នោត) ។

(២៤០) សម័យនោះឯង ផ្លិតសម្រាប់បក់មូស កើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លិតសម្រាប់បក់មូស ។ (សម័យខាងក្រោយមក) ផ្លិតដែលគេធ្វើដោយរោមចាមរីកើតឡើង (ដល់សង្ឃ) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ផ្លិតដែលគេធ្វើដោយរោមចាមរីទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លិត ៣ យ៉ាង គឺ ផ្លិតដែលគេធ្វើដោយសំបកឈើ ១ ផ្លិតដែលគេក្រងដោយស្បូវភ្លាំង ១ ផ្លិតដែលគេធ្វើដោយរោមកន្ទុយក្ងោក ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៤១) តេន ខោ បន សមយេន សង្ឃស្ស ឆត្តំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឆត្តន្តិ ។

(២៤២) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឆត្តប្បគ្គហិតា(១) អាហិណ្ឌន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ឧបាសកោ សម្ពហុលេហិ អាជីវកសាវកេហិ សទ្ធឹ ឧយ្យានំ អគមាសិ ។ អទ្ទសំសុ ខោ តេ អាជីវកសាវកា ឆព្វគ្គិយេ ភិក្ខូ ទូរតោវ ឆត្តប្បគ្គហិតេ អាគច្ឆន្តេ ទិស្វាន តំ ឧបាសកំ ឯតទវោចុំ ឯតេ ខោ អយ្យោ តុម្ហាកំ ភទ្ទន្តា ឆត្តប្បគ្គហិតា អាគច្ឆន្តិ សេយ្យថាបិ គណកមហាមត្តាតិ ។ ន អយ្យោ ឯតេ ភិក្ខូ បរិព្វាជកាតិ ។ ភិក្ខូ ន ភិក្ខូតិ អព្ភុតំ អកំសុ ។ អថខោ សោ ឧបាសកោ ឧបគតោ(២) សញ្ជានិត្វា ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថញ្ហិ នាម ភទ្ទន្តា ឆត្តប្បគ្គហិតា អាហិណ្ឌិស្សន្តិតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស ឧបាសកស្ស

១ ឱ. ម. ឆត្តំ បគ្គហេត្វា ។ ២ ឱ. ម. ឧបកតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៤១) សម័យនោះឯង មានឆត្រកើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆត្រ ។

(២៤២) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប៉ាំងឆត្រដើរទៅ ។ សម័យនោះឯង មានឧបាសកម្នាក់ដើរទៅកាន់ឧទ្យាន ជាមួយនឹងពួកសាវ័ករបស់អាជីវកជាច្រើននាក់ ។ សាវ័ករបស់អាជីវកទាំងឡាយនោះ បានឃើញពួកឆព្វគ្គិយភិក្ខុប៉ាំងឆត្រដើរមកអំពីចម្ងាយលឹម ។ លុះឃើញហើយក៏និយាយនឹងឧបាសកនោះយ៉ាងនេះថា លោកទាំងអម្បាលនេះជាជីតុនរបស់អ្នក លោកប៉ាំងឆត្រដើរមក ដូចជាពួកមហាមាត្យត្រួតពល ។ ឧបាសកនោះក៏តបថា លោកទាំងអម្បាលនេះមិនមែនជាភិក្ខុទេ គឺជាបរិញ្វាជក ។ ពួកសាវ័កអាជីវកនឹងឧបាសក ក៏ភ្នាល់គ្នាដោយពាក្យថា ភិក្ខុ (ឬ) មិនមែនជាភិក្ខុ ។ ទើបឧបាសកនោះដើរចូលទៅជិតមើលស្គាល់ច្បាស់ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីក៏លោកម្ចាស់ដ៏ចំរើន ប៉ាំងឆត្រដើរ ។ ភិក្ខុទាំងឡាយបានឮឧបាសកនោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ ឆត្តំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៤៤៣) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តស្ស វិនា ឆត្តំ(១) ផាសុ ន(២) ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គិលានស្ស ឆត្តន្តិ ។

(៤៤៤) តេន ខោ បន សមយេន ភិក្ខូ គិលានស្ស ភគវតា ឆត្តំ អនុញ្ញាតំ នោ អគិលានស្សាតិ អារាមេ អារាមូបចារេ ឆត្តំ ធារេតុំ កុក្កុច្ចាយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ អគិលានេនបិ(៣) ភិក្ខុនា(៤) អារាមេ អារាមូបចារេ ឆត្តំ ធារេតុន្តិ ។

---

១ ឱ. ឆត្តេន ។ ២ ឱ. ម. ន ផាសុ ។ ៣ ឱ. គិលានេនបិ អគិលានេនបិ ។
៤ ឱ. ម. ពោត្ថកេសុ ភិក្ខុនាតិ បទំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះ ។ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (អំពើនោះ) ពិតមែនឬ ។បេ។ ភិក្ខុទាំងអម្បាលនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។បេ។ ព្រះអង្គទ្រង់បន្ទោស រួចហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឆត្រទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

(២៤៣) សម័យនោះឯង ភិក្ខុ ១ រូបទៀតមានជម្ងឺ ។ ភិក្ខុនោះបើខានបាំងឆត្រ មិនបានសេចក្តីសប្បាយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆត្រដល់ភិក្ខុមានជម្ងឺ ។

(២៤៤) សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតឆត្រដល់ភិក្ខុមានជម្ងឺតែម្យ៉ាង មិនបានទ្រង់អនុញ្ញាតដល់ភិក្ខុគ្មានជម្ងឺទេ ហើយរង្កៀសនឹងការបាំងឆត្រក្នុងអារាម និងឧបចាររបស់អារាម ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមិនមានជម្ងឺបាំងឆត្រក្នុងអារាម និងឧបចារនៃអារាមបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



[៦៤៥] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សិក្កាយ បត្តំ ឧឌ្ឍិត្វា(១) ឧណ្ហោ អាលម្ពេត្វា វិហារេ អញ្ញតរេន តាមទ្វារេន អតិក្កមតិ ។ មនុស្សា ឯសយ្យា(២) ឃោរោ គច្ឆតិ អសិស្ស វិជ្ជោតលតីតិ អនុបតិត្វា គហេត្វា សញ្ជានិត្វា មុញ្ចិំសុ ។ អថខោ សោ ភិក្ខុ អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ កិំ បន ត្វំ អាវុសោ ឧណ្ហាសិក្កំ ធារេសីតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ ឧណ្ហាសិក្កំ ធារេស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ ឧណ្ហាសិក្កា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៦៤៦] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ន សក្កោតិ វិនា ឧណ្ហោន អាហិណ្ឌិតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ ឧណ្ហាសម្មតឹ ទាតុំ ។

១ ទី. ឧឌ្ឌិត្វា ។ ២ ទី. ម. ឯសយ្យោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[២៤៥] សម័យនោះឯង ភិក្ខុ ១ រូបប្រកបបាត្រក្នុងសង្រែក ហើយពាក់លើឈើច្រត់ ដើរទៅតាមទ្វារស្រុកមួយ ក្នុងវេលាវិកាល ។ មនុស្សទាំងឡាយនាំគ្នានិយាយថា បពិត្រអ្នកម្ចាស់ទាំងឡាយ បុរសនេះជាចោរដើរទៅ ដាវរបស់វា (មានមុខ) ភ្លឺស្វាង ហើយក៏ដេញតាមចាប់ លុះចាប់បានហើយ ស្គាល់ថា (ជាភិក្ខុ) ក៏លែងទៅវិញ ។ ទើបភិក្ខុនោះទៅកាន់អារាម ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុផងគ្នា ។ ភិក្ខុទាំងឡាយនោះសួរថា ម្នាលអាវុសោ អ្នកទ្រទ្រង់ឈើច្រត់ទាំងសង្រែកឬអ្វី ។ ភិក្ខុនោះប្រាប់ថា អើអាវុសោ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមបើនឹងទ្រទ្រង់ឈើច្រត់ទាំងសង្រែកសោះ ។ ទើបភិក្ខុទាំងឡាយនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់បន្ទោស ហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឈើច្រត់ទាំងសង្រែកទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[២៤៦] សម័យនោះឯង ភិក្ខុ ១ រូបមានជម្ងឺ តែរៀរលែងឈើច្រត់ចេញហើយ មិនអាចនឹងដើរទៅមកបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យទណ្ឌសម្មតិដល់ភិក្ខុមានជម្ងឺ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(២៦៧) ឯវញ្ច បន ភិក្ខវេ យាចិតព្វា ។ តេន គិលានេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ គិលានោ ន សក្កោមិ វិនា ទណ្ឌេន អាហិណ្ឌិតុំ សោហំ ភន្តេ សង្ឃំ ទណ្ឌសម្មុតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។

(២៦៨) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ វិនា ទណ្ឌេន អាហិណ្ឌិតុំ សោ សង្ឃំ ទណ្ឌសម្មុតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ ទណ្ឌសម្មុតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ វិនា ទណ្ឌេន អាហិណ្ឌិតុំ សោ សង្ឃំ ទណ្ឌសម្មុតឹ យាចតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕





(២៤៧) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ភិក្ខុមានជម្ងឺនោះត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ថ្វាយបង្គំបាទារបស់ភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីពោលពាក្យយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំមានជម្ងឺ បើវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមកបាន បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមទណ្ឌសម្មតិនឹងសង្ឃ ។ ភិក្ខុនោះគប្បីសូមជាគំរប់ពីរដងផង គប្បីសូមជាគំរប់បីដងផង ។

(២៤៨) ភិក្ខុដែលឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះមានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមកបាន ភិក្ខុនោះមកសូមទណ្ឌសម្មតិនឹងសង្ឃ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យទណ្ឌសម្មតិដល់ភិក្ខុឈ្មោះនេះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះមានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមកបាន ភិក្ខុនោះមកសូមទណ្ឌសម្មតិនឹងសង្ឃ ៘

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ ទណ្ឌសម្មុតឹ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ទណ្ឌសម្មុតិយា ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ ទណ្ឌសម្មុតិ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(២៤៩) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ន សក្កោតិ វិនា សិក្កាយ បត្តំ បរិហរិតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ សិក្កាសម្មុតឹ ទាតុំ ។

(២៥០) ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តេន គិលានេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ គិលានោ ន សក្កោមិ វិនា សិក្កាយ បត្តំ បរិហរិតុំ សោហំ ភន្តេ សង្ឃំ សិក្កាសម្មុតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សង្ឃឲ្យទណ្ឌសម្មតិដល់ភិក្ខុឈ្មោះនេះ ។ ការឲ្យទណ្ឌសម្មតិ ដល់ភិក្ខុឈ្មោះនេះ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវពោលឡើង ។ សង្ឃបានឲ្យទណ្ឌសម្មតិ ដល់ភិក្ខុឈ្មោះនេះហើយ ការឲ្យនោះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(២៤៩) សម័យនោះឯង ភិក្ខុ ១ រូបមានជម្ងឺ តែវៀរលែងសង្រែកចេញ ក៏មិនអាចនឹងនាំយកបាត្រទៅបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសង្ឃឲ្យសិក្កាសម្មតិដល់ភិក្ខុមានជម្ងឺ ។

(២៥០) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ភិក្ខុមានជម្ងឺនោះត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងថ្វាយបង្គំបាទារបស់ភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីពោលពាក្យយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំមានជម្ងឺ បើវៀរលែងសង្រែកចេញ ក៏មិនអាចនាំយកបាត្រទៅបាន បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវនេះ) ខ្ញុំមកសូមសិក្កាសម្មតិនឹងសង្ឃ ។ ភិក្ខុនោះគប្បីសូមជាគំរប់ពីរដងផង គប្បីសូមជាគំរប់បីដងផង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកេ សិក្កាសម្មុតិយា ទានំ

(៤៨១) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ វិនា សិក្កាយ បត្តំ បរិហរិតុំ សោ សង្ឃំ សិក្កាសម្មុតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ សិក្កាសម្មុតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ វិនា សិក្កាយ បត្តំ បរិហរិតុំ សោ សង្ឃំ សិក្កាសម្មុតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ សិក្កាសម្មុតឹ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សិក្កាសម្មុតិយា ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ សិក្កាសម្មុតិ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(២៥១) ភិក្ខុដែលឈ្លាសប្រតិពល គប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះមានជម្ងឺ តែវៀរលែងសាង្រែកចេញ ក៏មិនអាចនាំយកបាត្រទៅបាន (ឥឡូវនេះ) ភិក្ខុនោះមកសូមសិក្កាសម្មតិនឹងសង្ឃ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យសិក្កាសម្មតិដល់ភិក្ខុឈ្មោះនេះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះមានជម្ងឺ តែវៀរលែងសាង្រែកចេញ ក៏មិនអាចនាំយកបាត្រទៅបាន (ឥឡូវនេះ) ភិក្ខុនោះមកសូមសិក្កាសម្មតិនឹងសង្ឃ ។ សង្ឃក៏ឲ្យសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះ ។ ការឲ្យសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវពោលឡើង ។ សង្ឃបានឲ្យសិក្កាសម្មតិដល់ភិក្ខុឈ្មោះនេះហើយ ការឲ្យនោះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤៩២) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ន សក្កោតិ វិនា ទណ្ឌេន អាហិណ្ឌិតុំ ន សក្កោតិ វិនា សិក្កាយ បត្តំ បរិហរិតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ ទណ្ឌសិក្កាសម្មុតឹ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តេន គិលានេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ គិលានោ ន សក្កោមិ វិនា ទណ្ឌេន អាហិណ្ឌិតុំ ន សក្កោមិ វិនា សិក្កាយ បត្តំ បរិហរិតុំ សោហំ ភន្តេ សង្ឃំ ទណ្ឌសិក្កាសម្មុតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។

(៤៩៣) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ វិនា ទណ្ឌេន អាហិណ្ឌិតុំ ន សក្កោតិ វិនា សិក្កាយ បត្តំ បរិហរិតុំ សោ សង្ឃំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤៩២) សម័យនោះឯង ភិក្ខុ ១ រូបមានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមក បើវៀរលែងសាក្រែកចេញ ក៏មិនអាចនឹងនាំយកបាត្រទៅបាន ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យទណ្ឌសិក្កាសម្មតិ ដល់ភិក្ខុមានជម្ងឺ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ភិក្ខុដែលមានជម្ងឺនោះត្រូវចូលទៅកេសង្ឃ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីពោលពាក្យយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំមានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមក តែវៀរលែងសាក្រែកចេញ ក៏មិនអាចនឹងនាំយកបាត្រ ទៅបាន បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំមកសូមទណ្ឌសិក្កាសម្មតិនឹងសង្ឃ ។ ភិក្ខុនោះគប្បីសូមជាគំរប់ពីរដងផង គប្បីសូមជាគំរប់បីដងផង ។

(៤៩៣) ភិក្ខុដែលឈ្លាសប្រតិពល គប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះមានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមក វៀរលែងតែសាក្រែកចេញ ក៏មិនអាចនឹងនាំយកបាត្រទៅបាន (ឥឡូវនេះ) ភិក្ខុនោះមក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទណ្ឌសិក្កាសម្មុតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ ទណ្ឌសិក្កាសម្មុតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ វិនា ទណ្ឌេន អាហិណ្ឌិតុំ ន សក្កោតិ វិនា សិក្កាយ បត្តំ បរិហរិតុំ សោ សង្ឃំ ទណ្ឌសិក្កាសម្មុតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ ទណ្ឌសិក្កាសម្មុតឹ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ទណ្ឌសិក្កាសម្មុតិយា ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ ទណ្ឌសិក្កាសម្មុតិ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(២៥៤) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ រោមដ្ឋកោ អហោសិ(១) ។ សោ រោមដ្ឋិត្វា រោមដ្ឋិត្វា(២) អជ្ឈោហរតិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ វិកាលាយំ(៣) ភិក្ខុ ភោជនំ ភុញ្ជតីតិ ។

---

១ ឱ. ម. រោមន្ថកោ ហោតិ ។ ២ ឱ. ម. រោមន្ថិត្វា រោមន្ថិត្វា ។ ៣ ឱ. វិកាលេ យំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សូមទណ្ឌសិក្ខាសម្មតិនឹងសង្ឃ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យទណ្ឌសិក្ខាសម្មតិដល់ភិក្ខុឈ្មោះនេះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះមានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមក វៀរលែងសាម្រែកចេញក៏មិនអាចនឹងនាំយកបាត្រទៅបាន (ដូច្នេះ) ភិក្ខុនោះមកសូមទណ្ឌសិក្ខា-សម្មតិនឹងសង្ឃ ។ សង្ឃឲ្យទណ្ឌសិក្ខាសម្មតិដល់ភិក្ខុឈ្មោះនេះ ។ ការឲ្យទណ្ឌសិក្ខាសម្មតិដល់ភិក្ខុឈ្មោះនេះ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវពោលឡើង ។ សង្ឃបានឲ្យទណ្ឌ-សិក្ខាសម្មតិដល់ភិក្ខុឈ្មោះនេះហើយ ការឲ្យនោះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(៦៥៤) សម័យនោះឯង ភិក្ខុ ១ រូបទំពាអៀងជាប្រក្រតី ។ ភិក្ខុនោះទំពាអៀង ៗ ហើយលេបចូលទៅ ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនេះឆាន់ភោជនក្នុងវេលាវិកាល ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឯសោ ភិក្ខវេ ភិក្ខុ អចិរំ គោយោនិយា ចុតោ អនុជានាមិ ភិក្ខវេ រោមន្ថកស្ស រោមន្ថំ ន ច ភិក្ខវេ ពហិមុខទ្វារំ នីហរិត្វា អជ្ឈោហរិតព្វំ យោ អជ្ឈោហរេយ្យ យថាធម្មោ ការេតព្វោតិ ។

(៤៤៨) តេន ខោ បន សមយេន អញ្ញតរស្ស បូគស្ស សង្ឃភត្តំ ហោតិ ។ ភត្តគ្គេ ពហូ សិត្ថានិ បរិកិរីសុ(១) ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ឱទនេ ទិយ្យមានេ ន សក្កច្ចំ បដិគ្គហេស្សន្តិ ឯកមេកំ សិត្ថំ កម្មសតេន និដ្ឋាយតីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថ ខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ អនុជានាមិ ភិក្ខវេ យំ ទិយ្យមានំ បតតិ តំ សាមំ គហេត្វា បរិភុញ្ជិតុំ តំ តស្ស ហោតុ(២) បរិច្ចត្តំ តំ ភិក្ខវេ ទាយកេហីតិ ។

---

១ ឧ. ម. បកិរិយឹសុ ។ ២ ឥទំ បទត្តយំ ឧ. ម. បោត្ថកេសុ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះទើបតែបួសមកអំពីកំណើតនៃគោ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទំពារៀនដល់ភិក្ខុអ្នកទំពារៀនជាប្រក្រតី ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំខ្ជាក់អាហារចេញមកខាងក្រៅទ្វារមាត់ហើយលេបចូលទៅវិញ បើភិក្ខុណាលេបចូលទៅវិញ វិនយធរគប្បីឲ្យភិក្ខុនោះធ្វើតាមធម៌ (សំដែងអាបត្តិចេញ) ។

(២៨៥) សម័យនោះឯង មានសង្ឃភត្តរបស់ប្រជុំជន ១ ពួក ។ គ្រាប់បាយដ៏ច្រើនក៏ជ្រុសរោយរាយក្នុងរោងភត្ត ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្តិយ៍ កាលបើគេកំពុងប្រគេនបាយ មិនសមបើមិនទទួលដោយសេចក្តីគោរពសោះ ធម្មតាគ្រាប់បាយមួយគ្រាប់ៗរមែងញុំាងការហ៊ើច្រើនឲ្យសម្រេចបាន ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ។ ទើបភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រាប់បាយណា ដែលគេកំពុងឲ្យហើយធ្លាក់ចុះ តថាគតអនុញ្ញាតឲ្យភិក្ខុរើសគ្រាប់បាយនោះខ្លួនឯង ហើយឆាន់ចុះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាគ្រាប់បាយនោះ ទាយកគេលះ គឺប្រគេនរួចស្រេចហើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



[២៩៦] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ទីឃេហិ នខេហិ បិណ្ឌាយ ចរតិ ។ អញ្ញតរា ឥត្ថី បស្សិត្វា តំ ភិក្ខុំ ឯតទវោច ឯហិ ភន្តេ មេថុនំ ធម្មំ បដិសេវាតិ ។ អលំ ភគិនិ នេតំ កប្បតីតិ ។ សចេ ខោ ត្វំ ភន្តេ ន បដិសេវិស្សសិ ឥទានាហំ អត្តនោ នខេហិ គត្តានិ វិលិខិត្វា កុប្បំ ករិស្សាមិ អយំ មំ ភិក្ខុ វិប្បការេតីតិ ។ បជានាហិ(១) ត្វំ ភគិនីតិ ។ អថ ខោ សា ឥត្ថី អត្តនោ នខេហិ គត្តានិ វិលិខិត្វា កុប្បំ អកាសិ អយំ មំ ភិក្ខុ វិប្បការេតីតិ ។ មនុស្សា ឧបធាវិត្វា តំ ភិក្ខុំ អគ្គហេសុំ ។ អទ្ទសំសុ ខោ តេ មនុស្សា តស្សា ឥត្ថិយា នខេ ឆវិម្បិ លោហិតម្បិ ទិស្វាន ឥមិស្សាយេវ ឥត្ថិយា ឥទំ កម្មំ អការកោ ភិក្ខូតិ តំ ភិក្ខុំ មុញ្ចិំសុ ។ អថ ខោ សោ ភិក្ខុ អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ កឹ បន ត្វំ អាវុសោ ទីឃេ នខេ ធារេសីតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ

១ ឱ. ម. បជានាសិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ខុទ្ទកវត្ថុក្ខន្ធកៈ រឿងភិក្ខុមួយរូប និងរឿងស្រីម្នាក់

(២៥៦) សម័យនោះឯង ភិក្ខុ ១ រូប មានក្រចកវែងដើរទៅបិណ្ឌបាត ។ ស្រីម្នាក់ឃើញហើយនិយាយនឹងភិក្ខុនោះដូច្នេះថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និមន្តមកសេពមេថុនធម្ម (នឹងខ្ញុំចុះ) ។ ភិក្ខុនោះឃាត់ថា នែប្អូនស្រី កុំឡើយ ការនុ៎ះមិនគួរទេ ។ ស្រីនោះនិយាយទៀតថា បពិត្រលោកដ៏ចំរើន បើលោកម្ចាស់មិនសេពទេ ខ្ញុំនឹងខ្វារក្រចៅខ្លួនដោយក្រចករបស់ខ្លួន ហើយនឹងស្រែកឥឡូវនេះថា ភិក្ខុនេះធ្វើវិប្បការនឹងខ្ញុំ ។ ភិក្ខុនោះក៏បណ្តោយថា ប្អូនស្រី នាងឯងចូរដឹងចុះ ។ ទើបស្រីនោះខ្វារក្រចៅកន្លែងកាយដោយក្រចករបស់ខ្លួន ហើយស្រែកថា ភិក្ខុនេះធ្វើវិប្បការនឹងខ្ញុំ ។ មនុស្សទាំងឡាយក៏ស្ទុះទៅចាប់ភិក្ខុនោះ ។ មនុស្សទាំងអម្បាលនោះ បានឃើញស្បែកនិងឈាមក្នុងក្រចកស្រីនោះ លុះឃើញហើយក៏ជឿជាក់ថាភិក្ខុនេះមិនបានធ្វើកម្មនេះដល់ស្រីនេះទេ ហើយក៏លែងភិក្ខុនោះទៅ ។ ទើបភិក្ខុនោះទៅកាន់អារាមប្រាប់ដំណើរនុ៎ះដល់ភិក្ខុផងគ្នា ។ ភិក្ខុទាំងឡាយសួរថា ម្នាលលោកមានអាយុ ចុះលោកទុកក្រចកវែងឬ ។ ភិក្ខុនោះប្រាប់ថា អើករុណា ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនោះពោលទោស តិះដៀល បន្ទោសថា ភិក្ខុមិនសមបើ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទីឃេ នខេ ធារេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ទីឃា នខា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៤៧) តេន ខោ បន សមយេន ភិក្ខូ នខេនបិ នខំ ឆិន្ទន្តិ ។ មុខេនបិ នខំ ឆិន្ទន្តិ ។ កុឌ្ឌេបិ នខំ ឃំសេន្តិ ។ អង្គុលិយោ ទុក្ខា ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ នខច្ឆេទនន្តិ ។ សលោហិតំ នខំ ឆិន្ទន្តិ ។ អង្គុលិយោ ទុក្ខា ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ មំសប្បមាណេន នខំ ឆិន្ទិតុន្តិ ។

(២៤៨) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ វីសតិមដ្ឋំ[១] ការាបេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ វីសតិមដ្ឋំ ការាបេតព្វំ យោ ការាបេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ មលមត្តំ អបកឌ្ឍិតុន្តិ ។

---
១ ឱ. វីសតិមដ្ឋំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទីងទុកក្រចកវែងសោះ ។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុក ក្រចកវែងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ។

(៤៩៧) សម័យនោះឯង ភិក្ខុទាំងឡាយកាត់ក្រចកដោយក្រចកខ្លះ ។ កាត់ក្រចកដោយមាត់ខ្លះ ។ ត្រដុសក្រចកនឹងជញ្ជាំងខ្លះ ។ ម្រាមដៃទាំងឡាយក៏ឈឺចាប់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកាត់ក្រចក ។ ភិក្ខុទាំងនោះកាត់ក្រចកត្រាតែដល់ឈាម ។ ម្រាមដៃទាំងឡាយក៏ឈឺចាប់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាត់ក្រចកត្រឹមនឹងសាច់ ។

(៤៩៨) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យគេខាត់ក្រចកទាំង ២០ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេខាត់ក្រចកទាំង ២០ ទេ ភិក្ខុណាឲ្យគេខាត់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុគ្រាន់តែជម្រះក្អែលចំណោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[២៥៩] តេន ខោ បន សមយេន ភិក្ខូនំ កេសា ទីឃា ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឧស្សហន្តិ បន ភិក្ខវេ ភិក្ខូ អញ្ញមញ្ញំ កេសេ ឱហារេតុន្តិ ។ ឧស្សហន្តិ ភគវាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ។បេ។ ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ខុរំ ខុរសិលំ ខុរសិបាដិកំ នមតកំ សព្វំ ខុរភណ្ឌន្តិ ។

(២៦០) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ មស្សុំ កប្បាបេន្តិ ។ មស្សុំ វឌ្ឍាបេន្តិ ។ គោលោមិកំ ការាបេន្តិ ។ ចតុរស្សកំ ការាបេន្តិ ។ បរិមុខំ ការាបេន្តិ ។ អឌ្ឍុរុកំ ការាបេន្តិ ។ ទាឋិកំ ឋបេន្តិ ។ សម្ពាធេ លោមំ សំហរាបេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។បេ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(២៥៩) សម័យនោះឯង ភិក្ខុទាំងឡាយមានសក់វែង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយអាចនឹងកោរសក់គ្នាទៅវិញទៅមកបានឬទេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ អាចនឹងកោរបាន ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ប្រជុំភិក្ខុសង្ឃ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាំបិតកោរ ថ្មសំលៀងកាំបិតកោរ ស្រោមកាំបិតកោរ គ្រឿងស្មាប់ដែលគេធ្វើដោយរោមចៀម និងគ្រឿងប្រដាប់កាំបិតកោរទាំងពួង ។

(២៦០) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យគេកាត់ពុកមាត់ (ដោយកន្ត្រៃខ្លះ) ។ ទុកពុកមាត់ (ឲ្យវែង)ខ្លះ ។ ឲ្យគេធ្វើពុកចង្កាឲ្យវែងដូចជាពុកចង្កាពពែខ្លះ ។ ឲ្យគេធ្វើពុកមាត់ជា ៤ ជ្រុងខ្លះ ។ ប្រមូលដួររោមត្រង់ទ្រូងខ្លះ ។ ទុកដួររោមត្រង់ពោះខ្លះ ។ ទុកពុកមាត់ឲ្យដូចជាចង្កូមខ្លះ ។ ឲ្យគេដករោមក្នុងទីចង្កេះខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀលបន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ន ភិក្ខវេ មស្សុ កប្បាបេតព្វំ ន មស្សុ វឌ្ឍាបេតព្វំ ន គោលោមិកំ ការាបេតព្វំ ន ចតុរស្សកំ ការាបេតព្វំ ន បរិមុខំ ការាបេតព្វំ ន អឌ្ឍទុកំ ការាបេតព្វំ ន ទាឋិកា ឋបេតព្វា ន សម្ពាធេ លោមំ សំហរាបេតព្វំ យោ សំហរាបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៦១) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ សម្ពាធេ វណោ ហោតិ ។ ភេសជ្ជំ ន សណ្ឋតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា សម្ពាធេ លោមំ សំហរាបេតុន្តិ ។

(២៦២) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កត្តរិកាយ កេសេ ឆេទាបេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ប ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ កត្តរិកាយ កេសា ឆេទាបេតព្វា យោ ឆេទាបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេកាត់ពុកមាត់ (ដោយកន្ត្រៃ) មិនត្រូវទុកពុកមាត់ឲ្យវែង មិនត្រូវឲ្យគេធ្វើពុកចង្កាឲ្យវែង (ដូចជាពុកចង្កាពពែ) មិនត្រូវឲ្យគេធ្វើពុកមាត់ ៤ ជ្រុង មិនត្រូវប្រមូលដុះរោមត្រង់ទ្រូង មិនត្រូវទុកដុះរោមត្រង់ពោះ មិនត្រូវទុកពុកមាត់ឲ្យដូចជាចង្កូម មិនត្រូវឲ្យគេដករោមក្នុងទីបង្កៀត ភិក្ខុណាឲ្យគេដក ត្រូវអាបត្តិទុក្កដ ។

(៤៦១) សម័យនោះឯង ភិក្ខុមួយរូបកើតដំបៅក្នុងទីបង្កៀត ។ លាបថ្នាំមិនជាប់ ។បេ។ ភិក្ខុទាំងនោះក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មានអាពាធជាហេតុ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យគេដករោមក្នុងទីបង្កៀតបាន ។

(៤៦២) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើគេឲ្យកាត់សក់ដោយកន្ត្រៃ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។បេ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេកាត់សក់ដោយកន្ត្រៃទេ ។ ភិក្ខុណាឲ្យគេកាត ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៦៣) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ សីសេ វណោ ហោតិ ។ ន សក្កោតិ ខុរេន កេសេ ឆេទាបេតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា កត្តរិកាយ កេសេ ឆេទាបេតុន្តិ ។

(២៦៤) តេន ខោ បន សមយេន ភិក្ខូ ទីឃានិ នាសិកាលោមានិ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ បិសាចិល្លិកាតិ ។បេ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ទីឃំ នាសិកាលោមំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៦៥) តេន ខោ បន សមយេន ភិក្ខូ សក្ខរិកាយបិ មធុសិត្ថកេនបិ នាសិកាលោមំ គាហាបេន្តិ ។ នាសិកា ទុក្ខា ហោន្តិ ។បេ។ អនុជានាមិ ភិក្ខវេ សណ្ឌាសន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៦៣) សម័យនោះឯង ភិក្ខុមួយរូបកើតដំបៅត្រង់ក្បាល ។ ភិក្ខុនោះមិនអាចនឹងកោរសក់ដោយកាំបិតកោរបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មានអាពាធជាហេតុ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យគេកាត់សក់ដោយកន្ត្រៃបាន ។

(២៦៤) សម័យនោះឯង ភិក្ខុទាំងឡាយទុករោមច្រមុះវែង ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពិសាច ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុករោមច្រមុះឲ្យវែងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ។

(២៦៥) សម័យនោះឯង ភិក្ខុទាំងឡាយឲ្យគេដករោមច្រមុះ ដោយដុំក្រួសខ្លះ ដោយក្រមួនឃ្មុំខ្លះ ។ ច្រមុះក៏ឈឺចាប់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសណ្ឌាស ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៦៦) តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ បលិតំ គាហាបេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ បលិតំ គាហាបេតព្វំ យោ គាហាបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៦៧) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ កណ្ណគូថកេហិ កណ្ណា ថកិតា ហោន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ កណ្ណមលហរណិន្តិ ។

(២៦៨) តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឧច្ចាវចា កណ្ណមលហរណិយោ ធារេន្តិ សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឧច្ចាវចា កណ្ណមលហរណិយោ ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៦៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ឲ្យគេដកសក់ស្កូវ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេដកសក់ស្កូវទេ ភិក្ខុណាឲ្យគេដក ត្រូវអាបត្តិទុក្កដ ។

(២៦៧) សម័យនោះឯង ភិក្ខុមួយរូបមានត្រចៀកធ្ងន់ ដោយអាចម៍ត្រចៀក ។ បេ ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត បន្តៀលអាចម៍ត្រចៀក ។

(២៦៨) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់បន្តៀលអាចម៍ត្រចៀកខ្ពស់ទីងទាប (មិនពបសា) គឺធ្វើដោយមាសខ្លះ ដោយប្រាក់ខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បន្តៀលអាចម៍ត្រចៀកខ្ពស់ទីងទាប (មិនពបសា) ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



កណ្ណមលហរណិយោ(១) អដ្ឋិមយំ ទន្តមយំ វិសាណមយំ នឡមយំ វេឡុមយំ កដ្ឋមយំ ជតុមយំ ផលមយំ លោហមយំ សង្ខនាភិមយន្តិ ។

(២៦៩) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ពហុំ លោហភណ្ឌំ កំសភណ្ឌំ សន្និចយំ ករោន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យ-បុត្តិយា ពហុំ លោហភណ្ឌំ កំសភណ្ឌំ សន្និចយំ ករិស្សន្តិ សេយ្យថាបិ កំសបត្ថរិកាតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ពហុំ លោហភណ្ឌំ កំសភណ្ឌំ សន្និចយោ កាតព្វោ យោ ករេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៧០) តេន ខោ បន សមយេន ភិក្ខូ អញ្ជនិម្បិ អញ្ជនិសលាកម្បិ កណ្ណមលហរណិម្បិ ពន្ធនមត្តំ កុក្កុច្ចាយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ អញ្ជនឹ អញ្ជនិសលាកំ កណ្ណម-លហរណឹ ពន្ធនមត្តន្តិ ។

---

១ ខ. ម. បោត្ថកេសុ អយំ កណ្ណមលហរណិយោតិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តថាគតអនុញ្ញាតបន្ទៀលអាចម៍ត្រចៀក ដែលធ្វើដោយឆ្អឹង ភ្លុក ស្នែង បបុស ឫស្សី ឈើ ជ័រឈើ ផ្លែឈើ លោហជាតិ គួបស័ង្ខ ។

(២៦៩) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសន្សំទុកដាក់គ្រឿងលោហជាតិ នឹងសំរិទ្ធជាច្រើន ។ មនុស្សទាំងឡាយដើរទៅកាន់វិហារ-ចារិកឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកសមណសក្យបុត្តិយ៍ សន្សំទុកដាក់គ្រឿងលោហជាតិនឹងគ្រឿងសំរិទ្ធដូចពួកអ្នកជួញសំរិទ្ធសោះ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសន្សំទុកដាក់គ្រឿងលោហជាតិនឹងសំរិទ្ធទេ ភិក្ខុណាសន្សំទុកដាក់ ត្រូវអាបត្តិទុក្កដ ។

(២៧០) សម័យនោះឯង ពួកភិក្ខុរន្ទៀសនឹងកិច្ចសព្វបើគ្រាន់តែបង់បំពង់ថ្នាំភ្នែកខ្លះ (គឺបង់ចន្ទុំ) ចន្ទុះបំពង់ថ្នាំភ្នែកខ្លះ បន្ទៀលអាចម៍ត្រចៀកខ្លះ ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្រឹមតែការបង់បំពង់ថ្នាំភ្នែក ចន្ទុះបំពង់ថ្នាំភ្នែក បន្ទៀលអាចម៍ត្រចៀកបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៧១) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សង្ឃាដិបល្លត្ថិកាយ និសីទន្តិ ។ សង្ឃាដិយា បត្តា លុជ្ជន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ សង្ឃាដិបល្លត្ថិកាយ និសីទិតព្វំ យោ និសីទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៧២) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តស្ស វិនា អាយោគា(១) ន ផាសុ ហោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ អាយោគន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កថំ នុ ខោ អាយោគោ វេធិតព្វោតិ(២) ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ តន្តកំ វេមកំ វដំ សលាកំ សព្វំ តន្តភណ្ឌកន្តិ ។

(២៧៣) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អកាយពន្ធនោ គាមំ បិណ្ឌាយ បាវិសិ ។ តស្ស រថិយាយ អន្តរវាសកោ បភស្សិត្ថ ។

---

១ ឱ. ម. អាយោគេន ។ ២ ឱ. ប. កាតព្វោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៧១) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុអង្គុយត្រដោកក្បាលជង្គង់ទាំងសង្ឃាដិ ។ ផត់សង្ឃាដិក៏ទក់ខូចអស់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវអង្គុយត្រដោកក្បាលជង្គង់ទាំងសង្ឃាដិទេ ភិក្ខុណាអង្គុយ ត្រូវអាបត្តិទុក្កដ ។

(២៧២) សម័យនោះឯង ភិក្ខុ ១ រូបមានជម្ងឺ ។ ភិក្ខុនោះវៀរលែងសំពត់អាយោគចេញ ក៏មិនបានសេចក្ដីសប្បាយកាយ ។ បេ ។ ទើបពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់អាយោគ ។ ទើបភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះយ៉ាងនេះថា សំពត់អាយោគយើងពល់ត្នា គប្បីធ្វើដូចម្ដេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្តាម្បូរ ចេញឈើ ខ្សែសម្រាប់ត បន្ទាល់ ទីនប្រដាប់តម្បាញទាំងអស់ ។

(២៧៣) សម័យនោះឯង ភិក្ខុមួយរូបមិនមានកាយពន្ធ គឺវត្ថពន្ធចង្កេះ ចូលទៅបិណ្ឌបាតក្នុងស្រុក ។ ស្បង់របស់ភិក្ខុនោះរបូតចុះក្នុងច្រកផ្លូវ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មនុស្សា បស្សិត្វា(១) ឧក្កុដ្ឋិមកំសុ ។ សោ ភិក្ខុ មង្កុ អហោសិ ។ អថខោ សោ ភិក្ខុ អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ អកាយពន្ធនេន គាមោ បវិសិតព្វោ ។ យោ បវិសេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ កាយពន្ធនន្តិ ។

(២៧៤) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចាវចានិ កាយពន្ធនានិ ធារេន្តិ កលាពុកំ ទេឌ្ឌុភកំ មុរជំ មទ្ទវីណំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឧច្ចាវចានិ កាយពន្ធនានិ ធារេតព្វានិ កលាពុកំ ទេឌ្ឌុភកំ

---

១ ឱ. ម. ហេដ្ឋាក្រេសុ បស្សិត្វាតិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មនុស្សទាំងឡាយឃើញហើយក៏ស្រែកហៅឡើង ។ ភិក្ខុនោះមានសេចក្តីអៀនខ្មាស ។ ទើបភិក្ខុនោះទៅកាន់អារាមប្រាប់ដំណើរនុ៎ះ ដល់ពួកភិក្ខុផងគ្នា ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានកាយពន្ធ[១] មិនត្រូវចូលទៅកាន់ស្រុកទេ ភិក្ខុណាចូលទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាយពន្ធ ។

(៤៧៤) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់កាយពន្ធខ្លះ ទីងទាប (មិនរាបស្មា) គឺកាយពន្ធមានខ្សែច្រើន កាយពន្ធមានសណ្ឋានដូចក្បាលពស់ទឹក កាយពន្ធមានសណ្ឋានដូចខ្សែតសំគោរ ទីងកាយពន្ធមានសណ្ឋានដូចសង្វារ ។ មនុស្សទាំងឡាយពោលទោស តិះដៀលបន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់កាយពន្ធខ្លះ ទីងទាប (មិនរាបស្មា) គឺកាយពន្ធមានខ្សែច្រើន កាយពន្ធមានសណ្ឋាន

---

១ ក្នុងអដ្ឋកថា ពន្យល់ថា បើភ្លេចមិនបានក្រវាត់កាយពន្ធដើរចេញ (ពីវត្ត) ទៅ លុះនឹកឃើញត្រឹមណា ត្រូវក្រវាត់ត្រឹមណោះ (ទើបរួចទោស) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មុរជ្ជិំ មទ្ទវិណំ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ទ្វេ កាយពន្ធនានិ បដ្ដិកំ សូករន្តកន្តិ ។បេ។ កាយពន្ធនស្ស ទសា ជីរន្តិ ។បេ។ អនុជានាមិ ភិក្ខវេ មុរជ្ជិំ មទ្ទវិណន្តិ ។ កាយពន្ធនស្ស អន្តា ជីរន្តិ ។បេ។ អនុជានាមិ ភិក្ខវេ សោភកំ[1] គុណកន្តិ[2] ។ កាយពន្ធនស្ស បវនន្តា ជីរន្តិ ។បេ។ អនុជានាមិ ភិក្ខវេ វិធន្តិ[3] ។

(៦៧៤) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចាវចេ វិធេ ធារេន្តិ សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។បេ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ ឧច្ចាវចា វិធា ធារេតព្វា យោ ធារេយ្យ

---

១ ឱ. ម. សោភណំ ។ ២ ឱ. ម. គុណកន្តិ ។ ៣ ឱ. វិធន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដូចក្បាលពស់ទឹក កាយពន្ធដូចខ្សែរឹតបំពោរ ទើងកាយពន្ធមានសណ្ឋានដូចសង្វារទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាយពន្ធពីរយ៉ាង គឺកាយពន្ធធ្វើជាផ្ទាំង ១ កាយពន្ធមានសណ្ឋានដូចពោះវៀនជ្រូក ១ ។ បេ ។ លុះដល់កាយពន្ធមានជាយរេច ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជាយកាយពន្ធ មានសណ្ឋានដូចខ្សែរឹតសំពោរ ទើងជាយកាយពន្ធមានសណ្ឋានដូចសង្វារ ។ (ក្រោយមកទៀត) រិមកាយពន្ធក៏រេច ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដេរលិន ទើងដេរឡើមានអាការដូចក្តែផ្សួយ ។ (យូរមកទៀត) ចុងអន្ទាក់កាយពន្ធក៏រេច ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រវិលកាយពន្ធ ។

(២៧៥) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់គ្រវិលកាយ-ពន្ធខ្ពស់ទើងទាប (មិនពបសា) គឺធ្វើដោយមាសខ្លះ ប្រាក់ខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់គ្រវិលកាយពន្ធខ្ពស់ទើងទាបទេ ភិក្ខុណាប្រើប្រាស់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ វិធេ(១) អដ្ឋិមយំ ទន្តមយំ វិសាណមយំ នឡមយំ វេឡុមយំ ។ បេ ។ សង្ខនាភិមយំ សុត្តមយន្តិ ។

(២៧៦) តេន ខោ បន សមយេន អាយស្មា អានន្ទោ លហុកា សង្ឃាដិយោ បារុបិត្វា គាមំ បិណ្ឌាយ បាវិសិ ។ តស្ស វាតមណ្ឌលិកាយ សង្ឃាដិយោ ឧក្ខិបិយឹសុ ។ អថខោ អាយស្មា អានន្ទោ អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ គណ្ឋិកំ បាសកន្តិ ។

(២៧៧) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចាវចា គណ្ឋិកាយោ ធារេន្តិ សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឧច្ចាវចា គណ្ឋិកា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស

១ ឱ. ម. បោត្ថកេសុ វិធេតិ សទ្ទោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្រវិលកាយពន្ធ ដែលធ្វើដោយឆ្អឹង ដោយភ្លុក ដោយស្នែង ដោយបបុះ ដោយឫស្សី ។ បេ ។ ធ្វើដោយគូថសង្ខ ធ្វើដោយសូត្រឬអំបោះ ។

[២៧៦] សម័យនោះឯង ព្រះអានន្ទមានអាយុ ឃុំសង្ឃាដីនឹងឧត្តរាសង្គៈដែលស្រាល ហើយចូលទៅបិណ្ឌបាតក្នុងស្រុក ។ ខ្យល់កំបុតត្បៀងក៏ប៉ើងសង្ឃាដីនឹងឧត្តរាសង្គៈរបស់ព្រះអានន្ទនោះ ។ លំដាប់នោះ ព្រះអានន្ទមានអាយុទៅកាន់អារាមហើយប្រាប់រឿងនុ៎ះ ដល់ពួកភិក្ខុផងគ្នា ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឡៀវនឹងអន្ទាក់ឡៀវ ។

[២៧៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ឡៀវខ្ពស់នឹងទាប គឺធ្វើដោយមាសខ្លះ ប្រាក់ខ្លះ ។ ពួកមនុស្សពោលទោសតិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឡៀវខ្ពស់នឹងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ គណ្ឋិកំ(១) អដ្ឋិមយំ ទន្តមយំ វិសាណមយំ នឡមយំ វេឡុមយំ កដ្ឋមយំ ជតុមយំ ផលមយំ លោហមយំ សង្ខនាភិមយំ សុត្តមយន្តិ។

(២៧៨) តេន ខោ បន សមយេន ភិក្ខូ គណ្ឋិកម្បិ បាសកម្បិ ចីវរេ អប្បេន្តិ។ ចីវរំ ជីរតិ។ ភគវតោ ឯតមត្ថំ អារោចេសុំ។ បេ។ អនុជានាមិ ភិក្ខវេ គណ្ឋិកផលកំ បាសកផលកន្តិ។ គណ្ឋិកផលកម្បិ បាសកផលកម្បិ អន្តេ អប្បេន្តិ។ កោណោ វិវរិយតិ។ ភគវតោ ឯតមត្ថំ អារោចេសុំ។ បេ។ អនុជានាមិ ភិក្ខវេ គណ្ឋិកផលកំ អន្តេ អប្បេតុំ បាសកផលកំ សត្តង្គុលំ វា អដ្ឋង្គុលំ វា ឱគាហេត្វា អប្បេតុន្តិ។

[២៧៩] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ គិហិនិវត្ថំ និវាសេន្តិ ហត្ថិសោណ្ឌកំ មច្ឆវាឡកំ

១ ឱ.ម. ពោត្ថកេសុ គណ្ឋិកន្តិ សព្វត្ថ ទិស្សតិ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឡៀវដែលធ្វើដោយឆ្អឹង ដោយភ្លុក ដោយស្នែង ដោយបបុះ ដោយឫស្សី ដោយឈើ ដោយជ័រឈើ ដោយផ្លែឈើ ដោយលោហជាតិ ដោយគុចស័ង្ខ ដោយសូត្រប្អំអំបោះ ។

(២៧៨) សម័យនោះឯង ពួកភិក្ខុដេរភ្ជាប់ឡៀវនឹងអន្ទាក់ក្នុងផ្ទៃចីវរ ។ ចីវរក៏គ្រាំគ្រា ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ឡៀវ នឹងទ្រនាប់អន្ទាក់ឡៀវ ។ ពួកភិក្ខុទាំងនោះដេរភ្ជាប់ទ្រនាប់ឡៀវនឹងទ្រនាប់អន្ទាក់ឡៀវក្នុងទីបំផុត ( ចីវរ ) ។ មុំចីវរក៏របើក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដេរភ្ជាប់ទ្រនាប់ឡៀវក្នុងទីបំផុតចីវរ ដេរទ្រនាប់អន្ទាក់បន្ទយចូលមកខាងក្នុង ត្រឹម ៧ ធ្នាប់ ឬ ៨ ធ្នាប់ ។

(២៧៩) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លៀកស្បង់ដូចសំលៀករបស់គ្រហស្ថ គឺស្លៀកឲ្យស្រុយមុខ ដូចប្រមោយដំរី ( ដូចសំលៀកមនុស្សស្រីក្នុងពោឡកប្រទេស ) ស្លៀកមានសណ្ឋានដូចកន្ទុយត្រី (១)

១ ស្លៀកលយជាយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ចតុក្កណ្ណកំ តាលវណ្ដកំ សតវល្លិកំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ គិហិនិវត្ថំ និវាសេតព្វំ ហត្ថិសោណ្ឌកំ មច្ឆវាឡកំ ចតុក្កណ្ណកំ តាលវណ្ដកំ សតវល្លិកំ យោ និវាសេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៤៨០) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ គិហិបារុតំ បារុបន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ គិហិបារុតំ បារុបិតព្វំ យោ បារុបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៤៨១) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សំវេល្លិយំ និវាសេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ រញ្ញោ មុណ្ឌវដ្ដីតិ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ស្លៀកឲ្យមានជ្រុង៤ (ស្លៀកបត់ខ្ទប់ជ្រុងស្បង់ទាំង៤ឲ្យប្រាកដ) ស្លៀកដោយអាការដូចដាងត្នោត (ស្លៀកសំឡុយសាជកឲ្យស្រួយចុះ) ស្លៀកអង្កាញ់ឲ្យមានផ្នត់ច្រើន ៗ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្លៀកស្បង់ ដូចសំលៀកគ្រហស្ថ គឺស្លៀកឲ្យស្រួយមុខដូចប្រមោយដំរី មានសណ្ឋានដូចកន្ទុយត្រី ស្លៀកឲ្យមានជ្រុង៤ ស្លៀកមានអាការដូចដាងត្នោត ស្លៀកអង្កាញ់ឲ្យមានផ្នត់ច្រើនទេ ភិក្ខុណាស្លៀក ត្រូវអាបត្តិទុក្កដ ។

(២៨០) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដណ្ដប់ដូចគ្រហស្ថ ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដណ្ដប់ដូចពួកគ្រហស្ថទេ ភិក្ខុណាដណ្ដប់ ត្រូវអាបត្តិទុក្កដ ។

(២៨១) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លៀកចងក្បិន ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកមនុស្សអ្នកនាំគ្រឿងបរិក្ខាររបស់ព្រះរាជា ដែលយានទៅកាន់ទីណាមួយ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ សំវេល្លិយំ និវាសេតព្វំ យោ និវាសេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៨២) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧភតោកាជំ ហរន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ រញ្ញោ មុណ្ឌវដ្ដីតិ ។បេ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ ឧភតោកាជំ ហរិតព្វំ យោ ហរេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ឯកតោកាជំ អន្តរកាជំ សីសភារំ ខន្ធភារំ កដិភារំ ឱលម្ពកន្តិ ។

(២៨៣) តេន ខោ បន សមយេន ភិក្ខូ ទន្តកដ្ឋំ ន ខាទន្តិ ។ មុខំ ទុគ្គន្ធំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ បញ្ចិមេ ភិក្ខវេ អាទីនវា ទន្តកដ្ឋស្ស អខាទនេ អចក្ខុស្សំ មុខំ ទុគ្គន្ធំ ហោតិ រសហរណិយោ ន វិសុជ្ឈន្តិ បិត្តំបិ សេម្ហំបិ ភត្តំ បរិយោនទ្ធតិ[១] ភត្តមស្ស ន ឆាទេតិ ឥមេ ខោ ភិក្ខវេ

---

១ ឱ ម. បរិយោនទ្ធតី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្លៀកបង់ក្បិនទេ ភិក្ខុណាស្លៀក ត្រូវអាបត្តិទុក្កដ ។

(៤៨២) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ នាំយកអម្រែកទាំងសងខាង គឺរែក ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកមនុស្សនាំគ្រឿងបរិក្ខាររបស់ព្រះរាជាដែលយាងទៅកាន់ទីណាមួយ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនាំអម្រែកទេ ភិក្ខុណានាំទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុពុន សែង ទូល លី កណ្តៀត ដៃយួរបាន ។

(៤៨៣) សម័យនោះឯង ពួកភិក្ខុមិនទំពារឈើស្ទន់ ។ មាត់ក៏មានក្លិនស្អុយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទោសក្នុងការមិនទំពារឈើស្ទន់នេះមាន ៥ ប្រការ គឺ នាំឲ្យថយកំលាំងភ្នែក ១ មាត់មានក្លិនស្អុយ ១ សរសៃសម្រាប់នាំរសមិនបរិសុទ្ធ ១ ប្រមាត់និងស្លេស្មរុំបិតបាយ ១ ភិក្ខុនោះឆាន់ចង្ហាន់មិនឆ្ងាញ់ ១ ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បញ្ច អាទីនវា ទន្តកដ្ឋស្ស អខាទនេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា ទន្តកដ្ឋស្ស ខាទនេ ចក្ខុស្សំ មុខំ ន ទុគ្គន្ធំ ហោតិ រសហរណិយោ វិសុជ្ឈន្តិ បិត្តំ សេម្ហំ ភត្តំ ន បរិយោនន្ធតិ ភត្តមស្ស ឆាទេតិ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា ទន្តកដ្ឋស្ស ខាទនេ ។ អនុជានាមិ ភិក្ខវេ ទន្តកដ្ឋន្តិ ។

(២៨២) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ទីឃានិ ទន្តកដ្ឋានិ ខាទន្តិ តេហេវ សាមណេរេ អាកោដេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ទីឃំ ទន្តកដ្ឋំ ខាទិតព្វំ យោ ខាទេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ អដ្ឋង្គុលបរមំ ទន្តកដ្ឋំ ន ច តេនេវ សាមណេរោ អាកោដេតព្វោ យោ អាកោដេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទោសក្នុងការមិនទំពាឈើស្ទន់មាន ៥ ប្រការនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការទំពាឈើស្ទន់នេះមាន ៥ ប្រការ គឺ ធ្វើឲ្យមានកំលាំងភ្នែក ១ មាត់មិនមានក្លិនស្អុយ ១ សរសៃសម្រាប់នាំរសបរិសុទ្ធ ១ ប្រមាត់និងស្លេស្មមិនរួបរិតបាយ ១ ភិក្ខុនោះឆ្ងាញ់បាយ ១ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការទំពាឈើស្ទន់មាន ៥ ប្រការនេះផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើស្ទន់ ។

(២៨៤) សម័យនោះ ពួកឆព្វគ្គិយភិក្ខុទំពាឈើស្ទន់វែងៗ ហើយគោះវាយសាមណេរដោយឈើស្ទន់នោះឯង ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទំពាឈើស្ទន់វែងៗទេ ភិក្ខុណាទំពា ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើស្ទន់យ៉ាងវែង ត្រឹម ៨ (១) ធ្នាប់ តែថាកុំគោះវាយសាមណេរដោយឈើស្ទន់នោះឡើយ ភិក្ខុណាគោះ ត្រូវអាបត្តិទុក្កដ ។

---

១ អដ្ឋកថា ពន្យល់ថា ឈើស្ទន់ប្រវែង ៨ ធ្នាប់មនុស្សប្រក្រតី ដីកាថា៨ធ្នាប់ជាងឈើ ។ ឈើស្ទន់ប្រវែង ៤ ធ្នាប់ មានន័យដូចគ្នា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៨៥) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ អតិមដ្ឋាហកំ(១) ទន្តកដ្ឋំ ខាទន្តស្ស កណ្ឋេ វិលគ្គំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ អតិមដ្ឋាហកំ ទន្តកដ្ឋំ ខាទិតព្វំ យោ ខាទេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ចតុរង្គុលំ បច្ឆិមំ(២) ទន្តកដ្ឋន្តិ ។

(២៨៦) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ទាយំ អាឡិម្បេន្តិ(៣) ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ ទវឌាហកាតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ទាយោ អាឡិម្បេតព្វោ យោ អាឡិម្បេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៨៧) តេន ខោ បន សមយេន វិហារា តិណច្ឆទនា ហោន្តិ ។ ទវឌាហេ ឌយ្ហមានេ វិហារា ឌយ្ហន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តិ បដគ្គឹ ទាតុំ បរិត្តំ កាតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ទវឌាហេ ឌយ្ហមានេ បដគ្គឹ ទាតុំ បរិត្តំ កាតុន្តិ ។

---

១ ឱ. ម. អតិមដាហកំ ។ ២ ឱ. ម. ចតុរង្គុលបច្ឆិមំ ។ ៣ ឱ. ម. អាលិម្បេន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៨៥) សម័យនោះឯង ភិក្ខុមួយរូបមានឈើស្ទន់វែងពេក ឈើស្ទន់ក៏របូតចូលទៅក្នុងបំពង់ក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទំពាឈើស្ទន់វែងពេកទេ ភិក្ខុណាទំពា ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើស្ទន់យ៉ាងខ្លីបំផុតត្រឹម ៤ ធ្នាប់ ។

(២៨៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដុតព្រៃ ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចអ្នកដុតព្រៃ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដុតព្រៃទេ ភិក្ខុណាដុតព្រៃ ត្រូវអាបត្តិទុក្កដ ។

(២៨៧) សម័យនោះឯង វិហារទាំងឡាយ ក៏ស្មុកស្មាញដោយស្មៅ ។ កាលដែលភ្លើងឆេះព្រៃ(រាលមក)ក៏ឆេះទាំងវិហារផង ។ ភិក្ខុទាំងឡាយរង្កៀសនឹងការដុតភ្លើងតទល់គ្នា ដើម្បីនឹងធ្វើសេចក្តីការពារ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភ្លើងព្រៃឆេះមក តថាគតអនុញ្ញាតឲ្យដុតភ្លើងតទល់ ដើម្បីនឹងធ្វើសេចក្តីការពារបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ខុទ្ទកវត្ថុក្ខន្ធកេ រុក្ខាភិរូហនា

(២៨៨) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ រុក្ខំ អភិរូហន្តិ រុក្ខា រុក្ខំ សង្កមន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ មក្កដាតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ រុក្ខោ អភិរូហិតព្វោ យោ អភិរូហេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៨៩) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ កោសលេសុ ជនបទេសុ សាវត្ថឹ គច្ឆន្តស្ស អន្តរាមគ្គេ ហត្ថី បរិយុដ្ឋាសិ ។ អថខោ សោ ភិក្ខុ រុក្ខមូលំ ឧបធាវិត្វា កុក្កុច្ចាយន្តោ រុក្ខំ នាភិរូហិ ។ សោ ហត្ថី អញ្ញេន អគមាសិ ។ អថខោ សោ ភិក្ខុ សាវត្ថឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សតិ ករណីយេ បោរិសិយំ រុក្ខំ អភិរូហិតុំ អាបទាសុ យាវទត្ថន្តិ ។

## ខុទ្ទកវត្ថុក្ខន្ធកៈ ការឡើងដើមឈើ

[២៨៨] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឡើងដើមឈើឆ្លងពីដើមឈើមួយទៅដើមឈើមួយ ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកស្វា ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឡើងដើមឈើទេ ភិក្ខុណាឡើង ត្រូវអាបត្តិទុក្កដ ។

[២៨៩] សម័យនោះឯង ភិក្ខុមួយរូបដើរសំដៅទៅក្រុងសាវត្ថីក្នុងកោសលជនបទ ក៏មានដំរីដេញព្រេចពាក់កណ្តាលផ្លូវ ។ ទើបភិក្ខុនោះស្ទុះចូលទៅរកដើមឈើក៏មានសេចក្តីរង្កៀស មិនហ៊ានឡើងដើមឈើ ។ ដំរីនោះក៏ហួសទៅទីដទៃ ។ គ្រានោះឯង ភិក្ខុនោះទៅដល់ក្រុងសាវត្ថី ប្រាប់ដំណើរនុ៎ះ ដល់ពួកភិក្ខុផងគ្នា ។ ពួកភិក្ខុក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើមានកិច្ចគួរធ្វើ តថាគតអនុញ្ញាតឲ្យឡើងដើមឈើបានត្រឹមមួយបុរស បើមានអន្តរាយ(១)ឲ្យឡើងកំណត់ត្រឹមណាក៏បាន ។

---

១ អដ្ឋកថា ពន្យល់ថា ភិក្ខុឃើញម្រឹគសាហាវជាដើមក្តី វង្វេងផ្លូវហើយប្រាថ្នានឹងរមិលមើលទិសក្តី ឃើញភ្លើងឆេះក្តី ឃើញទឹកជំនន់កំពុងហូរមកក្តី ហើយឡើងដើមឈើខ្ពស់ហួសប្រមាណ ព្រោះអន្តរាយនុ៎ះក៏បាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[២៩០] តេន ខោ បន សមយេន មេដ្ឋកោតុដ្ឋា(១) នាម ភិក្ខូ ទ្វេ ភាតិកា ហោន្តិ ព្រាហ្មណជាតិកា កល្យាណវាចា កល្យាណវាក្ករណា ។ តេ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឯតរហិ ភន្តេ ភិក្ខូ នានានាមា នានាគោត្តា នានាជច្ចា នានាកុលា បព្វជិតា តេ សកាយ និរុត្តិយា ពុទ្ធវចនំ ទូសេន្តិ ហន្ទ មយំ ភន្តេ ពុទ្ធវចនំ ឆន្ទសោ អារោបេមាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ឯវំ វក្ខថ ហន្ទ មយំ ភន្តេ ពុទ្ធវចនំ ឆន្ទសោ អារោបេមាតិ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ ពុទ្ធវចនំ

១ ឱ. យមេឡុកេកុលា ។ ម. យមេឡកេកុឡា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៦៩០] សម័យនោះឯង មានភិក្ខុពីររូបជាបងប្អូននឹងគ្នា ឈ្មោះមេដ្ឋកៈ ១ ឧកុដ្ឋៈ ១ ជាជាតិព្រាហ្មណ៍ មានសំដីពីរោះ មានសំឡេងពីរោះ ៗ ភិក្ខុទាំងពីររូបនោះ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សព្វថ្ងៃនេះពួកភិក្ខុមានឈ្មោះផ្សេងគ្នា មានគោត្រផ្សេងគ្នា មានជាតិផ្សេងគ្នា ចេញអំពីត្រកូលទីទៃ ៗ មកបួស ភិក្ខុទាំងនោះធ្វើពុទ្ធវចនៈឲ្យខូចដោយភាសារបស់ខ្លួន បពិត្រព្រះមានព្រះភាគ បើដូច្នោះខ្ញុំព្រះអង្គទាំងអម្បាលនេះ សូមលើកពុទ្ធវចនៈតាមឆន្ទ(១) ៗ ព្រះពុទ្ធទ្រង់ព្រះភាគជាម្ចាស់ព្រះអង្គទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ មិនសមបើអ្នកពល់គ្នាពោលថា បពិត្រព្រះអង្គដ៏ចំរើន បើដូច្នោះខ្ញុំព្រះអង្គពល់គ្នាសូមលើកពុទ្ធវចនៈតាមឆន្ទដូច្នេះទេ នែមោឃបុរស អំពើដែលអ្នកពល់គ្នាធ្វើនេះ មិននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ៗ បេ ៗ លុះទ្រង់បន្ទោសហើយក៏ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវលើកពុទ្ធវចនៈ

---

១ ពាក្យថា ឆន្ទ នេះ ក្នុងទីដទៃសំដៅពាក្យឃ្លោង ឯក្នុងទីនេះសំដៅយកសក្កដភាសា គឺភាសាសំស្ក្រឹត ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឆន្ទសោ អារោបេតព្វំ យោ អារោបេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ សកាយ និរុត្តិយា ពុទ្ធវចនំ បរិយាបុណិតុន្តិ ។

(២៨១) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ លោកាយតំ បរិយាបុណន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។បេ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ អបិ នុ ខោ ភិក្ខវេ លោកាយតសារទស្សាវី ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យាតិ ។ នោ ហេតំ ភន្តេ(១) ។ ឥមស្មឹ វា បន ធម្មវិនយេ សារទស្សាវី លោកាយតំ បរិយាបុណេយ្យាតិ ។ នោ ហេតំ ភន្តេ ។ ន ភិក្ខវេ លោកាយតំ បរិយាបុណិតព្វំ យោ បរិយាបុណេយ្យ អាបត្តិ ទុក្កដស្សាតិ ។

---

១ ម. បោត្ថកេសុ ឥតិសទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



តាមធម្មទេ ភិក្ខុណាលើក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុរៀនពុទ្ធវចនៈតាមសកភាសា (១) គឺមគធភាសា ។

[២៩១] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុរៀនគម្ពីរលោកាយតៈ(២) ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ ពួកភិក្ខុបានឮមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។បេ។ ទើបភិក្ខុទាំងអម្បាលនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាប់ឃើញថាមានខ្លឹមក្នុងគម្ពីរលោកាយតៈហើយ គួរដល់នូវសេចក្តីចំរើនលូតលាស់ធំទូលាយក្នុងធម្មវិន័យនេះដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ សេចក្តីនេះមិនមែនទេ ។ ទ្រង់ត្រាស់សួរទៀតថា ចុះភិក្ខុដែលឃើញថាមានខ្លឹមក្នុងធម្មវិន័យនេះហើយ គួររៀនគម្ពីរលោកាយតៈដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ សេចក្តីនេះមិនមែនទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវរៀនគម្ពីរលោកាយតៈទេ ភិក្ខុណារៀនត្រូវអាបត្តិទុក្កដ ។

---

១ ក្នុងអដ្ឋកថា ពន្យល់ថា វោហារ (ពាក្យពោល) របស់អ្នកស្រុកមគធដែលព្រះសម្មាសម្ពុទ្ធតែងពោល ឈ្មោះថា សកភាសា ។ ២ គម្ពីរតិត្ថិយដែលប្រកបដោយហេតុឥតប្រយោជន៍មានពាក្យថា វត្ថុទាំងពួងជារបស់ដែល (គេលះបោស) វត្ថុទាំងពួងមិនមែនជារបស់ដែល ពីរបស់ ឆ្អឹង ក្អែកស បានជាសព្រោះហេតុនេះ ក្ងោកបានជាខ្មៅ ព្រោះហេតុនេះជាដើម ឈ្មោះថា លោកាយតៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[២៩២] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ លោកាយតំ វាចេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ លោកាយតំ វាចេតព្វំ យោ វាចេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២៩៣] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ តិរច្ឆានវិជ្ជំ បរិយាបុណន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ តិរច្ឆានវិជ្ជា បរិយាបុណិតព្វា យោ បរិយាបុណេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២៩៤] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ តិរច្ឆានវិជ្ជំ វាចេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ តិរច្ឆានវិជ្ជា វាចេតព្វា យោ វាចេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៩២) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបង្រៀនគម្ពីរលោកាយតៈ ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបង្រៀនគម្ពីរលោកាយតៈទេ ភិក្ខុណាបង្រៀន ត្រូវអាបត្តិទុក្កដ ។

(២៩៣) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុរៀនតិរច្ឆានវិជ្ជា ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវរៀនតិរច្ឆានវិជ្ជាទេ ភិក្ខុណារៀន ត្រូវអាបត្តិទុក្កដ ។

(២៩៤) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបង្រៀនតិរច្ឆានវិជ្ជា ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបង្រៀនតិរច្ឆានវិជ្ជាទេ ភិក្ខុណាបង្រៀន ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



[២៩៥] តេន ខោ បន សមយេន ពុទ្ធោ ភគវា មហតិយា បរិសាយ បរិវុតោ ធម្មំ ទេសេន្តោ ខិបិ ។ ភិក្ខូ ជីវតុ ភន្តេ ភគវា ជីវតុ សុគតោតិ ឧច្ចាសទ្ទំ មហាសទ្ទំ អកំសុ ។ តេន សទ្ទេន ធម្មកថា អន្ត-រា អហោសិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ អបិ នុ ខោ ភិក្ខវេ ខិបិតេ ជីវាតិ វុត្តោ(១) តប្បច្ចយា ជីវេយ្យ វា មរេយ្យ វាតិ ។ នោ ហេតំ ភន្តេតិ(២) ។ ន ភិក្ខវេ ខិបិតេ ជីវាតិ វត្តព្វោ យោ វទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២៩៦] តេន ខោ បន សមយេន មនុស្សា ភិក្ខូនំ ខិបិតេ ជីវថ ភន្តេតិ វទន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាល-បន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ

---

១ ឱ. ម. វុត្តេ ។ ២ ឱ. ម. បោត្ថកេសុ ឥតិសទ្ទោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ខុទ្ទកវត្ថុក្ខន្ធកៈ រឿងព្រះមានព្រះភាគទ្រង់កណ្តាស

(២៩៥) សម័យនោះឯង ព្រះពុទ្ធទ្រង់ព្រះភាគ មានបរិសទ្យជាច្រើនចោមរោម ទ្រង់សំដែងធម៌ហើយទ្រង់កណ្តាស ។ ពួកភិក្ខុក៏ធ្វើសម្លេងគឹកកងយ៉ាងខ្លាំងថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគចំរើនព្រះជន្មាយុរស់នៅ សូមព្រះសុគតចំរើនព្រះជន្មាយុរស់នៅ(១) ។ ធម្មកថាក៏ដាច់ពាក់កណ្តាល ដោយសំឡេងនោះ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកសួរថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេនិយាយថា អ្នកចូររស់នៅដូច្នេះ ក្នុងវេលាដែលកណ្តាស បុគ្គលនោះគួររស់នៅ ឬគួរស្លាប់ ព្រោះហេតុប៉ុណ្ណោះដែរឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ហេតុនុ៎ះមិនមែនទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកដទៃ ភិក្ខុមិនត្រូវពោលថា អ្នកចូររស់នៅក្នុងវេលាកណ្តាស(ប៉ុណ្ណោះ)ទេ ភិក្ខុណាពោល ត្រូវអាបត្តិទុក្កដ ។

(២៩៦) សម័យនោះឯង មនុស្សទាំងឡាយទៅនិយាយនឹងពួកភិក្ខុ ក្នុងវេលាដែលកណ្តាសថា បពិត្រលោកទាំងឡាយដ៏ចំរើន ចូរលោករស់នៅ ។ ពួកភិក្ខុមានសេចក្តីស្ទើរស្ទៀស មិនហ៊ានពោលតបវិញ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ

---

១ ត្រង់ពាក្យថា ព្រះមានព្រះភាគចូររស់នៅ នឹងពាក្យថា ព្រះសុគតចូររស់នៅ ពាក្យទាំងពីរនេះ ជាពាក្យថ្វាយព្រះពរ តែព្រះពុទ្ធជាម្ចាស់ទ្រង់ហាម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នាម សមណា សក្យបុត្តិយា ជីវថ ភន្តេតិ វុច្ចមានា
នាលបិស្សន្តីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។
គិហី ភិក្ខវេ មង្គលិកា អនុជានាមិ ភិក្ខវេ គិហីនំ
ជីវថ ភន្តេតិ វុច្ចមានេន ចិរំ ជីវាតិ វត្តុន្តិ ។

(៤៩៧) តេន ខោ បន សមយេន ភគវា មហតិយា
បរិសាយ បរិវុតោ ធម្មំ ទេសេន្តោ និសិន្នោ ហោតិ ។
អញ្ញតរេន ភិក្ខុនា លសុណំ ខាយិតំ ហោតិ ។ សោ
ច(១) មា ភិក្ខូ ព្យាពាហិំសូតិ ឯកមន្តំ និសីទិ ។
អទ្ទសា ខោ ភគវា តំ ភិក្ខុំ ឯកមន្តំ និសិន្នំ ទិស្វាន
ភិក្ខូ អាមន្តេសិ កិន្នុ ខោ សោ ភិក្ខវេ ភិក្ខុ ឯក-
មន្តំ និសិន្នោតិ ។ ឯតេន ភន្តេ ភិក្ខុនា លសុណំ
ខាយិតំ សោ ច មា ភិក្ខូ ព្យាពាហិំសូតិ ឯកមន្តំ
និសិន្នោតិ ។ អបិ នុ ខោ ភិក្ខវេ ភិក្ខុនា(២) តំ ខាទិ-
តព្វំ យំ ខាទិត្វា ឯវរូបាយ ធម្មកថាយ បរិពាហិរោ

---

១ ឱ.ម. បោត្ថកេសុ ចសទ្ទោ ន បញ្ញាយតិ ។ ២ មរម្មបោត្ថកេ អយំ សទ្ទោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សមណសក្យបុត្តិយ៍ទាំងនេះ កាលបើពួកយើងនិយាយថា បពិត្រលោកទាំងឡាយដ៏ចំរើន ចូរលោករស់នៅជូបេះ ហើយលោកមិនពោលតបនឹងយើងសោះ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាគ្រហស្ថទាំងឡាយតែងត្រូវការដោយមង្គល ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលគ្រហស្ថទាំងឡាយនិយាយថា បពិត្រលោកដ៏ចំរើន លោកចូររស់នៅ ជូបេះ ឲ្យនិយាយតបទៅវិញថា អ្នកចូររស់នៅអស់កាលយូរជូបេះបាន ។

(២៩៧) សម័យនោះឯង ព្រះមានព្រះភាគមានបរិសទ្យច្រើនចោមរោមទ្រង់គង់សំដែងធម៌ ។ ភិក្ខុមួយរូបឆាន់ខ្ទឹម ។ ភិក្ខុនោះអង្គុយក្នុងទីបំផុតដោយគិតថា ពួកភិក្ខុកុំធុំក្លិនឡើយ ។ ព្រះមានព្រះភាគទ្រង់ទតឃើញភិក្ខុនោះអង្គុយក្នុងទីបំផុត លុះឃើញហើយទើបត្រាស់ហៅពួកភិក្ខុមកសួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលអង្គុយក្នុងទីបំផុតនោះដោយហេតុអ្វី ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគដ៏ចំរើន (ព្រោះ) ភិក្ខុនោះឆាន់ខ្ទឹម បានជាភិក្ខុនោះអង្គុយក្នុងទីបំផុតដោយគិតថា ពួកភិក្ខុកុំធុំក្លិនឡើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលនៅឆ្ងាយពីធម្មកថា មានសភាពយ៉ាងនេះ ព្រោះតែឆាន់ខ្ទឹមណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អស្សាតិ ។ នោ ហេតំ ភន្តេតិ ។ ន ភិក្ខវេ លសុណំ ខាទិតព្វំ យោ ខាទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៩៨) តេន ខោ បន សមយេន អាយស្មតោ សារីបុត្តស្ស ឧទរវាតាពាធោ ហោតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោច បុព្វេ តេ អាវុសោ សារីបុត្ត ឧទរវាតាពាធោ កេន ផាសុ ហោតីតិ ។ លសុណេន មេ អាវុសោតិ(១) ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា លសុណំ ខាទិតុន្តិ ។

(២៩៩) តេន ខោ បន សមយេន ភិក្ខូ អារាមេ តហំ តហំ បស្សាវំ ករោន្តិ ។ អារាមោ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ឯកមន្តំ បស្សាវំ កាតុន្តិ ។ អារាមោ ទុគ្គន្ធោ ហោតិ ។ បេ ។

---

១ មរម្មបោត្ថកេ បុព្វេ ខោ មេ អាវុសោ មោគ្គល្លាន ឧទរវាតាពាធោ លសុណេន ផាសុ ហោតីតិ បាឋោ អាគតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខ្ទឹមនោះភិក្ខុគួរឆាន់ដែរឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះមិនគួរទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ខ្ទឹមទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

(២៩៨) សម័យនោះឯង ព្រះសារីបុត្តមានអាយុ មានអាពាធកើតអំពីខ្យល់ក្នុងផ្ទៃ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ មានថេរវាចាសួរព្រះសារីបុត្តមានអាយុដូច្នេះថា នែអាវុសោ សារីបុត្ត អាពាធដែលកើតអំពីខ្យល់ក្នុងផ្ទៃរបស់លោកពីមុន តែងជាសះស្បើយដោយថ្នាំអ្វី ។ ព្រះសារីបុត្តតបថា ម្នាលអាវុសោ ខ្ញុំតែងជាសះស្បើយដោយខ្ទឹម ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានអាពាធជាហេតុ តថាគតអនុញ្ញាតឲ្យឆាន់ខ្ទឹមបាន ។

(២៩៩) សម័យនោះឯង ពួកភិក្ខុបន្ទោបង់បស្សាវៈក្នុងទីពីសពាស ។ អារាមមិនស្អាត ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបន្ទោបង់បស្សាវៈតែក្នុងកន្លែងមួយ ។ អារាមមានក្លិនអាក្រក់ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ បស្សាវកុម្ភិន្តិ ។ ទុក្ខំ និសិន្នា បស្សាវំ ករោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ បស្សាវបាទុកន្តិ ។ បស្សាវបាទុកា បាកដា ហោន្តិ ។ ភិក្ខូ ហិរិយន្តិ បស្សាវំ កាតុំ ។ បេ ។ អនុជានាមិ ភិក្ខវេ បរិក្ខិបិតុំ តយោ បាការេ ឥដ្ឋកាបាការំ សិលាបាការំ ទារុបាការន្តិ ។ បស្សាវកុម្ភី អបារុតា ទុគ្គន្ធា ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ អបិធានន្តិ ។

(៣០០) តេន ខោ បន សមយេន ភិក្ខូ អារាមេ តហំ តហំ វច្ចំ ករោន្តិ ។ អារាមោ ទុស្សតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ឯកមន្តំ វច្ចំ កាតុន្តិ ។ អារាមោ ទុគ្គន្ធោ ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ វច្ចកូបន្តិ ។ វច្ចកូបស្ស កូលំ លុជ្ជតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ វច្ចកូបោ និចវត្ថុកោ ហោតិ ។ ឧទកេន ឱត្ថរិយតិ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថ្នាំងសម្រាប់រងើបស្សាវៈ ។ ពួកភិក្ខុលំបាកនឹងអង្គុយបន្ទោបង់បស្សាវៈ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ជើងសម្រាប់បន្ទោបង់បស្សាវៈ ។ ទ្រនាប់ជើងសម្រាប់បន្ទោបង់បស្សាវៈ នៅទីវាលមិនបិទបាំង ។ ពួកភិក្ខុអៀននឹងបន្ទោបង់បស្សាវៈ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបិទបាំងដោយកំពែង ៣ យ៉ាង គឺកំពែងឥដ្ឋ ១ កំពែងថ្ម ១ កំពែងឈើ ១ ។ ថ្នាំងសម្រាប់រងើបស្សាវៈមិនបានមានគម្រប ក៏ធុំក្លិនស្អុយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគម្រប ។

(៣០១) សម័យនោះឯង ពួកភិក្ខុបន្ទោបង់វច្ចៈក្នុងទីពីសពាសក្នុងអារាម ។ អារាមក៏មិនស្អាត ។ បេ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបន្ទោបង់វច្ចៈតែក្នុងកន្លែងមួយ ។ អារាមក៏ធុំក្លិនស្អុយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរណ្តៅវច្ចៈ ។ មាត់រណ្តៅវច្ចៈក៏ធ្លាក់រលុះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកខឿន ៣ យ៉ាង គឺ ខឿនឥដ្ឋ១ ខឿនថ្ម ១ ខឿនឈើ ១ ។ រណ្តៅវច្ចៈបាននៅដីទាប ។ ទឹកក៏លិចកន្លែងនោះ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ ប-
រិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ
ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោហន្តា
វិហញ្ញន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ តយោ សោបានេ
ឥដ្ឋកាសោបានំ សិលាសោបានំ ទារុសោបានន្តិ ។
អារោហន្តា បរិបតន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ អាលម្ព-
នពាហន្តិ ។ អន្តេ និសិន្នា វត្ថុំ ការោន្តា បរិបតន្តិ ។ បេ ។
អនុជានាមិ ភិក្ខវេ សន្ថរិត្វា មជ្ឈេ និទ្ធំ កត្វា វត្ថុំ
កាតុន្តិ ។ ឧក្ខំ និសិន្នា វត្ថុំ ការោន្តិ ។ បេ ។ អនុជានាមិ
ភិក្ខវេ វត្ថុទានុកន្តិ ។ ពហិទ្ធា បស្សាវំ ការោន្តិ ។ បេ ។
អនុជានាមិ ភិក្ខវេ បស្សាវទោណិកន្តិ ។ អវលេខនកដ្ឋំ
ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ អវលេខនកដ្ឋន្តិ ។
អវលេខនបិឋរោ[1] ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ

---

១ ឱ, ម. បិធរោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើទីដើរឲ្យខ្ពស់ឡើង ។ ខឿនក៏បាក់លុះហូរចេញ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកខឿន ៣ យ៉ាង គឺ ខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១ ។ ពួកភិក្ខុឡើងក៏លំបាក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ ៣ យ៉ាង គឺ ជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១ ។ ពួកភិក្ខុឡើងទៅក៏ដួល ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ ។ ពួកភិក្ខុអង្គុយកន្ទីបំផុតក៏ពុងបន្ទោបង់វច្ចៈក៏ធ្លាក់ចុះមក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុក្រាលក្តារហើយចោះប្រហោងកណ្តាលហើយបន្ទោបង់វច្ចៈ ។ ពួកភិក្ខុក៏លំបាកទីអង្គុយបន្ទោបង់វច្ចៈ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ជើងសម្រាប់បន្ទោបង់វច្ចៈ ។ ពួកភិក្ខុបន្ទោបង់បស្សាវៈខាងក្រៅ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទសម្រាប់ធេបស្សាវៈ ។ ឈើខ្ទៀសមិនទាន់មាននៅឡើយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើខ្ទៀស ។ ត្រកសម្រាប់ដាក់ឈើខ្ទៀសមិនទាន់មាននៅឡើយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អវលេខនបិឋរន្តិ ។ វច្ចកូបោ អបារុតោ ទុគ្គន្ធោ ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ អបិធានន្តិ ។

(៣០១) តេន ខោ បន សមយេន ភិក្ខូ(១) អជ្ឈោកាសេ វច្ចំ ករោន្តា សីតេនបិ ឧណ្ហេនបិ កិលមន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ វច្ចកុដិន្តិ ។ វច្ចកុដិយា កវាដំ ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ កវាដំ បិដ្ឋសង្ឃាដំ ឧទុក្ខលិកំ ឧត្តរបាសកំ អគ្គឡវដ្ដិំ កបិសីសកំ សូចិកំ ឃដិកំ តាឡច្ឆិទ្ទំ អាវិញ្ឆនច្ឆិទ្ទំ អាវិញ្ឆនរជ្ជុំ ។ វច្ចកុដិយា តិណចុណ្ណំ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឱគុម្ផេត្វា ឧល្លិត្តាវលិត្តំ កាតុំ សេតវណ្ណំ កាឡវណ្ណំ គេរុកបរិកម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកំ ចីវរវំសំ ចីវររជ្ជុន្តិ ។

---

១ តេន ខោ បន សមយេន ភិក្ខូតិបិ ឧភោបិយមរម្មបោត្ថកេសុ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ត្រូវសម្រាប់ដាក់ឈើខ្សៀស ។ រណ្តៅវច្ចៈមិនទាន់មានគ្រប កំពុងក្លិនស្អុយ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគម្រប ។

[៣០១] សម័យនោះឯង ពួកភិក្ខុបន្ទោបង់វច្ចៈក្នុងទីកណ្តាលវាលក៏លំបាកដោយត្រជាក់ខ្លះ ក្តៅខ្លះ ។ ភិក្ខុទាំងឡាយនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវច្ចកុដិ ។ សន្ទះទ្វារវច្ចកុដិមិនទាន់មាន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារក្បាល (ជំណាប់ក្រោម) អន្ទាក់លើ (ជំណាប់លើ) សសររបស់សន្ទះទ្វារ ត្រដោកទ្វារ ទេកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់ទាញនឹងខ្សែសម្រាប់ទាញ ។ កំទេចស្មៅធ្លាក់ចុះក្នុងវច្ចកុដិ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុគាបដំបូលហើយបូកលាបទាំងខាងក្នុងខាងក្រៅ(១) នឹងជាំមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ ក្បាច់កីផ្កា ក្បាច់កីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥ ស្នរសំពត់ចីវរ នឹងខ្សែសំពត់ចីវរ ។

---

១ អដ្ឋកថា ថា ទ្រង់អនុញ្ញាតឲ្យប្រក់ដំបូលហើយប្រះឈើពាន់ ហើយបូកទាំងខាងក្នុងខាងក្រៅដោយដីស្អិត ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣០២) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ជរាទុព្ពលោ វច្ចំ កត្វា វុដ្ឋហន្តោ បរិបតតិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ឱលម្ពកន្តិ ។

(៣០៣) តេន ខោ បន សមយេន វច្ចកុដិ អបរិក្ខិត្តា ហោតិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បរិក្ខិបិតុំ តយោ បាការេ ឥដ្ឋកាបាការំ សិលាបាការំ ទារុបាការន្តិ ។

(៣០៤) កោដ្ឋកោ ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ កោដ្ឋកន្តិ ។ កោដ្ឋកោ នីចវត្ថុកោ ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោហន្តា វិហញ្ញន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ តយោ សោបានេ ឥដ្ឋកាសោបានំ សិលាសោបានំ ទារុសោបានន្តិ ។ អារោហន្តា បរិបតន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣០២) សម័យនោះឯង ភិក្ខុមួយរូបជរាទុព្វល កាលទីងបន្ទាបទំ ផ្ចុះ ហើយក្រោកឡើង ក៏ដួលទៅវិញ ។ ភិក្ខុទាំងនោះក្រាបបង្គំទូល សេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរបស់សម្រាប់តោង ។

(៣០៣) សម័យនោះឯង វច្ចកុដិមិនទាន់មានរបង ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបិទបាំងដោយកំពែង ៣ យ៉ាង គឺ កំពែងឥដ្ឋ ១ កំពែងថ្ម ១ កំពែងឈើ ១ ។

(៣០៤) បន្ទប់មិនទាន់មាន ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតបន្ទប់ ។ បន្ទប់មានទីដ៏ទាប ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើទីដីឲ្យខ្ពស់ឡើង ។ ខឿនក៏បាក់លុះរលាយ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកខឿន ៣ យ៉ាង គឺខឿនឥដ្ឋ ១ ខឿនថ្ម ១ ខឿនឈើ ១ ។ ពួកភិក្ខុលំបាកនឹងឡើង ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ ៣ យ៉ាង គឺ ជណ្តើរឥដ្ឋ ១ ជណ្តើរថ្ម ១ ជណ្តើរឈើ ១ ។ កាលពួកភិក្ខុនាំគ្នា ឡើងក៏ធ្លាក់មកវិញ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាលម្ពនពាហន្តិ ។ កោដ្ឋកស្ស កវាដំ ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ កវាដំ បិដ្ឋសង្ឃាដំ ឧទុក្ខលិកំ ឧត្តរបាសកំ អគ្គឡវដ្ដិំ កបិសីសកំ សូចិកំ ឃដិកំ តាលច្ឆិទ្ទំ អាវិញ្ឆនច្ឆិទ្ទំ អាវិញ្ឆនរជ្ជុន្តិ ។ កោដ្ឋកេ តិណចុណ្ណំ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឱគុម្ពេត្វា ឧល្លិត្តាវលិត្តំ កាតុំ សេតវណ្ណំ កាឡវណ្ណំ គេរុកបរិកម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដ្ឋិកន្តិ ។ បរិវេណំ ចិក្ខល្លំ ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ មរុម្ពំ បកិរិតុន្តិ ។ ន បរិយាបុណាតិ[1] ។ បេ ។ អនុជានាមិ ភិក្ខវេ បទរសិលំ និក្ខិបិតុន្តិ ។ ឧទកំ សណ្ឋាតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧទកនិទ្ធមនន្តិ ។ អាចមនកុម្ភី ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ អាចមនកុម្ភិន្តិ ។ អាចមនសរាវកោ ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ

---

១ ឱ បរិបុរតីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តថាគតអនុញ្ញាតបង្កាម់ដៃ ៗ សន្ទះទ្វាររបស់បន្ទប់មិនទាន់មាន ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ក្បាល (ជំណាប់ក្រោម) អន្ទាក់លើ (ជំណាប់លើ) សសររបស់សន្ទះទ្វារ ត្រដោកទ្វារ ខ្នុកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់ទាញ ខ្សែសម្រាប់ទាញ ៗ កំទេចស្មៅក៏ធ្លាក់ចុះក្នុងបន្ទប់ ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាបដំបូល ហើយបូកលាបទាំងខាងក្នុងទាំងខាងក្រៅ ទីងថ្នាំមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ ក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ ក្បាច់ធ្មេញមករ . ទីងក្បាច់មានស្រទាប់៥ ៗ ដីលានក៏កក់ជ្រាំ ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរោយរាយដោយគ្រួសរៀន ៗ ដីលានមិនរាបស្មើ ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាលថ្ម ៗ ទឹកក៏ដក់នៅ ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទទឹក ៗ ឆ្នាំងទឹកសម្រាប់ជម្រះមិនទាន់មាន ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆ្នាំងទឹកសម្រាប់ជម្រះ ៗ ផ្តិលសម្រាប់ជម្រះមិនទាន់មាន ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាចមនសរាវកន្តិ ។ ទុក្ខំ និសិន្នា អាចមេន្តិ ។ បេ ។
អនុជានាមិ ភិក្ខវេ អាចមនបាទុកន្តិ ។ អាចមនបា-
ទុកា បាកដា ហោន្តិ ។ ភិក្ខូ ហិរិយន្តិ អាចមេតុំ
។ បេ ។ អនុជានាមិ ភិក្ខវេ បរិក្ខិបិតុំ តយោ បាការេ
ឥដ្ឋកាបាការំ សិលាបាការំ ទារុបាការន្តិ ។ អាច-
មនកុម្ភី អបារុតា ហោតិ ។ តិណចុណ្ណេហិបិ បំសុ-
កេហិបិ ឱកិរិយតិ ។ បេ ។ អនុជានាមិ ភិក្ខវេ
អបិធានន្តិ ។

(៣០៥) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ
ឯវរូបំ អនាចារំ អាចរន្តិ មាលាវច្ឆំ រោបេន្តិបិ រោបា-
បេន្តិបិ សិញ្ចន្តិបិ សិញ្ចាបេន្តិបិ ឱចិនន្តិបិ ឱចិនាបេន្តិបិ
គន្ថេន្តិបិ គន្ថាបេន្តិបិ ឯកតោវណ្ដិកមាលំ ករោន្តិបិ
ការាបេន្តិបិ ឧភតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ
មញ្ជរិកំ ករោន្តិបិ ការាបេន្តិបិ វិធូតិកំ ករោន្តិបិ
ការាបេន្តិបិ វដំសកំ ករោន្តិបិ ការាបេន្តិបិ អាវេឡំ
ករោន្តិបិ ការាបេន្តិបិ ឧរច្ឆទំ ករោន្តិបិ ការាបេន្តិបិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តថាគតអនុញ្ញាតផ្តិលសម្រាប់ជម្រះ ។ ពួកភិក្ខុលំបាកនឹងអង្គុយជម្រះ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ជើងសម្រាប់ជម្រះ ។ ទ្រនាប់ជើងសម្រាប់ជម្រះ នៅកណ្តាលវាល ។ ពួកភិក្ខុអៀនខ្មាសនឹងជម្រះ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបិទបាំងដោយកំពែង ៣ យ៉ាង គឺកំពែងឥដ្ឋ ១ កំពែងថ្ម ១ កំពែងឈើ ១ ។ ផ្តិលទឹកសម្រាប់ជម្រះមិនទាន់មានគម្រប ។ ផ្តិលទឹកសម្រាប់ជម្រះស្មោកគ្រោកដោយកំទេចស្មៅខ្លះអាចម៍ដីខ្លះ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគម្រប។

( ៣០៥ ) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះ គឺដាំកូនផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើកម្រងផ្កាឲ្យមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើតាក់តែងលេបទងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើដោត[១] ជាបង្អោមខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ

---

១ អដ្ឋកថា ពន្យល់ថា កម្រងផ្កាដែលគេដោត ដោយម្ជុលឬកន្លាស់ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



តេ កុលិត្ថីនំ កុលធីតានំ កុលកុមារីនំ កុលសុណ្ហានំ កុលទាសីនំ ឯកតោវណ្ដិកមាលំ ហរន្តិបិ ហរាបេន្តិបិ ឧភតោវណ្ដិកមាលំ ហរន្តិបិ ហរាបេន្តិបិ មញ្ជរិកំ ហរន្តិបិ ហរាបេន្តិបិ វិធូតិកំ ហរន្តិបិ ហរាបេន្តិបិ វដំសកំ ហរន្តិបិ ហរាបេន្តិបិ អាវេឡំ ហរន្តិបិ ហរាបេន្តិ ឧរច្ឆទំ ហរន្តិបិ ហរាបេន្តិបិ តេ កុលិត្ថីហិ កុលធីតាហិ កុលកុមារីហិ កុលសុណ្ហាហិ កុលទាសីហិ សទ្ធឹ ឯកភាជនេបិ ភុញ្ជន្តិ ឯកថាលកេបិ បិវន្តិ ឯកាសនេបិ និសីទន្តិ ឯកមញ្ចេបិ តុវដ្ដេន្តិ ឯកត្ថរណាបិ តុវដ្ដេន្តិ ឯកបាវុរណាបិ តុវដ្ដេន្តិ ឯកត្ថរណាបាវុរណាបិ តុវដ្ដេន្តិ វិកាលេបិ ភុញ្ជន្តិ មជ្ជម្បិ បិវន្តិ មាលាគន្ធវិលេបនម្បិ ធារេន្តិ នច្ចន្តិបិ គាយន្តិបិ វាទេន្តិបិ លាសេន្តិបិ នច្ចន្តិយាបិ នច្ចន្តិ នច្ចន្តិយាបិ គាយន្តិ នច្ចន្តិយាបិ វាទេន្តិ នច្ចន្តិយាបិ លាសេន្តិ ។បេ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពួកភិក្ខុទាំងអម្បាលនោះ នាំផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យទាំទៅខ្លះ នាំផ្កាកម្រងមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាឈើចាក់លេចទងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាឈើដែលដោតជាចង្កោមទៅខ្លួនឯងខ្លះ ប្រើគេឲ្យទាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ ដើម្បីពួកស្រីក្រមុំនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូល ពួកភិក្ខុទាំងអម្បាលនោះ ឆាន់(ភោជន)ក្នុងភាជន៍មួយជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយខ្លះ ផឹកទឹកក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនៈជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់សំពត់ជាមួយគ្នាខ្លះ ដេកលើកម្រាលទាំងដណ្តប់សំពត់ជាមួយគ្នាខ្លះ ស៊ីខុសពេលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូបនឹងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីដែលរាំខ្លះ ច្រៀងជាមួយនឹងស្រីដែលរាំខ្លះ ប្រគំជាមួយនឹងស្រីដែលរាំខ្លះ កែក្រាយជាមួយនឹងស្រីដែលរាំខ្លះ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លាសេន្តិយាបិ នច្ចន្តិ លាសេន្តិយាបិ គាយន្តិ លា-
សេន្តិយាបិ វាទេន្តិ លាសេន្តិយាបិ លាសេន្តិ អដ្ឋបទេបិ
កីឡន្តិ ទសបទេបិ កីឡន្តិ អាកាសេបិ កីឡន្តិ ប-
រិហារបថេបិ កីឡន្តិ សន្តិកាយបិ កីឡន្តិ ខលិកា-
យបិ កីឡន្តិ ឃដិកាយបិ កីឡន្តិ សលាកហត្ថេនបិ
កីឡន្តិ អក្ខេនបិ កីឡន្តិ បង្គចីរេនបិ កីឡន្តិ វង្ក-
កេនបិ កីឡន្តិ មោក្ខចិកាយបិ កីឡន្តិ ចិង្គុលកេ-
នបិ កីឡន្តិ បត្តាឡ្ហកេនបិ កីឡន្តិ រថកេនបិ កីឡន្តិ
ធនុកេនបិ កីឡន្តិ អក្ខរិកាយបិ កីឡន្តិ មនេសិ-
កាយបិ កីឡន្តិ យថាវជ្ជេនបិ កីឡន្តិ ហត្ថិស្មិម្បិ
សិក្ខន្តិ អស្សស្មិម្បិ សិក្ខន្តិ រថស្មិម្បិ សិក្ខន្តិ
ធនុស្មិម្បិ សិក្ខន្តិ ថរុស្មិម្បិ សិក្ខន្តិ ហត្ថិស្សបិ
បុរតោ ធាវន្តិ អស្សស្សបិ បុរតោ ធាវន្តិ រថស្សបិ
បុរតោ ធាវន្តិ ធាវន្តិបិ អាធាវន្តិបិ ឧស្សេឡ្ហេន្តិបិ
អប្ផោដេន្តិបិ និព្វុជ្ឈន្តិបិ មុដ្ឋីហិបិ យុជ្ឈន្តិ រង្គមជ្ឈេបិ
សង្ឃាដឹ បត្ថរិត្វា នច្ចកឹ ឯវំ វទេន្តិ ឥធ ភគិនិ
នច្ចស្សូតិ នលាដិកម្បិ ទេន្តិ វិវិធម្បិ អនាចារំ អាចរន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



រាំជាមួយនឹងស្រីដែលកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីដែលកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីដែលកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីដែលកែក្រាយខ្លះ លេងបាស្កាមានក្រឡាប្រាំបីខ្លះ លេងបាស្កាមានក្រឡាដប់ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងរាំងផ្លូវដែលគូរវាង (លេងពួន) ខ្លះ លេងផ្ដាត់គ្រាប់មានគ្រាប់គ្រួសជាដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងលោស់ទឹកល័ក្តឲ្យចាយរូបខ្លះ លេងអង្គុញខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងនង្គ័លតូចខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ (បាយឡុកបាយឡ) ខ្លះ លេងរថតូចខ្លះ លេងធ្នូតូចខ្លះ លេងសរសេរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត (ស្មូចចង់) ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់វិជ្ជាដងមានដងដាវជាដើមខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហោខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្ដាលរោងរាំ ហើយនិយាយនឹងស្រីដែលរាំយ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទីនេះខ្លះ ដាក់ម្រាមដៃលើថ្ងាសខ្លួននឹងថ្ងាសស្រីដែលរាំខ្លះ ប្រព្រឹត្តអនាចារផ្សេង ៗ ខ្លះ (ក្រៅអំពីនេះទៅទៀត) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ វីធិ អឆាចារំ អាចរិតព្វំ យោ អាចរេយ្យ យថាធម្មោ ការេតព្វោតិ ។

(៣០៦) តេន ខោ បន សមយេន អាយស្មន្តេ ឧរុវេលកស្សបេ បព្វជិតេ សង្ឃស្ស ពហុំ លោហភណ្ឌំ ទារុភណ្ឌំ មត្តិកាភណ្ឌំ ឧប្បន្នំ ហោតិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កិន្នុ ខោ ភគវតា លោហភណ្ឌំ អនុញ្ញាតំ កឹ អននុញ្ញាតំ កឹ ទារុភណ្ឌំ អនុញ្ញាតំ កឹ អននុញ្ញាតំ កឹ មត្តិកាភណ្ឌំ អនុញ្ញាតំ កឹ អននុញ្ញាតន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ឋបេត្វា បហរណឹ សព្វំ លោហភណ្ឌំ ឋបេត្វា អាសន្ទឹ បល្លង្កំ ទារុបត្តំ ទារុបាទុកំ សព្វំ ទារុភណ្ឌំ ឋបេត្វា កតកញ្ច កុម្ភការិកញ្ច សព្វំ មត្តិកាភណ្ឌន្តិ ។

ខុទ្ទកវត្ថុក្ខន្ធកំ និដ្ឋិតំ បញ្ចមំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រព្រឹត្តអនាចារផ្សេង ៗ ទេ ភិក្ខុណាប្រព្រឹត្ត វិន័យធរគប្បីឲ្យភិក្ខុនោះធ្វើតាមធម៌ ។

(៣០៦) សម័យនោះឯង កាលព្រះសង្ឃរលែកសង្រួមមានអាយុចូលមកបួសហើយ ក៏មានគ្រឿងលោហៈ គ្រឿងឈើ គ្រឿងដី ជាច្រើនកើតឡើងដល់សង្ឃ ។ ពួកភិក្ខុគិតយ៉ាងនេះថា គ្រឿងលោហៈ ព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ឬមិនទាន់អនុញ្ញាតទេ គ្រឿងឈើព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ឬមិនទាន់អនុញ្ញាតទេ គ្រឿងដីព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ឬមិនទាន់អនុញ្ញាតទេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រឿងលោហៈទាំងពួង វៀរលែងតែលោហៈដែលជាគ្រឿងសម្រាប់ប្រហារ អនុញ្ញាតគ្រែទាំងពួង វៀរលែងតែអាសនៈកន្ទួនហួសប្រមាណដែលហៅថាអាសន្ទិ អនុញ្ញាតគ្រឿងឈើទាំងពួង វៀរលែងតែបាត្រឈើ និងទ្រនាប់ជើងឈើ អនុញ្ញាតគ្រឿងដីទាំងពួង វៀរលែងតែគ្រឿងជូតជើងដែលគេធ្វើជាពកឲ្យស្រួចៗឡើងមានអាការដូចពកគ្រាប់ផ្លែឈូកទនឹងក្អមធ្វើដោយដីស្ងួត (ដូចក្អមធមិយភិក្ខុ) ។

ចប់ខុទ្ទកវត្ថុក្ខន្ធកៈ ជាគំរប់ ៥ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## តស្សុទ្ទានំ

(៣០៧) រុក្ខេ ជម្ភេ ច កុច្ឆេ ច

អដ្ឋាឆេ គន្ធសុត្តិយា

វិត្តយ្ហ មល្លកោ កាចុ

ជគ ច បុថុចាណិកា

វល្លិកាបិច ចាមដ្ឋោ

កណ្ឌសុត្តំ ច ជារយេ

តជិ ឱរដ្ឋិ កាយុរំ

ហត្ថាករណោមុទ្ទិកា

ធីយេ កោច្ចេ ជណោ ហត្ថេ

សិត្តា ឧទកតេលកោ

អាធាសុទបត្តវណា

អាលោចា មទ្ទុចុណ្ណចា

លញ្ចេដ្ឋិ អង្គភគញ្ញ

មុខភគំ តន្ទុកយិ

ចក្ខុភេគំ តិរក្ខញ្ញ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ខុទ្ទកវត្ថុក្ខន្ធកៈ ឧទ្ទានគាថា

### ឧទ្ទាន គឺបញ្ជីរឿងនៃខុទ្ទកវត្ថុក្ខន្ធកៈនោះដូច្នេះ

[៣០៧] រឿងភិក្ខុងូតទឹកត្រដុសកាយនឹងដើមឈើ នឹងសសរ នឹងជញ្ជាំង តាំងងូតទឹកក្នុងទីមិនសមគួរ ងូតទឹកដុសខ្លួនដោយឈើដែលគេធ្វើជាដៃគន្ធព្វ ងូតទឹកដុសដោយលំអិតឬឈ្មោះកុរុវិន្ទកសុត្តិ ងូតទឹកត្រដុសគ្នាទៅវិញទៅមក ងូតទឹកដោយឈើមានសណ្ឋានដូចជើងកន្ធោរ ១ រឿងភិក្ខុកើតកមរមាស់ នឹងភិក្ខុជរា ទ្រង់អនុញ្ញាតឲ្យដុសខ្លួនដោយបាតដៃបាន ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុទ្រទ្រង់ប្រដាប់ត្រចៀក សង្វារប្រដាប់ក ប្រដាប់ចង្កេះ កងប្រដាប់ដើមដៃ ប្រដាប់ដៃ នឹងចិញ្ចៀន ១ រឿងភិក្ខុទុកសក់វែង សិតសក់ដោយស្និត សិតសក់ដោយក្រាស សិតសក់ដោយដៃ សិតសក់ដោយក្រមួន លាបសក់ដោយប្រេង លាយដោយទឹក ១ រឿងភិក្ខុឆ្លុះមុខក្នុងកញ្ចក់ ក្នុងភាជន៍ទឹក ១ រឿងភិក្ខុកើតដំបៅមុខ លាបមុខ ផាត់មុខ ប្រស់មុខ ចុចមុខ លាបអវយវៈ លាបមុខនឹងលាបទាំងអវយវៈទាំងមុខ ១ រឿងភិក្ខុកើតរោគភ្នែក ១ រឿងមហោស្រពលើកំពូលភ្នំ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



រាឃន្តំ សរេ ពាភេរិ

អដ្ឋមេ ឃំសកលោមំ

អហិ និដ្ឋំ ច ចដ្ឋំ

ឧច្ចាវចា បត្តមូលា

សុវណ្ណា (១) ពហុលា វលី

ចិត្រា ទុស្សតិ ទុក្ខោ

ឧណ្ហោ ភិជ្ជិសុ មិលិយរ

បរិកណ្ឌំ តិណំ ចោឡំ

មាឡេ (២) កុណ្ឌលិកាយ ច

ថវិកា អំសវទ្ធកោ

តថា ពន្ធនសុត្តកា

ខីលំ មញ្ចេ ច ពីឋេ ច

១ ឱ. ម. សុវណ្ណោ ។ ២ ឱ. ម. ហឡ្យំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងភិក្ខុប្រៀនធម៌ដោយសំឡេងវែង ១ រឿងភិក្ខុមានសេចក្តីរង្កៀស នឹងសូត្រជាបទសរភញ្ញ ១ រឿងភិក្ខុទ្រទ្រង់សំពត់ដែលធ្វើដោយរោមសត្វ មានរោមចេញមកខាងក្រៅ ១ រឿងអនុញ្ញាតបំណិតស្វាយ ១ រឿងពួកជននាំយកផ្លែស្វាយទាំងមូលទៅក្នុងរោងភត្ត ១ រឿងភិក្ខុពស់ចឹក ១ រឿងភិក្ខុកាត់អង្គជាតរបស់ខ្លួន ១ រឿងបាត្រខ្លឹមចន្ទន៍ ១ រឿងភិក្ខុប្រើបាត្រខ្ពស់នឹងទាប ១ រឿងផ្ទៃបាត្រសឹករិលព្រោះគ្មានជើង ១ រឿងបញ្ញត្តជើងបាត្រធ្វើដោយមាសនិងប្រាក់ ១ រឿងជើងបាត្រក្រាសពេក ១ រឿងលួសកើតឡើងដល់ភិក្ខុ ១ រឿងភិក្ខុប្រើជើងបាត្រវិចិត្រផ្សេងៗ ១ រឿងភិក្ខុទុកបាត្រទាំងទទឹក បាត្រក៏ខូចទៅ ១ រឿងបាត្រធុំក្លិនអាក្រក់ ១ រឿងភិក្ខុទុកបាត្រក្នុងទីក្តៅ បាត្រមៀលបាក់បែក ១ រឿងភិក្ខុទុកបាត្រក្នុងទីបំផុតនៃក្តារតាំង ទុកបាត្រក្នុងទីបំផុតនៃថ្នាក់ ១ រឿងអនុញ្ញាតកម្រាលស្មៅ អនុញ្ញាតកំណាត់សំពត់ អនុញ្ញាតរោងទុកបាត្រ អនុញ្ញាតថង់សម្រាប់ទុកបាត្រ អនុញ្ញាតស្លោកបាត្រ យោគបាត្រ និងខ្សែសម្រាប់ចងបាត្រ ១ រឿងភិក្ខុព្យួរបាត្រនឹងចំរឹងជញ្ជាំង ទុកបាត្រលើគ្រែនិងតាំង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ខុទ្ទកវត្ថុក្ខន្ធកេ ខគ្គគាថា

អដ្ឋោ ឆត្តោ បណាមតា (១)

តុម្ហយដិជរសីសំ

ចលគាធិ បធិក្កហោ

វិជាលិឧណ្ហាសោវណ្ណំ

បត្តោ បេសិ ច ឆាឡិកា

កំណ្ណា សត្ថុ សរិតញ្ញុ

មនុសិត្ថំ សិថាជិតំ

វិភោណ្ណំ ពន្ធិ វិសមំ

ឆមា ជិរប្បហោតិ ច

កេឡិត្ថំ មោឃសុត្តញ្ញុ

អនោតល្លំ ឧទាហាណា

---

១ ខ. បណាមិតា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដាក់បាត្រលើភ្លៅ ទុកបាត្រក្នុងឆត្រ ទឹងមានបាត្រក្នុងដៃច្រាន សន្ទះទ្វារ ១ រឿងភិក្ខុត្រាច់ទៅបិណ្ឌបាតដោយសំបកឃ្លោក ដោយអំបែងឆ្នាំង ១ រឿងភិក្ខុប្រើបាត្រក្បាលខ្មោច ១ រឿងភិក្ខុយកបាត្រទៅដាក់កាកអាមិសៈ ហើយយកទៅចាក់ចោល ទ្រង់អនុញ្ញាតកន្ទោរ ១ រឿងភិក្ខុហែកចីវរដោយដៃ ១ រឿងកាំបិតមានដង កើតឡើងដល់សង្ឃ ភិក្ខុប្រើដងកាំបិតធ្វើដោយមាសជា(ដើម) ១ រឿងភិក្ខុដេរចីវរដោយស្លាបមាន់ ទឹងបំរៀកឫស្សី ទ្រង់អនុញ្ញាតបំពង់ម្ជុល អនុញ្ញាតឲ្យយកលំអិតពូជសុព (ដំបែ) ប្រកក្នុងបំពង់ម្ជុល អនុញ្ញាតឲ្យយកលំអិតម្សៅលាយដោយរមៀត ឲ្យយកលំអិតថ្មប្រកក្នុងបំពង់ម្ជុល ក្រមួនឃ្មុំ ទឹងស្រោមលំអិតថ្ម ១ រឿងៈដេរចីវរមានមុំមិនស្មើគ្នា ទ្រង់អនុញ្ញាតឈើស្ទឹង ទឹងខ្សែស្ទឹងឲ្យភិក្ខុចងដេរចីវរ ១ រឿងភិក្ខុលាឈើស្ទឹងក្នុងទីមិនរាបទាប ភិក្ខុក្រាលឬលាឈើស្ទឹងលើផែនដី ឈើស្ទឹងរេចរិលត្រង់ជាយជុំវិញ ១ រឿងអនុញ្ញាតខ្នាតសម្រាប់វាស់ចីវរ ទឹងខ្សែបន្ទាត់ ១ រឿងភិក្ខុមិនលាងជើងហើយជាន់លើឈើស្ទឹង ភិក្ខុពាក់ស្បែកជើងជាន់លើ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អង្កុលេ បដិគ្គហញ្ច
អាវេសនញ្ច វិត្ថតំ
បដិគ្គហត្ថវិកញ្ច
អំសសុត្តំ ច ពន្ធកា (១)
អជ្ឈោកាសេ ឆីចវគ្គុ
ចយោ ឆាបិ វិហាញ្ញារេ
បរិបតំ តិណចុណ្ណំ
ឧល្លិត្តញ្ចាវលិត្តកំ
សេតំ កាឡកវណ្ណញ្ច
បរិកម្មញ្ច គេរុកំ
មាលាកម្មំ លតាកម្មំ
មករទន្តថាដិកំ (២)
ចីវរំសិ រជ្ជុញ្ច
អនុញ្ញាសិ វិនាយកោ ។
ឧជ្ឈិត្វា បក្កមន្តិ ច

១ ម. អង្គុលេ បដិគ្គហញ្ច វិត្ថកំ ថវិកពន្ធកា ។ ២ ឱ.ម. មករទន្តកំ បាដិកា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឈើស្ទឹង ១ រឿងភិក្ខុឈឺម្រាមដៃ ព្រោះដេរចីវរ ទ្រង់អនុញ្ញាត ស្នាប់ម្រាមដៃដេរ ប្រអប់សម្រាប់ដាក់ម្ជុលកាំបិត ស្នាប់ម្រាមដៃដេរ ថង់សម្រាប់ដាក់ស្នាប់ម្រាមដៃដេរ ខ្សែយោគនឹងខ្សែថង់ ១ រឿងភិក្ខុដេរចីវរក្នុងទីវាល កេងសម្រាប់ដាក់ឈើស្ទឹង មានទីដីទាប ១ រឿងខ្មៀនបាក់ហុះឡើងទៅ ភិក្ខុលំបាកឡើងខ្មៀនដែលគ្មានជណ្តើរ ភិក្ខុជួលធ្លាក់ដោយឡើងជណ្តើរ កំទេចស្មៅធ្លាក់ចុះក្នុងកេងឈើស្ទឹង ទ្រង់អនុញ្ញាតឱ្យបូកលាបដីបូលទាំងក្នុងទាំងក្រៅ ធ្វើឱ្យមានពណ៌ស ពណ៌ខ្មៅនឹងបរិកម្មដោយរេង ទ្រង់អនុញ្ញាតឱ្យធ្វើក្បាច់ផ្កា ភិវល្លិ ក្បាច់ធ្មេញមករ ក្បាច់អានស្រពាប់ព្រំ ទាំងអនុញ្ញាតស្នប់ចីវរ នឹងខ្សែស្បៀង១។ រឿងភិក្ខុទោលឈើស្ទឹងហើយចៀសចេញទៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកេ ឧទ្ទានគាថា

កឋិនំ បរិភិជ្ជតិ
វិនិវេឋិយតិ កុឌ្ឌេ (១)
បត្តេ ឈាឈាយ កច្ឆេ
ថវិកា ពន្ធសុត្តកំ (២)
ពន្ធិត្វា ច ឧចាវចា
ឧចាវចត្តរិកញ្ច
អំសវទ្ធញ្ច សុត្តកំ (៣)
ឧទកាកប្បិយំ មគ្គេ
បរិស្សាវនចោឡកំ
ធម្មករកំ(៤) ទ្វេ ភិក្ខូ
វេសាលី អគមា មុនិ
ទណ្ឌំ ឱត្ថរិកំ តត្ថ-
នុញ្ញាសិ(៥) បរិស្សាវនំ ។
មកសេហិ បណីតេន
ពហ្វាពាធា ច ជីវកោ
ចង្កមនជន្តាឃរំ

១ ឱ. ម. វិនិវេឋិយ កុឌ្ឌេបិ ។ ២ ឱ. ម. ពន្ធសុត្តកំ ។ ៣ អយំ ឱ. ម. ពោត្ថកេសុ ន ទិស្សតិ ។ ៤ ឱ. ធម្មករកោ ។ ម. ធម្មករណោ ។ ៥ ឱ. ទណ្ឌឱត្ថរកំ តត្ថ អនុញ្ញាសិ ។ ម. ទណ្ឌ ឱត្ថរណំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឈើស្ដឹងវិនាសខូចទៅ ភិក្ខុមូរឈើស្ដឹង ៗ ចេះតែលោះចេញ ភិក្ខុផ្អែកឈើស្ដឹងនឹងជញ្ជាំង ភិក្ខុយកបាត្រដាក់ម្ជុល កាំបិត នឹងថ្នាំហើយដើរទៅ អនុញ្ញាតថង់សម្រាប់ដាក់ថ្នាំ នឹងខ្សែថង់ ១ រឿងភិក្ខុចងស្បែកជើងនឹងវត្ថពន្ធចង្កេះ អនុញ្ញាតថង់សម្រាប់ដាក់ស្បែកជើង ខ្សែយោគនឹងខ្សែថង់ ១ រឿងទឹកជាអកប្បិយៈមានកណ្ដាលផ្លូវ អនុញ្ញាតសំពត់តម្រងទឹកនឹងធម្មក្រក ១ រឿងភិក្ខុពីររូបដើរផ្លូវឆ្ងាយ ១ រឿងព្រះមហាមុនីយាងទៅកាន់ក្រុងវេសាលី អនុញ្ញាតសំពត់តម្រងទឹកដែលមានដងនឹងសំពត់តម្រងត្រាំ ក្នុងក្រុងវេសាលីនោះ ១ ៗ រឿងភិក្ខុមានមូសខាំ ភិក្ខុមានអាពាធច្រើន ព្រោះឆាន់បណីតភោជន ១ រឿងជីវកកោមារភច្ច ១ រឿងអនុញ្ញាតចង្ក្រមនឹងរោងភ្លើង ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



វិសមេ ចីចវត្ថុកោ
តយោ ចយេ វិហាញ្ញិ
សោបាណាលម្ពវេទិកំ
អជ្ឈោកាសេ តិណចុណ្ណំ
ឧល្លិត្តញ្ចាវលិត្តកំ (១)
សេតកំ កាឡវណ្ណញ្ច
បរិកម្មញ្ច គេរុកំ
មាលាកម្មំ លតាកម្មំ
មករទន្តបដិកំ(២)
វំសំ ចីវររជ្ជុញ្ច
ឧច្ចំ(៣) ច វត្ថុកំ ការេ
ចយោ សោបាណពាហញ្ច
កាចំ បិដ្ឋសង្ឃាដំ
ឧទុក្ខលុគ្គរបាសកំ
វដ្ដញ្ច កបិសីសកំ
សូចិឃដិតាលឆិទ្ទំ

---

១ ឱ. ម. ឧល្លិត្តាវលិត្តកំ ។ ២ ឱ. មករវត្តកបដិកំ ។ ម. មការវត្តកបដិកំ ។ ៣ ឱ. ម. ឧច្ចា ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



រឿងភិក្ខុចង្ក្រមក្នុងទីចង្ក្រមមិនស្មើ ទីចង្ក្រមមានទីដ៏ទាប ទ្រង់អនុញ្ញាតខឿន ៣ យ៉ាង ពួកភិក្ខុលំបាកនឹងឡើង ព្រោះគ្មានជណ្តើរ ទ្រង់អនុញ្ញាតជណ្តើរ និងបង្កាន់ដៃ និងដៃរាវនៃទីចង្ក្រម ១ រឿងភិក្ខុចង្ក្រមក្នុងទីវាល កំទេចស្មៅធ្លាក់ចុះក្នុងរោងចង្ក្រម ទ្រង់អនុញ្ញាតឲ្យបូកលាបទាំងក្នុងទាំងក្រៅ ទ្រង់អនុញ្ញាតថ្នាំមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង៌ ធ្វើក្បាច់ភ្ញីផ្កា ក្រវិល ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់ប្រាំ ស្នូរចីវរនិងខ្សែស្បៀង ១ រឿងអនុញ្ញាតឲ្យធ្វើទីដ៏រោងភ្លើងឲ្យខ្ពស់ឡើង ខឿនជណ្តើរនិងបង្កាន់ដៃជណ្តើរ សន្ទះទ្វារ រោងភ្លើង គ្រប់ទ្វារក្បាល (ជំណាប់ក្រោម) អន្ទាក់ខាងលើ (ជំណាប់លើថ្កឡោះ) សសរនៃសន្ទះទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឹះទ្វារ មេសោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ខុទ្ទកវត្ថុក្ខន្ធកេ ឧទ្ទានគាថា

អាវិញ្ឆនញ្ច រជ្ជុកំ
មណ្ឌលំ ធម្មនេត្តញ្ច
មជ្ឈេ ច មុទមត្តិកា
លោណិ ធុក្កត្វា ច ឧហតិ
ឧទបានំ(១) សរាវកំ
ន សេធេតិ ច ចិក្ខល្លំ
ដោរិ និទ្ធមនំ ការេ
បីឋញ្ច កោដ្ឋកេ កម្មំ
មរុម្ពា សិលនិទ្ធមំ(២)
នត្តា ចមាយំ វស្សន្តេ
បដិច្ឆាទី តយោ តហឹ
ឧទបានំ លុជ្ជតិ ច
វល្លិយា កាយពន្ធនេ
តុលំ ការកាដំ ចក្កំ
ពហូ ភិជ្ជន្តិ ភាជនា

---

១ ឱ. ទុគ្គន្ធោ ច ទហេតិ ច ឧទកាតរ សរាវកំ ។ ២ ឱ. ម. សិលនិទ្ធមតា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សមថក្ខន្ធកៈ ការសំដែងអាបត្តិ

ប្រហោងសម្រាប់បិទបើក ខ្សែទាញបិទបើក ទ្រង់អនុញ្ញាតឲ្យធ្វើមណ្ឌល គឺ ដីឲ្យទាបជុំវិញរោងភ្លើង បំពង់ផ្សែង (បំពង់ភ្លើង) ១ រឿងភិក្ខុធ្វើចង្ក្រានពាក់កណ្តាលរោងភ្លើងតូច អនុញ្ញាតដីលាបមុខ ទាំងអនុញ្ញាតស្នូកសម្រាប់លាយដីស្អិត ដីជំខ្លួនអាក្រក់ ១ រឿងភ្លើងលោកភិក្ខុ ១ រឿងអនុញ្ញាតគាងទឹក ទីងផ្តិលទឹក ១ រឿងជម្ពូលស្មៅមិនមានចំហាយញើស ១ រឿងរោងភ្លើងមានភក់ជ្រាំ ១ រឿងអនុញ្ញាតឲ្យលាងក្រាលរោងភ្លើងទីងធ្វើឲ្យទទឹក ១ រឿងអនុញ្ញាតតាំងសម្រាប់រោងភ្លើង ១ រឿងអនុញ្ញាតបន្ទប់ទឹកទីងកំពូការក្នុងរោងភ្លើង ១ រឿងអនុញ្ញាតឲ្យរោយក្រួសរាប អនុញ្ញាតក្រាលថ្ម ទីងទទឹក ១ រឿងភិក្ខុអាក្រាតសំពះគ្នា ១ រឿងភិក្ខុដាក់ចីវរលើផែនដី ភ្លៀងទទឹកចីវរ ១ រឿងអនុញ្ញាតគ្រឿងបិទបាំងកាយបីយ៉ាង ១ រឿងទឹកមិនមានក្នុងរោងភ្លើងនោះ អនុញ្ញាតអណ្តូងទឹក មាត់អណ្តូងទឹក បាក់រលុះរលាយ ភិក្ខុយោងទឹកដោយវល្លិខ្លះ ដោយវត្ថុពន្ធការឆ្អិះខ្លះ អនុញ្ញាតថ្នឹងសម្រាប់យោងទឹក យន្តសម្រាប់ទាញទឹក ទីងហោតទឹក ១ រឿងភាជន៍បែកជាច្រើន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លោហនាវុចម្មខណ្ឌំ

សាលា តិណាបិជាតិ ច

ទោណិ ចន្ទនិ បាការ

ចិក្ខល្លំ និទ្ធមេន ច

សីតិកាតំ ពោក្ខរណី

បុរាណាញ្ច និល្លេខតំ

ចតុន្នាសំ សយន្តិ ច

កទ្ធុបុប្ផំ នធិជ្ឈហោ[1]

អាសិត្តកមឡោរិកំ

កុញ្ជុព្ពេតិ តុវដ្ដយុំ

វេឡុក ពោធិ ច អក្កមិ

១ ឱ. ម. នមគកញ្ញ នធិជ្ឈហេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

បំពង់លោហៈបំពង់ឈើ ទឹងចម្ពុះណ្ណ ១ រឿងអនុញ្ញាតសាលា ជិតអណ្តូងទឹក កំទេចស្មៅធ្លាក់ចុះក្នុងសាលា អនុញ្ញាតគ្រប អណ្តូងទឹក ស្នូកទឹក អណ្តូងជ្រាំ ទីងកំពែង ៣ យ៉ាង ១ រឿង អណ្តូងជ្រាំមានភក់អនុញ្ញាតឲ្យបង្ហូរទឹក ១ រឿងភិក្ខុមានកាយ រងា ១ រឿងឧបាសកជីកស្រះបោក្ខរណី ទឹកដក់នៅយូរក្នុង ស្រះបោក្ខរណី ១ រឿងឧបាសកបង់រោងភ្លើងមានជហ្វាជង ក្តារ ១ រឿងភិក្ខុនៅប្រាសចាកសំពត់និសីទនៈ ៤ ខែ ១ រឿងភិក្ខុដេកនៅលើទីដំណេក ដែលគេរោយដោយផ្កា ពួក មនុស្សនាំយកគ្រឿងក្រអូប ទីងផ្កាកម្រងមកកាន់អារាម ១ រឿងទ្រង់ហាមមិនឲ្យអធិដ្ឋានសំពត់ស្លាប់ ដោយរោមចៀម ១ រឿងភិក្ខុឆាន់លើគុម្ពថាស អនុញ្ញាតភាជន៍ឈើសម្រាប់តម្កល់ បាត្រ ១ រឿងភិក្ខុឆាន់ ក្នុងភាជន៍ជាមួយគ្នា ដេកលើគ្រែ ជាមួយគ្នា លើកម្រាលជាមួយគ្នា ១ រឿងវឌ្ឍលិច្ឆវី ១ រឿង ពោធិរាជកុមារ ១ រឿងមិនទ្រង់ជាន់លើកម្រាលសំពត់ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឃដឹ កតកសម្មជ្ជនី
សក្ខរំ កឋលញ្ចេវ
ផេណកំ បាទឃំសនី
វិធូបនំ តាលវណ្ដំ
មកសព្យាបិ ចាមរី
ឆត្តំ វិនា ច អារាមេ
តយោ សិក្កាយ សម្មតិ
រោមា សិត្ថា នខា ទីឃា
ឆិន្ទន្តង្គុលិកា ទុក្ខា
សលោហិតំ បមាណញ្ច
វីសតិ ទីឃកេសតា
ខុរំ សិលំ សិបាដិកំ
នមតំ(១) ខុរភណ្ឌកំ
មស្សុំ កប្បេន្តិ វឌ្ឍេន្តិ
គោលោមិ ចតុរស្សកំ

---

១ ឱ. ម. នមតកំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកៈ ឧទ្ទានគាថា

រឿងនាងវិសាខានាំយកក្អម និងច្រទាប់សម្រាប់ជូតជើង ដែលមានពកកនិងអំបោស ទ្រង់អនុញ្ញាតច្រទាប់សម្រាប់ជូតជើង ៣ យ៉ាង គឺ ច្រទាប់ថ្ម ក្បឿង ប្ញុសផែងនិងច្រទាប់ផ្សិតសមុទ្រ រឿងនាងវិសាខានាំយកផ្លិតបួនជ្រុងនិងផ្លិតមូលទៅថ្វាយព្រះមានព្រះភាគ ១ រឿងផ្លិតបក់មូសកើតឡើងដល់សង្ឃ ទ្រង់ហាមមិនឲ្យភិក្ខុប្រើប្រាស់ផ្លិតចាមរី ១ រឿងភិក្ខុឈឺតែខានបាំងឆត្រមិនសប្បាយ និងភិក្ខុស្ដៀសនឹងបាំងឆត្រក្នុងអារាម ១ រឿងអនុញ្ញាតសិក្ខាសម្មតិដល់ភិក្ខុ ៣ រូប រឿងភិក្ខុចំពារអៀង ១ រឿងគ្រាប់បាយ ធ្លាក់រាត់រាយក្នុងរោងភត្ត រឿងភិក្ខុមានក្រចកវែង ភិក្ខុកាត់ក្រចកដោយក្រចក ភិក្ខុត្រដុសក្រចកនឹងធ្មេញ ម្រាមដៃឈឺចាប់ ភិក្ខុកាត់ក្រចក ត្រាតែចេញឈាម ទ្រង់អនុញ្ញាតឲ្យកាត់ក្រចកស្មើនឹងសាច់ ១ រឿងភិក្ខុដុសខាត់ក្រចកទាំងម្ភៃ ១ រឿងភិក្ខុទុកសក់វែង អនុញ្ញាតកាំបិតកោរ ថ្មសំលៀងកាំបិតកោរ ស្រោមកាំបិតកោរគ្រឿងស្នាប់ធ្វើដោយរោមចៀម និងគ្រឿងប្រដាប់កាំបិតកោរទាំងអស់ ១ រឿងភិក្ខុកោរពុកមាត់ ទុកពុកមាត់ ទុកពុកចង្កាឲ្យវែងដូចជាពុកចង្កាពពែ ទុកពុកមាត់ឲ្យមានជ្រុង ៤

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បរិសុទ្ធំ អន្តរាគតញ្ច

ឆាបិ សម្មាជសំហារេ

អាតាជា គរត្តរិ វលោហា

ឆឹឃំ សត្ថារិកាយ ច

បលិតំ ជតិតំ ឧទ្ធា

លោហភណ្ឌញ្ជនី សហ

បល្លត្ថិកញ្ច អាយោគោ

វដ្ដំ ច កាយពន្ធនំ

កលាពុកំ ទេឌ្ឌុភកំ

មុរជំ មទ្ទវីណកំ

បដ្ដិកា សូករន្តញ្ច

ទសា មុរជវេណិកា

អន្តោ សោភកុណកញ្ច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ប្រមូលផ្ដុំរោមត្រង់ដើមច្រមុះ ទុកផ្ដុំរោមត្រង់ពោះ ទុកពុកមាត់ដូចចង្កូម ១ រឿងទ្រង់អនុញ្ញាតឲ្យដករោមក្នុងទីចង្អៀតដោយមានអាពាធជាហេតុ ១ រឿងភិក្ខុកាត់សក់ដោយកន្ត្រៃ រឿងភិក្ខុកើតដំបៅក្បាល ១ រឿងភិក្ខុទុករោមច្រមុះវែង ភិក្ខុឲ្យគេដករោមច្រមុះដោយក្រួស ភិក្ខុឲ្យគេដកសក់ស្កូវ ១ រឿងភិក្ខុថ្ពង់ ឆព្វគ្គិយភិក្ខុប្រើចង្កៀលត្រចៀកខ្ពប់មិនពាប ភិក្ខុសន្សំទុកគ្រឿងលោហៈជាច្រើន ១ រឿងភិក្ខុស្លៀកសទឹងបង់ចង្កឹកាត់ដាក់ថ្នាំសម្រាប់លាបភ្នែក ១ រឿងភិក្ខុអង្គុយត្រដាមក្បាលជង្គង់ទាំងសង្ឃាដិ ១ រឿងភិក្ខុសង្ស័យមិនសំពត់អាយោគ ទ្រង់អនុញ្ញាតក្ដារម្ជូរសម្រាប់ធ្វើសំពត់អាយោគ ១ ទ្រង់អនុញ្ញាតកាយពន្ធ ភិក្ខុប្រើកាយពន្ធមានខ្សែច្រើន មានសណ្ឋានដូចក្បាលពស់ទឹក មានសណ្ឋានដូចខ្សែស្មោរ ទឹងមានសណ្ឋានដូចសង្វារ ទ្រង់អនុញ្ញាតកាយពន្ធពីរយ៉ាង គឺសំពត់ផ្ទាំងមួយ សំពត់ដូចពោះវៀនជ្រូកមួយ រឿងជាយកាយពន្ធរេច ទ្រង់អនុញ្ញាតកាយពន្ធមានសណ្ឋានដូចខ្សែតែស្មោរ ទឹងមានសណ្ឋានដូចសង្វារ រឿងរឹមកាយពន្ធរេច ទ្រង់អនុញ្ញាតឲ្យដេរលើ ទឹងដេរឲ្យមានគាកាដូចក្ដៃផ្សួយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកេ ឧទ្ទានគាថា

បវេឆ្តាបិ ជីរតិ
គណ្ឋិកា ឧក្កាវចញ្ចូ
ផលកាឆេត្តិបិ ឱកេហោ
តិហាវត្ថុ សោណ្ណំ មជ្ជ
វាឡ្យកំ ចតុក្កណ្ណកំ
តាលវណ្តំ សតវស្សេ
តិហិ ធារុតធារុបំ
សំវេល្លិ ឧកតោកាជិ
ទន្តកដ្ឋាភិកោដនេ(១)
កណ្ណេ វិលគ្គំ នាយញ្ច
បដគ្គិ រុក្ខាហត្ថិធា
សកដ្តេ(២) លោកាយតកំ
បរិយាបុណឹសុ វាចយុំ
តិរច្ឆានកថា វិជ្ជា
ខិបិ មង្គលំ ខាទិ ច
វាតាពាធោ ទុស្សតិ ច

---

១ ឱ. ទន្តកដ្ឋំ អាកោដិតេ ។ ម. ទន្តកដ្ឋំ អាកោដិតោ ។ ២ ឱ. ម. យមេឡេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកៈ ឧទ្ទានគាថា

រឿងអ្នកកាយពន្ធរេចនឹងរឿងភិក្ខុប្រើខ្សែក្តុំខ្ពស់និងទាប ១ រឿងភិក្ខុដេរច្រនាប់ខ្សែ ច្រនាប់អន្ទាក់ក្នុងទីបំផុតនៃចីវរ ច្រង់អន្ទាក់ឲ្យជាក់ច្រនាប់អន្ទាក់លូកចូលទៅខាងក្នុង ១ រឿងភិក្ខុស្លៀកស្បង់ដូចគ្រហស្ថ ស្លៀកស្បង់ស្រុយមុខ ដូចប្រមោយដំរី ស្លៀកមានសណ្ឋានដូចកន្ទុយត្រី ស្លៀកបន្ទិចជ្រុងស្បង់ទាំង ៤ ឲ្យប្រាកដ ស្លៀកដោយអាការដូចកំពូលត្នោត ស្លៀកអង្រ្កញ់ឲ្យមានផ្នត់ច្រើន ដណ្តប់ដូចគ្រហស្ថ និងស្លៀកចងក្បិន ១ រឿងភិក្ខុរែក ១ រឿងភិក្ខុមិនទំពាឈើស្ទន់ ភិក្ខុគោះហាមណេរដោយឈើស្ទន់ ភិក្ខុទំពាឈើស្ទន់ខ្លីពេក ឈើស្ទន់ក៏រប៉ូតចូលក្នុងបំពង់ក ១ រឿងភិក្ខុដុតព្រៃ ភិក្ខុរង្កៀសនឹងការដុតភ្លើងតទល់ ភិក្ខុរត់ឡើងដើមឈើព្រោះដំរីដេញ ១ រឿងភិក្ខុទូលសូមសូត្រពុទ្ធវចនៈជាភាសាសំស្រ្កឹត ភិក្ខុរៀនទាំងបង្រៀនគម្ពីរលោកាយតៈ និងភិក្ខុរៀនតិរច្ឆានវិជ្ជា ១ រឿងព្រះអង្គកណ្តាស រឿងអនុញ្ញាតឲ្យភិក្ខុឆ្លើយតបដើម្បីមង្គល រឿងភិក្ខុឆាន់ខ្ទឹម ១ រឿងព្រះសារីបុត្រអាពាធដោយខ្យល់ ១ រឿងភិក្ខុបន្ទោបង់បស្សាវៈក្នុងអាកម ១ ក៏មិនប្រោក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទុគ្គន្ធោ ទុក្ខបាទុកា
ហិរិយន្តិ បារុទុគ្គន្ធោ
តហំ តហំ ករោន្តិ ច
ទុគ្គន្ធោ កូបំ លុជ្ជតិ
ឧច្ចវត្ថុ ចយេន ច
សោបាណាលម្ពនពាហា
អន្តោ ទុក្ខញ្ច បាទុកា
ពហិទ្ធា ទោណិ កដ្ឋញ្ច
បិឋរេ ច អបារុតោ
វច្ចកុដិ កវាដញ្ច
បិដ្ឋសង្ឃាដមេវ ច
ឧទុក្ខលុគ្គរបាសោ
វដ្ដិញ្ច កបិសីសកំ
សូចិឃដិតាលច្ឆិទ្ទំ
អាវិញ្ឆនច្ឆិទ្ទមេវ ច
វដ្ដុ ឧល្លិត្តាវលិត្តំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អារាមមានក្លិនអាក្រក់ ភិក្ខុលំបាកនឹងអង្គុយបន្ទោបង់បស្សាវៈ ទ្រង់អនុញ្ញាតទ្រនាប់ជើងសម្រាប់បន្ទោបង់បស្សាវៈ ភិក្ខុអៀនខ្មាស នឹងបន្ទោបង់បស្សាវៈ ឆ្នាំងបស្សាវៈមិនមានគ្រប មានក្លិនអាក្រក់ ភិក្ខុបន្ទោបង់វច្ចៈក្នុងទីពាសពាស អារាមមានក្លិនអាក្រក់ ទ្រង់អនុញ្ញាតឱ្យធ្វើរណ្ដៅវច្ចៈ ។ ជើងមាត់រណ្ដៅធ្លាក់រលុះ ទ្រង់អនុញ្ញាតឲ្យធ្វើទីដីទ្រខ្ពស់ឡើង មួយអន្ទើដោយខឿន ៣ យ៉ាង នឹងជណ្ដើរ បង្កាន់ដៃជណ្ដើរ ពួកភិក្ខុអង្គុយបន្ទោបង់វច្ចៈក្នុងទីបំផុតក៏ធ្លាក់ចុះ ភិក្ខុលំបាកនឹងអង្គុយបន្ទោបង់វច្ចៈ ទ្រង់អនុញ្ញាតទ្រនាប់ជើងសម្រាប់បន្ទោបង់វច្ចៈ ពួកភិក្ខុបន្ទោបង់បស្សាវៈខាងក្រៅ ទ្រង់អនុញ្ញាតស្នូកបស្សាវៈ ទ្រង់អនុញ្ញាតឈើខ្ទៀស នឹងត្រកសម្រាប់ដាក់ឈើខ្ទៀស រណ្ដៅវច្ចៈមិនមានគ្រប ។ ទ្រង់អនុញ្ញាតវច្ចកុដិ នឹងសន្ទះទ្វារ គ្របទ្វារ ក្បាល (ដំណាប់ក្រោម) អន្ទាក់លើ (ដំណាប់លើ) សសរទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឹះទ្វារ បេសោ ប្រហោងសម្រាប់ទាញ នឹងខ្សែសម្រាប់ទាញ ទ្រង់អនុញ្ញាតឲ្យបូកលាបវច្ចកុដិ ទាំងខាងក្នុងទាំងខាងក្រៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទកវត្ថុក្ខន្ធកេ ឧទ្ទានគាថា

សេតវណ្ណញ្ច កាឡកំ
មាលាកម្មំ លតាកម្មំ
មករំ បញ្ចបដិកំ
ចីវរវំសំ រជ្ជុញ្ច
ជភទុព្វលធាករំ
កោដ្ឋកេ ចាបិ តថេវ
មរុម្ពបធកសិលា
សន្ធិដ្ឋតិ និទ្ធមនំ
កុម្ភិញ្ចាបិ សភាវកំ
ធុក្ខិំ ហរី អបិធានំ
អាធាចារញ្ច អាចរុំ ។
លោហភណ្ឌំ អនុញ្ញាសិ
ឋបយិត្វា បភោរណំ ។
ឋបយិត្វាសន្ធឹ បល្លង្កំ
ធារុបត្តញ្ច ធាតុកំ
សព្វំ ធារុមយំ ភណ្ឌំ
អនុញ្ញាសិ មហាមុនិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ខុទ្ទកវត្ថុក្ខន្ធកៈ ខុទ្ទកកថា

ទឹងថ្នាំមានពណ៌ស ពណ៌ខ្មៅ ក្បាច់ក្រងផ្កា ក្បាច់ក្រីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់ប្រាំ ស្ពរចីវរ ខ្សែស្រៀង ១ រឿងភិក្ខុមានកំលាំងថយ ដោយដក អនុញ្ញាតកំពែង ៣ យ៉ាង អនុញ្ញាតបន្ទប់ទឹក ទឹងកំពែងជុំព័ទ្ធ អនុញ្ញាតឲ្យរោយក្រួសរនាប អនុញ្ញាតឲ្យក្រាលគម្រាលថ្ម ១ រឿងទឹកដក់នៅក្នុងបន្ទប់នោះ ទ្រង់អនុញ្ញាតទទឹក អនុញ្ញាតឆ្នាំងសម្រាប់ដាក់ទឹកជម្រះ អនុញ្ញាតផ្តិលសម្រាប់ជម្រះ ភិក្ខុលំបាកទឹងអង្គុយជម្រះ ភិក្ខុអៀនខ្មាសទឹងជម្រះ ទ្រង់អនុញ្ញាតគ្រប ១ រឿងភិក្ខុប្រព្រឹត្តអនាចារ ១ ៗ រឿងអនុញ្ញាតលោហកណ្ឋ លើកលែងតែលោហកណ្ឋដែលជាគ្រឿងប្រហារទាំងពួង ១ ៗ រឿងព្រះមហាមុនីទ្រង់អនុញ្ញាតគ្រែ វៀរលែងតែអាសន្ទិ ព្រះមហាមុនីទ្រង់អនុញ្ញាតគ្រឿងឈើទាំងអស់ វៀរលែងតែបាត្រឈើ ទឹងទ្រនាប់ជើងកៅ ១ ៗ

*ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ*
*ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។*



កតកំ កុម្ភការញ្ច
ឋបយិត្វា តថាគតោ
សព្វម្បិ មត្តិកាភណ្ឌំ
អនុញ្ញាសិ អនុកម្បកោ ។
យស្ស វត្ថុស្ស និទ្ទេសោ
បុរិមេន យទិ សមំ
តម្បិ សង្ខិត្តំ ឧទ្ទានេ
នយតោ តំ វិជានិយា ។
ឯវំ ទសសតា វត្ថូ
វិនយេ ខុទ្ទកវត្ថុកេ
សទ្ធម្មដ្ឋិតិកោ ចេវ
បេសលានញ្ចនុគ្គហោ
សុសិក្ខិតោ វិនយធរោ
ហិតចិត្តោ សុបេសលោ
បទីបករណោ ធីរោ
បូជារហោ ពហុស្សុតោតិ ។

---

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងព្រះតថាគតមានសេចក្តីអនុគ្រោះច្រើនអនុញ្ញាតគ្រឿងដំតាំងពួង រឿងលេងតែច្រនាប់សម្រាប់ដូតជើង ដែលគេធ្វើមានពកឡើង ទីងកុដិធ្វើដោយដីសុទ្ធ១ ។ កិរិយាសំដែងចេញនូវវត្តណា វត្តនោះដូចគ្នានឹងវត្តមុនដែល យើងបានពោលទុកដោយសង្ខេបក្នុងឧទ្ទាន អ្នកប្រាជ្ញគប្បីដឹងនូវវត្តនោះតាមន័យ ( សមគួរចុះ ) ។ អ្នកប្រាជ្ញជាវិន័យធរ មានចិត្តប្រកបដោយប្រយោជន៍ មានសីលជាទីស្រឡាញ់ដោយប្រពៃ អ្នកធ្វើនូវប្រទីបគឺព្រះសទ្ធម្ម គួរដល់ការបូជា ជាពហុស្សូតជាអ្នកញុំាងព្រះសទ្ធម្មឲ្យតាំងនៅមាំផង ជាអ្នកអនុគ្រោះដល់ភិក្ខុមានសីលជាទីស្រឡាញ់ទាំងឡាយផង បានសិក្សាហើយដោយប្រពៃ នូវវត្ថុមានចំនួន ១១០ ក្នុងខុទ្ទកវត្ថុក្ខកៈក្នុងព្រះវិន័យ ដោយប្រការដូច្នេះហោង ។

---

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សេនាសនក្ខន្ធកំ

(៣០៨) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ភគវតា ភិក្ខូនំ សេនាសនំ អប្បញ្ញត្តំ ហោតិ ។ តេ ច(១) ភិក្ខូ តហំ តហំ វិហរន្តិ អរញ្ញេ រុក្ខមូលេ បព្វតេ កន្ទរាយំ គិរិគុហាយំ សុសានេ វនបត្ថេ អជ្ឈោកាសេ បលាលបុញ្ជេ ។ តេ កាលស្សេវ តតោ តតោ ឧបនិក្ខមន្តិ អរញ្ញា រុក្ខមូលា បព្វតា កន្ទរា គិរិគុហា សុសានា វនបត្ថា អជ្ឈោកាសា បលាលបុញ្ជា បាសាទិកេន អភិក្កន្តេន បដិក្កន្តេន អាលោកិតេន វិលោកិតេន សម្មិញ្ជិតេន បសារិតេន ឱក្ខិត្តចក្ខូ ឥរិយាបថសម្បន្នា ។

(៣០៩) តេន ខោ បន សមយេន រាជគហកោ សេដ្ឋី កាលស្សេវ ឧយ្យានំ អគមាសិ ។ អទ្ទសា ខោ រាជគហកោ សេដ្ឋី តេ ភិក្ខូ កាលស្សេវ តតោ តតោ ឧបនិក្ខមន្តេ អរញ្ញា រុក្ខមូលា បព្វតា កន្ទរា គិរិគុហា សុសានា វនបត្ថា អជ្ឈោកាសា

១ ម. តេធ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សេនាសនក្ខន្ធកៈ

(៣០៨) សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមានព្រះភាគមិនទាន់បានបញ្ញត្តសេនាសនៈ ដល់ពួកភិក្ខុនៅឡើយ ។ ភិក្ខុទាំងនោះ ក៏នៅក្នុងទីនោះ ៗ គឺ ព្រៃ គល់ឈើ ភ្នំ ជ្រក គុហាទៀបភ្នំ ព្រៃស្មសាន ព្រៃធំ ទីកណ្ដាលវាល នឹងគំនរចំបើង ។ លុះព្រលឹមឡើង ភិក្ខុទាំងនោះដើរចេញអំពីទីនោះ ៗ គឺ ព្រៃ គល់ឈើ ភ្នំ ជ្រក គុហាទៀបភ្នំ ព្រៃស្មសាន ព្រៃធំ ទីកណ្ដាលវាល នឹងគំនរចំបើង សឹងមានចក្ខុសំឡឹងចុះ បរិបូណ៌ដោយឥរិយាបថ គឺឈានទៅមុខ ថយក្រោយ ក្រឡេកស្ដាំ ក្រឡេកឆ្វេង បត់ចូល លាចេញ គួរឲ្យកើតសេចក្ដីជ្រះថ្លា ។

(៣០៩) គ្រានោះឯង រាជគហសេដ្ឋីបានទៅឧទ្យានអំពីព្រលឹម ។ រាជគហសេដ្ឋីក៏បានឃើញភិក្ខុទាំងនោះ កំពុងនិមន្តចេញពីទីនោះ ៗ គឺព្រៃ គល់ឈើ ភ្នំ ជ្រក គុហាទៀបភ្នំ ព្រៃស្មសាន ព្រៃធំ ទីកណ្ដាលវាល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



បលាលបុញ្ជា បាសាទិកេន អភិក្កន្តេន បដិក្កន្តេន អាលោកិតេន វិលោកិតេន សម្មិញ្ជិតេន បសារិតេន ឱក្ខិត្តចក្ខូ ឥរិយាបថសម្បន្នា ។ ទិស្វានស្ស ចិត្តំ បសីទិ ។ អថខោ រាជគហកោ សេដ្ឋី យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច សចាហំ ភន្តេ វិហារេ ការាបេយ្យំ វសេយ្យាថ មេ វិហារេសូតិ ។ ន ខោ គហបតិ ភគវតា វិហារោ អនុញ្ញាតោតិ ។ តេនហិ ភន្តេ ភគវន្តំ បដិបុច្ឆិត្វា មម អារោចេយ្យាថាតិ ។ ឯវំ គហបតីតិ ខោ តេ ភិក្ខូ រាជគហកស្ស សេដ្ឋិស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ រាជគហកោ ភន្តេ សេដ្ឋី វិហារេ ការាបេតុកាមោ កថំ នុ ខោ ភន្តេ អម្ហេហិ (១) បដិបជ្ជិតព្វន្តិ ។

---

១ ឱ. ម. បោត្ថកេសុ អម្ហេហីតិ បទំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទង់គន្លងបង្អួចអំពីព្រលឹមថ្ងៃ សឹងមានបក្ខុសំឡឹងចុះ បរិបូណ៌ដោយឥរិយាបថ គឺ ឈានទៅមុខ ថយក្រោយ ក្រឡេកស្ដាំ ក្រឡេកឆ្វេង បត់ចូល លាចេញ គួរឲ្យកើតសេចក្ដីជ្រះថ្លា ។ លុះរាជគហសេដ្ឋីនោះឃើញហើយក៏មានចិត្តជ្រះថ្លា ។ លំដាប់នោះ រាជគហសេដ្ឋីក៏ដើរចូលទៅរកពួកភិក្ខុនោះ លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងភិក្ខុទាំងនោះថា បពិត្រលោកទាំងឡាយដ៏ចំរើន ប្រសិនបើខ្ញុំព្រះករុណាឲ្យគេធ្វើវិហារ(១) (ប្រគេន) តើលោកម្ចាស់ទាំងឡាយនឹងនៅក្នុងវិហាររបស់ខ្ញុំព្រះករុណាឬទេ ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលគហបតិ ព្រះមានព្រះភាគមិនទាន់បានអនុញ្ញាតវិហារទេ ។ រាជគហសេដ្ឋីឆ្លើយថា បពិត្រលោកទាំងឡាយដ៏ចំរើន បើដូច្នោះ សូមលោកម្ចាស់ក្រាបបង្គំទូលសួរ ចំពោះព្រះមានព្រះភាគ (អំពីរឿងវិហារនោះ) ហើយមេត្តាប្រាប់ដល់ខ្ញុំព្រះករុណាផង ។ ភិក្ខុទាំងនោះទទួលស្ដាប់ពាក្យរាជគហសេដ្ឋី ដោយពាក្យថា យ៉ាងហ្នឹងហើយគហបតិ រួចក៏ចូលទៅកាន់ទីដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ ភិក្ខុទាំងនោះអង្គុយ ក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន រាជគហសេដ្ឋីមានសេចក្ដីប្រាថ្នានឹងឲ្យគេធ្វើវិហារ បពិត្រព្រះអង្គដ៏ចំរើន តើយើងខ្ញុំគប្បីប្រតិបត្តិដូចម្ដេច ។

---

១ សំដៅយកទីនៅរបស់សង្ឃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៣១០) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ បញ្ច សេនាសនានិ(១) វិហារំ អឌ្ឍយោគំ បាសាទំ ហម្មិយំ គុហន្តិ ។

(៣១១) អថខោ តេ ភិក្ខូ យេន រាជគហកោ សេដ្ឋី តេនុបសង្កមឹសុ ឧបសង្កមិត្វា រាជគហកំ សេដ្ឋឹ ឯតទវោចុំ អនុញ្ញាតា ខោ គហបតិ ភគវតា វិហារា យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ រាជគហកោ សេដ្ឋី ឯកាហេនេវ សដ្ឋី វិហារេ បតិដ្ឋាបេសិ ។ អថខោ រាជគហកោ សេដ្ឋី តេ សដ្ឋី វិហារេ បរិយោសាបេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជគហកោ សេដ្ឋី ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ

---

១ ឱ. លេនានិ ។ ម. លេណានិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣១០) ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេនាសនៈ៥ យ៉ាង គឺ វិហារ[១] ១ អឌ្ឍយោគ[២] ១ ប្រាសាទ[៣] ១ ហម្មិយៈ[៤] ១ គុហា[៥] ១ ។

(៣១១) គ្រានោះ ពួកភិក្ខុនោះចូលទៅរករាជគហសេដ្ឋី លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងរាជគហសេដ្ឋីថា ម្នាលគហបតិ ព្រះមានព្រះភាគទ្រង់អនុញ្ញាតវិហារហើយ ឥឡូវនេះ អ្នកយល់ថាកាលណាគួរ (ក៏គប្បីធ្វើចុះ) ។ គ្រានោះ រាជគហសេដ្ឋីឲ្យគេសាងវិហារចំនួន ៦០ តែមួយថ្ងៃគត់ ក៏ហើយជាស្រេច ។ រាជគហសេដ្ឋីឲ្យគេសាងវិហារ ៦០ រួចស្រេចហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ រាជគហសេដ្ឋី លុះអង្គុយក្នុងទីសមគួរហើយ បានក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ

---

១ លំនៅដែលក្រៅពីសេនាសនៈ មានអឌ្ឍយោគជាដើម ។ ២ ផ្ទះមានសណ្ឋានដូចស្លាបគ្រុឌ ឬផ្ទះដែលមានដំបូលតែម្ខាង ក៏បង្ហា ។ ៣ ប្រាសាទវែង ។ ៤ ផ្ទះឬប្រាសាទមានកំពូល ។ ៥ គុហាដែលធ្វើដោយឥដ្ឋ ដោយថ្ម ដោយឈើ ដោយអាចម៍ដីឬដែលកើតឯងក្នុងភ្នំ(អដ្ឋកថា)។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ រាជគហកោ សេដ្ឋី ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ រាជគហកោ សេដ្ឋី តស្សា រត្តិយា អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចា-បេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។

(៣១៦) អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន រាជគហកស្ស សេដ្ឋិស្ស និវេ-សនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ រាជគហកោ សេដ្ឋី ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជគហកោ សេដ្ឋី ភគវន្តំ ឯតទវោច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



មួយអន្លើដោយភិក្ខុសង្ឃទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីធ្វើភត្តកិច្ចក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ គ្រានោះ រាជគហសេដ្ឋីដឹងច្បាស់ថា ព្រះមានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចចៀសចេញទៅ ។ គ្រាកាលកន្លងរាត្រីនោះទៅ រាជគហសេដ្ឋីក៏ឲ្យគេតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម ហើយឲ្យទៅក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន វេលាគួរហើយ ភត្តសម្រេចហើយ ។

(៣១៤) លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ទ្រង់បាត្រចីវរក្នុងវេលាបុព្វណ្ហសម័យ ហើយទ្រង់យាងទៅកាន់លំនៅនៃរាជគហសេដ្ឋី លុះយាងទៅដល់ហើយក៏គង់លើអាសនៈដែលគេក្រាល (បម្រុងទុក) មួយអន្លើដោយភិក្ខុសង្ឃ ។ ឯរាជគហសេដ្ឋីបានអង្គាសខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសារដោយដៃខ្លួនឯង ថ្វាយចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ លុះព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ (សេដ្ឋីនោះ) ក៏អង្គុយក្នុងទីសមគួរ ។ រាជគហសេដ្ឋី លុះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯតេ មេ ភន្តេ សដ្ឋី វិហារា បុញ្ញត្ថិកេន សគ្គត្ថិកេន ការាបិតា កថាហំ ភន្តេ តេសុ វិហារេសុ បដិបជ្ជាមីតិ ។ តេនហិ ត្វំ គហបតិ តេ សដ្ឋី វិហារេ អាគតានាគតស្ស ចាតុទ្ទិសស្ស សង្ឃស្ស បតិដ្ឋាបេហីតិ ។ ឯវំ ភន្តេតិ ខោ រាជគហកោ សេដ្ឋី ភគវតោ បដិស្សុត្វា តេ សដ្ឋី វិហារេ អាគតានាគតស្ស ចាតុទ្ទិសស្ស សង្ឃស្ស បតិដ្ឋាបេសិ ។ អថខោ ភគវា រាជគហកំ សេដ្ឋឹ ឥមាហិ គាថាហិ អនុមោទិ

(៣១៣) សីតំ ឧណ្ហំ បដិហន្តិ
តតោ វាឡមិគានិ ច
សិរីសបេ ច មកសេ
សិសិរេ ចាបិ វុដ្ឋិយោ
តតោ វាតាតបោ ឃោរោ
សញ្ជាតោ បដិហញ្ញតិ ។
លេណត្ថញ្ច សុខត្ថញ្ច
ឈាយិតុញ្ច វិបស្សិតុំ
វិហារទានំ សង្ឃស្ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបុណ្យនឹងឋានសួគ៌ បានសាងវិហារទាំង ៦០ នុ៎ះស្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងវិហារទាំងនោះដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតិ បើដូច្នោះ អ្នកចូរប្រតិស្ឋានវិហារទាំង ៦០ នោះ សម្រាប់សង្ឃដែលមកហើយ និងមិនទាន់មកអំពីទិសទាំង ៤ ចុះ ។ រាជគហសេដ្ឋីទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានភាគដោយពាក្យថា ព្រះករុណា ព្រះអង្គ រួចក៏ប្រតិស្ឋានវិហារទាំង ៦០ នោះ ដើម្បីសង្ឃ ដែលមកហើយទាំងមិនទាន់មក អំពីទិសទាំង ៤ ។ ទើបព្រះមានព្រះភាគទ្រង់អនុមោទនា ចំពោះរាជគហសេដ្ឋីដោយគាថាទាំងឡាយនេះថា

(៣១៣) (វិហារ គឺ ទីអាវាស ឬសេនាសនៈជាទីនៅនៃសង្ឃទាំងឡាយ) រមែងការពាររងាផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូចនឹងពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់នឹងកំដៅថ្ងៃដ៏ក្លាខ្លាំងដែលកើតឡើងហើយ រមែងបាត់ទៅវិញព្រោះវិហារនោះ ។ ។ វិហារទាន គឺ ការឲ្យលំនៅ (ដែលបុគ្គលបានឲ្យហើយ) ដល់សង្ឃដើម្បីជាទីជ្រកកោនផង ដើម្បីនៅជាសុខផង ដើម្បីផុតបាបធម៌ផង ដើម្បីចំរើនវិបស្សនាផង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អត្ថំ ពុទ្ធេហិ(១) វណ្ណិតំ ។
តស្មា ហិ បណ្ឌិតោ បោសោ
សម្បស្សំ អត្ថមត្តនោ
វិហារេ ការយេ រម្មេ
វាសយេត្ថ ពហុស្សុតេ ។
តេសំ អន្នញ្ច បានញ្ច
វត្ថសេនាសនានិ ច
ទទេយ្យ ឧជុភូតេសុ
វិប្បសន្នេន ចេតសា ។
តេ តស្ស ធម្មំ ទេសេន្តិ
សព្វទុក្ខាបនូទនំ
យំ សោ ធម្មំ ឥធញ្ញាយ
បរិនិព្វាតិ អនាសវោតិ ។

អថខោ ភគវា រាជគហកំ សេដ្ឋឹ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។

---

១ ឱ. ម. ពុទ្ធេន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះពុទ្ធទាំងឡាយតែងសរសើរ ថាជាទានដ៏ប្រសើរ ។ ព្រោះហេតុនោះឯង បុរស (ស្ត្រី) ជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន គប្បីកសាងព្រះវិហារ គឺអាវាស ឲ្យសេនាសនៈទាំងឡាយដ៏ជាទីគួររីករាយ ហើយគួរនិមន្តលោកដែលជាពហុស្សូត[១] គឺលោកអ្នកចេះដឹងច្រើនទាំងឡាយឲ្យនៅក្នុងទីនោះ ។ គួរមានចិត្តជ្រះថ្លាចំពោះលោកទាំងឡាយដែលមានចិត្តត្រង់ ហើយប្រគេនបាយទឹកសំពត់ និងសេនាសនៈទាំងឡាយ ដល់លោកទាំងនោះចុះ ។ លោកទាំងនោះរមែងសំដែងធម៌ជាគ្រឿងបន្ទោបង់ ឲ្យឃ្លាតចាកទុក្ខគ្រប់ប្រការដល់អ្នកនោះ លុះអ្នកនោះបានដឹងធម៌ណាក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ។

កាលដែលព្រះមានព្រះភាគ ទ្រង់អនុមោទនាចំពោះរាជគហសេដ្ឋី ដោយគាថាទាំងឡាយនេះហើយ ទើបទ្រង់ក្រោកចាកអាសនៈ យាងចៀសចេញទៅ ។

---

១ ពាក្យថា ពហុស្សូត សំដៅយកពហុស្សូតពីរយ៉ាង គឺ បរិយត្តិពហុស្សូត និងបដិវេធពហុស្សូត (អដ្ឋកថា) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣១៤) អស្សោសុំ ខោ មនុស្សា ភគវតា កិរ វិហារា អនុញ្ញាតាតិ ។ តេ[១] សក្កច្ចំ វិហារេ ការាបេន្តិ ។ តេ វិហារា អកវាដកា ហោន្តិ ។ អហិបិ វិច្ឆិកាបិ សតបទិយោបិ បវិសន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កវាដន្តិ ។ ភិត្តិំ ឆិទ្ទំ ករិត្វា វល្លិយាបិ រជ្ជុយាបិ កវាដំ ពន្ធន្តិ ។ ឧន្ទូរេហិបិ ឧបចិកាហិបិ ខជ្ជន្តិ ។ ខាយិតពន្ធនានិ កវាដានិ បតន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បិដ្ឋសង្ឃាដំ ឧទុក្ខលិកំ ឧត្តរបាសកន្តិ ។ កវាដា ន ផុសិយន្តិ[២] ។ បេ ។ អនុជានាមិ ភិក្ខវេ អាវិញ្ឆនច្ឆិទ្ទំ អាវិញ្ឆនរជ្ជុន្តិ ។ កវាដា ន ថកិយន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ អគ្គឡវដ្ដិំ កបិសីសកំ សូចិកំ ឃដិកន្តិ ។

---

១ ឱ. ម. ពោត្ថកេសុ តេសបត្តេ ន វិស្សជ្ជតិ ។ ២ ឱ. ផុស្សីយន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សេនាសនក្ខន្ធកៈ ការទ្រង់អនុញ្ញាតសន្លះទ្វារជាដើម

(៣១៤) មនុស្សទាំងឡាយបានឮដំណឹងថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតវិហារហើយ ។ មនុស្សទាំងនោះក៏យកចិត្តទុកដាក់នាំគ្នាកសាងវិហារ ។ វិហារទាំងនោះមិនទាន់មានសន្លះទ្វារនៅឡើយ ។ ពស់ទីង ខ្មួយខ្លះ ក្អែបខ្លះ ក៏តែងចូលទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យមានសន្លះទ្វារ ។ ពួកភិក្ខុធ្វើប្រហោងជញ្ជាំងហើយ បង់សន្លះទ្វារដោយវល្លិខ្លះ ដោយខ្សែខ្លះ ។ កណ្តុរខ្លះ កណ្តៀរខ្លះ ក៏ចេះតែ គោរកាត់ ។ ចំណងដែលសត្វកាត់ហើយ សន្លះទ្វារក៏ធ្លាក់ចុះមក ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ក្របទ្វារ ដំណាប់ក្រោមនិងដំណាប់លើ ។ សន្លះទ្វារទាំងឡាយ មិនជិតស្និទ្ធល្អ ។ បេ ។ ព្រះទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ប្រហោងសម្រាប់ដាក់ខ្សែទាញ និងខ្សែសម្រាប់ទាញ ។ ភិក្ខុបិទសន្លះទ្វារមិនកើត ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) មេទ្វារ ត្រដោកទ្វារ រនុកទ្វារខើងគន្ទឹសទ្វារខាងលើ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៣១៥) តេន ខោ បន សមយេន ភិក្ខូ ន សក្កោន្តិ កវាដំ អបាបុរិតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តាលច្ឆិទ្ទំ តីណិ តាឡានិ លោហតាលំ កដ្ឋតាលំ វិសាណតាលន្តិ ។ យេហិ តេ ឧគ្ឃាដេត្វា បវិសន្តិ ។ វិហារា អគុត្តា ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ យន្តកំ សូចិកន្តិ ។

(៣១៦) តេន ខោ បន សមយេន វិហារា តិណច្ឆទនា ហោន្តិ សីតកាលេ សីតា ឧណ្ហកាលេ ឧណ្ហា។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឱគុម្ផេត្វា ឧល្លិត្តាវលិត្តំ កាតុន្តិ ។

(៣១៧) តេន ខោ បន សមយេន វិហារា អវាតបានកា ហោន្តិ អចក្ខុស្សា ទុគ្គន្ធា ។ ភគវតោ ឯតមត្ថំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣១៥) សម័យនោះ ពួកភិក្ខុបិទសន្ទះទ្វារមិនកើត ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ប្រហោងសោនឹងសោ ៣ យ៉ាងគឺ សោធ្វើដោយលោហជាតិ១ សោធ្វើដោយឈើ ១ សោធ្វើដោយស្នែង១ ។ ភិក្ខុទាំងឡាយណាបើកទ្វារចូលទៅ ។ (ភិក្ខុទាំងនោះ) មិនបានបិទវិហារទៅវិញ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) គ្រឿងយន្តនឹងគន្លឹះ ។

(៣១៦) សម័យនោះឯង វិហារប្រក់ស្បូវ រដូវរងាក៏រងាណាស់ រដូវក្តៅក៏ក្តៅណាស់ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអប ឬឲ្យគាបដម្បូលហើយបូកលាបទាំងខាងក្នុងនិងខាងក្រៅ ។

(៣១៧) សម័យនោះឯង វិហារមិនទាន់មានបង្អួចនៅឡើយ ទៅជាងងិតមើលអ្វីមិនឃើញ ទាំងធំក្លិនស្អុយ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តីណិ វាតបានានិ វេទិកាវាតបានំ ជាលវាតបានំ សលាកវាតបានន្តិ ។ វាតបានន្តរិកាយ កាឡកាបិ វគ្គុលិយោបិ បវិសន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វាតបានចក្កលិកន្តិ ។ ចក្កលិកន្តរិកាយ កាឡកាបិ វគ្គុលិយោបិ បវិសន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ វាតបានកវាដំ វាតបានភិសិកន្តិ ។

[៣១៨] តេន ខោ បន សមយេន ភិក្ខូ ឆមាយំ សយន្តិ ។ គត្តានិបិ ចីវរានិបិ បំសុកិតានិ ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តិណសន្ថារកន្តិ ។ តិណសន្ថារកោ(១) ឧន្ទូរេហិបិ ឧបចិកាហិបិ

---

១ ឱ. ម. តិណសន្តារកន្តិ តិណសន្តារកោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្អួច ៣ យ៉ាង គឺ បង្អួចមានវេទី(១) (ដូចវេទីចេតិយ) ១ បង្អួចដែលគេបិទឲ្យមានសណ្ឋានដូចក្រឡាសំណាញ់ ១ បង្អួចមានឈើបំរឹង ១ ។ សត្វកន្ហែខ្លះ ប្រចៀវខ្លះ ចូលទៅតាមចន្លោះបង្អួចបាន ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរនាំងបង្អួច ។ សត្វកន្ហែខ្លះ ប្រចៀវខ្លះ ក៏ចូលទៅតាមចន្លោះរនាំង (នោះទៀត) ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះបង្អួចឬរនាំងពូកបង្អួច ។

(៣១៨) សម័យនោះឯង ពួកភិក្ខុដេកផ្ទាល់នឹងផែនដី ។ ខ្លួននឹងចីវររបស់ភិក្ខុប្រឡាក់ដោយកាចម៍ដី ។ ភិក្ខុទាំងនោះក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកម្រាលធ្វើដោយស្មៅ ។ សត្វកណ្ដុរទីងកណ្ដៀរកែង

---

១ ជាពាក្យហៅរបស់សម្រាប់រង សម្រាប់កល់ របស់សម្រាប់អង្គុយ ជើងម៉ាសម្រាប់អង្គុយ និងក្របរងស្បូវ ដូចទីបំពុតរងស្បូវជាន់លើនិងរងស្បូវជាន់ក្រោម ឬក្បាច់ខ្សែចេតិយដែលធ្វើជាគ្រឿបកល្បូកផ្កាផ្ងារនិងគ្រឿបកល្បូកផ្កាប់ គឺត្រង់កចេតិយនិងតួចេតិយ បង្កាន់ដៃស្ពាន ទាំងនេះហៅថា វេទី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខជ្ជតិ ។ បេ ។ អនុជានាមិ ភិក្ខវេ មិឍន្តិ ។ មិឍិយា គត្តានិ ទុក្ខានិ ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ វិទលមញ្ចកន្តិ(១) ។

(៣១៩) តេន ខោ បន សមយេន សង្ឃស្ស សោសានិកោ មសារកោ មញ្ចោ ឧប្បន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មសារកំ មញ្ចន្តិ ។ មសារកំ ពីឋំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មសារកំ ពីឋន្តិ ។

(៣២០) តេន ខោ បន សមយេន សង្ឃស្ស សោសានិកោ ពុន្ទិកាពទ្ធោ មញ្ចោ ឧប្បន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ពុន្ទិកាពទ្ធំ មញ្ចន្តិ ។ ពុន្ទិកាពទ្ធំ ពីឋំ ឧប្បន្នំ ហោតិ ។

---

១ ឧ. បិទលមញ្ចកន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាត់កម្រាលស្មៅ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបន្ទះក្តារសម្រាប់ដេក ។ ពួកភិក្ខុឈឺខ្នងព្រោះដេកលើបន្ទះក្តារ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្រែផ្តៅ ។

(៣១៩) សម័យនោះឯង ក្រែដែលមានមេគេបញ្ឈរទៅក្នុងជំណាប់ជើង ដែលគេចោលក្នុងព្រៃស្មសានកើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្រែដែលមានមេគេបញ្ឈរទៅក្នុងជំណាប់ជើង ។ (តមកទៀត) មានតាំងដែលមានមេគេបញ្ឈរទៅក្នុងជំណាប់ជើងកើតឡើង(ដល់សង្ឃ) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងដែលមានមេគេបញ្ឈរទៅក្នុងជំណាប់ជើង ។

(៣២០) សម័យនោះឯង ក្រែដែលគេបង្ខាំជើងដោយមេក្រែ ចោលក្នុងព្រៃស្មសានកើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្រែដែលគេបង្ខាំជើងដោយមេក្រែ ។ (តមកទៀត) តាំងដែលគេបង្ខាំជើងដោយមេតាំងកើតឡើង(ដល់សង្ឃ) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ពុន្ទិកាពទ្ធំ បីឋន្តិ ។

(៣២១) តេន ខោ បន សមយេន សង្ឃស្ស សោសានិកោ កុឡិរបាទកោ មញ្ចោ ឧប្បន្នោ ហោតិ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កុឡិរបាទកំ មញ្ចន្តិ ។ កុឡិរបាទកំ បីឋំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កុឡិរបាទកំ បីឋន្តិ ។

(៣២២) តេន ខោ បន សមយេន សង្ឃស្ស សោសានិកោ អាហច្ចបាទកោ មញ្ចោ ឧប្បន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាហច្ចបាទកំ មញ្ចន្តិ ។ អាហច្ចបាទកំ បីឋំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងដែលគេបង្ហាំជើងជាប់នឹងមេតាំង ។

(៣២១) សម័យនោះឯង គ្រែមានជើងដូចជើងក្តាម[១] ដែលគេហាលក្នុងព្រៃស្មសានកើតឡើងដល់សង្ឃ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមានជើងដូចជើងក្តាម ។ (តមកទៀត) តាំងមានជើងដូចជើងក្តាម[២] កើតឡើង (ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងមានជើងដូចជើងក្តាម ។

(៣២២) សម័យនោះឯង គ្រែមានជើងទល់នឹងមេ ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ ដែលគេហាលក្នុងព្រៃស្មសានកើតឡើងដល់សង្ឃ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមានជើងទល់នឹងមេ ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ ។ (តមកទៀត) តាំងមានជើងទល់នឹងមេ ឬតាំងដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ

១.២ គ្រែដែលមានជើងដូចជើងសេះ ជើងគោ ជើងក្តាមជាដើម ឯតាំងក៏មានជើងដូចជើងគ្រែដែរ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាហច្ចបាទកំ បីឋន្តិ ។

(៣៦៣) តេន ខោ បន សមយេន សង្ឃស្ស អាសន្ទិកោ ឧប្បន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាសន្ទិកន្តិ ។ ឧច្ចកោ អាសន្ទិកោ ឧប្បន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧច្ចកម្បិ អាសន្ទិកន្តិ ។ សត្តង្គោ ឧប្បន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សត្តង្គន្តិ ។ ឧច្ចកោ សត្តង្គោ ឧប្បន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧច្ចកម្បិ សត្តង្គន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កើតឡើង(ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងមានជើងទល់ទឹងមេ ឬតាំងដែលគេបញ្ឈរជើងទៅក្នុងដំណាប់មេ ។

(៣២៣) សម័យនោះឯង តាំង ៤ ជ្រុងកើតឡើងដល់សង្ឃ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង ៤ ជ្រុង ។ (តមកទៀត) តាំង ៤ ជ្រុងមានជើងខ្ពស់កើតឡើង (ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង ៤ ជ្រុងសូម្បីមានជើងខ្ពស់[១] ។ (តមកទៀត) គ្រែមានអង្គ ៧ កើតឡើង(ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមានអង្គ ៧[២] ។ (តមកទៀត) គ្រែមានអង្គ ៧ មានជើងខ្ពស់កើតឡើង (ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមានអង្គ ៧

---

១ អដ្ឋកថា ថា តាំង៤ជ្រុងសូម្បីមានជើងខ្ពស់ហួសប្រមាណក៏គួរ បើតាំងដែលវែង លុះតែធ្វើឲ្យមានជើងកំពស់ត្រឹម៨ធ្នាប់ទើបគួរ ។ ២ គ្រែដែលមានបង្អែក ១ ភ្នាក់ដៃ ២ និងជើង ៤ ទុកជាកន្លងហួសប្រមាណក៏គួរ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភទ្ទបីឋំ ឧប្បន្នំ ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ
ភទ្ទបីឋន្តិ ។ បីឋិកា ឧប្បន្នា ហោតិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បីឋិកន្តិ ។
ឯឡកបាទកំ បីឋំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ
អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឯឡកបាទកំ
បីឋន្តិ ។ អាមលកវណ្ដិកំ បីឋំ ឧប្បន្នំ ហោតិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ
អាមលកវណ្ដិកំ បីឋន្តិ ។ ផលកំ ឧប្បន្នំ ហោតិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ
ភិក្ខវេ ផលកន្តិ ។ កោច្ឆំ ឧប្បន្នំ ហោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សូម្បីមានជើងខ្ពស់ក៏បាន ។ (តមកទៀត) មានតាំងពាក់ផ្តៅ[1] កើតឡើង (ដល់សង្ឃ) ។ បេ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងពាក់ផ្តៅ ។ (តមកទៀត) មានតាំងសំពត់កើតឡើង (ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងសំពត់ ។ (តមកទៀត) តាំងមានជើងដូចជើងពពែកើតឡើង (ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងមានជើងដូចជើងពពែ ។ (តមកទៀត) ក៏មានតាំង (មានជើងច្រើនដែលគេប្រកបដោយ) អាការដូចជាផ្លែកន្ទួតព្រៃកើតឡើង (ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង (មានជើងច្រើនដែលគេប្រកបដោយ) អាការដូចជាផ្លែកន្ទួតព្រៃ ។ (តមកទៀត) ផែនក្តារក៏កើតឡើង (ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផែនក្តារ ។ (តមកទៀត) កៅអីក៏កើតឡើង (ដល់សង្ឃ) ។

---

១ អដ្ឋកថា ពន្យល់ថាធ្វើអំពីផ្តៅសុទ្ធ គឺទាំងតួទាំងជើងទាំងបង្អែកសុទ្ធតែផ្តៅទាំងអស់ ឥតមានអ្វីលាយសោះឡើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កោច្ឆំ ។ បលាលបីឋំ ឧប្បុឡ្ហំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បលាលបីឋន្តិ ។

(៣២៤) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចេ មញ្ចេ សយន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឧច្ចេ មញ្ចេ សយិតព្វំ យោ សយេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៣២៥) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ នីចេ មញ្ចេ សយន្តោ អហិនា ទដ្ឋោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មញ្ចប្បដិបាទកន្តិ ។

(៣២៦) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចេ មញ្ចប្បដិបាទកេ ធារេន្តិ ។ សហ មញ្ចប្បដិបាទកេហិ បវេធេន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកៅអី ។ (តមកទៀត) តាំងដែលធ្វើពីចំបើងក៏កើតឡើង ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងដែលធ្វើពីចំបើង ។

(៣២៤) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដេកលើគ្រែខ្ពស់ ។ មនុស្សទាំងឡាយដើរមកកាន់វិហារចារិកបានឃើញ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំដេកលើគ្រែខ្ពស់ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ ។

(៣២៥) សម័យនោះឯង ភិក្ខុ ១ រូបដេកលើគ្រែទាប ពស់ក៏ចឹក(ភិក្ខុនោះ) ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់គ្រែ ។

(៣២៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ទ្រនាប់គ្រែខ្ពស់ ។ ភិក្ខុធ្វើគ្រែឲ្យរញ្ជួយទាំងទ្រនាប់គ្រែ ។ មនុស្សទាំងឡាយដើរមកកាន់វិហារចារិកបានឃើញ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឧច្ចា មញ្ចប្បដិបាទកា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ អដ្ឋង្គុលបរមំ មញ្ចប្បដិបាទកន្តិ ។

(៣២៧) តេន ខោ បន សមយេន សង្ឃស្ស សុត្តំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សុត្តំ[១] មញ្ចំ វេឋេតុន្តិ[២] ។ អង្គានិ ពហុំ សុត្តំ បរិយាទិយន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ អង្គេ វិជ្ឈិត្វា អដ្ឋបទកំ វេឋេតុន្តិ ។ ចោឡកំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចិមិលិកំ កាតុន្តិ ។ តូលិកា ឧប្បន្នា ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ វិជដេត្វា ពិម្ពោហនំ កាតុំ តីណិ តូលានិ រុក្ខតូលំ លតាតូលំ បោដកីតូលន្តិ ។

---

១ អយំ សុត្តសទ្ទោ ឱ. ម. បោត្ថកេសុ ន ទិស្សតិ ។ ២ ឱ. វេឋុំ ។ ម. វេឋេតុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ទ្រនាប់ក្រែខ្ពស់ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ក្រែយ៉ាងខ្ពស់ត្រឹម ៨ ធ្នាប់ ។

(៣២៧) សម័យនោះឯង អម្បោះកើតឡើងដល់សង្ឃ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកអម្បោះចងប្រទាក់ក្រែ ។ ភិក្ខុចងប្រទាក់កង់ក្រែ (ទាំងនោះ) គឺអស់អម្បោះច្រើន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចោះត្រង់កង់ក្រែ ហើយចងទាក់ជាក្រឡាចត្រគ្គ ។ (តមកទៀត) កំណាត់សំពត់ក៏កើតឡើង (ដល់សង្ឃ) ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទ្រនាប់ ។ (តមកទៀត) គ្រឿងសេនាសនៈដែលញាត់ដោយប៉ុយក៏កើតឡើង (ដល់សង្ឃ) ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដផុះចេញហើយធ្វើជាខ្នើយបាន ឯប៉ុយមាន ៣ យ៉ាង គឺ ប៉ុយដើមឈើ ១ ប៉ុយវល្លិ ១ ប៉ុយស្មៅ ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣២៨) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អឌ្ឍកាយិកានិ ពិម្ពោហនានិ ធារេន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អឌ្ឍកាយិកានិ ពិម្ពោហនានិ ធារេតព្វានិ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ សីសប្បមាណំ ពិម្ពោហនំ កាតុំ ។

(៣២៩) តេន ខោ បន សមយេន រាជគហេ គិរគ្គសមជ្ជោ ហោតិ ។ មនុស្សា មហាមត្តានំ អត្ថាយ ភិសិយោ បដិយាទេន្តិ ឧណ្ណភិសឹ ចោឡភិសឹ វាកភិសឹ តិណភិសឹ បណ្ណភិសឹ ។ តេ វីតិវត្តេ សមជ្ជេ ឆវឹ ឧប្បាដេត្វា(១) ហរន្តិ ។ អទ្ទសំសុ ខោ ភិក្ខូ សមជ្ជដ្ឋានេ ពហុំ ឧណ្ណម្បិ ចោឡម្បិ វាកម្បិ តិណម្បិ បណ្ណម្បិ

១ ឱ. ម. ឱបាដេត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣២៨) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ខ្សែពាក់កណ្ដាលកាយ ។ មនុស្សទាំងឡាយដើរទៅកាន់វិហារចារិក ឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ខ្សែពាក់កណ្ដាលកាយទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើខ្សែ ឲ្យល្មមប៉ុនក្បាល ។

(៣២៩) សម័យនោះឯង មានមហោស្រពលេងលើកំពូលភ្នំ ជិតក្រុងរាជគ្រឹះ ។ មនុស្សទាំងឡាយនាំគ្នាតាក់តែងពួកជាច្រើន គឺពួកញាត់កេមកែះ ញាត់សំពត់ ញាត់សម្បកឈើ ញាត់ស្មៅ ញាត់ស្លឹកឈើ ដើម្បីប្រយោជន៍ដល់ពួកមហាមាត្យ ។ លុះមហោស្រពស្ងប់ស្ងាត់ឈប់លេងហើយ មនុស្សទាំងនោះក៏បកតែស្រោមពួក យកទៅ ។ ពួកភិក្ខុក៏បានឃើញពួកទាំងឡាយញាត់កេមកែះខ្លះ ញាត់សំពត់ខ្លះ ញាត់សម្បកឈើខ្លះ ញាត់ស្មៅខ្លះ ញាត់ស្លឹកឈើខ្លះ ជាច្រើន

ឆឌ្ឌិតំ(១) ។ ទិស្វាន ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ច ភិសិយោ ឧណ្ណភិសឹ ចោឡភិសឹ វាកភិសឹ តិណភិសឹ បណ្ណភិសិន្តិ ។

(៣៣០) តេន ខោ បន សមយេន សង្ឃស្ស សេនាសនបរិក្ខារិកំ(២) ទុស្សំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិសឹ ឱនទ្ធិតុន្តិ(៣) ។

(៣៣១) តេន ខោ បន សមយេន ភិក្ខូ មញ្ចភិសឹ បីឋេ សំហរន្តិ(៤) បីឋភិសឹ មញ្ចេ សំហរន្តិ ។ ភិសិយោ បរិភិជ្ជន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឱនទ្ធមញ្ចំ ឱនទ្ធបីឋន្តិ ។ ឧល្លោកំ អករិត្វា សន្ថរន្តិ(៥) ។ ហេដ្ឋតោ និប្បាដេន្តិ(៦) ។បេ។ អនុជានាមិ ភិក្ខវេ ឧល្លោកំ ករិត្វា សន្ថរិត្វា ភិសឹ ឱនទ្ធិតុន្តិ ។ ឆវឹ ឧប្បាដេត្វា ហរន្តិ ។បេ។

---

១ ឱ., ឆឌ្ឌិតានិ ។ ២ ឱ. សេនាសនបរិក្ខារទុស្សំ ។ ៣ ឱ. ម. ឱនន្ធិតុន្តិ ។ ៤ ម. សន្ថរន្តិ ។ ៥ ឱ. សំភេរន្តិ ។ ៦ ឱ. ម. និប្បតន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ដែលគេចោលនៅទីមហោស្រព ។ លុះឃើញហើយក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតពូក៥ យ៉ាងគឺ ពូកញាត់រោមកែះ ១ ពូកញាត់សំពត់ ១ ពូកញាត់សម្បកឈើ ១ ពូកញាត់ស្មៅ ១ ពូកញាត់ស្លឹកឈើ ១ ។

(៣៣០) សម័យនោះឯង មានសំពត់ជារបស់គួរប្រើប្រាស់ ក្នុងសេនាសនៈកើតឡើងដល់សង្ឃ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុញាត់ពូកដោយសំពត់ ។

(៣៣១) សម័យនោះឯង ពួកភិក្ខុយកពូកសម្រាប់គ្រែទៅក្រាលលើតាំង យកពូកសម្រាប់តាំងទៅក្រាលគ្រែវិញ ។ ពូកទាំងឡាយក៏រហែកអស់ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែដែលញាត់ភ្ជាប់ នឹងតាំងដែលញាត់ភ្ជាប់ (ដោយគ្រឿងញាត់) ។ ពួកភិក្ខុមិនបានក្រាលទ្រនាប់ពីក្រោមហើយក៏ក្រាល ។ គ្រឿងញាត់ទាំងនោះក៏លៀនចេញទៅខាងក្រោម ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុក្រាបទ្រនាប់រួចក្រាលហើយ សឹមញាត់ពូក ។ ពួកចោរក៏បកតែស្រោមពូកយកទៅ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ ឡោសិតុន្តិ(១) ។ ហរន្តិយេវ ។ បេ ។
អនុជានាមិ ភិក្ខវេ ភិត្តិកាបន្ធិ ។ ហរន្តិយេវ ។ បេ ។
អនុជានាមិ ភិក្ខវេ ហត្ថកិត្តិន្តិ(២) ។

(៣៣២) តេន ខោ បន សមយេន តិត្ថិយានំ
សេយ្យាយោ សេតវណ្ណាយោ ហោន្តិ ។ កាឡវណ្ណកតា
ភូមិ ។ គេរុកបរិកម្មកតា ភិត្តិ ។ ពហូ មនុស្សា
សេយ្យាបេក្ខកា គច្ឆន្តិ ។ ភគវតោ ឯតមត្ថំ អារោ-
ចេសុំ ។ អនុជានាមិ ភិក្ខវេ វិហារេ សេតវណ្ណំ កា-
ឡវណ្ណំ គេរុកបរិកម្មន្តិ ។

(៣៣៣) តេន ខោ បន សមយេន ផរុសាយ
ភិត្តិយា សេតវណ្ណោ ន និបតតិ ។ ភគវតោ ឯតមត្ថំ
អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ថុសបិណ្ឌំ ទត្វា
បាណិកាយ បដិពាហេត្វា(៣) សេតវណ្ណំ និបាតេតុន្តិ ។

១ ឱ. ឡោសិតុន្តិ ។ ម. ឡោសេតុន្តិ ។ ២ ឱ. ម. ភិត្តិកម្មន្តិ ។ ៣ ឱ. បដិពាហេត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រស់ព្រំ(១) ។ ពួកចោរក៏នៅតែលួចយកទៀត ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ភិក្ខុគូសដោយគំនូសផ្សេងៗ ។ ពួកចោរក៏នៅតែលួចយកទៀត ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្តិតនឹងស្រាមដៃ ។

(៣៣២) សម័យនោះឯង ទីដេករបស់ពួកភិក្ខុ មានពណ៌ស ។ ផ្ទៃលាបពណ៌ខ្មៅ ។ ជញ្ជាំងលាបដោយរង់ ។ មនុស្សទាំងឡាយជាច្រើន (ដែលទៅដល់ទីនោះ) មៀងមើលទីដេកហើយទើបដើរទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបូកលាបវិហារឲ្យមានពណ៌ស ពណ៌ខ្មៅ នឹងលាបដោយរង់ ។

(៣៣៣) សម័យនោះឯង ពណ៌សដិតមិនស្មើ ព្រោះផ្ទៃជញ្ជាំងមិនស្អាត ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាយអង្កាមហើយកៀសដោយខ្នៀស ឲ្យពណ៌សដិតស្មើ ។

---

១ អដ្ឋកថា ពន្យល់ថា ត្រូវឲ្យភិក្ខុយកទឹកជ្រលក់ឬរមៀតមកប្រស់ព្រំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេតវណ្ណោ អនិពន្ធនីយោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សណ្ហមត្តិកំ ទត្វា បាណិកាយ បដិពាហេត្វា សេតវណ្ណំ និបាតេតុន្តិ ។ សេតវណ្ណោ អនិពន្ធនីយោ ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឥក្កាសំ បិដ្ឋមទ្ទន្តិ ។

(៣៣៤) តេន ខោ បន សមយេន ផរុសាយ ភិត្តិយា គេរុកា ន និបតតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ថុសបិណ្ឌំ ទត្វា បាណិកាយ បដិពាហេត្វា គេរុកំ និបាតេតុន្តិ ។ គេរុកា អនិពន្ធនីយា ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ កុណ្ឌកមត្តិកំ ទត្វា បាណិកាយ បដិពាហេត្វា គេរុកំ និបាតេតុន្តិ ។ គេរុកា អនិពន្ធនីយា ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សាសបកុដ្ឌំ(១) សិត្ថតេលកន្តិ ។ អច្ចុស្សន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចោឡកេន បច្ចុទ្ធរិតុន្តិ ។

---

១ ឱ. សាសបកុដ្ឋំ ។ ម. សាសបកុដ្ដំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ពណ៌សក៏នៅតែមិនស្អិតជាប់គ្នា ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថា-គតអនុញ្ញាតឲ្យលាយដីស្អិតដំមដ្ឋហើយកៀស ដោយខ្សៀសឲ្យពណ៌សជិតស្មើ ។ ពណ៌សក៏នៅតែមិនស្អិតជាប់គ្នា ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជ័រឈើ ឬបាយមាំនក៏បាន ។

(៣៣៤) សម័យនោះឯង ផ្ទៃជញ្ជាំងការក្រក់ ជ័ររង់ជិតមិនស្មើ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាយអង្កាម ហើយកៀសដោយខ្សៀសឲ្យជ័ររង់ជិតស្មើ ។ ជ័ររង់ក៏នៅតែជិតមិនស្មើ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកដីដែលលាយដោយកុណ្ឌកហើយកៀស ដោយខ្សៀសឲ្យជ័ររង់ជិតស្មើ ។ ជ័ររង់ក៏នៅតែជិតមិនស្មើ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកម្សៅគ្រាប់ស្ពៃ ឬប្រេងលាយក្រមួន ។ ដំណក់ថ្នាំលាបក៏ជោរឡើង (ហូរហៀរចេញ) ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យជូតដោយកំណាត់សំពត់ចេញ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៣៥) តេន ខោ បន សមយេន ផរុសាយ ភូមិយា កាឡវណ្ណោ ន និបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ថុសបិណ្ឌំ ទត្វា ទាណិកាយ បដិពាហេត្វា កាឡវណ្ណំ និបាតេតុន្តិ ។ កាឡវណ្ណោ អនិពទ្ធិយោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សណ្ហមត្តិកំ(១) ទត្វា ទាណិកាយ បដិពាហេត្វា កាឡវណ្ណំ និបាតេតុន្តិ ។ កាឡវណ្ណោ អនិពទ្ធិយោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឥក្កាសំ កសាវន្តិ ។

(៣៣៦) តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ វិហារេ បដិភាណចិត្តំ ការាបេន្តិ ឥត្ថីរូបកំ បុរិសរូបកំ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហី កាមភោគិនោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ បដិភាណចិត្តំ ការាបេតព្វំ ឥត្ថីរូបកំ បុរិសរូបកំ យោ ការាបេយ្យ អាបត្តិ ទុក្កដស្ស

១ ម. គណ្ឌុមត្តិកំ ។ ឱ. គណ្ឌុមត្តិកំ ។

(៣៣៥) សម័យនោះឯង ផ្ទៃជញ្ជាំងអាក្រក់ ពណ៌ខ្មៅជិតមិនសព្វ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាយអង្កាមហើយកៀស ដោយខ្មៀស ឲ្យពណ៌ខ្មៅជិតស្មើ ។ ពណ៌ខ្មៅក៏នៅតែមិនស្អិតជាប់គ្នា ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាយដីអាចម៍ជន្លេន ហើយកៀសដោយខ្មៀសឲ្យពណ៌ខ្មៅជិតស្មើ ។ ពណ៌ខ្មៅក៏នៅតែមិនស្អិតជាប់គ្នា ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជ័រឈើនឹងទឹកចត់(១) ។

(៣៣៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យគេគូរគំនូរជារូបស្រីនឹងរូបបុរសក្នុងវិហារ ។ មនុស្សទាំងឡាយ ដើរមកកាន់វិហារចារិក ឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ។បេ។ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ។បេ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេគូរគំនូរជារូបស្រីនឹងរូបបុរសទេ ភិក្ខុណាឲ្យគេគូរ ត្រូវអាបត្តិទុក្កដ

---

១ អដ្ឋកថា ថាទឹកចត់សំដៅយកទឹកផ្លែសម៉ឬផ្លែកន្ទួតព្រៃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកន្តិ ។

(៣៣៧) តេន ខោ បន សមយេន វិហារា នីចវត្ថុកា ហោន្តិ ។ ឧទកេន ឱត្ថរិយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោហន្តា វិហញ្ញន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ តយោ សោបានេ ឥដ្ឋកាសោបានំ សិលាសោបានំ ទារុសោបានន្តិ ។ អារោហន្តា បរិបតន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ អាលម្ពនពាហន្តិ ។

(៣៣៨) តេន ខោ បន សមយេន វិហារា អាឡកមន្ទា ទាកជា(១) ហោន្តិ ។ ភិក្ខូ ហិរិយន្តិ និបជ្ជិតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តិរោករណិន្តិ ។ តិរោករណី ឧក្ខិបិត្វា ឱលោកេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

១ អយំ សទ្ទោ ម. យ. បោត្ថកេសុ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគំនូរភ្ញីផ្កា ទំនងគំនូរក្រវិល្លិ៍ ទំនងក្បាច់ធ្មេញមករ ទំនងក្បាច់មានស្រទាប់ ៥ ។

(៣៣៧) សម័យនោះឯង វិហារមានទីទាប ។ ទឹកក៏លិច ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទី ឲ្យខ្ពស់ឡើង ។ ខឿនវិហារក៏រលំ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកខឿន ៣ យ៉ាង គឺ ខឿនឥដ្ឋ ១ ខឿនថ្ម ១ ខឿនឈើ ១ ។ ពួកភិក្ខុនាំគ្នាឡើងទៅក៏លំបាក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្ដើរ ៣ យ៉ាង គឺ ជណ្ដើរឥដ្ឋ ១ ជណ្ដើរថ្ម ១ ជណ្ដើរឈើ ១ ។ ពួកភិក្ខុនាំគ្នាឡើងទៅក៏ធ្លាក់ចុះមកវិញ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃ ។

(៣៣៨) សម័យនោះឯង វិហារមានមនុស្សកុះករច្រើនពេក ។ ពួកភិក្ខុក៏អៀនខ្មាស (មិនអាច) ទំនងសិងបាន ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) វាំង ។ ពួកមនុស្សក៏នៅតែបើកវាំងមើល ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ អឌ្ឍកុឌ្ឌកន្តិ ។ អឌ្ឍកុឌ្ឌកា ឧបរិតោ ឱលោកេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តយោ គព្ភេ សិវិកាគព្ភំ នាឡិកា-គព្ភំ ហម្មិយគព្ភន្តិ ។

(៣៣៩) តេន ខោ បន សមយេន ភិក្ខូ ខុទ្ទកេ វិហារេ មជ្ឈេ គព្ភំ ករោន្តិ ។ ឧបចារោ ន ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ខុទ្ទកេ វិហារេ ឯកមន្តំ គព្ភំ កាតុំ មហល្លកេ មជ្ឈេតិ ។

(៣៤០) តេន ខោ បន សមយេន វិហារស្ស កុឌ្ឌបាទោ ជីរតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កុលង្កបាទកន្តិ ។ វិហារស្ស កុឌ្ឌោ ឱវស្សតិ ។បេ។ អនុជានាមិ ភិក្ខវេ បរិត្តាណ-កិដិកំ ឧទ្ធាសុធន្តិ[1] ។

---

១ ឱ. ម. ឧទ្ទសុធន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជញ្ជាំងកឿ ។ ពួកមនុស្សក៏នៅតែអើតមើលពីខាងលើជញ្ជាំងកឿទៀត ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបន្ទប់ ៣ យ៉ាង គឺ បន្ទប់មានជ្រុងបួន ១ បន្ទប់មានបណ្ដោយវែង ១ បន្ទប់មានដម្បូលខ្ពស់ ១ ។

(៣៣៩) សម័យនោះឯង ពួកភិក្ខុធ្វើបន្ទប់ត្រង់កណ្ដាលវិហារតូច ។ ទីឧបចារៈមិនមាន ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបន្ទប់ក្នុងទីសមគួរក្នុងវិហារតូច ឲ្យធ្វើបន្ទប់ត្រង់កណ្ដាលវិហារធំបាន ។

(៣៤០) សម័យនោះឯង ជើងជញ្ជាំងវិហារក៏ពុកផុយទៅ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទ្រនាប់ជើងជញ្ជាំង ។ ភ្លៀងក៏សាចមកត្រូវជញ្ជាំងវិហារ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រជីសសម្រាប់ការពារភ្លៀង ហើយលាបដីស្អិត(១) ។

---

១ អដ្ឋកថា ថាឲ្យយកដីស្អិតលាយផងមួយនឹងអាចម៍គោនិងផេះហើយលាបប្រជីសនោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកេ វិតានាទិកានុជាននំ

(៣៤១) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ តិណចុណ្ណកា អហិ ខន្ធេ បបតិ ។ សោ ភីតោ វិស្សរមកាសិ ។ ភិក្ខូ ឧបធាវិត្វា តំ ភិក្ខុំ ឯតទវោចុំ កិស្ស ត្វំ អាវុសោ វិស្សរមកាសីតិ ។ អថខោ សោ ភិក្ខូ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វិតានន្តិ ។

(៣៤២) តេន ខោ បន សមយេន ភិក្ខូ មញ្ចបាទេបិ បីឋបាទេបិ ថវិកាយោ លគ្គេន្តិ ។ ឧន្ទុរេហិបិ ឧបចិកាហិបិ ខជ្ជន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិត្តិខីលំ នាគទន្តកន្តិ ។

(៣៤៣) តេន ខោ បន សមយេន ភិក្ខូ មញ្ចេបិ បីឋេបិ ចីវរំ និក្ខិបន្តិ ។ ចីវរំ បរិភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វិហារេ ចីវរវំសំ ចីវររជ្ជុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(៣៨១) សម័យនោះឯង មានពស់ធ្លាក់ពីដម្បូលស្លាមកលើកភិក្ខុ ១ រូប ។ ភិក្ខុនោះខ្លាចក៏ស្រែកភ្ញាត់សំឡេង ។ ភិក្ខុទាំងឡាយក៏ស្ទុះទៅសួរភិក្ខុនោះដូច្នេះថា ម្នាលអាវុសោ ព្រោះហេតុអ្វីបានជាលោកស្រែកភ្ញាត់សំឡេងដល់ម៉្លេះ ។ ទើបភិក្ខុនោះបានប្រាប់សេចក្តីនុ៎ះ ដល់ពួកភិក្ខុ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ពិតានឡើង ។

(៣៨២) សម័យនោះឯង ពួកភិក្ខុព្យួរថង់នឹងជើងគ្រែខ្លះ នឹងជើងតាំងខ្លះ ។ អស់ទាំងសត្វកណ្តុរ នឹងកណ្តៀរ កាត់ដាច់ដាចអស់ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ចំរឹងជញ្ជាំងនឹងដៃកែវ ។

(៣៨៣) សម័យនោះឯង ពួកភិក្ខុទុកចីវរលើគ្រែខ្លះ លើតាំងខ្លះ ។ ចីវរក៏ផុយស្លាយអស់ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្នួចីវរ នឹងខ្សែស្ទៀងទុកក្នុងវិហារ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៦៦) តេន ខោ បន សមយេន វិហារា អនាឡិន្ទកា ហោន្តិ អប្បដិសរណា ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាឡិន្ទំ បឃនំ បកុដ្ដំ(១) ឱសារកន្តិ(២) ។ អាឡិន្ទា បាកដា ហោន្តិ ។ ភិក្ខូ ហិរិយន្តិ និបជ្ជិតុំ ។បេ។ អនុជានាមិ ភិក្ខវេ សំសរណកិដិកំ ឧគ្ឃាដនកិដិកន្តិ ។

(៣៦៧) តេន ខោ បន សមយេន ភិក្ខូ អជ្ឈោកាសេ ភត្តវិស្សគ្គំ ករោន្តា សីតេនបិ ឧណ្ហេនបិ កិលមន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧបដ្ឋានសាលន្តិ ។ ឧបដ្ឋានសាលា នីចវត្ថុកា ហោតិ ។ ឧទកេន ឱត្ថរិយតិ ។បេ។ អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។បេ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោហន្តា វិហញ្ញន្តិ ។បេ។ អនុជានាមិ ភិក្ខវេ

---

១ ឱ. ម. បកុដំ ។ ២ ឱ. ឱសារកន្តិ ។ ម. ឱសរណន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៤៤) សម័យនោះឯង វិហារនៅមិនទាន់មានរបៀង ឥតមានទីពឹងជ្រកកោនបាន ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយ៉ម្ង ជើងជញ្ជាំងប្ដូររណើបាំងសាចជុំវិញនឹងហោណាំង ។ យ៉ម្ងក៏នៅវាល (ឥតមានវត្ថុបិទបាំង) ។ ពួកភិក្ខុអកមានអៀនខ្មាស (មិនអាច) នឹងសិងបាន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរនាំងព្រួលសម្រាប់រុតចុះឡើង នឹងឡប់ថ្ងៃ ។

(៣៤៥) សម័យនោះឯង ពួកភិក្ខុធ្វើនូវការឆាន់អាហារក្នុងទីវាលលំបាកដោយត្រជាក់ខ្លះ ក្ដៅខ្លះ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបដ្ឋានសាលា(១) ។ ឧបដ្ឋានសាលាក៏មានទីទាប ។ ទឹកក៏លិច ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង ។ ខឿនសាលានោះក៏រលំ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកខឿន ៣ យ៉ាង គឺ ខឿនឥដ្ឋ ១ ខឿនថ្ម ១ ខឿនឈើ ១ ។ ពួកភិក្ខុឡើងទៅតាមខឿននោះក៏លំបាក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

---

១ សាលាសម្រាប់សម្រេចសាធារណកិច្ចគ្រប់យ៉ាង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តយោ សោបាណេ ឥដ្ឋកាសោបាណំ សិលាសោបាណំ ទារុសោបាណន្តិ ។ អារោហន្តា បរិបតន្តិ ។បេ។ អនុជានាមិ ភិក្ខវេ អាលម្ពនពាហន្តិ ។ ឧបដ្ឋានសាលាយ តិណចុណ្ណំ បរិបតតិ ។បេ។ អនុជានាមិ ភិក្ខវេ ឱគុម្ផេត្វា ឧល្លិត្តាវលិត្តំ កាតុំ សេតវណ្ណំ កាឡវណ្ណំ គេរុកបរិកម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកំ ចីវរវំសំ ចីវររជ្ជុន្តិ ។

(៣៦៦) តេន ខោ បន សមយេន ភិក្ខូ អជ្ឈោកាសេ ឆមាយ ចីវរំ បត្ថរន្តិ ។ ចីវរំ បំសុកិតំ ហោតិ ។បេ។ អនុជានាមិ ភិក្ខវេ អជ្ឈោកាសេ ចីវរវំសំ ចីវររជ្ជុន្តិ ។បេ។ បានីយំ ឱតប្បតិ ។បេ។ អនុជានាមិ ភិក្ខវេ បានីយសាលំ បានីយមណ្ឌបន្តិ ។ បានីយសាលា នីចវត្ថុកា ហោតិ ។ ឧទកេន ឱត្ថរិយតិ ។បេ។ អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។បេ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



តថាគតអនុញ្ញាតឲ្យធ្វើជណ្ដើរ ៣ យ៉ាង គឺ ជណ្ដើរឥដ្ឋ ១ ជណ្ដើរថ្ម ១ ជណ្ដើរឈើ ១ ។ ពួកភិក្ខុឡើងតាមជណ្ដើរនោះក៏ធ្លាក់មកវិញ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃឡើង ។ កំទេចស្មៅក៏ធ្លាក់ពេយពាយចុះមកក្នុងឧបដ្ឋានសាលា ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបជម្រុលហើយលាប ទាំងខាងក្នុងខាងក្រៅ ហើយបរិកម្មឲ្យមានពណ៌ស ពណ៌ខ្មៅ ពណ៌រង់ គូរគំនូរកម្រងផ្កា គំនូរក្រវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់ ៥ ស្នរចីវរ ទីងខ្សែសៀង ។

(៣៤៦) សម័យនោះឯង ពួកភិក្ខុហាលចីវរលើដីក្នុងទីវាល ។ ចីវរក៏ប្រឡាក់អាចម៍ដី ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើស្នរចីវរ ទីងខ្សែសៀងក្នុងទីវាល ។បេ។ ទឹកសម្រាប់ឆាន់ក៏ក្ដៅ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើរោងសម្រាប់ដាក់ទឹកឆាន់ ទីងបារាំសម្រាប់ដាក់ទឹកឆាន់ ។ រោងសម្រាប់ដាក់ទឹកឆាន់នោះក៏មានទីទាប ។ ទឹកក៏លិច ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង ។ ខឿនរោងនោះក៏រលំ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យករខឿន ៣ យ៉ាង គឺ ខឿន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុចយន្តិ ។ អារោ-ហន្តា វិហញ្ញន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ តយោ សោបាណោ ឥដ្ឋកាសោបាណំ សិលាសោបាណំ ទារុ-សោបាណន្តិ ។ អារោហន្តា បរិបតន្តិ ។ បេ ។ អនុ-ជានាមិ ភិក្ខវេ អាលម្ពនពាហន្តិ ។ បានីយសាលាយ តិណចុណ្ណំ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឱគុម្ផេត្វា ឧល្លិត្តាវលិត្តំ កាតុំ សេតវណ្ណំ កាឡវណ្ណំ គេរុកបរិ-កម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកំ ចីវរវំសំ ចីវររជ្ជុន្តិ ។ បានីយភាជនំ ន សំវិជ្ជតិ ។ បេ ។ អនុជានាមិ ភិក្ខវេ បានីយសង្ខំ បានីយសរាវកន្តិ ។

(៣៤៧) តេន ខោ បន សមយេន វិហារា អប-រិក្ខិត្តា ហោន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ បរិក្ខិបិតុំ តយោ បាការេ ឥដ្ឋកាបាការំ សិលាបាការំ ទារុបា-ការន្តិ ។ កោដ្ឋកោ ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ កោដ្ឋកន្តិ ។ កោដ្ឋកោ នីចវត្ថុកោ ហោតិ ។ ឧទកេន ឱត្ថរិយតិ ។ បេ ។ អនុជានាមិ ភិក្ខវេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥដ្ឋ ១ ខឿនថ្ម ១ ខឿនឈើ ១ ។ ពួកភិក្ខុឡើងទៅតាមខឿននោះក៏លំបាក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជណ្តើរ ៣ យ៉ាង គឺ ជណ្តើរឥដ្ឋ ១ ជណ្តើរថ្ម ១ ជណ្តើរឈើ ១ ។ ពួកភិក្ខុឡើងទៅតាមជណ្តើរក៏ធ្លាក់មកវិញ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃឡើង ។ កំទេចស្មៅក៏ធ្លាក់រោយរាយចុះមក ក្នុងរោងសម្រាប់ដាក់ទឹកឆាន់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដំបូល ហើយឲ្យលាបទាំងខាងក្នុងខាងក្រៅ បរិកម្មឲ្យមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ គូរគំនូរភ្ញីផ្កា គំនូរភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់ ៥ ស្នួរចីវរនឹងខ្សែស្បៀង ។ (គ្រានោះ) ភាជនសម្រាប់ដាក់ទឹកឆាន់មិនទាន់មាន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស័ង្ខសម្រាប់ដាក់ទឹកឆាន់និងផ្តិលទឹក ។

(៣៤៧) សម័យនោះឯងវិហារមិនមានគ្រឿងបិទបាំង ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបិទបាំងដោយកំពែង ៣ យ៉ាង គឺ កំពែងឥដ្ឋ ១ កំពែងថ្ម ១ កំពែងឈើ ១ ។ បន្ទប់ទឹកមិនទាន់មាន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបន្ទប់ទឹក ។ បន្ទប់ទឹកមានទីទាប ។ ទឹកក៏លិច ។ បេ ។ ព្រះអង្គទ្រង់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឧច្ចវត្ថុកំ កាតុន្តិ ។ កោដ្ឋកស្ស កវាដំ ន ហោតិ ។បេ។ អនុជានាមិ ភិក្ខវេ កវាដំ បិដ្ឋសង្ឃាដំ ឧទុក្ខលិកំ ឧត្តរបាសកំ អគ្គឡវដ្ដិំ កបិសីសកំ សូចិកំ ឃដិកំ តាឡច្ឆិទ្ទំ អាវិញ្ឆនច្ឆិទ្ទំ អាវិញ្ឆនរជ្ជុន្តិ ។ កោដ្ឋកេ(១) តិណចុណ្ណំ បរិបតតិ ។បេ។ អនុជានាមិ ភិក្ខវេ ឱគុម្ពេត្វា ឧល្លិត្តាវលិត្តំ កាតុំ សេតវណ្ណំ កាឡវណ្ណំ គេរុកបរិកម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកន្តិ ។

(៣៤៨) តេន ខោ បន សមយេន បរិវេណំ ចិក្ខល្លំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មរុម្ពំ ឧបកិរិតុន្តិ ។ ន បរិយាបុណន្តិ ។បេ។ អនុជានាមិ ភិក្ខវេ បទរសិលំ និក្ខិបិតុន្តិ ។ ឧទកំ សន្តិដ្ឋតិ ។បេ។ អនុជានាមិ ភិក្ខវេ ឧទកនិទ្ធមនន្តិ ។

១ ឱ. កោដ្ឋកា ។ ម. កោដ្ឋកាយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទំឡប់ខ្ពល់ឡើង ។ សន្ទះទ្វារបន្ទប់ក៏មិនទាន់មាន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ដំណាប់ក្រោម ដំណាប់លើ មេទ្វារ ត្រដោកទ្វារ ខ្ទុកទ្វារ គន្ទឹះទ្វារខាងលើ ប្រហោងសោ ប្រហោងសម្រាប់ទាញ ទឹងខ្សែសម្រាប់ទាញ ។ កំទេចស្មៅក៏ធ្លាក់រោយរាយចុះមកក្នុងបន្ទប់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបជម្រុះហើយធ្វើប្រដេស ហើយលាបទាំងខាងក្នុងខាងក្រៅ លាបឲ្យមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ ធ្វើជាក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥ ។

(៣៤៨) សម័យនោះឯង ទីបរិវេណមានភក់ជ្រាំ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាត ឲ្យចាក់ក្រាលក្រួសរ៉ែន (នៅទីនោះ) ។ ក្រួសរ៉ែនក៏មិនបានរាបស្មើ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលថ្ម ។ ទឹកក៏ដក់នៅ (លើថ្មនោះ) ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតប្រឡាយទឹក ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៣៤៩] តេន ខោ បន សមយេន ភិក្ខូ បរិវេណេ តហិំ តហិំ អគ្គិដ្ឋានំ ករោន្តិ ។ បរិវេណំ ឧក្លាបំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឯកមន្តំ អគ្គិសាលំ កាតុន្តិ ។ អគ្គិសាលា នីចវត្ថុកា ហោតិ ។ ឧទកេន ឱត្ថរិយតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុន្តិ ។ ចយោ បរិបតតិ ។ បេ ។ អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ ឥដ្ឋកាចយំ សិលាចយំ ទារុ-ចយន្តិ ។ អារោហន្តា វិហញ្ញន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ តយោ សោបានេ ឥដ្ឋកាសោបានំ សិលា-សោបានំ ទារុសោបានន្តិ ។ អារោហន្តា បរិបតន្តិ ។ បេ ។ អនុជានាមិ ភិក្ខវេ អាលម្ពនពាហន្តិ ។ អគ្គិសា-លាយ កវាដំ ន ហោតិ ។ បេ ។ អនុជានាមិ ភិក្ខវេ កវាដំ បិដ្ឋសង្ឃាដំ ឧទុក្ខលិកំ ឧត្តរបាសកំ អគ្គឡ-វដ្ដិំ កបិសីសកំ សូចិកំ ឃដិកំ តាឡច្ឆិទ្ទំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៣៤៩) សម័យនោះឯង ភិក្ខុទាំងឡាយធ្វើបង្រ្កានត្រង់ទីនោះ ៗ ក្នុងបរិវេណ ៗ ទីបរិវេណក៏ខ្ចាំដោយសម្រាម ៗ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើរោងភ្លើង ក្នុងទីដ៏សមគួរ ៗ រោងភ្លើងមានទីទាប ៗ ទឹកក៏លិច ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង ៗ ខឿន(រោងភ្លើងនោះ)រលំ ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រខឿន ៣ យ៉ាង គឺ ខឿនឥដ្ឋ ១ ខឿនថ្ម ១ ខឿនឈើ ១ ៗ ពួកភិក្ខុឡើង (តាមខឿននោះទៅ) ក៏លំបាក ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជណ្ដើរ ៣ យ៉ាង គឺ ជណ្ដើរឥដ្ឋ ១ ជណ្ដើរថ្ម ១ ជណ្ដើរឈើ ១ ៗ ពួកភិក្ខុឡើងទៅ (តាមជណ្ដើរ)ក៏ធ្លាក់ចុះមក ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃឡើង ៗ សន្លឹះទ្វារនៃរោងភ្លើង នៅមិនទាន់មាន ៗ បេ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្លឹះទ្វារ ក្របទ្វារ ដំណាប់ក្រោម ដំណាប់លើ មេទ្វារ ត្រដោកទ្វារ គន្លឹះទ្វារខាងលើ ប្រហោងសោ ប្រហោងសម្រាប់ដាក់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាវិញ្ឆនច្ឆិទ្ទំ អាវិញ្ឆនរជ្ជុន្តិ ។ អត្ថិសាលាយ តិណ-
ចុណ្ណំ បរិបតតិ ។បេ។ អនុជានាមិ ភិក្ខវេ ឱគុម្ផេត្វា
ឧល្លិត្តាវលិត្តំ កាតុំ សេតវណ្ណំ កាឡវណ្ណំ គេរុកប-
រិកម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកំ
ចីវរវំសំ ចីវររជ្ជុន្តិ ។ អារាមោ អបរិក្ខិត្តោ ហោតិ ។
អជកាបិ បសុកាបិ ឧបរោបេ វិហេឋេន្តិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បរិក្ខិបិតុំ
តយោ វាដេ វេឡុវាដំ កណ្ដកវាដំ(១) បរិខន្តិ ។ កោដ្ឋកោ
ន ហោតិ ។ តថេវ អជកាបិ បសុកាបិ ឧបរោបេ វិហេ-
ឋេន្តិ ។ អនុជានាមិ ភិក្ខវេ កោដ្ឋកំ អបេសិំ យមកក-
វាដំ តោរណំ បលិឃន្តិ ។ កោដ្ឋកេ តិណចុណ្ណំ បរិបតតិ
។ បេ ។ អនុជានាមិ ភិក្ខវេ ឱគុម្ផេត្វា ឧល្លិត្តាវលិត្តំ

---

១ ឱ. ម. វាដេ វេឡុវាដំ កណ្ដកវាដំ ។ ម. កណ្ដកវាដំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ខ្សែតាញ និងខ្សែតាញ ។ កំទេចស្មៅធ្លាក់រាយពាយចុះមក ក្នុងរោងភ្លើង ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបជម្បូល ហើយធ្វើប្រដឹសលាប ទាំងខាងក្នុងខាងក្រៅ ធ្វើឲ្យមានពណ៌ស ពណ៌ខ្មៅ លាបដោយរេង្គ ធ្វើជាក្បាច់ផ្កា ក្បាច់វល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់ ៥ ស្ពរចីវរ និងខ្សែស្បៀង ។ អារាមនៅមិនទាន់មានរបង ។ ពួកសត្វពពែនិងសត្វចិញ្ចឹម (ឯទៀត ៗ) តែងចូលទៅបៀតបៀនដំណាំ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបិទបាំងរបង ៣ យ៉ាង គឺ របងឫស្សី ១ របងបន្លា ១ និងស្នាមក្លោះ ១ ។ ខ្លោងទ្វារនៅមិនទាន់មាន ។ ពួកសត្វពពែនិងសត្វចិញ្ចឹម (ឯទៀត ៗ) នៅតែចូលទៅបៀតបៀនដំណាំបានដដែល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លោងទ្វារ ទ្វារគោបបន្លា(១) សន្ទះទ្វារទាំងគូ របងសសរ និងទ្វារដើងគុល ។ កំទេចស្មៅក៏ធ្លាក់រាយពាយចុះមកក្នុងខ្លោងទ្វារ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបជម្បូលធ្វើប្រដឹស ហើយលាប

១ អដ្ឋកថា ពន្យល់ថា ទ្វារញាត់បន្លាដែលគេបញ្ចូលឈើសម្រួចក្នុងមេឈើវែងហើយចងរឹតបន្លាឲ្យណែនហើយទើបធ្វើ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



កាតុំ សេតវណ្ណំ កាឡវណ្ណំ គេរុកបរិកម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកំ ។ អារាមោ ចិក្ខល្លោ ហោតិ ។បេ។ អនុជានាមិ ភិក្ខវេ មរុម្ពំ ឧបកិរិតុន្តិ ។ ន បរិយាបុណន្តិ ។បេ។ អនុជានាមិ ភិក្ខវេ បទរសិលំ និក្ខិបិតុន្តិ ។ ឧទកំ សន្តិដ្ឋតិ ។បេ។ អនុជានាមិ ភិក្ខវេ ឧទកនិទ្ធមនន្តិ ។

(៣៩០) តេន ខោ បន សមយេន រាជា មាគធោ សេនិយោ ពិម្ពិសារោ សង្ឃស្ស អត្ថាយ សុធាមត្តិកាលេបនំ បាសាទំ ការាបេតុកាមោ ហោតិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កឹ នុ ខោ ភគវតា ឆទនំ អនុញ្ញាតន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ច ឆទនានិ ឥដ្ឋកាឆទនំ សិលាឆទនំ សុធាឆទនំ តិណច្ឆទនំ បណ្ណច្ឆទនន្តិ ។

ភាណវារំ និដ្ឋិតំ បឋមំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទាំងខាងក្នុងខាងក្រៅ លាបឲ្យមានពណ៌ស ពណ៌ខ្មៅ លាបដោយវត្ត ធ្វើក្បាច់ផ្កា ក្បាច់វល្លិ ក្បាច់ធ្មេញមករ និងក្បាច់មានខ្សែរទាប់ ៥ ៗ អាចមក៏មានគក់ជ្រាំ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលក្រួសរៀន ។ ក្រួសនោះក៏មិនបានរាបស្មើ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាលថ្ម ។ ទឹកក៏ដក់នៅ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយទឹក ។

(៣៩០) សម័យនោះឯង ព្រះបាទពិម្ពិសារមគធសេនិយរាជទ្រង់មានបំណងឲ្យគេសាងប្រាសាទលាបដោយបាយអ ដើម្បីប្រយោជន៍ដល់សង្ឃ ។ វេលានោះ ពួកភិក្ខុមានសេចក្តីត្រិះរិះថា គ្រឿងសម្រាប់ប្រក់ព្រះមានព្រះភាគ បានអនុញ្ញាតហើយឬ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រឿងប្រក់ ៥ យ៉ាង គឺ ប្រក់ដោយឥដ្ឋ ១ ប្រក់ដោយថ្ម ១ ប្រក់ដោយបាយអ ១ ប្រក់ដោយស្មៅ ១ ប្រក់ដោយស្លឹកឈើ ១ ។

ចប់ភាណវារៈ ទីបួន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៥១) តេន ខោ បន សមយេន អនាថបិណ្ឌិកោ គហបតិ រាជគហកស្ស សេដ្ឋិស្ស ភគិនីបតិកោ ហោតិ ។ អថ ខោ អនាថបិណ្ឌិកោ គហបតិ រាជគហំ អគមាសិ កេនចិទេវ ករណីយេន ។

(៣៥២) តេន ខោ បន សមយេន រាជគហកេន សេដ្ឋិនា ស្វាតនាយ ពុទ្ធប្បមុខោ សង្ឃោ និមន្តិតោ ហោតិ ។ អថ ខោ រាជគហកោ សេដ្ឋី ទាសេ ច កម្មការេ ច អាណាបេសិ តេនហិ ភណេ កាលស្សេវ ឧដ្ឋាយ យាគុយោ បចថ ភត្តានិ បចថ សូបានិ សម្បាទេថ ឧត្តរិភង្គានិ សម្បាទេថាតិ ។

(៣៥៣) អថ ខោ អនាថបិណ្ឌិកស្ស គហបតិស្ស ឯតទហោសិ បុព្វេ ខ្វាយំ គហបតិ មយិ អាគតេ សព្វកិច្ចានិ និក្ខិបិត្វា មមញ្ញេវ សទ្ធឹ បដិសម្មោទតិ សោ ទានាយំ វិក្ខិត្តរូបោ ទាសេ ច កម្មការេ ច អាណាបេសិ តេនហិ ភណេ កាលស្សេវ ឧដ្ឋាយ

## សេនាសនក្ខន្ធកៈ រឿងអនាថបិណ្ឌិកសេដ្ឋីនឹងរឿងរាជគហសេដ្ឋី

(៣៩១) សម័យនោះឯង អនាថបិណ្ឌិកគហបតិជាប្តីប្អូនស្រីរបស់រាជគហសេដ្ឋី គឺជាប្អូនថ្លៃរាជគហសេដ្ឋី ។ គ្រានោះ អនាថបិណ្ឌិកគហបតិបានទៅកាន់ក្រុងរាជគ្រឹះដោយកិច្ចការនីមួយ ។

(៣៩២) សម័យនោះឯង រាជគហសេដ្ឋីនិមន្តព្រះសង្ឃមានព្រះពុទ្ធអង្គជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ។ ឯរាជគហសេដ្ឋី ក៏បានបង្គាប់ខ្ញុំប្រុសស្រីខ្លះ នឹងពួកអ្នកធ្វើការឈ្នួលខ្លះថា នែនាយរាល់គ្នា បើដូច្នោះ ចូរអ្នករាល់គ្នាក្រោកពីព្រលឹមហើយ ចំអិនបបរ ចំអិនបាយ ចាត់ចែងសម្ល នឹងតាក់តែងសម្លឧត្តរិភង្គៈ (ឲ្យល្អ) ។

(៣៩៣) លំដាប់នោះ អនាថបិណ្ឌិកគហបតិមានសេចក្តីត្រិះរិះថា កាលពីដើមបើអញបានមកដល់ហើយ គហបតិនេះក៏រមែងតែបញ្ឈប់កិច្ចការទាំងពួង ហើយនិយាយរាក់ទាក់មកនឹងអញ ក៏ឥឡូវគហបតិនេះជាអ្នកតោះតើយ (បែរទៅ) បង្គាប់ខ្ញុំប្រុសស្រីខ្លះ ពួកអ្នកធ្វើការឈ្នួលខ្លះថា នែនាយរាល់គ្នា បើដូច្នោះចូរអ្នករាល់គ្នាក្រោកពីព្រលឹម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យាគុយោ បចថ ភត្តានិ បចថ សូបានិ សម្បាទេថ ឧត្តរិភង្គានិ សម្បាទេថាតិ កិន្នុ ខោ ឥមស្ស គហបតិស្ស អាវាហោ វា ភវិស្សតិ វិវាហោ វា ភវិស្សតិ មហាយញ្ញោ វា បច្ចុបដ្ឋិតោ រាជា វា មាគធោ សេនិយោ ពិម្ពិសារោ និមន្តិតោ ស្វាតនាយ សទ្ធឹ ពលនិកាយេនាតិ(១) ។

(៣៨៥) អថខោ រាជគហកោ សេដ្ឋី ទាសេ ច កម្មករេ ច អាណាបេត្វា យេន អនាថបិណ្ឌិកោ គហបតិ តេនុបសង្កមិ ឧបសង្កមិត្វា អនាថបិណ្ឌិកេន គហបតិនា សទ្ធឹ បដិសម្មោទិត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ រាជគហកំ សេដ្ឋឹ អនាថបិណ្ឌិកោ គហបតិ ឯតទវោច បុព្វេ ខោ ត្វំ គហបតិ មយិ អាគតេ សព្វកិច្ចានិ និក្ខិបិត្វា មមញ្ញេវ សទ្ធឹ បដិសម្មោទសិ សោទានិ ត្វំ វិក្ខិត្តរូបោ ទាសេ ច កម្មករេ ច អាណាបេសិ តេនហិ ភណេ កាលស្សេវ ឧដ្ឋាយ យាគុយោ បចថ ភត្តានិ បចថ សូបានិ សម្បាទេថ

---

១ ឱ. ម. ពលកាយេនាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហើយចំអិនបបរ ចំអិនបាយ ចាត់ចែងសម្ល ទឹងតាក់តែងសម្លឧត្តរិភង្គៈ (ម្ហូប) ប្រហែលជាគហបតីនេះ មានអាវាហមង្គលឬវិវាហមង្គល ឬក៏មហាយញ្ញពិធី ឬ ក៏នោះគាត់អញ្ជើញព្រះបាទពិម្ពិសារមគធសេនិយរាជ ព្រមទាំងពួកពលឲ្យមកទទួលក្រយាហារក្នុងថ្ងៃស្អែកឡើង ។

(៣៥៤) គ្រានោះ រាជគហសេដ្ឋីបង្គាប់ខ្ញុំប្រុសស្រីខ្លះ ពួកអ្នកធ្វើការឈ្នួលខ្លះ រួចហើយទើបចូលទៅរកអនាថបិណ្ឌិកគហបតិ លុះចូលទៅដល់ហើយក៏និយាយរាក់ទាក់ ជាមួយនឹងអនាថបិណ្ឌិកគហបតី ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ អនាថបិណ្ឌិកគហបតិ និយាយនឹងរាជគហសេដ្ឋីដែលអង្គុយក្នុងទីដ៏សមគួរដោយពាក្យដូច្នេះថា នែគហបតិកាលពីដើមបើខ្ញុំបានមកដល់ហើយ អ្នករមែងតែបញ្ឈប់កិច្ចការទាំងពួង ហើយនិយាយរាក់ទាក់មកជាមួយនឹងខ្ញុំ ក៏ឥឡូវនេះអ្នកធ្វើតោះតើយ បែរជាបង្គាប់ខ្ញុំប្រុសស្រីខ្លះ ពួកអ្នកធ្វើការឈ្នួលខ្លះ ថា នែនាយរាល់គ្នា បើដូច្នេះចូរអ្នករាល់គ្នាក្រោកពីព្រលឹម ហើយចំអិនបបរ ចំអិនបាយ ចាត់ចែងសម្ល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឧត្តរិភង្គានិ សម្បាទេថាតិ កិន្នុ ខោ តេ គហបតិ អាវាហោ វា ភវិស្សតិ វិវាហោ វា ភវិស្សតិ មហាយញ្ញោ វា បច្ចុបដ្ឋិតោ រាជា វា មាគធោ សេនិយោ ពិម្ពិសារោ និមន្តិតោ ស្វាតនាយ សទ្ធឹ ពលនិកាយេនាតិ ។ ន មេ ខោ(១) គហបតិ អាវាហោ វា(២) ភវិស្សតិ នបិ វិវាហោ វា ភវិស្សតិ នបិ រាជា មាគធោ សេនិយោ ពិម្ពិសារោ និមន្តិតោ ស្វាតនាយ សទ្ធឹ ពលនិកាយេន អបិច មេ មហាយញ្ញោ បច្ចុបដ្ឋិតោ ស្វាតនាយ ពុទ្ធប្បមុខោ សង្ឃោ និមន្តិតោតិ ។ ពុទ្ធោតិ ត្វំ គហបតិ វទេសីតិ ។ ពុទ្ធាហំ គហបតិ វទាមីតិ ។ ពុទ្ធោតិ ត្វំ គហបតិ វទេសីតិ ។ ពុទ្ធាហំ គហបតិ វទាមីតិ ។ ពុទ្ធោតិ ត្វំ គហបតិ វទេសីតិ ។ ពុទ្ធាហំ គហបតិ វទាមីតិ ។ ឃោសោបិ ខោ ឯសោ គហបតិ ទុល្លភោ លោកស្មឹ យទិទំ ពុទ្ធោតិ(៣) សក្កា នុ ខោ គហបតិ

---

១ អយំ ខោសទ្ទោ ឱ. ម. បោត្ថកេសុ ន ទិស្សតិ ។ ២ វាសទ្ទោ ឱ. ម. បោត្ថកេសុ សព្វត្ថ ន ទិស្សតិ ។ ៣ ឱ. ម. យទិទំ ពុទ្ធោ ពុទ្ធោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នឹងតាក់តែងសម្ភារៈភត្តកិច្ចៈ (ផ្សេងៗ) នែគហបតិ អាវាហមង្គល នឹងវិវាហមង្គល ឬ មហាយញ្ញពិធីនឹងកើតមានឡើង ប្រាកដដល់អ្នកឬ ឬមួយអ្នកបានអញ្ជើញព្រះបាទពិម្ពិសារមគធសេនិយរាជ ព្រមទាំងពួកពលឲ្យមកទទួលក្រយាហារក្នុងថ្ងៃស្អែក ៗ រាជគហសេដ្ឋីនិយាយថា នែគហបតិ អាវាហ-មង្គលនឹងវិវាហមង្គលរបស់ខ្ញុំមិនមានទេ ឬមួយខ្ញុំអញ្ជើញព្រះបាទពិម្ពិសារមគធសេនិយរាជ ព្រមទាំងពួកពល ឲ្យមកទទួល ក្រយាហារក្នុងថ្ងៃស្អែកនេះក៏ទេដែរ ខ្ញុំមានតែមហាយញ្ញពិធីមែន គឺនិមន្តព្រះសង្ឃមានព្រះពុទ្ធអង្គជាប្រធានមកទទួលភត្តក្នុងថ្ងៃស្អែកនេះ ៗ អនាថបិណ្ឌិកគហបតិសួរថា នែគហបតិ អ្នកពោលថា ពុទ្ធោ ដូច្នេះឬ ៗ រាជគហសេដ្ឋីតបថា អើគហបតិ ខ្ញុំពោលថា ពុទ្ធោ ដូច្នេះមែន ៗ អនាថបិណ្ឌិកគហបតិ សួរទៀតថា នែគហបតិ អ្នកពោលថា ពុទ្ធោ ដូច្នេះឬ ៗ រាជគហសេដ្ឋីតបថា អើគហបតិ ខ្ញុំពោលថា ពុទ្ធោ ដូច្នេះមែន ៗ អនាថបិណ្ឌិកគហបតិ សួរទៀតថា នែគហបតិ អ្នកពោលថា ពុទ្ធោ ដូច្នេះឬ ៗ រាជគហសេដ្ឋីតបថា អើគហបតិ ខ្ញុំពោលថា ពុទ្ធោ ដូច្នេះមែន ៗ អនាថបិណ្ឌិកគហបតិពោលទៀតថា អើគហបតិ សំឡេងកឹកកងថា ពុទ្ធោ ដូច្នេះ នេះជាសំឡេងដែលគេរកបាន ដោយកម្រក្នុងលោក ម្នាលគហបតិ តើខ្ញុំនឹងអាច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥមំ កាលំ តំ ភគវន្តំ ទស្សនាយ ឧបសង្កមិតុំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ អកាលោ ខោ គហបតិ ឥមំ កាលំ តំ ភគវន្តំ ទស្សនាយ ឧបសង្កមិតុំ អរហន្តំ សម្មាសម្ពុទ្ធំ ស្វេទានិ ត្វំ កាលេន តំ ភគវន្តំ ទស្សនាយ ឧបសង្កមិស្សសិ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។

(៣៩៩) អថខោ អនាថបិណ្ឌិកោ គហបតិ ស្វេទានាហំ កាលេន តំ ភគវន្តំ ទស្សនាយ ឧបសង្កមិស្សាមិ អរហន្តំ សម្មាសម្ពុទ្ធន្តិ ពុទ្ធគតាយ សតិយា និបជ្ជិ(១) រត្តិយា សុទំ តិក្ខត្តុំ ឧដ្ឋាសិ បភាតន្តិ មញ្ញមានោ ។ អថខោ អនាថបិណ្ឌិកោ គហបតិ យេន សីតវនទ្វារំ តេនុបសង្កមិ ។ អមនុស្សា ទ្វារំ វិវរិំសុ ។ អថខោ អនាថបិណ្ឌិកស្ស គហបតិស្ស នគរម្ហា និក្ខមន្តស្ស អាលោកោ អន្តរធាយិ ។ អន្ធការោ បាតុរហោសិ ។ ភយំ ឆម្ភិតត្តំ លោមហំសោ ឧទបាទិ ។ តតោវ បុន និវត្តិតុកាមោ អហោសិ ។

១. ម. និបជ្ជិត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះទាន់ក្នុងពេលនេះបានដែរឬ ។ រាជគហសេដ្ឋីតបថា ម្នាលគហបតិ កាលនេះជាកាលមិនគួរដើម្បីនឹងចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះទាន់ក្នុងពេលនេះទេ ចាំដល់វេលាថ្ងៃស្អែកសឹមអ្នកចូលទៅគាល់ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះទើបគួរ ។

(៣៥៥) គ្រានោះ អនាថបិណ្ឌិកគហបតិគិតថា ឥឡូវនេះវេលាថ្ងៃស្អែកនេះ អញនឹងចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មា-សម្ពុទ្ធនោះទើបគួរ គិតហើយក៏ដកល់ស្មារតី ចំពោះទៅរកព្រះពុទ្ធជាអារម្មណ៍ ហើយក៏ដេកទៅ ក៏ក្នុងវេលាយប់ (នោះ) អនាថបិណ្ឌិក-គហបតិស្មានថាភ្លឺហើយ ក៏ក្រោកឡើង ៣ ដង ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិចូលទៅកាន់ទ្វារសីតវន (ព្រៃត្រជាក់) ។ ពួកអមនុស្ស[១]ក៏នាំគ្នាបើកទ្វារឲ្យ ។ កាលអនាថបិណ្ឌិកគហបតិចេញផុតអំពីនគរហើយ ពន្លឺ ក៏បាត់ទៅវិញ ។ ស្រាប់តែមានងងឹតកើតឡើង ។ ភ័យសេចក្តីតក់ស្លុតនិងព្រឺរោមក៏កើតឡើង ។ អនាថបិណ្ឌិកគហបតិចង់ត្រឡប់អំពីទីនោះមកវិញ ។

---

១ អមនុស្ស គឺខ្មោចឬទេវតា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៩៦) អថ ខោ សីវកោ យក្ខោ អន្តរហិតោ សទ្ទមនុស្សាវេសិ

សតំ ហត្ថី សតំ អស្សា សតំ អស្សតរីរថា
សតំ កញ្ញាសហស្សានិ អាមុត្តមណិកុណ្ឌលា
ឯកស្ស បទវីតិហារស្ស កលំ នាគ្ឃន្តិ សោឡសឹ ។
អភិក្កម គហបតិ អភិក្កម គហបតិ អភិក្កន្តន្តេ
សេយ្យោ នោ បដិក្កន្តន្តិ ។

(៣៩៧) អថ ខោ អនាថបិណ្ឌិកស្ស គហបតិស្ស អន្ធការោ អន្តរធាយិ ។ អាលោកោ បាតុរហោសិ ។ យំ អហោសិ ភយំ ឆម្ភិតត្តំ លោមហំសោ សោ បដិប្បស្សម្ភិ ។ ទុតិយម្បិ ខោ ។បេ។ តតិយម្បិ ខោ អនាថបិណ្ឌិកស្ស គហបតិស្ស អាលោកោ អន្តរធាយិ ។ អន្ធការោ បាតុរហោសិ ។ ភយំ ឆម្ភិតត្តំ លោមហំសោ ឧទបាទិ ។ តតោ វ បុន និវត្តិតុកាមោ អហោសិ ។ តតិយម្បិ ខោ សីវកោ យក្ខោ អន្តរហិតោ សទ្ទមនុស្សាវេសិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(៣៩៦) គ្រានោះ សីវកយក្សដែលបាត់ទៅ ក៏បញ្ចេញសម្លេងឡើងថា

ដំរី ១ សែន សេះ ១ សែន រថទឹមដោយមេសេះអស្សតរ ១ សែន ស្រីពំទង់ដែលប្រដាប់ដោយកុណ្ឌល ជាវិការៈនៃកែវមណី ១ សែន ក៏មិនដល់មួយចំណិត នៃការឈានទៅ ១ ជំហាន ដែលបណ្ឌិតចែកឲ្យជាចំណែក ១៦ អស់វារៈ ១៦ ដងទេ ។

ម្នាលគហបតិ អ្នកចូរឈានដើរទៅ ម្នាលគហបតិ អ្នកចូរឈានដើរទៅ ការឈានដើរទៅរបស់អ្នកប្រសើរណាស់ ការត្រឡប់ទៅវិញ មិនប្រសើរទេ ។

(៣៩៧) លំដាប់នោះ អនាថបិណ្ឌិកគហបតិ ក៏បាត់ងងឹតទៅវិញ ។ ពន្លឺក៏កើតប្រាកដឡើង ។ ភ័យសេចក្តីតក់ស្លុតព្រឺរោមនោះឯងក៏រម្ងាប់បាត់ទៅ ។ អនាថបិណ្ឌិកគហបតិ ក៏បាត់ពន្លឺអស់វារៈពីរដងផង ។ បេ ។ អស់វារៈបីដងផង ។ ងងឹតក៏កើតប្រាកដឡើង ។ ភ័យសេចក្តីតក់ស្លុតព្រឺរោមក៏កើតឡើង ។ អនាថបិណ្ឌិកគហបតិ ចង់ត្រឡប់អំពីទីនោះមកវិញ សីវកយក្សដែលបាត់ទៅហើយនោះ ស្រាប់តែបញ្ចេញសម្លេងអស់វារៈជាគំរប់បីដងថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សតំ ហត្ថី សតំ អស្សា សតំ អស្សតរីរថា
សតំ កញ្ញា សហស្សានិ អាមុត្តមណិកុណ្ឌលា
ឯកស្ស បទវីតិហារស្ស កលំ នាគ្ឃន្តិ សោឡសឹ ។

អភិក្កម គហបតិ អភិក្កម គហបតិ អភិក្កន្តន្តេ សេយ្យោ នោ បដិក្កន្តន្តិ ។ តតិយម្បិ ខោ អនាថបិណ្ឌិកស្ស គហបតិស្ស អន្ធការោ អន្តរធាយិ ។ អាលោកោ បាតុរហោសិ ។ យំ អហោសិ ភយំ ឆម្ភិតត្តំ លោមហំសោ សោ បដិប្បស្សម្ភិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ យេន សីតវនំ តេនុបសង្កមិ ។

(៣៥៨) តេន ខោ បន សមយេន ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ អព្ភោកាសេ ចង្កមតិ ។ អទ្ទសា ខោ ភគវា តំ[1] អនាថបិណ្ឌិកំ គហបតឹ ទូរតោវ អាគច្ឆន្តំ ទិស្វាន ចង្កមា ឱរោហិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អនាថបិណ្ឌិកំ គហបតឹ ឯតទវោច ឯហិ សុទត្តាតិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ នាមេន មំ ភគវា អាលបតីតិ ហដ្ឋោ ឧទគ្គោ

---

១ អយំ តំសទ្ទោ ។ ម. បោត្ថកេសុ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដំរី ១ សែន សេះ ១ សែន រថដែលទឹមដោយមេសេះអស្សតរ ១ សែន ស្រីកំលោះ ១ សែន ដែលពាក់កុណ្ឌលជាវិការៈនៃកែវមណី ១ សែន មិនដល់ចំណិត នៃការឈានទៅ ១ ជំហាន ដែលបណ្ឌិតចែកឲ្យជាចំណែក ១៦ អស់វារៈ ១៦ ដងទេ ។

ម្នាលគហបតិ អ្នកចូរឈានដើរទៅ ម្នាលគហបតិ អ្នកចូរឈានដើរទៅ ការឈានដើរទៅរបស់អ្នកប្រសើរណាស់ ដំណើរត្រឡប់ថយក្រោយវិញ មិនប្រសើរទេ ។ អនាថបិណ្ឌិកគហបតិ ក៏បាត់ងងឹតទៅវិញ អស់វារៈប៉ុណ្ណឹង ៗ ពន្លឺក៏កើតប្រាកដឡើង ។ ភ័យសេចក្ដីតក់ស្លុតព្រឺរោមនោះ ឯងក៏រម្ងាប់ទៅ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិចូលទៅកាន់សីតវន ។

(៣៥៨) សម័យនោះឯង ព្រះមានព្រះភាគទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយទ្រង់ចង្រ្កមក្នុងទីវាល ។ ព្រះមានព្រះភាគទ្រង់ទតឃើញអនាថបិណ្ឌិកគហបតិ ដើរមកពីចម្ងាយលើម ។ លុះទ្រង់ទតឃើញហើយក៏ថយចុះអំពីទីចង្រ្កម ទ្រង់គង់លើអាសនៈដែលគេតាក់តែងថ្វាយស្រាប់ ។ ព្រះមានព្រះភាគទ្រង់គង់ហើយ ទើបមានព្រះបន្ទូលនេះទៅនឹងអនាថបិណ្ឌិកគហបតិថា ម្នាលសុទត្ត អ្នកចូរមកនេះ ។ ឯអនាថបិណ្ឌិកគហបតិ មានចិត្តត្រេកអរីករាយ ដោយគិតថា ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលត្រាស់ហៅ អាត្មាអញចំឈ្មោះ ហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច កច្ចិ ភន្តេ ភគវា សុខំ សយិត្ថាតិ ។

(៣៥៩) សព្វទា វេ សុខំ សេតិ
ព្រាហ្មណោ បរិនិព្វុតោ
យោ ន លិម្បតិ កាមេសុ
សីតិភូតោ និរូបធិ ។
សព្វា អាសត្តិយោ ឆេត្វា
វិនេយ្យ ហទយេ ទរំ
ឧបសន្តោ សុខំ សេតិ
សន្តឹ បប្បុយ្យ(១) ចេតសោតិ ។

(៣៦០) អថខោ ភគវា អនាថបិណ្ឌិកស្ស គហបតិស្ស អនុបុព្វីកថំ កថេសិ ។ សេយ្យថីទំ ។ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។

១ ឱ. អប្បុយ្យ ។ ម. សន្តឹមព្ភុយ្ហ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបទៀបព្រះបាទទាំងគូ នៃព្រះមានព្រះភាគ ហើយក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ផ្ទំស្កល់ស្រួលទេឬ ។

(៣៥៩) ព្រះអង្គទ្រង់ត្រាស់ថា បុគ្គលណាមានសេចក្តីត្រជាក់មិនមានកិលេសគ្រឿងសៅហ្មងមិនជាប់នៅក្នុងកាមទាំងឡាយ បុគ្គលនោះឈ្មោះថាព្រាហ្មណ៍អ្នកមានទុក្ខរម្ងត់ហើយ រមែងដេកនៅជាសុខគ្រប់កាលទាំងពួង ។ (មនុស្សណា) កាត់បង់នូវសេចក្តីប្រាថ្នា ក្នុងភពទាំងពួង ហើយនាំបង់នូវសេចក្តីក្រវល់ក្រវាយក្នុងហឫទ័យចេញ (មនុស្សនោះ) ឈ្មោះថាជាអ្នកស្ងប់រម្ងាប់ ដល់ហើយនូវសេចក្តីរម្ងាប់នៃចិត្ត រមែងដេកនៅជាសុខ ។

(៣៦០) លំដាប់នោះ ព្រះមានព្រះភាគទ្រង់សំដែងអនុបុព្វីកថាដល់អនាថបិណ្ឌិកគហបតិ ។ អនុបុព្វីកថានោះគឺអ្វីខ្លះ ។ អនុបុព្វីកថានោះ គឺ ទ្រង់ប្រកាសនូវទានកថា ១ សីលកថា ១ សគ្គកថា ១ កាមាទីនវៈដ៏លាមកសៅហ្មង ១ និងអានិសង្សក្នុងការចេញកសាងផ្នួស ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យទា ភគវា អញ្ញាសិ អនាថបិណ្ឌិកំ គហបតឹ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ អនាថបិណ្ឌិកស្ស គហបតិស្ស តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។

(៣៦១) អថខោ អនាថបិណ្ឌិកោ គហបតិ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ សាសនេ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ថា អនាថបិណ្ឌិកគហបតិ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លាក្នុងពេលណា ក៏ធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង ព្រះអង្គទ្រង់ប្រកាសនូវធម្មទេសនានោះ គឺ ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ក្នុងពេលនោះ ៗ សំពត់ដ៏ស្អាតដែលមិនមានពណ៌ខ្មៅ តែងទទួលយកនូវទឹកជ្រលក់ដោយប្រពៃយ៉ាងណាមិញ ក៏ដូចជាធម្មចក្ខុ គឺ សោតាបត្តិផលមានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ ក៏បានកើតឡើងដល់អនាថ-បិណ្ឌិកគហបតិ លើអាសនៈនោះដូច្នេះថា ធម្មជាតឯណានីមួយ មានស-ភាពកើតឡើងហើយជាធម្មតា ធម្មជាតទាំងអស់នោះមានសភាព រលត់ទៅវិញជាធម្មតា ។

(៣៦១) គ្រានោះ អនាថបិណ្ឌិកគហបតិបានឃើញធម៌ហើយ បានលុះធម៌ហើយ បានជ្រាបច្បាស់ធម៌ហើយ មានចិត្តចុះកាន់ធម៌ស៊ប់ហើយ ឆ្លងចាកសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លា លែងជឿនូវពាក្យបុគ្គលដទៃក្នុងសាសនា របស់ព្រះសាស្តា ហើយបានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ(១) ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ អធិវាសេតុ ច មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ អនាថបិណ្ឌិកោ គហបតិ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

---

១ សព្វត្ថ ឯវមេវ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គទ្រង់សំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ក៏ច្បាស់ណាស់) គួរនាដូចជាមនុស្ស បើកវត្ថុដែលគេផ្កាប់ឲ្យផ្ងារឡើង ឬដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំងទុក ពុំនោះសោតដូចជាមនុស្សប្រាប់ផ្លូវ ដល់អ្នកវង្វេង ឬដូចមនុស្សកាន់ប្រទីបទ្រោលបំភ្លឺ ក្នុងទីងងឹតដោយគិតថាមនុស្សដែលមានភ្នែកនឹងមើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះសូមដល់ នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ថាជាទីពឹងទីរលឹក សូមព្រះមានព្រះភាគទ្រង់ជ្រាប នូវខ្ញុំព្រះអង្គថា ជាឧបាសកដល់ហើយនូវព្រៃត្រៃសរណគមន៍ ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះជាដើមរៀងទៅ បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀត សូមព្រះមានព្រះភាគមួយអន្លើដោយព្រះភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ គ្រានោះ អនាថបិណ្ឌិកគហបតីដឹងច្បាស់ថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគធ្វើប្រទក្សិណរួចចៀសចេញទៅ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៣៦២) អស្សោសិ ខោ រាជគហកោ សេដ្ឋី អនាថបិណ្ឌិកេន កិរ គហបតិនា ស្វាតនាយ ពុទ្ធប្បមុខោ សង្ឃោ និមន្តិតោតិ ។ អថខោ រាជគហកោ សេដ្ឋី អនាថបិណ្ឌិកំ គហបតឹ ឯតទវោច តយា កិរ គហបតិ ស្វាតនាយ ពុទ្ធប្បមុខោ សង្ឃោ និមន្តិតោ ត្វញ្ចាសិ អាគន្តុកោ ទេមិ តេ គហបតិ វេយ្យាយិកំ យេន ត្វំ ពុទ្ធប្បមុខស្ស សង្ឃស្ស ភត្តំ ករេយ្យាសីតិ ។ អលំ គហបតិ អត្ថិ មេ វេយ្យាយិកំ យេនាហំ ពុទ្ធប្បមុខស្ស សង្ឃស្ស ភត្តំ ករិស្សាមីតិ ។

(៣៦៣) អស្សោសិ ខោ រាជគហកោ នេគមោ អនាថបិណ្ឌិកេន កិរ គហបតិនា ស្វាតនាយ ពុទ្ធប្បមុខោ សង្ឃោ និមន្តិតោតិ ។ អថខោ រាជគហកោ នេគមោ អនាថបិណ្ឌិកំ គហបតឹ ឯតទវោច តយា កិរ គហបតិ ស្វាតនាយ ពុទ្ធប្បមុខោ សង្ឃោ និមន្តិតោ ត្វញ្ចាសិ អាគន្តុកោ ទេមិ តេ គហបតិ វេយ្យាយិកំ យេន ត្វំ ពុទ្ធប្បមុខស្ស សង្ឃស្ស ភត្តំ ករេយ្យាសីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៦២) រាជគហសេដ្ឋីបានឮថា អនាថបិណ្ឌិកគហបតិ និមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែកជាបឋមហើយ ។ ចំណែកខាងរាជគហសេដ្ឋី បាននិយាយពាក្យនេះនឹងអនាថបិណ្ឌិកគហបតិថា ម្នាលគហបតិ បានឮថា អ្នកនិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធានដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក តែអ្នកជាអាគន្តុកៈ នឹងធ្វើភត្តដើម្បីព្រះសង្ឃមានព្រះពុទ្ធជាប្រធានដោយវត្ថុសម្រាប់ចាយវាយ (ស្បៀង) ឯណា ម្នាលគហបតិ ខ្ញុំនឹងឲ្យវត្ថុសម្រាប់ចាយវាយនោះដល់អ្នក ។ អនាថបិណ្ឌិកគហបតិឆ្លើយថា ម្នាលគហបតិ កុំចុះ ខ្ញុំមានវត្ថុសម្រាប់ចាយវាយធ្វើភត្តដើម្បីសង្ឃមានព្រះពុទ្ធជាប្រធានហើយ ។

(៣៦៣) អ្នកនិគមក្រុងរាជគ្រឹះ បានឮដំណឹងច្បាស់ថា អនាថបិណ្ឌិកគហបតិបាននិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ។ វេលានោះ អ្នកនិគមក្រុងរាជគ្រឹះនិយាយពាក្យនេះទៅនឹងអនាថបិណ្ឌិកគហបតិថា បពិត្រគហបតិ ឮថា អ្នកបាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក តែអ្នកជាអាគន្តុកៈ នឹងធ្វើភត្តកិច្ចដើម្បីព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយវត្ថុសម្រាប់ចាយវាយឯណា ម្នាលគហបតិ ខ្ញុំឲ្យវត្ថុសម្រាប់ចាយវាយនោះដល់អ្នក ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អលំ អយ្យ អត្ថិ មេ វេយ្យាយិកំ យេនាហំ ពុទ្ធប្បមុខស្ស សង្ឃស្ស ភត្តំ ករិស្សាមីតិ ។

(៣៦៤) អស្សោសិ ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អនាថបិណ្ឌិកោ កិរ គហបតិ ស្វាតនាយ ពុទ្ធប្បមុខោ សង្ឃោ និមន្តិតោតិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អនាថបិណ្ឌិកំ គហបតឹ ឯតទវោច តយា កិរ គហបតិ ស្វាតនាយ ពុទ្ធប្បមុខោ សង្ឃោ និមន្តិតោ ត្វញ្ចាសិ អាគន្តុកោ ទេមិ តេ គហបតិ វេយ្យាយិកំ យេន ត្វំ ពុទ្ធប្បមុខស្ស សង្ឃស្ស ភត្តំ ករេយ្យាសីតិ ។ អលំ ទេវ អត្ថិ មេ វេយ្យាយិកំ យេនាហំ ពុទ្ធប្បមុខស្ស សង្ឃស្ស ភត្តំ ករិស្សាមីតិ ។

(៣៦៥) អថខោ អនាថបិណ្ឌិកោ គហបតិ តស្សា រត្តិយា អច្ចយេន រាជគហកស្ស សេដ្ឋិស្ស និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនាថបិណ្ឌិកឆ្លើយថា នែអ្នក កុំចុះ ខ្ញុំមានវត្ថុសម្រាប់ចាយវាយ ធ្វើភត្ត ដើម្បីព្រះសង្ឃមានព្រះពុទ្ធជាប្រធានហើយ ។

(៣៦៤) ព្រះបាទពិម្ពិសារមាគធសេនិយរាជជ្រាបច្បាស់ថា ឮថា អនាថបិណ្ឌិកគហបតិ បាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ។ ឯព្រះបាទពិម្ពិសារមាគធសេនិយរាជ ទ្រង់មានបន្ទូលនេះទៅនឹងអនាថបិណ្ឌិកគហបតិថា ម្នាលគហបតិ ឮថា អ្នកបាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក តែអ្នកជាអាគន្តុកៈ នឹងធ្វើភត្តដើម្បីព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដោយវត្ថុសម្រាប់ចាយវាយឯណា យើងនឹងឲ្យនូវវត្ថុសម្រាប់ចាយវាយនោះដល់អ្នក ។ អនាថបិណ្ឌិកគហបតិក្រាបទូលតបថា បពិត្រព្រះសម្មតិទេព ពុំបាច់ទេ ខ្ញុំព្រះអង្គមានវត្ថុសម្រាប់ចាយវាយធ្វើភត្ត ដើម្បីព្រះសង្ឃមានព្រះពុទ្ធជាប្រធានហើយ ។

(៣៦៥) គ្រានោះ អនាថបិណ្ឌិកគហបតិ លុះកន្លងរាត្រីនោះទៅ ក៏ឲ្យជនតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម ក្នុងលំនៅរបស់រាជគហសេដ្ឋី ហើយឲ្យជនក្រាបបង្គំទូលភត្តកាលចំពោះព្រះមានបុណ្យថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តក៏សម្រេចហើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន រាជគហកស្ស សេដ្ឋិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធិំ ភិក្ខុសង្ឃេន ។ អថខោ អនាថបិណ្ឌិកោ គហបតិ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អនាថបិណ្ឌិកោ គហបតិ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា សាវត្ថិយំ វស្សាវាសំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។ សុញ្ញាគារេ ខោ គហបតិ តថាគតា អភិរមន្តីតិ ។ អញ្ញាតំ ភគវា អញ្ញាតំ សុគតាតិ ។ អថខោ ភគវា អនាថបិណ្ឌិកំ គហបតឹ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ទ្រង់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់លំនៅរបស់រាជគហសេដ្ឋី លុះចូលទៅដល់ ហើយក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ជាមួយនឹងភិក្ខុសង្ឃ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតី បានអង្គាសថ្វាយខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសាដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់គ្រាន់តែដល់លោកប្រកែកលែងទទួលទៀត លុះព្រះមានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ អនាថបិណ្ឌិកគហបតីលុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃ ទទួលនិមន្តគង់ចាំវស្សាក្នុងក្រុងសាវត្ថីរបស់ខ្ញុំព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតី ព្រះតថាគតទាំងឡាយរមែងត្រេកអរ ចំពោះក្នុងលំនៅដ៏ស្ងាត់នែម្ល៉ោះ ។ អនាថបិណ្ឌិកគហបតីក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គដឹងច្បាស់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គដឹងច្បាស់ហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ពន្យល់អនាថបិណ្ឌិកគហបតីឲ្យឃើញព្រម ឲ្យកាន់យកព្រម ឲ្យឧស្សាហ៍ព្រម ឲ្យរីករាយព្រម ដោយធម្មីកថា ហើយព្រះអង្គក្រោកចាកអាសនៈ ទ្រង់ពុទ្ធដំណើរចៀសចេញទៅ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៣៦៦) តេន ខោ បន សមយេន អនាថបិណ្ឌិកោ គហបតិ ពហុមិត្តោ ហោតិ ពហុសហាយោ អាទេយ្យវាចោ ។ អថខោ អនាថបិណ្ឌិកោ គហបតិ រាជគហេ តំ ករណីយំ តីរេត្វា យេន សាវត្ថឹ តេន បក្កាមិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ អន្តរាមគ្គេ មនុស្សេ អាណាបេសិ អារាមេ អយ្យា ការេថ វិហារេ បតិដ្ឋាបេថ ទានានិ បដ្ឋបេថ ឥទានិ ពុទ្ធោ លោកេ ឧប្បន្នោ សោ ច មយា ភគវា និមន្តិតោ ឥមិនា មគ្គេន អាគច្ឆិស្សតីតិ ។ អថខោ តេ មនុស្សា អនាថបិណ្ឌិកេន គហបតិនា ឧយ្យោជិតា អារាមេ អការំសុ វិហារេ បតិដ្ឋាបេសុំ ទានានិ បដ្ឋបេសុំ ។ អថខោ អនាថបិណ្ឌិកោ គហបតិ សាវត្ថឹ គន្ត្វា សមន្តា សាវត្ថឹ អនុវិលោកេសិ កត្ថ នុ ខោ ភគវា វិហរេយ្យ យំ អស្ស គាមតោ នេវ អតិទូរេ ន អច្ចាសន្នេ គមនាគមនសម្បន្នំ អត្ថិកានំ អត្ថិកានំ មនុស្សានំ អភិក្កមនីយំ ទិវា អប្បាកិណ្ណំ រត្តឹ អប្បសទ្ទំ អប្បនិគ្ឃោសំ វិជនវាតំ មនុស្សរាហស្សេយ្យកំ បដិសល្លានសារុប្បន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៦៦) សម័យនោះឯង អនាថបិណ្ឌិកគហបតី ជាបុគ្គលមានមិត្តច្រើន មានសម្លាញ់ច្រើន មានវាចាគួរឲ្យអ្នកផងកាន់យក ។ ទើបអនាថបិណ្ឌិកគហបតីពិចារណា នូវកិច្ចដែលគួរធ្វើនោះ ក្នុងក្រុងរាជគ្រឹះរួចហើយក៏ត្រឡប់មកក្រុងសាវត្ថីវិញ ។ លុះដល់ពាក់កណ្តាលផ្លូវ អនាថ-បិណ្ឌិកគហបតីបង្គាប់មនុស្សទាំងឡាយថា ម្នាលអ្នកទាំងឡាយ បូរអ្នកកល់គ្នាធ្វើអារាម សាងវិហារ ផ្តើមធ្វើទាន ឥឡូវនេះព្រះពុទ្ធត្រាស់ហើយក្នុងលោក ឯព្រះអង្គនោះសោត ខ្ញុំក៏បាននិមន្តហើយ ព្រះអង្គនឹងស្តេចពុទ្ធដំណើរមកតាមផ្លូវនេះ ។ គ្រានោះ ពួកមនុស្សដែលអនាថ-បិណ្ឌិកគហបតីបញ្ជូនទៅនោះ ក៏បានធ្វើអារាម សាងវិហារ ចាប់ផ្តើមធ្វើទាន ។ លំដាប់នោះ អនាថបិណ្ឌិកគហបតីទៅដល់ក្រុងសាវត្ថីហើយ ក៏គយគន់មើល ( កន្លែង ) ក្នុងក្រុងសាវត្ថីគ្រប់អន្លើ ដោយគិតថា ព្រះមានព្រះភាគសម្តេចគង់នៅក្នុងទីណាហ្ន៎ ទីណាមិនជិតពេក មិនឆ្ងាយពេក អំពីស្រុក ល្មមទៅល្មមមកបាន ល្មមពួកមនុស្សដែលត្រូវការដោយប្រយោជន៍ងាយនឹងទៅមក ជាទីមិនច្រឡូកច្រឡំក្នុងវេលាថ្ងៃ មានសម្លេងតិច ឥតមានសម្លេងគឹកកង ជាទីប្រាសចាកខ្យល់បក់មកអំពីសរីរៈនៃជន គួរជាទីធ្វើការសម្ងាត់នៃមនុស្ស និងជាទីគួរដល់វិវេកក្នុងវេលាយប់ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អទ្ទសា ខោ អនាថបិណ្ឌិកោ គហបតិ ជេតស្ស រាជកុមារស្ស[១] ឧយ្យានំ គាមតោ នេវ អតិទូរេ ន អច្ចាសន្នេ គមនាគមនសម្បន្នំ អត្ថិកានំ អត្ថិកានំ មនុស្សានំ អភិក្កមនីយំ ទិវា អប្បាកិណ្ណំ រត្តឹ អប្បសទ្ទំ អប្បនិគ្ឃោសំ វិជនវាតំ មនុស្សរាហស្សេយ្យកំ បដិសល្លានសារុប្បំ ទិស្វាន យេន ជេតោ រាជកុមារោ[២] តេនុបសង្កមិ ឧបសង្កមិត្វា ជេតំ រាជកុមារំ ឯតទវោច ទេហិ មេ អយ្យបុត្ត ឧយ្យានំ អារាមំ កាតុន្តិ ។ អទេយ្យោ គហបតិ អារាមោ អបិ កោដិសន្ថរេនាតិ ។ គហិតោ អយ្យបុត្ត អារាមោតិ ។ ន គហបតិ គហិតោ អារាមោតិ ។ គហិតោ ន គហិតោតិ វោហារិកេ មហាមត្តេ បុច្ឆឹសុ ។ មហាមត្តា ឯវមាហំសុ យតោ តយា អយ្យបុត្ត អគ្ឃោ កតោ គហិតោ អារាមោតិ ។

---

១ ឱ. ម. កុមារស្ស ។ ២ ឱ. ម. កុមារោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនាថបិណ្ឌិកគហបតិ បានឃើញឧទ្យានរបស់រាជកុមារឈ្មោះជេត ជាទីមិនឆ្ងាយពេក មិនជិតពេកអំពីស្រុក ល្មមទៅមកបាន ល្មមពួកមនុស្សដែលត្រូវការដោយប្រយោជន៍នោះៗទៅមកបាន មិនច្រឡូកច្រឡំ ក្នុងវេលាថ្ងៃ មានសំឡេងតិច ឥតមានសំឡេងគឹកកងជាទីប្រាសចាកខ្យល់បក់មកអំពីសរីរៈនៃមនុស្ស គួរជាទីធ្វើការសម្ងាត់នៃមនុស្ស ជាទីគួរដល់វិវេកក្នុងវេលាយប់ លុះឃើញហើយក៏ចូលទៅរកព្រះរាជកុមារឈ្មោះជេត លុះចូលទៅដល់ហើយ បានទូលពាក្យនេះ នឹងព្រះរាជកុមារឈ្មោះជេតថា បពិត្រព្រះអយ្យបុត្រ សូមព្រះអង្គប្រទានឧទ្យានមកខ្ញុំព្រះអង្គ ដើម្បីនឹងធ្វើអារាម ។ ជេតរាជកុមារឆ្លើយថា ម្នាលគហបតិ អារាមខ្ញុំឲ្យ (អ្នកទេ) មិនបានទេ លុះតែ (អ្នកឲ្យថ្លៃ) គឺក្រាលដោយកោដិនៃកហាបណៈ(ទើបឲ្យបាន) ។ អនាថបិណ្ឌិកគហបតិឆ្លើយថា បពិត្រព្រះអយ្យបុត្រ អារាមខ្ញុំព្រះអង្គមុខជានឹងយកហើយ ។ ជេតរាជកុមារឆ្លើយថា ម្នាលគហបតិ អ្នកកុំអាលយកអារាម (ចាំយើងសួរពួកមហាមាត្រអ្នកវិនិច្ឆ័យសេចក្ដីសិន) ។ ជេតរាជកុមារនឹងអនាថបិណ្ឌិកគហបតិ ក៏សួរពួកមហាមាត្រអ្នកវិនិច្ឆ័យសេចក្ដីថា អារាមគួរឲ្យអនាថបិណ្ឌិកគហបតិយក ឬមិនឲ្យយកទេ ។ ពួកមហាមាត្រពោលយ៉ាងនេះថា បពិត្រព្រះអយ្យបុត្រ ព្រះអង្គបានកាត់ថ្លៃអារាមចំនួនប៉ុន្មាន ក៏ឲ្យអនាថបិណ្ឌិកគហបតិទទួលយក ដោយថ្លៃប៉ុណ្ណោះបុះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អថខោ អនាថបិណ្ឌិកោ គហបតិ សកដេហិ ហិរញ្ញំ និព្វាហាបេត្វា ជេតវនេ កោដិសន្ថរំ សន្ថរាបេសិ ។ សកិំ នីហដំ ហិរញ្ញំ ថោកស្ស ឱកាសស្ស កោដ្ឋកសាមន្តា នប្បហោតិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ មនុស្សេ អាណាបេសិ គច្ឆថ ភណេ ហិរញ្ញំ អាហរថ ឥមំ ឱកាសំ សន្ថរិស្សាមាតិ ។ អថខោ ជេតស្ស រាជកុមារស្ស ឯតទហោសិ ន ខោ ឥទំ ឱរកំ ភវិស្សតិ យថាយំ គហបតិ តាវពហុំ ហិរញ្ញំ បរិច្ចជតីតិ ។ អថខោ ជេតោ រាជកុមារោ[១] អនាថបិណ្ឌិកំ គហបតិំ ឯតទវោច អលំ គហបតិ មា តំ ឱកាសំ សន្ថរាបេសិ ទេហិ មេ ឯតំ ឱកាសំ មមេតំ ទានំ ភវិស្សតីតិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ អយំ ខោ ជេតោ រាជកុមារោ អភិញ្ញាតោ ញាតមនុស្សោ មហិទ្ធិកោ ខោ បន ឯវរូបានំ ញាតមនុស្សានំ ឥមស្មឹ ធម្មវិនយេ បសាទោតិ តំ ឱកាសំ ជេតស្ស រាជកុមារស្ស អទាសិ ។ អថខោ ជេតោ រាជកុមារោ

---

១ ឱ. ម. ពោត្ថកេ អថខោ ជេតោ រាជកុមារោតិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លំដាប់នោះ អនាថបិណ្ឌិកគហបតិបានឲ្យគេដឹកប្រាក់ដោយរទេះទាំងឡាយហើយឲ្យក្រាលតំរៀប ដោយកោដិនៃកហាបណៈ ក្នុងព្រៃរបស់ជេតរាជកុមារ ។ ប្រាក់ដែលដឹកនាំយកមកនៃតម្លៃប៉ុណ្ណោះ មិនគ្រាន់គ្រង់ទីឱកាសបន្តិចជុំវិញខ្លោងទ្វារ ។ ឯអនាថបិណ្ឌិកគហបតិក៏បានបង្គាប់ពួកមនុស្សថា នែនាយកល់គ្នា ចូរអ្នកទៅនាំយកប្រាក់មកទៀត យើងនឹងក្រាលគ្រង់ទីឱកាសនេះ ។ គ្រានោះ ជេតរាជកុមារមានសេចក្ដីត្រិះរិះដូច្នេះថា គហបតិនេះចំណាយប្រាក់ច្រើនដល់ម៉្លោះ ចំពោះកិច្ចណា កិច្ចនោះមិនមែនជារបស់ថោកទាបទេ ។ វេលានោះ ជេតរាជកុមារពោលនូវពាក្យនេះនឹងអនាថបិណ្ឌិកគហបតីថា ណ្ហើយគហបតិ អ្នកកុំឲ្យក្រាលទីឱកាសនោះឡើយ អ្នកចូរឲ្យទីឱកាសនោះដល់ខ្ញុំ ទាននុ៎ះនឹងមានដល់ខ្ញុំ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិបានថ្វាយទីឱកាសនោះ ដល់ជេតរាជកុមារដោយគិតថា ជេតរាជកុមារនេះ ជាមនុស្សល្បីល្បាញមានមនុស្សស្គាល់ (ច្រើន) មានបុណ្យច្រើន ឯសេចក្ដីជ្រះថ្លាក្នុងធម្មវិន័យនេះ (នឹងមាន) ដល់ពួកមនុស្សដែលគេស្គាល់ មានសភាពយ៉ាងនេះ ។ គ្រានោះជេតរាជកុមារ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



តស្មឹ ឱកាសេ កោដ្ឋកំ មាបេសិ ។ អថខោ អនា-
ថបិណ្ឌិកោ គហបតិ ជេតវនេ វិហារេ ការាបេសិ បរិ-
វេណានិ ការាបេសិ កោដ្ឋកេ ការាបេសិ ឧបដ្ឋាន-
សាលាយោ ការាបេសិ អគ្គិសាលាយោ ការាបេសិ
កប្បិយកុដិយោ ការាបេសិ វច្ចកុដិយោ ការាបេសិ
ចង្កមេ ការាបេសិ ចង្កមនសាលាយោ ការាបេសិ
ឧទបានេ ការាបេសិ ឧទបានសាលាយោ ការាបេសិ
ជន្តាឃរេ ការាបេសិ ជន្តាឃរសាលាយោ ការាបេសិ
បោក្ខរណិយោ(១) ការាបេសិ មណ្ឌបេ ការាបេសិ ។

[៣៦៧] អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន វេសាលី តេន ចារិកំ បក្កាមិ ។ អនុបុព្វេន ចារិកំ ចរមានោ យេន វេសាលី តទវសរិ ។ តត្រ សុទំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។

---

១ ម. បោក្ខរណី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



បានកសាងខ្លោងទ្វារក្នុងទីឱកាសនោះ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ ឲ្យគេធ្វើវិហារ ឲ្យគេធ្វើបរិវេណ ឲ្យធ្វើបន្ទប់ ឲ្យធ្វើឧបដ្ឋានសាលា ឲ្យធ្វើរោងភ្លើង ឲ្យធ្វើកប្បិយកុដិ ឲ្យធ្វើវច្ចកុដិ ឲ្យធ្វើទីចង្ក្រម ឲ្យធ្វើសាលាសម្រាប់ចង្ក្រម ឲ្យធ្វើអណ្តូងទឹក ឲ្យធ្វើសាលារៀងអណ្តូងទឹក ឲ្យធ្វើរោងភ្លើង ឲ្យធ្វើសាលារៀងរោងភ្លើង ឲ្យធ្វើស្រះបោក្ខរណី ឲ្យធ្វើមណ្ឌបក្នុងជេតវ័ន ។

( ៣៦៧ ) គ្រានោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងរាជគ្រឹះ គួរដល់ព្រះអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្រុងវេសាលី ព្រះអង្គទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ដោយលំដាប់ឆ្ពោះត្រង់ទៅក្រុងវេសាលី ។ មានសេចក្តីដំណាលថា ព្រះមានព្រះភាគគង់នៅក្នុងកូដាគារសាលា ក្នុងព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សេនាសនក្ខន្ធកេ នវកម្មករណំ តុន្នវាយវត្ថុ

(៣២៨) តេន ខោ បន សមយេន មនុស្សា សក្កច្ចំ នវកម្មំ ករោន្តិ យេបិ ភិក្ខូ នវកម្មំ អធិដ្ឋេន្តិ តេបិ សក្កច្ចំ ឧបដ្ឋេន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ។

(៣២៩) អថខោ អញ្ញតរស្ស ទលិទ្ទស្ស តុន្នវាយស្ស ឯតទហោសិ ន ខោ ឥទំ ឱរកំ ភវិស្សតិ យថយិមេ មនុស្សា សក្កច្ចំ នវកម្មំ ករោន្តិ យន្នូនាហម្បិ នវកម្មំ ករេយ្យន្តិ ។ អថខោ សោ ទលិទ្ទោ តុន្នវាយោ សាមំ ចិក្ខល្លំ មទ្ទិត្វា ឥដ្ឋកាយោ ចិនិត្វា កុឌ្ឌំ(១) ឧដ្ឋាបេសិ ។ តេន អកុសលេន ចិតា វង្កា ភិត្តិ បរិបតតិ(២) ។ ទុតិយម្បិ ខោ ។បេ។ តតិយម្បិ ខោ សោ ទលិទ្ទោ តុន្នវាយោ សាមំ ចិក្ខល្លំ មទ្ទិត្វា ឥដ្ឋកាយោ ចិនិត្វា កុឌ្ឌំ ឧដ្ឋាបេសិ ។ តេន អកុសលេន ចិតា វង្កា ភិត្តិ បរិបតតិ ។ អថខោ សោ ទលិទ្ទោ តុន្នវាយោ ឧជ្ឈាយតិ ខិយ្យតិ វិបាចេតិ យេ

---

១ ឱ. កុដ្ដំ ។ ២ ឱ, ម. បរិបតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





( ៣៦៨ ) សម័យនោះឯង មនុស្សទាំងឡាយកំពុងយកចិត្តទុកដាក់ធ្វើនវកម្ម គឺការសាងថ្មី ក៏បានផ្គត់ផ្គង់ពួកភិក្ខុដែលជាអ្នកចាត់ចែងនូវនវកម្ម ដោយចីវរ បិណ្ឌបាត សេនាសនៈ នឹងភេសជ្ជបរិក្ខារថ្នាំជាបច្ច័យសម្រាប់អ្នកជម្ងឺដោយគោរព ។

( ៣៦៩ ) លំដាប់នោះ មានជាងផុលឬដេរម្នាក់ ជាអ្នកកំសត់ មានសេចក្តីត្រិះរិះដូច្នេះថា ពួកមនុស្សទាំងនេះកំពុងយកចិត្តទុកដាក់ធ្វើនវកម្ម ព្រោះអំពើណា អំពើនេះមិនមែនជារបស់ថោកទាបទេ បើដូច្នោះគួរតែអញធ្វើនវកម្មដែរ ។ ឯជាងផុលឬដេរជាអ្នកកំសត់នោះជាន់ដីបោះឥដ្ឋ ហើយធ្វើជញ្ជាំងដោយខ្លួនឯង ។ ជាងផុលនោះមិនឈ្លាសវៀច ជញ្ជាំងវៀច ជញ្ជាំងក៏រលំទៅ ។ ជាងផុលកំសត់នោះជាន់ដីឥដ្ឋធ្វើជញ្ជាំងដោយខ្លួនឯង អស់វារៈជាគំរប់ពីរដងផង ។ បេ ។ អស់វារៈជាគំរប់បីដងផង ។ ជាងផុលមិនឈ្លាសនោះធ្វើជញ្ជាំងវៀច ជញ្ជាំងក៏រលំទៅ ។ លំដាប់នោះជាងផុលកំសត់នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ជនទាំងឡាយណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥមេសំ សមណានំ សក្យបុត្តិយានំ ទេន្តិ ចីវរបិណ្ឌ-
បាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ តេ ឥមេ
ឱវទន្តិ អនុសាសន្តិ តេសញ្ច នវកម្មំ អធិដ្ឋេន្តិ
អហំ បនម្ហិ ទលិទ្ទោ ន មំ កោចិ ឱវទតិ វា អ-
នុសាសតិ វា នវកម្មំ វា អធិដ្ឋេតីតិ ។ អស្សោសុំ ខោ
ភិក្ខូ តស្ស ទលិទ្ទស្ស តុន្នវាយស្ស ឧជ្ឈាយន្តស្ស
ខីយន្តស្ស វិបាចេន្តស្ស ។ អថខោ តេ ភិក្ខូ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ
ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ
អនុជានាមិ ភិក្ខវេ នវកម្មំ ទាតុំ នវកម្មិកោ ភិក្ខវេ
ភិក្ខុ ឧស្សុក្កំ អាបជ្ជិស្សតិ កិន្តិ នុ ខោ វិហារោ
ខិប្បំ បរិយោសានំ គច្ឆេយ្យាតិ ខណ្ឌផុល្លំ បដិសង្ខ-
រិស្សតិ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វំ ។ បឋមំ ភិក្ខុ
យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន
សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ឲ្យចីវរ បិណ្ឌបាតសេនាសនៈ និងភេសជ្ជបរិក្ខារថ្នាំជាបច្ច័យសម្រាប់អ្នកជម្ងឺ ដល់ពួកសមណៈជាសក្យបុត្តិយ៍នេះ ពួកសមណសក្យបុត្តិយ៍នេះទូន្មានប្រៀនប្រដៅនូវជនទាំងឡាយផង ក៏រ៉ាប់រងនូវនវកម្មរបស់ជនទាំងនោះផង បំណែកខាងអញជាមនុស្សកំសត់ គ្មានអ្នកណាមួយជួយទូន្មានប្រៀនប្រដៅឬក៏រ៉ាប់រង នូវនវកម្មរបស់អញនោះឡើយ ។ ពួកភិក្ខុក៏បានឮជាងជុលកំសត់នោះពោលទោស តិះដៀល បន្ទុះបន្អាប់ ។ ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុ) ឲ្យនវកម្ម(១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយនវកម្មនឹងដល់នូវសេចក្ដីខ្វល់ខ្វាយថា គិតដូចម្ដេចនឹងឲ្យវិហារហើយឆាប់ នឹងជួសជុលនូវទីដែលបាក់បែកឡើងវិញបាន ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ៗ មុនគប្បីត្រូវសង្ឃសូមភិក្ខុ ។ លុះសូមហើយត្រូវភិក្ខុដែលឈ្លាសប្រតិពលផ្ដៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ

---

(១) បើមានឧបាសកមានសទ្ធាធ្វើការងារថ្មី គឺសាងវិហារកុដិជាដើមប្រគេនសង្ឃ សង្ឃត្រូវចាត់ភិក្ខុដែលប៉ិនប្រសប់ណាមួយឲ្យជាអ្នកជួយរ៉ាប់រងត្រួតត្រាការងារនោះ ដូចកាលនាងវិសាខាសាងបុព្វារាម ព្រះសម្មាសម្ពុទ្ធទ្រង់ចាត់ព្រះមោគ្គល្លានឲ្យជាអ្នកជួយត្រួតត្រាផ្ទៃព្រោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស គហបតិនោ វិហារំ ឥត្ថន្នាមស្ស ភិក្ខុនោ នវកម្មំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមស្ស គហបតិនោ វិហារំ ឥត្ថន្នាមស្ស ភិក្ខុនោ នវកម្មំ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស គហបតិនោ វិហារស្ស ឥត្ថន្នាមស្ស ភិក្ខុនោ នវកម្មស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នោ សង្ឃេន ឥត្ថន្នាមស្ស គហបតិនោ វិហារោ ឥត្ថន្នាមស្ស ភិក្ខុនោ នវកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៣៧០) អថខោ ភគវា វេសាលិយំ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ ។ តេន ខោ បន សមយេន ឆព្វគ្គិយានំ ភិក្ខូនំ អន្តេវាសិកា ភិក្ខូ ពុទ្ធប្បមុខស្ស សង្ឃស្ស បុរតោ បុរតោ គន្ត្វា វិហារេ បរិគ្គណ្ហន្តិ សេយ្យាយោ បរិគ្គណ្ហន្តិ ឥទំ អម្ហាកំ ឧបជ្ឈាយានំ ភវិស្សតិ ឥទំ អម្ហាកំ អាចរិយានំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវនវកម្មដល់ភិក្ខុមានឈ្មោះនេះ ចំពោះវិហាររបស់គហបតិឈ្មោះនេះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃឲ្យនវកម្មដល់ភិក្ខុឈ្មោះនេះ ចំពោះវិហាររបស់គហបតិឈ្មោះនេះ ការឲ្យនវកម្មដល់ភិក្ខុឈ្មោះនេះ ចំពោះវិហាររបស់គហបតិឈ្មោះនេះ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីពោលឡើង ។ សង្ឃឲ្យនវកម្មដល់ភិក្ខុឈ្មោះនេះ ចំពោះវិហាររបស់គហបតិឈ្មោះនេះ គួរដល់សង្ឃព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយការស្ងៀមយ៉ាងនេះ ។

(៣៧០) គ្រានោះ ព្រះមានព្រះភាគគង់នៅក្នុងក្រុងវេសាលី គួរដល់ព្រះអធ្យាស្រ័យ ហើយទ្រង់ព្រះដំណើរទៅកាន់ក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុជាអន្តេវាសិក របស់ពួកឆព្វគ្គិយភិក្ខុនាំគ្នា ដើរដែងទៅខាងមុខៗ សង្ឃមានព្រះពុទ្ធជាប្រធាន ក៏ហួងហែងវិហារ ហួងហែងទីដេកថា ទីនេះសម្រាប់ឧបជ្ឈាយ៍របស់ពួកយើង ទីនេះសម្រាប់អាចារ្យ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភវិស្សតិ ឥទំ អម្ហាកំ ភវិស្សតីតិ ។ អថខោ អាយស្មា សារីបុត្តោ ពុទ្ធប្បមុខស្ស សង្ឃស្ស បិដ្ឋិតោ បិដ្ឋិតោ គន្ត្វា វិហារេសុ បរិគ្គហិតេសុ សេយ្យាសុ បរិគ្គហិតាសុ សេយ្យំ អលភមានោ អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។ អថខោ ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ឧក្កាសិ ។ អាយស្មាបិ សារីបុត្តោ ឧក្កាសិ ។ កោ ឯត្ថាតិ ។ អហំ ភគវា សារីបុត្តោតិ ។ កិស្ស ត្វំ សារីបុត្ត ឥធ និសិន្នោតិ ។ អថខោ អាយស្មា សារីបុត្តោ ភគវតោ ឯតមត្ថំ អារោចេសិ ។

(៣៧១) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយានំ ភិក្ខូនំ អន្តេវាសិកា ភិក្ខូ ពុទ្ធប្បមុខស្ស សង្ឃស្ស បុរតោ បុរតោ គន្ត្វា វិហារេ បរិគ្គណ្ហន្តិ សេយ្យាយោ បរិគ្គណ្ហន្តិ ឥទំ អម្ហាកំ ឧបជ្ឈាយានំ ភវិស្សតិ ឥទំ អម្ហាកំ អាចរិយានំ ភវិស្សតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



របស់ពួកយើង ទីនេះសម្រាប់ពួកយើង ។ កាលនោះ ព្រះសារីបុត្ត មានអាយុទៅអំពីខាងក្រោយ ៗ សង្ឃមានព្រះពុទ្ធជាប្រធាន កាលបើពួកអន្តេវាសិក របស់ពួកឆព្វគ្គិយភិក្ខុហួងហែងវិហារ ហួងហែងទីដេកហើយ លោកក៏រកទីសំណាក់មិនបាន ទើបទៅគង់ទៀបគល់ឈើ ១ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់តើនឡើង ក្នុងពេលបច្ចូសសម័យនៃរាត្រី ហើយទ្រង់ក្អកគ្រហែម ។ ព្រះសារីបុត្តមានអាយុក៏ក្អកគ្រហែមដែរ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នរណានៅក្នុងទីនុ៎ះ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះសារីបុត្ត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ហេតុអ្វីក៏អ្នកមកអង្គុយក្នុងទីនេះ ។ ឯព្រះសារីបុត្តមានអាយុក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។

(៣៧១) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុជាអន្តេវាសិករបស់ពួកឆព្វគ្គិយភិក្ខុ ដើរដែងទៅខាងមុខៗ សង្ឃមានព្រះពុទ្ធជាប្រធាន ហើយហួងហែងវិហារ ហួងហែងទីដំណេកថា ទីនេះសម្រាប់ឧបជ្ឈាយ៍របស់ពួកយើង ទីនេះសម្រាប់អាចារ្យរបស់ពួកយើង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥទំ អម្ហាកំ ភវិស្សតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ពុទ្ធប្បមុខស្ស សង្ឃស្ស បុរតោ បុរតោ គន្ត្វា វិហារេ បរិគ្គហេស្សន្តិ សេយ្យាយោ បរិគ្គហេស្សន្តិ ឥទំ អម្ហាកំ ឧបជ្ឈាយានំ ភវិស្សតិ ឥទំ អម្ហាកំ អាចរិយានំ ភវិស្សតិ ឥទំ អម្ហាកំ ភវិស្សតីតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ កោ ភិក្ខវេ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា ខត្តិយកុលា បព្វជិតោ សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា ព្រាហ្មណកុលា បព្វជិតោ សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទីនេះសម្រាប់ពួកយើង ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធមានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសនោះមិនសមបើនឹង ដើរដែនទៅខាងមុខៗ សង្ឃ មានព្រះពុទ្ធជាប្រធាន ហើយហួនហែនវិហារ ហួនហែនទីដំណេក ថា ទីនេះសម្រាប់ឧបជ្ឈាយ៍របស់ពួកយើង ទីនេះសម្រាប់អាចារ្យរបស់ពួកយើង ទីនេះសម្រាប់ពួកយើងដូច្នេះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែនដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ ។បេ។ លុះទ្រង់បន្ទោសហើយ ក៏ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដំបូងមេបគួរទទួលអាសនៈប្រសើរ (១) ទឹកប្រសើរ (២) នឹងដុំបាយប្រសើរ (៣) បាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាចេញអំពីខត្តិយត្រកូលមកបួស ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ នឹងដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាចេញអំពីព្រាហ្មណត្រកូលមកបួស ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ នឹងដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះ

---

១ អដ្ឋកថា ថា សំដៅយកអាសនៈសម្រាប់ព្រះថេរៈ ។ ២ សំដៅយកទឹកទក្ខិណោទកៈ ។
៣ សំដៅយកដុំបាយសម្រាប់សង្ឃត្ថេរ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឯវមាហំសុ យោ ភគវា គហបតិកុលា បព្វជិតោ សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា សុត្តន្តិកោ សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា វិនយធរោ ។បេ។ យោ ភគវា ធម្មកថិកោ សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា បឋមស្ស ឈានស្ស លាភី សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា ទុតិយស្ស ឈានស្ស លាភី សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា តតិយស្ស ឈានស្ស លាភី ។បេ។ យោ ភគវា ចតុត្ថស្ស ឈានស្ស លាភី សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាចេញអំពីគហបតិត្រកូលមកបួស ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ ដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណារៀនគម្ពីរព្រះសូត្រ ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ ដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាទ្រទ្រង់វិន័យ ។ បេ ។ បពិត្រព្រះមានព្រះភាគ ភិក្ខុណាជាធម្មកថិក ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ ដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានបឋមជ្ឈាន ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ ដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានទុតិយជ្ឈាន ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ ដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានតតិយជ្ឈាន ។ បេ ។ បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានចតុត្ថជ្ឈាន ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ ដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯវមាហំសុ យោ ភគវា សោតាបន្នោ សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា សកទាគាមី[១] ។បេ។ យោ ភគវា អនាគាមី ។បេ។ យោ ភគវា អរហា សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា តេវិជ្ជោ សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឯកច្ចេ ភិក្ខូ ឯវមាហំសុ យោ ភគវា ឆឡភិញ្ញោ សោ អរហតិ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។

(៣៧២) អថខោ ភគវា ភិក្ខូ អាមន្តេសិ ភូតបុព្វំ ភិក្ខវេ ហិមវន្តបស្សេ[២] មហានិគ្រោធោ អហោសិ ។ តំ តយោ សហាយា ឧបនិស្សាយ វិហរិំសុ តិត្តិរោ ច មក្កដោ ច ហត្ថិនាគោ ច ។ តេ អញ្ញមញ្ញំ អគារវា អប្បតិស្សា អសភាគវុត្តិកា វិហរិំសុ[៣] ។ អថខោ ភិក្ខវេ តេសំ សហាយានំ ឯតទហោសិ អហោ នូន

---

១ ឱ. ម. សកទាគាមី ។ ២ ម. ហិមវន្តបទេសេ ។ ៣ ឱ. ម. វិហរន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាជាសោតាបន្ន ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាជាសកិទាគាមី ។ បេ ។ បពិត្រព្រះមានព្រះភាគ ភិក្ខុណាជាអនាគាមី ។ បេ ។ បពិត្រព្រះមានព្រះភាគ ភិក្ខុណាជាអរហន្ត ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានវិជ្ជា ៣ ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន ។ ពួកភិក្ខុខ្លះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានអភិញ្ញា ៦ ភិក្ខុនោះទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន ។

( ៣៧៦ ) គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ហេតុ (នេះ) ធ្លាប់មានមកហើយ នៅខាងហិមវន្តប្បទេសមានដើមជ្រៃធំ ១ ដើម ។ សត្វ៣ពួក គឺ ទទា ១ ស្វា ១ ដំរី ១ ជាសំឡាញ់គ្នា តែងនៅអាស្រ័យនឹងដើមជ្រៃធំនោះ ។ សត្វទាំងនោះមិនគោរព មិនកោតក្រែង មិនប្រព្រឹត្តស្មោះស្មើទៅវិញទៅមកនឹងគ្នាឡើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វជាសំឡាញ់ទាំង៣នោះមានសេចក្តីត្រិះរិះថា ន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មយំ ជានេយ្យាម យំ អម្ហាកំ ជាតិយា មហល្លតរំ តំ មយំ សក្ករេយ្យាម គរុករេយ្យាម មានេយ្យាម បូជេយ្យាម តស្ស ច មយំ ឱវាទេ តិដ្ឋេយ្យាមាតិ ។ អថខោ ភិក្ខវេ តិត្តិរោ ច មក្កដោ ច ហត្ថិនាគំ បុច្ឆិសុ តុំ សម្ម កឹ បោរាណំ សរសីតិ ។ យទាហំ សម្ម ពោតកោ(១) ហោមិ ឥមំ និគ្រោធំ អន្តរា សត្ថីនំ ករិត្វា អតិក្កមាមិ អគ្គង្កុរកំ មេ ឧទរំ ឆុបតិ ឥមាហំ សម្ម បោរាណំ សរាមីតិ ។ អថខោ ភិក្ខវេ តិត្តិរោ ច ហត្ថិនាគោ ច មក្កដំ បុច្ឆិសុ តុំ សម្ម កឹ បោរាណំ សរសីតិ ។ យទាហំ សម្ម ឆាបោ ហោមិ ឆមាយំ និសីទិត្វា ឥមស្ស និគ្រោធស្ស អគ្គង្កុរកំ ខាទាមិ ឥមាហំ សម្ម បោរាណំ សរាមីតិ ។ អថខោ ភិក្ខវេ មក្កដោ ច ហត្ថិនាគោ ច តិត្តិរំ បុច្ឆិសុ តុំ សម្ម កឹ បោរាណំ សរសីតិ ។ អមុកស្មឹ សម្ម ឱកាសេ មហានិគ្រោធោ អហោសិ តតោ អហំ ផលំ(២) ភក្ខិត្វា ឥមស្មឹ ឱកាសេ វច្ចំ អកាសឹ តស្សាយំ និគ្រោធោ ជាតោ តទាហំ(៣) សម្ម ជាតិយា មហល្លតរោតិ ។ អថខោ ភិក្ខវេ

---

១ ឱ. ឆាបោ ។ ២ ឱ. ឯកំ ផលំ ។ ៣ ឱ. តទាបហំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ពួកយើង ធ្វើម្តេចនឹងដឹងពិតថា នរណាជាធំពីកំណើតជាងយើង ។ ត្រូវធ្វើ សក្ការៈ ធ្វើសេចក្តីគោរព កប់អាន បូជាអ្នកនោះ ម្យ៉ាងទៀតយើងត្រូវឋិត នៅក្នុងឱវាទរបស់អ្នកនោះ ៗ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទទានឹងស្វា សួរដំរីថា ម្នាលសម្លាញ់ អ្នកបានរលឹកឃើញហេតុពីមុនដូចម្តេច ។ ដំរីឆ្លើយ ថា ម្នាលសម្លាញ់ទាំងឡាយ កាលដែលខ្ញុំនៅតូច ខ្ញុំធ្វើដើមជ្រៃនេះ ក្នុង ចន្លោះភ្លៅទាំងពីរហើយដើរទៅ ចុងត្រួយ (ជ្រៃនេះ) ទល់នឹងពោះខ្ញុំ ម្នាល សម្លាញ់ទាំងឡាយ ខ្ញុំរលឹកឃើញនូវហេតុពីមុនដូច្នេះ ។ ម្នាលភិក្ខុទាំង ឡាយ កាលនោះ ទទានឹងដំរីសួរស្វាថា ម្នាលសម្លាញ់ អ្នករលឹកឃើញ ហេតុពីមុនដូចម្តេចខ្លះ ។ ស្វាឆ្លើយថា ម្នាលសម្លាញ់ទាំងឡាយ កាល ដែលខ្ញុំនៅតូច ខ្ញុំអង្គុយលើផែនដី ហើយទំពាស៊ីត្រួយជ្រៃនេះ ម្នាល សម្លាញ់ទាំងឡាយ ខ្ញុំរលឹកឃើញហេតុពីមុនដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្វានឹងដំរីសួរទៅទទាថា ម្នាលសម្លាញ់ អ្នករលឹកឃើញហេតុ ពីមុនដូចម្តេចខ្លះ ។ ទទាឆ្លើយថា ម្នាលសម្លាញ់ទាំងឡាយ ក្នុងទីឯណោះ មានដើមជ្រៃធំ ១ ដើម ខ្ញុំស៊ីផ្លែរួចហើយ ហើរមកអំពីនោះ មកបន្ទោបង់ វច្ចៈក្នុងឱកាសនេះ ជ្រៃនេះក៏កើតអំពីវច្ចៈរបស់ខ្ញុំ ម្នាលសម្លាញ់ទាំងឡាយ ខ្ញុំជាសត្វធំពីកំណើត តាំងអំពីកាលនោះមក ។ ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មគ្គោ ច បដិបទា ច តិត្តិរំ ឯតទវោចុំ ត្វំ សម្ម អម្ហាកំ ជាតិយា មហន្តតរោ តំ មយំ សក្ការិស្សាម គរុការិស្សាម មានេស្សាម បូជេស្សាម តុម្ហាកញ្ច មយំ ឱវាទេ តិដ្ឋេយ្យាមាតិ(១) ។ អថខោ ភិក្ខវេ តិត្តិរោ មក្កដញ្ច ហត្ថិនាគញ្ច បញ្ចសុ សីលេសុ សមាទបេសិ អត្តនា ច បញ្ចសុ សីលេសុ សមាទាយ វត្តតិ ។ តេ អញ្ញមញ្ញំ សគារវា សប្បតិស្សា សភាគវុត្តិកា វិហរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជឹសុ ។ ឯតំ ខោ ភិក្ខវេ តិត្តិរិយំ នាម ព្រហ្មចរិយំ អហោសីតិ ។

(៣៧៣) យេ វុឌ្ឍមបចាយន្តិ
នរា ធម្មស្ស កោវិទា
ទិដ្ឋេ ធម្មេ ច បាសំសា
សម្បរាយោ ច សុគ្គតីតិ ។

តេ ហិ នាម ភិក្ខវេ តិរច្ឆានគតា បាណា អញ្ញមញ្ញំ សគារវា សប្បតិស្សា សភាគវុត្តិកា វិហរិស្សន្តិ ឥធ ខ្វំ(២) ភិក្ខវេ សោភេថ យំ តុម្ហេ ឯវំស្វាក្ខាតេ

---

១ ឱ. ម. តិដ្ឋិស្សាមាតិ ។ ២ ឱ. ម. ខោតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ស្វានឹងដំរីបានពោលពាក្យនេះនឹងទទាថា ម្នាលសម្លាញ់ អ្នកជាធំពីកំណើតជាងយើង យើងនឹងធ្វើសក្ការៈ គោរព រាប់អាន បូជាអ្នក មួយទៀត យើងនឹងតាំងនៅក្នុងឱវាទរបស់អ្នក ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទទាឲ្យស្វានឹងដំរីកាន់សីលទាំង ៥ ហើយសមាទានប្រព្រឹត្តសីលទាំង ៥ ដោយខ្លួនឯង ។ សត្វទាំងឡាយនោះគោរពកោតក្រែង ប្រព្រឹត្តស្មោះស្មើទៅវិញទៅមកនឹងគ្នា លុះទំលាយខន្ធ ទៅកាន់លោកខាងមុខ ក៏បានទៅកើតក្នុងសុគតិ គឺ ឋានសួគ៌ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយធម៌នុះឯង ឈ្មោះតិត្តិរិយព្រហ្មចរិយៈ ។

(៣៧៣) ព្រះអង្គទ្រង់ត្រាស់ថា ពួកជនដែលឈ្លាស ក្នុង
ធម៌ កោតក្រែងចាស់ព្រឹទ្ធាចារ្យ រមែងបានសេចក្ដីសរសើរ
ក្នុងបច្ចុប្បន្នផង បានសុគតិក្នុងបរលោកផង ។

ម្នាលភិក្ខុទាំងឡាយ អម្បាលពួកសត្វតិរច្ឆានទាំងនោះ ម្ដេចក៏បេះគោរព កោតក្រែងប្រព្រឹត្តស្មោះស្មើ ដល់គ្នានឹងគ្នានៅបាន ចំណង់បើអ្នកទាំងឡាយបួសក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយដោយប្រពៃ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ធម្មវិនយេ បព្ពជិតា សមានា អញ្ញមញ្ញំ សគារវា សប្បតិស្សា សភាគវុត្តិកា វិហរេយ្យាថ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ ន ច ភិក្ខវេ សង្ឃិកំ យថាវុឌ្ឍំ បដិពាហិតព្វំ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្ស(១) ។

(៣៧៤) ទសយិមេ ភិក្ខវេ អវន្ទិយា បុរេ ឧបសម្បន្នេន បច្ឆា ឧបសម្បន្នោ អវន្ទិយោ អនុបសម្បន្នោ អវន្ទិយោ នានាសំវាសកោ វុឌ្ឍតរោ អធម្មវាទី អវន្ទិយោ មាតុគ្គាមោ អវន្ទិយោ បណ្ឌកោ អវន្ទិយោ បារិវាសិកោ អវន្ទិយោ មូលាយ បដិកស្សនារហោ អវន្ទិយោ មានត្តារហោ អវន្ទិយោ មានត្តចារិកោ អវន្ទិយោ អព្ភានារហោ អវន្ទិយោ ឥមេ ខោ

---

១ ឱ. ម. ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យានទេះ គួរណាស់តែគោពេកោតក្រែង ប្រព្រឹត្តស្មោះស្មើដល់គ្នានឹងគ្នា ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរធ្វើហេតុនុ៎ះឲ្យល្អ ក្នុងសាសនានេះចុះ ម្នាលភិក្ខុទាំងឡាយ អំពើនុ៎ះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការថ្វាយបង្គំ ការក្រោកទទួល អញ្ជលីកម្ម សាមីចិកម្ម អាសនៈប្រសើរ ទឹកប្រសើរ នឹងដុំបាយប្រសើរ (ដល់ភិក្ខុ) តាមលំដាប់ចាស់ទុំ ម្នាលភិក្ខុទាំងឡាយ តែថាវត្ថុជារបស់សង្ឃ ភិក្ខុមិនត្រូវឃាត់ទាំងតាមលំដាប់ចាស់ទុំទេ ភិក្ខុណាឃាត់ទាំង ត្រូវអាបត្តិទុក្កដ ។

(៣៧៤) ម្នាលភិក្ខុទាំងឡាយ អវន្ទិយបុគ្គល (បុគ្គលដែលភិក្ខុមិនត្រូវសំពះ) នេះមាន ១០ ពួក គឺ ភិក្ខុដែលបានឧបសម្បទាមុន មិនត្រូវសំពះភិក្ខុ ដែលបានឧបសម្បទាក្រោយ ១ មិនត្រូវសំពះអនុបសម្បន្ន ១ មិនត្រូវសំពះភិក្ខុចាស់ ដែលមានសំវាសផ្សេងគ្នា ជាអធម្មវាទី ១ មិនត្រូវសំពះមាតុគ្រាម ១ មិនត្រូវសំពះមនុស្សខ្ទើយ ១ មិនត្រូវសំពះភិក្ខុដែលកំពុងនៅបរិវាស ១ មិនត្រូវសំពះភិក្ខុដែលគួរទាញមក កាន់មូលាបត្តិ ១ មិនត្រូវសំពះភិក្ខុដែលគួរដល់មានត្ត ១ មិនត្រូវសំពះភិក្ខុដែលកំពុងប្រព្រឹត្តមានត្ត ១ មិនត្រូវសំពះភិក្ខុដែលគួរដល់អព្ភានកម្ម ១ ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខវេ ទស អវន្ទិយា ។ តយោមេ ភិក្ខវេ វន្ទិយា បច្ឆា ឧបសម្បន្នេន បុរេ ឧបសម្បន្នោ វន្ទិយោ នានាសំវាសកោ វុឌ្ឍតរោ ធម្មវាទី វន្ទិយោ សទេវកេ លោកេ ភិក្ខវេ(១) សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ តថាគតោ អរហំ សម្មាសម្ពុទ្ធោ វន្ទិយោ ឥមេ ខោ ភិក្ខវេ តយោ វន្ទិយាតិ ។

(៣៧៩) តេន ខោ បន សមយេន មនុស្សា សង្ឃំ ឧទ្ទិស្ស មណ្ឌបេ បដិយាទេន្តិ សន្ថរេ បដិយាទេន្តិ ឱកាសេ បដិយាទេន្តិ ។ ឆព្វគ្គិយានំ ភិក្ខូនំ អន្តេវាសិកា ភិក្ខូ សង្ឃិកញ្ញេវ ភគវតា យថាវុឌ្ឍំ អនុញ្ញាតំ នោ ឧទ្ទិស្សកតន្តិ ពុទ្ធប្បមុខស្ស សង្ឃស្ស បុរតោ បុរតោ គន្ត្វា មណ្ឌបេ បរិគ្គណ្ហន្តិ សន្ថរេ បរិគ្គណ្ហន្តិ ឱកាសេ បរិគ្គណ្ហន្តិ ឥទំ អម្ហាកំ ឧបជ្ឈាយានំ ភវិស្សតិ ឥទំ អម្ហាកំ អាចរិយានំ ភវិស្សតិ ឥទំ អម្ហាកំ ភវិស្សតីតិ ។ អថ ខោ អាយស្មា សារីបុត្តោ

១ ម. សទេវកេ ភិក្ខវេ លោកេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





បុគ្គលដែលភិក្ខុមិនត្រូវសំពះមាន ១០ ចំពូកដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍិយបុគ្គល (បុគ្គលដែលភិក្ខុត្រូវសំពះ) នេះមាន ៣ ពួក គឺភិក្ខុដែលបានឧបសម្បទាក្រោយត្រូវសំពះភិក្ខុ ដែលបានឧបសម្បទាមុន ១ ត្រូវសំពះភិក្ខុចាស់ជាង ដែលមានសំវាសផ្សេងគ្នាជាធម្មវាទី ១ ម្នាលភិក្ខុទាំងឡាយ ត្រូវថ្វាយបង្គំព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណៈនឹងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនឹងមនុស្សដ៏សេស ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលភិក្ខុត្រូវសំពះមាន ៣ ចំពូកដូច្នេះឯង ។

(៣៧៨) សម័យនោះឯង មនុស្សទាំងឡាយ តាក់តែងមណ្ឌប តាក់តែងកម្រាល តាក់តែងទីឱកាសចំពោះសង្ឃ ។ ភិក្ខុទាំងឡាយជាសិស្សរបស់ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា វត្ថុជារបស់សង្ឃ ព្រះមានព្រះភាគទ្រង់អនុញ្ញាតទៅតាមលំដាប់ចាស់ខ្ចី ពិតមែនហើយ តែវត្ថុដែលគេធ្វើឧទ្ទិស ( ដល់សង្ឃ ) ព្រះមានព្រះភាគមិនទាន់ទ្រង់អនុញ្ញាតនៅឡើយ (លុះគិតដូច្នោះហើយ) ក៏នាំគ្នាដើរដែងទៅពីខាងមុខ ៗ សង្ឃមានព្រះពុទ្ធជាប្រធាន ហើយហួងហែងមណ្ឌប ហួងហែងកម្រាល ហួងហែងទីឱកាស ថា ទីនេះសម្រាប់ឧបជ្ឈាយ៍របស់ពួកយើង ទីនេះសម្រាប់អាចារ្យរបស់ពួកយើង ទីនេះសម្រាប់ពួកយើង ៗ លំដាប់នោះ ព្រះសារីបុត្រមានអាយុ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពុទ្ធប្បមុខស្ស សង្ឃស្ស បិដ្ឋិតោ បិដ្ឋិតោ គន្ត្វា មណ្ឌបេសុ បរិគ្គហិតេសុ សន្ថរេសុ បរិគ្គហិតេសុ ឱកាសេសុ បរិគ្គហិតេសុ ឱកាសំ អលភមានោ អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។ អថខោ ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ឧក្កាសិ ។ អាយស្មាបិ សារីបុត្តោ ឧក្កាសិ ។ កោ ឯត្ថាតិ ។ អហំ ភគវា សារីបុត្តោតិ ។ កិស្ស ត្វំ សារីបុត្ត ឥធ និសិន្នោតិ ។ អថខោ អាយស្មា សារីបុត្តោ ភគវតោ ឯតមត្ថំ អារោចេសិ ។

(៣៧៦) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយានំ ភិក្ខូនំ អន្តេវាសិកា ភិក្ខូ សង្ឃិកញ្ញេវ ភគវតា យថាវុឌ្ឍំ អនុញ្ញាតំ នោ ឧទ្ទិស្សកតន្តិ ពុទ្ធប្បមុខស្ស សង្ឃស្ស បុរតោ បុរតោ គន្ត្វា មណ្ឌបេ បរិគ្គណ្ហន្តិ សន្ថរេ បរិគ្គណ្ហន្តិ ឱកាសេ បរិគ្គណ្ហន្តិ ឥទំ អម្ហាកំ ឧបជ្ឈាយានំ ភវិស្សតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទិមន្តទៅពីខាងក្រោយ ៗ សង្ឃមានព្រះពុទ្ធជាប្រធាន កាលបើពួកអន្តេវា-សិករបស់ឆព្វគ្គិយភិក្ខុ ហួងហែងមណ្ឌប ហួងហែងកម្រាល ហួងហែងទីឧកាស (ដូច្នោះ) លោកមិនបានទីឧកាស ក៏ទៅគង់ទៀបគល់ឈើ ១ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់តើនឡើង ក្នុងបច្ចូសសម័យនៃរាត្រី ហើយទ្រង់ក្អកគ្រហែម ។ ព្រះសារីបុត្តមានអាយុ ក៏ក្អកគ្រហែមដែរ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នរណានៅក្នុងទីនុ៎ះ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះសារីបុត្ត ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលសារីបុត្ត ហេតុអ្វីបានជាអ្នកមកអង្គុយក្នុងទីនេះ ។ ព្រះសារីបុត្តមានអាយុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។

[៣៧៦] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុទាំងឡាយជាសិស្ស របស់ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា វត្តជារបស់សង្ឃ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតតាមលំដាប់ចាស់ខ្ចី ពិតមែនហើយ តែវត្ថុដែលគេឧទ្ទិស ( ដល់សង្ឃ ) ព្រះមានព្រះភាគមិនទាន់ទ្រង់អនុញ្ញាតនៅឡើយ ( លុះគិតដូច្នោះហើយ ) ក៏នាំគ្នាដើរដែងទៅពីខាងមុខ ៗ សង្ឃមានព្រះពុទ្ធជាប្រធាន ហើយក៏នាំគ្នា ហួងហែងមណ្ឌប ហួងហែងកម្រាល ហួងហែងទីឧកាសថា ទីនេះសម្រាប់ឧបជ្ឈាយ៍ របស់យើង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឥទំ អញ្ញតរំ អាចរិយានំ ករិស្សតិ ឥទំ អញ្ញតរំ ករិស្សតីតិ ។ សង្ឃំ កតភតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ ឧទ្ទិស្សកតម្បិ យថាវុឌ្ឍំ បដិពាហិតព្វំ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៣៧៧) តេន ខោ បន សមយេន មនុស្សា ភត្តគ្គេ អន្តរឃរេ ឧច្ចាសយនមហាសយនានិ បញ្ញាបេន្តិ សេយ្យថីទំ អាសន្ទឹ បល្លង្កំ គោណកំ ចិត្តកំ បដិកំ បដលិកំ តូលិកំ វិកតិកំ ឧទ្ទលោមឹ ឯកន្តលោមឹ កដិស្សំ[១]

---

១ ម. កដ្ឋិស្សំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទីនេះសម្រាប់អាចារ្យរបស់យើង ទីនេះសម្រាប់យើងពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ បេ ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ពោះបើវត្ថុដែលគេធ្វើឧទ្ទិស (ដល់សង្ឃ) ពួកភិក្ខុមិនត្រូវឃាត់ទាំងទៅតាមលំដាប់ចាស់ខ្ចីទេ ភិក្ខុណាឃាត់ទាំង ត្រូវអាបត្តិទុក្កដ ។

(៣៧៧) សម័យនោះឯង មនុស្សទាំងឡាយនាំគ្នាក្រាលអាសនៈខ្ពស់ អាសនៈប្រសើរ ក្នុងរោងភត្តទីឯណោះផង (ប្រគេនពួកភិក្ខុ) អាសនៈខ្ពស់ អាសនៈប្រសើរដូចម្តេចខ្លះ អាសនៈខ្ពស់ អាសនៈប្រសើរនោះ គឺអាសន្ទិ (អាសនៈខ្ពស់ហួសប្រមាណ) បល្លង្កៈ (គ្រែដែលមានជើងខ្ពស់វិចិត្រដោយរូបសត្វសាហាវ) គោណកៈ (ព្រំដែលមានរោមវែងជាង ៤ ធ្នាប់) ចិត្តកៈ (កម្រាលដែលធ្វើពីរោមសត្វវិចិត្រ ដោយរូបសត្វសាហាវ) បដិកៈ (កម្រាលមានពណ៌សដែលធ្វើដោយរោមសត្វ) បដលិកៈ (កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម) តូលិកៈ (កម្រាលដែលញាត់ដោយសំឡីគ) វិកតិកៈ (កម្រាលដែលធ្វើដោយរោមសត្វវិចិត្រ ដោយរូបសត្វមានសីហៈនឹងខ្លាធំជាដើម) ឧទ្ធលោមិ (កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងតែម្ខាង) ឯកន្តលោមិ (កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងទាំងពីរខាង) កដិស្សៈ (កម្រាលដែលធ្វើដោយខ្សែមាសនឹងសូត្រ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កោសេយ្យំ កម្ពលំ(១) កុត្តកំ ហត្ថត្ថរំ អស្សត្ថរំ រថត្ថរំ អជិនប្បវេណី កាទលិមិគប្បវរប្បច្ចត្ថរណំ សឧត្តរច្ឆទំ ឧភតោលោហិតកុបធានំ ។ ភិក្ខូ កុក្កុច្ចាយន្តា នាភិនិសីទន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឋបេត្វា តីណិ អាសន្ទឹ បល្លង្កំ តូលិកំ អវសេសំ(២) គិហិវិកដំ អភិនិសីទិតុំ ន ត្វេវ អភិនិបជ្ជិតុន្តិ ។

(៣៧៨) តេន ខោ បន សមយេន មនុស្សា ភត្តគ្គេ អន្តរឃរេ តូលោនទ្ធំ មញ្ចម្បិ បីឋម្បិ បញ្ញាបេន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន អភិនិសីទន្តិ ។

---

១ អយំ ឱ.ម. ពោត្ថកេសុ ន ទិស្សតិ។ ២ អយំ អវសេសសទ្ទោ ឱ.ម. ពោត្ថកេសុ ន ទិស្សតិ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហើយចាក់ស្រែះដោយគេនវត្ថ) កោសេយ្យៈ (កម្រាលដែលធ្វើដោយសរសៃសូត្រ ហើយចាក់ស្រែះដោយគេនវត្ថ) កម្ពលៈ (កម្រាលដែលធ្វើដោយរោមសត្វ) កុត្តកៈ (កម្រាលដែលធ្វើដោយរោមសត្វល្មមពួកស្រីរបាំ ១៦ នាក់ឈរកំបាន) ហត្ថត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងដំរី) អស្សត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងសេះ) រថត្ថរៈ (កម្រាលសម្រាប់ក្រាលលើរថ) អជិនប្បវេណិ (កម្រាលដែលធ្វើដោយស្បែកខ្លា) កទលិមិគបវរ-បច្ចត្ថរណៈ (កម្រាលដ៏ឧត្តមដែលធ្វើដោយស្បែកសត្វឈ្មុស) សឧត្ត-រច្ឆទៈ (ទីដេកដែលមានពិតានក្រហមពីខាងលើ) ឧភតោលោហិតកូបធានៈ (កម្រាលដែលមានខ្នើយមានពណ៌ក្រហមទាំងពីរខាង គឺខ្នើយក្បាលនិងខ្នើយជើង) ។ ពួកភិក្ខុរង្កៀសមិនហ៊ានអង្គុយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអង្គុយលើអាសនៈ ដ៏សេសជាគិហិវិ-កដ គឺអាសនៈដែលប្លែកសម្រាប់គ្រហស្ថបាន តែដេកមិនបាន វៀរលែងតែសេនាសនៈ ៣ យ៉ាង គឺ អាសន្ទិ ១ បល្លង្កៈ ១ តូលិកៈ ១ ។

(៣៧៨) សម័យនោះឯង ពួកមនុស្សតាក់តែងត្រែងផង តាំងផង ដែលញាក់សំឡៀត ក្នុងកេងកត្តនិងចន្ទោះផ្ទះ " ពួកភិក្ខុរង្កៀសមិនហ៊ានអង្គុយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គិហិវិកតំ អភិនិសីទិតុំ ន ត្វេវ អភិនិបជ្ជិតុំ ។

(៣៧៩) អថ ខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថ ខោ អនាថ-បិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្ក-មិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អនាថបិណ្ឌិកោ គហបតិ ភគវន្តំ ឯត-ទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភា-វេន ។ អថ ខោ អនាថបិណ្ឌិកោ គហបតិ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអង្គុយលើអាសនៈជាគិហិវិកដ ដែលប្លែកសម្រាប់គ្រហស្ថបាន តែដេកមិនបាន ។

(៣៧៩) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកតាមលំដាប់ សំដៅត្រង់ទៅកាន់ក្រុងសាវត្ថី ។ មានរឿងដំណាលថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតិអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់ទទួលភត្ត របស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឃ ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លុះអនាថបិណ្ឌិកគហបតិដឹងច្បាស់ថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៨០) អថខោ អនាថបិណ្ឌិកោ គហបតិ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ អនាថបិណ្ឌិកោ គហបតិ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ, ខោ អនាថបិណ្ឌិកោ គហបតិ ភគវន្តំ ឯតទវោច កថាហំ ភន្តេ ជេតវនេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ គហបតិ ជេតវនំ អាគតានាគតស្ស ចាតុទ្ទិសស្ស សង្ឃស្ស បតិដ្ឋាបេហីតិ ។ ឯវំ ភន្តេតិ ខោ អនាថបិណ្ឌិកោ គហបតិ ភគវតោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៨០) លំដាប់នោះ អនាថបិណ្ឌិកគហបតិឲ្យតាក់តែងខាទនីយ-ភោជនីយាហារ ដ៏ឆ្ងាញ់ពិសា ក្នុងពេលដែលកន្លងរាត្រីនោះទៅហើយ ឲ្យទៅក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តសម្រេចហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ទ្រង់បាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់លំនៅរបស់អនាថបិណ្ឌិកគហបតិ លុះយាងទៅដល់ហើយក៏គង់លើអាសនៈដែលគេតាក់តែងថ្វាយជាមួយនឹងភិក្ខុសង្ឃ ។ អនាថបិណ្ឌិក-គហបតិក៏បានអង្គាសខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពិសាថ្វាយដោយដៃឯង ចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ត្រាតែទ្រង់ប្រកែកលែងទទួលទៀត (លុះដឹងថា) ព្រះមានព្រះភាគទ្រង់សោយស្រេចលែងលូកព្រះហស្ដទៅក្នុងបាត្រហើយ ទើបអង្គុយនៅក្នុងទីសមគួរ ។ អនាថបិណ្ឌិកគហបតិអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គត្រូវប្រតិបត្តិក្នុងវត្តជេតវ័នដូចម្ដេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតិ បើដូច្នោះអ្នកចូរប្រតិស្ឋានវត្តជេតវ័ន សម្រាប់សង្ឃដែលបានមកហើយ នឹងមិនទាន់បានមកអំពីទិសទាំង ៤ ។ អនាថបិណ្ឌិកគហបតិទទួលស្ដាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងហ្នឹងហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





បដិស្សុត្វា ជេតវនំ អាគតានាគតស្ស ចាតុទ្ទិសស្ស សង្ឃស្ស បតិដ្ឋាបេសិ ។ អថខោ ភគវា អនាថបិណ្ឌិកំ គហបតឹ ឥមាហិ គាថាហិ អនុមោទិ ។

(៣៨១) សីតំ ឧណ្ហំ បដិហន្តិ
តតោ វាឡមិគានិ ច
សិរីសបេ ច មកសេ
សិសិរេ ចាបិ វុដ្ឋិយោ
តតោ វាតាតបោ ឃោរោ
សញ្ជាតោ បដិហញ្ញតិ ។
លេណត្ថញ្ច សុខត្ថញ្ច
ឈាយិតុញ្ច វិបស្សិតុំ
វិហារទានំ សង្ឃស្ស
អគ្គំ ពុទ្ធេហិ វណ្ណិតំ ។
តស្មា ហិ បណ្ឌិតោ បោសោ
សម្បស្សំ អត្ថមត្តនោ
វិហារេ ការយេ រម្មេ
វាសយេត្ថ ពហុស្សុតេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ហើយក៏ប្រតិស្ឋានវត្តជេតវ័ន សម្រាប់សង្ឃដែលបានមកហើយ និងមិនទាន់បានមកអំពីទិសទាំង៤ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់អនុមោទនាចំពោះអនាថបិណ្ឌិកគហបតិ ដោយគាថាទាំងនេះថា

(៣៨១) (វិហារ គឺ ទីអាវាស ឬ សេនាសនៈជាទីនៅនៃសង្ឃទាំងឡាយ) រមែងការពាររងាផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូចពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់និងកំដៅថ្ងៃ ដ៏ក្លាខ្លាំងដែលកើតឡើងហើយ រមែងបាត់ទៅវិញព្រោះវិហារនោះ ៗ វិហារទាន គឺ ការឲ្យលំនៅ (ដែលបុគ្គលបានឲ្យហើយ)ដល់សង្ឃសម្រាប់ជ្រកកោនផង សម្រាប់នៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចំរើនវិបស្សនាផង ព្រះពុទ្ធជាម្ចាស់ទាំងឡាយ តែងត្រាស់សរសើរថាជាអគ្គទាន(ទានដ៏ប្រសើរ) ។ ព្រោះហេតុនោះឯង បុរស(ស្ត្រី)ជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ហើយគប្បីកសាងវិហារ គឺ អាវាសឬសេនាសនៈទាំងឡាយដ៏ជាទីគួររីករាយ ហើយគប្បីនិមន្តលោកដែលជាពហុស្សូត គឺ លោកអ្នកចេះដឹងច្រើនទាំងឡាយ ឲ្យនៅក្នុងទីនោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តេសំ អន្នញ្ច បានញ្ច
វត្ថសេនាសនានិ ច
ទទេយ្យ ឧជុភូតេសុ
វិប្បសន្នេន ចេតសា ។
តេ តស្ស ធម្មំ ទេសេន្តិ
សព្វទុក្ខាបនូទនំ
យំ សោ ធម្មំ ឥធញ្ញាយ
បរិនិព្វាតិ អនាសវោតិ ។

អថខោ ភគវា អនាថបិណ្ឌិកំ គហបតឹ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។

(៣៨២) តេន ខោ បន សមយេន អញ្ញតរស្ស អាជីវកសាវកស្ស មហាមត្តស្ស សង្ឃភត្តំ ហោតិ ។ អាយស្មា ឧបនន្ទោ សក្យបុត្តោ បច្ឆា អាគន្ត្វា វិប្បកតភោជនេ[១] អនន្តរិកំ ភិក្ខុំ វុដ្ឋាបេសិ ។ ភត្តគ្គំ កោលាហលំ អហោសិ ។ អថខោ សោ មហាមត្តោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម សមណា សក្យបុត្តិយា បច្ឆា អាគន្ត្វា វិប្បកតភោជនេ អនន្តរិកំ ភិក្ខុំ[២]

១ ម. វិប្បកតភោជនំ ។ ២ ឱ. ម. វិប្បកតភោជនេ ភិក្ខូ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គប្បីមានចិត្តជ្រះថ្លាចំពោះលោកទាំងឡាយ ដែលមានកាយនឹងចិត្តត្រង់ ហើយឲ្យម្ហូបចំណីផង ទឹកផង សំពត់ទឹក សេ-នាសនៈទាំងឡាយផង ដល់លោកទាំងនោះចុះ ៗ លោកទាំងនោះ រមែងសំដែងធម៌ជាគ្រឿងបន្ទោបង់សេចក្តីទុក្ខគ្រប់ប្រ-ការដល់អ្នកនោះ លុះអ្នកនោះបានដឹងធម៌ណា ក្នុងព្រះពុទ្ធ-សាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ៗ

លុះព្រះមានព្រះភាគ ទ្រង់អនុមោទនា ចំពោះអនាថបិណ្ឌិកគហបតី ដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈ ទ្រង់ពុទ្ធដំណើរចៀសចេញទៅ ។

[ ៣៨២ ] សម័យនោះ មានមហាមាត្រម្នាក់ជាសាវ័ករបស់អាជីវក ធ្វើសង្ឃភត្ត ។ ឧបនន្ទសក្យបុត្រមានអាយុមកដល់ក្រោយគេ ក៏បណ្តេញភិក្ខុដែលមានវស្សាជាលំដាប់ខ្លួន កំពុងឆាន់មិនទាន់លែងឲ្យក្រោកចេញ ។ ពេលភត្តក៏កើតមានសេចក្តីជ្រួលច្រើម ។ មហាមាត្រនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តិយ៍មកដល់ក្រោយគេ មិនគួរនឹងបណ្តេញភិក្ខុ ដែលមានវស្សាជាលំដាប់ខ្លួនកំពុងឆាន់មិនទាន់លែង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វុដ្ឋាបេស្សន្តិ ភត្តគ្គំ កោលាហលំ អហោសិ ននុ នាម លព្ភា អញ្ញត្រាបិ និសិន្នេន យាវទត្ថំ ភុញ្ជិតុន្តិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស មហាមត្តស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ បច្ឆា អាគន្ត្វា វិប្បកតភោជនេ អនន្តរិកំ ភិក្ខុំ វុដ្ឋាបេស្សតិ ភត្តគ្គំ កោលាហលំ អហោសីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ឧបនន្ទ បច្ឆា អាគន្ត្វា វិប្បកតភោជនេ អនន្តរិកំ ភិក្ខុំ វុដ្ឋាបេសិ ភត្តគ្គំ កោលាហលំ អហោសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស បច្ឆា អាគន្ត្វា វិប្បកតភោជនេ អនន្តរិកំ ភិក្ខុំ វុដ្ឋាបេស្សសិ ភត្តគ្គំ កោលាហលំ អហោសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឲ្យក្រោកចេញសោះ (នាំឲ្យ) ពេធកត្តកើតមានសេចក្តីជ្រួលជ្រើម បើយ៉ាងហ្នឹងភិក្ខុឯទៀតអាចធាន់ផ្ទួតស្រួលបួលដែរ វៀរលែងតែភិក្ខុដែលអង្គុយស៊ប់ហើយ ។ ពួកភិក្ខុបានឮមហាមាត្រនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទសក្យបុត្រដ៏មានអាយុមកក្រោយគេ មិនគួរនឹងបណ្តេញភិក្ខុដែលមានវស្សាជាលំដាប់ខ្លួន កំពុងធាន់មិនទាន់លែងឲ្យក្រោកចេញសោះ (នាំឲ្យ) ពេធកត្តកើតមានសេចក្តីជ្រួលជ្រើម ។ គ្រានោះភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកមកដល់ក្រោយគេ ហើយបណ្តេញភិក្ខុ ដែលមានវស្សាជាលំដាប់ខ្លួន កំពុងធាន់មិនទាន់លែងឲ្យក្រោកចេញ (នាំឲ្យ) ពេធកត្តកើតមានសេចក្តីជ្រួលជ្រើម ពិតមែនឬ ។ ឧបនន្ទក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ ព្រះពុទ្ធមានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស មិនគួរបើអ្នកមកក្រោយគេហើយបណ្តេញភិក្ខុដែលមានវស្សាជាលំដាប់ កំពុងធាន់មិនទាន់លែងឲ្យក្រោកចេញសោះ (នាំឲ្យ) ពេធកត្តកើតមានសេចក្តីជ្រួលជ្រើម នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ លុះទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខូ អាមន្តេសិ ន ភិក្ខវេ វិប្បកតភោជនោ(១) អនន្តរិកោ(២) ភិក្ខុ វុដ្ឋាបេតព្វោ យោ វុដ្ឋាបេយ្យ អាបត្តិ ទុក្កដស្ស សចេ វុដ្ឋាបេតិ បវារិតោ ច ហោតិ គច្ឆ ឧទកំ អាហរាហីតិ វត្តព្វោ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ សាធុកំ សិត្ថានិ គិលិត្វា វុឌ្ឍតរស្ស ភិក្ខុនោ(៣) អាសនំ ទាតព្វំ នត្វេវាហំ ភិក្ខវេ កេនចិ បរិយាយេន វុឌ្ឍតរស្ស ភិក្ខុនោ អាសនំ បដិពាហិតព្វន្តិ វទាមិ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៣៨៣] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ គិលានេ ភិក្ខូ វុដ្ឋាបេន្តិ ។ គិលានា ឯវំ វទេន្តិ ន មយំ អាវុសោ សក្កោម វុដ្ឋាតុំ គិលានម្ហាតិ ។ មយំ អាយស្មន្តេ វុដ្ឋាបេស្សាមាតិ បរិគ្គហេត្វា វុដ្ឋាបេត្វា ឋិតកេ មុញ្ចន្តិ ។ គិលានា មុច្ឆិតា បបតន្តិ ។បេ។

---

១ ម. វិប្បកតភោជនោ ។ ២ ឱ. ម. អនន្តរិកោតិ បាឋោ ន ទិស្សតិ ។ ៣ ឱ. ម. ភិក្ខុនោតិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបណ្តេញភិក្ខុដែលអង្គុយខាងក្រោយគេបង្អស់ ដែលកំពុងនៅឆាន់មិនទាន់លែង ឲ្យក្រោកចេញទេ ភិក្ខុណាបណ្តេញត្រូវអាបត្តិទុក្កដ តែបើ (ភិក្ខុចាស់) បណ្តេញ (ភិក្ខុថ្មីដែលកំពុងឆាន់) ឲ្យក្រោកចេញ ត្រូវភិក្ខុថ្មីឃាត់ហើយនិយាយថា ចូរលោកទៅយកទឹកមក បើបានទឹកនោះមកដោយអាការដូច្នេះ ការនេះជាការផុតទោស បើមិនបានទឹកមកទេ ត្រូវភិក្ខុថ្មីលេបគ្រាប់បាយឲ្យស្រួល ហើយឲ្យអាសនៈដល់ភិក្ខុចាស់ជាង (នោះ) ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលថា ឲ្យភិក្ខុទាំងឡាយឃាត់អាសនៈចំពោះភិក្ខុចាស់ជាង ដោយបរិយាយឯណាមួយទេ ភិក្ខុណាឃាត់ ត្រូវអាបត្តិទុក្កដ ។

(៣៨៣) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ នាំគ្នាបណ្តេញពួកភិក្ខុឈឺឲ្យក្រោកចេញ ។ ភិក្ខុឈឺទាំងឡាយពោលយ៉ាងនេះថា ម្នាលអាវុសោ ពួកខ្ញុំករុណាសុទ្ធតែជាអ្នកឈឺ មិនអាចនឹងក្រោកចេញបានទេ ។ ពួកឆព្វគ្គិយភិក្ខុ គិតគ្នាថា យើងនឹងបណ្តេញលោកមានអាយុទាំងឡាយឲ្យក្រោកចេញ ហើយក៏នាំគ្នាចាប់ភិក្ខុទាំងនោះឲ្យក្រោកឈរឡើងហើយលែងចេញ ។ ពួកភិក្ខុឈឺក៏ព្រប់ផ្លួលទៅ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ គិលានោ វុដ្ឋាបេតព្វោ យោ វុដ្ឋាបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៣៨៦) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ គិលានា មយន្តិ អវុដ្ឋាបនីយាតិ វរសេយ្យាយោ បលិពុន្ធន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ គិលានស្ស បដិរូបំ សេយ្យំ ទាតុន្តិ ។

(៣៨៧) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ លេសកប្បេន សេនាសនំ បដិពាហន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ លេសកប្បេន សេនាសនំ បដិពាហិតព្វំ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបណ្តេញភិក្ខុឈឺទេ ភិក្ខុណាបណ្តេញ ត្រូវអាបត្តិទុក្កដ ។

(៣៨៤) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ គិតគ្នាថា យើងទាំងឡាយជាអ្នកឈឺ ទុកជាអ្នកណាក៏មិនគប្បីបណ្តេញ ឲ្យក្រោកចេញបាន ហើយក៏ដេកជាប់នៅទីដំណេកដ៏ប្រសើរ ។ បេ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ។ ទំដំណេកដ៏សមគួរដល់ភិក្ខុឈឺបាន ។

(៣៨៥) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឃាត់អាសនៈដោយកលមាយាអាក្រក់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវហាមឃាត់អាសនៈ ដោយកលមាយាអាក្រក់ទេ[១] ភិក្ខុណាហាមឃាត់ ត្រូវអាបត្តិទុក្កដ ។

---

១ ដោយកលមាយាអាងហេតុ ឬដោយពុតមាយា ដូចអាងដល់ជម្ងឺឈឺក្បាលជាដើម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៣៨៦] តេន ខោ បន សមយេន សត្តរសវគ្គិយា ភិក្ខូ អញ្ញតរំ បច្ចន្តិមំ មហាវិហារំ បដិសង្ខរោន្តិ ឥធ មយំ វស្សំ វសិស្សាមាតិ ។ អទ្ទសំសុ[១] ខោ ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយេ ភិក្ខូ វិហារំ បដិសង្ខរោន្តេ ទិស្វាន ឯវមាហំសុ ឥមេ អាវុសោ សត្តរសវគ្គិយា ភិក្ខូ វិហារំ បដិសង្ខរោន្តិ ហន្ទ នេ វុដ្ឋាបេស្សាមាតិ[២] ឯកច្ចេ ឯវមាហំសុ អាគមេថាវុសោ យាវ បដិសង្ខរោន្តិ បដិ-សង្ខតេ វុដ្ឋាបេស្សាមាតិ ។ អថខោ ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយេ ភិក្ខូ ឯតទវោចុំ ឧដ្ឋេថាវុសោ អម្ហាកំ វិហារោ បាបុណាតីតិ ។ ននុ អាវុសោ បដិកច្ចេវ[៣] អាចិក្ខិតព្វំ មយញ្ច អញ្ញំ បដិសង្ខរេយ្យាមាតិ ។ ននុ អាវុសោ សង្ឃិកោ វិហារោតិ ។ អាមាវុសោ សង្ឃិកោ វិហារោតិ ។ ឧដ្ឋេថាវុសោ អម្ហាកំ វិហារោ បាបុណាតីតិ ។ មហល្លកោ អាវុសោ វិហារោ

---

១ ឱ. ម. អទ្ទសាសុំ ។ ២ ឱ. វុដ្ឋាបេមាតិ ។ ៣ ឱ. បដិគច្ចេវ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៨៦) សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុ ជួសជុលវិហារធំមួយដែលមាននៅក្នុងទីបំផុតដែនដោយគិតគ្នាថា ពួកយើងនឹងនៅចាំស្រុកក្នុងវិហារធំនេះ ។ ពួកឆព្វគ្គិយភិក្ខុបានឃើញពួកសត្តរសវគ្គិយភិក្ខុ កំពុងតែជួសជុលវិហារ លុះឃើញហើយក៏បានពោលពាក្យយ៉ាងនេះថា ម្នាលអាវុសោ ពួកសត្តរសវគ្គិយភិក្ខុទាំងនេះ កំពុងតែជួសជុលវិហារ បើដូច្នោះ ពួកយើងនឹងនាំគ្នាបណ្ដេញភិក្ខុទាំងនោះ ឲ្យដើរចេញ ភិក្ខុពួកខ្លះពោលយ៉ាងនេះថា លោកទាំងឡាយចូរបង្អង់សិន ដ្បិតសត្តរសវគ្គិយភិក្ខុកំពុងតែជួសជុល ចាំដល់លោកទាំងនោះជួសជុលរួចស្រេច សឹមយើងនាំគ្នាបណ្ដេញឲ្យដើរចេញ ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុពោលពាក្យនេះនឹងពួកសត្តរសវគ្គិយភិក្ខុថា ម្នាលអាវុសោ លោកចូរក្រោកចេញ វិហារ (នេះ) ត្រូវបានមកពួកយើងទេ ។ សត្តរសវគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ លោកទាំងឡាយ គួរប្រាប់មកឲ្យប្រាកដជាមុន ពួកយើងនឹងនាំគ្នាជួសជុលវិហារដទៃទៀត ។ ឆព្វគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ វិហារ (នេះ) ជារបស់សង្ឃមិនមែនឬ ។ សត្តរសវគ្គិយភិក្ខុនិយាយតបថា ម្នាលលោកដ៏មានអាយុ អើ វិហារ (នេះ) ជារបស់សង្ឃមែន ។ ឆព្វគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ លោកត្រូវក្រោកចេញទៅ វិហារ(នេះ) ត្រូវបានមកពួកយើងទេ ។ សត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ វិហារធំដែរ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តុម្ហេបិ វសថ មយំបិ វសិស្សាមាតិ ។ ឧដ្ឋេថាវុសោ អម្ហាកំ វិហារោ បាបុណាតីតិ កុបិតា អនត្តមនា គីវាយំ គហេត្វា និក្កឌ្ឍន្តិ ។ តេ តេហិ(១) និក្កឌ្ឍិយមានា រោទន្តិ ។ ភិក្ខូ ឯវមាហំសុ កិស្ស តុម្ហេ អាវុសោ រោទថាតិ ។ ឥមេ អាវុសោ ឆព្ពគ្គិយា ភិក្ខូ កុបិតា អនត្តមនា អម្ហេ សង្ឃិកា វិហារា និក្កឌ្ឍន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ កុបិតា អនត្តមនា ភិក្ខូ សង្ឃិកា វិហារា និក្កឌ្ឍិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្ពគ្គិយា ភិក្ខូ កុបិតា អនត្តមនា ភិក្ខូ សង្ឃិកា វិហារា និក្កឌ្ឍន្តីតិ ។ សច្ចំ ភគវាតិ ។បេ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ កុបិតេន អនត្តមនេន ភិក្ខុ សង្ឃិកា វិហារា និក្កឌ្ឍិតព្វោ(២)

---

១ ឱ. ម. ពោត្ថកេសុ តេហិសទ្ទោ ន បញ្ញាយតិ ។ ២ ឱពេចិយម្មពោត្ថកេសុ ន ភិក្ខវេ កុបិតេន អនត្តមនេន ភិក្ខុ សង្ឃិកា វិហារា និក្កឌ្ឍិតព្វោតិ បាឋោ អាគតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកៈ រឿងសត្តរសវគ្គិយភិក្ខុ

លោកទាំងឡាយនៅក៏បាន យើងនៅក៏បាន ។ ឆព្វគ្គិយភិក្ខុខឹងអាក់អន់ចិត្តហើយច្បាមគ្រង់ក ទាញចេញដោយពាក្យថា ម្នាលអាវុសោ លោកទាំងឡាយចូរក្រោកដើរចេញ វិហារត្រូវបានមកពួកយើងទេ ។ សត្តរសវគ្គិយភិក្ខុនោះ កាលបើឆព្វគ្គិយភិក្ខុទាញចេញ ក៏នាំគ្នាស្រែកយំ ។ ភិក្ខុទាំងឡាយសួរហេតុនេះថា ម្នាលអាវុសោ ព្រោះហេតុអ្វីបានជាលោកយំ ។ សត្តរសវគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ឆព្វគ្គិយភិក្ខុទាំងនេះខឹងអាក់អន់ចិត្តហើយ ចាប់ទាញពួកយើងឲ្យចេញចាកវិហាររបស់សង្ឃ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ភិក្ខុទាំងនោះក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ឆព្វគ្គិយភិក្ខុមិនសមបើនឹងខឹងអាក់អន់ចិត្ត ហើយចាប់ទាញភិក្ខុទាំងឡាយឲ្យចេញចាកវិហារ ជារបស់សង្ឃសោះ ។ លំដាប់នោះ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយភិក្ខុខឹងអាក់អន់ចិត្ត ហើយចាប់កន្ត្រាក់ភិក្ខុទាំងឡាយ ឲ្យចេញចាកវិហារជារបស់សង្ឃពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ បេ ។ ព្រះមានព្រះភាគទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវខឹងអាក់អន់ចិត្ត ហើយចាប់កន្ត្រាក់ភិក្ខុទាំងឡាយ ឲ្យចេញចាកវិហារជារបស់សង្ឃទេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យោ និក្កាមេយ្យ យថាធម្មោ ការេតព្វោ អនុជានាមិ ភិក្ខវេ សេនាសនំ គាហេតុំ ។

(៣៨៧) អថខោ ភិក្ខូនំ ឯតទហោសិ កេន នុ ខោ សេនាសនំ គាហេតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ សេនាសនគ្គាហាបកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ គាហិតាគាហិតញ្ច[១] ជានេយ្យ ។

(៣៨៨) ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សេនាសនគ្គាហាបកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។

១ ឱ. ម. គហិតាគហិតញ្ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុណាចាប់កន្ត្រាក់ទាញចេញ វិន័យធរគប្បីកាត់សម្រេចឲ្យសមគួរតាមអាបត្តិ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យមានភិក្ខុប្រគល់សេនាសនៈ (ដល់ភិក្ខុណាមួយ) ។

(៣៨៧) គ្រានោះ ភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុដូចម្តេចហ្ន៎ ដែលគួរប្រគល់សេនាសនៈឲ្យបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកប ដោយអង្គ ៥ ឲ្យជាសេនាសនគ្គាហាបកៈ (អ្នកប្រគល់សេនាសនៈ) គឺភិក្ខុមិនលុះក្នុងឆន្ទាគតិ ១ មិនលុះក្នុងទោសាគតិ ១ មិនលុះក្នុងមោហាគតិ ១ មិនលុះក្នុងភយាគតិ ១ ដឹងច្បាស់នូវសេនាសនៈដែលខ្លួនបានប្រគល់និងមិនទាន់បានប្រគល់ ១ ។

(៣៨៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវសន្មតយ៉ាងនេះ ។ សង្ឃត្រូវសូមភិក្ខុជាមុនសិន ។ លុះសូមហើយ ត្រូវភិក្ខុដែលឈ្លាសប្រតិពល ប្រកាសសង្ឃ ឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាសេនាសនគ្គាហាបកៈ (អ្នកប្រគល់សេនាសនៈ) ។ នេះជាញត្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សេនាសនគ្គាហាបកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សេនាសនគ្គាហាបកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ សេនាសនគ្គាហាបកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៣៨៩) អថខោ សេនាសនគ្គាហាបកានំ ភិក្ខូនំ ឯតទហោសិ កថំ នុ ខោ សេនាសនំ គាហេតព្វន្តិ(១) ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បឋមំ ភិក្ខូ គណេតុំ ភិក្ខូ គណេត្វា សេយ្យា គណេតុំ សេយ្យា គណេត្វា សេយ្យគ្គេន គាហេតុន្តិ ។ សេយ្យគ្គេន គាហេន្តា សេយ្យា ឧស្សាទិយឹសុ(២) ។ បេ ។ អនុជានាមិ ភិក្ខវេ វិហារគ្គេន គាហេតុន្តិ ។ វិហារគ្គេន គាហេន្តា វិហារា ឧស្សាទិយឹសុ(៣) ។ បេ ។ អនុជានាមិ ភិក្ខវេ បរិវេណគ្គេន

---

១ ឱ. ម. គាហេតព្វន្តិ ។ ២-៣ ម. ឧស្សារយឹសុ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ជៀតសង្ឃទើងសន្មតភិក្ខុឈ្មោះនេះឲ្យជាសេនាសនគ្គាហាបកៈ ។ ការសន្មតិភិក្ខុឈ្មោះនេះឲ្យជាសេនាសនគ្គាហាបកៈសមគួរ ដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវថ្លែងមក ។ ភិក្ខុឈ្មោះនេះសង្ឃបានសន្មតឲ្យជាសេនាសនគ្គាហាបកៈគួរដល់សង្ឃ ព្រោះហេតុដូច្នោះ បានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំសេចក្ដីនុ៎ះទុក ដោយអាការស្ងៀមយ៉ាងនេះ ។

(៣៨៩) គ្រានោះឯង ពួកភិក្ខុជាសេនាសនគ្គាហាបកៈមានសេចក្ដីត្រិះរិះដូច្នេះថា យើងគប្បីប្រគល់សេនាសនៈដូចម្ដេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរាប់ភិក្ខុមុន លុះរាប់ភិក្ខុរួចហើយ ឲ្យរាប់ដំណេក លុះរាប់ដំណេករួចហើយ សឹមប្រគល់ឲ្យតាមកំណត់នៃដំណេក ។ ភិក្ខុទាំងឡាយក៏ប្រគល់ឲ្យតាមកំណត់នៃដំណេក ដំណេកក៏សល់នៅច្រើន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រគល់តាមកំណត់នៃវិហារ ។ ភិក្ខុទាំងឡាយក៏ប្រគល់ឲ្យតាមកំណត់នៃវិហារ វិហារក៏សល់នៅច្រើន ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រគល់តាមកំណត់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គាហេតុន្តិ ។ បរិវេណគ្គេន គាហេន្តា បរិវេណា ឧស្សាទិយឹសុ ។ អនុជានាមិ ភិក្ខវេ អនុភាគម្បិ ទាតុំ គហិតេ អនុភាគេ អញ្ញោ ភិក្ខុ អាគច្ឆតិ ន អកាមា ទាតព្វោតិ ។

(៣៩០) តេន ខោ បន សមយេន ភិក្ខូ និស្សីមេ ឋិតស្ស សេនាសនំ គាហេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ និស្សីមេ ឋិតស្ស សេនាសនំ គាហេតព្វំ ។ យោ គាហេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៣៩១) តេន ខោ បន សមយេន ភិក្ខូ សេនាសនំ គហេត្វា សព្វកាលំ បដិពាហន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ សេនាសនំ គហេត្វា សព្វកាលំ បដិពាហិតព្វំ ។ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ វស្សានំ តេមាសំ បដិពាហិតុំ ឧតុកាលំ ន បដិពាហិតុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នៃចីវរ ។ ពួកភិក្ខុក៏ប្រគល់ឲ្យតាមកំណត់នៃចីវរ ចីវរ ក៏សល់នៅច្រើន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ។ នូវចីវរតាមចំណែកជាលំដាប់ទៅចុះ កាលបើចំណែកនៃចីវរតាមលំដាប់ ពួកភិក្ខុបានទទួលយកហើយ ទើបមានភិក្ខុឯទៀតមកដល់ (តែបើភិក្ខុនោះ) មិនត្រូវការ មិនត្រូវឲ្យទេ ។

(៣៩០) សម័យនោះឯង ភិក្ខុទាំងឡាយប្រគល់សេនាសនៈដល់ភិក្ខុដែលឋិតនៅក្នុងទីក្រៅសីមា ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រគល់សេនាសនៈ ដល់ភិក្ខុដែលឋិតនៅក្នុងទីក្រៅសីមាទេ ភិក្ខុណាប្រគល់ឲ្យ ត្រូវអាបត្តិទុក្កដ ។

(៣៩១) សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកសេនាសនៈ[១] ហើយឃាត់ខាំងទុកគ្រប់កាល[២] ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលយកសេនាសនៈ ហើយឃាត់ខាំងទុកគ្រប់កាលទេ ភិក្ខុណា ឃាត់ខាំងទុក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឃាត់ខាំងបានតែត្រឹម ៣ ខែក្នុងវស្សានរដូវ (ប៉ុណ្ណោះ) មិនឲ្យឃាត់ខាំងគ្រប់រដូវទេ ។

---

១ (អដ្ឋកថា) ទទួលយកសេនាសនៈក្នុងថ្ងៃចូលវស្សា ។ ២ អស់វស្សានរដូវ ៤ ខែ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៣៩២] អថខោ ភិក្ខូនំ ឯតទហោសិ កតិ នុ ខោ សេនាសនគ្គាហាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តយោមេ ភិក្ខវេ សេនាសនគ្គាហា បុរិមកោ បច្ឆិមកោ អន្តរាមុត្តកោ អបរជ្ជុគតាយ អាសាឡ្ហិយា បុរិមកោ គាហេតព្វោ មាសគតាយ អាសាឡ្ហិយា បច្ឆិមកោ គាហេតព្វោ អបរជ្ជុគតាយ បវារណាយ អាយតឹ វស្សាវាសត្ថាយ អន្តរាមុត្តកោ គាហេតព្វោ ឥមេ ខោ ភិក្ខវេ តយោ សេនាសនគ្គាហាតិ ។

ទុតិយភាណវារំ ។

[៣៩៣] តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ សាវត្ថិយំ សេនាសនំ គហេត្វា អញ្ញតរំ គាមកាវាសំ អគមាសិ តត្របិ(១) សេនាសនំ អគ្គហេសិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អយំ ខោ អាវុសោ អាយស្មា ឧបនន្ទោ សក្យបុត្តោ

១ ឧ. ម. តត្ថបិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៣៩២) គ្រានោះឯង ភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះដូច្នេះថា ការប្រគល់សេនាសនៈមានប៉ុន្មានហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការប្រគល់សេនាសនៈនេះមាន ៣ យ៉ាង គឺ បុរិមកៈ ១ បច្ឆិមកៈ ១ អន្តរាមុត្តកៈ ១ ដែលឈ្មោះថា បុរិមកៈ ត្រូវភិក្ខុប្រគល់ឲ្យតាំងអំពីថ្ងៃ១រោចខែអាសាឍទៅ ដែលឈ្មោះថា បច្ឆិមកៈ ត្រូវភិក្ខុប្រគល់ឲ្យតាំងអំពីថ្ងៃ១រោចខែស្រាពណ៍ទៅ ដែលឈ្មោះថា អន្តរាមុត្តកៈ ត្រូវភិក្ខុប្រគល់ឲ្យតាំងអំពីថ្ងៃបវារណាក្នុងខែអស្សុជទៅ ដើម្បីនៅចាំវស្សាតទៅ ម្នាលភិក្ខុទាំងឡាយ ការប្រគល់សេនាសនៈមាន ៣ យ៉ាងដូច្នេះឯង ។

ចប់ ភាណវារៈជាគំរប់ពីរ ។

(៣៩៣) សម័យនោះឯង ឧបនន្ទភិក្ខុមានអាយុជាសក្យបុត្តទទួលយកសេនាសនៈ ទៀបក្រុងសាវត្ថី ហើយដើរទៅកាន់អាវាស ក្នុងស្រុកតូចមួយ ក៏ទទួលយកសេនាសនៈក្នុងទីនោះទៀត ។ លំដាប់នោះ ភិក្ខុទាំងនោះ (ដែលនៅក្នុងទីអាវាសនោះ) គិតគ្នាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ឧបនន្ទភិក្ខុមានអាយុ ជាសក្យបុត្តនេះ ជាអ្នកធ្វើនូវ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ សចាយំ ឥធ វស្សំ វសិស្សតិ សព្វេវ មយំ ន ផាសុ វសិស្សាម ហន្ទ នំ បុច្ឆាមាតិ ។ អថខោ តេ ភិក្ខូ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោចុំ ឥធ តយា អាវុសោ ឧបនន្ទ សាវត្ថិយំ សេនាសនំ គហិតន្តិ ។ ឯវមាវុសោតិ ។ កឹ បន ត្វំ អាវុសោ ឧបនន្ទ ឯកោ ទ្វេ បដិពាហសីតិ ។ ឥធនាហំ អាវុសោ មុញ្ចាមិ តត្ថ គណ្ហាមីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ ឯកោ ទ្វេ បដិពាហេស្សតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ឧបនន្ទ ឯកោ ទ្វេ បដិពាហសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេចក្តីប្រកួតប្រកាន់ ធ្វើនូវជំលោះ ធ្វើនូវការទាស់ទែង ធ្វើនូវតិរច្ឆាន-
កថា ធ្វើនូវអធិករណ៍ក្នុងសង្ឃ ប្រសិនបើឧបនន្ទភិក្ខុនេះនៅចាំវស្សាក្នុង
ទីនេះ យើងទាំងអស់គ្នានឹងនៅពុំបានសប្បាយឡើយ បើដូច្នោះមានតែ
យើងសួរលោកមើល ។ ភិក្ខុទាំងនោះក៏សួរឧបនន្ទភិក្ខុមានអាយុជាសក្យ-
បុត្តដូច្នេះថា ម្នាលអាវុសោឧបនន្ទ លោកបានទទួលយកសេនាសនៈទៀប
ក្រុងសាវត្ថី មែនឬ ។ ឧបនន្ទភិក្ខុឆ្លើយថា ម្នាលអាវុសោទាំងឡាយ ខ្ញុំ
បានទទួលយកមែន ។ ភិក្ខុទាំងនោះសួរថា ម្នាលអាវុសោឧបនន្ទ ចុះលោក
តែម្នាក់ឯងទេ ម្តេចក៏ហួងហែងសេនាសនៈដល់ទៅពីរកន្លែង ។ ឧបនន្ទ
ភិក្ខុឆ្លើយថា ម្នាលអាវុសោទាំងឡាយ ឥឡូវនេះ ខ្ញុំលែងយកក្នុងទីនេះ
ហើយ ខ្ញុំនឹងទៅទទួលយកក្នុងទីនោះវិញ ។ ពួកភិក្ខុណាមានសេចក្តី
ប្រាថ្នាតិច មានសេចក្តីសន្តោស ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោសតិះ
ដៀល បន្តុះបង្អាប់ថា ឧបនន្ទភិក្ខុមានអាយុជាសក្យបុត្តតែមួយរូបមិនសម
បើនឹងហួងហែងសេនាសនៈដល់ទៅពីរកន្លែងសោះ ។ ភិក្ខុទាំងឡាយក្រាប
បង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់
ថា ម្នាលឧបនន្ទ ឮថាអ្នកតែម្នាក់ឯង ហួងហែងសេនាសនៈដល់ទៅពីរ
កន្លែង មែនឬ ។ ឧបនន្ទភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ
ពិតមែន ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់មានព្រះភាគ ទ្រង់បន្ទោសថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្វំ មោឃបុរិស ឯកោ ទ្វេ បដិពាហិស្សសិ តត្ថ តយា មោឃបុរិស គហិតំ ឥធ មុញ្ចិតំ ឥធ គហិតំ តត្រ មុញ្ចិតំ(១) ឯវំ ខោ ត្វំ មោឃបុរិស ឧភយត្ថ បរិពាហិរោ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ ឯកេន ទ្វេ បដិពាហិតព្វា យោ បដិពា-ហេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៣៩៤) តេន ខោ បន សមយេន ភគវា ភិក្ខូនំ អនេកបរិយាយេន វិនយកថំ កថេតិ វិនយស្ស វណ្ណំ ភាសតិ វិនយបរិយត្តិយា វណ្ណំ ភាសតិ អាទិស្ស អា-ទិស្ស អាយស្មតោ ឧបាលិស្ស វណ្ណំ ភាសតិ(២) ។ ភិក្ខូនំ ឯតទហោសិ ភគវា ខោ ភិក្ខូនំ អនេកបរិយា-យេន វិនយកថំ កថេតិ វិនយស្ស វណ្ណំ ភាសតិ វិន-យបរិយត្តិយា វណ្ណំ ភាសតិ អាទិស្ស អាទិស្ស អាយ-ស្មតោ ឧបាលិស្ស វណ្ណំ ភាសតិ ហន្ទ មយំ អាវុសោ

---

១ ម. មុត្តំ ឥធ តយា គហិតំ តត្រ មុត្តំ ។ ២ ឱ. ម. បោត្ថកេសុ តតោ បរំ ភិក្ខូនំ ឯតទហោសីតិ វចនំ នត្ថិ ។ តត្ថ ភិក្ខូ ភគវា ខោ ភិក្ខូនំ អនេកបរិយាយេន វិនយកថំ កថេតីតិ អាទិវចនំ យេវ អាគតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នែមោឃបុរស អ្នកតែម្នាក់ឯងមិនសមបើនឹងហួងហែងសេនាសនៈដល់ទៅពីរកន្លែងទេ ម្នាលមោឃបុរស (បើ) អ្នកទទួលយកសេនាសនៈក្នុងទីនោះហើយ មានតែលែងទទួលយកក្នុងទីនេះ(បើ)អ្នកទទួលយកក្នុងទីនេះហើយ មានតែលែងទទួលយកក្នុងទីនោះ នែមោឃបុរស បើយ៉ាងហ្នឹងអ្នកចាត់ថាជាមនុស្សខាងក្រៅ គឺថាមិនត្រូវបានសេនាសនៈក្នុងទីទាំងពីរនោះទេ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុម្នាក់ឯងមិនត្រូវហួងហែងសេនាសនៈពីរកន្លែងទេ ភិក្ខុណាហួងហែងទុក ត្រូវអាបត្តិទុក្កដ ។

(៣៩៤) សម័យនោះឯង ព្រះមានព្រះភាគទ្រង់សំដែងវិនយកថា សំដែងគុណរបស់វិន័យ សំដែងគុណរបស់ការសិក្សាវិន័យ សំដែងគុណរបស់ព្រះថេរៈឈ្មោះឧបាលិដ៏មានអាយុរឿយ ៗ ដល់ភិក្ខុទាំងឡាយដោយបរិយាយជាច្រើន ។ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគទ្រង់សំដែងវិនយកថា សំដែងគុណរបស់វិន័យ សំដែងគុណរបស់ការសិក្សាវិន័យ សំដែងគុណរបស់ព្រះថេរៈឈ្មោះឧបាលិដ៏មានអាយុរឿយ ៗ ដល់ភិក្ខុទាំងឡាយដោយបរិយាយជាច្រើន ម្នាលអាវុសោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាយស្មតោ ឧបាលិស្ស សន្តិកេ វិនយំ បរិយាបុណាមាតិ ។ តេ ច[១] ពហូ ភិក្ខូ ថេរា ច នវា ច មជ្ឈិមា ច អាយស្មតោ ឧបាលិស្ស សន្តិកេ វិនយំ បរិយាបុណន្តិ ។ អាយស្មា ឧបាលិ ឋិតកោវ[២] ឧទ្ទិសតិ ថេរានំ ភិក្ខូនំ គារវេន ។ ថេរាបិ ភិក្ខូ ឋិតកាវ ឧទ្ទិសាបេន្តិ ធម្មគារវេន ។ តត្រ[៣] ថេរា ចេវ ភិក្ខូ កិលមន្តិ អាយស្មា ច ឧបាលិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ នវកេន ភិក្ខុនា ឧទ្ទិសន្តេន សមកេ វា អាសនេ និសីទិតុំ ឧច្ចតរកេ[៤] វា ធម្មគារវេន ថេរេន ភិក្ខុនា ឧទ្ទិសាបេន្តេន សមកេ វា អាសនេ និសីទិតុំ នីចតរកេ[៥] វា ធម្មគារវេនាតិ ។

(៣៩៥) តេន ខោ បន សមយេន ពហូ ភិក្ខូ អាយស្មតោ ឧបាលិស្ស សន្តិកេ ឋិតកាវ ឧទ្ទេសំ បដិមានេន្តា កិលមន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សមានាសនិកេហិ សហ និសីទិតុន្តិ ។

---

១ ឱ. តេន ។ ២ ឱ. បោត្ថកេ វសទ្ទោ ន ទិស្សតិ ។ ៣ ឱ. ម. តត្ថ ។ ៤ ឱ. ម. ឧច្ចតរេ ។ ៥ ឱ. ម. នីចតរេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហើយដូច្នេះ យើងនឹងរៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុចុះ ។ ភិក្ខុច្រើនរូបទាំងនោះ ទោះជាថេរៈក្តី ខ្ចីក្តី កណ្តាលក្តី តែងនាំគ្នាមករៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ ។ ព្រះថេរៈឈ្មោះឧបាលិដ៏មានអាយុ ក៏ចេះតែឈរសំដែង (វិន័យ) ដោយសេចក្តីគោរពចំពោះពួកភិក្ខុជាថេរៈ ។ ឯពួកភិក្ខុជាថេរៈក៏ឈរទៀតលោកសំដែង (វិន័យ) ដោយសេចក្តីគោរពក្នុងធម៌ដែរ ។ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុជាថេរៈក្តី ព្រះឧបាលិដ៏មានអាយុក្តី ក៏លំបាក (ពេកណាស់) ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុខ្ចីដែលសំដែង (វិន័យ) អង្គុយលើអាសនៈស្មើគ្នាក៏បាន ខ្ពស់ជាងក៏បាន ដោយសេចក្តីគោរពក្នុងធម៌ មិនអនុញ្ញាតឲ្យភិក្ខុជាថេរៈដែលនិមន្តភិក្ខុខ្ចីឲ្យសំដែងវិន័យ អង្គុយលើអាសនៈស្មើគ្នាក៏បាន ទាបជាងណាស់ទៅក៏បាន ដោយសេចក្តីគោរពក្នុងធម៌ ។

(៣៩៨) សម័យនោះឯង ភិក្ខុច្រើនរូបនាំគ្នាឈររៀនបាលីក្នុងសំណាក់នៃព្រះឧបាលិដ៏មានអាយុ ក៏លំបាក ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកភិក្ខុ ដែលមានអាសនៈស្មើគ្នាអង្គុយជាមួយគ្នាបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៩៦) អថខោ ភិក្ខូនំ ឯតទហោសិ កិត្តាវតា នុ ខោ សមានាសនិកោ ហោតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តិវស្សន្តរេន សហ និសីទិតុន្តិ ។

(៣៩៧) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ(១) សមានាសនិកា ឯកមញ្ចេ(២) និសីទិត្វា មញ្ចំ ភិន្ទឹសុ ។ ឯកបីឋេ(៣) និសីទិត្វា បីឋំ ភិន្ទឹសុ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តិវគ្គស្ស មញ្ចំ តិវគ្គស្ស បីឋន្តិ ។ តិវគ្គោបិ មញ្ចេ និសីទិត្វា មញ្ចំ ភិន្ទិ ។ បីឋេ និសីទិត្វា បីឋំ ភិន្ទិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ទុវគ្គស្ស មញ្ចំ ទុវគ្គស្ស បីឋន្តិ ។

---

១ ឱ. ម. ពោត្ថកេសុ ភិក្ខូតិ ន ទិស្សតិ ។ ២ ឱ. ម. មញ្ចេ ។ ៣ ឱ. ម. បីឋេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៩៦) គ្រានោះឯង ពួកភិក្ខុមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុដែលហៅថាមានអាសនៈស្មើគ្នាដោយវស្សាប៉ុន្មានហ្ន៎ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានវស្សាវ៉ាង ៣ អង្គុយជាមួយគ្នាបាន(១) ។

(៣៩៧) សម័យនោះឯង ភិក្ខុច្រើនរូបមានអាសនៈស្មើគ្នា នាំគ្នាទៅអង្គុយលើគ្រែមួយ ពាល់តែបាក់គ្រែ ។ ទៅអង្គុយលើតាំងមួយ ក៏បាក់តាំងទៅទៀត ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមួយដល់ភិក្ខុ ៣ រូប តាំងមួយដល់ភិក្ខុ ៣ រូប ។ ភិក្ខុ ៣ រូប អង្គុយលើគ្រែមួយក៏បាក់គ្រែទៅ ។ អង្គុយលើតាំងមួយក៏បាក់តាំងទៀត ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមួយដល់ភិក្ខុពីររូប តាំងមួយដល់ភិក្ខុពីររូប(២) ។

---

១ អដ្ឋកថា ថា សំដៅយកភិក្ខុដែលចាស់ជាងគ្នាពីរវស្សា ឬក្មេងជាងគ្នាពីរវស្សា ។

២ អដ្ឋកថា ថា បើគ្រែឬតាំងចំណុះភិក្ខុបីរូបទ្រង់អនុញ្ញាតឲ្យអង្គុយតែពីររូប ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៩៨) តេន ខោ បន សមយេន ភិក្ខូ អសមានាសនិកេហិ សហ ទីឃាសនេ និសីទិតុំ កុក្កុច្ចាយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឋបេត្វា បណ្ឌកំ មាតុគ្គាមំ ឧភតោព្យញ្ជនំ អសមានាសនិកេហិ សហ ទីឃាសនេ និសីទិតុន្តិ ។

(៣៩៩) អថខោ ភិក្ខូនំ ឯតទហោសិ កិត្តកំ បច្ឆិមំ(១) នុ ខោ ទីឃាសនំ ហោតីតិ ។ បេ ។ អនុជានាមិ ភិក្ខវេ យំ តិណ្ណន្នំ បហោតិ ឯត្តកំ បច្ឆិមំ(២) ទីឃាសនន្តិ ។

(៤០០) តេន ខោ បន សមយេន វិសាខា មិគារមាតា សង្ឃស្ស អត្ថាយ សាលិន្ទំ បាសាទំ ការាបេតុកាមា ហោតិ ហត្ថិនខកំ ។ អថខោ ភិក្ខូនំ ឯតទហោសិ កិន្នុ ខោ ភគវតា បាសាទបរិភោគោ អនុញ្ញាតោ កឹ អននុញ្ញាតោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សព្វំ បាសាទបរិភោគន្តិ ។

---

១ ឧ. កិត្តកបច្ឆិមំ ។ ២ ឧ. ឯត្តកបច្ឆិមំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៩៨) សម័យនោះឯង ពួកភិក្ខុមានសេចក្ដីសង្ស័យនឹងការអង្គុយលើអាសនៈវែងជាមួយនឹងភិក្ខុដែលមានអាសនៈមិនស្មើគ្នា ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យអង្គុយលើអាសនៈវែងជាមួយនឹងភិក្ខុដែលមានអាសនៈមិនស្មើគ្នាបាន វៀរលែងតែមនុស្សខ្ទើយ មាតុគ្រាម និងមនុស្សមានភេទពីរ ។

(៣៩៩) គ្រានោះ ភិក្ខុទាំងឡាយ មានសេចក្ដីត្រិះរិះដូច្នេះថា អាសនៈវែង តើមានទីបំផុតត្រឹមណា ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអាសនៈវែង ដែលមានទីបំផុតល្មមភិក្ខុ ៣ រូប (អង្គុយបាន) ។

(៤០០) សម័យនោះឯង នាងវិសាខាជាមិគារមាតា ចង់ឲ្យធ្វើប្រាសាទប្រកបដោយរបៀងឈ្មោះហត្ថិនខកៈ[១] បំរើប្រគេនព្រះសង្ឃ ។ លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគបានទ្រង់អនុញ្ញាតការប្រើប្រាស់ប្រាសាទហើយឬ ។ មិនទាន់បានទ្រង់អនុញ្ញាតទេហ្ន៎ ។ ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការប្រើប្រាស់ប្រាសាទគ្រប់យ៉ាងបាន ។

---

១ ប្រែថា ប្រាសាទតាំងនៅលើពោងដំរី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៤០១] តេន ខោ បន សមយេន រញ្ញោ បសេន-ទិស្ស កោសលស្ស អយ្យិកា កាលកតា ហោតិ ។ តស្សា កាលកិរិយាយ សង្ឃស្ស ពហុំ អកប្បិយភណ្ឌំ ឧប្បន្នំ ហោតិ សេយ្យថីទំ អាសន្ទិ បល្លង្កោ គោណកោ ចិត្តកា បដិកា បដលិកា តូលិកា វិកតិកា ឧទ្ធ-លោមី ឯកន្តលោមី កដ្ដិស្សំ កោសេយ្យំ កុត្តកំ ហត្ថត្ថរំ អស្សត្ថរំ រថត្ថរំ អជិនប្បវេណិ កាទលិមិគ-បវរប្បច្ចត្ថរណំ សឧត្តរច្ឆទំ ឧភតោលោហិតកូបធានំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៤០១] សម័យនោះ ព្រះអយ្យិការបស់ព្រះបាទបសេនទិកោសល សុគត ។ កាលដែលព្រះអយ្យិកានោះសុគតទៅ សង្ឃក៏បានអកប្បិយភណ្ឌជាច្រើន ឯអកប្បិយភណ្ឌនោះ គឺ អាសនៈដែលកន្ទង់ហួសប្រមាណ ក្រែមានជើងវិចិត្រដោយរូបសត្វសាហាវ ព្រំមានរោមវែងជាង ៤ ធ្នាប់ កម្រាលដែលធ្វើពីរោមសត្វ វិចិត្រដោយរូបសត្វសាហាវ កម្រាលមានពណ៌សដែលធ្វើពីរោមសត្វ កម្រាលដែលធ្វើពីរោមសត្វជាផ្កាចង្កោម កម្រាលដែលញាត់គ កម្រាលដែលធ្វើពីរោមសត្វវិចិត្រ ដោយរូបសីហៈនិងខ្លាធំជាដើម កម្រាលដែលធ្វើពីរោមសត្វមានរោមប្រោងតែម្ខាង កម្រាលដែលធ្វើពីរោមសត្វមានរោមប្រោងទាំងពីរខាង កម្រាលដែលធ្វើពីទិនមាស ឬខ្សែសយតាក់ស្រែះដោយរតនវត្ថុ កម្រាលដែលធ្វើពីសរសៃសូត្រតាក់ស្រែះដោយរតនវត្ថុ កម្រាលដែលធ្វើពីរោមសត្វល្មមស្រីរបាំ ១៦ នាក់ឈររាំបាន កម្រាលសម្រាប់ក្រាលលើខ្នងដំរី កម្រាលសម្រាប់ក្រាលលើខ្នងសេះ កម្រាលសម្រាប់ក្រាលលើរថ កម្រាលដែលធ្វើដោយស្បែកខ្លា កម្រាលដ៏ឧត្តមដែលធ្វើពីស្បែកឈ្លូស ខ្នើយពណ៌ក្រហមទាំងពីរខាង (គឺខ្នើយក្បាលនិងខ្នើយជើង) ព្រមទាំងពិតានដែលមានពណ៌ក្រហម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាសន្ទិយា បាទេ ឆិន្ទិត្វា បរិភុញ្ជិតុំ បល្លង្កស្ស វាឡេ ភិន្ទិត្វា បរិភុញ្ជិតុំ តូលិកំ វិជដេត្វា ពិម្ពោហនំ កាតុំ អវសេសំ ភុម្មត្ថរណំ កាតុន្តិ ។

(៤០២) តេន ខោ បន សមយេន សាវត្ថិយា អវិទូរេ អញ្ញតរស្មឹ គាមកាវាសេ អាវាសិកា ភិក្ខូ ឧបទ្ទុតា ហោន្តិ អាគន្តុកគមិកានំ ភិក្ខូនំ សេនាសនំ បញ្ញាបេន្តា ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ ឯតរហិ ខោ មយំ អាវុសោ ឧបទ្ទុតា អាគន្តុកគមិកានំ ភិក្ខូនំ សេនាសនំ បញ្ញាបេន្តា ហន្ទ មយំ អាវុសោ សព្វំ សង្ឃិកំ សេនាសនំ ឯកស្ស ទេម តស្ស សន្តកំ បរិភុញ្ជិស្សាមាតិ ។ តេ សព្វំ សង្ឃិកំ សេនាសនំ ឯកស្ស អទំសុ ។ អាគន្តុកា(១) តេ អាវាសិកេ(២) ភិក្ខូ ឯតទវោចុំ អម្ហាកំ អាវុសោ សេនាសនំ បញ្ញាបេថាតិ ។

១ ឱ. ម. អាគន្តុកា ភិក្ខូ ។ ២ ឱ. ម. ហេដ្ឋកេសុ អយំ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យកាត់ជើងអាសនៈដែលគន្ទិងហួសប្រមាណ ហើយសឹមប្រើប្រាស់ ឲ្យទំលាយរូបសត្វសាហាវនៃគ្រែមានជើងវិចិត្រដោយរូបសត្វសាហាវ ហើយសឹមប្រើប្រាស់ ឲ្យកកាយសម្រាលដែលញាត់គយកមកធ្វើជាខ្នើយ អាសនៈក្រៅអំពីនោះ យកមកធ្វើជាកម្រាលសម្រាប់ក្រាលលើផែនដីបាន ។

(៤០២) សម័យនោះឯង ពួកអាវាសិកភិក្ខុ នៅក្នុងអាវាសជិតស្រុកតូច ១ មិនឆ្ងាយពីក្រុងសាវត្ថី មានសេចក្តីលំបាកនឹងរៀបចំក្រាលសេនាសនៈបម្រុងពួកភិក្ខុមកថ្មីនឹងពួកភិក្ខុរៀបដំណើរទៅ ។ ភិក្ខុទាំងនោះក៏គិតគ្នាថា ម្នាលអាវុសោទាំងឡាយ ឥឡូវនេះពួកយើងលំបាកនឹងក្រាលសេនាសនៈបម្រុងពួកភិក្ខុមកថ្មី នឹងពួកភិក្ខុរៀបដំណើរទៅ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ យើងនឹងប្រគល់សេនាសនៈទាំងអស់ជារបស់សង្ឃទៅភិក្ខុមួយរូប ឯយើងរាល់គ្នាចាំប្រើប្រាស់ទ្រព្យរបស់ ដោយសារភិក្ខុនោះវិញ ។ ភិក្ខុទាំងនោះ ក៏បានប្រគល់សេនាសនៈទាំងអស់ជារបស់សង្ឃទៅភិក្ខុមួយរូប ។ ពួកអាគន្តុកភិក្ខុនិយាយពាក្យនេះនឹងអាវាសិកភិក្ខុនោះថា ម្នាលអាវុសោ ចូរលោករៀបចំសេនាសនៈបម្រុងយើង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នត្ថាវុសោ សង្ឃិកំ សេនាសនំ សព្វំ អម្ហេហិ ឯកស្ស ធិន្នន្តិ ។ កឹ បន តុម្ហេ អាវុសោ សង្ឃិកំ សេនាសនំ វិស្សជ្ជេថាតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ សង្ឃិកំ សេនាសនំ វិស្សជ្ជេស្សន្តីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ សង្ឃិកំ សេនាសនំ វិស្សជ្ជេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា សង្ឃិកំ សេនាសនំ វិស្សជ្ជេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ បញ្ចិមានិ ភិក្ខវេ អវិស្សជ្ជិយានិ ន វិស្សជ្ជេតព្វានិ សង្ឃេន វា គណេន វា បុគ្គលេន វា វិស្សជ្ជិតានិបិ អវិស្សជ្ជិតានិ ហោន្តិ យោ វិស្សជ្ជេយ្យ អាបត្តិ ថុល្លច្ចយស្ស ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សេនាសនក្ខន្ធកៈ របស់ដែលភិក្ខុលះមិនដាច់មាន ៥ យ៉ាង

អាវាសិកភិក្ខុឆ្លើយថា ម្នាលអាវុសោ សេនាសនៈរបស់សង្ឃមិនមានទេ (ព្រោះ) យើងបានប្រគល់ឲ្យភិក្ខុមួយរូបអស់ទៅហើយ ។ អាគន្តុកភិក្ខុសួរថា ម្នាលអាវុសោ ពួកលោកហ៊ានលះសេនាសនៈរបស់សង្ឃឬ ។ អាវាសិកភិក្ខុឆ្លើយថា យ៉ាងហ្នឹងហើយ អាវុសោ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ពួកភិក្ខុមិនសមបើហ៊ានលះសេនាសនៈ ជារបស់សង្ឃសោះ ។ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយបានឮថា ពួកភិក្ខុលះសេនាសនៈរបស់សង្ឃ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធមានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងលះសេនាសនៈរបស់សង្ឃសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ របស់ដែលមិនគួរលះបេញ ៥ យ៉ាងនេះ ពោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះបេញ សូម្បីលះបេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះបេញ ត្រូវអាបត្តិថុល្លច្ច័យ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាតព្វានិ បញ្ច ។ អារាមោ អារាមវត្ថុ ឥទំ បឋមំ អ-
វិស្សជ្ជិយំ ន វិស្សជ្ជេតព្វំ សង្ឃេន វា គណេន វា បុគ្គលេន
វា វិស្សជ្ជិតម្បិ អវិស្សជ្ជិតំ ហោតិ យោ វិស្សជ្ជេយ្យ អាបត្តិ
ថុល្លច្ចយស្ស វិហារោ វិហារវត្ថុ ឥទំ ទុតិយំ អវិស្សជ្ជិយំ
ន វិស្សជ្ជេតព្វំ សង្ឃេន វា គណេន វា បុគ្គលេន វា
វិស្សជ្ជិតម្បិ អវិស្សជ្ជិតំ ហោតិ យោ វិស្សជ្ជេយ្យ អាបត្តិ
ថុល្លច្ចយស្ស មញ្ចោ បីឋំ ភិសិ ពិម្ពោហនំ ឥទំ តតិយំ
អវិស្សជ្ជិយំ ន វិស្សជ្ជេតព្វំ សង្ឃេន វា គណេន វា
បុគ្គលេន វា វិសជ្ជិតម្បិ អវិស្សជ្ជិតំ ហោតិ យោ
វិស្សជ្ជេយ្យ អាបត្តិ ថុល្លច្ចយស្ស លោហកុម្ភី លោហ-
ភាណកំ លោហវារកោ លោហកដាហំ វាសិ ផរសុ
កុឋារី កុទ្ទាលោ និខាទនំ ឥទំ ចតុត្ថំ អវិស្សជ្ជិយំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



របស់ទី ៤ នោះដូចម្ដេច ។ គឺ អារាម គឺ សួនច្បារ(១) ១ អារាមវត្ថុ គឺ ទីដីជាសួនច្បារ ១ នេះជារបស់មិនគួរលះបង់ជាដំបូង នោះសង្ឃក្ដី គណៈក្ដី បុគ្គលក្ដី ក៏មិនត្រូវលះបង់ សូម្បីលះបង់ហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះបង់ ត្រូវអាបត្តិថុល្លច្ច័យ វិហារ គឺ លំនៅ ១ វិហារវត្ថុ គឺ ទីដីសម្រាប់សង់លំនៅ ១ នេះជារបស់មិនគួរលះបង់ជាគំរប់ពីរ នោះសង្ឃក្ដី គណៈក្ដី បុគ្គលក្ដី ក៏មិនត្រូវលះបង់ សូម្បីលះហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះបង់ ត្រូវអាបត្តិថុល្លច្ច័យ មញ្ចៈ គឺគ្រែ ១ បីឋៈ គឺ តាំងឬកៅអី ១ ភិសិ គឺ ពូក ១ ពិម្ពោហនៈ គឺ ខ្នើយ ១ នេះជារបស់មិនគួរលះបង់ជាគំរប់បី នោះសង្ឃក្ដី គណៈក្ដី បុគ្គលក្ដី ក៏មិនត្រូវលះបង់ សូម្បីលះបង់ហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះបង់ ត្រូវអាបត្តិថុល្លច្ច័យ លោហកុម្ភី គឺ ឆ្នាំងដែលធ្វើពីលោហជាតិ ១ លោហភាណកៈ គឺ ខ្ទះលោហៈ ១ លោហវារកៈ គឺក្អមលោហៈ ១ លោហកដាហៈ គឺផើងលោហៈ ១ វាសី គឺ កាំបិត ១ ផរសុ គឺ ពូថៅ ១ កុឋារី គឺ ដឹងពាង ១ កុទ្ទាលៈ គឺ ចប ១ និខាទនៈ គឺ ពន្លាក ១ នេះជារបស់មិនគួរលះបង់ជាគំរប់ ៤ នោះសង្ឃ

---

១ អដ្ឋកថា ថា សួនផ្កា សួនផ្លែ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ន វិស្សជ្ជេតព្វំ សង្ឃេន វា គណេន វា បុគ្គលេន វា វិស្សជ្ជិតម្បិ អវិស្សជ្ជិតំ ហោតិ យោ វិស្សជ្ជេយ្យ អាបត្តិ ថុល្លច្ចយស្ស វល្លិ វេឡុ មុញ្ជំ បព្វជំ[១] តិណំ មត្តិកា ទារុភណ្ឌំ មត្តិកាភណ្ឌំ ឥមំ បញ្ចមំ អវិស្សជ្ជិយំ ន វិស្ស-ជ្ជេតព្វំ សង្ឃេន វា គណេន វា បុគ្គលេន វា វិស្សជ្ជិតម្បិ អវិស្សជ្ជិតំ ហោតិ យោ វិស្សជ្ជេយ្យ អាបត្តិ ថុល្លច្ចយស្ស ឥមានិ ខោ ភិក្ខវេ បញ្ច អវិស្សជ្ជិយានិ ន វិស្សជ្ជេតព្វានិ សង្ឃេន វា គណេន វា បុគ្គលេន វា វិស្សជ្ជិតានិបិ អវិស្សជ្ជិតានិ ហោន្តិ យោ វិស្សជ្ជេយ្យ អាបត្តិ ថុល្ល-ច្ចយស្សាតិ ។

(៤០៣) អថខោ ភគវា សាវត្ថិយំ យថាភិរន្តំ វិហរិត្វា យេន កិដាគិរិ តេន ចារិកំ បក្កាមិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សារីបុត្ត-មោគ្គល្លានេហិ ច ។ អស្សោសុំ ខោ អស្សជិបុនព្វសុកា ភិក្ខូ ភគវា កិរ កិដាគិរឹ អាគច្ឆតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សារីបុត្តមោគ្គល្លានេហិ

---

១ ឧ. មុញ្ជបព្វជំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិន ឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ វល្លិ៍ គឺ វល្លិ៍ ១ វេឡុ គឺ ឫស្សី ១ មុញ្ជៈ គឺ ស្មៅជំណោកខន្សាយ ១ បព្វជៈ គឺស្មៅ យាប្លង ១ តិណៈ គឺ ស្មៅធម្មតា ១ មត្តិកា គឺ ដីស្អិត ១ ទារុភណ្ឌៈ គឺ គ្រឿងឈើ ១ មត្តិកាភណ្ឌៈ គឺ គ្រឿងធ្វើពីដី ១ នេះជាវត្ថុមិនគួរលះ ចេញ ជាគំរប់ ៥ ព្រោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិ ថុល្លច្ច័យ ម្នាលភិក្ខុទាំងឡាយ របស់ទាំង ៥ ពួកនេះឯង ជារបស់មិន គួរលះចេញ ព្រោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះ ចេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ ។

(៤០៣) គ្រានោះឯង ព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុង សាវត្ថី សំរាន្តព្រះឥរិយាបថ ហើយយាងទៅកាន់ចារិកក្នុងកិដាគិរីជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនប្រមាណ ៥០០រូប ព្រមទាំងព្រះសារីបុត្តនិងព្រះ មោគ្គល្លានផង ។ ពួកអស្សជិនិងបុនព្វសុកភិក្ខុបានឮដំណឹងថា ព្រះមានព្រះ ភាគយាងមកដល់កិដាគិរីជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនប្រមាណ ៥០០ រូប ព្រមទាំងព្រះសារីបុត្តនិងព្រះមោគ្គល្លានផង ក៏និយាយថា ម្នាលអាវុសោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ច ហន្ទ មយំ អាវុសោ សព្វំ សង្ឃិកំ សេនាសនំ ភាជេម បាបិច្ឆា សារីបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសំ គតា ន មយំ តេសំ សេនាសនំ បញ្ញាបេស្សាមាតិ ។ តេ សព្វំ សង្ឃិកំ សេនាសនំ ភាជេសុំ ។ អថខោ ភគវា អនុបុព្វេន ចារិកញ្ចរមានោ យេន កិដាគិរិ តទវសរិ ។ អថខោ ភគវា សម្ពហុលេ ភិក្ខូ អាមន្តេសិ គច្ឆថ តុម្ហេ ភិក្ខវេ អស្សជិបុនព្វសុកេ ភិក្ខូ ឧបសង្កមិត្វា ឯវំ វទេថ ភគវា អាវុសោ អាគច្ឆតិ មហតា ភិក្ខុសង្ឃេន សទ្ធិំ បញ្ចមត្តេហិ ភិក្ខុសតេហិ សារីបុត្តមោគ្គល្លានេហិ ច ភគវតោ ច អាវុសោ សេនាសនំ បញ្ញាបេថ ភិក្ខុសង្ឃស្ស ច សារីបុត្តមោគ្គល្លានានញ្ចាតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា យេន អស្សជិបុនព្វសុកា ភិក្ខូ តេនុបសង្កមិំសុ ឧបសង្កមិត្វា អស្សជិបុនព្វសុកេ ភិក្ខូ ឯតទវោចុំ ភគវា អាវុសោ អាគច្ឆតិ

បើដូច្នោះ មានតែយើងនាំគ្នាចែកសេនាសនៈជារបស់សង្ឃទាំងអស់ (ដ្បិត) សារីបុត្តនិងមោគ្គល្លានជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចសេចក្តីប្រាថ្នាលាមក យើងពលគ្នាកុំរៀបចំក្រាលសេនាសនៈប្រគេនលោកឡើយ ៗ ភិក្ខុទាំងនោះក៏នាំគ្នាចែកសេនាសនៈដែលជារបស់សង្ឃទាំងអស់ ។ គ្រានោះ ព្រះមានព្រះភាគកំពុងស្តេចមកកាន់ចារិកតាមលំដាប់ ទ្រង់តម្រង់ទៅកាន់កិដាគិរិជនបទនោះ ៗ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុច្រើនរូបមកថា ម្នាលភិក្ខុទាំងឡាយ អ្នកពលគ្នាចូរដើរទៅរកពួកអស្សជិនិងបុនព្វសុកភិក្ខុ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគ កំពុងតែស្តេចមកជាមួយនឹងភិក្ខុសង្ឃច្រើន ប្រមាណ ៥០០ រូប ព្រមទាំងព្រះសារីបុត្តនិងព្រះមោគ្គល្លានផង ម្នាលអាវុសោ លោកពលគ្នា ចូររៀបចំក្រាលសេនាសនៈទុកបម្រុងព្រះមានព្រះភាគផង បម្រុងព្រះភិក្ខុសង្ឃផង បម្រុងព្រះសារីបុត្តនិងព្រះមោគ្គល្លានផង ៗ ភិក្ខុទាំងនោះទទួលស្តាប់ (ព្រះពុទ្ធដីកា) នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏នាំគ្នាចូលទៅរកពួកអស្សជិនិងបុនព្វសុកភិក្ខុ លុះចូលទៅដល់ហើយទើបថ្លែងបណ្តាំនេះ ប្រាប់ពួកអស្សជិនិងបុនព្វសុកភិក្ខុថា ម្នាលអាវុសោ ដ្បិតព្រមានព្រះភាគស្តេចមក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សារីបុត្តមោគ្គល្លានេហិ ច ភគវតោ ច អាវុសោ សេនាសនំ បញ្ញាបេថ ភិក្ខុសង្ឃស្ស ច សារីបុត្តមោគ្គល្លានានញ្ចាតិ ។ ឯត្ថាវុសោ សង្ឃិកំ សេនាសនំ សព្វំ អម្ហេហិ ភាជិតំ ស្វាគតំ អាវុសោ ភគវតោ យស្មិំ វិហារេ ភគវា ឥច្ឆិស្សតិ តស្មិំ វិហារេ វសិស្សតិ បាបិច្ឆា សារីបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសំ គតា ន មយំ តេសំ សេនាសនំ បញ្ញាបេស្សាមាតិ ។ កិម្បន តុម្ហេ អាវុសោ សង្ឃិកំ សេនាសនំ ភាជិត្ថាតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អស្សជិបុនព្វសុកា ភិក្ខូ សង្ឃិកំ សេនាសនំ ភាជេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ សច្ចំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ជាមួយនឹងភិក្ខុសង្ឃច្រើន ប្រមាណ ៥០០ រូប ព្រមទាំងព្រះសារីបុត្តនឹងព្រះមោគ្គល្លានផង ម្នាលអាវុសោ លោកទាំងឡាយ ចូរនាំគ្នារៀបចំក្រាលសេនាសនៈទុកបម្រុងព្រះមានព្រះភាគផង បម្រុងព្រះភិក្ខុសង្ឃផង បម្រុងព្រះសារីបុត្តនឹងព្រះមោគ្គល្លានផង ។ ពួកអស្សជិនឹងបុនព្វសុកភិក្ខុឆ្លើយថា ម្នាលអាវុសោ សេនាសនៈដែលជារបស់សង្ឃមិនមានទេ (ព្រោះ) សេនាសនៈទាំងអស់យើងចែកគ្នាអស់ហើយ ម្នាលអាវុសោ ព្រះមានព្រះភាគស្តេចមកល្អហើយ ព្រះអង្គសព្វព្រហឫទ័យគង់ក្នុងវិហារណា ក៏នឹងគង់ក្នុងវិហារនោះទៅ ឯសារីបុត្តនឹងមោគ្គល្លាន ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះអំណាចនៃសេចក្តីប្រាថ្នាលាមក យើងកល់គ្នាមិនបានរៀបចំក្រាលសេនាសនៈឲ្យលោកទាំងនោះទេ ។ ភិក្ខុទាំងនោះសួរថា ម្នាលអាវុសោ លោកទាំងឡាយនាំគ្នាចែកសេនាសនៈរបស់សង្ឃ មែនឬ ។ ពួកអស្សជិនឹងបុនព្វសុកភិក្ខុឆ្លើយថា ម្នាលអាវុសោ យើងចែកមែន ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកអស្សជិនឹងបុនព្វសុកភិក្ខុមិនសមបើមកនាំគ្នាចែកសេនាសនៈរបស់សង្ឃសោះ ។ លំដាប់នោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កឹ ភិក្ខវេ អស្សជិបុនព្វសុកា ភិក្ខូ សង្ឃិកំ សេនា-សនំ ភាជេន្តិ ។ សច្ចំ ភគវាតិ ។ កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា សង្ឃិកំ សេនាសនំ ភាជេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ បញ្ចិមានិ ភិក្ខវេ អវេភង្គិយានិ ន វិភជិតព្វានិ សង្ឃេន វា គណេន វា បុគ្គលេន វា វិភត្តានិបិ អវិភត្តានិ ហោន្តិ យោ វិភជេយ្យ អាបត្តិ ថុល្លច្ចយស្ស ។ កតមានិ បញ្ច ។ អារាមោ អារាមវត្ថុ ឥទំ បឋមំ អវេភង្គិយំ ន វិភជិតព្វំ សង្ឃេន វា គណេន វា បុគ្គលេន វា វិភត្តម្បិ អវិភត្តំ ហោតិ យោ វិភជេយ្យ អាបត្តិ ថុល្លច្ចយស្ស វិហារោ វិហា-រវត្ថុ ឥទំ ទុតិយំ អវេភង្គិយំ ន វិភជិតព្វំ សង្ឃេន វា គណេន វា បុគ្គលេន វា វិភត្តម្បិ អវិភត្តំ ហោតិ យោ វិភជេយ្យ អាបត្តិ ថុល្លច្ចយស្ស មញ្ចោ បីឋំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអស្សជិនិងបុនព្វសុកភិក្ខុនាំគ្នាបែកសេនាសនៈរបស់សង្ឃ មែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនគួរនឹងហ៊ាននាំគ្នាបែកសេនាសនៈរបស់សង្ឃទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ របស់ដែលមិនគួរបែក ៥ ពួកនេះ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវបែក សូម្បីបែកហើយ ក៏មិនឈ្មោះថាបែក ភិក្ខុណាបែក ត្រូវអាបត្តិថុល្លច្ច័យ ។ របស់ ៥ ពួកដូចម្តេច ។ (របស់ ៥ ពួកនោះ គឺ) អារាម គឺសួនច្បារ ១ អារាមវត្ថុ គឺទីដីជាសួនច្បារ ១ នេះជារបស់មិនគួរបែក ជាដំបូង ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវបែក សូម្បីបែកហើយក៏មិនឈ្មោះថាបែក ភិក្ខុណាបែក ត្រូវអាបត្តិថុល្លច្ច័យ វិហារ គឺលំនៅ ១ វិហារវត្ថុ គឺទីដីសម្រាប់សង់លំនៅ ១ នេះជារបស់មិនគួរបែក ជាគំរប់ពីរ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវបែក សូម្បីបែកហើយក៏មិនឈ្មោះថាបែក ភិក្ខុណាបែក ត្រូវអាបត្តិថុល្លច្ច័យ មញ្ចៈគឺគ្រែ ១ បីឋៈ គឺតាំងឬកៅអី ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិសី ពិព្ពោហនំ ឥទំ តតិយំ អវេភង្គិយំ ន វិភជិតព្វំ សង្ឃេន វា គណេន វា បុគ្គលេន វា វិភត្តម្បិ អវិភត្តំ ហោតិ យោ វិភជេយ្យ អាបត្តិ ថុល្លច្ចយស្ស លោហកុម្ភី លោហភាណកំ លោហវារកោ លោហកដាហំ វាសី ផរសុ កុឋារី(១) កុទ្ទាលោ និខាទនំ ឥទំ ចតុត្ថំ អវេភង្គិយំ ន វិភជិតព្វំ សង្ឃេន វា គណេន វា បុគ្គលេន វា វិភត្តម្បិ អវិភត្តំ ហោតិ យោ វិភជេយ្យ អាបត្តិ ថុល្លច្ចយស្ស វល្លិ វេឡុ មុញ្ជំ បព្វជំ តិណំ មត្តិកា ទារុភណ្ឌំ មត្តិកាភណ្ឌំ ឥទំ បញ្ចមំ អវេភង្គិយំ ន វិភជិតព្វំ សង្ឃេន វា គណេន វា បុគ្គលេន វា វិភត្តម្បិ អវិភត្តំ ហោតិ យោ វិភជេយ្យ អាបត្តិ ថុល្លច្ចយស្ស ឥមានិ ខោ ភិក្ខវេ បញ្ច អវេភង្គិយានិ ន វិភជិតព្វានិ សង្ឃេន វា គណេន វា បុគ្គលេន វា វិភត្តានិបិ អវិភត្តានិ ហោន្តិ យោ វិភជេយ្យ អាបត្តិ ថុល្លច្ចយស្សាតិ ។

(៤០៤) អថខោ ភគវា កីដាគិរិស្មឹ យថាភិរន្តំ វិហរិត្វា យេន អាឡវី តេន ចារិកំ បក្កាមិ

១ សព្វត្ថ កុដារី ឥតិ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកៈ របស់ដែលមិនត្រូវចែកមាន ៥ យ៉ាង

ភិសី គឺពូក ១ ពិម្ពោហនៈ គឺខ្នើយ ១ នេះជាវត្ថុមិនគួរចែក ជាគំរប់បី ព្រោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះជាចែក ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ លោហកុម្ភី គឺឆ្នាំងដែលធ្វើពីលោហជាតិ ១ លោហភាណកៈគឺខ្នះលោហៈ ១ លោហវារកៈគឺក្អមលោហៈ ១ លោហកដាហៈ គឺផើងលោហៈ ១ វាសី គឺកាំបិត ១ ផរសុ គឺពូថៅ ១ កុឋារី គឺដឹងបាំង ១ កុទ្ទាលៈ គឺចប ១ និខាទនៈ គឺពន្លាក ១ នេះជាវត្ថុមិនគួរចែក ជាគំរប់ ៤ ព្រោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះជាចែក ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ វល្លិ គឺវល្លិ ១ វេឡុ គឺឫស្សី ១ មុញ្ជៈ គឺស្មៅដំណេកទន្សាយ ១ បព្វជៈ គឺស្មៅយ៉ាប្លង ១ តិណៈ គឺស្មៅធម្មតា ១ មត្តិកា គឺដីស្អិត ១ ទារុភណ្ឌៈ គឺគ្រឿងឈើ ១ មត្តិកាភណ្ឌៈ គឺគ្រឿងធ្វើពីដី ១ នេះជាវត្ថុមិនគួរចែក ជាគំរប់ ៥ ព្រោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះជាចែក ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ ម្នាលភិក្ខុទាំងឡាយ របស់ទាំង ៥ ពួកនេះឯង ជាវត្ថុមិនគួរចែក ព្រោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយក៏មិនឈ្មោះជាចែកឡើយ ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ ។

(៤០៤) គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកិដាគិរិ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយយាងទៅកាន់ចារិកក្នុងដែនអាឡវី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អនុបុព្វេន ចារិកញ្ចរមានោ យេន អាឡវី តទវសរិ ។ តត្រ សុទំ ភគវា អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ ។

(២០៩) តេន ខោ បន សមយេន អាឡវកា ភិក្ខូ ឯវរូបានិ នវកម្មានិ ទេន្តិ បិណ្ឌនិក្ខេបនមត្តេនបិ នវកម្មំ ទេន្តិ កុដ្ឋលេបនមត្តេនបិ នវកម្មំ ទេន្តិ ទ្វារដ្ឋបនមត្តេនបិ នវកម្មំ ទេន្តិ អគ្គឡវដ្ដិករណមត្តេនបិ នវកម្មំ ទេន្តិ អាលោកសន្ធិករណមត្តេនបិ នវកម្មំ ទេន្តិ សេតវណ្ណករណមត្តេនបិ នវកម្មំ ទេន្តិ កាឡវណ្ណករណមត្តេនបិ នវកម្មំ ទេន្តិ គេរុកបរិកម្មករណមត្តេនបិ នវកម្មំ ទេន្តិ ឆាទនមត្តេនបិ នវកម្មំ ទេន្តិ ពន្ធនមត្តេនបិ នវកម្មំ ទេន្តិ ភណ្ឌិកាឋានមត្តេនបិ(១) នវកម្មំ ទេន្តិ ខណ្ឌផុល្លប្បដិសង្ខរណមត្តេនបិ នវកម្មំ ទេន្តិ បរិភណ្ឌករណមត្តេនបិ នវកម្មំ ទេន្តិ វីសតិវស្សិកម្បិ នវកម្មំ ទេន្តិ តឹសវស្សិកម្បិ នវកម្មំ ទេន្តិ យាវជីវិកម្បិ នវកម្មំ ទេន្តិ ធូមកាលិកម្បិ បរិយោសិតំ វិហារំ នវកម្មំ ទេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

១ ឱ. គណ្ឌិកាឋានមត្តេនាតិ ។ ម. ភណ្ឌិកាឋបនមត្តេនបិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទ្រង់ត្រាច់ទៅកាន់ចារិកតាមលំដាប់ សំដៅទៅកាន់ដែនអាឡវីនោះ ។ ឮដំណឹងថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងអគ្គាឡវចេតិយ ទៀបដែនអាឡវីនោះ ។

[៤០៥] សម័យនោះឯង ពួកភិក្ខុនៅក្នុងដែនអាឡវី ឲ្យនវកម្មមានសភាពយ៉ាងនេះ គឺឲ្យនវកម្មដោយគ្រាន់តែទុកដាក់ដុំដីឬដុំបាយអខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបជញ្ជាំងខ្លះ ឲ្យនវកម្មដោយគ្រាន់តែដំកល់ទ្វារខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើសសរមេទ្វារខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើបង្អួចខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបពណ៌សខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបពណ៌ខៀវខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើបរិកម្មដោយជ័ររង្គខ្លះ(១) ឲ្យនវកម្មដោយគ្រាន់តែប្រក់ព្រំខ្លះ ឲ្យនវកម្មដោយគ្រាន់តែចងខ្លះ ឲ្យនវកម្មដោយគ្រាន់តែបិទបាំងទីអាស្រ័យនៅនៃសត្វព្រាបខ្លះ ឲ្យនវកម្មដោយគ្រាន់តែផ្សផុល ត្រង់កន្លែងដែលដាច់ទឹងធ្លុះខ្លះ ឲ្យនវកម្មដោយគ្រាន់តែប្រោះព្រំខ្លះ ឲ្យនវកម្មអស់ ២០ ឆ្នាំខ្លះ ឲ្យនវកម្មអស់ ៣០ ឆ្នាំខ្លះ ឲ្យនវកម្មអស់ ១ ជីវិតខ្លះ ឲ្យនវកម្មចំពោះវិហារដែលធ្វើស្រេចហើយ ដែលខ្លួនបានអបលោកឲ្យក្នុងកាលមានផ្សែងខ្លះ ។ ភិក្ខុទាំងឡាយ ណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា

១ មិនចំពោះតែជ័ររង្គប៉ុណ្ណោះទេ សូម្បីជ័រឈើដទៃដូចយ៉ាងជ័របុងជ័រទឹក ក៏រាប់បញ្ចូលក្នុងជ័រសម្រាប់ផ្លិតដែរ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





កថំ ហិ ណាម អាឡវិកា ភិក្ខូ ឯវរូបានិ នវកម្មានិ ទស្សន្តិ បិណ្ឌនិក្ខេបនមត្តេនបិ នវកម្មំ ទស្សន្តិ កុឌ្ឌលេបនមត្តេនបិ នវកម្មំ ទស្សន្តិ ទ្វារដ្ឋបនមត្តេនបិ នវកម្មំ ទស្សន្តិ អគ្គឡវដ្ដិករណមត្តេនបិ នវកម្មំ ទស្សន្តិ អាលោកសន្ធិករណមត្តេនបិ នវកម្មំ ទស្សន្តិ សេតវណ្ណករណមត្តេនបិ នវកម្មំ ទស្សន្តិ កាឡវណ្ណ-ករណមត្តេនបិ នវកម្មំ ទស្សន្តិ គេរុកបរិកម្មករណ-មត្តេនបិ នវកម្មំ ទស្សន្តិ ឆាទនមត្តេនបិ នវកម្មំ ទស្សន្តិ ពន្ធនមត្តេនបិ នវកម្មំ ទស្សន្តិ ភណ្ឌិកាឋា-នមត្តេនបិ នវកម្មំ ទស្សន្តិ ខណ្ឌផុល្លប្បដិសង្ខរណ-មត្តេនបិ នវកម្មំ ទស្សន្តិ បរិភណ្ឌករណមត្តេនបិ នវ-កម្មំ ទស្សន្តិ វីសតិវស្សិកម្បិ នវកម្មំ ទស្សន្តិ តឹស-វស្សិកម្បិ នវកម្មំ ទស្សន្តិ យាវជីវិកម្បិ នវកម្មំ ទស្សន្តិ ធូមកាលិកម្បិ បរិយោសិតំ វិហារំ នវកម្មំ ទស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ពួកភិក្ខុនៅក្នុងដែនអាឡវីមិនសមនឹងឲ្យនវកម្មមានសភាពយ៉ាងនេះទេ គឺឲ្យនវកម្មដោយគ្រាន់តែទុកដាក់ដុំដីឬដុំបាយអខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបជញ្ជាំងខ្លះ ឲ្យនវកម្មដោយគ្រាន់តែដាក់កលទ្វារខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើសសរមេទ្វារខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើបង្អួចខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបឲ្យមានពណ៌សខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបឲ្យមានពណ៌ខ្មៅខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើបរិកម្មដោយដីរេគ្គខ្លះ ឲ្យនវកម្មដោយគ្រាន់តែប្រក់ព្រំខ្លះ ឲ្យនវកម្មដោយគ្រាន់តែបង់ខ្លះ ឲ្យនវកម្មដោយគ្រាន់តែបិទបាំងទីអាស្រ័យនៅ នៃសត្វព្រាបខ្លះ ឲ្យនវកម្មដោយគ្រាន់តែជួសជុលត្រង់កន្លែងដែលដាច់ធ្លុះខ្លះ ឲ្យនវកម្មដោយគ្រាន់តែព្រោះព្រំខ្លះ ឲ្យនវកម្មអស់ ២០ ឆ្នាំខ្លះ ឲ្យនវកម្មអស់ ៣០ ឆ្នាំខ្លះ ឲ្យនវកម្មអស់ ១ ជីវិតខ្លះ ឲ្យនវកម្មចំពោះវិហារដែលធ្វើស្រេចហើយ ដែលខ្លួនបានអបលោកឲ្យក្នុងកាលមានផ្សែងខ្លះ ។ ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការនោះពិតមែនឬ ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគពិតមែន ។ បេ ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាមន្តេសិ ន ភិក្ខវេ បិណ្ឌិក្ខោបនមត្តេន នវកម្មំ ទាតព្វំ ន កុឌ្ឌលេបនមត្តេន នវកម្មំ ទាតព្វំ ន ទ្វារដ្ឋបនមត្តេន នវកម្មំ ទាតព្វំ ន អគ្គឡវដ្ដិករណមត្តេន នវកម្មំ ទាតព្វំ ន អាលោកសន្ធិករណមត្តេន នវកម្មំ ទាតព្វំ ន សេតវណ្ណករណមត្តេន នវកម្មំ ទាតព្វំ ន កាឡវណ្ណករណមត្តេន នវកម្មំ ទាតព្វំ ន គេរុកបរិកម្មករណមត្តេន នវកម្មំ ទាតព្វំ ន ឆាទនមត្តេន នវកម្មំ ទាតព្វំ ន ពន្ធនមត្តេន នវកម្មំ ទាតព្វំ ន ភណ្ឌិកាឋបនមត្តេន នវកម្មំ ទាតព្វំ ន ខណ្ឌផុល្លប្បដិសង្ខរណមត្តេន នវកម្មំ ទាតព្វំ ន បរិភណ្ឌករណមត្តេន នវកម្មំ ទាតព្វំ ន វីសតិវស្សិកំ នវកម្មំ ទាតព្វំ ន តឹសវស្សិកំ នវកម្មំ ទាតព្វំ ន យាវជីវិកំ នវកម្មំ ទាតព្វំ ន ធូមកាលិកំ បរិយោសិតំ វិហារំ នវកម្មំ ទាតព្វំ យោ ទទេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ អកតំ វា វិហារំ វិប្បកតំ វា នវកម្មំ ទាតុំ ខុទ្ទកេ វិហារេ កម្មំ ឱលោកេត្វា ឆប្បញ្ចវស្សិកំ នវកម្មំ ទាតុំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យនវកម្មដោយគ្រាន់តែទុកដាក់ដុំដីឬដុំបាយអ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែលាបជញ្ជាំង មិនត្រូវឲ្យនវកម្មដោយគ្រាន់តែដំកលទ្វារ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែធ្វើសសរមេទ្វារ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែធ្វើបង្អួច មិនត្រូវឲ្យនវកម្មដោយគ្រាន់តែលាបឲ្យមានពណ៌ស មិនត្រូវឲ្យនវកម្មដោយគ្រាន់តែលាបឲ្យមានពណ៌ខ្មៅ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែធ្វើបរិកម្មដោយដីរេង្គ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែប្រក់ព្រំ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែបង់ទុក មិនត្រូវឲ្យនវកម្មដោយគ្រាន់តែបិទបាំងទីអាស្រ័យនៅ នៃសត្វព្រាប មិនត្រូវឲ្យនវកម្មដោយគ្រាន់តែជួសជុលគ្រង់កន្ទែង ដែលដាច់ទឹងផុះ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែប្រោះព្រំ មិនត្រូវឲ្យនវកម្មអស់ ២០ ឆ្នាំ មិនត្រូវឲ្យនវកម្មអស់ ៣០ ឆ្នាំ មិនត្រូវឲ្យនវកម្មអស់ ១ ជីវិត មិនត្រូវឲ្យនវ-កម្មចំពោះវិហារដែលធ្វើស្រេចហើយ ដែលខ្ទួនអបរលោកឲ្យក្នុងកាលមានផ្សែង ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យនវកម្មចំពោះតែវិហារ ដែលមិនទាន់ធ្វើ ឬធ្វើមិនទាន់ហើយ (បើ) វិហារតូចឲ្យត្រួតមើលការងារហើយ សឹមឲ្យនវកម្មអស់ត្រឹម ៦ ឆ្នាំ ឬ ៥ ឆ្នាំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អឌ្ឍយោគេ កម្មំ ឱលោកេត្វា សត្តដ្ឋវស្សិកំ នវកម្មំ ទាតុំ មហល្លកេ វិហារេ បាសាទេ វា កម្មំ ឱលោកេត្វា ទសទ្វាទសវស្សិកំ នវកម្មំ ទាតុន្តិ ។

(៤០៦) តេន ខោ បន សមយេន ភិក្ខូ សព្វំ វិហារំ នវកម្មំ ទេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សព្វេ វិហារេ នវកម្មំ ទាតព្វំ[១] យោ ទទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៤០៧) តេន ខោ បន សមយេន ភិក្ខូ ឯកស្ស ទ្វេ នវកម្មេ[២] ទេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឯកស្ស ទ្វេ ទាតព្វា យោ ទទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៤០៨) តេន ខោ បន សមយេន ភិក្ខូ នវកម្មំ គហេត្វា អញ្ញំ វាសេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ នវកម្មំ គហេត្វា អញ្ញោ វាសេតព្វោ យោ វាសេយ្យ អាបត្តិ ទុក្កដស្សាតិ ។

---

១ ឱ. ម. ន ភិក្ខវេ សព្វោ វិហារោ នវកម្មំ ទាតព្វោ ។ ២ ឱ ម. ពោត្ថកេសុ អយំ សទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឲ្យរួច (ហើ) អឌ្ឍយោគ ឲ្យគ្រួតមើលការងារ ហើយសឹមឲ្យនវកម្មអស់ត្រឹម ៧ ឆ្នាំ ឬ ៨ ឆ្នាំឲ្យរួច (ហើ) វិហារធំឬប្រាសាទ ឲ្យគ្រួតមើលការងារ ហើយ សឹមឲ្យនវកម្មអស់ត្រឹម ១០ ឆ្នាំ ឬ ១២ ឆ្នាំឲ្យរួច ។

(៤០៦) សម័យនោះឯង ភិក្ខុទាំងឡាយឲ្យនវកម្មចំពោះវិហារទាំងអស់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យនវកម្មចំពោះវិហារទាំងអស់ទេ ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ ។

(៤០៧) សម័យនោះឯង ភិក្ខុទាំងឡាយឲ្យនវកម្មពីរកន្លែងដល់ភិក្ខុ ១ រូប ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យនវកម្មពីរកន្លែងដល់ភិក្ខុ ១ រូបទេ ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ ។

(៤០៨) សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកនវកម្ម (ក្នុងវិហាររបស់សង្ឃ) ហើយឲ្យភិក្ខុដទៃនៅវិញ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលយកនវកម្ម (ក្នុងវិហាររបស់សង្ឃ) ហើយឲ្យភិក្ខុដទៃនៅទេ ភិក្ខុណាឲ្យភិក្ខុដទៃនៅ ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤០៩) តេន ខោ បន សមយេន ភិក្ខូ ឧទកម្ហិ គាហេត្វា សង្ឃិកំ បដិពាហន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឧទកម្ហិ គាហេត្វា សង្ឃិកំ បដិពាហិតព្វំ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ឯកំ វារសេយ្យំ គាហេតុន្តិ ។

(៤១០) តេន ខោ បន សមយេន ភិក្ខូ និស្សីមេ ឋិតស្ស ឧទកម្ហិ ទេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ និស្សីមេ ឋិតស្ស ឧទកម្ហិ ទាតព្វំ យោ ទទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៤១១) តេន ខោ បន សមយេន ភិក្ខូ ឧទកម្ហិ គាហេត្វា សព្វកាលំ បដិពាហន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឧទកម្ហិ គាហេត្វា សព្វកាលំ បដិពាហិតព្វំ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ វស្សានំ តេមាសំ បដិពាហិតុំ ឧតុកាលំ ន បដិពាហិតុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៤០៩) សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកនវកម្ម (កុដិវិហាររបស់សង្ឃ) ហើយហាមឃាត់សេនាសនៈរបស់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលយកនវកម្ម ហើយហាមឃាត់សេនាសនៈរបស់សង្ឃទេ ភិក្ខុណាហាមឃាត់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុដែលធ្វើការនោះ) ទទួលយកទីដេកដ៏ប្រសើរ ១ (បន្ទប់បាន) ។

(៤១០) សម័យនោះឯង ភិក្ខុទាំងឡាយឲ្យនវកម្មដល់ភិក្ខុនៅក្នុងទីឥតសីមា ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យនវកម្មដល់ភិក្ខុនៅក្នុងទីឥតសីមាទេ ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ ។

(៤១១) សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកនវកម្មហើយហាមឃាត់គ្រប់កាល ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលយកនវកម្មហើយហាមឃាត់គ្រប់កាលទេ ភិក្ខុណាហាមឃាត់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យហាមឃាត់ត្រឹម ៣ ខែនៃវស្សានរដូវ (ប៉ុណ្ណោះ) មិនមែនហាមឃាត់គ្រប់កាលនៃរដូវទេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៤១២] តេន ខោ បន សមយេន ភិក្ខូ នវកម្មំ ទត្វា បក្កមន្តិបិ វិព្ភមន្តិបិ កាលំបិ ករោន្តិ សាមណេរាបិ(១) បដិជានន្តិ សិក្ខំ បច្ចក្ខាតកាបិ បដិជានន្តិ អន្តិមវត្ថុំ អជ្ឈាបន្នកាបិ បដិជានន្តិ ឧម្មត្តកាបិ បដិជានន្តិ ខិត្តចិត្តាបិ បដិជានន្តិ វេទនដ្ដាបិ បដិជានន្តិ អាបត្តិយា អទស្សនេ ឧក្ខិត្តកាបិ បដិជានន្តិ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកាបិ បដិជានន្តិ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកាបិ បដិជានន្តិ បណ្ឌកាបិ បដិជានន្តិ ថេយ្យសំវាសកាបិ បដិជានន្តិ តិត្ថិយបក្កន្តកាបិ បដិជានន្តិ តិរច្ឆានគតាបិ បដិជានន្តិ មាតុឃាតកាបិ បដិជានន្តិ បិតុឃាតកាបិ បដិជានន្តិ អរហន្តឃាតកាបិ បដិជានន្តិ ភិក្ខុនីទូសកាបិ បដិជានន្តិ សង្ឃភេទកាបិ បដិជានន្តិ លោហិតុប្បាទកាបិ បដិជានន្តិ ឧភតោព្យញ្ជនកាបិ បដិជានន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

---

១ ម. សាមណេរកាបិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សេនាសនក្ខន្ធកៈ ការដែលពួកភិក្ខុទទួលនវកម្មហើយដើរវៀសចេញទៅជាដើម

(៤១២) សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកនវកម្មហើយដើរចេញទៅខ្លះ សឹកខ្លះ ធ្វើមរណកាលខ្លះ ប្តេជ្ញាខ្លួនទៅជាសាមណេរខ្លះ ប្តេជ្ញាជាអ្នកលាសិក្ខាខ្លះ ប្តេជ្ញាជាអ្នកត្រូវអន្តិមវត្ថុខ្លះ ប្តេជ្ញាជាមនុស្សឆ្កួតខ្លះ ប្តេជ្ញាជាអ្នកមានចិត្តរវើរវាយខ្លះ ប្តេជ្ញាជាអ្នកមានទុក្ខវេទនាគ្របសង្កត់ខ្លះ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិខ្លះ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិខ្លះ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញខ្លះ ប្តេជ្ញាជាមនុស្សខ្ទើយខ្លះ ប្តេជ្ញាជាមនុស្សលួចសំវាសខ្លះ ប្តេជ្ញាជាមនុស្សស្រុះទៅកាន់លទ្ធិតិរ្ថិយខ្លះ ប្តេជ្ញាជាសត្វតិរច្ឆានខ្លះ ប្តេជ្ញាជាអ្នកសម្លាប់មាតាខ្លះ ប្តេជ្ញាជាអ្នកសម្លាប់បិតាខ្លះ ប្តេជ្ញាជាអ្នកសម្លាប់ព្រះអរហន្តខ្លះ ប្តេជ្ញាជាអ្នកប្រទូស្តភិក្ខុនីខ្លះ ប្តេជ្ញាជាអ្នកបំបែកសង្ឃខ្លះ ប្តេជ្ញាជាអ្នកធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុរពងខ្លះ ប្តេជ្ញាជាអ្នកមានភេទពីរខ្លះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤១៣) ឥធ បន ភិក្ខវេ ភិក្ខុ នវកម្មំ ករោន្តោ បក្កមតិ ។ មា សង្ឃស្ស ហាយីតិ អញ្ញស្ស ទាតព្វំ ។ ឥធ បន ភិក្ខវេ ភិក្ខុ នវកម្មំ ករោន្តោ វិព្ភមតិ កាលំ ករោតិ សាមណេរោ បដិជានាតិ សិក្ខំ បច្ចក្ខាតកោ បដិជានាតិ អន្តិមវត្ថុំ អជ្ឈាបន្នកោ បដិជានាតិ ឧម្មត្តកោ បដិជានាតិ ខិត្តចិត្តោ បដិជានាតិ វេទនដ្ដោ បដិជានាតិ អាបត្តិយា អទស្សនេ ឧក្ខិត្តកោ បដិជានាតិ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកោ បដិជានាតិ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកោ បដិជានាតិ បណ្ឌកោ បដិជានាតិ ថេយ្យសំវាសកោ បដិជានាតិ តិត្ថិយបក្កន្តកោ បដិជានាតិ តិរច្ឆានគតោ បដិជានាតិ មាតុឃាតកោ បដិជានាតិ បិតុឃាតកោ បដិជានាតិ អរហន្តឃាតកោ បដិជានាតិ ភិក្ខុនិទូសកោ បដិជានាតិ សង្ឃភេទកោ បដិជានាតិ លោហិតុប្បាទកោ បដិជានាតិ ឧភតោព្យញ្ជនកោ បដិជានាតិ ។ មា សង្ឃស្ស ហាយីតិ អញ្ញស្ស ទាតព្វំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤១៣) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយចៀសចេញទៅ ។ ត្រូវភិក្ខុនោះឲ្យ (នវកម្មនោះ) ដល់ភិក្ខុដទៃ ដោយគិតថា សូមកុំឲ្យនវកម្មរបស់សង្ឃវិនាសឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយសឹកចេញ ធ្វើមរណកាល ប្តេជ្ញាទៅជាសាមណេរ ប្តេជ្ញាជាអ្នកលាសិក្ខា ប្តេជ្ញាជាអ្នកត្រូវអន្តិមវត្ថុ ប្តេជ្ញាជាមនុស្សឆ្កួត ប្តេជ្ញាជាអ្នកមានចិត្តរវើរវាយ ប្តេជ្ញាជាអ្នកត្រូវទុក្ខវេទនាគ្របសង្កត់ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ប្តេជ្ញាជាមនុស្សខ្ទើយ ប្តេជ្ញាជាមនុស្សលួចសំវាស ប្តេជ្ញាជាមនុស្សស្ទុះទៅកាន់លទ្ធិតិរ្ថិយ ប្តេជ្ញាជាសត្វតិរច្ឆាន ប្តេជ្ញាជាអ្នកសម្លាប់មាតា ប្តេជ្ញាជាអ្នកសម្លាប់បិតា ប្តេជ្ញាជាអ្នកសម្លាប់ព្រះអរហន្ត ប្តេជ្ញាជាអ្នកប្រទូស្តភិក្ខុនី ប្តេជ្ញាជាអ្នកបំបែកសង្ឃ ប្តេជ្ញាជាអ្នកធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុរពង ប្តេជ្ញាជាអ្នកមានភេទពីរ ។ ត្រូវភិក្ខុនោះឲ្យ ( នវកម្មនោះ ) ដល់ភិក្ខុដទៃ ដោយគិតថា សូមកុំឲ្យនវកម្មរបស់សង្ឃវិនាសឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤១៤) ឥធ បន ភិក្ខវេ ភិក្ខុ នវកម្មំ ករោន្តោ វិប្បកតេ បក្កមតិ ។ មា សង្ឃស្ស ហាយីតិ អញ្ញស្ស ទាតព្វំ ។ ឥធ បន ភិក្ខវេ ភិក្ខុ នវកម្មំ ករោន្តោ វិប្បកតេ វិព្ភមតិ ។ កាលំ ករោតិ ។ បេ ។ ឧភតោ-ព្យញ្ជនកោ បដិជានាតិ ។ មា សង្ឃស្ស ហាយីតិ អញ្ញស្ស ទាតព្វំ ។

(៤១៥) ឥធ បន ភិក្ខវេ ភិក្ខុ នវកម្មំ ករោន្តោ បរិយោសិតេ បក្កមតិ តស្សេវេតំ ។

(៤១៦) ឥធ បន ភិក្ខវេ ភិក្ខុ នវកម្មំ ករោន្តោ បរិយោសិតេ វិព្ភមតិ កាលំ ករោតិ សាមណេរោ បដិ-ជានាតិ សិក្ខំ បច្ចក្ខាតកោ បដិជានាតិ អន្តិមវត្ថុំ អជ្ឈាបន្នកោ បដិជានាតិ ។ សង្ឃោ សាមី ។

(៤១៧) ឥធ បន ភិក្ខវេ ភិក្ខុ នវកម្មំ ករោន្តោ បរិយោសិតេ ឧម្មត្តកោ បដិជានាតិ ខិត្តចិត្តោ បដិជា-

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤១៤) ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះទទួលយកនវកម្មហើយចៀសចេញទៅក្នុងវេលាដែលធ្វើ (នវកម្ម) មិនទាន់ស្រេច ។ ត្រូវភិក្ខុនោះឲ្យ(នវកម្មនោះ)ដល់ភិក្ខុឯទៀត ដោយគិតថា សូមកុំឲ្យនវកម្មរបស់សង្ឃវិនាសឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយសឹកចេញ ក្នុងវេលាដែលធ្វើនវកម្មមិនទាន់ស្រេច ។ ធ្វើមរណកាល ។ បេ ។ ប្តេជ្ញាជាអ្នកមានភេទពីរ ។ ត្រូវភិក្ខុនោះឲ្យ (នវកម្មនោះ) ដល់ភិក្ខុដទៃ ដោយគិតថា សូមកុំឲ្យនវកម្មរបស់សង្ឃវិនាសឡើយ ។

(៤១៥) ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្ម ហើយចៀសចេញទៅក្នុងវេលាដែលធ្វើ (នវកម្ម) ហើយស្រេច (លុះត្រឡប់មកនៅវិញ) នវកម្មនុ៎ះ ជារបស់ភិក្ខុនោះឯង ។

(៤១៦) ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយសឹកចេញ ធ្វើមរណកាល ប្តេជ្ញាជាសាមណេរ ប្តេជ្ញាជាអ្នកលាសិក្ខា ប្តេជ្ញាជាអ្នកត្រូវអន្តិមវត្ថុ ក្នុងវេលាដែលធ្វើនវកម្មហើយស្រេច ។ ត្រូវសង្ឃជាម្ចាស់ ។

(៤១៧) ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុ ក្នុងសាសនានេះ ទទួលយកនវកម្មហើយប្តេជ្ញាជាមនុស្សឆ្កួត ប្តេជ្ញាជាអ្នកមានចិត្តរវើរវាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



នាតិ វិព្ភន្តោ បដិជានាតិ អាបត្តិយា អទស្សនេ ឧក្ខិត្តកោ បដិជានាតិ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្ត-កោ បដិជានាតិ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកោ បដិជានាតិ តស្សេវេតំ ។

(៤១៨) ឥធ បន ភិក្ខវេ ភិក្ខុ នវកម្មំ គហេត្វា បរិយោសិតេ បណ្ឌកោ បដិជានាតិ ថេយ្យសំវាសកោ បដិជានាតិ តិត្ថិយបក្កន្តកោ បដិជានាតិ តិរច្ឆានគតោ បដិជានាតិ មាតុឃាតកោ បដិជានាតិ បិតុឃាតកោ បដិជានាតិ អរហន្តឃាតកោ បដិជានាតិ ភិក្ខុនិទូស-កោ បដិជានាតិ សង្ឃភេទកោ បដិជានាតិ លោហិ-តុប្បាទកោ បដិជានាតិ ឧភតោព្យញ្ជនកោ បដិជា-នាតិ ។ សង្ឃោ សាមីតិ ។

(៤១៩) តេន ខោ បន សមយេន ភិក្ខូ អញ្ញតរស្ស ឧបាសកស្ស វិហារបរិភោគំ សេនាសនំ អញ្ញត្រ បរិភុញ្ជន្តិ ។ អថ ខោ សោ ឧបាសកោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភទ្ទន្តា អញ្ញត្រ បរិភោគំ អញ្ញត្រ បរិភុញ្ជិស្សន្តីតិ ។ ភគវតោ ឯតមត្ថំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ប្ដេជ្ញាជាអ្នកត្រូវទុក្ខវេទនាគ្របសង្កត់ ប្ដេជ្ញាជាអ្នកត្រូវសង្ឃ លើកវត្ត ព្រោះមិនឃើញអាបត្តិ ប្ដេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិចេញ ប្ដេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្នុងវេលាដែលធ្វើនវកម្មហើយស្រេច នវកម្មនុ៎ះជារបស់ភិក្ខុនោះឯង។

(៤១៨) ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយ ប្ដេជ្ញាជាមនុស្សខ្ទើយ ប្ដេជ្ញាជាអ្នកលួចសំវាស ប្ដេជ្ញាជាអ្នកស្ទុះទៅកាន់លទ្ធិតិរ្ថិយ ប្ដេជ្ញាជាសត្វតិរច្ឆាន ប្ដេជ្ញាជាអ្នកសម្លាប់មាតា ប្ដេជ្ញាជាអ្នកសម្លាប់បិតា ប្ដេជ្ញាជាអ្នកសម្លាប់ព្រះអរហន្ត ប្ដេជ្ញាជាអ្នកប្រទូស្តភិក្ខុនី ប្ដេជ្ញាជាអ្នកបំបែកសង្ឃ ប្ដេជ្ញាជាអ្នកធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុះពង ប្ដេជ្ញាជាអ្នកមានភេទពីរ ក្នុងវេលាដែលធ្វើ (នវកម្ម) ហើយស្រេច ។ ត្រូវសង្ឃជាម្ចាស់ ។

(៤១៩) សម័យនោះឯង ភិក្ខុទាំងឡាយយកសេនាសនៈរបស់ឧបាសកម្នាក់ (ដែលគេឧទ្ទិស) ជាគ្រឿងសម្រាប់ប្រើប្រាស់ក្នុងវិហារទៅប្រើប្រាស់ក្នុងទីឯទៀត ។ គ្រានោះ ឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកដ៏ចំរើនទាំងឡាយមិនសមបើនឹងយកគ្រឿងប្រើប្រាស់អំពីទីឯទៀត ទៅប្រើប្រាស់ក្នុងទីឯទៀតសោះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អារោចេសុំ ។ ន ភិក្ខវេ អញ្ញត្រ បរិភោគោ អញ្ញត្រ បរិភុញ្ជិតព្វោ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៦២០) តេន ខោ បន សមយេន ភិក្ខូ ឧបោស-ថគ្គំបិ សន្និសជ្ជំបិ បរិហរិតុំ(១) កុក្កុច្ចាយន្តា ឆមាយំ និសីទន្តិ ។ គត្តានិបិ ចីវរានិបិ បំសុកិតានិ ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តាវកាលិកំ ហរិតុន្តិ ។

(៦២១) តេន ខោ បន សមយេន សង្ឃស្ស មហាវិហារោ ឧទ្រិយតិ(២) ។ ភិក្ខូ កុក្កុច្ចាយន្តា សេ-នាសនំ នាភិហរន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គុត្តត្ថាយ ហរិតុន្តិ ។

(៦២២) តេន ខោ បន សមយេន សង្ឃស្ស សេនា-សនបរិក្ខារិកោ មហគ្ឃោ កម្ពលោ ឧប្បន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ផាតិកម្មត្ថាយ បរិវត្តេតុន្តិ ។

---

១ ឱ. ហរិតុំ ។ ២ ម. ឧន្ទ្រិយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវយកគ្រឿងប្រើប្រាស់ ក្នុងទីឯទៀតទៅប្រើប្រាស់ក្នុងទីឯទៀតទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

(៤២០) សម័យនោះឯង ពួកភិក្ខុមានសេចក្តីសង្ស័យ (មិនហ៊ាន) នាំយក (គ្រឿងប្រើប្រាស់) ទៅកាន់រោងឧបោសថ កាន់រោងជាទីប្រជុំ ហើយក៏នាំគ្នាអង្គុយផ្ទាល់លើផែនដី ។ ទាំងខ្លួនទាំងចីវរ (របស់ភិក្ខុនោះ) ក៏ប្រឡាក់ប្រឡូសដោយអាចម៍ដី ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យនាំយក (គ្រឿងប្រើប្រាស់នោះ) ឲ្យជារបស់ខ្ចីបាន ។

(៤២១) សម័យនោះឯង វិហារធំរបស់សង្ឃទ្រុឌទ្រោម ។ ពួកភិក្ខុសង្ស័យមិនហ៊ាននាំយកសេនាសនៈចេញ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យនាំយក (សេនាសនៈ) ទៅទុកថែរក្សាបាន ។

(៤២២) សម័យនោះឯង សំពត់កម្ពលមានតម្លៃច្រើន ជាសេនាសនបរិក្ខារកើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យផ្លាស់ប្តូរ ដើម្បីប្រយោជន៍ជាផាតិកម្ម គឺការចំរើនបាន ។

(៤២៣) តេន ខោ បន សមយេន សង្ឃស្ស សេនាសនបរិក្ខារិកំ មហគ្ឃំ ទុស្សំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ផាតិកម្មត្ថាយ បរិវត្តេតុន្តិ ។

(៤២៤) តេន ខោ បន សមយេន សង្ឃស្ស អច្ឆចម្មំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បាទបុញ្ឆនឹ កាតុន្តិ ។

(៤២៥) តេន ខោ បន សមយេន សង្ឃស្ស ចក្កលី ឧប្បន្នា ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បាទបុញ្ឆនឹ កាតុន្តិ ។

(៤២៦) តេន ខោ បន សមយេន សង្ឃស្ស ចោឡកំ ឧប្បន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បាទបុញ្ឆនឹ កាតុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤២៣) សម័យនោះឯង សំពត់មានតម្លៃច្រើន ជាបរិក្ខារក្នុងសេនាសនៈកើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យផ្លាស់ប្តូរ ដើម្បីប្រយោជន៍ជាផាតិកម្មបាន ។

(៤២៤) សម័យនោះឯង ស្បែកខ្លាឃ្មុំកើតឡើង ដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជាទ្រនាប់សម្រាប់ជូតជើងបាន ។

(៤២៥) សម័យនោះឯង វត្ថុមានសណ្ឋានដូចជាកង់ (ដែលគេវេញដោយសំពត់កម្ពលជាដើម) កើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជារង្វេលសម្រាប់ជូតជើងបាន ។

(៤២៦) សម័យនោះឯង មានកំណាត់សំពត់កើតឡើង ដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជាសំពត់សម្រាប់ជូតជើងបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៤២៧] តេន ខោ បន សមយេន ភិក្ខូ អធោតេហិ បាទេហិ សេនាសនំ អក្កមន្តិ ។ សេនាសនំ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អធោតេហិ បាទេហិ សេនាសនំ អក្កមិតព្វំ យោ អក្កមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៤២៨] តេន ខោ បន សមយេន ភិក្ខូ អល្លេហិ បាទេហិ សេនាសនំ អក្កមន្តិ ។ សេនាសនំ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អល្លេហិ បាទេហិ សេនាសនំ អក្កមិតព្វំ យោ អក្កមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៤២៩] តេន ខោ បន សមយេន ភិក្ខូ សឧបាហនា សេនាសនំ អក្កមន្តិ ។ សេនាសនំ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សឧបាហនេន សេនាសនំ អក្កមិតព្វំ យោ អក្កមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(៤៦៧) សម័យនោះឯង ពួកភិក្ខុមិនទាន់លាងជើង(១)ហើយដើរជាន់សេនាសនៈ ។ សេនាសនៈក៏ប្រឡាក់អស់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឥតលាងជើង មិនត្រូវដើរជាន់សេនាសនៈទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ

(៤៦៨) សម័យនោះឯង ពួកភិក្ខុដើរជាន់សេនាសនៈទាំងជើងទទឹក ។ សេនាសនៈក៏សើមអស់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដើរជាន់សេនាសនៈទាំងជើងទទឹកទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ ។

(៤៦៩) សម័យនោះឯង ពួកភិក្ខុពាក់ស្បែកជើងដើរជាន់សេនាសនៈ ។ សេនាសនៈក៏ប្រឡាក់អស់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុពាក់ស្បែកជើងមិនត្រូវដើរជាន់សេនាសនៈទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ ។

---

១ បញ្ញត្តិនេះចំពោះយកជើងមិនស្អាតជាប្រមាណ សូម្បីជើងដែលបានលាងហើយតែនៅមិនទាន់ស្អាត ក៏មិនគួរជាន់សេនាសនៈឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤៣០) តេន ខោ បន សមយេន ភិក្ខូ បរិកម្មកតាយ ភូមិយា និបជ្ជន្តិ[1] ។ វណ្ណោ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ បរិកម្មកតាយ ភូមិយា និបជ្ជិតព្វំ យោ និបជ្ជេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ចិមិលិកន្តិ ។

(៤៣១) តេន ខោ បន សមយេន មញ្ចបាទាបិ បីឋបាទាបិ បរិកម្មកតំ ភូមឹ វិលិខន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចោឡកេន បលិវេឋេតុន្តិ[2] ។

(៤៣២) តេន ខោ បន សមយេន ភិក្ខូ បរិកម្មកតំ ភិត្តឹ អបស្សេន្តិ ។ វណ្ណោ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ បរិកម្មកតា ភិត្តិ អបស្សេតព្វា យោ អបស្សេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ អបស្សេនផលកន្តិ ។ អបស្សេនផលកំ ហេដ្ឋតោ ភូមឹ វិលិខតិ

---

១ ឱ. ម. ឧដ្ឋិហន្តិ ។ ២ ម. បលិវេធេតុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕





(៤៣០) សម័យនោះឯង ពួកភិក្ខុស្ដោះទឹកមាត់លើទីដែលគេតាក់តែងឲ្យស្អាត ។ (ទីនោះ) ក៏អាប់អន់ពណ៌សម្បុរទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្ដោះទឹកមាត់លើទីដែលគេតាក់តែងទេ ភិក្ខុណាស្ដោះ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យប្រើ) កន្ធោទឹកមាត់ ។

(៤៣១) សម័យនោះឯង ជើងគ្រែខ្លះ ជើងតាំងខ្លះ ក៏កោសជាប់ទីកន្លែងដែលគេតាក់តែងឲ្យល្អ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរុំ (ជើងគ្រែ ជើងតាំងនោះ) ដោយកំណាត់សំពត់ ។

(៤៣២) សម័យនោះឯង ពួកភិក្ខុផ្អែកនឹងជញ្ជាំងដែលគេលាប (ថ្នាំផ្សេង ៗ) ។ ពណ៌សម្បុរ (ជញ្ជាំង) ក៏អាប់អន់ទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវផ្អែកនឹងជញ្ជាំងដែលគេលាប (ថ្នាំផ្សេង ៗ) ទេ ភិក្ខុណាផ្អែក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផែនក្ដារសម្រាប់ផ្អែក ។ ឯផែនក្ដារសម្រាប់ផ្អែក ក៏កោសផ្ទៃទីខាងក្រោម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧបរិតោ ភិត្តិញ្ច(១) ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ហេដ្ឋតោ ច ឧបរិតោ ច ចោឡកេន បលិវេឋេតុន្តិ ។

[៤៣៣] តេន ខោ បន សមយេន ភិក្ខូ ធោត-បាទកា និបជ្ជិតុំ កុក្កុច្ចាយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បច្ចត្ថរិត្វា និបជ្ជិតុន្តិ ។

[៤៣៤] អថខោ ភគវា អាឡវិយំ យថាភិរន្តំ វិហរិត្វា យេន រាជគហំ តេន ចារិកំ បក្កាមិ អនុ-បុព្វេន ចារិកំ ចរមានោ យេន រាជគហំ តទវសរិ ។ តត្រ សុទំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទ-កនិវាបេ ។

[៤៣៥] តេន ខោ បន សមយេន រាជគហំ ទុព្ភិក្ខំ ហោតិ ។ មនុស្សា ន សក្កោន្តិ សង្ឃភត្តំ កាតុំ ឥច្ឆន្តិ ឧទ្ទេសភត្តំ និមន្តនំ សលាកភត្តំ បក្ខិកំ ឧបោសថិកំ បាដិបទិកំ កាតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

---

១ ឱ. ឧបរិតោ ភិត្តិ ហត្ថ ។ ម. ឧបរិតោ ភិត្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



នឹងជញ្ជាំងខាងលើ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរុំសំពត់ទាំងខាងលើទាំងខាងក្រោម ។

(៤៣៣) សម័យនោះឯង ភិក្ខុមានជើងលាងស្រេចហើយ តែនៅមានសង្ស័យ (មិនហ៊ាន) ដេក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាលរួចសឹមដេក ។

(៤៣៤) គ្រានោះ ព្រះមានព្រះភាគគង់នៅ ក្នុងដែនកាឡី គួរតាមព្រះអធ្យាស្រ័យ រួចហើយទ្រង់ស្តេចទៅកាន់ចារិកក្រុងរាជគ្រឹះ ស្តេចទៅកាន់ចារិកតាមលំដាប់ សំដៅទៅកាន់ក្រុងរាជគ្រឹះនោះ ។ បានឮថា ព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។

(៤៣៥) សម័យនោះឯង ក្រុងរាជគ្រឹះកើតទុរ្ភិក្ស (អត់បាយ) មនុស្សទាំងឡាយមិនអាចនឹងធ្វើសង្ឃភត្តបាន ហើយក៏ប្រាថ្នានឹងធ្វើឧទ្ទេសភត្ត និមន្តនភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត និងបាដិបទិកភត្ត ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ សង្ឃភត្តំ ឧទ្ទេសភត្តំ និមន្តនំ សលាកភត្តំ បក្ខិកំ ឧបោសថិកំ បាដិបទិកន្តិ ។

[៤៣៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អត្តនោ វរភត្តានិ(១) គហេត្វា លាមកានិ ភត្តានិ ភិក្ខូនំ ទេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ភត្តុទ្ទេសកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ ឧទ្ទិដ្ឋានុទ្ទិដ្ឋញ្ច ជានេយ្យ ។

[៤៣៧] ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ ។ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ភត្តុទ្ទេសកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ភត្តុទ្ទេសកំ សម្មន្នតិ ។

---

១ ឱ. មធុរភត្តានិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសង្ឃភត្ត ឧទ្ទេសភត្ត និមន្តនភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត និងបាដិបទិកភត្ត ។

(៤៣៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ទទួលយកភត្តប្រសើរចំពោះខ្លួនឯង ហើយឲ្យភត្តមិនថ្លៃថ្លា ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ៥ ឲ្យជាភត្តុទ្ទេសកៈ គឺអ្នកសំដែងភត្ត (អង្គ៥ នោះគឺ)មិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ស្គាល់ភត្តដែលខ្លួនបានសំដែងនឹងមិនទាន់បានសំដែង ១ ។

(៤៣៧) ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ ។ សង្ឃត្រូវសូមភិក្ខុជាមុនសិន ។ លុះសូមរួចហើយ ត្រូវឲ្យភិក្ខុជាអ្នកឈ្លាសប្រតិពលប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះឲ្យជាភត្តុទ្ទេសកៈ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃបានសន្មតភិក្ខុឈ្មោះនេះឲ្យជាភត្តុទ្ទេសកៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ភត្តុទ្ទេសកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ ភត្តុទ្ទេសកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤៣៨) អថខោ ភត្តុទ្ទេសកានំ ភិក្ខូនំ ឯតទហោសិ កថំ នុ ខោ ភត្តំ ឧទ្ទិសិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សលាកាយ វា បដិកាយ(១) វា ឧបនិពន្ធិត្វា ឱបុញ្ជិត្វា ភត្តំ(២) ឧទ្ទិសិតុន្តិ ។

(៤៣៩) តេន ខោ បន សមយេន សង្ឃស្ស សេនាសនបញ្ញាបកោ ន ហោតិ ។បេ។ ភណ្ឌាគារិកោ ន ហោតិ ។បេ។ ចីវរប្បដិគ្គាហកោ ន ហោតិ ។បេ។ ចីវរភាជកោ ន ហោតិ ។បេ។ យាគុភាជកោ ន ហោតិ

---

១ ឱ.ម. បដ្ដិកាយ ។ ២ អយំ ទេបិយមរម្មពោត្ថកេសុ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ការសន្មតិភិក្ខុឈ្មោះនេះឲ្យជាភត្តុទ្ទេសកៈ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីថ្លែងមក ។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះឲ្យជាភត្តុទ្ទេសកៈហើយ ការសន្មតិនេះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(៤៣៨) លំដាប់នោះ ពួកភិក្ខុជាភត្តុទ្ទេសកៈមានសេចក្តីត្រិះរិះដូច្នេះថា យើងគួរសំដែងភត្តដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចាប់កែ ដោយសលាកប្តដំបា (មានចង្អុះឫស្សីនិងស្លឹកត្នោតជាដើម) លាឬបើកហើយសំដែងភត្ត ។

(៤៣៩) សម័យនោះឯង មិនទាន់មានភិក្ខុជាសេនាសនបញ្ញាបកៈ (អ្នកក្រាលសេនាសនៈ) បម្រុងសង្ឃ ។បេ។ មិនទាន់មានភិក្ខុជាភណ្ឌាគារិកៈ (អ្នករក្សាឃ្លាំង) ។បេ។ មិនទាន់មានភិក្ខុជាចីវរប្បដិគ្គាហកៈ (អ្នកទទួលចីវរទុក) ។បេ។ មិនទាន់មានភិក្ខុជាចីវរភាជកៈ (អ្នកចែកចីវរ) ។បេ។ មិនទាន់មានភិក្ខុជាយាគុភាជកៈ (អ្នកចែកបបរ) ។បេ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



។ បេ ។ ផលភាជកោ ច ហោតិ ។ បេ ។ ខជ្ជកភាជកោ ច ហោតិ ។ ខជ្ជកំ អភាជិយមានំ នស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ខជ្ជកភាជកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ ភាជិតាភាជិតញ្ច ជានេយ្យ ។

(៤៤០) ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ខជ្ជកភាជកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ខជ្ជកភាជកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ខជ្ជកភាជកស្ស សម្មុតិ សោ តុណ្ហស្ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



មិនទាន់មានភិក្ខុជាផលភាជកៈ (អ្នកចែកផ្លែឈើ) ។ បេ ។ មិនទាន់មានភិក្ខុជាខជ្ជកភាជកៈ (អ្នកចែកបង្អែម) នៅឡើយ ។ បេ ។ បង្អែមដែលមិនបានចែកក៏ខូចអស់ទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាខជ្ជកភាជកៈ (អង្គ ៥ នោះគឺ) មិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ស្គាល់វត្ថុដែលខ្លួនបានចែកនឹងមិនទាន់បានចែក ១ ។

(៤៤០) ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ ។ សង្ឃគប្បីសូមភិក្ខុជាមុនសិន ។ លុះសូមរួចហើយ ត្រូវឲ្យភិក្ខុជាអ្នកឈ្លាសប្រតិពលប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះឲ្យជាខជ្ជកភាជកៈ (អ្នកចែកបង្អែម) ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឥឡូវសង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាខជ្ជកភាជកៈ ។ ការសន្មតិភិក្ខុឈ្មោះនេះ ឲ្យជាខជ្ជកភាជកៈ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ ខជ្ជកភាជកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤៤១) តេន ខោ បន សមយេន សង្ឃស្ស ភណ្ឌាគារេ អប្បមត្តកោ បរិក្ខារោ ឧស្សន្នោ(១) ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ អប្បមត្តកវិស្សជ្ជកំ សម្មន្និតុំ យោ ន ឆន្ទាគតិំ គច្ឆេយ្យ ន ទោសាគតិំ គច្ឆេយ្យ ន មោហាគតិំ គច្ឆេយ្យ ន ភយាគតិំ គច្ឆេយ្យ វិស្សជ្ជិតាវិស្សជ្ជិតញ្ច ជានេយ្យ ។

(៤៤២) ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ អប្បមត្តកវិស្សជ្ជកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។

១ ឱ. ម. ឧប្បន្នោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវឆ្លើយមក ។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះឲ្យជាខជ្ជកភាជកៈហើយ ការសន្មតិនេះសមគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(៤៤១) សម័យនោះឯង បរិក្ខារតិចតួច មានក្រាស់ក្រែលឡើងក្នុងឃ្លាំងរបស់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអប្បមត្តកវិស្សជ្ជកៈ (អ្នកចែកចាយនូវបរិក្ខារតិចតួច) (អង្គ ៥ នោះគឺ) មិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ស្គាល់បរិក្ខារដែលខ្លួនបានចែកចាយហើយ នឹងមិនទាន់បានចែកចាយហើយ ១ ។

(៤៤២) ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ ។ សង្ឃគប្បីសូមភិក្ខុជាមុនសិន ។ លុះសូមរួចហើយ ត្រូវភិក្ខុដែលឈ្លាសប្រតិពលប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះឲ្យជាអប្បមត្តកវិស្សជ្ជកៈ (អ្នកចែកចាយបរិក្ខារតិចតួច) ។ នេះជាញត្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ អប្បមត្តកវិស្សជ្ជកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ អប្បមត្តកវិស្សជ្ជកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ អប្បមត្តកវិស្សជ្ជកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤៤៣) តេន អប្បមត្តកវិស្សជ្ជកេន ភិក្ខុនា ឯកា[១] សូចិ ទាតព្វា ។ សត្ថកំ ទាតព្វំ ។ ឧបាហនា ទាតព្វា ។ កាយពន្ធនំ ទាតព្វំ ។ អំសពទ្ធកោ ទាតព្វោ ។ បរិស្សាវនំ ទាតព្វំ ។ ធម្មករកោ ទាតព្វោ ។ កុសិ ទាតព្វា ។ អឌ្ឍកុសិ ទាតព្វា ។ មណ្ឌលំ ទាតព្វំ ។ អឌ្ឍមណ្ឌលំ ទាតព្វំ ។ អនុវាតោ ទាតព្វោ ។ បរិភណ្ឌំ ទាតព្វំ ។ សចេ ហោតិ សង្ឃស្ស សប្បិ វា តេលំ វា មធុ វា ផាណិតំ វា សកឹ បដិសាយិតុំ ទាតព្វំ ។ សចេ បុនបិ អត្ថោ ហោតិ បុនបិ ទាតព្វំ ។ សចេ បុនបិ អត្ថោ ហោតិ បុនបិ ទាតព្វន្តិ[២] ។

---

១ ឱ. ឯកេកា ។ ២ មរម្មបោត្ថកេ អាមេឌិតំ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាអប្បមត្តកវិស្សជ្ជកៈ ។ ការសន្មតិភិក្ខុឈ្មោះនេះឲ្យជាអប្បមត្តកវិស្សជ្ជកៈ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវឆ្លើយមក ។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអប្បមត្តកវិស្សជ្ជកៈហើយ ការសន្មតិនេះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(៤៤៣) ភិក្ខុជាអប្បមត្តកវិស្សជ្ជក នោះ (បើមានភិក្ខុមកសូមម្ជុល) ត្រូវឲ្យម្ជុលមួយ (ម្តង) ។ ត្រូវឲ្យកាំបិត ។ ត្រូវឲ្យស្បែកជើង ។ ត្រូវឲ្យវត្ថ-ពន្ធចង្កេះ ។ ត្រូវឲ្យយោគបាត្រ ។ ត្រូវឲ្យសំពត់តម្រងទឹក ។ ត្រូវឲ្យធម្ម-ក្រក ។ ត្រូវឲ្យសំពត់កុសិ (ខ្នង់វែង) ។ ត្រូវឲ្យសំពត់អឌ្ឍកុសិ (ខ្នង់ខ្លី) ។ ត្រូវឲ្យសំពត់មណ្ឌល (ផ្ទាំងធំ) ។ ត្រូវឲ្យសំពត់អឌ្ឍមណ្ឌល (ផ្ទាំងតូច) ។ ត្រូវឲ្យសំពត់អនុវាត ។ ត្រូវឲ្យសំពត់សម្រាប់ថែមឬសំពត់សំប៉ះ ។ បើមានសប្បិក្តី ប្រេងក្តី ទឹកឃ្មុំក្តី ស្ករអំពៅក្តី (ភិក្ខុអ្នកចែកចាយបរិក្ខារនោះ) ត្រូវឲ្យដល់សង្ឃឆាន់ក្នុងគ្រាម្តង ៗ ។ បើសង្ឃត្រូវការទៀត ត្រូវឲ្យទៀត ។ បើសង្ឃត្រូវការម្តងទៀត ត្រូវឲ្យម្តងទៀត ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សេនាសនក្ខន្ធកេ សាដិយគ្គាហាបកាទិកោ

[៤៤៤] តេន ខោ បន សមយេន សង្ឃស្ស សាដិយគ្គាហាបកោ ន ហោតិ ។បេ។ បត្តគ្គាហាបកោ ន ហោតិ ។បេ។ អារាមិកបេសកោ ន ហោតិ ។បេ។ សាមណេរបេសកោ ន ហោតិ ។ សាមណេរា អបេសិយមានា កម្មំ ន ករោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ សាមណេរបេសកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ បេសិតាបេសិតញ្ច ជានេយ្យ ។

[៤៤៥] ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សាមណេរបេសកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៤៤៨] សម័យនោះឯង មិនទាន់មានភិក្ខុជាសាដិយគ្គាហាបកៈ (អ្នកប្រគល់សំពត់ដល់សង្ឃ) ។ បេ ។ មិនទាន់មានភិក្ខុជាបត្តគ្គាហាបកៈ (អ្នកប្រគល់បាត្រ) ។ បេ ។ មិនទាន់មានភិក្ខុជាអារាមិកបេសកៈ (អ្នកប្រើក្មេងវត្ត) ។ បេ ។ មិនទាន់មានសាមណេរបេសកៈ (អ្នកប្រើសាមណេរ) ។ បេ ។ សាមណេរទាំងឡាយកាលបើភិក្ខុមិនប្រើ ក៏មិនធ្វើការងារ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាសាមណេរបេសកៈ (អ្នកប្រើសាមណេរ) (អង្គ ៥ នោះគឺ) មិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ស្គាល់សាមណេរដែលខ្លួនបានប្រើនិងមិនទាន់បានប្រើ ១ ។

(៤៤៩) ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ ។ សង្ឃគប្បីសូមភិក្ខុជាមុនសិន ។ លុះសូមរួចហើយត្រូវភិក្ខុដែលឈ្លាសប្រតិពល ប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគួរសន្មតភិក្ខុឈ្មោះនេះឲ្យជាសាមណេរបេសកៈ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សាមណេរបេសកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សាមណេរបេសកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ សាមណេរបេសកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

ភាណវារំ និដ្ឋិតំ តតិយំ ។

សេនាសនក្ខន្ធកំ និដ្ឋិតំ ឆដ្ឋំ ។

តស្សុទ្ទានំ

(៤៤៦) វិហារំ ពុទ្ធសេដ្ឋេន
អបញ្ញត្តំ តទា អហុ
តហំ តហំ និក្ខមន្តិ
វសា តេ ជិនសាវកា(១) ។
តេ(២) សេដ្ឋី គហបតិ ទិស្វា
ភិក្ខូនំ ឥទមព្រវិ

---

១ ឱ. អាវសា តត្ថ តេ ជិនសាវកា ។ ២ ឱ. ម. ពោត្ថកេសុ អយំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សាមណេរបេសកៈ ។ ការសន្មតិភិក្ខុឈ្មោះនេះឲ្យជាសាមណេរបេសកៈ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវឆ្លើយមក ។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះ ឲ្យជាសាមណេរបេសកៈហើយ ការសន្មតិនេះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ចប់ ភាណវារៈ ទី៣ ។

ចប់ សេនាសនក្ខន្ធកៈទី៦ ។

ឧទ្ទាននៃសេនាសនក្ខន្ធកៈនោះ ( ដូចតទៅនេះ )

(៤៤៦) រឿងព្រះសម្មាសម្ពុទ្ធប្រសើរមិនទាន់បានបញ្ញត្តវិហារក្នុងគ្រានោះ ១ រឿងសាវ័កព្រះជិនស្រី ដើរចេញទៅនៅក្នុងទីនោះៗ ១ រឿងសេដ្ឋីគហបតិបានឃើញព្រះសាវ័កទាំងនោះ ហើយដំណាលរឿងនេះប្រាប់ភិក្ខុទាំងឡាយថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកេ ឧទ្ទានគាថា

ការាបេយ្យំ ករេយ្យាថ
បដិក្កិសុ ឆាយេហិ ។
វិហារំ អឌ្ឍយោគញ្ច
បាសាទំ ហម្មិយំ គុហំ
បញ្ចលេណំ អនុញ្ញាសិ
វិហារេ សដ្ឋិ ការយិ ។
ជនោ វិហារំ ការេតិ
អកវាដំ អសំវុតំ
កវាដំ បិដ្ឋសង្ឃាដំ
ឧទុក្ខលញ្ច ឧត្តរិ ។
អាវិញ្ឆនច្ឆិទ្ទំ វដ្ដិំ
វដ្តិញ្ច កបិសីសកំ
សូចិ ឃដិ តាលច្ឆិទ្ទំ
លោហកដ្ឋវិសាណកំ ។
យន្តកំ សូចិកាញ្ចេវ
ឆទនំ ឧល្លិត្តំ(១) ច

---
១ ឱ. ម. ឧល្លិត្តាវលិត្តំ ។

ខ្ញុំព្រះករុណាបម្រុងនឹងឲ្យជាងធ្វើវិហារ សូមលោកម្ចាស់តាំងឲ្យាយតង់នៅក្នុងវិហាររបស់យើង ១ រឿងពួកភិក្ខុក្រាបបង្គំទូល (ដំណើរនេះ) ចំពោះព្រះសម្មាសម្ពុទ្ធជានាយក ១ ។ រឿងទ្រង់អនុញ្ញាតទីជ្រកកោន ៥ យ៉ាង គឺ វិហារ ១ អឌ្ឍ-យោគ ១ ប្រាសាទ ១ ប្រាសាទដំបូលត្រងិល ១ គុហា ១ រឿងសេដ្ឋីឲ្យជាងធ្វើវិហារ ១ ។ រឿងមហាជនឲ្យជាងធ្វើវិហារឥតមានសន្ទះទ្វារ ១ រឿងទ្រង់អនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ត្រណាប់ក្រោមនឹងត្រណាប់លើជាដើម ១ ។ រឿងទ្រង់អនុញ្ញាតប្រហោងដាក់ខ្សែសម្រាប់ទាញ នឹងខ្សែសម្រាប់ទាញគន្ទឹស មេទ្វារ ត្រដោកទ្វារ ទ្រុក គន្ទឹសនឹងសោ ៣ យ៉ាង គឺ សោធ្វើពីលោហៈ សោធ្វើពីឈើ សោធ្វើពីស្នែង ១ ។ រឿងទ្រង់អនុញ្ញាតសោយន្ត នឹងគន្ទឹស រឿងទ្រង់អនុញ្ញាតដម្បូលនឹងឲ្យបូកលាបខាងក្នុងខាងក្រៅ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វេធិកំ ជាលសលាកញ្ច

ចក្កលិ សន្ថរេន ច

មិឍិ វិធលមញ្ចញ្ច

សោសាធិកាមសារកោ

តុណ្ឌិ កុឡ្បិរធានញ្ច

អាហាឡ្ហាសន្ធិ ឱរូកោ

សត្តផ្តា ច កន្ធូបឹបំ

បឹបិកេឡ្បការធានកំ

អាមលា ផលកា កោច្ឆា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងទ្រង់អនុញ្ញាតបង្អួច ៣ យ៉ាង គឺបង្អួចមានវេទិ បង្អួចមានក្រឡាសំណាញ់ បង្អួចមានសសរចម្រឹង ១ រឿងទ្រង់អនុញ្ញាតឲ្យយកវត្ថុសម្រាប់ជូតជើង ដែលគេវេញមានសណ្ឋានដូចជាកង់បង្អួច ១ រឿងទ្រង់អនុញ្ញាតកម្រាលស្មៅ ១ រឿងទ្រង់អនុញ្ញាតបន្ទះក្តារសម្រាប់អង្គុយឬដេក ១ រឿងទ្រង់អនុញ្ញាតគ្រែផ្តៅ ១ រឿងទ្រង់អនុញ្ញាត គ្រែដែលគេជាប់ជើងហើយបញ្ចូលមេទៅក្នុងដំណាច់ ដែលគេហាលក្នុងព្រៃស្មសាន ១ រឿងទ្រង់អនុញ្ញាតគ្រែ ដែលគេបង្កាំជើងគ្រែដោយមេគ្រែ ១ រឿងទ្រង់អនុញ្ញាតគ្រែ ដែលគេធ្វើជើងប្រហែលនឹងជើងសេះឬជើងពពែជាដើម ១ រឿងទ្រង់អនុញ្ញាតគ្រែ ដែលគេបញ្ចុះពន្ទួញទៅក្នុងមេ ១ រឿងទ្រង់អនុញ្ញាតគ្រែបួនជ្រុងមានជើងខ្ពស់ ១ រឿងទ្រង់អនុញ្ញាតគ្រែមានអង្គប្រាំពីរ ១ រឿងទ្រង់អនុញ្ញាតតាំងផ្តៅ ១ រឿងទ្រង់អនុញ្ញាតគ្រែ និងតាំងមានជើងដូចជើងពពែ ១ រឿងទ្រង់អនុញ្ញាតតាំងមានជើងច្រើន ដែលគេប្រកបដោយអាការដូចជាផ្លែកន្ទួតព្រៃ ១ រឿងទ្រង់អនុញ្ញាតផែនក្តារ ១ រឿងទ្រង់អនុញ្ញាតកៅអីមានទ្រនាប់ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សេនាសនក្ខន្ធកេ ឧទ្ទានគាថា

បលាសបីឋមេវ ច
ឧច្ចេ ច អហិ ចាតាធិ
អដ្ឋង្គុលកចាទកា(១)
សុត្តំ អដ្ឋបទំ ចោឡំ
តូលិកំ អឌ្ឍកាយិកំ
កិរគ្គា កិសិយោ ចាបិ
ទុស្សំ សេនាសនេ ច យំ(២)
ឱឆន្នំ ហេដ្ឋា បតតិ
ឧប្បាដេត្វា ហរន្តិ ច
ភិត្តិ ច ហត្ថភិត្តិ ច
អនុញ្ញាសិ ច តិត្ថិយា(៣)
សេតកាឡវិហារេ ចាបិ(៤)
ថុសំ សណ្ហញ្ច មត្តិកំ
ឥក្កាសំ ចាណកំ កុណ្ឌំ

១ ឧ.ម. ឧច្ចាហិ អតិបាទកា អដ្ឋង្គុលិ ច បាទកា ។ ២ ឧ.ម. សេនាសនញ្ចាបិ ។
៣ ឧ. ភិត្តិញ្ច ហត្ថភិត្តិញ្ច អនុញ្ញាសិ តថាគតោ ។ ៤ ឧ. ម. តិត្ថិយា វិហារេ ចាបិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកៈ ឧទ្ទានគាថា

រឿងទ្រង់អនុញ្ញាតតាំងញាត់បម្រើង ១ រឿងទ្រង់ហាមគ្រែខ្ពស់ហួសប្រមាណ ១ រឿងពស់ចឹកភិក្ខុ ទើបទ្រង់អនុញ្ញាតទ្រនាប់គ្រែ ១ រឿងទ្រង់អនុញ្ញាតទ្រនាប់ជើងគ្រែមានកំពស់៨ធ្នាប់ ១ រឿងទ្រង់អនុញ្ញាតអំបោះសម្រាប់គ្រែ ១ រឿងទ្រង់អនុញ្ញាតឲ្យបាក់ស្រែះគ្រែជាក្រឡាចត្រង្គ ១ រឿងទ្រង់អនុញ្ញាតសំពត់សម្រាប់ទ្រាប់គ្រែ ១ រឿងទ្រង់អនុញ្ញាតឲ្យកកាយវត្ថុដែលញាត់ដោយសំឡីយកមកធ្វើជាខ្នើយបាន ១ រឿងទ្រង់បញ្ញត្តខ្នើយកន្លះកាយ ១ រឿងមហោស្រពលើកំពូលភ្នំ ១ រឿងទ្រង់អនុញ្ញាតពូក ១ រឿងសំពត់សម្រាប់ប្រើប្រាស់ ក្នុងសេនា–សនៈ ១ រឿងទ្រង់អនុញ្ញាតគ្រែតាំងដែលញាត់ភ្ជាប់ គ្រឿងញាត់ ក៏លៀនចេញធ្លាក់មកខាងក្រោម ១ រឿងពួកចោរបកយកស្រោមពូកទៅ ១ រឿងទ្រង់អនុញ្ញាតឲ្យគូសដោយគំនូសផ្សេង ៗ ១ រឿងទ្រង់អនុញ្ញាតឲ្យផ្ដិតទឹងម្រាមដៃ ១ រឿងដំណេកពួកតិរ្ថិយ ១ រឿងទ្រង់អនុញ្ញាតឲ្យលាបវិហារ ដោយដីមានពណ៌សឬខ្មៅ ១ រឿងទ្រង់អនុញ្ញាតឲ្យលាយអង្កាមនឹងដីដែលម៉ដ្ឋ១ រឿងទ្រង់អនុញ្ញាតជ័រឈើ ១ រឿងទ្រង់អនុញ្ញាតដីលាយទឹកកុណ្ឌកហើយកៀសដោយខ្នៀស ១ រឿងទ្រង់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សាសបំ សិត្ថតេលកំ

ឧស្សេឡ្ហ បច្ចុទ្ធរិតុំ

ផរុសំ លណ្ឌុមត្តិកំ(១)

ឥក្កាសំ បដិកាណញ្ច

ឆីតា ចយោ ច អារុហិំ

បរិបតន្តិ អាឡកា

អឌ្ឍកុឌ្ឌំ តយោ បុន

ខុទ្ទកេ កុឌ្ឌចាណោ ច

ឱវស្សតិ ច វស្សុំ(២)

ថីលី ចីវរវំសោ ច(៣)

អាលិន្ទំ កិដិកេន ច

អាលម្ពនំ តិណចុណ្ណំ

---

១ ឱ. ម. គណ្ឌុមត្តិកំ ។ ២ ឱ. ម. ឱវស្សតិ សុរំ ទិសំ ។ ៣ ឱ. ម. ចីវរវំសំ រជ្ជុញ្ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុញ្ញាតមេព្រៅគ្រាប់ស្ពឺប្រេងលាយនឹងក្រមួន ១ រឿងទ្រង់អនុញ្ញាត ឲ្យយកកំណាត់សំពត់ជូតប្រេងដែលជោរឡើង ១ រឿងផ្ទៃជញ្ជាំងកាក្រក់ ១ រឿងទ្រង់អនុញ្ញាត ឲ្យលាយដីកាបម៌ជាខ្មៅ ១ រឿងទ្រង់អនុញ្ញាតដីឈើនឹងទឹកបត់ ១ រឿងទ្រង់បញ្ញត្តមិនឲ្យភិក្ខុ គូររូបស្រីប្រុស ១ រឿងទីវិហារទាប ទ្រង់អនុញ្ញាតឲ្យធ្វើខឿន (៣យ៉ាង) ១ រឿងទ្រង់អនុញ្ញាត ជណ្តើរ (៣យ៉ាង) ១ រឿងភិក្ខុធ្លាក់ពីលើជណ្តើរ ១ រឿងវិហារមានមនុស្សកុះករច្រើន ភិក្ខុមានខ្មាស មិនហ៊ានដេក ទើបទ្រង់អនុញ្ញាត ឲ្យធ្វើជញ្ជាំងគៀ ១ រឿងទ្រង់អនុញ្ញាតបន្ទប់ ៣ យ៉ាងទៀត ១ រឿងទ្រង់អនុញ្ញាត ឲ្យធ្វើបន្ទប់ក្នុងវិហារតូច ១ រឿងជើងជញ្ជាំងវិហារពុកផុយ ១ រឿងភ្លៀងសាចមកត្រូវជញ្ជាំង ១ រឿងភិក្ខុស្រែកខ្លាំង (ព្រោះខ្លាចពស់) ១ រឿងទ្រង់អនុញ្ញាតបម្រើងជញ្ជាំង នឹងដៃកែវ ១ រឿងទ្រង់អនុញ្ញាត ស្នួរចីវរនឹងខ្សែស្បៀង ១ រឿងទ្រង់អនុញ្ញាតឲ្យធ្វើរបៀងវិហារ ១ រឿងទ្រង់អនុញ្ញាតសំពត់រនាំងព្រួលសម្រាប់រូតចុះរូតឡើងបាន ១ រឿងទ្រង់អនុញ្ញាតបង្អាន់ដៃ ១ រឿងកំទេចបាយ (ជ្រុះក្នុងឧបដ្ឋានសាលា) ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកេ ឧទ្ទានគាថា

ហេដ្ឋាមញ្ចេ នយំ ការេ
អជ្ឈោកាសេ ចិតប្បតិ
សាលំ ហេដ្ឋា ច ភាជនំ
វិហារេ កោដ្ឋកោ ចេវ
បរិវេណគ្គិសាលកំ
អារាមេ ច បុនកោដ្ឋេ
ហេដ្ឋា ចេវ[១] នយំ ការេ
សុធំ[២] អដ្ឋបិណ្ឌិ ច
សន្ថោ សីតវំ អកា
និដ្ឋធម្មោ និមន្តសិ
សហ សវេជ្ជន នាយកំ
អាណាបេសន្តាមត្តេ
អាភមំ ការយិ គណោ
វេសាលិយំ នវកម្មំ
បុរតោ ច បរិគ្គហំ[៣]

---

១ ឱ. ម. ហេដ្ឋញ្ញេវ ។ ២ ឱ. ម. សុទ្ធំ ។ ៣ ឱ. ម. បដិគ្គហំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សេនាសនក្ខន្ធកៈ ឧទ្ទានគាថា

រឿងទ្រង់អនុញ្ញាតឲ្យពូនដីក្នុងទីទាប ១ រឿងភិក្ខុដាក់ទឹកឆាន់ក្នុងទីវាល (ទឹកក៏ក្តៅឆាន់មិនកើត) ទើបទ្រង់អនុញ្ញាតឲ្យធ្វើរោងដាក់ទឹក ១ រឿងភាជន៍សម្រាប់ដាក់ទឹកមិនទាន់មាន ១ រឿងវិហារមិនទាន់មានគ្រឿងបិទបាំង ១ រឿងទ្រង់អនុញ្ញាតបន្ទប់ ១ រឿងទ្រង់អនុញ្ញាតបរិវេណ ១ រឿងទ្រង់អនុញ្ញាតរោងភ្លើង ១ រឿងទ្រង់អនុញ្ញាតឲ្យពូនដីត្រង់ទីទាបក្នុងអារាម ១ រឿងទ្រង់អនុញ្ញាតក្លោងទ្វារជាដើម ១ (រឿងតទៅ) បណ្ឌិតគប្បីធ្វើន័យដូចពោលរួចហើយខាងក្រោយ រឿងអនាថបិណ្ឌិក. សេដ្ឋីមានសទ្ធាយល់ធម៌ច្បាស់លាស់ (ថ្ងៃមួយ) បានដើរទៅកាន់ព្រៃជាំ (ព្រៃត្រជាក់) ហើយនិមន្តព្រះសម្មាសម្ពុទ្ធជានាយក ព្រមទាំងភិក្ខុសង្ឃ (ដើម្បីឆាន់ក្នុងថ្ងៃស្អែក) បានបង្គាប់ទាសកម្មករ ឲ្យបាត់តែងភត្តក្នុងពាក់កណ្តាលផ្លូវ (លុះខាងក្រោយមក) បានឲ្យព្រួកជាងសាងវត្ត (បម្រុងព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន) ១ រឿង (មនុស្សទាំងឡាយធ្វើ) នវកម្មក្នុងនគរវេសាលី ១ រឿង (កូនសិស្សឆព្វគ្គិយភិក្ខុ) ដើរដេញទៅមុខភិក្ខុសង្ឃ ហើយហួងហែងសេនាសនៈ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កោ អរហតិ ភត្តគ្គំ(១)

តិត្តិរញ្ច អវន្ទិយា

បរិគ្គេភិត្តរឃរេ

តូលោ សាវត្ថិ ឱសរិ

បតិដ្ឋាបេសិ អារាមំ

ភត្តគ្គេ ច កោលាហលំ

តិណាណា វរសេយ្យា ច

លេសា សត្តរសា តហឹ

កោដ ធុ ទោ កាថំ ធុ ទោ

វិហារគ្គេន ភាជយិ

បរិវេណាធុភាគញ្ច

អកាមា ភាគ នោ ឧទេ

---

១ ឱ. ម. ភត្តគ្គេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿង (ព្រះអង្គត្រាស់សួរថា) នរណាគួរទទួលភត្តដ៏ប្រសើរជាដើម ១ រឿង (ស្វានឹងដំរី) និយាយនឹងសត្វទទា ១ រឿង (អវន្ទិយបុគ្គល)១ រឿង (ពួកសិស្សឆព្វគ្គិយភិក្ខុ) ហួងហែងសេនាសនៈរបស់សង្ឃ ១ រឿង (មនុស្សទាំងឡាយតាក់តែង) គ្រែតាំងដែលញាត់ដោយសំឡី ហើយទុកនៅក្នុងចន្លោះផ្ទះ ១ រឿងព្រះមានព្រះភាគ ស្តេចយាងសំដៅទៅក្រុងសាវត្ថី ១ រឿងអនាថបិណ្ឌិកគហបតិវេរអារាម (ចំពោះព្រះសង្ឃដែលមកអំពីទិសទាំងបួន) ១ រឿងកើតកោលាហលក្នុងពេលភត្ត ១ រឿង (ឆព្វគ្គិយភិក្ខុ) បណ្តេញភិក្ខុឈឺ ១ រឿង (ឆព្វគ្គិយភិក្ខុ) ដេកជាប់នឹងដំណេកដ៏ប្រសើរ ១ រឿងទ្រង់បញ្ញត្តមិនឲ្យហាមឃាត់សេនាសនៈដោយអាងលេស ១ រឿងសត្តរសវគ្គិយភិក្ខុ (ជួសជុលវិហារ) ក្នុងទីនោះៗ ១ រឿងភិក្ខុគិតគ្នាថា ភិក្ខុណាហ្ន៎ គួរប្រគល់សេនាសនៈ ១ រឿងសេនាសនគ្គាហាបកៈភិក្ខុគិតគ្នាថា យើងគួរប្រគល់សេនាសនៈដូចម្តេចហ្ន៎ ១ រឿងភិក្ខុប្រគល់សេនាសនៈតាមកំណត់វិហារ ១ រឿងទ្រង់អនុញ្ញាតឲ្យឲ្យបរិវេណ តាមចំណែកជាលំដាប់ បើមានភិក្ខុឯទៀតមកដល់ (បើលោក) មិនត្រូវការ ក៏មិនត្រូវឲ្យចំណែក ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកេ ខុទ្ទកគាថា

ឆិសដ្ឋឹ សត្តកាលញ្ច

កាយា សេនាសនេ តយោ

ឧបនន្ទោ ច វណ្ណាសិ

ឋិតកា សមហាសនា

សមានាសនិកា កិច្ចិសុ

តិវគ្គា ច ចុវគ្គិកា

អសមានាសនិកា ទីឃំ

សាលិន្ទំ បរិភុញ្ជិតុំ

អយ្យិកា ច អវិទូរេ

កាជិតញ្ច កាជាតិ

អាទ្យ្រំ បិណ្ឌកាកុដ្ឋេហិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកៈ ឧទ្ទានគាថា

រឿងទ្រង់បញ្ញត្តមិនឲ្យភិក្ខុប្រគល់សេនាសនៈ ដល់ភិក្ខុបិតនៅក្នុងទីឥតសីមា ១ រឿង (ទ្រង់បញ្ញត្តមិនឲ្យភិក្ខុហាមឃាត់) សេនាសនៈ អស់កាលទាំងពួង ១ រឿងភិក្ខុអ្នកប្រគល់សេនា-សនៈ៣ពួក ១ រឿងឧបនន្ទភិក្ខុ (ហួងហែងសេនាសនៈច្រើនកន្លែង) ១ រឿងព្រះសម្មាសម្ពុទ្ធទ្រង់សំដែងគុណនៃវិន័យ ១ រឿងព្រះថេរៈឈប់រៀនវិន័យ ទើបទ្រង់អនុញ្ញាតឲ្យអង្គុយលើអាសនៈស្មើគ្នា ១ រឿងភិក្ខុមានអាសនៈស្មើគ្នាអង្គុយលើគ្រែជាមួយគ្នាពាល់តែបាក់ ទើបទ្រង់អនុញ្ញាតឲ្យភិក្ខុ ៣ រូបខ្លះ ២ រូបខ្លះអង្គុយលើសេនាសនៈជាមួយគ្នាបាន ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុមានអាសនៈមិនស្មើគ្នាអង្គុយលើអាសនៈវែងជាមួយគ្នាបាន ១ រឿងទ្រង់អនុញ្ញាតឲ្យប្រើប្រាស់ប្រាសាទមានរបៀង ១ រឿងព្រះអយ្យិកា (នៃព្រះបាទបសេនទិកោសលសុគត) ១ (រឿងអាវាសិកភិក្ខុនៅក្នុងអាវាសជិតស្រុកតូចមួយ) ក្នុងទីមិនឆ្ងាយ (ពីក្រុងសាវត្ថី) ១ រឿងភិក្ខុចែកសេនាសនៈរបស់សង្ឃ ១ រឿងព្រះមានព្រះភាគ ស្តេចយាងទៅកាន់កិដាគិរិជនបទ ១ រឿងព្រះមានព្រះភាគស្តេចយាងទៅកាន់ដែនអាឡវី ១ រឿងភិក្ខុឲ្យនវកម្ម ដោយគ្រាន់តែទុកដាក់ដុំដីឬបាយអណាបជញ្ជាំង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទ្វារំ អគ្គឡវដ្ដិកា
អាលោកសេតកាឡញ្ច
គេរុក្ខា ធនពន្ធនា
កណ្ឌំ ខណ្ឌា បរិកណ្ឌំ
វីស តីសា ច កាលិកា
ទ្វិសិនេ អកាតំ វិប្បំ
ខុទ្ទេ ជប្បញ្ច វស្សិកំ
អឌ្ឍយោគេ ច សត្តដ្ឋ
មហល្លកេ ទស ទ្វាទស
សព្វំ វិហារំ ឯកស្ស
អញ្ញាភាសេន្តិ សង្ឃិកំ
ធំស្សេមិ សព្វកាលញ្ច
បក្កាម វិព្ភមន្តិ ច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដំកល់សន្ទះទ្វារ សសរមេទ្វារ ធ្វើបង្អួច ធ្វើឲ្យមានពណ៌ស ឲ្យមានពណ៌ខ្មៅ ធ្វើឲ្យជិតស្និទ្ធដោយបិទដីរេគ្គដោយបិទបាំង ដោយគ្រាន់តែបិទបាំងទីអាស្រ័យនៅនៃសត្វព្រាប ជួសជុលត្រង់កន្លែងដែលដាច់ ឲ្យនវកម្មអស់ ២០ ឆ្នាំខ្លះ ៣០ ខ្លះ ឲ្យនវកម្មចំពោះវិហារ ដែលខ្លួនអបលោកឲ្យក្នុងកាលមានផ្សែងខ្លះ ១ រឿងទ្រង់អនុញ្ញាតឲ្យឲ្យនវកម្ម ចំពោះវិហារដែលមិនទាន់ធ្វើឬធ្វើមិនទាន់ហើយ បើវិហារតូចទ្រង់អនុញ្ញាតឲ្យត្រួតមើលការងារហើយសឹមឲ្យនវកម្មត្រឹម ៦ ឆ្នាំឬ ៥ ឆ្នាំបាន បើអឌ្ឍយោគទ្រង់អនុញ្ញាតឲ្យឲ្យនវកម្មត្រឹម ៧ ឆ្នាំឬ ៨ ឆ្នាំបាន បើវិហារធំទ្រង់អនុញ្ញាតឲ្យឲ្យនវកម្មត្រឹម ១០ ឆ្នាំឬ ១២ ឆ្នាំបាន ១ រឿងភិក្ខុឲ្យនវកម្ម ចំពោះវិហារទាំងអស់ ១ រឿងភិក្ខុឲ្យនវកម្មពីរកន្លែងដល់ភិក្ខុមួយរូប ១ រឿងភិក្ខុទទួលនវកម្មក្នុងវិហាររបស់សង្ឃ ហើយប្រើឲ្យភិក្ខុឯទៀតនៅ ១ រឿងភិក្ខុហាមឃាត់សេនាសនៈរបស់សង្ឃ ១ រឿងទ្រង់បញ្ញត្តមិនឲ្យឲ្យនវកម្មដល់ភិក្ខុ ដែលនៅក្នុងទីឥតសីមា ១ រឿងទ្រង់បញ្ញត្តមិនឲ្យហាមឃាត់ (សេនាសនៈ) អស់កាលទាំងពួង ១ រឿងភិក្ខុទទួលយកនវកម្ម ហើយចៀសចេញទៅខ្លះ សឹកខ្លះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សេនាសនក្ខន្ធកេ ឧទ្ទានគាថា

កាលញ្ច សាមណេរញ្ច
សិក្ខាបច្ចក្ខាអន្តិមំ
ឧម្មត្តកា ខិត្តចិត្តា
វេទនាបត្តិទស្សនា
អប្បដិកម្មំ ទិដ្ឋិយា
បណ្ឌកា ថេយ្យតិត្ថិយា
តិរច្ឆានមាតុបិតុ
អរហន្តា ច ទូសកា
ភេទកា លោហិតុប្បាទា
ឧភតោ ចាបិ ព្យញ្ជនា
មា សង្ឃស្ស បរិហាយិ
កម្មំ អញ្ញស្ស ទាតវេ
វិប្បកតេ ច អញ្ញស្ស
កតេ នស្សេវ បក្កមេ
វិព្ភមតិ កាលកតោ
សាមណេភេ ច ជាយតិ
បច្ចក្ខាតោ ច សិក្ខាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ស្លាប់ខ្លះ បេក្ខជាជាសាមណេរខ្លះ ជាអ្នកលាសិក្ខាខ្លះ ជាអ្នកត្រូវអន្តិមវត្ថុខ្លះ ជាមនុស្សឆ្កួតខ្លះ ជាអ្នកមានចិត្តរាយមាយខ្លះ ជាអ្នកត្រូវទុក្ខវេទនាគ្របសង្កត់ខ្លះ ជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិខ្លះ ព្រោះមិនសំដែងអាបត្តិខ្លះ ព្រោះមិនលះបង់ទិដ្ឋិខ្លះ ជាមនុស្សខ្ទើយខ្លះ ជាមនុស្សលួចសំវាសខ្លះ ជាមនុស្សចូលលទ្ធិតិរ្ថិយខ្លះ ជាតិរច្ឆានខ្លះ ជាមនុស្សសម្លាប់មាតាខ្លះ ជាមនុស្សសម្លាប់បិតាខ្លះ ជាមនុស្សសម្លាប់ព្រះអរហន្តខ្លះ ជាមនុស្សប្រទូស្តភិក្ខុនីខ្លះ ជាមនុស្សបំបែកសង្ឃខ្លះ ជាមនុស្សធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុរពងខ្លះ ជាមនុស្សមានភេទពីរខ្លះ ១ រឿងភិក្ខុឲ្យនវកម្មដល់ភិក្ខុដទៃដោយគិតថាសូមកុំឲ្យនវកម្មរបស់សង្ឃវិនាស ១ រឿងភិក្ខុធ្វើនវកម្មមិនទាន់ហើយ ១ ប្រគល់ឲ្យដល់ភិក្ខុដទៃ ១ រឿងភិក្ខុនោះធ្វើនវកម្មហើយចៀសចេញទៅខ្លះ សឹកចេញទៅខ្លះ ស្លាប់ទៅខ្លះ បេក្ខជាជាសាមណេរខ្លះ ជាអ្នកលាសិក្ខាខ្លះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អន្តិមជ្ឈាបន្នោ យំ
សង្ឃោ វ សាមិកោ ហោតិ
ឧម្មត្តចិត្តវេទនា
អទស្សនាបដិកម្មេ
ទិដ្ឋិ តស្សេវ ហោតិ តំ
បណ្ឌកោ ថេយ្យតិត្ថី ច
តិរច្ឆានមាតុបេតិកំ
ឃាតកោ ទូសកោ ចាបិ
ភេទលោហិតុប្បាទកា
បដិជានាតិ យេន សោ
សង្ឃោ វ ហោតិ សាមិកោ
ហារន្តញ្ញត្រ កុក្កុច្ចំ
ឧទ្រិយតិ ច កម្មលំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ជាអ្នកត្រូវអន្តិមវត្ថុខ្លះ សង្ឃត្រូវជាម្ចាស់ (នវកម្មនោះ) ១ ភិក្ខុធ្វើនវកម្មរួចស្រេចហើយប្តូរជាជាមនុស្សឆ្កួតខ្លះ ជាមនុស្សមានចិត្តរាយមាយខ្លះ ជាអ្នកត្រូវទុក្ខវេទនា គ្របសង្កត់ខ្លះ ឬជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិខ្លះ ព្រោះមិនបំផែងអាបត្តិខ្លះ ព្រោះមិនលះបង់ទិដ្ឋិខ្លះ នវកម្មនោះជារបស់ភិក្ខុនោះឯង ១ ភិក្ខុធ្វើនវកម្មរួចស្រេចហើយ ឬបើភិក្ខុនោះប្តូរជាខ្លួនជាមនុស្សខ្ទើយខ្លះ ជាអ្នកលួចសំវាសខ្លះ ជាមនុស្សចូលកាន់លទ្ធិតិរ្ថិយខ្លះ ប្តូរជាសត្វតិរច្ឆានខ្លះ ជាអ្នកសម្លាប់មាតាខ្លះ ជាអ្នកសម្លាប់បិតាខ្លះ ជាអ្នកសម្លាប់ព្រះអរហន្តខ្លះ ជាអ្នកប្រទូស្តភិក្ខុនីខ្លះ ជាអ្នកបំបែកសង្ឃខ្លះ ជាអ្នកធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុរពងខ្លះ ជាអ្នកមានភេទពីរខ្លះ សង្ឃត្រូវជាម្ចាស់ (នវកម្មនោះ)១ រឿងភិក្ខុនាំយកសេនាសនៈ (របស់គ្រហស្ថដែលគេឧទ្ទិសជាគ្រឿងសម្រាប់ប្រើប្រាស់ក្នុងវិហារ) ទៅប្រើប្រាស់ក្នុងទីដទៃ ១ រឿងភិក្ខុមានសេចក្តីសង្ស័យ ១ រឿងវិហារទ្រុឌទ្រោម ១ រឿងសំពត់កម្ពលកើតឡើងដល់សង្ឃ ១ រឿងសំពត់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកេ ឧទ្ទានគាថា

ធុស្សា ច ចម្មចក្កលិ

ចោឡកំ អក្កមន្តិ ច

អល្លា ឧចាហាណា ធុដ្ឋ(១)

លិខន្តិ អបស្សេន្តិ ច

អបស្សេនំ លិខតោ(២)

ដោតិ បច្ចត្ថរេន ច

ភជកហោ ន សក្កោន្តិ

លាមកំ កត្តុ ធ្វេសកំ

គាថំ ធុ ចោ បញ្ញាបកំ

កណ្ឋាគារកសម្មតិ

---

១ ឱ. ម. ធុដ្ឋ វិលក្ខិ ។ ២ ឱ.ម. វលិតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាសនក្ខន្ធកៈ ឧទ្ទានគាថា

មានថ្ងៃច្រើនកើតឡើងដល់សង្ឃ ១ រឿងស្បែកខ្លាឃ្មុំកើតឡើងដល់សង្ឃ ១ រឿងខ្សែដែលគេវេញឲ្យមានសណ្ឋានដូចជាកង់កើតឡើងដល់សង្ឃ ១ រឿងកំណាត់សំពត់កើតឡើងដល់សង្ឃ ១ រឿងភិក្ខុមិនលាងជើងដើរជាន់ (សេនាសនៈ) ១ រឿងភិក្ខុជើងទទឹកដើរជាន់សេនាសនៈ ១ រឿងភិក្ខុពាក់ស្បែកជើង(ដើរជាន់សេនាសនៈ) ១ រឿងភិក្ខុស្តោះទឹកមាត់ដាក់(លើទីវិចិត្រល្អ) ១ រឿងជើងគ្រែកោសជាប់ទីផ្ទៃ ១ រឿងភិក្ខុផ្អែក (ទីងជញ្ជាំង) ១ រឿងទ្រង់អនុញ្ញាតផែនក្តារសម្រាប់ផ្អែក ១ រឿងផែនក្តារសម្រាប់ផ្អែកកោសជាប់ទីផ្ទៃ ១ រឿងភិក្ខុមានជើងលាងរួចហើយ (តែមិនហ៊ានដេក) ទ្រង់អនុញ្ញាតឲ្យក្រាលកម្រាលសិន (សឹមដេក) ១ រឿងក្រុងរាជគ្រឹះ (កើតទុរ្ភិក្ស) មនុស្សទាំងឡាយ (ចង់ធ្វើសង្ឃភត្ត) តែមិនអាចនឹងធ្វើបាន ១ រឿងឆព្វគ្គិយភិក្ខុទទួលភត្តថ្លៃថ្លា បម្រុងខ្លួនឯង ហើយឲ្យភត្តមិនថ្លៃថ្លាដល់ភិក្ខុដទៃ ១ រឿងទ្រង់អនុញ្ញាតឲ្យសន្មតភត្តុទ្ទេ-សកភិក្ខុ ១ រឿងភត្តុទ្ទេសកភិក្ខុមានសេចក្តីសង្ស័យថាធ្វើដូចម្តេចហ្ន៎ ១ រឿងមិនទាន់មានភិក្ខុអ្នកចាត់ចែងសេនាសនៈបម្រុងសង្ឃ ១ រឿងសន្មតភិក្ខុឲ្យជាអ្នករក្សាឃ្លាំង ១ រឿងសន្មត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បដិគ្គាហភាជកោ ចាបិ
យាគុ ច ផលភាជកោ
ខជ្ជកភាជកោ ចេវ
អប្បមត្តកវិស្សជេ
សាដិយគ្គាហាបកោ ចេវ
តថា បត្តគ្គាហាបកោ(១)
អារាមិកសាមណេរ
បេសកស្ស ច សម្មុតិ
សព្វាកិណ្ណំ លោកវិទូ
ហិតចិត្តោ វិនាយកោ
លេណត្ថញ្ច សុខត្ថញ្ច
ឈាយិតុញ្ច វិបស្សិតុំ ។

---

១ ឱ. ម. តថេវ បត្តគ្គាហកោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុឲ្យជាអ្នកទទួល (ចីវរ) ទុក ១ រឿងទ្រង់អនុញ្ញាត ឲ្យជាអ្នកចែកបបរ ១ ឲ្យជាអ្នកចែកផ្លែឈើ ១ ឲ្យជាអ្នកចែកបង្អែម ១ ឲ្យជាអ្នកចាត់ចែងបរិក្ខារតិចតួច ១ ឲ្យជាអ្នកប្រគល់សំពត់ ១ ឲ្យជាអ្នកប្រគល់បាត្រ ១ រឿងសន្មតភិក្ខុឲ្យជាអ្នកប្រើញាមវត្តទីនសាមណេរ ១ រឿងព្រះសម្មាសម្ពុទ្ធ ជាវិនាយក ព្រះអង្គមានព្រះហឫទ័យប្រាថ្នានូវប្រយោជន៍ (ដល់សត្វ) ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ត្រួតសង្កត់ជនទាំងពួង (ទ្រង់អនុញ្ញាតសេនាសនៈដូចបានថ្លែងមកនេះ) ដើម្បីជ្រកកោនផង ដើម្បីនៅជាសុខសប្បាយផង ដើម្បីជុតបង់[១] (នូវអកុសលធម៌) ផង ដើម្បីពិចារណា នូវសង្ខារ[២]ផង ។

---

១ ចំរើនសមថកម្មដ្ឋាន ៤០ ប្រភេទ ។ ២ ចំរើនវិបស្សនា ១០ យ៉ាង ។

*ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ*
*ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។*

# សន្លឹកចង្អុលប្រាប់មាតិកា

## ទុតិយភាគ

លេខទំព័រ

### *សមថក្ខន្ធកៈ*


រឿងពួកឆព្វគ្គិយភិក្ខុធ្វើកម្មមានតជ្ជនីយកម្មជាដើម មិនមានក្នុងទីចំពោះមុខ . . . ១
បុគ្គលជាអធម្មវាទីនឹងបុគ្គលជាធម្មវាទី . . . . . . . . ៣
សង្ឃជាអធម្មវាទីនឹងសង្ឃជាធម្មវាទី. . . . . . . . ៥
ភិក្ខុទាំងឡាយច្រើនជាធម្មវាទី នឹងសង្ឃជាអធម្មវាទី . . . . . . ៧
និទានព្រះទព្វមល្លបុត្ត . . . . . . . . . . ៩
សេចក្តីសន្មតិនូវការចាត់ចែងសេនាសនៈជាដើម . . . . . . ១១
និទានព្រះទព្វមល្លបុត្ត . . . . . . . . . . ១២
និទានមេត្តិយភុម្មជកភិក្ខុ . . . . . . . . . . ១៥
ការសូមសតិវិន័យ . . . . . . . . . . . ២៤
និទានគគ្គភិក្ខុ. . . . . . . . . . . ២៧
ការសូមអមូឡ្ហវិន័យ . . . . . . . . . . . ២៨
ការឲ្យអមូឡ្ហវិន័យ . . . . . . . . . . . ៣០
ការឲ្យអមូឡ្ហវិន័យមិនប្រកបដោយធម៌មាន ៣ យ៉ាង . . . . . . ៣៣
ការឲ្យអមូឡ្ហវិន័យប្រកបដោយធម៌មាន ៣ យ៉ាង . . . . . . . ៣៤
រឿងពួកឆព្វគ្គិយភិក្ខុធ្វើកម្មទាំងឡាយ ដល់ពួកភិក្ខុមិនតាមពាក្យប្តេជ្ញា . . . ៣៦
ការធ្វើតាមពាក្យប្តេជ្ញាមិនប្រកបដោយធម៌ . . . . . . . ៣៧
ភិក្ខុប្រកបដោយអង្គ ៥ ជាអ្នកចាត់ចែងឲ្យគេចាប់ស្លាក . . . . . ៤១
ការឲ្យចាប់ស្លាកដែលប្រកបដោយធម៌មាន ១០ យ៉ាង . . . . . ៤៣
ការធ្វើតស្សបាបិយសិកាកម្មដល់ឧបវាឡភិក្ខុ. . . . . . . ៤៥
តស្សបាបិយសិកាកម្ម ដែលជាកម្មមិនប្រកបដោយធម៌វិន័យ . . . . ៤៦

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# សព្វនាមចង្អុលប្រាប់មាតិកា

| | លេខទំព័រ |
|---|---|
| គស្សបាបិយសិកាកម្ម ដែលជាកម្មប្រកបដោយធម៌វិន័យ . . . . . | ៤៧ |
| ការធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុ ៣ ពួក . . . . . . . | ៤៩ |
| ការរម្ងាប់(អធិករណ៍ )ដោយតិណវត្ថារកសមថៈ . . . . . | ៥១ |
| ការសំដែង ( អាបត្តិ ) ដោយតិណវត្ថារកសមថៈ . . . . . | ៥២ |
| អធិករណ៍ ៤ យ៉ាង . . . . . . . . . . | ៥៩ |
| មូលនៃវិវាទាធិករណ៍ . . . . . . . . . | ៦១ |
| មូលនៃអនុវាទាធិករណ៍ . . . . . . . . | ៦៥ |
| វិវាទាធិករណ៍ជាកុសលក៏មាន ជាអកុសលក៏មាន . . . . . | ៧១ |
| អនុវាទាធិករណ៍ជាកុសល ជាអកុសល ជាអព្យាកតៈ. . . . . | ៧២ |
| កិច្ចាធិករណ៍ជាកុសល ជាអកុសល ជាអព្យាកតៈ . . . . . | ៧៥ |
| ការចោទចាត់ជាអនុវាទាធិករណ៍ . . . . . . . | ៧៦ |
| អាបត្តិចាត់ជាអាបត្តាធិករណ៍ . . . . . . . . | ៧៨ |
| កិច្ចចាត់ជាកិច្ចាធិករណ៍ . . . . . . . . | ៧៩ |
| វិវាទាធិករណ៍រម្ងាប់ ដោយសមថៈ ២ យ៉ាង . . . . . . | ៨០ |
| ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ . . . . . . . | ៨១ |
| អធិករណ៍រម្ងាប់ . . . . . . . . . . | ៨៥ |
| ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ . . . . . . . | ៨៧ |
| ការសន្មតិភិក្ខុដែលប្រកប ដោយអង្គ ១០ ដោយឧព្វាហិកាកម្ម . . . | ៨៩ |
| ធម្មកថិកមិនចាំសុត្តៈ មិនចាំសុត្តវិភង្គ . . . . . . | ៩០ |
| ការប្រគល់អធិករណ៍ដល់សង្ឃ . . . . . . . | ៩៣ |
| អធិករណ៍កើតឡើងក្នុងក្រុងសាវត្ថី . . . . . . . | ៩៥ |
| ពួកភិក្ខុមិនត្រេកអរដោយរម្ងាប់អធិករណ៍ . . . . . . | ៩៧ |
| ការចាប់ស្លាកឈ្មោះសកណ្ណជប្បកៈ . . . . . . . | ៩៩ |
| អនុវាទាធិករណ៍រម្ងាប់ដោយសមថៈ ៤ យ៉ាង . . . . . . | ១០០ |
| ការឲ្យសតិវិន័យដល់ភិក្ខុ ជាអ្នកមានសតិពេញបរិបូណ៌ . . . . | ១០១ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សន្លឹកបញ្ជីប្រាប់មាតិកា 

លេខទំព័រ

ភិក្ខុច្ឆន្នមានចិត្តវិបល្លាសប្រែប្រួល . . . . . . . . ១០៣
ការឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុបាត់វង្វេងហើយ. . . . . . ១០៤
អនុវាទាធិករណ៍មិនបាច់អាស្រ័យសមថៈ ២ យ៉ាង . . . . . ១០៧
ការធ្វើតស្សបាបិយសិកាកម្ម . . . . . . . . ១០៩
អាបត្តាធិករណ៍រម្ងាប់ ដោយសមថៈ ៣ យ៉ាង. . . . . . ១១១
កិច្ចនៃបដិញ្ញាតករណកម្ម . . . . . . . . ១១៣
ការសំដែងអាបត្តិ . . . . . . . . . ១១៥
អាបត្តាធិករណ៍មិនបាច់អាស្រ័យសមថៈ ១ . . . . . . ១១៦
ការរម្ងាប់អធិករណ៍ ដោយតិណវត្ថារកៈកណ្តាលជំនុំសង្ឃ. . . . ៤
ការសំដែងដោយតិណវត្ថារកៈកណ្តាលជំនុំសង្ឃ . . . . . ១១៨
ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ . . . . . . ១២១

## ខុទ្ទកវត្ថុក្ខន្ធកៈ

រឿងពួកឆព្វគ្គិយភិក្ខុនាំគ្នាងូតទឹក . . . . . . . ១២៣
រឿងឆព្វគ្គិយភិក្ខុ នហានវត្ត . . . . . . . . ១២៥
រឿងភិក្ខុចាស់ជរាកំឡាំងថយ នហានវត្ត . . . . . . ១២៩
រឿងឆព្វគ្គិយភិក្ខុ ការសិតសក់ដោយស្និតជាដើម . . . . . ១៣១
រឿងឆព្វគ្គិយភិក្ខុ ការដាត់មុខជាដើម . . . . . . . ១៣៣
ទោស ៥ ប្រការនៃការច្រៀងធម៌ ដោយសម្លេងច្រៀងដ៏វែង . . . ១៣៥
ព្រះបាទពិម្ពិសារទ្រង់មានសេចក្តីត្រូវការ ដោយផ្ទៃក្ពាយ . . . . ១៣៦
រឿងអញ្ញតរភិក្ខុ ត្រកូលស្តេចពស់ ៤ ត្រកូល . . . . . ១៣៩
រឿងអញ្ញតរភិក្ខុ កិរិយាកាត់អង្គជាត . . . . . . . ១៤១
រឿងគ្រូ ៦ នាក់ បាត្រពពកចន្ទន៍ . . . . . . . ១៤៣
រឿងព្រះបិណ្ឌោលភារទ្វាជត្ថេរ . . . . . . . ១៤៥

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



# សន្លឹកបញ្ជីសម្រាប់មាតិកា

លេខទំព័រ

និយាយអំពីបាត្រ រឿងឆព្វគ្គិយភិក្ខុ . . . . . . . . ១៤៧
រឿងភិក្ខុច្រើនរូប និយាយអំពីបាត្រ . . . . . . . . ១៥១
ការហែកចីវរដោយដៃ និយាយអំពីចីវរ . . . . . . ១៥៣
ការដឹកដាំបង្គោល និយាយអំពីចីវរ . . . . . . . ១៥៩
ពួកភិក្ខុពាក់ស្បែកជើង ដើរជាន់ឈើស្តឹង និយាយអំពីស្នាប់ម្រាមដៃ . . ១៦១
ការទ្រង់អនុញ្ញាតរោងសម្រាប់ដាក់ឈើស្តឹង និងបាវសម្រាប់ដាក់ឈើស្តឹងជាដើម. ១៦៣
ការទ្រង់អនុញ្ញាតខ្សែយោគនឹងខ្សែសម្រាប់ចង . . . . . ១៦៥
រឿងអនុញ្ញាតសំពត់ត្រងទឹក . . . . . . . ១៦៦
ភិក្ខុ ២ រូបនាំគ្នាដើរទៅកាន់ផ្លូវឆ្ងាយ . . . . . . . ១៦៧
ការទ្រង់អនុញ្ញាតមុង . . . , . . . . . ១៦៩
ការទ្រង់អនុញ្ញាតដំណើរ ៣ យ៉ាង . . . . . . . ១៧១
ការទ្រង់អនុញ្ញាតប្រហោង សម្រាប់បង្ហុយផ្សែងជាដើម . . . . ១៧៣
ការទ្រង់អនុញ្ញាតទឿង ៣ យ៉ាងជាដើម . . . . . . ១៧៥
ការទ្រង់អនុញ្ញាតខ្សែស្នួរចីវរ នឹងខ្សែស្ទៀងចីវរជាដើម . . . . ១៧៧
ការទ្រង់អនុញ្ញាត ( ឡ្យធ្វើ ) បង្កាន់ដៃជាដើម . . . . . ១៧៩
ការទ្រង់អនុញ្ញាតវត្ថុមានសំពត់សម្រាប់ងូតទឹកជាដើម . . . . ១៨១
ទីមានដំណេកដែលគេរាយរាយដោយផ្កាជាដើម . . . . . ១៨៣
កិច្ចមានបរិភោគក្នុងភាជនៈជាមួយគ្នាជាដើម នឹងរឿងវឌ្ឍលិច្ឆវី . . . ១៨៥
រឿងវឌ្ឍលិច្ឆវី នឹងរឿងមេត្តិយភុម្មជកភិក្ខុ . . . . . , ១៨៦
ការផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី . . . . . . . . ១៨៩
មិត្តអមាត្យនឹងញាតិសាលោហិតរបស់វឌ្ឍលិច្ឆវី . . . . . ១៩១
ការផ្ងារបាត្រឡើងវិញ . . . . . . . . ១៩៣
រឿងព្រះពោធិរាជកុមារ . . . . . . . . ១៩៥
ព្រះមានព្រះភាគយាងទៅកាន់ព្រះរាជនិវេសន៍ របស់ព្រះពោធិរាជកុមារ . . ១៩៧

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# សន្ទិកាបផ្អុលទ្រាប់មាតិកា


| | លេខទំព័រ |
|---|---|
| កម្រាលសំពត់នឹងរឿងស្រីម្នាក់ | ១៩៩ |
| ក្អម អម្បោសនឹងរឿងនាងវិសាខាមិគារមាតា | ២០១ |
| ការទ្រង់អនុញ្ញាតផ្តិត ៤ ជ្រុងនឹងផ្តិតមូល (ផ្តិតស្លឹកឈោត) ជាដើម | ២០៣ |
| រឿងភិក្ខុ ១ រូប នឹងការទ្រង់អនុញ្ញាតឆត្រ | ២០៥ |
| រឿងភិក្ខុ ១ រូបច្រកបាត្រក្នុងស្បែកនឹងភិក្ខុ ១ រូបមានជម្ងឺ | ២០៦ |
| ការស្ងួមនឹងការឲ្យទណ្ឌសម្មតិ | ២០៧ |
| ការឲ្យសិក្កាសម្មតិ | ២០៩ |
| ការឲ្យទណ្ឌសិក្កាសម្មតិ នឹងរឿងភិក្ខុទំពាអៀង | ២១០ |
| រឿងភិក្ខុ ១ រូបនឹងរឿងស្រីម្នាក់ | ២១៣ |
| ការទ្រង់អនុញ្ញាតឲ្យភិក្ខុកាត់ក្រចកត្រឹមនឹងសាច់ | ២១៤ |
| ការទ្រង់អនុញ្ញាតគ្រឿងប្រដាប់សម្រាប់កោរ មានកំបិតកោរជាដើម | ២១៥ |
| ការឲ្យកាត់សក់ដោយកន្ត្រៃ នឹងការទ្រង់អនុញ្ញាតសណ្ដាស | ២១៧ |
| គ្រឿងលោហៈ គ្រឿងសម្រិទ្ធ នឹងការទ្រង់អនុញ្ញាតបំពង់ថ្នាំភ្នែកជាដើម | ២១៩ |
| ការទ្រង់អនុញ្ញាតកាយពន្ធ (វត្ថពន្ធចង្កេះ) | ២២១ |
| ការទ្រង់អនុញ្ញាតក្រវិលឡេវ អន្ទាក់ឡេវ | ២២២ |
| ភិក្ខុស្លៀកស្បង់ដូចសម្លៀកគ្រហស្ថ ជិណ្ណាប់ដូចគ្រហស្ថ | ២២៤ |
| អានិសង្ស ៥ ប្រការក្នុងការទំពាឈើស្ទន់ នឹងរឿងឆព្វគ្គិយភិក្ខុ | ២២៦ |
| ការឡើងដើមឈើ | ២២៩ |
| រឿងភិក្ខុ ២ រូបជាបងប្អូននឹងគ្នា នាំគ្នាទៅគាល់ព្រះមានព្រះភាគ | ២៣០ |
| ការរៀនគម្ពីរលោកាយតៈ | ២៣១ |
| រឿងព្រះមានព្រះភាគទ្រង់កណ្ដាស់ | ២៣៣ |
| ការទ្រង់អនុញ្ញាតខ្ទឹមនឹងការបន្ទោបង់បស្សាវៈ | ២៣៥ |
| ការទ្រង់អនុញ្ញាតឲ្យភិក្ខុធ្វើទីដីឲ្យខ្ពស់ឡើងជាដើម | ២៣៦ |
| ការទ្រង់អនុញ្ញាតវត្ថុសម្រាប់គោងជាដើម | ២៣៩ |
| រឿងឆព្វគ្គិយភិក្ខុនឹងអនាចារមានប្រការផ្សេង ៗ | ២៤១ |
| ឧទ្ទានគាថា នៃខុទ្ទកវត្ថុក្ខន្ធកៈ | ២៤៥ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# សន្លឹកចង្អុលប្រាប់មាតិកា

លេខទំព័រ

## សេនាសនក្ខន្ធកៈ


រឿងរាជគហសេដ្ឋី . . . . . . . . . . ២៥៩
ការទ្រង់អនុញ្ញាតសេនាសនៈ ៥ យ៉ាងនឹងរឿងរាជគហសេដ្ឋី . . . . ២៦១
គាថាសម្រាប់អនុមោទនាសេនាសនៈ . . . . . . . . ២៦៣
ការទ្រង់អនុញ្ញាតសន្ទុះទ្វារជាដើម . . . . . . . . ២៦៥
ការទ្រង់អនុញ្ញាតបង្អួច ៣ យ៉ាងជាដើម . . . . . . . ២៦៧
ការទ្រង់អនុញ្ញាតតាំង ដែលគេបង្ហាំជើងជាប់នឹងមេតាំងជាដើម . . . ២៦៩
ការទ្រង់អនុញ្ញាតតាំងបាក់ផ្ដៅជាដើម . . . . . . . . ២៧១
ការទ្រង់អនុញ្ញាតទ្រនាប់គ្រែជាដើម . . . . . . . . ២៧៣
ការទ្រង់អនុញ្ញាតពូកទាំងឡាយ មានពូកញាត់រោមកែះជាដើម . . . ២៧៥
ការទ្រង់អនុញ្ញាតដីរឈើនឹងបាយម៉ានជាដើម . . . . . . ២៧៧
ការទ្រង់អនុញ្ញាតគំនូរភ្ញីផ្កាជាដើម . . . . . . . . ២៧៩
ការទ្រង់អនុញ្ញាតពិតានជាដើម . . . . . . . . ២៨១
ការទ្រង់អនុញ្ញាតជណ្ដើរឥដ្ឋជាដើម . . . . . . . . ២៨៣
ការទ្រង់អនុញ្ញាតសន្ទុះទ្វារជាដើម . . . . . . . . ២៨៥
ការទ្រង់អនុញ្ញាតញ៉ាំពណ៌សជាដើម . . . . . . . . ២៨៧
រឿងអនាថបិណ្ឌិកសេដ្ឋីនឹងរឿងរាជគហសេដ្ឋី. . . . . . ២៨៩
សីលវិកគាថា . . . . . . . . . . ២៩៣
អនុបុព្វីកថា . . . . . . . . . . ២៩៥
ធម្មចក្ខុ . . . . . . . . . . ២៩៧
ការថ្វាយភត្ត . . . . . . . . . . ២៩៩
រឿងអនាថបិណ្ឌិកគហបតីនឹងវត្តព្រះជេតពន . . . . . . ៣០១
ការធ្វើនវកម្មនឹងរឿងដាងផ្ទុលឬជើរ . . . . . . . ៣០៥
ការឲ្យនវកម្មនឹងពួកអន្តេវាសិករបស់ឆព្វគ្គិយភិក្ខុ . . . . . ៣០៧
អាសនៈប្រសើរ ទឹកប្រសើរ នឹងដុំបាយប្រសើរ . . . . . ៣០៩

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លេខទំព័រ

រឿងសត្វជាសំឡាញ់នឹងគ្នា ៣ តួ . . . . . . . ៣១១
ការរកថា . . . . . . . . . . ៣១៣
អវន្ទិយបុគ្គលមាន ១០ ពួក . . . . . . . ៣១៤
វន្ទិយបុគ្គលមាន ៣ ពួក . . . . . . . . ៣១៥
វត្ថុដែលគេធ្វើឧទ្ទិសដល់សង្ឃ . . . . . . . 〃
អាសនៈខ្ពស់នឹងអាសនៈប្រសើរ . . . . . . . ៣១៧
ការក្រាយវត្ថុព្រះជេតពន . . . . . . . . ៣១៩
កថានៃវិហារទាន . . . . . . . . . ៣២១
ការបណ្តេញភិក្ខុដែលកំពុងឆាន់ មិនទាន់លែងឲ្យក្រោកចេញ . . . ៣២៣
រឿងឆព្វគ្គិយភិក្ខុ . . . . . . . . . ៣២៥
រឿងសត្តរសវគ្គិយភិក្ខុ . . . . . . . . . ៣២៦
ការសន្មតិសេនាសនគ្គាហាបកភិក្ខុ . . . . . . . ៣២៨
ការប្រគល់សេនាសនៈមាន ៣ យ៉ាង នឹងរឿងឧបនន្ទភិក្ខុ . . . . ៣៣១
ការហួងហែងសេនាសនៈមាន ២ យ៉ាង នឹងការសំដែងវិន័យ . . . ៣៣៣
ការទ្រង់អនុញ្ញាតឲ្យភិក្ខុអង្គុយ ជាមួយនឹងភិក្ខុមានវស្សាវាង ៣ ជាដើម . . ៣៣៥
រឿងព្រះអយ្យិការបស់ព្រះបាទបសេនទិកោសល . . . . . ៣៣៧
របស់ដែលភិក្ខុលះមិនដាច់មាន ៥ យ៉ាង . . . . . . ៣៣៩
របស់មិនត្រូវលះមាន ៥ យ៉ាង . . . . . . . ៣៤១
រឿងអស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុ . . . . . . . 〃
ការចែកសេនាសនៈជារបស់សង្ឃ . . . . . . . ៣៤៣
របស់ដែលមិនត្រូវចែកមាន ៥ យ៉ាង . . . . . . ៣៤៤
រឿងភិក្ខុនៅក្នុងដែនអាឡវី . . . . . . . ៣៤៦

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



# សន្ទិកជផ្តុលច្រាប់មាតិកា


| | លេខទំព័រ |
|---|---|
| ការឲ្យនវកម្ម | ៣៤៧ |
| ការឲ្យនវកម្មចំពោះវិហារទាំងអស់ជាដើម | ៣៤៩ |
| ការដែលភិក្ខុទទួលនវកម្មហើយដើរចៀសចេញទៅជាដើម | ៣៥១ |
| ការដែលភិក្ខុទទួលនវ កម្មហើយចៀសចេញទៅ ក្នុងវេលាដែលធ្វើរួចជាដើម | ៣៥៣ |
| ការនាំយកគ្រឿងប្រើប្រាស់ឲ្យជារបស់ទីជាដើម | ៣៥៥ |
| ការជាន់សេនាសនៈដោយជើង មិនទាន់លាងជាដើម | ៣៥៧ |
| ការទ្រង់អនុញ្ញាតឲ្យក្រាលកម្រាល ហើយសឹងដេកជាដើម | ៣៥៩ |
| ភត្តុទ្ទេសកភិក្ខុនិងសេនាសនបញ្ញាបកភិក្ខុ | ៣៦១ |
| ការសម្មតិអប្បមត្តកវិស្សជ្ជកភិក្ខុ | ៣៦៣ |
| ភិក្ខុជាសាដិយគ្គាហាបកៈជាដើម | ៣៦៥ |
| ឧទ្ទានគាថានៃសេនាសនក្ខន្ធកៈ | ៣៦៦ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# វិរុទ្ធាវិរុទ្ធបត្តិ

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្ក | ជួរលេខាយំ |
|---|---|---|---|
| សង្ខ្យា | សង្ខ្យា | ៣ | ៤ |
| ចុលវគ្គ | ចុល្លវគ្គ | ១០ | ១ |
| ចោរប្បញាតេ | ចោរប្បញាតេ | ១៣ | ១៣ |
| ឥទំ | ឥមំ | ១៩ | ៧ |
| ត្បំ | ត្វំ | ២០ | ១១ |
| មេត្តិយកម្ម- | មេត្តិយភុម្ម- | ២៣ | ១ |
| មេត្តិយកម្មជកា | មេត្តិយភុម្មជកា | ២៣ | ៦ |
| វិគហិត្វា | វិគហេត្វា | ២៤ | ៤ |
| សតិវនយ- | សតិវិនយ- | ២៥ | ១ |
| មល្លបុត្តស្ស | មល្លបុត្តស្ស | ២៦ | ១០ |
| មយ្ហម្ប | មយ្ហម្បិ | ៣៤ | ៦ |
| ការេ | ការេតិ | ៣៨ | ២ |
| កាសតី | កាសតិ | ៥០ | ៦ |
| កវណស្ស | ករណស្ស | ៦១ | ៥ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | បិដ្ឋេ | វដ្ដលេខាយំ |
|---|---|---|---|
| សម | សម- | ៦២ | ៣ |
| កាបត្តី | កាបត្តិកំ | ៦៤ | ១៦ |
| អនុប្បាទាធីករណំ | អនុប្បាទាធិករណំ | ៧៧ | ១ |
| យថា កថំ វិយ | យថា កថំ វិយ ។ | ៨០ | ១៨ |
| វិនយសម្មុខតា | វិនយសម្មុខតា | ៨៣ | ៤ |
| វិហរតេ | វិហរន្តិ | ៩៦ | ១១ |
| ចិត្តវិវរិយាសករោ | ចិត្តវិបរិយាសកតោ | ១០៣ | ១ |
| បារេបត្តិ | វិបារេបត្តិ | ១២៧ | ២ |
| កាមេត្តុស | កាមេត្តុសិ | ១៣០ | ១០ |
| មម្ពបេសិការោ | អម្ពបេសិការោ | ១៣៨ | ១៦ |
| ឆស្សត្តរត្តិ | ឆស្សុត្តរត្តិ | ១៤៣ | ១ |
| វិនយបិដក | វិនយបិដកេ | ១៤៦ | " |
| បុត្តំ | បត្តំ | " | ២ |
| សង្ឃ | សង្ឃេ | ១៨៩ | ១៥ |
| បណ្ឌលត្តាយ | មណ្ឌលត្តាយ | ២០០ | ២ |
| វសាខា | វិសាខា | ២០១ | ៣ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# វិសុទ្ធាវិសុទ្ធប្បត្តិ

| វិសុទ្ធបត្តិ | អវិសុទ្ធបត្តិ | អង្ក | ជួរលេខាយំ |
|---|---|---|---|
| វិសតិមដ្ឋិ | វីសតិមដ្ឋិ | ២១៤ | ១៩ |
| បំសុំ– | បំសុ– | ២៤១ | ៧ |
| អញ្ញកុក្ខកំ | អញ្ញក្រុក្ខកំ | ២៨០ | ២ |
| ពុទ្ធោតិ(៣) | ពុទ្ធោតិ(៣) | ២៩១ | ១៥ |
| កុមារកោ | កុមារកោ | ៣០២ | „ |
| គារហតពុន្ធ | គារហតពុន្ធិ | ៣២៩ | ១៨ |
| និសីត | និសដ្ឋ | ៣៣៥ | ១ |
| បរេសនិទិស្ស | បរេសនទិស្ស | ៣៣៧ | „ |
| បុលវគ្គ | បុល្លវគ្គ | ៣៥៦ | ១ |
| ទុជ្ជហត្ថិ | នជ្ជហត្ថិ | ៣៥៨ | ៣ |
| នជុហត្ថិ | នជ្ជុហត្ថិ | „ | ១៧ |
| កត្តុខេសរកោ | កត្តុទ្ទេសរកោ | ៣៦១ | ៥ |
| ហោឡ្យំ | ហោឡ្យំ | ៣៦៩ | „ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| បុត្គល | បុគ្គល | ៣ | ២ |
| ម្ងាប់ | រម្ងាប់ | ៨ | ១១ |
| មច្ឆុកដ្ឋិ | មច្ឆុកុដ្ឋិ | ១៤ | ១២ |
| មល្លបត្ត | មល្លបុត្ត | ១៤ | ១៣ |
| សប្បី | សប្បិ | ១៦ | ៣ |
| ទឹន | ទឹង | ២០ | ១៥ |
| និយាយឡើយ | និយាយឡើង | ២៦ | ៩ |
| បានិយាយ | បាននិយាយ | ៣០ | ៤ |
| កឲ្យ | កុំឲ្យ | ៣៥ | ១១ |
| បន្តិបបន្តួប | បន្តិចបន្តួច(១) | ៤២ | ១៦ |
| ប្រដា | ប្រដៅ | ៥០ | ១២ |
| ដើម្ប | ដើម្បី | ៥៧ | ៥ |
| „ | " | " | ៨ |
| មិនមាននៅ | មិនមាននៅ(១) | ៥៨ | ៩ |
| សេចក្តិ | សេចក្តី | ៦១ | ១៦ |
| អាបត្តាធករណ៍ | អាបត្តាធិករណ៍ | ៧៤ | ១៤ |
| ត្រង់បទណា | ត្រង់បទណា ៗ | ៨០ | ១៦ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សន្លឹកប្រាប់ពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| អដ្ឋកថា | ៦ អដ្ឋកថា | ៩៨ | ១៥ |
| ចុះការចាប់ | ការចាប់ | ៩៩ | ១២ |
| យ៉ាងនេះ | យ៉ាងនេះហើយ | " | ១៣ |
| វិន័យកម្ម | វិនយកម្ម | ១០៧ | ៨ |
| ភិក្ខុង | ភិក្ខុ | ១១៣ | ៦ |
| សេចក្តិ | សេចក្តី | ១១៧ | ៤ |
| រំងស្បេ | រឹងស្បេ | ១១៨ | ១១ |
| បល្លវគ្គ | បុល្លវគ្គ | ១៤៦ | ១ |
| វត្តក្ខន្ធៈ | វត្តក្ខន្ធកៈ | ១៧៥ | |
| ទុកដ | ទុក្កដ | ១៨៤ | ១១ |
| ឈេ | ឈើ | " | ១៥ |
| កុម្ភជក | កុម្ភជក | ១៨៧ | ១០ |
| សេក្តី | សេចក្តី | ១៩១ | ១៥ |
| វត្តន្ធកៈ | វត្តក្ខន្ធកៈ | ១៩៥ | ១ |
| នយបិដក | វិនយបិដក | ១៩៦ | " |
| អនុគ្រោះ | អនុគ្រោះ | ១៩៨ | ១៣ |
| តាំងង | តាំង | ១៩៨ | ១៧ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សន្លឹកប្រាប់ពាក្យខុស - ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| មហាមាត្យ | មហាមាត្រ | ២០៤ | ១០ |
| ៅបាន | ទៅបាន | ២១០ | ១២ |
| គប្ប | គប្បី | " | ១៤ |
| អនញ្ញាត | អនុញ្ញាត | ២១២ | ៤ |
| ការងា | ការងារ | " | ១២ |
| ឲ្យកាត់ក្រចក | ឲ្យកំបិតកាត់ក្រចក | ២១៤ | ៩ |
| ឲ្យតាំទៅ | ឲ្យនាំទៅ | ២៤២ | ៥ |
| ទីដំណេ | ទីដំណេក | ២៥២ | ៩ |
| ព្រះទ្រង់ | ព្រះអង្គទ្រង់ | ២៦៥ | ១៣ |
| វហារ | វិហារ | ២៦៦ | ១០ |
| ពក | ពូក | ២៨៤ | ២ |
| ក្បាប់ | ក្បាច់ | " | ១០ |
| ទ្រត្រាស់ | ទ្រង់ត្រាស់ | ២៨៥ | ១៦ |
| គន្ទឹសទ្វារទាងឈើ | ខ្ទុកទ្វារ គន្ទឹសទ្វារ | ២៨៦ | ១៧ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សន្លឹកប្រាប់ពាក្យខុស - ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| មគធ | មាគធ | ២៩០ | ៤ |
| គហបតី | គហបតិ | ,, | ៨ |
| មគធ | មាគធ | ២៩១ | ៤ |
| ,, | ,, | ,, | ៧ |
| សីលវកគាថា | សីវកគាថា | ២៩៣ | ១ |
| ជន៍ទ | ជន៍ទេ | ,, | ៧ |
| អនាថបិណ្ឌិក | អនាថបិណ្ឌិក | ២៩៦ | ១៣ |
| ជិវិត | ជីវិត | ២៩៧ | ១០ |
| សាវត្ថិ | សាវត្ថី | ៣០១ | ៤ |
| បប | បប់ | ៣៣១ | ១១ |
| គឺសៅ | គឺស្មៅ | ៣៤៥ | ១០ |
| ដ្រោយ | ដោយ | ៣៤៨ | ៣ |
| បេជ្ញា | ប្តេជ្ញា | ៣៥១ | ៩ |
| តិត្ថិ៍យ | តិត្ថិយ | ,, | ,, |
| (៤១៤) | (៤១៩) | ៣៥៤ | ១៣ |